# THEORY OF CONSTITUTION AL LAW

# ទ្រឹស្តី: នីតិរដ្ឋធម្មនុញ្ញ

Media by : www.law-society.asia

អ៊ិន បុផា (ម៉ាស្ទ័រនីតិសាស្ត្រ)

២០០៣

In.Bopha (M.A.Law)

វិទ្យាសាស្ត្រនៃនីតិសាស្ត្រ

Jurisprudence

ទ្រឹស្តី

# នីតិរដ្ឋធម្មនុញ្ញ

ដោយ ៖ អ៊ុន ឬធា ម៉ាស្ទ័រនីតិសាស្ត្រ

ភ្នំពេញ
ព.ស. ២៥៤៧
គ.ស. ២០០៣

រក្សាសិទ្ធិដោយ ៖ អ៊ុន ឬធា

# អារម្ភកថា

នេះគឺជាស្នាដៃដំបូងរបស់អ្នករៀបរៀង ហើយក៏ជាមុខវិជ្ជាទីមួយផ្នែកទ្រឹស្តីនៃនីតិរដ្ឋធម្មនុញ្ញ ដែលបានឃើញជាភាសាខ្មែរលើកដំបូងផងដែរ សំរាប់អ្នកដែលចាប់អារម្មណ៍ក្នុងវិស័យនៃនីតិសាស្ត្រ ។

នៅក្នុងស្នាដៃនេះ អាចប្រើប្រាស់ជាមូលដ្ឋានទ្រឹស្តីផ្នែកវិទ្យាសាស្ត្រ នៃនីតិរដ្ឋធម្មនុញ្ញសំរាប់ : **អ្នកស្រាវជ្រាវ, អ្នកមានមុខងារគ្រប់គ្រងក្នុងអំណាចសាធារណៈ** (ដូចជានៅក្នុងអំណាចនីតិបញ្ញត្តិ, អំណាចនីតិប្រតិបត្តិ និងនៅក្នុងអំណាចតុលាការ), **និស្សិត និងសាស្ត្រាចារ្យនៃឧត្តមសិក្សាផ្នែកនីតិសាស្ត្រ និងរាល់តែអ្នកណាដែលចាប់អារម្មណ៍ទៅលើវិស័យនយោបាយ និងការគ្រប់គ្រងរដ្ឋ** ។

ស្នាដៃនេះត្រូវបានស្រាវជ្រាវ ចងក្រង តាំងពីឆ្នាំ ១៩៩៦ ហើយបានយកទៅធ្វើបទឧទ្ទេសសំរាប់និស្សិតនីតិសាស្ត្រ រហូតដល់បច្ចុប្បន្ននេះ ដោយមានការកែប្រែ និងសំរួលទៅលើអត្ថន័យជាច្រើនលើកច្រើនសារ ដើម្បីឱ្យស្របតាមការវិវត្តន៍នៃសង្គមជាតិ និងអន្តរជាតិ ។ នៅក្នុងទ្រឹស្តីនៃនីតិរដ្ឋធម្មនុញ្ញនេះ ត្រូវបានលើកយកឧទាហរណ៍នៃមាត្រារដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ មកបញ្ជាក់នៅក្នុងវិធាននានានៃទ្រឹស្តី ប៉ុន្តែកន្លែងខ្លះដែលរដ្ឋធម្មនុញ្ញរបស់យើងពុំមានមូលដ្ឋានគ្រប់គ្រាន់តាមទ្រឹស្តីនោះ តំរូវឱ្យយកមាត្រាខ្លះ ឬក៏ជាគោលការណ៍គតិយុត្តិខ្លះៗរបស់ច្បាប់នៃរដ្ឋបរទេស ឬក៏យកគំនិតរបស់អ្នកប្រាជ្ញល្បីៗក្នុងវិស័យនីតិសាស្ត្រ មកបញ្ជាក់ជាហេតុផលគោល ។ នៅក្នុងខ្លឹមសារនៃស្នាដៃទាំងមូល គឺផ្តោតទៅលើតែវិធានជាទ្រឹស្តីនៃនីតិរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ គឺពុំមែនសំដៅទៅលើការប្រៀបធៀបនៃរដ្ឋធម្មនុញ្ញ និងរដ្ឋធម្មនុញ្ញនៃសម័យកាលណាមួយនោះទេ ប៉ុន្តែវាជាទ្រឹស្តីទូទៅដែលអ្នកសិក្សាត្រូវតែយល់ដឹងនូវវិធានជាមូលដ្ឋានគ្រឹះទាំងនោះ ។ អ្នករៀបរៀងក៏សូមបញ្ជាក់ផងដែរថា នៅក្នុងស្នាដៃជាទ្រឹស្តីនេះពុំមែនមានន័យថាជារដ្ឋធម្មនុញ្ញ (ច្បាប់គ្រឹះ) នោះទេ ប៉ុន្តែវាជានីតិរដ្ឋធម្មនុញ្ញ (ទ្រឹស្តី) ។ មុខវិជ្ជានេះត្រូវបានប្រទេសជឿនលឿនលើពិភពលោក យកចិត្តទុកដាក់ជាខ្លាំងសំរាប់អភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ ព្រោះគេចាត់ទុករដ្ឋធម្មនុញ្ញជាច្បាប់គោលនៃច្បាប់ដទៃ

ទៀត ។ មុខវិជ្ជានេះមានការវិវត្តន៍ ខ្លាំង ចាប់តាំងពី ស.វ ទី XIX មកម្ល៉េះ នៅពេលដែលពលរដ្ឋយល់ច្បាស់នូវសិទ្ធិអំណាចរបស់ពួកគេ ក្នុងការចូលរួមកសាងប្រទេសរបស់ខ្លួន ។ បច្ចុប្បន្ននេះគេបានចាត់ទុកវាជាមុខវិជ្ជាគ្រឹះមួយដ៏សំខាន់ ដាក់ចូលក្នុងកម្មវិធីសិក្សាជាទ្រឹស្តីនៅគ្រឹះស្ថានឧត្តមសិក្សានីតិសាស្ត្រ ដែលពីមុនមកគេគ្រាន់តែបានសិក្សាទៅលើបញ្ញត្តិ ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញដ៏តិចតួចប៉ុណ្ណោះ ។ រីឯបញ្ញត្តិមួយចំនួននៃរដ្ឋធម្មនុញ្ញដែលជាច្បាប់គោលនោះ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានានា នៅក្នុងប្រព័ន្ធអប់រំចំណេះទូទៅទៀតផង ដូចជាមាត្រាដែលទាក់ទិននឹងសិទ្ធិ និងកាតព្វកិច្ចរបស់ពលរដ្ឋជាដើម ។

នៅក្នុងទ្រឹស្តីនៃនីតិរដ្ឋធម្មនុញ្ញនេះត្រូវបានកំណត់ឱ្យអ្នកអាន យល់ដឹងនូវចំណុចបីជាមូលដ្ឋានគន្លឹះគឺ :

**ក. ការកំណត់នូវទីតាំងរបស់មនុស្ស ក្នុងសមាសភាពនៃសមាជិករបស់រដ្ឋមួយគឺថា** : ពលរដ្ឋគ្រប់រូបមានសិទ្ធិគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវចំពោះជោគវាសនារបស់រដ្ឋខ្លួន ក្នុងការអភិវឌ្ឍន៍នានា ។ ការកំណត់ទាំងនេះមានដូចជា : សិទ្ធិបោះឆ្នោត, និងសិទ្ធិឈរឈ្មោះក្នុងការដឹកនាំប្រទេសជាដើម ដែលសិទ្ធិនោះត្រូវបានកំណត់តាមនីតិវិធីមួយច្បាស់លាស់ ក្នុងការទទួលបានតាមរយៈបោះឆ្នោត ដោយប្រើប្រព័ន្ធកំណត់មួយយ៉ាងជាក់លាក់ ។ ក្រៅពីនេះក៏មានសិទ្ធិផ្សេងៗទៀត ដែលទាក់ទិននឹងសិទ្ធិអត្តភាព និងសិទ្ធិសេដ្ឋកិច្ចជាដើម ។ល។

**ខ. ការកំណត់ទៅលើការគ្រប់គ្រងរដ្ឋគឺថា** : មនុស្សនៅក្នុងរដ្ឋមួយត្រូវបានគ្រប់គ្រងតាមបែបបទ និងទំរង់ផ្សេងៗគ្នា ដោយអាស្រ័យនឹងប្រវត្តិសាស្ត្រ និងការរីកចំរើននៃសង្គមមនុស្សរបស់រដ្ឋនោះ ។ ការគ្រប់គ្រងរដ្ឋដែលបានកំណត់នេះមានដូចជា ទំរង់សាធារណរដ្ឋ ឬរាជាធិបតេយ្យ, រីឯរចនាសម្ព័ន្ធរដ្ឋ ដូចជា : ឯកភូត (ទោល), សហព័ន្ធ ឬសមាគតរដ្ឋជាដើម ។ល។

**គ. ការកំណត់ទៅលើការបែងចែកអំណាចគឺថា** :បុគ្គលដែលមានអំណាចរដ្ឋពុំមែនទទួលបន្ទុកនូវគ្រប់អំណាចនោះទេ គឺត្រូវតែទទួលបែងចែកអំណាចឱ្យបានច្បាស់លាស់ក្នុងការទទួលខុសត្រូវ ដូចជាអំណាចនីតិបញ្ញត្តិ, អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

ដូចនេះមូលដ្ឋានលំអិតជាលក្ខណៈទ្រឹស្តី អ្នកអាននឹងបានឃើញតាមរយៈនៃខ្លឹមសារទាំងមូលក្នុងស្នាដៃនេះ ដែលមានប្រាំបួនជំពូក និង ១៧ អត្ថបទ ។

ការរៀបចំជំពូក និងអត្ថបទ ធ្វើឡើងតាមលក្ខណៈលំដាប់លំដោយនៃអត្ថន័យតាមបែបវិទ្យាសាស្ត្រនីតិសាស្ត្រ ។ ជំពូកទាំងនោះមាន :

- លក្ខណៈទូទៅនៃនីតិរដ្ឋធម្មនុញ្ញ.
- អត្ថន័យគ្រឹះនៃរដ្ឋធម្មនុញ្ញ.
- ឋានៈធម្មនុញ្ញគតិយុត្តិនៃមនុស្ស និងពលរដ្ឋ
- លក្ខណៈធម្មនុញ្ញគតិយុត្តិទៅលើប្រព័ន្ធគ្រប់គ្រងនៃសង្គម-សេដ្ឋកិច្ច.
- រដ្ឋ
- អត្ថន័យធម្មនុញ្ញគតិយុត្តិលើអំណាចគ្រប់គ្រងរដ្ឋ.
- អំណាចនីតិបញ្ញត្តិ.
- អំណាចនីតិប្រតិបត្តិ និង
- អំណាចតុលាការ ។

អ្នករៀបរៀងក៏សូមអធ្យាស្រ័យផងដែរ ចំពោះអ្នកអាន ដែលមានការកត់សំគាល់ទៅលើការខុសឆ្គងណាមួយក្នុងស្នាដៃនេះ ព្រោះថារាល់កំហុសណាមួយដែលកើតមានគឺជាអំពើអចេតនាតែប៉ុណ្ណោះ ។ អ្នករៀបរៀងរីករាយទទួលយកនូវរាល់ចំណុចកែលំអរក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋាន ។

*សូមអរគុណ*

ចៅក្រម **អ៊ិន បូផា**

# មាតិកា

ទំព័រ

អារម្ភកថា ........................................ B

## ជំពូក I

## លក្ខណៈទូទៅនៃនីតិរដ្ឋធម្មនុញ្ញ

### អត្ថបទទី ១ : នីតិរដ្ឋធម្មនុញ្ញជាសាខានៃនីតិសាស្ត្រ

១- កម្មវត្ថុ និងវិធាននៃនីតិរដ្ឋធម្មនុញ្ញ ........................................ ១
២- និយមន័យនៃនីតិរដ្ឋធម្មនុញ្ញ ........................................ ៣
៣- ប្រព័ន្ធនៃនីតិរដ្ឋធម្មនុញ្ញ ........................................ ៤
៤- អត្ថានានា ឬប្រធាននៃនីតិរដ្ឋធម្មនុញ្ញ ........................................ ១២
៥- និយ័តកម្មរដ្ឋធម្មនុញ្ញគតិយុត្តិ ........................................ ១៣
៦- ប្រភពនៃនីតិរដ្ឋធម្មនុញ្ញ ........................................ ១៤
៧- អាសនៈ និងតួនាទីនៃនីតិរដ្ឋធម្មនុញ្ញក្នុងប្រព័ន្ធគតិយុត្តិនានា ........................................ ១៨
៨- និន្នាការគ្រឹះក្នុងការវិវត្តន៍នៃនីតិរដ្ឋធម្មនុញ្ញ ........................................ ១៨

### អត្ថបទទី ២ : នីតិរដ្ឋធម្មនុញ្ញជាវិទ្យាសាស្ត្រ និងជាមុខវិជ្ជាសិក្សា

១- កម្មវត្ថុវិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញ ........................................ ២៤
២- វិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញ ........................................ ២៨
៣- នីតិរដ្ឋធម្មនុញ្ញជាមុខវិជ្ជាសិក្សា ........................................ ៣១

# ជំពូក II
# អត្ថន័យគ្រឹះនៃរដ្ឋធម្មនុញ្ញ

## អត្ថបទទី ៣ : អត្ថន័យគ្រឹះនៃរដ្ឋធម្មនុញ្ញ


១- និយមន័យនៃរដ្ឋធម្មនុញ្ញ ........ ៣៣
២- ខ្លឹមសារសង្គមនយោបាយនៃរដ្ឋធម្មនុញ្ញ ........ ៣៨
៣- មុខងារសង្គមទូទៅនៃរដ្ឋធម្មនុញ្ញ ........ ៣៩
៤- កម្មវត្ថុនៃនិយ័តកម្មធម្មនុញ្ញគតិយុត្ត ........ ៤០
៥- សុពលភាពនៃរដ្ឋធម្មនុញ្ញ ........ ៤៨


## អត្ថបទទី ៤ : ទំរង់ និងរចនាសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ


១- ទំរង់ក្រៅនៃរដ្ឋធម្មនុញ្ញ ........ ៥១
២- រចនាសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ ឬទំរង់ក្នុងនៃរដ្ឋធម្មនុញ្ញ ........ ៥៥
៣- ភាសា និងរចនាបថនៃរដ្ឋធម្មនុញ្ញ ........ ៦៣


## អត្ថបទទី ៥ : ការអនុម័ត, ការផ្លាស់ប្តូរ និងការលុបចោលនៃរដ្ឋធម្មនុញ្ញ


១- ការអនុម័តនៃរដ្ឋធម្មនុញ្ញ ........ ៦៧
២- ការផ្លាស់ប្តូរនៃរដ្ឋធម្មនុញ្ញ ........ ៧១
៣- ការលុបចោលនៃរដ្ឋធម្មនុញ្ញ ........ ៧៤


## អត្ថបទទី ៦ : ចំណាត់ថ្នាក់នៃរដ្ឋធម្មនុញ្ញ


១- គោលការណ៍នៃការចាត់ថ្នាក់ ........ ៧៧
២- រដ្ឋធម្មនុញ្ញបណ្តោះអាសន្ន និងរដ្ឋធម្មនុញ្ញអចិន្ត្រៃយ៍ ........ ៧៩
៣- ចំណាត់ថ្នាក់តាមខ្លឹមសារ និងតាមលក្ខណៈគតិយុត្តគ្រឹះនៃរដ្ឋធម្មនុញ្ញ ........ ៨១
៤- ចំណាត់ថ្នាក់ផ្សេងៗទៀត ........ ៨៤

## ជំពូក III

## ឋានៈធម្មនុញ្ញគតិយុត្តិនៃមនុស្ស និងពលរដ្ឋ

### អត្ថបទទី ៧ : អត្ថន័យគ្រឹះទូទៅនៃឋានៈធម្មនុញ្ញគតិយុត្តិនៃមនុស្ស និងពលរដ្ឋ


១- សិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ .......... ៨៦

២- ប្រវត្តិសាស្ត្រនៃការវិវត្តន៍លើសិទ្ធិ និងសេរីភាព .......... ៨៨

៣- សិទ្ធិ និងសេរីភាព .......... ៩២

៤- សិទ្ធិ សេរីភាព និងកាតព្វកិច្ច .......... ៩៣

៥- មធ្យោបាយទាំងឡាយនៃរូបមន្តធម្មនុញ្ញក្នុងការសមិទ្ធិលើសិទ្ធិសេរីភាព និងកាតព្វកិច្ច .... ៩៤

៦- ចំណាត់ថ្នាក់នៃសិទ្ធិ, សេរីភាព និងកាតព្វកិច្ចរបស់ពលរដ្ឋ .......... ៩៥

៧- សមភាពនៃសិទ្ធិ, សេរីភាព និងកាតព្វកិច្ច .......... ៩៩

៨- ការកំរិតនៃសិទ្ធិ និងសេរីភាព .......... ១០១

៩- ការធានាសិទ្ធិ និងសេរីភាព .......... ១០១

១០- សញ្ជាតិ និងរបបជនបរទេស .......... ១០៣


## ជំពូក IV

## លក្ខណៈធម្មនុញ្ញគតិយុត្តិនៅលើប្រព័ន្ធគ្រប់គ្រងនៃសង្គម-សេដ្ឋកិច្ច

### អត្ថបទទី ៨ : អត្ថន័យនៃប្រព័ន្ធគ្រប់គ្រងសង្គម


១- និយមន័យ និងរចនាសម្ព័ន្ធនៃប្រព័ន្ធគ្រប់គ្រងសង្គម .......... ១១៥

២- រចនាសម្ព័ន្ធនៃប្រព័ន្ធគ្រប់គ្រងសង្គម .......... ១១៦

៣- ប្រព័ន្ធគ្រប់គ្រងសង្គម និងរដ្ឋធម្មនុញ្ញ .......... ១២៥

### អត្ថបទទី ៩ : ទំនាក់ទំនងសេដ្ឋកិច្ច

១- ប្រព័ន្ធសេដ្ឋកិច្ច ........................................ ១២៨

២- ប្រព័ន្ធហិរញ្ញវត្ថុ ........................................ ១៣៨

## ជំពូក V

## រដ្ឋ

### អត្ថបទទី ១០ : សិក្សាអំពីរដ្ឋ

១- រដ្ឋមានលក្ខណៈជាទ្រឹស្តី ........................................ ១៣៧

២- លក្ខណៈជាទ្រឹស្តីនៃទំរង់រដ្ឋ ........................................ ១៥៥

៣- លក្ខណៈគតិយុត្តិនៃរដ្ឋ ........................................ ១៦៤

### អត្ថបទទី ១១ : បក្សនយោបាយ និងប្រព័ន្ធបក្ស

១- និយមន័យ និងខ្លឹមសារនៃបក្សនយោបាយ ........................................ ១៨៥

២- ចំណាត់ថ្នាក់សង្គម-នយោបាយរបស់បក្ស ........................................ ១៩២

៣- ចំណាត់ថ្នាក់អង្គការគ្រប់គ្រងនៃបក្សនយោបាយ ........................................ ១៩៣

៤- ស្ថាប័នភាវូបនីយកម្មនៃបក្សនយោបាយ និងនិយ័តកម្មធម្មនុញ្ញគតិយុត្តិ .......... ១៩៥

៥- ប្រព័ន្ធបក្សនយោបាយ ........................................ ១៩៨

# ជំពូក VI

# អត្ថន័យធម្មនុញ្ញភាពនិយុត្តិលើអំណាចគ្រប់គ្រងរដ្ឋ

## អត្ថបទទី ១២ : អត្ថន័យនៃទំរង់គ្រប់គ្រង និងរបបរដ្ឋ


១- និយមន័យនៃទំរង់គ្រប់គ្រងរដ្ឋ ........ ២០២

២- ចំណាត់ថ្នាក់នៃទំរង់គ្រប់គ្រងរដ្ឋ ........ ២០៣

៣- ទំរង់ការរដ្ឋ ឬរបបរដ្ឋ ........ ២០៥

៤- រាជាធិបតេយ្យ ........ ២០៦

៥- សាធារណរដ្ឋ ........ ២១១


## អត្ថបទទី ១៣ : ការជ្រើសរើស ឬការបោះឆ្នោត និងការកោះហៅ


១- អត្ថន័យ និងមុខងារសង្គមនៃការជ្រើសរើស ........ ២១៥

២- ប្រភេទ ឬទិដ្ឋភាពនៃការជ្រើសរើស ........ ២១៧

៣- សាមយិកភាពនៃការជ្រើសរើស ឬភាពទៀងទាត់នៃការជ្រើសរើស ឬបោះឆ្នោត ........ ២១៩

៤- ប្រព័ន្ធបោះឆ្នោត ........ ២២០

៥- ការអនុវត្តន៍ផ្ទាល់តាមរូបមន្តនីមួយៗ ........ ២៣៣

៦- ការអនុវត្តន៍ក្នុងការប្រៀបធៀបលើប្រព័ន្ធមធ្យមភាគខ្ពស់ ........ ២៤០

៧- នីតិបោះឆ្នោត និងសិទ្ធិបោះឆ្នោត ........ ២៤៤

៨- ការអំពាវនាវ ឬការកោះហៅ ឬហៅថាការបញ្ចប់អាណត្តិមុនពេលកំណត់ ........ ២៧៥

៩- ប្រជាមតិ ........ ២៧៦

# ជំពូក VII
# អំណាចនីតិបញ្ញត្តិ

## អត្ថបទទី ១៤ : អំណាចនីតិបញ្ញត្តិ ឬអំណាចរបស់រដ្ឋសភា


១- និយមន័យ, មុខងារសង្គមទូទៅនៃរដ្ឋសភា ........ ២៨២
២- បុព្វចរិតតំណាងនៃរដ្ឋសភា ........ ២៨៤
៣- លក្ខណៈរូបទូទៅនៃសមត្ថកិច្ចរបស់រដ្ឋសភា ........ ២៨៦
៤- សមត្ថកិច្ចនីតិកម្មនៃរដ្ឋសភា ........ ២៩០
៥- សមត្ថកិច្ចហិរញ្ញវត្ថុរបស់រដ្ឋសភា ........ ២៩២
៦- សច្ចាប័ន និងអប្បដិបត្តិកម្មនៃសន្ធិសញ្ញាអន្តរជាតិរបស់រដ្ឋសភា ........ ២៩៣
៧- ចំណាត់ថ្នាក់ប្រជាមតិរបស់រដ្ឋសភា ........ ២៩៥
៨- ការបង្កើតអង្គការរដ្ឋ និងស្ថាប័ននានារបស់រដ្ឋសភា ........ ២៩៦
៩- ការត្រួតពិនិត្យរបស់រដ្ឋសភាចំពោះការងារអង្គការរដ្ឋ, ស្ថាប័ន និងមន្ត្រីរាជការ ........ ២៩៩
១០- សិទ្ធិអំណាចនៃរដ្ឋសភានៅក្នុងវិស័យការពារ និងសន្តិសុខសង្គម ........ ៣០០
១១- សិទ្ធិអំណាចតុលាការរបស់រដ្ឋសភា ........ ៣០១
១២- ការផ្ទេរសិទ្ធិអំណាចរបស់រដ្ឋសភា ........ ៣០៣
១៣- អាទេសកម្ម ឬការយកមកជំនួសនៃរដ្ឋសភា ........ ៣០៥
១៤- នីតិរដ្ឋសភា ........ ៣០៦


## អត្ថបទទី ១៥ : រចនាសម្ព័ន្ធនៃរដ្ឋសភា និងអង្គការគ្រប់គ្រងនៃរដ្ឋសភា


១- រចនាសម្ព័ន្ធនៃរដ្ឋសភា និងអង្គការគ្រប់គ្រងសភា ........ ៣០៨
២- ឋានៈនៃសមាជិករដ្ឋសភា ........ ៣២០
៣- សណ្តាប់ធ្នាប់នៃការងាររដ្ឋសភា ........ ៣២៨

៤- ដំណើរការនីតិកម្ម ............ ៣៣៧
៥- នីតិវិធីពិសេសៗរបស់រដ្ឋសភា ............ ៣៥២
៦- ឧបករណ៍ជំនួយការនៃរដ្ឋសភា ............ ៣៦០
៧- បំណកស្រាយដំណើរការនីតិកម្មនៃកម្ពុជា ............ ៣៦៧
៨- បំណកស្រាយនៃដំណើរការនីតិកម្មសហរដ្ឋអាមេរិក ............ ៣៧១

## ជំពូក VIII
## អំណាចនីតិប្រតិបត្តិ

### អត្ថបទទី ១៦ : ប្រមុខរដ្ឋ និងរដ្ឋាភិបាល

១- ប្រមុខរដ្ឋ ............ ៣៧៤
២- ព្រះរាជា ............ ៣៨៤
៣- ប្រធានាធិបតី ............ ៣៨៦
៤- រដ្ឋាភិបាល ............ ៣៩៤
៥- អត្ថន័យគតិយុត្តិនៃរដ្ឋាភិបាល ............ ៣៩៧

## ជំពូក IX
## អំណាចតុលាការ

### អត្ថបទទី ១៧ : អំណាចតុលាការ

១- លក្ខណៈទូទៅនៃអំណាចតុលាការ ............ ៤០៥
២- គោលការណ៍ធម្មនុញ្ញគតិយុត្តិនានានៃការគ្រប់គ្រង និងសកម្មភាពនៃប្រព័ន្ធតុលាការ ... ៤១៣
៣- ធម្មនុញ្ញត្រួតពិនិត្យ និងធម្មនុញ្ញយុត្តិធម៌ ............ ៤២៥
៤- អង្គការ និងស្ថាប័ននានាដែលជួយដល់អំណាចតុលាការ ............ ៤៥០

ការពន្យល់ពាក្យគន្លឹះសំខាន់ៗក្នុងអត្ថបទនីមួយៗ ............................................ I

ប្រភពឯកសារស្រាវជ្រាវ ............................. ................................................. XV

កំណត់សំគាល់ ........................................... ................................................ XIX

ក្របក្រោយខាងក្នុង .................................................... ប្រវត្តិរូបសង្ខេបរបស់អ្នកនិពន្ធ

**អត្ថបទទី ១**

# នីតិរដ្ឋធម្មនុញ្ញ ជាសាខានៃនីតិសាស្ត្រ

## ១. កម្មវត្ថុ និងវិធាននៃនីតិរដ្ឋធម្មនុញ្ញ

**ក.កម្មវត្ថុនៃនីតិរដ្ឋធម្មនុញ្ញ** : ការកើតមានស្វ័យភាពនៃនីតិរដ្ឋធម្មនុញ្ញ នៅក្នុងប្រព័ន្ធគតិយុត្តិ (Legal System) នៃគ្រប់ប្រទេសត្រូវបានកំនត់ដោយកម្មវត្ថុពិសេសមួយ ក្នុងការធ្វើនិយ័តកម្ម (Regulation) ។ កម្មវត្ថុពិសេសនៃនីតិរដ្ឋធម្មនុញ្ញ ធ្វើនិយ័តកម្មទៅលើ**ទំនាក់ទំនងសង្គមនានា** ដែលទំនាក់ទំនងទាំងនោះបង្កើតនូវមូលដ្ឋានគ្រឹះមួយនៃរចនាស**ម្ព័ន្ធគ្រប់គ្រងសង្គម** និង**រដ្ឋ** ហើយដែលសង្គម និងរដ្ឋនោះ **វាផ្សារភ្ជាប់ដោយផ្ទាល់ជាមួយនិងអាទិភាពនៃអំណាចរដ្ឋ** ។ ទាំងនោះគឺជាទំនាក់ទំនងមនុស្ស, សង្គម, រដ្ឋ និងទំនាក់ទំនងមូលដ្ឋានគ្រឹះទាំងឡាយ ដែលកំនត់នូវរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ និងមុខងារគ្រប់គ្រងផ្សេងៗរបស់វា ។

ដូចនេះកម្មវត្ថុនៃនីតិរដ្ឋធម្មនុញ្ញ **គឺជាទំនាក់ទំនងពុំប្រែប្រួលរបស់សង្គមមនុស្ស និងការគ្រប់គ្រងមនុស្ស តាមរយៈនៃការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ (រដ្ឋឯកភូត, រដ្ឋសហព័ន្ធ, សមាគតរដ្ឋ) និងកំនត់ទីតាំងនៃមនុស្ស (សិទ្ធិ, តួនាទី)** ។ ត្រង់នេះបញ្ជាក់ថា កម្មវត្ថុនៃនីតិរដ្ឋធម្មនុញ្ញ **គឺជាទំនាក់ទំនងរបស់មនុស្ស និងការគ្រប់គ្រងមនុស្ស** ។

**ខ.វិធាននៃនីតិរដ្ឋធម្មនុញ្ញ** : ដើម្បីធ្វើឱ្យសំរេចផលនូវកម្មវត្ថុនៃនីតិរដ្ឋធម្មនុញ្ញ វាត្រូវការនូវវិធាននានាសំរាប់ធ្វើឱ្យមានការសមិទ្ធិក្នុងសង្គមពិតៗ ។ វិធាននៃនីតិរដ្ឋធម្មនុញ្ញវាមានលក្ខណៈកំនត់ពិសេស ខុសពីវិធាននៃនិយ័តកម្មរបស់សាខានីតិសាស្ត្រផ្សេងៗទៀតត្រង់ថា : វិធាននេះជាការប្រមូលផ្តុំនូវមធ្យោបាយនៃ**អានុភាពគតិយុត្តិ** ទៅលើទំនាក់ទំនងសង្គម ។ មានន័យថាវិធាននេះ វាមានឥទ្ធិពលធំជាងវិធាននៃសាខានីតិសាស្ត្រផ្សេងៗទៀត ដែលវិធានទាំងនេះគ្មានបទដ្ឋានកិច្ចគតិយុត្តិ

ណាអាចផ្ទុយនឹងវាបានទេ ។ ជាទូទៅ ទំរង់នៃការធ្វើនិយ័តកម្មធម្មនុញ្ញគតិយុត្តិមានបីប្រភេទ ដែលវាអាចធ្វើឱ្យទៀងទាត់នូវទំនាក់ទំនងសង្គមបានគឺ :

**ខ១. បទដ្ឋានកាតព្វកិច្ច** : វិធាននេះវាជាទំនាក់ទំនងមួយ ដែលដឹកនាំបទដ្ឋានធម្មនុញ្ញគតិយុត្តិ ដោយទាក់ទិនតែចំពោះការគ្រប់គ្រងអំណាច ដែលមិនអាចគេចចេញបានពីភាគីនៃអង្គការរដ្ឋ ឬសមាជិករបស់សង្គមបានឡើយ ។ ឧទាហរណ៍ "**រដ្ឋាភិបាលត្រូវតែទទួលសេចក្តីទុកចិត្តពីរដ្ឋសភា**" ( មាត្រា ៤៩ រដ្ឋធម្មនុញ្ញអ៊ីតាលី ១៩៤៧) ។ "**សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។ សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវរៀងៗខ្លួន ចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភា អំពីការដែលខ្លួនបានប្រព្រឹត្ត**" ( មាត្រា ១២១ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣) ។ ប៉ុន្តែកាតព្វកិច្ចដែលបានចារឹកក្នុងរដ្ឋធម្មនុញ្ញមានច្រើនប្រភេទណាស់ ដូចជាកាតព្វកិច្ចទូទៅ ( កាតព្វកិច្ចពលរដ្ឋ............), កាតព្វកិច្ចឯកត្តបុគ្គល ( កិច្ចសន្យា.........) ។ល។ ត្រង់ចំណុចនេះបញ្ជាក់ថា រដ្ឋធម្មនុញ្ញកំនត់នូវកាតព្វកិច្ចទៅគ្រប់តែសមាជិកនៃសង្គម គ្រាន់តែមានទំហំខុសៗគ្នាតែប៉ុណ្ណោះ ។

**ខ២. បទដ្ឋានហាមឃាត់** : វិធានរបៀបនេះ ធ្វើឡើងតាមទំរង់ហាមឃាត់មួយយ៉ាងពិតប្រាកដ ដោយកំនត់ទៅលើទំនាក់ទំនងពិសេសណាមួយ ក្នុងចំណោមទំនាក់ទំនងសាធារណៈ ។ ជាឧទាហរណ៍ "**សេរីភាពនៃគំនិត និងសម្បជញ្ញៈមិនត្រូវបំពាន**" ( រដ្ឋធម្មនុញ្ញជប៉ុន ១៩៤៦ មាត្រា ១៩) ។ "**ការផលិត ការប្រើប្រាស់ ការរក្សាទុកអាវុធបរិមាណូ អាវុធគីមី អាវុធវេត្រាណូត្រូវហាមឃាត់ដាច់ខាត**" ( មាត្រា ៥៤ រដ្ឋធម្មនុញ្ញកម្ពុជា) ។ វិធានហាមឃាត់នេះក៏មានច្រើនប្រភេទដែរ ដូចជាក្នុងវិស័យកម្មសិទ្ធិមានដីធ្លីជាដើម ។

**ខ៣. បទដ្ឋានអនុញ្ញាត្តិ** : នេះគឺជាការធ្វើសម្បទានមួយនៃបទដ្ឋានធម្មនុញ្ញគតិយុត្តិ ក្នុងការផ្តល់សិទ្ធិឱ្យមានសកម្មភាពផ្សេងៗ ចំពោះសមាជិករបស់សង្គម ។ វិធាននេះអនុវត្តដ៏មានសក្តានុភាពទៅលើសកម្មភាពទៀងទាត់នៃឋានៈរបស់មនុស្ស និងពលរដ្ឋ ។ ជាឧទាហរណ៍ "**គណៈរដ្ឋមន្ត្រី**

រក្សាសិទ្ធិដោយ : អ៊ុន បូផា

**អាចធ្វើការកោះប្រជុំជាវិសាមញ្ញរបស់រដ្ឋសភាបាន**" ( មាត្រា ៩៣ រដ្ឋធម្មនុញ្ញជប៉ុន ១៩៤៦) ។ "**នាយករដ្ឋមន្ត្រី អាចរំលែកអំណាចរបស់ខ្លួនឱ្យទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន**" ( មាត្រា ១២៤ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣) ។

សរុបទៅ **វិធាននៃនីតិរដ្ឋធម្មនុញ្ញ ចាំបាច់ត្រូវធ្វើនិយ័តកម្មទៅលើទំនាក់ទំនងសង្គមដោយឈរនៅលើមូលដ្ឋានគ្រឹះមួយ គឺការកើតមាននូវលក្ខណៈជាអំណាចក្នុងអាជ្ញាបញ្ញា ប៉ុន្តែពុំមែនជាអំណាចអធិបញ្ញាទេ** ។ ត្រង់ចំនុចនេះមានន័យថា បទដ្ឋាននៃរដ្ឋធម្មនុញ្ញមានលក្ខណៈជាការបញ្ជាពិតមែនទៅលើទំនាក់ទំនងសង្គម ប៉ុន្តែសកម្មភាពពិតជាក់ស្តែងសមស្របតាមបទបញ្ញត្តិដែលបានចែងក្នុងរដ្ឋធម្មនុញ្ញនោះ គឺជាអ្នកមានអំណាចរដ្ឋឯណោះទេដែលជាអ្នកចាត់វិធានការអនុវត្ត ។

## ២. និយមន័យនៃនីតិរដ្ឋធម្មនុញ្ញ

បន្ទាប់ពីយើងបានវែកញែកនូវកម្មវត្ថុ និងវិធានរួចមកនោះ គេអាចកំនត់នូវសាខានៃនីតិសាស្ត្រដ៏ពិតនេះបាន ។ ព្រោះថានីតិរដ្ឋធម្មនុញ្ញជាសាខានៃនីតិសាស្ត្រទំនើប ដែលប្រទេសមួយចំនួនកំពុងតែចាប់អារម្មណ៍ និងស្រាវជ្រាវ ។

**នីតិរដ្ឋធម្មនុញ្ញ គឺជាប្រព័ន្ធបទដ្ឋានកិច្ចគតិយុត្តិទាំងឡាយនៃប្រទេសសុក្រឹត្យមួយ ដែលវាធ្វើនិយ័តកម្មទៅលើស្ថានភាពរបស់មនុស្សនៅក្នុងសង្គម និងរដ្ឋ ទៅលើមូលដ្ឋានគ្រឹះទាំងពួងនៃការគ្រប់គ្រង និងសកម្មភាពនៃប្រព័ន្ធអង្គការរដ្ឋ ហើយរួមទាំងអង្គការស្វ័យគ្រប់គ្រងទាំងឡាយទៀតផង** ។

នេះគឺជានិយមន័យទូទៅ ដែលគ្របដណ្តប់ទៅលើកម្មវត្ថុនៃនិយ័តកម្មជាអាទិភាព ប៉ុន្តែពុំបានរាប់ចូលនូវកម្មវត្ថុដោយឡែក១ ( ឯកជន) នោះទេដូចជានិម្មិតសញ្ញារដ្ឋជាដើម ។ល ។

## ៣. ប្រព័ន្ធនៃនីតិរដ្ឋធម្មនុញ្ញ

ប្រព័ន្ធនៃនីតិរដ្ឋធម្មនុញ្ញ វាជាខ្លឹមសារមួយដែលអាស្រ័យទៅនឹងមុខវិជ្ជាសិក្សា និងនិន្នាការទាំងឡាយនៃការស្រាវជ្រាវ (សាខាវិទ្យាសាស្ត្រ) នៅក្នុងនីតិរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗ ។ ជាទូទៅនីតិរដ្ឋធម្មនុញ្ញ គេច្រើនសិក្សាទៅលើខ្លឹមសារពីរផ្នែកគឺ **ផ្នែកទូទៅ និងផ្នែកពិសេស ឬនីតិរដ្ឋធម្មនុញ្ញប្រៀបធៀប** ។

**ក.ផ្នែកទូទៅនៃនីតិរដ្ឋធម្មនុញ្ញ** : កម្មវត្ថុនៃនីតិរដ្ឋធម្មនុញ្ញក្នុងផ្នែកនេះ គឺសិក្សាទៅលើសេចក្តីផ្តើមទូទៅ និងនិន្នាការទាំងឡាយក្នុងរចនាសម្ព័ន្ធគ្រប់គ្រងផ្សេងៗ នៅក្នុងសង្គមដែលត្រូវបានកំនត់ដោយនិយ័តភាព (Regularity) ទាំងឡាយនៃសកម្មភាពជាប្រវត្តិសាស្ត្រ ។ ដូចជាការកំនត់ដោយឥទ្ធិពលអញ្ញមញ្ញ នៃទស្សនៈធម្មនុញ្ញគតិយុត្តិទាំងពួងនៅគ្រប់ស្ថាប័នគ្រឹះទាំងឡាយ និងការប្រតិបត្តិនៃបណ្តាប្រទេសដោយឡែកៗ ។

សរុបទៅវាជាការបំភ្លឺនូវទ្រឹស្តីនៃឯកភាពមួយ (Unity) និងភាពទីទៃគ្នា (Diversity) នៃនីតិរដ្ឋធម្មនុញ្ញ ។ ផ្នែកនេះមានគោលការណ៍ទូទៅ និងស្ថាប័នគ្រឹះរបស់វាដូចជា :

**ក₁. គោលការណ៍ទូទៅនៃនីតិរដ្ឋធម្មនុញ្ញ** : ខ្លឹមសាររបស់វា គឺសំដែងចេញនៅក្នុងទំហំនៃសាខាពិតរបស់នីតិសាស្ត្រ ដោយការចាប់ផ្តើមគ្រាដំបូងរបស់វា គឺដូចគ្នានឹងប្រព័ន្ធនៃបទដ្ឋានកិច្ចគតិយុត្តិនានាដែរ ដែលក្នុងនោះបំពេញនាទីដោយនិយ័តកម្មធម្មនុញ្ញគតិយុត្តិ ទៅលើគ្រប់ទំនាក់ទំនងសង្គម ។ គោលការណ៍ទូទៅនេះ ពុំបានធ្វើនិយ័តកម្មផ្ទាល់ចំពោះទំនាក់ទំនងសង្គមនោះទេ តែវាធ្វើតាមរយៈបទដ្ឋានធម្មនុញ្ញគតិយុត្តទាំងឡាយ និងតំណាងនានានៅក្នុងបទដ្ឋានទាំងនោះ ព្រមទាំងតាមរយៈសកម្មភាពអនុវត្តគតិយុត្តិនៃអង្គការទាំងអស់របស់រដ្ឋ ។

**គោលការណ៍ទូទៅដែលប្រកាសដោយរដ្ឋធម្មនុញ្ញមានដូចជា :**

**ទីមួយ** : - អធិបតេយ្យជាតិ

- ការបែងចែកអំណាច ។ល។

ជាទូទៅ គោលការណ៍របៀបនេះពុំបានកំណត់នូវ**សិទ្ធិ** និង**ភាពឮតិច្ចពិត**ប្រាកដទេ ហើយក៏ពុំត្រូវបានផ្តត់ផ្តង់ជាអចិន្ត្រៃយ៍ ដោយទណ្ឌកម្មខាងផ្លូវច្បាប់ណាមួយនោះដែរ ប៉ុន្តែពេលខ្លះវាបានកំណត់នូវអត្ថន័យច្បាស់លាស់សំរាប់បទដ្ឋានធម្មនុញ្ញគតិយុត្តិ ។

**ទីពីរ** : គោលការណ៍ទាំងនេះ មានកំណត់នូវទំរង់គតិយុត្តច្បាស់លាស់នៃការសំដែងចេញ និងត្រូវបានអនុវត្តដោយផ្ទាល់នៅក្នុងសកម្មភាពរដ្ឋ ដូចជា :

- ភាពទទួលខុសត្រូវរបស់ប្រមុខរដ្ឋាភិបាល.
- ការការពាររដ្ឋធម្មនុញ្ញគតិយុត្តិ ។ល។

**គ២. ស្ថាប័នធម្មនុញ្ញគតិយុត្តិ ឬមូលដ្ឋានគ្រឹះធម្មនុញ្ញគតិយុត្តិ** : វាជាមូលដ្ឋានគ្រឹះមួយ ដែលនាំមកនូវប្រព័ន្ធកិរិតបទដ្ឋានច្បាស់លាស់នៃនីតិរដ្ឋធម្មនុញ្ញ ដោយវាធ្វើនិយ័តកម្មទៅលើទំនាក់ទំនងសង្គមក្នុង**ប្រភេទតែមួយ**[១] និង**ទំនាក់ទំនងអញ្ញមញ្ញ** ហើយដែលក្នុងនោះវាបង្កើតស្វ័យភាពទាក់ទិនមួយទៅវិញទៅមកនៅក្នុងសង្គមនោះ ។

**ស្ថាប័នធម្មនុញ្ញគតិយុត្តិ ឬលក្ខណៈគ្រឹះនៃរដ្ឋធម្មនុញ្ញមាន :**

- ចំណាត់ថ្នាក់គតិយុត្តចំពោះមនុស្ស និងពលរដ្ឋ.
- មូលដ្ឋានគ្រឹះទាំងឡាយនៃរចនាសម្ព័ន្ធគ្រប់គ្រងសង្គម.
- ទំរង់គ្រប់គ្រងរដ្ឋ.
- ច្បាប់បោះឆ្នោត.
- ធម្មនុញ្ញត្រួតពិនិត្យ និង
- តំណាងប្រជាជាតិ ជាដើម ។

[១]. រដ្ឋនីមួយៗ តែងកំនត់នូវប្រភេទរបស់ខ្លួន អំពីរបបនយោបាយ និងរចនាសម្ព័ន្ធនៅក្នុងច្បាប់គ្រឹះ ឬរដ្ឋធម្មនុញ្ញ ។

. មានន័យថា សង្គមមួយ ឬរដ្ឋមួយមានរបបនយោបាយតែមួយប៉ុណ្ណោះ ។

ស្ថាប័នទាំងនេះ អាចកំនត់ជាផ្នែកមួយសំរាប់ផ្តល់លទ្ធភាព នៃប្រភពអំណាចតាមរយៈពលរដ្ឋ ដូចជា :

- សិទ្ធិបោះឆ្នោត.
- ការប្រព្រឹត្តទៅនៃការបោះឆ្នោត.
- ការចាត់តាំងនៃការបោះឆ្នោត.
- ការឈរឈ្មោះជាបេក្ខជន ។ល។

**ក៣. បទប្បញ្ញត្តិធម្មនុញ្ញគតិយុត្តិ** : វាជាវិន័យដែលមានលក្ខណៈបំពេញនូវកាតព្វកិច្ចទូទៅ នៃចរិតដែលបានកើត ឬក៏ដាក់ទណ្ឌកម្មដោយរដ្ឋនៅក្នុងគោលដៅការការពារ និងការធ្វើនិយ័តកម្មចំពោះទំនាក់ទំនងសង្គមពិតប្រាកដ ដែលបទដ្ឋានទាំងនោះ (កាតព្វកិច្ចគតិយុត្តិទូទៅ) បំពេញកិច្ចតាមរយៈសិទ្ធិធម្មនុញ្ញ និងកាតព្វកិច្ច ហើយត្រូវបានការពារដោយតំណាងរបស់រដ្ឋ (អ្នកមានអំណាចរដ្ឋ) ។ នៅក្នុងលក្ខណៈទ្រឹស្តីនៃការកត់សំគាល់ទៅលើបទដ្ឋានធម្មនុញ្ញគតិយុត្តិ គេសង្កេតឃើញមានទំរង់ពីរគឺ **ទំរង់រចនាសម្ព័ន្ធផ្ទៃក្នុង** និង**ទំរង់ក្រៅ** ។

**ក៣.១. ទំរង់រចនាសម្ព័ន្ធផ្ទៃក្នុង** : ជាបទដ្ឋានដែលរចនាសម្ព័ន្ធរបស់វាផ្សំឡើងដោយធាតុបីគឺ : សម្មតិកម្ម (Hypothesis), អជ្ឈាស្រ័យ ឬអង្គច្បាប់ (Disposition) និងទណ្ឌកម្ម (Sanction) ។ ផ្ទុយទៅវិញធាតុទណ្ឌកម្ម គេពុំបានដាក់បញ្ចូលទៅក្នុងបទដ្ឋានធម្មនុញ្ញគតិយុត្តិទេ ប៉ុន្តែបញ្ជាក់នូវលក្ខណៈហាមឃាត់ជំនួសវិញ ។

- **សម្មតិកម្ម** : វាជាលក្ខណៈទាំងឡាយដែលមានក្នុងបទដ្ឋាន ដោយបញ្ជាក់នូវ**លក្ខខ័ណ្ឌ**ទាំងពួង ដែលបានកំណត់ជា**អង្គហេតុ**នៅក្នុងទំនាក់ទំនងសង្គមពិតៗ ។

- **អជ្ឈាស្រ័យ** : វាជាសិទ្ធិ និងកាតព្វកិច្ចដែលមានក្នុងបទដ្ឋាន ដោយកំនត់នូវសកម្មភាពតាមគោលការណ៍នៃ**អង្គច្បាប់** ដែលបានបញ្ជាក់នៅក្នុងអង្គហេតុនៃទំនាក់ទំនងសង្គមពិតៗ ។

- **ទណ្ឌកម្ម** : ជាវិន័យមួយដែលដាក់ទៅលើអំពើបំពាន ដែលមានចែងក្នុងបទដ្ឋាន កាលណាសកម្មភាពមួយនៅក្នុងសង្គមផ្ទុយនឹងអង្គច្បាប់ ។

ឧទាហរណ៍ **មាត្រាទី ១៦** រដ្ឋធម្មនុញ្ញបារាំង ១៩៤៨ បញ្ជាក់ថា "កាលណាការកំនត់របស់សាធារដ្ឋ នូវឯករាជ្យជាតិ, អធិបតេយ្យភាព, បូរណៈភាពទឹកដី ឬក៏បំពេញកាតព្វកិច្ចអន្តជាតិត្រូវស្ថិតនៅក្នុងភាពគំរាមកំហែងដោយផ្ទាល់, ឯមុខងារគ្រប់គ្រងធម្មតារបស់អង្គការ និងអំណាចរដ្ឋដែលបានបង្កើតឡើងស្របនឹងរដ្ឋធម្មនុញ្ញនោះត្រូវបានបំពាន (**សម្មតិកម្ម**) នោះប្រធានាធិបតីចាត់វិធានការទាំងឡាយដែលតំរូវតាមខណៈទាំងនោះ .... ( **អជ្ឈាស្រ័យ ឬអង្គច្បាប់ និងទណ្ឌកម្ម**)" ។

គួររំលឹកថា គ្រប់ធាតុនៃរចនាសម្ព័ន្ធរបស់បទដ្ឋានកំរមាននៅក្នុងតែមាត្រាមួយ នៃច្បាប់ណាមួយណាស់ ។ នៅក្នុងនីតិរដ្ឋធម្មនុញ្ញវាកំរជួបប្រទះ គឺវាច្រើនកើតមាននៅក្នុងមាត្រាផ្សេងៗនៃច្បាប់ ។ ដូចជា **មាត្រាទី ២៧** រដ្ឋធម្មនុញ្ញជប៉ុន ១៩៤៦ កំនត់ថា "ទាំងអស់គ្នាមានសិទ្ធិ និងកាតព្វកិច្ចចំពោះការងារ" ត្រង់នេះវាអនុវត្តនូវសម្មតិកម្ម និងអង្គច្បាប់ផងដែរ ។ ដូច្នេះវាចាំបាច់ត្រូវកំណត់ក្នុងមាត្រាផ្សេង ឬច្បាប់ណាមួយទៀត ដើម្បីឱ្យមាត្រា ២៧ នេះមានសកម្មភាពពិតនៅក្នុងសង្គមរបស់គេ ។

**ក₃.₂. ទំរង់ក្រៅ** : ទំរង់របៀបនេះភាគច្រើននៃបទដ្ឋាន វាសំដែងចេញក្នុងមាត្រាទាំងឡាយនៃរដ្ឋធម្មនុញ្ញ និងប្រភេទផ្សេងៗទៀតនៃបទដ្ឋានកិច្ចតតិយុត្តិ ។ ក្នុងទំរង់នេះបទដ្ឋានភាគច្រើនមានធាតុពីរ ឬក៏ធាតុមួយតែប៉ុណ្ណោះ ហើយជារឿយៗក្នុងមាត្រាវាអនុវត្តនូវទណ្ឌកម្ម និងសឹងតែទាំងមូលបាត់នូវសម្មតិកម្ម ពីព្រោះបញ្ញត្តិដែលបានចែងក្នុងរដ្ឋធម្មនុញ្ញនោះ ត្រូវបានប្រើប្រាស់ដោយផ្ទាល់បាននៅក្នុងសង្គមពិតៗ ។ ដោយរដ្ឋធម្មនុញ្ញនៃប្រទេសនានា ខុសគ្នាទៅលើ**ចំនួនបទដ្ឋានធម្មនុញ្ញតតិយុត្តិ** នោះគេអាចកំនត់នូវចំណាត់ថ្នាក់នៃបទដ្ឋាន តាមគោលការណ៍គ្រឹះមួយចំនួនដូចខាងក្រោម :

**ក₃.₂.₁. តាមនិន្នាការមុខងារ** : តាមមុខងារនេះមាន**បទដ្ឋាននិយ័ត** និង**បទដ្ឋានរក្សា**

- **បទដ្ឋាននិយ័ត** : ជាបទដ្ឋានដែលមាននិន្នាការ ធ្វើនិយ័តកម្មទៅលើ**មុខងារ**នៃទំនាក់ទំនងសង្គមទូទៅ ( ជាភាគដ៏ធំមួយនៃបទដ្ឋាន) ដើម្បីឱ្យមានភាពទៀងទាត់ក្នុងការធ្វើសកម្មភាពនៃសមាជិកសង្គម ។

- **បទដ្ឋានរក្សា** : ជាបទដ្ឋានដែលនាំមកនូវការទប់ស្កាត់ ( អាយ័តកម្ម) ចំពោះសកម្មភាពនានាដែលនឹងកើតមាន ។ ឧទាហរណ៍ដូចជា "**សិទ្ធិនៃការឈ្លានពានមិនត្រូវបានទទួលស្គាល់ដោយរដ្ឋទេ**" ( មាត្រា ៩ រដ្ឋធម្មនុញ្ញជប៉ុន) ។

**ក៣.២.២. តាមបច្ចេកទេសនៃអានុភាពចំពោះអត្តានៃនីតិ** : នេះគឺជាបទដ្ឋានដែលផ្តល់សិទ្ធិអំណាច, កាតព្វកិច្ច, ការហាមឃាត់ ទៅឱ្យបុគ្គល ឬអង្គការរដ្ឋ ដោយបានកំនត់នៅក្នុងរដ្ឋធម្មនុញ្ញ ។ ជាទូទៅតាមលក្ខណៈទ្រឹស្តី គេសង្កេតឃើញបទបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញ ដែលផ្តល់សិទ្ធិអំណាចរបៀបនេះតាមទំរង់មួយចំនួនដូចខាងក្រោម :

- **បទដ្ឋានផ្តល់សិទ្ធិ** : ដូចជា "**រដ្ឋសភា និងព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ** ......." ( រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ មាត្រា ៩០ និង ៩៩) ។ ក្នុង**មាត្រា ៩៧** នៃរដ្ឋធម្មនុញ្ញកម្ពុជាក៏បានបញ្ជាក់ដែរថា "គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន" ។ បទដ្ឋាននេះបញ្ជាក់តែការផ្តល់សិទ្ធិទៅឱ្យបុគ្គល ឬអង្គការរដ្ឋណាមួយតែប៉ុណ្ណោះ ។

- **បទដ្ឋានកាតព្វកិច្ច** : ដូចជា "**អធិការបតីសហព័ន្ធ តាមសំណូមពរប្រធានាធិបតីសហព័ន្ធ ឯរដ្ឋមន្ត្រីសហព័ន្ធ តាមសំណូមពររបស់អធិការបតីសហព័ន្ធ ឬប្រធានាធិបតីសហព័ន្ធរួម ទទួលកាតព្វកិច្ចរួមគ្នាបន្តការងារ រហូតដល់មានការចាត់តាំងអ្នកជំនួសថ្មី**" ( មាត្រា ៦៩ រដ្ឋធម្មនុញ្ញសហព័ន្ធអាល្លឺម៉ង់ ១៩៤៩) និង "**ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី**" ( មាត្រា ៣០ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣) ។ បទដ្ឋានទាំងនេះវាកំនត់នូវកាតព្វកិច្ចរបស់បុគ្គល ឬអង្គការរដ្ឋ ។

- **បទដ្ឋានហាមឃាត់** : ដូចជា "**មុខងារទាំងអស់របស់សមាជិករដ្ឋាភិបាល មានវិសមិតភាពនឹងអាណត្តិរដ្ឋសភា**" ( មាត្រា ២៣ រដ្ឋធម្មនុញ្ញបារាំង ១៩៥៨) និង "**មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារ**

សាធារណៈ ប្រធាន ឬអនុប្រធានគណៈបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព" (រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ មាត្រា ១៣៩) ។ បទដ្ឋាននេះវាបញ្ជាក់នូវការទប់ស្កាត់តួនាទី ឬមុខងារផ្ទួនគ្នារបស់បុគ្គល ។

**ក៣.២.៣. តាមលក្ខណៈដែលធ្វើនិយ័តកម្មលើទំនាក់ទំនងសង្គម** : តាមលក្ខណៈរបៀបនេះ បទដ្ឋានមានលក្ខណៈជាសំភារៈ និងបទដ្ឋាននីតិវិធី ។

- **បទដ្ឋានសំភារៈ** : ជាបទដ្ឋានដែលមានលក្ខណៈនិយ័តកម្មលើទំនាក់ទំនងទូទៅទាំងពួង ដូចជា "**គ្រប់គ្នាមានភារកិច្ចចូលរួមនៅក្នុងការចំណាយរបស់រដ្ឋ**" (មាត្រា ៥៣ រដ្ឋធម្មនុញ្ញអ៊ីតាលី ១៩៤៧) ។ "**ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស .....**" (មាត្រា ៥០ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣) ។ បទដ្ឋាននេះពុំកំនត់កាតព្វកិច្ច ឬបុគ្គលណាមួយច្បាស់លាស់ទេ ។

- **បទដ្ឋាននីតិវិធី** : ជាបទដ្ឋានដែលធ្វើនិយ័តទៅលើទំនាក់ទំនងសង្គម ដែលមានលក្ខណៈជាការពិភាក្សាលើបញ្ហាណាមួយច្បាស់លាស់ ។ ដូចជា "**ការប្រជុំម្តងក្នុងមួយសប្តាហ៍ រៀបចំឡើងសំរាប់ពិភាក្សាលើសំនួរទាំងឡាយ ដែលចោទឡើងដោយសមាជិករដ្ឋសភា និងពិភាក្សាលើចំលើយទាំងអំបាល មានរបស់រដ្ឋាភិបាល**" (មាត្រា ៤៨ រដ្ឋធម្មនុញ្ញបារាំង) និង "**គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្តាហ៍ ជាប្រជុំធំ ឬជាប្រជុំពិនិត្យស្រាវជ្រាវ ........**" (មាត្រា ១២៣ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣) ។

* **ចំណាំ** : អ្នកឯកទេសមួយចំនួនបានបញ្ជាក់ថា បទដ្ឋាននីតិវិធីប្រព្រឹត្តិទៅបានតែក្នុងក្របខណ្ឌ័គតិយុត្តិរបស់តុលាការធម្មនុញ្ញតែប៉ុណ្ណោះ ព្រោះបទដ្ឋាននីតិវិធីសំដៅទៅលើដំណើរការនៃយុត្តិធម៌ធម្មនុញ្ញ រីឯដំណើរការក្នុងអង្គការរដ្ឋដទៃទៀតហៅថា : **បទដ្ឋាននីតិវិធី** ។ ប៉ុន្តែសារៈសំខាន់គ្រប់នីតិវិធីគតិយុត្តិ (Legal Procedure) ត្រូវតែមានការវិវត្តន៍ ឬដំណើរការ (Process) បើសិនជាដំណើរការនោះពុំមានសកម្មភាពទេ នោះក៏ពុំអាចរកភាពត្រឹមត្រូវណាមួយបានដែរ ។

**ក៣.២.៤. តាមសកម្មភាពជាធរមាន** : តាមលក្ខណៈនេះបទដ្ឋានចែកជាបីប្រភេទ ដែលទាក់ទិននឹងពេលវេលាគឺ :

- **បទដ្ឋានអចិន្ត្រៃយ៍** : ជាបទដ្ឋានដែលភាគច្រើនពុំមានពេលកំនត់ពិតប្រាកដទៅលើសកម្មភាពនៃទំនាក់ទំនងនោះទេ ។ ដូចជា "**ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិជាមួយក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ**" ( មាត្រា១៤៣, ១៥៣ និងមាត្រា ១៧ ជាដើម នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ) ។ បទដ្ឋានរបៀបនេះវាមានសកម្មភាពគ្រប់ពេល គឺមានន័យថា ទោះកាលៈទេសៈណាក៏ដោយត្រូវតែធ្វើសកម្មភាព ព្រោះបទដ្ឋានពុំបានកំនត់រយៈពេលទេ **អញ្ចឹងហើយបានជាបទដ្ឋានរបៀបនេះមានច្រើនជាងគេនៅក្នុងច្បាប់គ្រឹះនីមួយៗ** ។

- **បទដ្ឋានបណ្តោះអាសន្ន** : ជាបទដ្ឋានដែលធម្មតាកើតមានក្នុងស្ថានភាពជាអន្តរកម្ម ដែលវាធ្វើនិយ័តកម្មទៅលើដំណើរឆ្លងកាត់មួយ ពីស្ថានភាពមួយរហូតដល់ចូលជាធរមាននៃបទដ្ឋានកិច្ចមួយចំពោះស្ថានភាពមួយនោះ ។ មានដូចជា "**ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមានហើយ ក្នុងនីតិកាលទី ១ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គទ្រង់ចាត់តាំងនាយករដ្ឋមន្ត្រីទីមួយមួយរូប និងនាយករដ្ឋមន្ត្រីទីពីរមួយរូប ឱ្យបង្កើតរាជរដ្ឋាភិបាលក្រោយបានទទួលមតិឯកភាពពីប្រធានរដ្ឋសភា និងអនុប្រធានទាំងពីរនៃរដ្ឋសភា ......**" ។ ( មាត្រា ១៣៨ រដ្ឋធម្មនុញ្ញ កម្ពុជា ១៩៩៣ )[២] ។ បទដ្ឋាននៃរដ្ឋធម្មនុញ្ញរបៀបនេះ មានពេលវេលាកំនត់ច្បាស់លាស់សំរាប់ធ្វើសកម្មភាព ដូចជាការចែងនៅក្នុងអន្តរបញ្ញត្តិនៃរដ្ឋធម្មនុញ្ញកម្ពុជា ជាដើម ។

---

[២]. មាត្រានេះ មាននៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ក្នុងអាណត្តិទី ១ ( ១៩៩៣-៩៨ ) និងបានលប់ចោលមាត្រា ១៣៨ នេះ ក្រោយពីបានធ្វើវិសោធនកម្មលើកទីពីរ ថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩ ។
. វិសោធនកម្មលើកទី ១ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ១៩៩៤ ។

- **បទដ្ឋានលើកលែង** : ជាបទដ្ឋានដែលធ្វើនិយ័តទៅលើលក្ខណៈទាំងឡាយ ដែលមានជាវិសាមញ្ញ ។ ដូច**មាត្រា ៨៦** រដ្ឋធម្មនុញ្ញកម្ពុជាកំនត់ថា "ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ រដ្ឋសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះកាលបើសភាពការណ៍អនុញ្ញាត្តិ ។

បើរដ្ឋសភាមិនអាចប្រជុំបានទេដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកំលាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។ នៅពេលដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ"។ បទដ្ឋានរបៀបនេះសំរាប់បញ្ជាក់នូវសកម្មភាពរបស់អង្គការរដ្ឋ ក្នុងសភាពដំណើរការពុំប្រក្រតី ។

**ខ.ផ្នែកពិសេសនៃនីតិរដ្ឋធម្មនុញ្ញ ឬនីតិរដ្ឋធម្មនុញ្ញប្រៀបធៀប** : កម្មវត្ថុនៃផ្នែកពិសេសរបស់នីតិរដ្ឋធម្មនុញ្ញ វាជារដ្ឋធម្មនុញ្ញវិជ្ជមាន (ច្បាប់គ្រឹះ) នៃរដ្ឋសុក្រឹត្យមួយ ឬក៏ក្រុមរដ្ឋទាំងឡាយដែលប្រមូលផ្តុំតាមសញ្ញាណផ្សេងៗនោះ ។ ជាឧទាហរណ៍ ដូចជានីតិរដ្ឋធម្មនុញ្ញបារាំង. អាល្លឺម៉ង់. កាណាដា. រុស្ស៊ី. អ៊ីតាលី....។ល។ នីតិរដ្ឋធម្មនុញ្ញក្រុមរដ្ឋមួយចំនួន ដូចជាក្រុមរដ្ឋបែបសង្គមនិយម. ក្រុមប្រទេសអាមេរិចឡាទីន ក្រុមប្រទេសអតីតអាណានិគមបារាំង និងអង់គ្លេស ។ល។

ជារួមភាគពិសេសនៃនីតិរដ្ឋធម្មនុញ្ញ វាជាកម្មវត្ថុមួយនៃការសិក្សាទៅលើលក្ខណៈពិសេស និងសញ្ញាណផ្សេងៗដែលមាននៅក្នុងក្រុមប្រទេស ឬប្រទេសណាមួយពិតប្រាកដ។ ផ្នែកនេះគេសំដៅយកការប្រៀបធៀបរវាងការគ្រប់គ្រងរដ្ឋ. របទាសម្ព័ន្ធ. របបរដ្ឋ. ទំរង់រដ្ឋ. ទាំងការធ្វើសមិទ្ធិលើអំណាចរដ្ឋ និងបែបបទនៃការធ្វើសមិទ្ធិរបស់វានោះ ដែលមានក្នុងរដ្ឋសុក្រឹត្យនានា ដោយសំដៅយកតែសកម្មភាពទាំងឡាយណាដែលបានចារិកដោយរដ្ឋធម្មនុញ្ញ ។

ការសិក្សាទៅលើភាគពិសេស គឺគេសំដៅទៅលើការប្រៀបធៀបរដ្ឋធម្មនុញ្ញ នៃសម័យកាលនីមួយៗរបស់រដ្ឋមួយ និងសិក្សាទៅលើការប្រៀបធៀបរដ្ឋធម្មនុញ្ញរបស់រដ្ឋមួយ ជាមួយរដ្ឋមួយផ្សេងទៀត ។

## ៤. អត្តានានា ឬប្រធាននៃនីតិរដ្ឋធម្មនុញ្ញ

ពាក្យថាអត្តា ឬប្រធាននៃនីតិរដ្ឋធម្មនុញ្ញនេះ គឺជាការកំនត់សិទ្ធិ និងកាតព្វកិច្ចដែលបានចារិកដោយរដ្ឋធម្មនុញ្ញទៅលើក្រុមបុគ្គល ឬអង្គការរដ្ឋ ដើម្បីអនុវត្តតាមល័ក្ខខ័ណ្ឌនៃគ្រប់សាខានីតិសាស្ត្ររបស់ប្រទេស ។ អត្តានៃនីតិរដ្ឋធម្មនុញ្ញចែកចេញជាពីរក្រុមធំៗ គឺរូបវន្តបុគ្គល (Individual Person) និងនិម្មិតកម្មសង្គម (Social Formation) ឬក្រុមនីតិបុគ្គល ។

**ក.អត្តាក្រុមទីមួយ ឬរូបវន្តបុគ្គល** : មានពលរដ្ឋ, ជនបរទេស, អ្នកបោះឆ្នោត, តំណាងរាស្ត្រ ជាសមត្ថភាពពិសេសខាងផ្លូវច្បាប់ និងក្រុមរបស់គេ ។ ចំពោះសមត្ថភាពខាងផ្លូវច្បាប់នេះបទដ្ឋាននៃនីតិរដ្ឋធម្មនុញ្ញ បានកំណត់យ៉ាងច្បាស់លាស់របស់ប្រទេសនីមួយៗ ។ ក្រុមនេះសំដៅផ្តល់សិទ្ធិទៅឱ្យសមាជិកទាំងមូល ឬក៏រាល់បុគ្គលដែលមានវត្តមាននៅលើទឹកដីរបស់ខ្លួន ។

**ខ.អត្តាក្រុមទីពីរ ឬនិម្មិតកម្មសង្គម** : គឺក្រុមនេះផ្តុកផ្តាក់វាជាទូទៅគឺរដ្ឋ និងអង្គការរបស់វា (តែមានពេលខ្លះជាលក្ខណៈពិសេសរបស់វា ដូចជាសភា, គណៈកម្មការ, ក្រុមបក្ស ដែលនៅក្នុងរដ្ឋសភា) ដូចជាសហគមន៍ ឬទឹកដីឯករាជ្យ ស្ថាប័ន និងអង្គការស្វ័យគ្រប់គ្រង, រួមទាំងបក្សនយោបាយ និងកំលាំងមហាជនផ្សេងទៀត ។ ក្រុមនេះអាចកំនត់តួនាទីរដ្ឋក្នុងការអនុវត្តរដ្ឋធម្មនុញ្ញគឺ :

**ខ១. តួនាទីពិសេសរបស់រដ្ឋ** : រដ្ឋជាអ្នកកំនត់ (ធ្វើនិយ័ត) តួនាទីទៅលើទំនាក់ទំនងសង្គម ដែលតួនាទីនេះចារិកដោយបទដ្ឋានធម្មនុញ្ញគតិយុត្តិ ពីព្រោះថារដ្ឋមាននាទីជានិយ័តករនៃគ្រប់ទំនាក់ទំនងសង្គម ។ រដ្ឋបានកំណត់នូវទំនាក់ទំនងពិត រវាងអត្តាទាំងពួងនូវសិទ្ធិ និងកាតព្វកិច្ច ។ តួនាទីនេះរដ្ឋជាអ្នកកំនត់នូវទំនាក់ទំនងទូទៅ រវាងសមាជិកទាំងអស់របស់គេក្នុងប្រទេស ។ សរុបទៅ **អង្គការរដ្ឋជាអត្តានៃនីតិរដ្ឋធម្មនុញ្ញ** វាជាការបែងចែកសមត្ថកិច្ចដោយស្របទៅតាមភារកិច្ចរបស់ខ្លួន ដូចជាការបង្កើតច្បាប់, ការត្រួតពិនិត្យ, ការត្រួតពិនិត្យចំពោះសកម្មភាពនៃអង្គការផ្សេងៗទៀត ។

**ខ២. តួនាទីរដ្ឋក្នុងក្របខ័ណ្ឌសង្គមសាធារណៈ** : តួនាទីនេះ រដ្ឋអាចកំនត់ព្រំដែនសមត្ថកិច្ចទៅលើល័ក្ខខ័ណ្ឌទាំងឡាយ ក្នុងទំនាក់ទំនងសង្គមសាធារណៈ ដូចជា :

**៤.២.១. ក្រុមផលប្រយោជន៍** : វាធ្វើសមិទ្ធិនូវសិទ្ធិ ឬក៏តាមរយៈអង្គការរបស់ខ្លួន ឬក៏តាមមតិដោយផ្ទាល់ ។ ជាធម្មតារដ្ឋធម្មនុញ្ញតែងផ្តល់សិទ្ធិដល់និម្មិតកម្មសង្គមផ្សេងៗ ដើម្បីធ្វើសកម្មភាពក្នុងផលប្រយោជន៍នៃក្រុមរបស់ពួកគេ ។

**៤.២.២. បក្សនយោបាយ** : វាធ្វើសមិទ្ធិតាមផ្លូវច្បាប់របស់អត្តាទាំងពួង ។ បក្សនយោបាយនេះត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់ ដោយឈរលើគោលការណ៏អធិបតេយ្យភាពជាតិនៃប្រទេសនីមួយៗ ។ នៅបណ្តារដ្ឋខ្លះអត្តានៃនីតិរដ្ឋធម្មនុញ្ញ វាសំដែងជាពួកសាសនាជាដើម ដូចជាពួកគ្រីស្ត (Church) នៅប្រទេសអង់គ្លេស ។ល។

## ៥. និយ័តកម្មរដ្ឋធម្មនុញ្ញគតិយុត្តិ

និយ័តកម្មធម្មនុញ្ញគតិយុត្តិ វាជាធាតុមួយដែលមានលក្ខណៈជាបទដ្ឋាន សំដៅធ្វើឱ្យទៀងទាត់ទៅលើទំនាក់ទំនងសាធារណៈដែលមាននៅក្នុងសង្គម ។ និយ័តកម្មនេះ វាបាននាំមកនូវអានុភាពជាលក្ខណៈបទដ្ឋានគ្រប់គ្រងទៅលើទំនាក់ទំនងសង្គមកំនត់មួយច្បាស់លាស់ ។ ជារួមវាមានលក្ខណៈជា*កំរិតសណ្តាប់ធ្នាប់*, *ការថែរក្សា*, និង*ការអភិវឌ្ឍន៍* ។ លក្ខណៈរបៀបនេះ វាកំណត់ទៅលើទំនាក់ទំនងច្បាស់លាស់ គឺប្រព័ន្ធនៃ**មធ្យោបាយគតិយុត្តិ** ( បទដ្ឋានធម្មនុញ្ញគតិយុត្តិ... ។ល។) និងប្រព័ន្ធនៃវិធានយថាប្រភេទ[៣] នៃនិយ័តកម្មគតិយុត្តិដែលផ្តត់ផ្គង់នូវផលិតផលមួយចំនួន ។

លក្ខណៈរបៀបនេះ បទដ្ឋានបានកំនត់ដូចជាការបំពេញកិច្ច និងការហាមឃាត់ជាដើម ។ ចំពោះ**វិធាន**ទាំងឡាយនៃនិយ័តកម្មធម្មនុញ្ញគតិយុត្តិ គឺជាសកម្មភាពរបស់ខ្លួនផ្ទាល់ ( បុគ្គល) ដែលមានសំរាប់បុគ្គលមានអំណាច ដូចជា "**ប្រធានាធិបតីសាធារណរដ្ឋ អាចទាមទារឱ្យសភាពិភាក្សាជាថ្មីឡើងវិញតាមរយៈសារសំងាត់របស់ខ្លួន មុនពេលប្រកាសឱ្យប្រើច្បាប់មួយ**" ( មាត្រា ៧៤ រដ្ឋធម្មនុញ្ញអ៊ីតាលី) ។ នេះជាមធ្យោបាយមួយក្នុងការដោះស្រាយទំនាស់ រវាង**រដ្ឋសភា** និង**ប្រធានា**

[៣] . នៅក្នុងរដ្ឋធម្មនុញ្ញមាត្រាមួយចំនួនបានចែងយ៉ាងច្បាស់ ដើម្បីធ្វើឱ្យការអនុវត្តទៀងទាត់លើទំនាក់ទំនងសង្គមដោយផ្ទាល់ នៃសាខានីតិសាស្ត្រផ្សេងៗ ។

**ធិបតី** ដែលទាក់ទិនទៅនឹងខ្លឹមសារនៃច្បាប់នោះ ។ នេះបង្ហាញថាគាត់ជាបុគ្គល ដែលជាប្រធាននៃនីតិរដ្ឋធម្មនុញ្ញ មានសិទ្ធិទទួលខុសត្រូវមួយចំណែកនៅក្នុងអំណាចរដ្ឋ ។

គួរបញ្ជាក់ថា **រដ្ឋពុំសំដែងជាអត្តានៃទំនាក់ទំនងគតិយុត្តិទេ តែវាសំដែងជាស្ថាប័នអំណាចទេវិញ** ។ ពីព្រោះថា មានតែបុគ្គលទេដែលជាអត្តានៃទំនាក់ទំនងគតិយុត្តិ ។ សរុបទៅក្នុងអត្តានៃនីតិរដ្ឋធម្មនុញ្ញវាផ្តល់ទៅរូបវន្តបុគ្គល និងនិម្មិតកម្មសង្គមនូវសិទ្ធិទូទៅ គឺមានន័យថាវាកំណត់បាននូវ**ផលសិទ្ធិ** (សិទ្ធិខាងផ្លូវច្បាប់) និង**ផលសម្បទា** (សិទ្ធិខាងផ្លូវអំពើ) របស់វាទាំងនោះ ។ ជាឧទាហរណ៍ ដូចជាសិទ្ធិខាងផ្លូវច្បាប់ "**ប្រធានាធិបតីសាធារណរដ្ឋ ជាអគ្គមេបញ្ជាការកងកំលាំងប្រដាប់អាវុធ**" (មាត្រា ១៥ រដ្ឋធម្មនុញ្ញបារាំង) ។ និង**មាត្រា ៦៤** របស់បារាំងដដែលបានកំនត់ថា "ប្រធានាធិបតីនៃសាធារណរដ្ឋ ជាអ្នកធានានូវឯករាជ្យភាពនៃអំណាចតុលាការ" ។ ដូចនេះអ្នកដឹកនាំរដ្ឋ ត្រូវតែទទួលខុសត្រូវចំពោះទង្វើណាដែលខ្លួនបានប្រព្រឹត្តិខុសច្បាប់ ។

## ៦. ប្រភពនៃនីតិរដ្ឋធម្មនុញ្ញ

វាជាមូលហេតុត្រឹមត្រូវពិតប្រាកដនៃការកកើតឡើង និងអាទិភាពនៃនីតិរដ្ឋធម្មនុញ្ញដោយចាក់ឫសក្នុងលក្ខខណ្ឌជាសំភារៈនៃជីវភាពសង្គម (កិច្ចការសង្គម) ។ គួររំលឹកដែរថា ប្រភពនៃនីតិ (Source of Law) វាជាទំរង់ទាំងឡាយ ដែលស្ថិតនៅលើការសំដែងចេញនូវបទដ្ឋានកិច្ចគតិយុត្តិទាំងឡាយនៃសាខានីតិសាស្ត្រ ដូចជាបទដ្ឋានរដ្ឋប្បវេណីគតិយុត្តិ, បទដ្ឋានភូមិបាលគតិយុត្តិ, បទដ្ឋានរដ្ឋបាលគតិយុត្តិ, បទដ្ឋានព្រហ្មទណ្ឌគតិយុត្តិ....។ល។ ប៉ុន្តែ**បទដ្ឋានកិច្ចគតិយុត្តិណាដែលសំដែងចេញជាលក្ខណៈធម្មនុញ្ញគតិយុត្តិ ឬលក្ខណៈអំណាចរដ្ឋ បទដ្ឋានទាំងនោះវាជាប្រភពនៃនីតិរដ្ឋធម្មនុញ្ញ**។ ដូចនេះ ប្រភពសំខាន់ៗនៃនីតិរដ្ឋធម្មនុញ្ញមាន : **បទដ្ឋានគតិយុត្តិ, អាទិភាពគតិយុត្តិ** (សាលក្រមតុលាការ) **និងទំនៀបទំលាប់គតិយុត្តិ** ក្នុងពេលខ្លះក៏មានសន្ធិសញ្ញាអន្តរជាតិ និង**សន្ធិសញ្ញាផ្ទៃក្នុងរដ្ឋ** (សំរាប់រដ្ឋសហព័ន្ធ) ដែរ ។ បទដ្ឋានកិច្ចគតិយុត្តិនៃនីតិរដ្ឋធម្មនុញ្ញចែកជា : **ច្បាប់នានា, បទដ្ឋានកិច្ចនានា នៃអំណាចនីតិប្រតិបត្តិ, បទដ្ឋានកិច្ចអង្គការធម្មនុញ្ញត្រួតពិនិត្យ, បទបញ្ជាផ្ទៃក្នុងរដ្ឋសភា** និង**បញ្ញត្តិ** (Acts) ទាំងឡាយនៃអំណាចស្វ័យគ្រប់គ្រងមូលដ្ឋាន ។

ដូចនេះប្រភពនៃនីតិរដ្ឋធម្មនុញ្ញ **គឺជាទំរង់ក្រៅនៃការកំរិត និងការសំដែងចេញនៃបទដ្ឋានធម្មនុញ្ញគតិយុត្តិក្នុងទំនាក់ទំនងសាធារណៈ** ។ ត្រង់នេះបញ្ជាក់ថា បទដ្ឋានណាដែលមានលក្ខណៈអំណាចរដ្ឋ បទដ្ឋាននោះជាប្រភពនៃនីតិរដ្ឋធម្មនុញ្ញ ។ ចូរពិនិត្យមើលនូវប្រភេទបទដ្ឋានកិច្ចគតិយុត្តិនានាដូចខាងក្រោម ដែលជាប្រភពនៃនីតិរដ្ឋធម្មនុញ្ញ ។

**ក.ច្បាប់នានា** : វាជាបទដ្ឋានកិច្ចគតិយុត្តិដែរ ដែលគេអនុម័តឡើងដោយអង្គការនៃអំណាចជាន់ខ្ពស់របស់រដ្ឋ។ ជាទូទៅគេសង្កេតឃើញច្បាប់ទាំងនោះមានបីប្រភេទ ដែលប្រទេសនីមួយៗបានកំណត់គឺ : ច្បាប់ធម្មនុញ្ញ (ច្បាប់គ្រឹះ), ច្បាប់កំរិត និងច្បាប់ធម្មតា ។

**ក១. ច្បាប់គ្រឹះឬរដ្ឋធម្មនុញ្ញ** : គឺជាបទដ្ឋានកិច្ច ដែលមានកំលាំងគតិយុត្តិខ្ពស់ជាងកំលាំងគតិយុត្តិនៃបទដ្ឋានកិច្ចផ្សេងៗទៀត ហើយវាពិបាកក្នុងការកែប្រែ ។ វាប្រកាសនូវសិទ្ធិ និងសេរីភាពមនុស្ស និងពលរដ្ឋ, វាធ្វើនិយ័តកម្មលើរចនាសម្ព័ន្ធគ្រប់គ្រងដែនដី, កំណត់គោលការណ៍នៃការគ្រប់គ្រង និងសកម្មភាពនៃអង្គការរដ្ឋ ។ ចំពោះច្បាប់ធម្មនុញ្ញនេះ វាពុំមែនធ្វើឡើងដូចៗគ្នានៃបណ្តាប្រទេសនោះទេ គឺវាអាស្រ័យនឹងសាមីប្រទេស តែវាជាបទបញ្ញមួយ ដូចជាប្រទេសខ្លះចាត់ទុកជាច្បាប់ធម្មនុញ្ញផងដែរ កាលណាបទដ្ឋានទាំងនោះគេធ្វើឡើងសំរាប់កែប្រែ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ។

**ក២. ច្បាប់កំរិតផ្សេងៗ** : គឺជាបទដ្ឋានកិច្ចដែលមានកំលាំងគតិយុត្តិខ្ពស់ដែរ តែវាកំណត់ទៅលើកម្មវត្ថុពិតប្រាកដហើយក៏ពិបាកនឹងកែប្រែដែរ ។ ច្បាប់របៀបនេះ ជាពិសេសប្រព័ន្ធគតិយុត្តិរ៉ូម៉ាំង វាកំណត់នូវឋានៈនៃអង្គការនានារបស់រដ្ឋទៅលើមូលដ្ឋានគ្រឹះមួយ ដូចជា "**ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នឹងត្រូវកំណត់ក្នុងច្បាប់មួយ**" (មាត្រា ១២៧ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣)" ។ និង "**លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការនឹងត្រូវកំណត់ក្នុងច្បាប់មួយដោយឡែកពីគ្នា**" (មាត្រា ១៣៥ រដ្ឋធម្មនុញ្ញកម្ពុជា) ។

**ក៣. ច្បាប់ចម្មតា** : ជាបទដ្ឋានកិច្ចនានា ដែលអនុម័តដោយអង្គការរដ្ឋផ្សេងៗ ហើយមានការងាយស្រួលក្នុងការផ្លាស់ប្តូរ ។ បទដ្ឋានកិច្ចដែលអនុម័តដោយអង្គការមានសមត្ថកិច្ចអំណាចរដ្ឋទាំងនោះធ្វើឡើងតាមឋានានុក្រម ។

**ខ.បទដ្ឋានកិច្ចគតិយុត្តិនៃអំណាចនីតិប្រតិបត្តិ** : វាទាក់ទិននឹងកិច្ចគតិយុត្តិទាំងឡាយនៃប្រមុខរដ្ឋ ( ក្រឹត្យ, បទបញ្ជា..... ។ល ។ និងកិច្ចគតិយុត្តិនៃរដ្ឋាភិបាល ( អនុក្រឹត្យ, សេចក្តីសំរេច ..... ។ល ។) និងពេលខ្លះជារបស់អង្គការនៃស្ថាប័នផ្សេងៗផងដែរ ដែលស្ថិតក្រោមខ្សែបណ្តោយ ។

**គ.បទដ្ឋានកិច្ចគតិយុត្តិនៃអង្គការធម្មនុញ្ញត្រួតពិនិត្យ** : វាមានលក្ខណៈមួយដែលអាស្រ័យនឹងប្រព័ន្ធគតិយុត្តិនៃប្រទេសនីមួយៗ ដូចជាសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ( ប្រទេសបារាំង, កម្ពុជា....) សេចក្តីសំរេចរបស់អង្គការធម្មនុញ្ញ ( ប្រទេសអ៊ីតាលី, អាល្លឺម៉ង់, រុស្ស៊ី...), សេចក្តីសំរេចរបស់សាលាក្តីធម្មនុញ្ញ (Tribunal មានប្រទេសប៉ូឡូញ, អេស្ប៉ាញ), សេចក្តីសំរេចរបស់តុលាការជាន់ខ្ពស់ ( អាមេរិក, ជប៉ុន, ឥណ្ឌា.........) ។ល ។

រាល់សេចក្តីសំរេចដែលកើតឡើងតាមរយៈនៃអង្គការទាំងនេះ គេអាចចាត់ទុកថាជាប្រភពនៃនីតិរដ្ឋធម្មនុញ្ញដែរ ។

**ឃ.បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា** : វាផ្ទុកនូវបទដ្ឋានទាំងឡាយ ដែលបានកំណត់នូវសណ្តាប់ធ្នាប់នៃសកម្មភាពរបស់សភា និងរចនាសម្ព័ន្ធផ្ទៃក្នុងរបស់គេ ។ បទដ្ឋាននេះគឺវាធ្វើនិយ័តកម្មទៅលើកិច្ចការទាំងឡាយរបស់អំណាចរដ្ឋ ។

**ង.សេចក្តីសំរេចនៃអង្គការស្វ័យគ្រប់គ្រងមូលដ្ឋាន** :វាជាប្រភពនៃនីតិរដ្ឋធម្មនុញ្ញផងដែរ កាលណារាល់សេចក្តីសំរេចនោះធ្វើនិយ័តទៅលើទំនាក់ទំនងសាធារណៈ ដោយផ្សារភ្ជាប់ទៅនឹងអាទិភាពនៃអំណាចសាធារណៈ ដូចជាលក្ខខន្តិកៈ, បទបញ្ជាផ្ទៃក្នុង ........... ឬក៏សារាចរណែនាំផ្សេងៗ ។

**ច.អាទិភាពតុលាការ** : នេះជាសេចក្តីសំរេចរបស់តុលាការ ដែលមាននៅប្រទេសមួយចំនួនដោយប្រកាន់យកប្រព័ន្ធគតិយុត្តិអង់គ្លោសាក់សុង ហើយចាត់ទុកសេចក្តីសំរេចនោះជាប្រភពនៃនីតិរដ្ឋធម្មនុញ្ញ ។ សេចក្តីសំរេចនេះធ្វើឡើងតាមរឿងមួយពិតប្បាស់លាស់ ដែលទទួលស្គាល់នូវកាតព្វ

កិច្ចជាក់លាក់ ក្រោមរូបភាពនៃការពិភាក្សាយ៉ាងលំអិត និងហ្មត់ចត់បំផុត ។ ការប្រព្រឹត្តរបៀបនេះ ដូចជាប្រទេសអាមេរិក, ឥណ្ឌា, ចក្រភពអង់គ្លេស .......... ។

**ឆ.ទំនៀមទំលាប់គតិយុត្ត** : ជាទំរង់មួយដែលមានតាំងពីអតីតកាល ហើយគេយកមកអនុវត្តន៍រហូតដល់បច្ចុប្បន្នកាល ដោយវាមានលក្ខណៈជាប្រភពនៃនីតិរដ្ឋធម្មនុញ្ញដែរ ។ ត្រង់នេះគឺបញ្ជាក់ថា បើទំលាប់ពីអតីតកាលធ្វើយ៉ាងម៉េចនោះត្រូវតែអនុវត្តរហូត ឱ្យតែទំលាប់នោះប្រកាន់យកនូវលក្ខណៈល្អ ។ ផ្ទុយទៅវិញ បើគេទំលាប់កាត់ក្តីរឿងណាមួយ ដោយផ្អែកលើគោលការណ៍ណាមួយ នោះរឿងក្រោយៗទៀតក៏គេដោះស្រាយដូចគ្នាដែរ ឱ្យតែទំនៀមទំលាប់នោះមានលក្ខណៈជាអំណាច ។ ដូចជាប្រទេសអង់គ្លេស បើសិនជាគណៈបក្សណាមួយពុំមានអាសនៈច្រើននៅរដ្ឋសភា នោះព្រះមហាក្សត្រត្រូវតែចង្អុលបង្ហាញក្នុងការរើសនាយករដ្ឋមន្ត្រី ប្រសិនបើគណៈបក្សទាំងនោះពុំមានការឯកភាពណាមួយដែលច្បាប់ពុំបានចែង តែជាទំលាប់ ។

**ជ.សន្ធិសញ្ញាអន្តរជាតិ** : វាជាប្រភពនៃនីតិរដ្ឋធម្មនុញ្ញដែរ កាលណាវាធ្វើនិយ័តកម្មទៅលើបញ្ហាធម្មនុញ្ញទាំងឡាយ និងការអនុវត្តន៍ដោយផ្ទាល់របស់វាប្រកបដោយការបកស្រាយ និងពិចារណា ។

**ឈ.សន្ធិសញ្ញាផ្ទៃក្នុងរដ្ឋ** : សន្ធិសញ្ញារបស់រដ្ឋខ្លះវាធ្វើនិយ័តកម្មទៅលើបញ្ហាធម្មនុញ្ញ ដោយឈរលើមូលដ្ឋានគ្រឹះនៃកិច្ចព្រមព្រៀងរវាងរដ្ឋសមាជិកក្នុងប្រទេសនីមួយៗ ។ ការអនុវត្តន៍របៀបនេះមាននៅសហគមន៍អឺរ៉ុប និងប្រទេសតំបន់ខ្លះ ។ ប្រភពខ្លះទៀតដូចជាបណ្តុំបទដ្ឋានច្បាប់ឥស្លាម វាជាប្រភពនៃច្បាប់ធម្មនុញ្ញដែរ មាននៅសាធារណរដ្ឋអ៊ីរ៉ង់ ជាដើម ។ល។

ជាទូទៅ **យើងអាចចាត់ទុកសេចក្តីសំរេចណាមួយជាបទដ្ឋាន ដែលជាប្រភពនៃនីតិរដ្ឋធម្មនុញ្ញបាន លុះត្រាតែបទដ្ឋានទាំងនោះវាធ្វើនិយ័តកម្មទៅលើអំណាចគ្រប់គ្រងរដ្ឋ ប៉ុន្តែពុំមានលក្ខណៈជាឯកជនទេ ។**

## ៧. អាសនៈ និងតួនាទីនៃនីតិរដ្ឋធម្មនុញ្ញក្នុងប្រព័ន្ធគតិយុត្តិនានា

នេះគឺជាការកំនត់អំពីការបង្កើតច្បាប់របស់រដ្ឋមួយ ដើម្បីបំពេញបន្ថែមទៅលើការគ្រប់គ្រង នៃតំរូវការរដ្ឋធម្មនុញ្ញ ។ អត្ថន័យរបស់វាគឺផលិតកម្មគតិយុត្តិ (បង្កើតច្បាប់) ឧទាហរណ៍សហរដ្ឋអាមេរិកឆ្នាំ ១៩៨៨ បានអនុម័ត ២៥០ ច្បាប់ និងរដ្ឋសភាចក្រភពអង់គ្លេស ១០០ ច្បាប់ក្នុងមួយឆ្នាំ ។ អាសនៈ និងតួនាទី នៃរដ្ឋធម្មនុញ្ញក្នុងប្រព័ន្ធគតិយុត្តិនានាវាជាមុខងារមួយដ៏សំខាន់ ដើម្បីឱ្យរដ្ឋមួយដំណើរការបានល្អ លុះត្រាតែមានច្បាប់ជាច្រើនទៀតនៅអមរដ្ឋធម្មនុញ្ញនោះ ។ យើងគួរដឹងដែរថា ប្រព័ន្ធនៃនីតិរបស់រដ្ឋនីមួយៗវាបង្កើតសាខានៃនីតិសាស្ត្រជាច្រើន ដែលក្នុងនោះមាននីតិរដ្ឋធម្មនុញ្ញជាអាសនៈស្នូល (នាំផ្លូវ) គឺថានីតិរដ្ឋធម្មនុញ្ញដែលធ្វើនិយ័តកម្មទៅលើភាពដ៏ធំធេង នៃទំនាក់ទំនងសង្គមតាមរយៈនៃសាខានីតិសាស្ត្រនេះ ។ ជាពិសេសទៀតនោះ អាសនៈនៃនីតិរដ្ឋធម្មនុញ្ញវាស្ថិតនៅលើមជ្ឈមណ្ឌលមួយ នៃសកម្មភាពអញ្ញមញ្ញគ្រប់សាខានីតិសាស្ត្រ ។

ដូចនេះ តួនាទីនីតិរដ្ឋធម្មនុញ្ញកំណត់នូវរចនាសម្ព័ន្ធ, គោលការណ៍នៃការគ្រប់គ្រងសណ្តាប់ធ្នាប់នៃសកម្មភាព ដោយកំនត់នូវសមត្ថកិច្ចទូទៅនៃអង្គការរដ្ឋាភិបាល, កំណត់នូវទំនាក់ទំនងមនុស្ស និងពលរដ្ឋ ពិសេសបំផុតនោះ នីតិរដ្ឋធម្មនុញ្ញកំណត់នូវមូលដ្ឋានគ្រឹះទាំងឡាយនៃទំនាក់ទំនងសេដ្ឋកិច្ច, នីតិរដ្ឋប្បវេណី ជាដើម ........... ។ល។ (**មើលរូប ១**)

## ៨. និន្នាការគ្រឹះក្នុងការវិវត្តន៍នៃនីតិរដ្ឋធម្មនុញ្ញ

ប្រវត្តិសាស្ត្រនៃការវិវត្តន៍រដ្ឋធម្មនុញ្ញទៅលើពិភពលោកនេះ ចាប់ផ្តើមពិនិត្យនូវនិន្នាការពីចុងសតវត្សទី XVIII មកម្ល៉េះ ។ និន្នាការទាំងនេះគឺ ការវិវត្តនៃនិយ័តកម្មធម្មនុញ្ញគតិយុត្តិនៅក្នុងទំនាក់ទំនងសាធារណៈ (ទំនាក់ទំនងសង្គម) ។ និន្នាការទាំងនោះទាក់ទិននឹង**ខ្លឹមសារនៃច្បាប់គ្រឹះ** (រដ្ឋធម្មនុញ្ញ) និង**ខ្លឹមសារនៃប្រភពនីតិរដ្ឋធម្មនុញ្ញ**ផ្សេងៗទៀត ដែលនិន្នាការទាំងពីរនោះមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ ដូចនេះនិន្នាការនៃការវិវត្តនៃនីតិរដ្ឋធម្មនុញ្ញ ចាប់ពីសតវត្សទី XVIII មក រហូតដល់បច្ចុប្បន្ននេះ គេសង្កេតឃើញនូវមូលដ្ឋានធំៗមួយចំនួនដូចខាងក្រោម :

**ក.និន្នាការសង្គមបូនីយកម្មនៃរដ្ឋធម្មនុញ្ញ និងនីតិរដ្ឋធម្មនុញ្ញ** : នេះជានិន្នាការដែលធ្វើឱ្យកើតមានសង្គមដែលចារិកដោយច្បាប់គ្រឹះ កំនត់ទៅគ្រប់សម័យកាល ដូចជា :

នីតិរដ្ឋធម្មនុញ្ញ និងរដ្ឋធម្មនុញ្ញដែលមាននិន្នាការគ្រប់គ្រងសង្គម ។ ប្រព័ន្ធរដ្ឋធម្មនុញ្ញបានកំណត់នូវទំនាក់ទំនងរវាងមនុស្ស និងមនុស្ស. សង្គម និងរដ្ឋ. បរិយាកាសនយោបាយ ។ល។

នៅក្នុងរបៀបរៀបរយនៃរដ្ឋធម្មនុញ្ញ មានកំណត់របនាសម្ព័ន្ធគ្រប់គ្រងអំណាចរដ្ឋ ដូចជាការបែងចែកអំណាចនីតិបញ្ញត្តិ. នីតិប្រតិបត្តិ និងអំណាចតុលាការ ហើយបានកំណត់នូវទំនាក់ទំនងអញ្ញមញ្ញរវាងអំណាចទាំងនោះ ។

នៅក្នុងប្រទេសដែលមានរចនាសម្ព័ន្ធគ្រប់គ្រងជាសហព័ន្ធ រដ្ឋធម្មនុញ្ញបានកំណត់នូវទំនាក់ទំនងរវាងសមាជិកនៃសហព័ន្ធនោះទៀតផង ។ ដូចនេះ និន្នាការខាងលើជាកម្មវត្ថុនៃនិយ័តកម្មធម្មនុញ្ញគតិយុត្តិ ជាក់ស្តែងចំពោះនិន្នាការសង្គមបូនីយកម្ម ដូចជារដ្ឋធម្មនុញ្ញសហរដ្ឋមិកស៊ិកូ ឆ្នាំ ១៩១៧ ថ្ងៃទី ០៧ ខែកុម្ភៈ ចាប់ពីនោះមករហូតដល់បច្ចុប្បន្ន រដ្ឋធម្មនុញ្ញនេះត្រូវបានកែប្រែរាប់រយដង ។ មួយវិញទៀត ក្រោយសង្គ្រាមលោកលើកទី ២ ប្រទេសមួយចំនួនបានត្រលប់ទៅកាន់លទ្ធិប្រជាធិបតេយ្យ ដូចជាអ៊ីតាលីបានកំណត់នូវទំនាក់ទំនងពលរដ្ឋយ៉ាងច្បាស់លាស់ ត្រង់នេះបញ្ជាក់ថាបើសង្គមផ្លាស់ប្តូរ ច្បាប់ក៏ផ្លាស់ប្តូរដែរ ។

**ខ.និន្នាការលទ្ធិប្រជាធិបតេយ្យបូនីយកម្ម** : និន្នាការនេះបានកើតមាននៅក្នុងសតវត្សទី XIX ។ ការធានា និងការកំណត់នូវសិទ្ធិ. សេរីភាពរបស់ពលរដ្ឋជាមាត្រាមួយដែលគេចេញបាននូវសង្គ្រាមស៊ីវិល ។ វាបានបង្កើតថែមទៀតនូវស្ថាប័នលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសនីមួយៗ ដូចជាការកំណត់នូវយុត្តិធម៌ធម្មនុញ្ញ និងរដ្ឋបាល ។ល។ ដូចជា ការបង្កើតនូវការបោះឆ្នោតជ្រើសរើសតំណាងរបស់ពលរដ្ឋជាដើម ។ល។ និន្នាការទីពីរនេះ វាកំណត់នូវសង្គមមួយដែលអំណាចគ្រប់គ្រងសង្គមនោះ ត្រូវកើតឡើងតាមរយៈពលរដ្ឋ ( ឆន្ទៈរាស្ត្រ ) ។

**ច.និន្នាការអន្តរជាតូបនីយកម្ម** : គឺជានិន្នាការមួយ ដែលរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗដកស្រង់យកបទពិសោធគ្នាទៅវិញទៅមក ដោយគោរពនូវបទដ្ឋានរួមនៃហត្ថលេខីអន្តររដ្ឋ ហើយចាត់ទុកបទដ្ឋានទាំងនោះមានកំលាំងគតិយុត្តិ ដូចច្បាប់នានាក្នុងប្រទេសដែរ ។ វាមាននិន្នាការបៀបនេះត្រង់ថា ការខិតជិតនៃនីតិរដ្ឋធម្មនុញ្ញសំរាប់នៃរាល់ប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ ជាមួយនឹងនីតិអន្តរជាតិសាធារណៈ។ គឺថាតុល្យភាពអន្តរជាតិមានលក្ខណៈជាកិច្ច (Acts) នៃនីតិអន្តរជាតិ ដូចជា **កតិការសញ្ញា, អនុសញ្ញា**.......។ល។ ដែលត្រូវបានកំណត់កាតព្វកិច្ចតាមរយៈនៃការចូលរួមទាំងនោះ ។ នៅក្នុងរដ្ឋធម្មនុញ្ញភាគច្រើនបានសរសេរយ៉ាងច្បាស់ ដូចជា**មាត្រា ២៥** រដ្ឋធម្មនុញ្ញអល្លឺម៉ង់កំនត់ថា "វិន័យទូទៅនៃច្បាប់អន្តរជាតិជាផ្នែកមួយនៃច្បាប់សហព័ន្ធ ។ វិន័យទាំងនោះមានឥទ្ធិពលលើច្បាប់ទាំងឡាយ និងវាកើតដោយផ្ទាល់នូវសិទ្ធិ និងកាតព្វកិច្ចសំរាប់អ្នករស់នៅ លើទឹកដីសហព័ន្ធ" ។ ជាងនេះទៀត យើងអាចសង្កេតឃើញនូវកំហិតជិតនៃនយោបាយក្នុងតំបន់របស់រដ្ឋ គឺការបង្កើតនូវអង្គការរួមមួយ ដែលកំពុងមានសកម្មភាពក្នុងសហគមន៍អឺរ៉ុប (សហភាពអឺរ៉ុប) និងប្រជាជាតិអាស៊ីប៉ែកអាគ្នេយ៍ ហៅថាអាស៊ាន និងនៅសហគមន៍រដ្ឋឯករាជ្យ (CIS អតីតរដ្ឋសូវៀតមួយចំនួន) ជាដើម ។

## គំនូសបំព្រួញនៃសាខានីតិសាស្ត្រ (រូបទី ១)

## (របៀបទី ១)




**សំគាល់ :**

សាខាមូលដ្ឋានគ្រឹះ : គឺជាសានីតិសាស្ត្រ ដែលកំនត់នូវមូលដ្ឋានគ្រឹះនៃទំនាក់ទំនងសង្គម ដូចជានីតិរដ្ឋប្បវេណីវាកំនត់នូវទំនាក់ទំនងបេតិកភណ្ឌ ឬអបេតិកភណ្ឌ ហើយគេអាចបំបែកសាខាមូលដ្ឋានគ្រឹះនេះចេញទៀត ដូចជានីតិវិធីរដ្ឋប្បវេណីជាដើម ....... ។ល។ សាខានេះបានចារឹកខ្លឹមសារក្នុងរដ្ឋធម្មនុញ្ញ ។

**សាខាពិសេស** : នេះជាសាខានីតិសាស្ត្រ ដែលបំបែកចេញពីសាខាមូលដ្ឋានគ្រឹះដូចជានីតិរដ្ឋប្បវេណីអាចបំបែកជានីតិអាពាហ៍ពិពាហ៍ និងគ្រួសារ ...។ល។ ហើយសាខាពិសេសនេះ វាត្រូវបានចារីកខ្លឹមសារនៅក្នុងរដ្ឋធម្មនុញ្ញផងដែរ ។

**សាខាមិស្សភាគ** : គឺជាសាខានីតិសាស្ត្រដែលសាំញ៉ាំ ហើយមានខ្លឹមសារនៅក្នុងលក្ខណៈពិសេស និងមូលដ្ឋានគ្រឹះនៃនីតិសាស្ត្រផងដែរ ដូចជានីតិបរិស្ថានវិទ្យា វាមានខ្លឹមសារខ្លះនៅក្នុងរដ្ឋប្បវេណី. ខ្លះនៅក្នុងរដ្ឋបាល ......ឬក៏នៅក្នុងនីតិព្រហ្មទណ្ឌ។ ខ្លឹមសាររួមរបស់សាខានេះក៏ត្រូវបានចារីកដោយរដ្ឋធម្មនុញ្ញផងដែរ ។

## (របៀបទី ២)



* **កំណាត់ចំណាំ :**

ការកំនត់នូវសាខានៃនីតិសាស្ត្រ ពុំមែនធ្វើឡើងដោយអំណាចរដ្ឋនោះទេ ប៉ុន្តែធ្វើឡើងដោយក្រុមជំនាញនៃនីតិសាស្ត្រសំរាប់រដ្ឋនីមួយៗ ដោយមានការទទួលស្គាល់ជាផ្លូវការពីស្ថាប័នទទួលបន្ទុក និងនៅក្នុងប្រទេសទាំងមូល ។ ការកំនត់សាខានេះដើម្បីងាយស្រួលសិក្សា និងធ្វើការស្រាវជ្រាវដោយមានភាពសុក្រឹត្យសំរាប់ការអភិវឌ្ឍន៍នៃនីតិសាស្ត្រក្នុងប្រទេសនីមួយៗ ជាមួយនឹងអន្តរជាតិ។

គុណវិបត្តិដែលពុំបានកំនត់សាខានីតិសាស្ត្រច្បាស់លាស់នេះ ធ្វើឱ្យអ្នកសិក្សា និងអ្នកស្រាវជ្រាវ ពុំមានមូលដ្ឋានគ្រឹះរហូតដល់មានការអនុវត្តនៅក្នុងស្ថាប័នធំៗរបស់រដ្ឋ មានការស្រពិចស្រពិល មិនហ៊ានអាកាត់ ថាតើមុខវិជ្ជានេះជាមុខវិជ្ជារណបទៅលើមុខវិជ្ជាណាមួយពិតប្រាកដ ដូចជាច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ វាជាផ្នែកមួយនៃនីតិរដ្ឋប្បវេណីជាដើម ...... ។ល។ មានន័យថា កិច្ចសន្យា ឬកាតព្វកិច្ច ឬអាពាហ៍ពិពាហ៍ និងគ្រួសារ ទាំងអស់នេះវាជាមុខវិជ្ជារណបនៃមុខវិជ្ជានីតិរដ្ឋប្បវេណីតែប៉ុណ្ណោះ ។

## អត្ថបទទី ២

# នីតិរដ្ឋធម្មនុញ្ញជាវិទ្យាសាស្ត្រ និងជាមុខវិជ្ជាសិក្សា

## ១. កម្មវត្ថុវិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញ

វិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញ វាសិក្សាទៅលើ**បទដ្ឋានធម្មនុញ្ញគតិយុត្តិទាំងឡាយ** និង **មូលដ្ឋានគ្រឹះគតិយុត្តិទាំងពួង** ដែលបទដ្ឋានទាំងនោះវាធ្វើនិយ័តកម្មទៅលើទំនាក់ទំនងសង្គមនានា (ទំនាក់ទំនងសាធារណៈ) ។ ដូចនេះ យើងអាចយល់នូវមុខវិជ្ជាវិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញបាន ត្រង់ថាវាសិក្សាទៅលើ**រចនាសម្ព័ន្ធគ្រប់គ្រង** (រចនាសម្ព័ន្ធដែនដីរដ្ឋ) និង**ឋានៈទាំងឡាយរបស់មនុស្ស** ។ វាមានលក្ខណៈខុសពីនីតិសាស្ត្រផ្សេងៗទៀត ត្រង់ថានីតិរដ្ឋធម្មនុញ្ញជាទូទៅវាសិក្សា អំពី **រដ្ឋ** អំពី**គោលជំហរនីត្យានុកូលកម្ម** (Legalization) **នៃប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋ** និង**ទំនាក់ទំនងគតិយុត្តិទាំងពួង** ដែលលេចឡើងរវាង**ប្រព័ន្ធគ្រប់គ្រង** និង**រដ្ឋ**, **សង្គម** និង**ពលរដ្ឋ** ។

សំរាប់នីតិរដ្ឋធម្មនុញ្ញទំនើប វាមានលក្ខណៈមួយច្បាស់លាស់ត្រង់ថា **អាសនៈរបស់មនុស្ស ឬឋានៈនៃមនុស្ស**នៅក្នុងរចនាសម្ព័ន្ធ និងរដ្ឋចាប់ផ្ដើមកំណត់ដំបូងនៅក្នុងប្រព័ន្ធមួយនៃការធ្វើនិយ័តកម្មធម្មនុញ្ញគតិយុត្តិ ហើយដែលប្រព័ន្ធនោះសំដែងជាប្រភេទនៃតំលៃរបស់រដ្ឋ គឺ**ភាពប្រជាធិបតេយ្យ** ឯតំលៃរបស់សង្គមគឺជា**លទ្ធផលនៃតុល្យភាព**របស់មនុស្ស និងលក្ខណៈនៃសង្គមពលរដ្ឋ ។ ចំណុចនេះបង្ហាញថា គេឱ្យតំលៃ**មនុស្សជាប្រភពនៃអំណាចគ្រប់គ្រងរដ្ឋ** ។ ផ្ទុយទៅវិញវាក៏ជាសាខានៃនីតិសាស្ត្រដែរ ត្រង់ថានីតិរដ្ឋធម្មនុញ្ញសិក្សាទៅលើ**សាខាតែមួយគត់នៃនីតិ** ដែលមាននៅក្នុងប្រព័ន្ធគតិយុត្តិ (Legal System) មួយនៃ**រដ្ឋនីមួយៗ**ហើយវាដើរតួនាទីស្នូលក្នុងសាខានោះ ។ មានន័យថា វាជាសាខាគ្រឹះនៃនីតិផ្សេងៗដទៃទៀត (**មើលរូប ១**) ។ ប្រភេទគ្រឹះសំខាន់ៗនៃវិទ្យាសាស្ត្រនីតិរដ្ឋធម្មនុញ្ញ ត្រូវបានកំណត់នូវទិសដៅមួយចំនួន ដូចខាងក្រោមគឺ :

- មូលដ្ឋានគ្រឹះទាំងឡាយនៃប្រព័ន្ធគ្រប់គ្រងទៅលើសង្គម និងរដ្ឋ : វាកំនត់នូវបែបបទនៃរបបគ្រប់គ្រងរដ្ឋ ដូចជានយោបាយ. ប្រជាធិបតេយ្យ. ...... ។ល។

- មូលដ្ឋានគ្រឹះទាំងឡាយនៃឋានៈគតិយុត្តិនៃមនុស្ស និងពលរដ្ឋ : វាកំនត់នូវសិទ្ធិ និងកាតព្វកិច្ចរបស់ពលរដ្ឋចំពោះសង្គម ដូចជាការគ្រប់គ្រងប្រទេសតាមរយៈបោះឆ្នោត ........ ។ល។

- ប្រព័ន្ធគ្រប់គ្រងដែនដីរដ្ឋ (រដ្ឋឯកភូត. រដ្ឋសហព័ន្ធ. សមាគតរដ្ឋ) : វាកំនត់នូវបណ្តាញរដ្ឋបាលពីកណ្តាលដល់មូលដ្ឋាន ....... ។ល។

- ប្រព័ន្ធនៃអង្គការរដ្ឋ (អង្គការនីតិបញ្ញត្តិ. អង្គការនីតិប្រតិបត្តិ. អង្គការតុលាការ ......): វាកំនត់នូវការបែងចែកអំណាចធំៗរបស់រដ្ឋ ដោយភាពឯករាជ្យ និងទទួលខុសត្រូវ.... ។ល។ លក្ខណៈមួយទៀតដែលជាមុខវិជ្ជាវិទ្យាសាស្ត្រនោះត្រង់ថា ប្រវត្តិសាស្ត្រនៃវិទ្យាសាស្ត្រនីតិរដ្ឋធម្មនុញ្ញបាន ក៏វិតយ៉ាងពិតប្រាកដក្នុងការបាត់បង់ទាំងឡាយនៃ **"យុគ្គកណ្តាលគ្មានរដ្ឋ"** (មជ្ឈិមសម័យពីស.វ V ដល់ XIV) ដែលជាសម័យថ្មីមួយចាប់ផ្តើមបង្កើតរដ្ឋថ្មី ។ ប្រវត្តិសាស្ត្រនោះផ្ទុកនូវវិទ្យាសាស្ត្រធម្មនុញ្ញ នាស.វ XVI-XVIII ជាការប្រតិបត្តិពិតប្រាកដពុំមែនជាលក្ខណៈទ្រឹស្តីទេ ព្រោះថាវាជាភារកិច្ចបង្កើតយ៉ាងចាំបាច់បំផុត ដែលមិនមែនជាភារកិច្ចស្រមើស្រមៃនោះឡើយ ។ វិទ្យាសាស្ត្រនេះវាត្រូវតែបង្កើតនូវទ្រឹស្តីមួយនៃ**រដ្ឋ** (**រដ្ឋថ្មី**) ដោយវាតំរូវឱ្យកំណត់ច្បាប់មួយទៅលើអាទិភាពស្វ័យយ័តនៃទ្រឹស្តីដោយឡែកៗ ដូចជាកំនត់នូវភាពឯករាជ្យនៃព្រំដែនធម្មនុញ្ញចេញពីចក្រភព (Empire) ឬអាណានិគមជាដើម ។ គឺថាវាជាដំណាក់កាលដំបូងនៃការលេចឡើងនូវវិធាននានាក្នុងការគ្រប់គ្រងរដ្ឋតាមបែបសម័យថ្មី រីឯលក្ខណៈគ្រប់គ្រងសម័យចាស់ វិទ្យាសាស្ត្រនោះបានកំនត់ទំរង់រាជានិយមផ្តាច់ការ......។ល។ ហើយនៅទីបញ្ចប់ វាក៏កំនត់បាននូវទំរង់គ្រប់គ្រងរដ្ឋមួយយ៉ាងសមស្របតាមឆន្ទៈរបស់រាស្ត្រ ។

នៅចុង ស.វ ទី XVIII បញ្ហាទាំងឡាយដែលហៅថា**នីតិរដ្ឋធម្មនុញ្ញ** (Constitutional law) ត្រូវបានសិក្សាទៅលើទស្សនៈបីដែលមានគោលដៅវិទ្យាសាស្ត្រគឺ :

**ក.ការសិក្សាលើនយោបាយ** : នេះជាគោលដៅមួយ ដែលស្ថិតនៅក្នុងសមាសភាពនៃវិទ្យាសាស្ត្រនយោបាយច្បាប់ ( មានន័យថា ជាលទ្ធិនៃច្បាប់ពិត)។ កិច្ចការនេះគេបង្កើតប្រព័ន្ធគ្រប់គ្រងរដ្ឋ និងអាសនៈមនុស្សដោយប្រកាន់ខ្ជាប់នូវច្បាប់ជាបង្អែក គឺថាអំណាចរដ្ឋត្រូវតែកើតឡើងតាមរយៈនៃឆន្ទៈទូទៅរបស់ពលរដ្ឋ ហើយដែលបានចារិកក្នុងច្បាប់គ្រឹះរបស់ប្រទេស ។ នយោបាយជាប្រភពដ៏សំខាន់ក្នុងសង្គមមនុស្សដើម្បីដឹកនាំរដ្ឋ **ប្រសិនបើគ្មាននយោបាយ នោះការគ្រប់គ្រងរដ្ឋក៏គ្មានដែរ**[៤] ។

**ខ.ការសិក្សាលើសង្គម** : នេះជាការសិក្សាយ៉ាងលំអិតទៅលើបញ្ហាវត្តមានរបស់មនុស្ស និងការប្រមូលផ្តុំជាសង្គម ដើម្បីបង្កើតក្បាលម៉ាស៊ីនដឹកនាំ (រដ្ឋ) ។ គឺថាមនុស្សប្រមូលផ្តុំគ្នាបង្កើតជាសង្គមមួយ ហើយសង្គមនោះត្រូវមានឧបករណ៍មួយជាអ្នកដឹកនាំ និងគ្រប់គ្រង គឺរដ្ឋនេះឯងដោយពុំអាចខ្វះបាន ។

**គ.ការសិក្សាលើរដ្ឋ** : វាជាការសិក្សាទៅលើការងារសង្គម, សកម្មភាព និងបែបបទនៃការគ្រប់គ្រងរដ្ឋរបស់ប្រទេសនីមួយៗនៃសម័យកាលនានារបស់គេ ។ ការសិក្សារដ្ឋនេះ វាសំដៅទៅលើ **ទំរង់គ្រប់គ្រង និងរចនាសម្ព័ន្ធដែនដី** ដូចជាទំរង់បែបសាធារណរដ្ឋ ឬបែបរាជានិយម, និងរចនាសម្ព័ន្ធដែនដី ដូចជារដ្ឋឯកភូត, រដ្ឋសហព័ន្ធ ឬក៏សមាគតរដ្ឋជាដើម ។

សរុបទៅការកំណត់ទៅលើទស្សនៈបីប្រភេទ នូវសាខាស្វ័យភាពនៃវិទ្យាសាស្ត្រសំរាប់នីតិរដ្ឋធម្មនុញ្ញ ខាងលើនេះបានកើតមាននៅក្នុងក៏រិតមួយនៃអ្នកបោះផ្សាយជាសាធារណៈ របស់អាល្លឺម៉ង់ក្នុងពាក់កណ្តាល ស.វ ទី XIX ដែលក្នុងនោះមាន[៥] :

---

[៤]. នយោបាយជាកិច្ចការរដ្ឋ ឬសង្គម ដូចនេះ បើសិនជាគ្មានបុគ្គលដែលជាសមាជិកសង្គមណាមួយចាប់អារម្មណ៍ អំពីផលប្រយោជន៍រដ្ឋ ឬសង្គម ឬមានន័យថាមិនចាប់អារម្មណ៍ពីនយោបាយ ឬប្រយោជន៍សាធារណៈ នោះធ្វើឱ្យរដ្ឋនោះនឹងរលាយបាត់ពីពិភពលោក ។

[៥]. មើល Constitutional law, case study, Part II, Page 17, M. 1994 ។

- ទ្រឹស្តីនីតិរដ្ឋ
- ការសិក្សាទូទៅអំពីរដ្ឋ
- ការសិក្សាទៅលើនយោបាយ ។

ជាការពិតណាស់ មុខវិជ្ជាសិក្សាវិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញទិសដៅសំខាន់ គឺត្រូវ**សិក្សាលើទ្រឹស្តី និងទស្សនៈ**ទាំងឡាយ ដែលបានកែច្នៃឡើងដោយ**អ្នកស្រាវជ្រាវ**នៃនីតិរដ្ឋធម្មនុញ្ញ និងលក្ខខ័ណ្ឌទាំងឡាយដែលមានឥទ្ធិពលលើបរិវត្តន៍ (បំលាស់ប្តូរ) នៃសង្គម ហើយ**ជាវិទ្យាសាស្ត្រដែលសិក្សាលើទំនាក់ទំនងអំណាចសាធារណៈ** ។ ចំពោះមុខវិជ្ជាវិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញបរទេស វាមានផ្នែកទូទៅនៃវិទ្យាសាស្ត្រនីតិរដ្ឋធម្មនុញ្ញ ដោយអាស្រ័យនឹងប្រទេសនីមួយៗ ។ វិទ្យាសាស្ត្រនេះ វាមានការផ្តោតទៅលើការសិក្សានៃបទពិសោធន៍របស់ប្រទេសផ្សេងៗ ដោយរួមជាមួយនឹងទិសដៅមួយចំនួន ដូចជាលេចចេញនូវ**និន្នាការទូទៅ** និង**និយ័តភាព**នៃការរីកចំរើននីតិរដ្ឋធម្មនុញ្ញក្នុងសម័យទំនើប និងដោយអាស្រ័យនឹងគំរូនេះ គេបាននឹងកំពុងអនុវត្តន៍នូវដំណោះស្រាយធម្មនុញ្ញគតិយុត្តដ៏ជោគជ័យជាច្រើន ដោយគេបានរកឃើញនៅក្នុងបណ្តាប្រទេសទាំងនោះ ឬក៏គេអាចគេចចេញពីនោះដោយវាមានលក្ខណៈខុសឆ្គង ។ ត្រង់នេះបញ្ជាក់ថា ប្រទេសនានាអាចដកយកបទពិសោធន៍ពីគ្នាទៅវិញទៅមកក្នុងការគ្រប់គ្រងប្រទេស តាមរយៈនៃការពិនិត្យនូវលទ្ធផលជាក់ស្តែង ដោយផ្សារភ្ជាប់ទៅនឹងបទបញ្ញត្តិទាំងឡាយ ដែលបានចែងក្នុងច្បាប់គ្រឹះនៃប្រទេសទាំងនោះ ។

មុខវិជ្ជាវិទ្យាសាស្ត្រនេះ បានរកឃើញនូវ**ឧបករណ៍ដែលជាវិធាន**មួយ ស្ថិតនៅក្នុងបទដ្ឋានឬនិយាមនៃអ្នកស្រាវជ្រាវទៅលើរដ្ឋធម្មនុញ្ញដ៏សំបូរបែប ។ នៅក្នុងមុខវិជ្ជានេះ វាក៏ដូចជាមុខវិជ្ជានីតិសាស្ត្រដ៏ទៃទៀតដែរ ត្រង់ថាវិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញវាប្រព្រឹត្តទៅនូវ**វិធាន** នៃការវិភាគ**តក្កវិជ្ជា-ទំរង់**[៦] ដោយមានលក្ខណៈចាំបាច់សំរាប់បំនើកខ្លឹមសារនៃបទដ្ឋានជាសំភារៈ ដែលបានស្រាវជ្រាវរួចមកហើយនោះ ។

---

[៦] . នៅក្នុងនីតិសាស្ត្រ វាជាទំរង់គ្រប់គ្រងពិតប្រាកដដែលបានចារិកក្នុងច្បាប់គ្រឹះ តែពុំមែនជាការប្រឌិតទេ ។

មុខវិជ្ជានេះមានអត្ថន័យពិសេសក្នុងវិទ្យាសាស្ត្រ ត្រង់ថាមាន**វិធានប្រៀបធៀប**យ៉ាងសុក្រឹត្យនៃការស្រាវជ្រាវដែលពួកគេ (អ្នកនីតិរដ្ឋធម្មនុញ្ញ) បានកំណត់មក ។ ត្រង់នេះបង្ហាញថារាល់**និយ័តកម្មធម្មនុញ្ញគតិយុត្តិ** ដែលបានធ្វើការសិក្សារួចហើយ ទាក់ទិនចំពោះបរិយាកាសទាំងឡាយ ដែលមានលទ្ធភាពប្រើប្រាស់បទពិសោធន៍ទាំងនោះ សំរាប់ធ្វើជាប្រយោជន៍ដល់ប្រទេសផ្សេងៗទៀត ដោយចាត់ទុកបទពិសោធន៍ទាំងនោះជាផ្ទាល់ពិសោធន៍មួយ ឬវិធានមួយ ព្រមទាំងមានការប្រៀបធៀបបទពិសោធន៍របស់ប្រទេសដទៃទាំងនោះ មកធ្វើការដោះស្រាយបញ្ហាដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដែលកើតមានចំពោះប្រទេសផ្សេងៗទៀត ជាពិសេសគេអាចគេចចេញបានចំពោះបញ្ហាដែលនឹងកើតមាននោះទៀតផង ។

## ២. វិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញ

វិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញ គឺជាប្រព័ន្ធមួយនៃចំណេះដឹងអំពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ, អំពីឋានៈមនុស្សក្នុងរដ្ឋនោះ ហើយដែលត្រូវបានចារឹកនៅក្នុងទំនាក់ទំនងទាំងឡាយ ដោយបានផ្ទុកផ្ទាក់រវាងរចនាសម្ព័ន្ធរដ្ឋទាំងឡាយ, រវាងស្ថាប័នសង្គមទាំងឡាយ និងពលរដ្ឋក្នុងរង្វង់នៃនិយ័តកម្មធម្មនុញ្ញគតិយុត្តិ ។ ចំណែកវិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញបរទេស វាជាទូទៅនៅមានសភាពក្មេងខ្ចីនៅឡើយ គឺប្រហែលក្នុងកំឡុង ស.វ ទី XIX មានន័យថា យឺតជាងនីតិសាស្ត្រផ្សេងៗទៀតដូចជា : នីតិព្រហ្មទណ្ឌ, នីតិរដ្ឋប្បវេណី, នីតិវិធីផ្សេងៗទៀត .....។ល។ អញ្ចឹងហើយបានជានីតិរដ្ឋធម្មនុញ្ញពុំសូវមានការយល់ដឹងទូលាយនៅក្នុងសង្គមទន់ខ្សោយនោះឡើយ ។

ក្នុងអំឡុងពេលនៃការតស៊ូប្រឆាំងនឹងសក្តិភូមិនិយម, **ពួកប្រជាធិបតេយ្យវិទូ**មួយចំនួន ដូចជាលោក **ហុប, ម៉ុងតេស្គេ, ឡុក, រូស្សូ ហ្សិក្រាន់ហ្សិក្រាក់** និងអ្នកដទៃទៀត ដែលបានបង្កើតនូវទស្សនាទានសំខាន់ៗបំផុតនៃនីតិរដ្ឋធម្មនុញ្ញ ដូចជា**រដ្ឋធម្មនុញ្ញនិយម, អធិបតេយ្យប្រជាជន, តំណាងប្រជាជន, ការបែងចែកអំណាច** និងសិទ្ធិ ដែលមិនអាចកាត់ផ្តាច់របស់មនុស្ស ។ ការយល់ឃើញនូវទស្សនៈរួមរបៀបនេះបានបញ្ជាក់ថា នីតិរដ្ឋធម្មនុញ្ញពិតជាមានលក្ខណៈវិទ្យាសាស្ត្រមួយនៃសង្គមមនុស្ស ។

ដូច្នេះ ទ្រឹស្តីទាំងអស់ដែលមានលក្ខណៈដូចខាងលើនេះ វាបំរើឱ្យផលប្រយោជន៍មួយនៃអ្នកសង្គមវិទូ ដើម្បីបំផ្លាញចោលនូវរបបសក្តិភូមិនិយម ពីព្រោះថាសក្តិភូមិនិយមបង្កើតនូវទំរង់គ្រប់គ្រងសង្គមដោយឈរលើមូលដ្ឋានគ្រឹះនៃ**អត្តាវសនិយម** ឬពួកអត្តនោម័តនិយម (Despotism) និងទំនើងចិត្តទៀតផង។ ដោយប្រើមធ្យោបាយដ៏ជោគជ័យនៃឯកភាពគ្រប់គ្រងមួយ ប្រឆាំងនឹងកំលាំងនយោបាយសក្តិភូមិបានធ្វើឡើងតាម**ទ្រឹស្តី** និង**ការអនុវត្តន៍** រួចមកពួកអ្នកទស្សនៈវិទូទាំងនោះបានផ្សព្វផ្សាយនូវទ្រឹស្តីរបស់ខ្លួន **អំពីអំណាចនៃការគ្រប់គ្រងរដ្ឋ ត្រូវកើតមានឡើងតាមរយៈឆន្ទៈរបស់ពលរដ្ឋទូទៅ** ។ ក្នុងសម័យបដិវត្តន៍ប្រឆាំងសក្តិភូមិ បានចាប់ផ្តើមនូវទំរង់**គ្រប់គ្រងបែបធម្មនុញ្ញ** និងប្រែក្លាយវាឱ្យទៅជា**នីតិរដ្ឋធម្មនុញ្ញ** (Constitutional Law) ព្រមទាំងផ្តល់ទៅឱ្យវានោះនូវទំរង់គតិយុត្តិមួយប្រកបដោយលក្ខណៈកែច្នៃតាមអ្នកទ្រឹស្តីទាំងពួង នៃទស្សនៈលទ្ធិប្រជាធិបតេយ្យ បន្ទាប់មកអ្នកប្រាជ្ញច្បាប់ជាច្រើនបានបញ្ចេញការងារដោយយកចិត្តទុកដាក់បំផុត ទៅលើការអធិប្បាយនៃបទដ្ឋានធម្មនុញ្ញគតិយុត្តិថ្មីៗទៀត និងកំនត់នូវស្ថាប័នរបស់វាទៀតផង ។ ដូចជាអ្នកច្បាប់អង់គ្លេសម្នាក់ឈ្មោះ **ប្លិកស្តូន** ដែលបានរស់នៅក្នុង ស.វ XVIII -XIX បានបង្កើតស្នាដៃរបស់ខ្លួនឈ្មោះ "**ការអធិប្បាយចំពោះច្បាប់អង់គ្លេស**" ដែលមានចំនួនបួនក្បាល (Volume)[៧] ។ ស្នាដៃនេះ ជាលទ្ធផលនៃការចាប់ផ្តើមកើតមាននូវសករាជមួយ មានគោលដៅលើលក្ខណៈច្បាស់លាស់ចំពោះ**វិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញ** ។

នៅក្នុង ស.វ ទី XIX មានការលេចឡើងនូវស្នាដៃជាច្រើនទៀតនៃអ្នកច្បាប់រដ្ឋធម្មនុញ្ញដូចជានៅប្រទេស**អង់គ្លេស**, និងបង្កើតនូវទ្រឹស្តីនៃនីតិរដ្ឋធម្មនុញ្ញមាននៅ**អាល្លឺម៉ង់** ក្នុងនោះមាន**លទ្ធិធម្មនុញ្ញគតិយុត្តិ, សភានិយម, នីតិរដ្ឋ, រដ្ឋប្រជាធិបតេយ្យ** ។ល។

នៅដើមស.វ ទី XX ការប្រើប្រាស់ដ៏ហ្មត់ចត់ទៅលើស្នាដៃទាំងនេះ ក្នុងការអភិវឌ្ឍន៍នៃទ្រឹស្តីនីតិរដ្ឋធម្មនុញ្ញ ធ្វើឱ្យអ្នកប្រាជ្ញច្បាប់នៃបណ្តាប្រទេសមួយចំនួននៅអឺរ៉ុប បានខិតខំ និងបញ្ចេញស្នាដៃ

---

[៧] . មើល Constitutional law of foreign Country, Page 25. M. 1994

បន្ថែមទៀត ដូចជាអ្នកប្រាជ្ញា**បារាំង,អ៊ីតាលី,ចក្រភពអង់គ្លេស និងអាល្លឺម៉ង់** ជាដើម ។ល។ អ្នកប្រាជ្ញនៃបណ្ដាប្រទេសទាំងនេះបានខិតខំកែច្នៃស្នាដៃរបស់ខ្លួន សំរាប់ទុកឱ្យជំនាន់ក្រោយមកទៀត ដើម្បីធ្វើឱ្យប្រសើរឡើងនូវការវិវត្តន៍សង្គម ដោយក្នុងនោះមានអត្ថិភាព ( វត្តមាន) ទៅលើកិច្ចការសង្គមមួយនៃការសំរេចផលលើ**បច្ចេកវិទ្យា** ។ នៅក្នុងខណៈនេះ ដូចជាទ្រឹស្ដី**ប្រជាធិបតេយ្យសេរីពហុបក្ស** (Pluralistic democracy). **ទ្រឹស្ដីជំរើស, ទ្រឹស្ដីបច្ចេកាធិបតេយ្យ** (Technocracy លទ្ធភាពគ្រប់គ្រងដោយពឹងផ្អែកលើអ្នកបច្ចេកទេស ) ........... ។ល។

សរុបទៅនៅក្នុងវិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញ វាក៏ដូចជានៅក្នុងនីតិសាស្ត្រផ្សេងៗទៀតដែរ ដែលក្នុងក៏រិតនោះគេអាចកំណត់នូវធាតុផ្សេងៗគ្នាបីប្រភេទ ដោយមានបញ្ជាក់នូវវិទ្យាសាស្ត្រនៃនីតិរដ្ឋធម្មនុញ្ញគឺ :

**ក.ប្រវត្តិសាស្ត្រនៃច្បាប់** :បទដ្ឋានគតិយុត្តិទាំងឡាយអាចសិក្សា អំពីទស្សនៈនៃការកកើតឡើង និងការរីកចំរើនជាប្រវត្តិសាស្ត្រ, មានន័យថាសិក្សាលើ**ប្រវត្តិសាស្ត្រនៃច្បាប់** (History of Law)

**ខ.មូលដ្ឋានគ្រឹះនៃច្បាប់** : បទដ្ឋានគតិយុត្តិទាំងឡាយអាចសិក្សាបន្តទៀត ដែលមានអាទិភាព ( ភាពនាំមុខ) ក្នុងរដ្ឋល្បីល្បាញ ( សំខាន់ៗ) ដោយក្នុងខណៈនោះត្រូវបំភ្លឺនូវខ្លឹមសាររបស់វា និងស្រាយបំភ្លឺនូវដំណាក់ដំបូងៗដែលជាមូលដ្ឋានគ្រឹះរបស់វានោះ, បំនើកនូវឯករាជ្យភាពនៃបទដ្ឋានទាំងនោះ និងប្រមូលផ្ដុំឱ្យទៅជា**ប្រព័ន្ធរួមមួយ** ។ នៅក្នុងវិទ្យាសាស្ត្របែបនេះហៅថា**មូលដ្ឋានគ្រឹះនៃច្បាប់** (Basic of Law ) ដែលពលរដ្ឋនិមួយៗចាត់ទុករដ្ឋធម្មនុញ្ញជាច្បាប់គោលដ៏សំខាន់ ។

**គ.នយោបាយច្បាប់** : ច្បាប់ជាបទដ្ឋានកិច្ចគតិយុត្តិ ដែលមានលក្ខណៈមួយកើតចេញពីទស្សនៈវាយតំលៃពីគំនិតនៃមនុស្សគ្រប់ជំនាន់ ហើយសំរាប់ប្រជាជនទូទៅនៃសង្គមនីមួយៗរបស់ពួកគេ ក្នុងសម័យកាលនោះទៀតផង នេះគេហៅថា**នយោបាយច្បាប់** (Policy of Law) ។ ត្រង់នេះគឺបង្ហាញថា ច្បាប់នៃរដ្ឋនីមួយៗកើតមានតាមសម័យកាលរបស់សង្គម សមស្របតាមឆន្ទៈរួមនៃសករាជនីមួយៗ ។

## ៣. នីតិរដ្ឋធម្មនុញ្ញជាមុខវិជ្ជាសិក្សា

នីតិរដ្ឋធម្មនុញ្ញនៅបណ្តាប្រទេសមួយចំនួនធំលើពិភពលោក បើទោះជាប្រទេសនោះប្រកាន់របបគ្រប់គ្រងរបៀបនេះ ឬនោះក៏ដោយចុះ ក៏គេយកនីតិរដ្ឋធម្មនុញ្ញទៅបញ្ចូលក្នុងកម្មវិធីសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាផ្នែកនីតិសាស្ត្រដែរ ។ ជាពិសេសទៀតនោះ នីតិរដ្ឋធម្មនុញ្ញជាមុខវិជ្ជាមួយដែលនិស្សិតត្រូវដឹង និងសិក្សាទៅលើមូលដ្ឋានគ្រឹះសំខាន់ៗទាំងអស់របស់វា មួយវិញទៀតការសិក្សាទៅលើមុខវិជ្ជានេះ ពុំមែនតែនីតិរដ្ឋធម្មនុញ្ញរបស់ខ្លួនប៉ុណ្ណោះទេ គឺថែមទាំងសិក្សានីតិរដ្ឋធម្មនុញ្ញបរទេសទៀតផង ដើម្បីងាយស្រួលយកជាបទពិសោធន៍ និងប្រៀបធៀបរវាងនីតិរដ្ឋធម្មនុញ្ញទាំងនោះ ជាមួយនឹងច្បាប់គ្រឹះរបស់ប្រទេសខ្លួនផងដែរ ។

នីតិរដ្ឋធម្មនុញ្ញជាមុខវិជ្ជាសិក្សា គឺថាវាមានអត្ថន័យដ៏ធំ ដែលជាវិទ្យាសាស្ត្រមួយពិតប្រាកដដោយចាត់ទុកក្នុងកម្មវិធីសិក្សាទៅលើផ្នែកពីរយ៉ាងសំខាន់ គឺ**ផ្នែកទូទៅ** និង**ផ្នែកពិសេស** ។

**ផ្នែកទូទៅ** សិក្សាទៅលើស្ថាប័នមូលដ្ឋានគ្រឹះទាំងឡាយនៃនីតិរដ្ឋធម្មនុញ្ញ (មើលប្រព័ន្ធនៃនីតិរដ្ឋធម្មនុញ្ញ) រីឯ**ភាគពិសេស ឬនីតិរដ្ឋធម្មនុញ្ញប្រៀបធៀប** គឺសិក្សាទៅលើស្ថាប័ននយោបាយទាំងឡាយ និងមូលដ្ឋានគ្រឹះនៃនីតិរដ្ឋធម្មនុញ្ញរបស់ប្រទេសនីមួយៗ ក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋ ។

និយាយរួម នីតិរដ្ឋធម្មនុញ្ញជាមុខវិជ្ជាសិក្សា ដែលធ្វើឡើងសំរាប់គ្រប់ប្រទេសនៅលើពិភពលោក តែក៏មានប្រទេសតតិយលោកខ្លះនៅពុំទាន់បានធ្វើការកែច្នៃ នូវប្រព័ន្ធអប់រំឧត្តមសិក្សារបស់ខ្លួនឱ្យទាន់សម័យនោះដែរ. ដែលធ្វើឱ្យមុខវិជ្ជានេះស្រុតចុះ និងសឹងតែពុំស្គាល់តែម្តង ប៉ុន្តែគេគ្រាន់តែឱ្យដឹងនូវផ្នែកខ្លះៗ នៃបញ្ញត្តិធម្មនុញ្ញរបស់សាមីប្រទេសតែប៉ុណ្ណោះ ។ ទាំងនេះជាគុណវិបត្តិមួយដែលធ្វើឱ្យអ្នកសិក្សានីតិសាស្ត្រនៅឧត្តមសិក្សា ពុំបានយល់ដឹងស៊ីជំរៅទៅលើមូលដ្ឋានគ្រឹះនៃទ្រឹស្តីរបស់នីតិរដ្ឋធម្មនុញ្ញ តែគេទាំងនោះអាចយល់ច្រលំថា ការសិក្សានីតិរដ្ឋធម្មនុញ្ញដោយគ្រាន់តែយកច្បាប់រដ្ឋធម្មនុញ្ញមួយមកអានជាការគ្រប់គ្រាន់ទៅហើយ ។

ជាការពិតណាស់ រាល់ការសិក្សាទៅលើនីតិរដ្ឋធម្មនុញ្ញ ពុំអាចកាត់ផ្ដាច់ចេញបាននូវការសិក្សាអំពីទ្រឹស្ដីនៃច្បាប់ និងរដ្ឋ ឬក៏ទ្រឹស្ដីនៃវិទ្យាសាស្ត្រច្បាប់ និងរដ្ឋនោះឡើយ ព្រោះវាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធិបំផុត ជាពិសេសវាបំពេញគ្នាទៅវិញទៅមកដោយពុំអាចខ្វះបាន ។

**អត្ថបទទី ៣**

# អត្ថន័យគ្រឹះនៃរដ្ឋធម្មនុញ្ញ

## ១. និយមន័យនៃរដ្ឋធម្មនុញ្ញ

ប្រសិនបើយើងសង្កេតមើលរដ្ឋធម្មនុញ្ញជាទូទៅ នោះយើងអាចកំណត់បានថារដ្ឋធម្មនុញ្ញជាប្រព័ន្ធមួយនៃបទដ្ឋានកិច្ចគតិយុត្ត (Normative Acts) មានសភាពជាវិន័យមួយដែលមានកំលាំងគតិយុត្តិខ្ពស់ និងធ្វើនិយ័តកម្មទៅលើមូលដ្ឋានគ្រឹះទាំងឡាយនៃគ្រប់ទំនាក់ទំនង រវាង**មនុស្ស** និង**សង្គម** មានន័យថារវាង**រដ្ឋ** និង**អង្គការគ្រប់គ្រងរដ្ឋ** ។ រាល់បទបញ្ញត្តិទាំងនោះបណ្តុំចូលគ្នានៅក្នុង**បទដ្ឋានកិច្ចគតិយុត្តិ** (Normative Acts) តែមួយ ឬច្រើន ដែលហៅថា**ច្បាប់គ្រឹះ** ( រដ្ឋធម្មនុញ្ញ) និងអាចផ្ទុកនូវខ្លឹមសារដ៏សំបូរបែប ដោយពុំអាចកំណត់បានសំរាប់ច្បាប់ធម្មតា និងលើសពីនេះទៅទៀតវាផ្ទុកនូវអាទិភាពគតិយុត្តិ ( សេចក្តីសំរេចរបស់តុលាការ នៃប្រពន្ធ័គតិយុត្តិអង់គ្លេសាក់សុង) និងទំលាប់ធម្មនុញ្ញទៀតផង ។

រដ្ឋធម្មនុញ្ញជាទូទៅមានគំនិតមូលដ្ឋានគ្រឹះ ២ គឺ :**គំនិតជាសំភារៈ** (Materal Constitu - tion) និង**គំនិតជាទំរង់** (Formal Constitution) ដែលគេសង្កេតឃើញជាទូទៅនោះ ។ អត្ថន័យទាំងនោះយើងអាចពិនិត្យនូវខ្លឹមសារដូចខាងក្រោម :

**ក.រដ្ឋធម្មនុញ្ញជាសំភារៈ** :វាជាកិច្ច (Acts) ដែលមានសរសេរជាលាយល័ក្ខណ៏អក្សរ ឬជា**បណ្តុំនៃកិច្ចទាំងឡាយ ឬបណ្តុំនៃទំលាប់ធម្មនុញ្ញ**ដែលកិច្ចទាំងនោះ ជារួមមាន**ប្រកាស** និង**ការធានានូវសិទ្ធិ** និង**សេរីភាព**មនុស្ស និងពលរដ្ឋ គឺថាវាកំណត់នូវគ្រឹះគោលទាំងឡាយនៃ**របបគ្រប់គ្រងសង្គម**, **ទំរង់គ្រប់គ្រង** និង**រចនាសម្ព័ន្ធគ្រប់គ្រងដែនដី** **គ្រឹះគោលទាំងឡាយនៃអង្គការគ្រប់គ្រងអំណាចកណ្តាល** និង**អំណាចគ្រប់គ្រងអង្គការមូលដ្ឋាន**, **កំណត់នូវសមត្ថកិច្ចរបស់វា និងទំនាក់ទំនងអញ្ញមញ្ញ**, **កំណត់នូវនិមិត្តរូបរដ្ឋ និងរដ្ឋធានី** ។ល។ ដូចនេះ អត្ថន័យជាសំភារៈ

នៃរដ្ឋធម្មនុញ្ញ វាជាគ្រឹះគោលសំរាប់គ្រប់គ្រងនៃរដ្ឋនីមួយៗ ដែលគេចាត់ទុករដ្ឋធម្មនុញ្ញជាច្បាប់គោល មានលក្ខណៈពិតជាក់ស្តែងសំរាប់សង្គម ។

**ខ.រដ្ឋធម្មនុញ្ញជាទំរង់** : ជារដ្ឋធម្មនុញ្ញដែលគេសន្មត់ថា ជាសាខាគ្រឹះនៃនីតិសាស្ត្រផ្សេងៗទៀត (មើលរូបទី ១) ។ អត្ថន័យរបស់វាគឺថាវាជាច្បាប់មួយ ឬក៏ក្រុមមួយនៃច្បាប់ទាំងឡាយ ដែលមាន**កំលាំងគតិយុត្តិខ្ពស់** បើគិតក្នុងទំនាក់ទំនងចំពោះច្បាប់ដទៃទៀតក្រៅពីក្រុមវានោះ ។ រដ្ឋធម្មនុញ្ញនៅក្នុងអត្ថន័យរបៀបនេះ គឺជា**ច្បាប់មួយនៃច្បាប់ទាំងពួង** ពីព្រោះថា វាពុំអាចត្រូវបានផ្លាស់ប្តូរតាមវិធីនៃការបង្កើតច្បាប់ធម្មតាណាមួយនោះទេ ។ មានន័យថាវាពុំអាចផ្លាស់ប្តូរ ឬក៏យកច្បាប់ណាមួយមកជំនួសដូចច្បាប់ធម្មតាបាននោះទេ ។ រដ្ឋធម្មនុញ្ញមានអត្ថន័យជាទំរង់នេះ វាបានបង្ហាញនូវលក្ខណៈគោលសំរាប់ឱ្យច្បាប់ដទៃទៀតធ្វើឡើងស្របនឹងទំរង់របស់វា ។

ជារួមទៅអត្ថន័យជាសំភារៈ និងជាទំរង់នៃរដ្ឋធម្មនុញ្ញវាស្ថិតនៅក្នុង**សហសម្ព័ន្ធ**[៨] កំណត់មួយច្បាស់លាស់ និងត្រូវការបំពេញគ្នាយ៉ាងចាំបាច់បំផុតចំពោះអត្ថិភាពនៃរដ្ឋនីមួយៗ ។ ជាការពិតហើយ មានពេលខ្លះគេសង្កេតឃើញនូវទំរង់ពិសេសនៃការសំដែងចេញនៃរដ្ឋធម្មនុញ្ញ ត្រូវស្របនឹងកម្មវត្ថុនៃការធ្វើនិយ័តកម្មនៅក្នុងទំនាក់ទំនងពិតៗនៃសង្គម ដោយកំនត់នូវមូលដ្ឋានគ្រឹះទាំងឡាយនៃរបបគ្រប់គ្រងសង្គម និងរដ្ឋរបស់ប្រទេសជាចាំបាច់ស្របតាមលក្ខណៈជាក់ស្តែង ។ សហសម្ព័ន្ធ (Correlation) នោះបាននាំមកនូវលក្ខណៈតក្កវិជ្ជាត្រង់ថា : **គ្រប់រដ្ឋទាំងអស់មានរដ្ឋធម្មនុញ្ញ (ច្បាប់គ្រឹះ) ក្នុងអត្ថន័យជាសំភារៈ ប៉ុន្តែពុំមែនគ្រប់រដ្ឋទាំងអស់នោះមានរដ្ឋធម្មនុញ្ញក្នុងអត្ថន័យជាទំរង់នោះទេ** ។ នៅក្នុងអត្ថន័យនេះបញ្ជាក់យ៉ាងច្បាស់ថា គ្រប់ប្រទេសតែងមានច្បាប់គ្រឹះរបស់ខ្លួន ប៉ុន្តែច្បាប់គ្រឹះទាំងនោះ ពុំត្រូវបានអនុវត្តដោយជោគជ័យតាមទំរង់ដែលបានកំនត់នោះ

---

[៨]. អត្ថន័យ នៃរដ្ឋធម្មនុញ្ញក្នុងទំរង់ទាំងពីរនេះពុំអាចផ្តាច់ចេញពីគ្នាបានទេ ។ ការវែកញែកនេះគ្រាន់តែសំដៅទៅលើបទដ្ឋានទាំងឡាយនៃរដ្ឋធម្មនុញ្ញប៉ុណ្ណោះ តែពុំមែនរដ្ឋធម្មនុញ្ញមួយមានអត្ថន័យជាសំភារៈ ហើយគ្មានអត្ថន័យជាទំរង់នោះឡើយ គឺត្រូវមានទាំងពីរ ។

ឡើយ ។ ប្រទេសអង់គ្លេសពុំមានរដ្ឋធម្មនុញ្ញរួមទេ គឺវាជាកិច្ច (Acts) ដែលនៅដាច់ដោយឡែកៗពីគ្នា ដែលធ្វើឱ្យមានខ្លឹមសារទាក់ទិននឹងអត្ថន័យជាសំភារៈ ។

ចំពោះអត្ថន័យ**ជាសំភារៈ** នៃរដ្ឋធម្មនុញ្ញវាកើតមានត្រង់ថា **បទដ្ឋានកិច្ចគតិយុត្តិដែលបានបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញ ធ្វើនិយ័តកម្មទៅលើទំនាក់ទំនងសាធារណៈ** (លក្ខណៈអំណាចរដ្ឋភាគច្រើន) ។ ផ្ទុយទៅវិញចំពោះអត្ថន័យជាទំរង់នៃរដ្ឋធម្មនុញ្ញ កើតមានត្រង់ថាវាផ្ទុកនូវបទដ្ឋានទាំងឡាយ ដែលធ្វើនិយ័តកម្មលើ**ទំនាក់ទំនងមួយចំនួននោះ ពុំមានលក្ខណៈជាធម្មនុញ្ញ** (លក្ខណៈរដ្ឋ) ទេ[៩] មានន័យថាអត្ថន័យនៃរដ្ឋធម្មនុញ្ញជាទំរង់នេះ វាធ្វើនិយ័តកម្មទៅលើទំនាក់ទំនងអត្តភាពផងដែរ ។ គួរបញ្ជាក់ផងដែរថា ទំនាក់ទំនងសង្គមមានច្រើនប្រភេទណាស់ដូចជា : ទំនាក់ទំនងគ្រួសារ, ទំនាក់ទំនងការងារ, ទំនាក់ទំនងទ្រព្យសម្បត្តិ, ទំនាក់ទំនងព្រហ្មទណ្ឌ ..... ។

ប៉ុន្តែទោះបីជាអត្ថន័យនៃរដ្ឋធម្មនុញ្ញ មានអត្ថន័យពីរសំខាន់យ៉ាងណាក៏ដោយ ក៏លក្ខណៈទាំងពីរបានបង្កប់នូវធាតុរួមគ្នាពីរទៀត គឺ**រដ្ឋធម្មនុញ្ញគតិយុត្តិ ឬរដ្ឋធម្មនុញ្ញមានលក្ខណៈអង្គច្បាប់** (Judicial Constitution) និង**រដ្ឋធម្មនុញ្ញពិត ឬរដ្ឋធម្មនុញ្ញមានលក្ខណៈជាអង្គហេតុ** (Real Constitution) ។ អត្ថន័យនៃធាតុទាំងពីរនេះពុំមានលក្ខណៈដូចគ្នាទេ ថ្វីត្បិតតែវាអាចស្ថិតនៅក្នុងរដ្ឋធម្មនុញ្ញអត្ថន័យជាទំរង់ ឬក៏រដ្ឋធម្មនុញ្ញជាសំភារៈក៏ពិតមែន (**មើលរូប ២**) ។

**ក.រដ្ឋធម្មនុញ្ញគតិយុត្តិ (Juridical Constitution)** : រដ្ឋធម្មនុញ្ញគតិយុត្តិនៅក្នុងអត្ថន័យជាសំភារៈ ឬក៏ជាទំរង់វាជានិច្ចកាល គឺជា**ប្រព័ន្ធកំណត់មួយនៃបទដ្ឋានកិច្ចគតិយុត្តិ ដែលធ្វើនិយ័តកម្មទៅលើគ្រប់វង្វង់នៃទំនាក់ទំនងសាធារណៈ** ។ ត្រង់នេះបញ្ជាក់ថា រដ្ឋធម្មនុញ្ញជាច្បាប់កំពូល ប៉ុន្តែការអនុវត្តន៍នៅក្នុងសង្គមជាក់ស្តែងពុំកើតមានទេ ព្រោះវាជាបញ្ញត្តិដែលកើតមាននៅលើក្រដាសតែប៉ុណ្ណោះ ។ មានន័យថាបានចែងក្នុងច្បាប់ ប៉ុន្តែពុំមានកើតនៅក្នុងសង្គមពិត ។

---

[៩] . លក្ខណៈរដ្ឋមានន័យថា ជាលក្ខណៈអំណាចគ្រប់គ្រង ប៉ុន្តែលក្ខណៈអត្តភាព (សិទ្ធិ) ឬលក្ខណៈកម្មសិទ្ធិ (កាតព្វកិច្ច) ពុំមានលក្ខណៈជាអំណាចទេ ។

**ឃ.រដ្ឋធម្មនុញ្ញពិត** (Real Constitution) : រដ្ឋធម្មនុញ្ញពិតនៅក្នុងអត្ថន័យជាសំភារៈ ឬក៏ជាទំរង់វាជាប្រព័ន្ធកំណត់មួយនៃបទដ្ឋានកិច្ចគតិយុត្តិទាំងឡាយ ដែលធ្វើនិយ័តកម្មទៅគ្រប់ទំនាក់ទំនងសាធារណៈដែរ ប៉ុន្តែរដ្ឋធម្មនុញ្ញរបៀបនេះ បទដ្ឋានរបស់វាត្រូវធ្វើសមិទ្ធិពិតនៅក្នុងសង្គមរបស់ពួកគេនៃសម័យកាលណាមួយ ។ មានន័យថារដ្ឋធម្មនុញ្ញបានចារិកនូវបទដ្ឋាននោះហើយ ហើយក្នុងសកម្មភាពជាក់ស្តែងវាកើតមានដូចអ្វីៗដែលបានចារិកក្នុងរដ្ឋធម្មនុញ្ញ ។ ជា**ឧទាហរណ៍** ច្បាប់រដ្ឋធម្មនុញ្ញប្រទេសឆេកូស្លូវ៉ាគី នៅឆ្នាំ ១៩៦៨ បានពិនិត្យ និងបង្កើតនូវប្រព័ន្ធ**តុលាការធម្មនុញ្ញ** ប៉ុន្តែក្នុងករណីប្រតិបត្តិជាក់ស្តែងនោះ រហូតដល់បដិវត្តន៍ប្រឆាំងការិយាល័យនិយមបានជ័យជំនះឆ្នាំ ១៩៨៩ **តុលាការទាំងនោះពុំត្រូវបានបង្កើតទេ** ។ ត្រង់នេះបញ្ជាក់ថារដ្ឋធម្មនុញ្ញមានលក្ខណៈជា**គតិយុត្តិ ឬជាអង្គច្បាប់** ព្រោះប័ទដ្ឋានទាំងនេះ**កើតមានមែន** ប៉ុន្តែហេតុការណ៍ជាក់ស្តែងដែលលេចចេញពីបទដ្ឋានទាំងនោះពុំមានវត្តមានទេ ត្រង់នេះបញ្ជាក់ថា**រដ្ឋធម្មនុញ្ញពុំមានលក្ខណៈពិត ឬអង្គហេតុទេ**។ មានលក្ខណៈប្រហែលនេះប្រទេស**អ៊ីតាលី** ឆ្នាំ ១៩៤៧ រហូតដល់បច្ចុប្បន្នបទដ្ឋានមួយចំនួន ពុំមានដំណើរការណ៍ ដូចជាមាត្រាទី ៤០ (ការធ្វើនិយ័តកម្មនៃសិទ្ធិចំពោះកូដកម្ម) និងមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ដូចជាមាត្រាទី ១៤៧ .......។ល។ យើងអាចនិយាយថារដ្ឋធម្មនុញ្ញគតិយុត្តិជារដ្ឋធម្មនុញ្ញស្លាប់ ព្រោះបទដ្ឋានមួយចំនួនមិនអាចដំណើរការណ៍បាន ឯរដ្ឋធម្មនុញ្ញពិតជារដ្ឋធម្មនុញ្ញរស់ ព្រោះបទដ្ឋានទាំងអស់ ឬភាគច្រើន របស់វាមានសកម្មភាព ។

ភាពខុសគ្នារវាងរដ្ឋធម្មនុញ្ញនុញ្ញគតិយុត្តិ និងរដ្ឋធម្មនុញ្ញពិត (ហេតុការណ៍ពិត) ជាធម្មតាវាជាលទ្ធផល**នៃការផ្លាស់ប្តូរ**ក្នុងទំនាក់ទំនងនៃកំលាំងនយោបាយ ដែលកើតមានបន្ទាប់ពីការអនុម័តរដ្ឋធម្មនុញ្ញមានលក្ខណៈជាគតិយុត្តិនោះ ដូចនេះគេហៅថាជា**រដ្ឋធម្មនុញ្ញគតិយុត្តិទំរង់** ព្រោះពេលដែលអនុម័តវា គឺ**វាមានលក្ខណៈតែម្តងគត់** ហើយពុំធ្វើច្រើនដងនោះទេ ។ នេះគឺបញ្ជាក់តាមច្បាប់ធម្មនុញ្ញប្រទេសឆេកូ ការអនុម័តវាក្នុងពេលដែលប្រទេសទាំងមូលស្ថិតក្រោមការអន្តរាគមន៍ពីកងទ័ពសូវៀត អញ្ចឹងហើយបានជារង្វង់បទដ្ឋានលទ្ធិប្រជាធិបតេយ្យ ពុំបាន**ចារិកក្នុងអត្ថន័យច្បាប់**

នោះទេ រីក៏ប្រហែលជាគ្មានលទ្ធភាពធ្វើសមិទ្ធិលើច្បាប់នោះ ។ ភាពខុសគ្នាមួយទៀតត្រង់ថា ផ្នែកមួយនៃបទដ្ឋានរដ្ឋធម្មនុញ្ញគតិយុត្តិបានក្លាយទៅជាលក្ខណៈប្រឌិត (Fictitious) សំរាប់សង្គមយ៉ាងពិតប្រាកដ ។ ភាពចាំបាច់ពិសេសមួយទៀត បានលេចឡើងនូវរដ្ឋធម្មនុញ្ញគតិយុត្តិស្របនឹងទំនាក់ទំនងហេតុការណ៍សង្គមពិតៗ ឬក៏ផ្ទុយទៅវិញទំនាក់ទំនងទាំងនេះបង្កើតនូវភាពអាស្រ័យនឹងអធិបញ្ញា (Injunction) ទាំងឡាយនៃរដ្ឋធម្មនុញ្ញគតិយុត្តិ ។ ដូចនេះ ដោយការតាមដានទៅលើភាពខុសគ្នារវាងរដ្ឋធម្មនុញ្ញហេតុការណ៍ និងរដ្ឋធម្មនុញ្ញគតិយុត្តិ គឺត្រូវបានប្រគល់ទៅឱ្យ**យុត្តិធម៌ធម្មនុញ្ញដើរតួជាអ្នកធ្វើការវិនិច្ឆ័យវា** ។

ភាពប្រឌិតនៃរដ្ឋធម្មនុញ្ញ វាកើតមានសំរាប់ប្រទេសដែលគ្មានលក្ខណៈប្រជាធិបតេយ្យ ឬក៏អ្នកមានអំណាចរដ្ឋពុំអើពើ ។ រដ្ឋធម្មនុញ្ញគតិយុត្តិច្រើនកើតមានចំពោះប្រទេសទាំងនោះ ភាគច្រើនផ្ទុកនូវបញ្ញត្តិប្រជាធិបតេយ្យ ប៉ុន្តែពុំដែលបានធ្វើសមិទ្ធិទេ ។ ដោយសារមូលហេតុជាច្រើននៃប្រទេសទាំងនេះមានប្រភពចេញមកពីលក្ខណៈអប្រជាធិបតេយ្យ ហើយដើម្បីលើកទឹកចិត្តប្រជាជនរបស់ខ្លួននោះ គេបង្កើតរដ្ឋធម្មនុញ្ញឱ្យមានភាពល្អក្នុងគោលដៅ ដើម្បីបិទបាំងនូវរបបនយោបាយរបស់ខ្លួន ឬក៏ភាពអយុត្តិធម៌របស់អ្នកដឹកនាំរដ្ឋ ។

ជាទូទៅ គេអាចសង្កេតឃើញនូវភាពខុសគ្នាមួយចំនួន ទាក់ទិននិងកំលាំងគតិយុត្តិនៃរដ្ឋធម្មនុញ្ញនោះគឺ :

### ៦. កំលាំងគតិយុត្តិខ្ពស់នៃរដ្ឋធម្មនុញ្ញក្នុងអត្ថន័យគតិយុត្តិ-ទំរង់[10]

កំលាំងគតិយុត្តិនៃរដ្ឋធម្មនុញ្ញជាទំរង់មាន :

- **ទីមួយ** : បទដ្ឋានទាំងឡាយនៃរដ្ឋធម្មនុញ្ញ មានឥទ្ធិពលលើលំដាប់ថ្នាក់ទាំងឡាយនៃច្បាប់ផ្សេងៗ រួមទាំងកិច្ចទាំងឡាយនៃអំណាចនីតិប្រតិបត្តិផងដែរ ។

[10]. អត្ថន័យនៃរដ្ឋធម្មនុញ្ញ ភាគច្រើនគេសិក្សាលើលក្ខណៈគតិយុត្តិ-ទំរង់ ឬគតិយុត្តិ-សំភារៈ ប៉ុន្តែក៏មានសៀវភៅខ្លះគេអាចបកស្រាយនូវអត្ថន័យ នៃរដ្ឋធម្មនុញ្ញជាលក្ខណៈអង្គហេតុ-ទំរង់ ឬអង្គហេតុ-សំភារៈដែរ ។

- **ទីពីរ** : ច្បាប់ ឬឋានានុក្រមច្បាប់ ត្រូវតែអនុម័តដោយអង្គការទាំងឡាយ ដែលត្រូវបានកំណត់ ឬចារឹកក្នុងរដ្ឋធម្មនុញ្ញ និងធ្វើតាមការកំណត់នៃនីតិវិធីរបស់រដ្ឋធម្មនុញ្ញ ។

**ច. កំលាំងគតិយុត្តិខ្ពស់នៃរដ្ឋធម្មនុញ្ញក្នុងអត្ថន័យជាគតិយុត្តិ -សំភារៈ**

- បទដ្ឋានគតិយុត្តិទាំងឡាយត្រូវតែធ្វើឡើងតាមក៏រិត និងអាស្រ័យគ្នាជាអាទិភាព (គ្រប់ករណីពុំមានបដិមតិគ្នា) នៃបទដ្ឋានរបស់ច្បាប់គ្រឹះ (រដ្ឋធម្មនុញ្ញ) មានន័យថា កិច្ចទាំងឡាយដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬក៏តាមអាទិភាពណាមួយ ឬក៏តាមទំរង់ណាមួយត្រូវចាត់ទុកជាមោឃៈ **មាត្រា ១៥០** នៃរដ្ឋធម្មនុញ្ញកម្ពុជា "រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ និងសេចក្ដីសំរេចទាំងឡាយរបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត" ។

## ២. ខ្លឹមសារសង្គម-នយោបាយនៃរដ្ឋធម្មនុញ្ញ

ខ្លឹមសារនយោបាយនៃរដ្ឋធម្មនុញ្ញ វាជាការកំនត់មួយអំពីរដ្ឋធម្មនុញ្ញដែលជាច្បាប់គ្រឹះ ហើយដែលមានកំលាំងគតិយុត្តិខ្លាំងជាងច្បាប់នានាក្នុងប្រទេស ។ ផ្ទុយទៅវិញខ្លឹមសារសង្គម-នយោបាយរបស់វាគឺជាកិច្ចព្រមព្រៀងសហសម្ព័ន្ធមួយ (Correlation) **នៃគ្រប់កំលាំងនយោបាយដែលមានក្នុងប្រទេស** ។ កិច្ចព្រមព្រៀងរបៀបនេះ មានតាំងពីពេលអនុម័តវាជាលើកដំបូងមក ប៉ុន្តែកិច្ចព្រមព្រៀងនោះពុំមាន**អត្ថន័យគតិយុត្តិ**ទេ តែវាជាការ**ស្រុះស្រួលគ្នានៃផលប្រយោជន៍ភាគីនយោបាយគ្រប់ស្រទាប់សង្គមសាធារណៈ** ។ ស្រទាប់សង្គមសាធារណៈទាំងនេះមានដូចជា : វណ្ណៈសង្គម (អ្នកក្រ, អ្នកមាន, អ្នកធំ, អ្នកតូច), ស្រទាប់សង្គម (សង្គមនយោបាយ ឬសង្គមពលរដ្ឋ), សហគមន៍ទឹកដី, សហគមន៍ជនជាតិ ឬសហគមន៍សាសនាផ្សេងៗទៀត ។ល។ សហគមន៍ទាំងអស់នេះឯងដែលការពារនៅក្នុងការតស៊ូនយោបាយ ទៅលើផលប្រយោជន៍សង្គមរបស់ពួកគេ និងជាការក៏រិតមួយដែលនៅក្នុងនោះរាល់ដំណោះស្រាយផ្សេងៗ អាចសំរេចបានដោយមានការស្រុះស្រួលគ្នា ទុកចិត្តគ្នា ហើយ**រាល់គំនិតទាំងនេះត្រូវបានចារឹកក្នុងរដ្ឋធម្មនុញ្ញ** ។ ត្រង់នេះបញ្ជាក់យ៉ាងច្បាស់ថា **បើគ្មានការយល់ព្រមមួយនៅក្នុងសង្គមទេនោះក៏គ្មានវត្តមានដែរ នូវសណ្ដាប់ធ្នាប់គតិយុត្តិណាមួយនោះ** ។ ជាឧទាហរណ៍ លើគោលការណ៍នៃខ្លឹមសារនេះសំរាប់ប្រទេសកាន់

របបផ្តាច់ការ ដែលមានបក្សតែមួយសំរាប់កាន់តំណែងនោះ ដែលគេហៅថាជាប្រទេសដែលមានបក្សនយោបាយ**ឯកធិភាព** (Monopoly ផ្តាច់មុខ) ដែលប្រទេសទាំងនេះពុំយកចិត្តទុកដាក់ទៅលើខ្លឹមសារនៃរដ្ឋធម្មនុញ្ញរបៀបនេះទេ ប៉ុន្តែគេយកវិស័យសេដ្ឋកិច្ចសំរាប់ទប់ស្កាត់លើរបបពហុបក្សវិញ ។ មានន័យថា រាល់មតិយោបល់សង្គមពុំត្រូវបានចារឹកក្នុងរដ្ឋធម្មនុញ្ញ ដោយគោលការណ៍ស្រុះស្រួលគ្នានោះទេ ។ ជាឧទាហរណ៍មួយទៀតរដ្ឋធម្មនុញ្ញចក្រភពអង់គ្លេស ដែលបានបង្ហាញនៅក្នុងពេល**បដិវត្តន៍អង់គ្លេស** ស.វ XVII អំពីការស្រុះស្រួលគ្នា (Compromise) **រវាងអភិជនម្ចាស់ដី**និង**គហបតីឧស្សាហកម្ម** ដែលក្រុមទាំងពីរនេះ បានសំដែងចេញនូវគោលការណ៍បង្កើតសភាជាន់ខ្ពស់ (House of Lords) ឬសភាតំណាងឱ្យពួកអ្នកមានវណ្ណៈខ្ពស់ និងការជ្រើសរើសសភាជាន់ទាបឬសភាសហគមន៍ ឬសភាតំណាងរាស្ត្រ (House of Commons) ។ ប៉ុន្តែក្រោយមកមានការចុះខ្សោយជាលំដាប់នៃអំណាចសភាជាន់ខ្ពស់ ដែលជាសភាតំណាងត្រកូលអភិជននោះ ទាំងនេះសឱ្យឃើញថាមានការផ្លាស់ប្តូរ**សហព័ន្ធកំលាំង** រវាងវណ្ណៈតាំងពីក្នុងស្រទាប់សង្គម ។ ហើយរហូតដល់ពាក់កណ្តាល ស.វទី XX ទើបគេអាចរកភាពស្រុះស្រួលគ្នាបានក្នុងរដ្ឋសភា ដែលធ្វើឱ្យមានការផ្លាស់ប្តូរនូវច្បាប់កំពូលរបស់គេ ។

## ៣. មុខងារសង្គមនយោបាយនៃរដ្ឋធម្មនុញ្ញ

មុខងារសង្គមនៃរដ្ឋធម្មនុញ្ញវាជាការកំនត់នូវវាសនាសង្គម និងមធ្យោបាយទាំងឡាយនៃការធ្វើសមិទ្ធិទៅលើមុខងាររបស់វា ។ ជាទូទៅរដ្ឋធម្មនុញ្ញបានកំណត់នូវមុខងារធំៗ ចំនួនបីដូចខាងក្រោម :

**ក.មុខងារគតិយុត្តិនៃរដ្ឋធម្មនុញ្ញ** (Juridical Function) : គឺជាមុខងារដែលគេចាត់ទុករដ្ឋធម្មនុញ្ញគឺជាច្បាប់ ឬច្បាប់គ្រឹះ នៃច្បាប់ទាំងពួង ។ គឺថារដ្ឋធម្មនុញ្ញជាប្រភពដ៏ចំបងនៃច្បាប់របស់ប្រទេស ឋិតនៅគ្របដណ្តប់លើមូលដ្ឋានគ្រឹះមួយនៃគ្រប់ប្រព័ន្ធនិយ័តកម្មគតិយុត្តិ ក្នុងទំនាក់ទំនងសាធារណៈនៃប្រទេសនីមួយៗ ។

**ខ.មុខងារនយោបាយនៃរដ្ឋធម្មនុញ្ញ** (Political Function) ៖ គឺជាមុខងារដែលរដ្ឋធម្មនុញ្ញកំណត់នូវរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ, ទំនាក់ទំនងរបស់រចនាសម្ព័ន្ធគ្រប់គ្រង ជាមួយមនុស្សដោយឡែកៗ និងក្រុមមនុស្សទាំងពួង ហើយវាធ្វើសេវាកម្មឱ្យមូលដ្ឋានគ្រឹះគតិយុត្តិនៃប្រព័ន្ធនយោបាយ ។ គ្រប់កំលាំងនយោបាយវាជាបក្ស និងចលនាផ្សេងៗទៀត ដែលមានសកម្មភាពអញ្ជមញ្ជ្រវាងគ្នានឹងគ្នា ប្រឡងប្រណាំង តស៊ូ ប្រើប្រាស់នូវអំណាចរដ្ឋ ដោយឈរលើមូលដ្ឋានគ្រឹះមួយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ។ នេះជាមុខងារដែលរដ្ឋធម្មនុញ្ញកំណត់សកម្មភាពអំណាចរដ្ឋ និងប្រភពអំណាចរដ្ឋ។

**គ.មុខងារមនោគមវិជ្ជានៃរដ្ឋធម្មនុញ្ញ** ៖ មុខងារមនោគមន៍វិជ្ជា (Ideological Function) ឬក៏អាចនិយាយថាជាមុខងារអប់រំ ។ មុខងារនេះរដ្ឋធម្មនុញ្ញវាដូចជាច្បាប់ដែលមានអំណាចខ្លាំង បើប្រៀបទៅនឹងតំលៃនៃច្បាប់ផ្សេងៗទៀតនៅក្នុងសង្គម ព្រោះវាបានកំនត់នូវគោលការណ៍គ្រឹះមួយចំនួនដូចជា ៖ សិទ្ធិមនុស្ស, កម្មសិទ្ធិ, លទ្ធិប្រជាធិតេយ្យ, គ្រួសារ ។ល។ ដែលគោលការណ៍ទាំងនេះត្រូវបានរដ្ឋធម្មនុញ្ញផ្សព្វផ្សាយទៅដល់មនុស្សគ្រប់ស្រទាប់នៃសង្គម ។ តំលៃរបស់មនុស្សត្រូវបានគោរព ហើយត្រូវចារឹកក្នុងច្បាប់គ្រឹះនេះទៀតផង រីឯតំលៃមួយទៀតនោះ គឺថាបើអ្នកណាគោរពច្បាប់ អ្នកនោះមានតំលៃជាមនុស្សលោក តែបើអ្នកណាបំពានច្បាប់អ្នកនោះនឹងទទួលទណ្ឌកម្ម ។ នេះជាមុខងារផ្តល់ចំណេះដឹងដល់សមាជិករបស់ប្រទេសនីមួយៗ ក្នុងគោលបំណងអប់រំមនុស្សឱ្យទទួលស្គាល់នូវតំលៃមនុស្ស ។

## ៤. កម្មវត្ថុនៃនិយ័តកម្មធម្មនុញ្ញគតិយុត្តិ

ទីតាំងនៃរាល់ការធ្វើនិយ័តកម្មធម្មនុញ្ញទៅលើទំនាក់ទំនងសង្គម ត្រូវបានចារឹកយ៉ាងច្បាស់លាស់ដោយរដ្ឋធម្មនុញ្ញ ។ ខ្លឹមសារដែលជាមូលដ្ឋានគ្រឹះសំខាន់ៗ ហើយត្រូវបានរដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសមួយចំនួនចារឹក និងធ្វើឱ្យទៀងទាត់ចំពោះទំនាក់ទំនងទាំងនោះ មានខ្លឹមសារបីជាសំខាន់គឺ ៖ **ការកំនត់ទៅលើទីតាំងនៃសិទ្ធិមនុស្ស និងពលរដ្ឋ, ការកំនត់នូវរចនាសម្ព័ន្ធនៃអង្គការគ្រប់គ្រងអំណាចរដ្ឋ និងការកំនត់ទៅលើរចនាសម្ព័ន្ធគ្រប់គ្រងដែនដីរបស់រដ្ឋ ។**

**ក.ការកំនត់សិទ្ធិនានាទៅលើមនុស្សក្នុងសង្គម :** ក្នុងទីតាំងនេះរដ្ឋធម្មនុញ្ញកំណត់នូវ**សិទ្ធិ.សេរីភាពរបស់មនុស្ស** និង**ពលរដ្ឋ** ហើយជាពិសេស ជាទូទៅរដ្ឋធម្មនុញ្ញធានាការពារ**មនុស្ស**ពីអំពើទំនើងចិត្តរបស់រដ្ឋ ។ កំលាំងគតិយុត្តិខ្ពស់បំផុតរបស់វាគឺបានទទួលស្គាល់ និងការពារវាល់សិទ្ធិ និងកាតព្វកិច្ចដែលបានប្រកាស អំពីវិធីទាំងឡាយនៃការបង្កើតច្បាប់ធម្មតា និងបទដ្ឋានកិច្ចផ្សេងៗត្រូវតែស្របនឹងច្បាប់គ្រឹះ ហើយអ្នកដែលមានសិទ្ធិអនុម័តបទដ្ឋានទាំងនោះត្រូវតែកំនត់ក្នុងច្បាប់។ តាមខ្លឹមសារនៃជំហានទីមួយនេះ យើងអាចសង្កេតនៅក្នុងបញ្ញត្តិនៃ**មាត្រា ៣១** នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ ថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស, សិទ្ធិនារី, សិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន វីស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តិតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់" ។ ក្រៅពីនេះ គេអាចសង្កេតឃើញចាប់ពីមាត្រា ៣២ រហូតដល់ ៥០ នៃរដ្ឋធម្មនុញ្ញនេះបានកំនត់អំពីសិទ្ធិមនុស្ស។

**ខ.ការកំនត់អង្គការគ្រប់គ្រងរដ្ឋ** : រដ្ឋធម្មនុញ្ញកំណត់នូវសកម្មភាពនានា ទៅលើ**អង្គការគ្រប់គ្រងនៃអំណាចជាន់ខ្ពស់របស់រដ្ឋ** ។ អង្គការគ្រប់គ្រងមួយ ដែលបានបង្កើតឡើងនៅលើគោលការណ៍អធិបតេយ្យជាតិ ត្រូវបានអំពាវនាវឱ្យធ្វើសមិទ្ធិពីគោលការណ៍ទាំងឡាយ នៃតំណាងដឹកនាំ និង**ការបែងចែកអំណាច** ។ ក្នុងប្លុកនេះ មានគោលការណ៍មួយចំនួនដូចខាងក្រោម :

**ខ១. គោលការណ៍ដឹកនាំគ្រប់គ្រង** : វាជាគោលការណ៍គ្រឹះមួយ នៃអំណាចដែលមានលក្ខណៈជាតិទាំងមូល ហើយចាត់ទុកប្រជារាស្ត្រជាប្រភពនៃអំណាច ។ អំណាចទាំងនោះត្រូវជ្រើសតាំងដោយប្រជាជន ហើយសំដែងចេញ និងបង្កើតនូវទំរង់ឆន្ទៈរបស់ប្រជាជន ដូច**មាត្រា ៧៦**

រដ្ឋធម្មនុញ្ញកម្ពុជាចែងថា "រដ្ឋសភា មានសមាជិកដែលជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។ តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល, ដោយសេរី, ដោយស្មើភាព, ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសំងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

អង្គការរៀបចំការបោះឆ្នោតបែបបទ និងការប្រព្រឹត្តិទៅនៃការបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត" ។ និង **មាត្រាទី ៩០** "រដ្ឋសភា ជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ។ ហើយបំពេញភារៈកិច្ចរបស់ខ្លួនដូចបានកំនត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើតកែប្រែ រឺក៏លុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ ស្ដីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ ស្ដីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តិទៅដោយមតិភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភា បោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល" ។ និង **មាត្រា ៩៩** បានចែងអំពីព្រឹទ្ធសភា ថា "ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើន ស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ ។

សមាជិកព្រឹទ្ធសភា អាចត្រូវបានចាត់តាំង និងជ្រើសតាំងសារជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ៤០ ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត" ។

**៩.២. គោលការណ៍បែងចែកអំណាច** : រដ្ឋធម្មនុញ្ញបានកំណត់ទៅលើការបែងចែកយ៉ាងច្បាស់លាស់ ដាច់ពីគ្នានូវអំណាចនីតិបញ្ញត្តិ, នីតិប្រតិបត្តិ, និងអំណាចតុលាការ ហើយនឹងបំពេញនាទីដោយអង្គការរដ្ឋផ្សេង១គ្នា ដើម្បីជាតុល្យភាពទៅវិញទៅមក ដោយជៀសវាងនូវការបំពានដោយគ្មានព្រំដែន ។ ដូចមាត្រា ៥១ រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានបញ្ជាក់ថា "......អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។**មាត្រា ១១៨** បានកំនត់អំពីអង្គការនៃអំណាចនីតិប្រតិបត្តិ ហើយដែលបានបញ្ញត្តិថា "គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក" ។ ចំពោះអំណាចតុលាការត្រូវបានកំណត់ក្នុង**មាត្រា ១២៨** ចែងថា "អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការធានារក្សាអនាគត និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់" ។ **មាត្រា ១៣០** "គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ រឺនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ" ។ និងការកំនត់អំណាចនីតិបញ្ញត្តិ ដូចមាត្រា ៩០ កំនត់អំពីសភាតំណាងរាស្ត្រ និងមាត្រា ៩៩ កំនត់អំពីព្រឹទ្ធសភា ។

ឬកនេះជាទីតាំងមួយនៃរដ្ឋធម្មនុញ្ញ ដែលបទដ្ឋានរបស់វាបានកំណត់យ៉ាងច្បាស់លាស់ នូវគោលការណ៍គ្រឹះទាំងឡាយ នៃការបង្កើតទំរង់អំណាចផ្សេងៗរបស់រដ្ឋ. សមត្ថកិច្ច និងទំនាក់ទំនងអន្តរមន្ត្រីរវាងសមត្ថកិច្ចទាំងនោះ ។ **មាត្រា ៩៤** បញ្ជាក់ថា "រដ្ឋសភា បង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋសភា នឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា"។ **មាត្រា ៩៧** "គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន"។ **មាត្រា ៩៨** "រដ្ឋសភាអាចទំលាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទំលាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញ្ញត្តិបន្ទោស តាមសំលេងឆ្នោតពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកយកមកពិភាក្សាបាន"។ ទីតាំងដ៏ចាំបាច់ក្នុងគោលការណ៍នៃការបែងចែកអំណាចនេះ គេអាចកំណត់នូវបញ្ហាមួយចំនួនដូចខាងក្រោម ដែលជាវិធានការធ្វើឱ្យមានសកម្មភាពទៀងទាត់ក្នុងការគ្រប់គ្រងទៅលើអំណាចនីមួយៗ ដូចជា :

**៩.១. ការកំណត់គោលការណ៍ទាំងឡាយ នៃកិច្ចការនយោបាយក្រៅប្រទេសរបស់រដ្ឋ :** នេះជាវិធានការ ដែលធ្វើឱ្យអំណាចរដ្ឋធ្វើសកម្មភាពស្របតាមការកំណត់ និងពុំបានបំពានទៅលើលក្ខណៈណាដែលជាអំពើទំនើងចិត្ត នៃរាល់កិច្ចការរបស់រដ្ឋចំពោះសកម្មភាពក្រៅប្រទេស ។ ដូចជា **មាត្រា ៥៣** នៃរដ្ឋធម្មនុញ្ញកម្ពុជា កំនត់ថា "ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹត្យអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជា រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក ។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹត្យភាពរបស់ខ្លួនឡើយ ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតិឱ្យមានមូលដ្ឋានយោធាបរទេសនៅលើដែនដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជាសំភារៈ យោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកំលាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀតដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស" ។

**ខ២.២. និយ័តកម្មនៃបទបញ្ញត្តិទាំងឡាយដែលទាក់ទិននឹងការប្រកាសសង្គ្រាម និងការចុះបាត្តលេខាសន្តិភាព** : នេះជាការកំនត់អំពីសណ្តាប់ធ្នាប់នៃសន្តិសុខរបស់ជាតិទាំងមូល នៅពេលមានបញ្ហាចំពោះមុខដែលត្រូវដោះស្រាយ ។ លក្ខណៈនេះយើងអាចសង្កេតឃើញរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ កំណត់តាម**មាត្រា ២៤** ថា "ព្រះមហាក្សត្រ ទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រ ទ្រង់ប្រកាសសង្គ្រាមក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា" ។ និង **មាត្រា ២២** បញ្ជាក់ថា "នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា " ។

**ខ២.៣. និយ័តកម្មលើកិច្ចការអន្តរាគមន៍ផ្ទៃក្នុងរបស់រដ្ឋ និងអន្តរជាតិ** : នេះជាការកំនត់សមត្ថកិច្ចនានា ទៅលើអ្នកមានអំណាចរដ្ឋក្នុងការអនុវត្តសំរាប់រដ្ឋរបស់ខ្លួន ទាំងផ្ទៃក្នុង និងក្រៅប្រទេស ។ ដូចជា**មាត្រា ៥៥** "សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អាព្យាក្រឹត្យភាព និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល" ។ និង**មាត្រា ២០** "ព្រះមហាក្សត្រ ទ្រង់ទទួលសវនាការជាផ្លូវការពីរដងក្នុងមួយ

ខែឱ្យនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីចូលគាល់រាយការណ៍ទូលថ្វាយទ្រង់ជ្រាប អំពីសភាពការណ៍នៃប្រទេសជាតិ"។ និង**មាត្រា ២១** "តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព ។

តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬក៏ដកចៅក្រមផ្នែកយុត្តាធិកា "។

**ខ២.៤. ការកំណត់នូវសិទ្ធិអំណាចនៃអង្គការរដ្ឋ ក្នុងការចុះហត្ថលេខាលើសច្ចានុម័ត** (Ratification) **និងអប្បបិបត្តិកម្ម** (Denounciation) **នៃកិច្ចព្រមព្រៀងអន្តរជាតិ :** ដូចជា **មាត្រា ២៥** "ព្រះមហាក្សត្រទ្រង់ទទួលសារតាមឯកអគ្គរដ្ឋទូត ឬក៏ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅមកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា"។និង**មាត្រា ២៦** "ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា "។

**ខ២.៥. ការកំណត់លើវិធានទាំងឡាយ ដែលស្តីពីសហប្រតិបត្តិការក្នុងវិស័យការពារសិទ្ធិមនុស្ស ( សញ្ជាតិ) សិទ្ធិនិងសេរីភាពមនុស្ស បត្យាប័ននិងសិទ្ធិជ្រកកោន :** ដូចជា**មាត្រា ៣៣** "ប្រជាពលរដ្ឋខ្មែរមិនត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវបានកំណត់ក្នុងច្បាប់"។និង**មាត្រា ៤៥** "ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវលុបបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយប្រពន្ធមួយ"។ និង **មាត្រា ៤១** "ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ, ដល់ទំនាមទំលាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និង ដល់សន្តិសុខជាតិបានឡើយ ។

របបសារពត៌មានត្រូវរៀបចំឡើងដោយច្បាប់"។ ក្នុងរដ្ឋធម្មនុញ្ញខ្លះទៀត កំណត់នូវក្រុមប្រឹក្សាសង្គម និងសេដ្ឋកិច្ច ដូចជារដ្ឋធម្មនុញ្ញបារាំងឆ្នាំ ១៩៥៨ ជំពូក X និងជំពូក V រីឯរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ បានបញ្ជាក់តាម **មាត្រា ៥៦** ថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ និងមានកំនត់ក្នុងច្បាប់"។ និង **មាត្រា ៦១** "រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាល ដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូនបច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន"។ និងមាត្រាមួយចំនួនទៀត ដែលបានកំណត់អំពីវិស័យនេះ ។

សរុបទៅ ថ្វីត្បិតតែបទដ្ឋានធម្មនុញ្ញប្រទេសខ្លះដែលពុំមានលក្ខណៈគ្រប់គ្រាន់ ក្នុងការធ្វើនិយ័តកម្មលើវិស័យផ្សេងៗក៏ពិតមែន (ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍) ប៉ុន្តែសំរាប់ប្រទេសជឿនលឿនបទដ្ឋាននៃរដ្ឋធម្មនុញ្ញរបស់ពួកគេ ត្រូវបានចារឹកយ៉ាងច្បាស់លាស់ក្នុងការធ្វើនិយ័តកម្មលើគ្រប់វិស័យផ្សេងៗនៃទំនាក់ទំនងសង្គម ដើម្បីងាយស្រួលអនុវត្តឱ្យមានប្រសិទ្ធិភាពក្នុងការជាក់ស្ដែង ។

មួយវិញទៀត រដ្ឋធម្មនុញ្ញនៃប្រទេសខ្លះច្រើនមានឥទ្ធិពលលើប្រទេសផ្សេងៗ ដែលជាអតីតអាណាព្យាបាលរបស់ខ្លួន រឺក៏ជាប្រទេសមហាអំណាចខ្លះដែលបានដាក់អាណានិគមន៍ ឬក៏ផ្សេងៗពីនេះទៀតនោះ រដ្ឋធម្មនុញ្ញវាមាននិន្នាការទៅវិញទៅមកដោយឈរលើបទពិសោធន៍នៃប្រទេសផ្សេងៗទាំងនោះ ។

**ធ.ការកំនត់លើរចនាសម្ព័ន្ធគ្រប់គ្រងដែនដី** : ប្រទេសនានាក្នុងលោកមានការកើតឡើងខុសៗគ្នា តាមរចនាសម្ព័ន្ធរបស់រដ្ឋដូចជា : រដ្ឋទោល រដ្ឋសហព័ន្ធ ឬសមាគតរដ្ឋ ។ នៅក្នុងរដ្ឋធម្មនុញ្ញនីមួយៗ បទដ្ឋានរបស់វាតែងកំណត់នូវរចនាសម្ព័ន្ធរបស់រដ្ឋ ក្នុងការគ្រប់គ្រងដោយខ្លួនឯង ដូចជា : ប្រភេទនានានៃរចនាសម្ព័ន្ធទឹកដី, ទំនាក់ទំនងទាំងឡាយរវាងអំណាចកណ្ដាល និងមូលដ្ឋាន ។ ដូចជា **មាត្រា ១** កំណត់ថា "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិ តាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ "។ និង **មាត្រា ២** "បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួនដែលបានកំណត់ ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះ ឆ្នាំ ១៩៦៣-១៩៦៩"។ និង **មាត្រា ៣** "ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន"។ និង **មាត្រា ១៤៥** "ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និងក្រុង ។

ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់ "។ និង **មាត្រា ១៤៦** "ខេត្ត ក្រុង ស្រុក ខណ្ឌ័ ឃុំ និងសង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខណ្ឌ័ដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ"។ នេះគឺជាប្លុកដែលកំណត់រចនាសម្ព័ន្ធដែនដី ( រដ្ឋឯកភូត, រដ្ឋសហព័ន្ធ ឬសមាគតរដ្ឋ) ។

## ៥. សុពលភាពនៃរដ្ឋធម្មនុញ្ញ

ជានិច្ចកាល រដ្ឋធម្មនុញ្ញចាប់ផ្ដើមធ្វើសកម្មភាពតាំងតែពីពេលដែលគេបានបញ្ជាក់ក្នុងបញ្ញត្តិពិសេសណាមួយ ឬក៏ក្នុងពេលណាមួយដែលគេបានអនុម័តដោយឡែក ។ ចំពោះអន្តរបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ជាទូទៅវាច្រើនផ្ដើមប្រព្រឹត្តដោយបទដ្ឋានដោយឡែកៗ ដែលបទដ្ឋានទាំងនោះផ្ដើមប្រព្រឹត្តទៅនៅពេលយូរបន្តិច គឺមានន័យថាអាចចាប់ផ្ដើមតាមការចូលមកដល់ នៃព្រឹត្តការណ៍ណា

មួយ (ដូចជាជំរើសផ្សេងៗ............)។ តាម**មាត្រា ១៥៤** នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "រដ្ឋធម្មនុញ្ញនេះក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឱ្យចូលជាធរមានដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា"។

ម្យ៉ាងទៀតរដ្ឋធម្មនុញ្ញចូលជាធរមាន ជាផ្លូវច្បាប់ ចាប់ផ្តើមសកម្មភាពក្នុងល័ក្ខខណ្ឌនៃទឹកដីរបស់ខ្លួន និងវាមានកាតព្វកិច្ចពិសេសសំរាប់គ្រប់អង្គការរដ្ឋ, បុគ្គល, ក្រសួង, ស្ថាប័ននានាដែលនៅក្រៅប្រទេសទៀតផង ។ រដ្ឋបរទេសនានា និងអង្គការរដ្ឋាភិបាលអន្តរជាតិនានា ត្រូវតែគោពរដ្ឋធម្មនុញ្ញ លើកលែងតែបទដ្ឋាននៃរដ្ឋធម្មនុញ្ញដែលផ្ទុយនឹងគោលការណ៍នៃច្បាប់អន្តរជាតិ ដូចជាការដោះស្រាយនានាត្រូវតែប្រើប្រាស់សង្គ្រាម ដើម្បីកាន់កាប់, រំលោភសិទ្ធិមនុស្ស ។ល។ និងការបំពានផ្សេងៗទៀតជាដើម ។ ប៉ុន្តែទោះបីជារដ្ឋធម្មនុញ្ញទាំងមូលបានចូលជាធរមានហើយក៏ដោយ តែមាត្រាខ្លះ ឬបទបញ្ញត្តិខ្លះដែលបានចែងក្នុងច្បាប់គ្រឹះនោះ ចាំបាច់ត្រូវមានបទដ្ឋានណាមួយយោងសំរាប់ប្រើប្រាស់វា ។

ឧទាហរណ៍ ដូចជា**មាត្រា ២៧** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ កំណត់ថា "ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស"។ និង**មាត្រា ១២៧** រដ្ឋធម្មនុញ្ញ កម្ពុជាដែលបង្ហាញថា "ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នឹងត្រូវកំណត់ក្នុងច្បាប់មួយ "។

ដូច្នេះមាត្រានេះអាចមានសកម្មភាពបាន លុះត្រាតែមានច្បាប់មួយកំណត់វា ។ ទោះបីមាត្រាទាំងនេះចូលជាធរមានហើយក៏ដោយ ពុំអាច**អនុវត្តដោយផ្ទាល់**បានទេនៅក្នុងទំនាក់ទំនងសង្គមពិតៗនោះ ។

## គំនូសបំព្រួញលើអត្ថន័យនៃរដ្ឋធម្មនុញ្ញ (រូបទី ២)




*** សំគាល់ :**

ជាធម្មតារដ្ឋធម្មនុញ្ញដែលបង្កើតមកអ្នកនីតិករ ឬអ្នកទ្រឹស្តីនៃនីតិរដ្ឋធម្មនុញ្ញបានឱ្យគំនិតពីរ គឺ គំនិតទីមួយរដ្ឋធម្មនុញ្ញគ្រាន់តែជាសំភារៈសំរាប់មនុស្សប្រើប្រាស់ រីឯគំនិតទីពីររដ្ឋធម្មនុញ្ញជាខ្នាតមួយសំរាប់កំនត់នូវទំរង់រួមក្នុងការគ្រប់គ្រងសង្គមទាំងមូល ។

# អត្ថបទទី ៤

# ទំរង់ និងរចនាសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ

## ១. ទំរង់ក្រៅនៃរដ្ឋធម្មនុញ្ញ

ទំរង់នៃរដ្ឋធម្មនុញ្ញ គឺជាមធ្យោបាយមួយនៃអង្គការគ្រប់គ្រងរដ្ឋ ដែលវាសំដែងចេញតាមរយៈនៃបទដ្ឋានធម្មនុញ្ញ (Constitutional Norm) ។ នៅក្នុងអត្ថបទទីបី យើងបានស្គាល់អត្ថន័យនៃរដ្ឋធម្មនុញ្ញរួចទៅហើយ ដូចនេះយើងនឹងសិក្សានូវទំរង់នានានៃរដ្ឋធម្មនុញ្ញ តាមលក្ខណៈពីរប្រភេទដូចខាងក្រោមនេះ ។

**ក.រដ្ឋធម្មនុញ្ញសំណេរ** (Written Constitution) : រដ្ឋធម្មនុញ្ញរបៀបនេះ ត្រូវបានចារឹកជាអក្សរ ។ ជាទូទៅ រដ្ឋធម្មនុញ្ញនេះរៀបចំឡើងដោយ**បទដ្ឋានកិច្ច** (Normative Act) **មួយ ឬច្រើន** ។ ការរួមបញ្ចូលនៃកិច្ច (Act) ដ៏ច្រើននោះបានកកើតនូវរដ្ឋធម្មនុញ្ញមួយ (Constitution) យ៉ាងច្បាស់លាស់ ។ នៅក្នុងទំរង់សំណេរនេះ យើងឃើញមានលក្ខណៈផ្សេងៗទៀត ដូចជា :

**ក១.លក្ខណៈជាក្រុម** : ជាទំរង់ដែលរដ្ឋធម្មនុញ្ញប្រមូលផ្តុំនៅក្នុងច្បាប់តែមួយ ។ ផ្ទុយទៅវិញបទដ្ឋានកិច្ចនៃប្រទេសមួយចំនួនវាមានលក្ខណៈ និងប្រភេទប្រហាក់ប្រហែលគ្នា ដែលជាហេតុធ្វើឱ្យរដ្ឋធម្មនុញ្ញនៃប្រទេសទាំងនោះមានឈ្មោះផ្សេងគ្នា ។ ត្រង់នេះដែលគេហៅថា ប្រទេសដែលរដ្ឋធម្មនុញ្ញមាន**លក្ខណៈបង្រួបបង្រួម** (United Acts) ឬហៅថា**សហច្បាប់** ( សំរាប់សហព័ន្ធ......) និងរដ្ឋធម្មនុញ្ញមាន**លក្ខណៈប្រភេទជាកិច្ចឯកាធិភាព** (Single Act) ( សំរាប់រដ្ឋឯកភូត ដូចជា បារាំង, កម្ពុជា .........) និងមានឈ្មោះផ្សេងៗគ្នា ដូចជាប្រទេស**អាល្លឺម៉ង់** មានឈ្មោះថាច្បាប់គ្រឹះ (Basic Law of Germany), រដ្ឋធម្មនុញ្ញប្រទេស**អេស្ប៉ាញ** (Constitution), នយោបាយរដ្ឋធម្មនុញ្ញ**មិកសិក្វ ឆ្នាំ ១៩១៧** (Political Constitution) ជាដើម ។

ចំពោះប្រទេសអាល្លឺម៉ង់ និងប្រទេសមិកសិក្ វាមានទំរង់រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋជាសហព័ន្ធដូចគ្នា ដូចនេះរដ្ឋធម្មនុញ្ញវាមាននៅគ្រប់រដ្ឋដែលជាសមាជិករបស់វា ដែលមានឈ្មោះសំរាប់ប្រទេសអាល្លឺម៉ង់ សមាជិកក្នុងសមាសភាពសហព័ន្ធឈ្មោះថា **ប្រទេសអាល្លឺម៉ង់** ឬ Lander ឯសមាជិកក្នុងសមាសភាពមិកសិក្ ឈ្មោះថា "**រដ្ឋមិកសិក្**"។ ដូចនេះក្នុងសហព័ន្ធមានរដ្ឋធម្មនុញ្ញជាលក្ខណៈបង្រួបបង្រួម (United Acts) និងរដ្ឋធម្មនុញ្ញមួយៗដាច់ពីគ្នាមានលក្ខណៈតែមួយប្រភេទ ឬកិច្ចឯកាធិភាព ។

**ក២.លក្ខណៈគ្មានក្រម** : ជារដ្ឋធម្មនុញ្ញដែលកើតចេញពីច្បាប់ជាច្រើន នៅរាយប៉ាយគ្នា ។ ជាឧទាហរណ៍ ប្រទេស**ស៊ុយអ៊ែដ** ដែលជារដ្ឋឯកភូត (Unitary State) រដ្ឋធម្មនុញ្ញរបស់ប្រទេសនេះកើតពីសមាសភាពបទដ្ឋានកិច្ច ៣ ប្រភេទ ហើយពុំបានបណ្ដុំចូលគ្នាជាបទដ្ឋានតែមួយនោះទេ ដូចជា :

- **ច្បាប់ស្ដីពីទំរង់គ្រប់គ្រងឆ្នាំ** ១៩៧៤ ដែលនៅក្នុងនោះវាធ្វើនិយ័តកម្មទៅលើមូលដ្ឋានគ្រឹះទាំងឡាយនៃ**របបគ្រប់គ្រងរដ្ឋ**. និយ័តកម្មលើសិទ្ធិ និង**សេរីភាពគ្រឹះ** និង**ប្រព័ន្ធអង្គការរដ្ឋ**.
- **ច្បាប់ ស្ដីពីការឡើងស្នងរាជ** (Succession to the Throne) ឆ្នាំ ១៨១០.
- **ច្បាប់ ស្ដីពីសេរីភាពនៃសារព័ត៌មាន** ឆ្នាំ ១៩៧៤[១១] ។ និងមានប្រទេសមួយចំនួនទៀត ដែលរដ្ឋធម្មនុញ្ញរបស់គេរៀបចំឡើងដោយបទដ្ឋានកិច្ចច្រើនប្រភេទ ហើយដែលបទដ្ឋានកិច្ចទាំងនោះវាខុសពីបទដ្ឋានកិច្ចផ្សេងៗទៀត ត្រង់ថាវាមាន**កំលាំងគតិយុត្តិកំរិតខ្ពស់** ។

ដូចនេះ បើសិនរដ្ឋធម្មនុញ្ញណាមានលក្ខណៈជា**សហច្បាប់លាយល័ក្ខណ៍អក្សរ** (written United Act) ដែលធ្វើនិយ័តកម្មលើសំណួរគ្រឹះសំខាន់ៗ រដ្ឋធម្មនុញ្ញនោះមានឈ្មោះថា**រដ្ឋធម្មនុញ្ញមានទំរង់ជាក្រម**[១២] មួយ (Codification) ប៉ុន្តែបើបញ្ហាទាំងនោះ (សំនួរ) ត្រូវធ្វើនិយ័តកម្មដោយ

[១១] . ច្បាប់ទាំងនេះ សុទ្ធតែជាប្រភពសំខាន់ៗនៃនីតិរដ្ឋធម្មនុញ្ញ ។

[១២] . រដ្ឋធម្មនុញ្ញ ជាច្បាប់គ្រឹះតែមួយគត់ ដូចជា : ខ្មែរ. បារាំង. អាល្លឺម៉ង់. រុស្ស៊ី .... ។ល។

បទដ្ឋានកិច្ចលាយល័ក្ខណ៍ជាអក្សរ (ច្បាប់) ជាច្រើនមិនបណ្តុំគ្នា នោះគេហៅថា**រដ្ឋធម្មនុញ្ញពុំមានទំរង់ជាក្រម**[១៣] ទេ ។ រដ្ឋធម្មនុញ្ញមានទំរង់ជាក្រមនេះ គេសង្កេតឃើញនូវលំដាប់ថ្នាក់របស់វាពីរផ្សេងគ្នា ដែលអាស្រ័យនឹងការប្រមូលផ្តុំជាក្រមនោះ គឺលក្ខណៈ**លំអិត** និងលក្ខណៈ**មិនលំអិត** ដែលលក្ខណៈទាំងពីរនេះពុំមានព្រំដែនកំរិតច្បាស់លាស់នោះឡើយ[១៤] ។ ជាឧទាហរណ៍ រដ្ឋធម្មនុញ្ញមានលក្ខណៈលំអិត ដូចជាប្រទេសក្រិច, **ព័រទុយហ្គាល់** ......។ល។ រីរដ្ឋធម្មនុញ្ញមានលក្ខណៈមិនលំអិត ដូចជាបារាំង ជាដើម ។

សរុបទៅ ការរៀបរាប់ខាងលើទាំងអស់នេះ វាជា**ទំរង់ក្រៅនៃរដ្ឋធម្មនុញ្ញ**តែប៉ុណ្ណោះ ។ រីឯ**ទំរង់ក្នុង**គឺជា**រចនាសម្ព័ន្ធរបស់រដ្ឋធម្មនុញ្ញ** ដែលនឹងសិក្សាបន្តទៀត (មើលរូបទី ៣ និងទី ៤) ។ យើងកំនត់ចំពោះរដ្ឋធម្មនុញ្ញគ្មានលក្ខណៈចងក្រងជាក្រុម (Uncodified Act) ពុំមានប្រព័ន្ធបង្ហាញជា**សំភារៈ**ទេ ហើយវាក៏កើតមាននូវលក្ខណៈតក្កវិជ្ជាណាស់ក្នុងការសាងសង់ ឬបង្កើតវានោះ ដូចជារដ្ឋធម្មនុញ្ញ**ស៊ុយអែដ** ដែលកើតឡើងពីច្បាប់បី ដែលច្បាប់នីមួយៗធ្វើនិយ័តកម្មទៅលើបញ្ហាណាដែល**បានគូសបញ្ជាក់**ស្រាប់ ប៉ុន្តែបញ្ហាផ្សេងៗទៀតដែលជាលក្ខណៈធម្មនុញ្ញនោះ ពុំបានធ្វើនិយ័តកម្មឡើយ ។

**ក៣. លក្ខណៈចំរុះ** (Mixed Constitution) : រដ្ឋធម្មនុញ្ញក្រៅពីទំរង់ខាងលើនេះ នៅមានទំរង់មួយទៀតដែលមានលក្ខណៈចំរុះ ។ រដ្ឋធម្មនុញ្ញរបៀបនេះ ជារដ្ឋធម្មនុញ្ញដែលមានលក្ខណៈជា**លាយល័ក្ខណ៍អក្សរ**ដែរ ដែលច្បាប់នោះមានដូចជា**ច្បាប់ទាំងឡាយរបស់រដ្ឋសភា**, **សេចក្តីសំរេចរបស់តុលាការ**[១៥] ដែលបទដ្ឋានទាំងអស់នោះវាជាអាទិភាពចាំបាច់បំផុត ។

---

[១៣]. រដ្ឋធម្មនុញ្ញប្រភេទនេះ ផ្សំឡើងពីច្បាប់ជាច្រើនដូចជា ប្រទេសស៊ុយអែដជាដើម ។

[១៤]. រដ្ឋធម្មនុញ្ញលំអិត គឺបទបញ្ញត្តិវាបានចែងនូវលក្ខណៈលំអិតទៅលើចំនុចនានា ដោយជៀសវាងនូវការបកស្រាយពីពួកអ្នកមានអំណាចរដ្ឋ រីឯរដ្ឋធម្មនុញ្ញមិនលំអិត មាត្រារបស់វាច្រើនកំនត់នូវបញ្ញត្តិគោលៗតែប៉ុណ្ណោះ ហើយពេលអនុវត្តត្រូវការច្បាប់ចែងលំអិតបន្ថែម ។ តែទោះជាយ៉ាងណាក៏ដោយ លក្ខណៈទាំងពីរនេះត្រូវតែបំពេញគ្នាទៅវិញទៅមក ។

[១៥]. ប្រទេសអង់គ្លេស ចាត់ទុកសេចក្តីសំរេចរបស់តុលាការជាប្រភពនៃច្បាប់ដែរ អញ្ចឹងហើយបានជាបទដ្ឋានទាំងនោះ ចាត់ទុកជាប្រភពដ៏សំខាន់មួយដែរ សំរាប់ច្បាប់គ្រឹះ ។

រដ្ឋធម្មនុញ្ញលក្ខណៈចំរុះនេះ វាជាច្បាប់កំពូលផង និងជាច្បាប់ដែលធ្វើនិយ័តកម្មទៅលើអំណាចគ្រប់គ្រងរដ្ឋផង ( អំណាចនីតិបញ្ញត្តិ, អំណាចនីតិប្រតិបត្តិ, និងអំណាចតុលាការ) ដែលច្បាប់ឬបទដ្ឋានទាំងនោះពុំមានលក្ខណៈចងក្រងជាក្រមទេ (Uncodified Act) ។ ដូចជានៅ**ចក្រភពអង់គ្លេស** ពុំមានរដ្ឋធម្មនុញ្ញជា**លក្ខណៈសហច្បាប់** (United Act) ទេ ដែលគេច្រើននិយាយថាប្រទេសអង់គ្លេស ពុំមានរដ្ឋធម្មនុញ្ញដូចប្រទេសផ្សេងៗនោះទេ ពីព្រោះថាច្បាប់នានានោះស្ថិតនៅរាយប៉ាយពីគ្នា ឬរដ្ឋធម្មនុញ្ញដែលបទដ្ឋានកិច្ចវាពុំស្ថិតក្នុងបណ្តុំតែមួយ ។ ប៉ុន្តែរដ្ឋធម្មនុញ្ញរបស់ចក្រភពនេះ កើតឡើងបានពីសមាសភាពរបស់បទដ្ឋាននៃនីតិអាទិភាព (Statute Law) ដែលច្បាប់ទាំងនោះចាត់ទុកជាប្រភពសំខាន់ៗ ដូចជា :

- ***ច្បាប់ហាបឺសគ័រពូស*** (Habease Corpus Act) ច្បាប់ឆ្នាំ ១៦៧៩ ដែលច្បាប់នេះធានានូវច្បាប់នីតិរដ្ឋប្បវេណី គឺបានកំណត់នូវវិធាននៃការចាប់ខ្លួន និងការចោទប្រកាន់.
- **ច្បាប់ ស្តីពីសិទ្ធិ** (Bill of Rights) ឆ្នាំ ១៦៨៩ ជាបណ្តុំនៃបទដ្ឋានធម្មនុញ្ញ ដែលធានានូវសិទ្ធិពលរដ្ឋក្នុងទំនាក់ទំនងអញ្ញមញ្ញរបស់គេ ជាមួយអង្គការនានានៃអំណាចរដ្ឋ ។
- **ច្បាប់ ស្តីពីការសោយរាជ្យស្នងត្រកូល** ឆ្នាំ ១៧០១, **ច្បាប់មួយចំនួនស្តីពីរដ្ឋសភា** ១៩១១ ឆ្នាំ ១៩៤៩ ។ និងបទដ្ឋាននៃនីតិសាកល (Common Law) ជាដើម ។ល។
- **ច្បាប់ ស្តីពីសភាជាន់ទាប** (House of Commons) ដែលនិយាយពីការគ្រប់គ្រងការងារនាឆ្នាំ ១៩៧៨ ។

ដោយច្បាប់កំពូលនៃប្រទេសនេះ កើតឡើងពីច្បាប់ផ្សេងៗគ្រប់ស្រទាប់នោះ ទើបគេឱ្យឈ្មោះថា**កិច្ចព្រមព្រៀងធម្មនុញ្ញ** ដែលនៅក្នុងនោះផ្ទុកនូវ**បទដ្ឋានអនុសញ្ញា** ។ ចំពោះប្រទេសអង់គ្លេស **ការផ្លាស់ប្តូរទាំងឡាយដូចជា : ទំលាប់អាទិភាពតុលាការ** និងច្បាប់នានាដែលជាគ្រឹះនៃរដ្ឋធម្មនុញ្ញត្រូវតែធ្វើឡើងដោយច្បាប់ទាំងឡាយ ដែលអនុម័តដោយរដ្ឋសភា។ ចំពោះរដ្ឋធម្មនុញ្ញចំរុះនៅក្នុងឯកសារខ្លះគេហៅថា រដ្ឋធម្មនុញ្ញគ្មានសំណេរ ឬក៏ថាគ្មានរដ្ឋធម្មនុញ្ញ ឬក៏និយាយថារដ្ឋធម្មនុញ្ញគ្មានក្រម ។

**ខ.រដ្ឋធម្មនុញ្ញគ្មានសំណេរ** (Unwritten Constitution) : រដ្ឋធម្មនុញ្ញរបៀបនេះកំរជួបប្រទះណាស់ ព្រោះលក្ខណៈរបស់វាជាទូទៅ គេពុំបានចារឹកអក្សរនៅក្នុងឯកសារផ្សេងៗនោះទេ ។ ប៉ុន្តែរដ្ឋធម្មនុញ្ញរបៀបនេះកើតមានឡើងមានលក្ខណៈជា**បណ្តោះអាសន្ន** ដូចជាបន្ទាប់ពីធ្វើបដិវត្តន៍ ឬរដ្ឋប្រហារនានា ។ល។ ឧទាហរណ៍ [១៦] វាបានកើតមានឡើងក្នុងប្រទេស**រ៉ូម៉ានី** ក្នុងខែដំបូងបន្ទាប់ពីកុប្បកម្ម ខែធ្នូ ឆ្នាំ ១៩៨៩ ។ ក្នុងពេលនោះវាជាវិន័យមួយដែលគេរក្សាទុកនូវច្បាប់ ឬបទដ្ឋានកិច្ចទាំងឡាយណាដែលមានខ្លឹមសារ និងទិសដៅមិនប្រឆាំងនឹងរបបថ្មី[១៧] ។

ចំពោះការបែងចែកទំរង់រដ្ឋធម្មនុញ្ញតាមផ្នែកដូចខាងលើនេះ ក៏សឹងតែគ្រប់គ្រាន់ទៅហើយ ប៉ុន្តែនៅមានលក្ខណៈផ្សេងទៀត ដូចជារដ្ឋធម្មនុញ្ញមានលក្ខណៈជារដ្ឋធម្មនុញ្ញសំនេរនោះបានចារឹកត្រឹមត្រូវ ហើយតែបែរជាមិនធ្វើសកម្មភាពទៅវិញ ដោយក្នុងប្រទេសនោះយកទំលាប់មកអនុវត្ត ។ ដូចជាក្នុងប្រទេសបារាំង រដ្ឋធម្មនុញ្ញបានកំណត់ថា នាយករដ្ឋមន្ត្រីត្រូវទទួលខុសត្រូវចំពោះមុខសភាជាន់ទាប (សភាតំណាងរាស្ត្រ) តែក្នុងករណីជាក់ស្តែង ភាពទទួលខុសត្រូវរបស់គាត់ធ្វើឡើងចំពោះមុខប្រធានាធិបតីសាធារណរដ្ឋទៅវិញ ។[១៨] ត្រង់នេះបញ្ជាក់ថា ទំលាប់របស់គេដែលបានធ្វើពីមុនមានលក្ខណៈសណ្តាប់ធ្នាប់គតិយុត្តិនោះ គេចេះតែធ្វើសកម្មភាពនេះតៗមក ឱ្យតែទំលាប់នេះផ្តល់នូវសណ្តាប់ធ្នាប់ដល់សង្គម ។

## ២. រចនាសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ ឬទំរង់ក្នុងនៃរដ្ឋធម្មនុញ្ញ

នៅក្នុងការសាងសង់ច្បាប់គ្រឹះមួយឡើង ដោយសំដៅលើបញ្ហាមួយដែលគេចង់និយាយនោះគឺកិច្ច ឬច្បាប់ទាំងឡាយ (Acts) ដែលមានលក្ខណៈ**ប្រមូលផ្តុំជាក្រុម** ។ មានន័យថាច្បាប់ ឬក៏

---

[១៦]. Constitutional law of Foreign Country, Part I, Page 51, M. 1994 ។

[១៧]. ខ្លឹមសាររបស់វា គឺរាល់បទដ្ឋានទាំងឡាយដែលមានលក្ខណៈអំណាចរដ្ឋ បានអនុម័តក្នុងរបបចាស់ ហើយវាបំរើឱ្យរបបថ្មី បទដ្ឋាននោះចាត់ទុកជារដ្ឋធម្មនុញ្ញគ្មានសំណេរ ក្នុងរយៈពេលនៃអន្តរកាលណាមួយ ទំរាំនឹងមានច្បាប់ថ្មីជំនួស (ច្បាប់ធម្មនុញ្ញ) ។

[១៨]. មើល Constitutional law of foreign Country Page 51, Part I, M. 1994 ។

កិច្ចនោះមានលក្ខណៈជាសហ (បង្រួមគ្នាច្រើន) ឬលក្ខណៈតែមួយឯកតា ដោយបទដ្ឋានរបស់វាបាន គ្របដណ្តប់នៅក្នុងឯកសារនៃឯកតាមួយ និងមានកំលាំងគតិយុត្តិខ្ពស់បំផុត (មើលរូបទី ៤) បើប្រៀបទៅនឹងបទដ្ឋានផ្សេងៗទៀតរបស់រដ្ឋមួយ ។

រចនាសម្ព័ន្ធនៃច្បាប់កំពូលនេះ ជារឿយៗតែងរៀបចំឡើងតាមខ្នាតគំរូមួយប្រភេទច្បាស់លាស់ ឬហៅថា**បមណីយកម្ម** (Standardization) ដែលគេសង្កេតឃើញជាទូទៅកើតមានចំពោះច្បាប់កំពូលនេះ។ជាធម្មតាបមណីយកម្មនេះមានច្រើនប្រភេទណាស់ ដូចជាៈ**បុព្វកថា** (Preamble), **ខ្លឹមសារគ្រឹះ** (Bacis Section), **បញ្ញត្តិបញ្ចប់**, **អន្តរបញ្ញត្តិ**, **បញ្ញត្តិបន្ថែម**, ជួនកាលក៏កើតមាន**ឧបសម្ព័ន្ធ**ផងដែរ ។

**ក.បុព្វកថា** : វាជាទូទៅបង្ហាញនូវទិសដៅនៃរដ្ឋធម្មនុញ្ញ ឬច្បាប់កំពូលនោះ ដូចជាល័ក្ខខ័ណ្ឌដែលជាប្រវត្តិសាស្ត្រនៃការបង្កើតរដ្ឋធម្មនុញ្ញ ជួនកាលប្រកាសនូវសិទ្ធិ និងសេរីភាព ឬការចាប់ផ្តើមដឹកនាំនយោបាយរដ្ឋ ។ រីឯកំលាំងគតិយុត្តិនៃបុព្វកថារបស់រដ្ឋធម្មនុញ្ញ ពុំត្រូវបានទទួលស្គាល់ឡើយ ព្រោះវាពុំមែនជា**បទដ្ឋានគតិយុត្តិ**ទេ (Juridical Norm) ។ ប៉ុន្តែវាមាន**អត្ថន័យជាបញ្ញត្តិ**សំរាប់ធ្វើការ**បកស្រាយ** និងកិច្ចអនុវត្តន៍នៃបញ្ញត្តិផ្សេងៗទៀតរបស់រដ្ឋធម្មនុញ្ញ ។ ដូចជាបុព្វកថានៃរដ្ឋធម្មនុញ្ញ**បារាំង** ឆ្នាំ ១៩៤៦ ដែលបានប្រកាសនូវសិទ្ធិ និងកាតព្វកិច្ច ហើយបានបន្តធ្វើសកម្មភាពរហូតដល់បច្ចុប្បន្ននេះ គ្រង់ថាវាមានអត្ថន័យគតិយុត្តិ ព្រោះវាជាបទដ្ឋាននៃចំណែកគ្រឹះ ឬគោលការណ៍គ្រឹះនៃរដ្ឋធម្មនុញ្ញ ។

បុព្វកថាវាមានលក្ខណៈជាប្រវត្តិសាស្ត្រ ដូចជារដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ កំនត់ថា "**យើងប្រជារាស្ត្រខ្មែរ** ដែលធ្លាប់មានអារ្យធម៌ឧត្តុងឧត្តម ប្រទេសជាតិស្តុកស្តម្ភ ធំទូលាយ ថ្កុំថ្កើងកិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ ។ បានធ្លាក់ខ្លួនដ៏សែនទន្ទេត់ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយ ទ្រុឌទ្រោម ឱនថយមហាសោកស្តាយ ។

បានភ្ញាក់រលឹកក្រោកឈរឡើង ចងបាច់ឆន្ទៈមោះមុតប្តូរផ្តាច់រួបរួមគ្នាពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជាកោះសន្តិភាពឡើងវិញផ្អែកលើប្រព័ន្ធសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិឱ្យបានឈានឡើងរីកចំរើនលូតលាស់ សំបូររុងរឿងជានិរន្តរ៍ ។

## ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ.........." ។ យើងបានឃើញស័ព្ទ "**ផ្អែកករណីប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្សគោរពច្បាប់..... យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ** .........." ទាំងអស់នេះឯង ជាអត្ថន័យខ្លឹមសារគតិយុត្តិសំរាប់បង្កើតបទដ្ឋានគ្រឹះក្នុងរដ្ឋធម្មនុញ្ញ ។ ដូចនេះវាបំរើឱ្យបំណកស្រាយ ក្នុងការរីកញែកក្នុងបទដ្ឋានខ្លឹមសារគ្រឹះនៃរដ្ឋធម្មនុញ្ញ ។

**ខ.ខ្លឹមសារមូលដ្ឋានគ្រឹះ** : វាជាចំណុះរួមក្នុងអត្ថបទនៃរដ្ឋធម្មនុញ្ញ ដែលផ្តុំឡើងដោយបទដ្ឋានជាច្រើន ។ ទាំងនេះជាផ្នែកមួយនៃរដ្ឋធម្មនុញ្ញ ដែលលាតត្រដាងនូវបទដ្ឋានជាច្រើន ស្តីអំពីសិទ្ធិ និងសេរីភាព ដូចជា**មាត្រា ៣១** រដ្ឋធម្មនុញ្ញកម្ពុជាបញ្ជាក់ថា "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សំបុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់សិទ្ធិអ្នកដ៏ទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំនត់ក្នុងច្បាប់" ។ និង**មាត្រា ៤១** "ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិ

ផ្ទាល់ខ្លួន សេរីភាពខាងពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ ។

របបសារពត៌មាន ត្រូវរៀបចំឡើងដោយច្បាប់" ។ ក្នុងខ្លឹមសារដែលជាមូលដ្ឋានគ្រឹះនេះ គេអាចសង្កេតឃើញមានធាតុជាច្រើនទៀត សំរាប់ធ្វើឱ្យទៀងទាត់នូវទំនាក់ទំនងសាធារណៈដូចជា :

**៩.. បទប្បញ្ញត្តិស្តីអំពីប្រព័ន្ធនៃរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ** : ជាបទដ្ឋានធម្មនុញ្ញដែលបានធ្វើនិយ័តកម្មទៅលើដែនដីគ្រប់គ្រងរដ្ឋ ដូចជារដ្ឋឯកភូត. រដ្ឋសហព័ន្ធ។ល។ តាម**មាត្រា** ១ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ចែងថា "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។ ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ" ។ និង**មាត្រា** ៥១ "ព្រះរាជាណាចក្រកម្ពុជាអនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ហើយអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។ អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រត្តិបត្តិ និងអំណាចតុលាការ" ។ រីឯ**មាត្រា** ៣ ចែងថា "ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន" ។ ចំពោះ**មាត្រា** ៩០ "រដ្ឋសភា ជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារៈកិច្ចរបស់ខ្លួនដូចបានកំនត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើតកែប្រែ ឬក៏លុបចោលពន្ធដារ ។

- រដ្ឋសភា ឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។
- រដ្ឋសភា អនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។
- រដ្ឋសភា អនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញាអន្តរជាតិ ។
- រដ្ឋសភា អនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភាទាំងមូល ។

- រដ្ឋសភា បោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើន ពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល" ។

**ខ.១.១.គោលការណ៍បែងចែកអំណាច** : រដ្ឋធម្មនុញ្ញកំណត់នូវការបែងចែកយ៉ាងច្បាស់លាស់ដាច់ពីគ្នា នូវអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ ហើយនឹងបំពេញនាទីដោយអង្គការរដ្ឋផ្សេង១ពីគ្នា ដើម្បីជាតុល្យភាពទៅវិញទៅមក ដោយជៀសវាងនូវការបំពានគ្នាដោយគ្មានព្រំដែន ដូចបានចែងក្នុងមាត្រា ៥១ ស្រាប់ ។ ជាងនេះទៀត រដ្ឋធម្មនុញ្ញបានកំនត់នូវសកម្មភាពរបស់ប្រមុខរដ្ឋចំពោះសិទ្ធិអំណាចនានា ទាក់ទិននឹងហត្ថលេខា ដូចជា**មាត្រា ៩៣** "ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេល ១០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល ២០ ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។

ប៉ុន្តែបើច្បាប់នេះមានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសឱ្យទាន់ពេលកំណត់ខាងលើ" ។ **មាត្រា ១៣០** "គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ " ។

**ខ.១.២.ការកំណត់ដែនដីរដ្ឋបាល : មាត្រា ១៤៥** "ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និងក្រុង ។ ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកចេញជាខ័ណ្ឌ ខ័ណ្ឌចែកចេញជាសង្កាត់" ។ និង**មាត្រា ១៤៦** "ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ និងសង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ " ។

**ខ្ម. បទប្បញ្ញត្តិស្តីពីប្រព័ន្ធគ្រប់គ្រង និងឋានៈនៃអង្គការរដ្ឋ** : ជាបទដ្ឋានធម្មនុញ្ញនៃការកំនត់អង្គការនានារបស់រដ្ឋ និងទំនាក់ទំនងអង្គការទាំងនោះ ។ ដូចជា**មាត្រា ១៣៦** "...... ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្ម ទាក់ទិននឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ .........." ។ **មាត្រា ១១៨** "គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប ដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក" ។ **មាត្រា ១១៩** "តាមសេចក្តីស្នើពីប្រធានដោយមានមតិឯកភាពពីប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណៈបក្សដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះនាំសហការីដែលជាតំណាងរាស្ត្រ ឬសមាជិកគណៈបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្គូរផ្គងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយ នោះព្រះមហាក្សត្រចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។

មុនចូលកាន់តំណែង ត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦" ។ ចំពោះ **មាត្រា ៧៦** រដ្ឋធម្មនុញ្ញកម្ពុជា ចែងថា "រដ្ឋសភា មានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី, ដោយស្មើភាព, ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសំងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីរកំណើត ។

អង្គការរៀបចំការបោះឆ្នោតបែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត" ។ ទាក់ទិននឹងអំណាចតុលាការ រដ្ឋធម្មនុញ្ញបានកំនត់ក្នុង**មាត្រា ១២៨** ថា "អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការធានារក្សាអនាគត និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ " ។

**៩៣. បទប្បញ្ញត្តិស្តីពីនិមិត្តរូបរដ្ឋ** : ជាបទដ្ឋានធម្មនុញ្ញដែលកំនត់នូវសញ្ញាណ ឬរូបភាពនានា ដែលជានិមិត្តរូបរបស់រដ្ឋនីមួយៗ ។ ដូច **មាត្រា ៤** ចែងថា "បាវចនានៃព្រះរាជាណាចក្រកម្ពុជាគឺ : ជាតិ សាសនា ព្រះមហាក្សត្រ " ។ និង **មាត្រា ៥** "ភាសា និងអក្សរ ដែលប្រើជាផ្លូវការគឺ ភាសា និងអក្សរខ្មែរ" ។ **មាត្រា ៦** កំនត់ថា "ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។ ទង់ជាតិ ភ្លេងជាតិ និងសញ្ញាជាតិ មានកំណត់ក្នុងឧបសម្ព័ន្ធ ១,២ និង ៣" ។

**៩៤. បទប្បញ្ញត្តិស្តីពីការគ្រប់គ្រងអំណាចមូលដ្ឋាន** : ជាបទដ្ឋានធម្មនុញ្ញ ដែលធ្វើនិយ័តកម្ម ទៅលើអំណាចមូលដ្ឋាន ។ ដូចជា **មាត្រា ១៤៥** "ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និង ក្រុង ។

ខេត្តចែកចេញជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់" ។ និង **មាត្រា ១៤៦** "ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ និងសង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ" ។

**៩៥. បទប្បញ្ញត្តិស្តីអំពីសណ្តាប់ធ្នាប់នៃការផ្លាស់ប្តូររដ្ឋធម្មនុញ្ញ** : ជាបទដ្ឋានទាំងឡាយនៃរដ្ឋ ធម្មនុញ្ញ ដែលធ្វើនិយ័តកម្មទៅលើបញ្ហាផ្លាស់ប្តូរនៃរដ្ឋធម្មនុញ្ញ ។ ដូចជា **មាត្រា ១៥១** "ការផ្តើម គំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយក រដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិក រដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័ត ដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល" ។ **មាត្រា ១៤៣** "ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោ-ធនកម្មលើរដ្ឋធម្មនុញ្ញ " ។

**គ.បញ្ញត្តិបញ្ចប់** : ជាវិធានទាំងឡាយ ដែលក្នុងនោះវាផ្ទុកនូវបទដ្ឋានជាច្រើន ។ ជាទំលាប់បទបញ្ញត្តិបញ្ចប់ ច្រើនតែកំណត់នូវសណ្តាប់ធ្នាប់នៃការចូលជាធរមានផ្លូវច្បាប់ នៃរដ្ឋធម្មនុញ្ញ ។ ដូចជា**មាត្រា ១៥៤** "រដ្ឋធម្មនុញ្ញនេះក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា"។ និង**មាត្រា ១៥៥** ចែងថា "ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ត្រូវចូលជាធរមានក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ" ។

**ឃ.អន្តរបញ្ញត្តិ** : វាជាការកំណត់មួយទៅលើថេរវេលានៃការចូលជាធរមាន រាល់បទដ្ឋានធម្មនុញ្ញ ដែលបទដ្ឋានទាំងនោះពុំអាចត្រូវបានធ្វើសមិទ្ធិភ្លាម១ ។ ជាធម្មតារដ្ឋធម្មនុញ្ញកំនត់នូវសណ្តាប់ធ្នាប់ និងថេរវេលានៃការផ្លាស់ប្តូរនូវមូលដ្ឋានគ្រឹះធម្មនុញ្ញចាស់ ដោយរដ្ឋធម្មនុញ្ញថ្មី។ **មាត្រា ១៥៧** បានកំណត់ថា "នីតិកាលទី ១ នៃព្រឹទ្ធសភា មានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

សំរាប់នីតិកាលទី ១ នៃព្រឹទ្ធសភា :

- សមាជិកព្រឹទ្ធសភា មានចំនួនសរុបហុកសិបមួយរូប ។

- ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី ១ អនុប្រធានទី ២ នៃព្រឹទ្ធសភា ។

- សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

- កិច្ចប្រជុំជាសមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន"។ **មាត្រា ១៥៨** "ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របទឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានបទដ្ឋានថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទបញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ"។

**ខ.បញ្ញត្តិបន្ថែម** : វាជាធម្មតាផ្ទុកនូវបទដ្ឋានដែលមានលក្ខណៈ**បំណកស្រាយ** ឬបកស្រាយ ហើយវាជាផ្នែកពិសេស១ដែលលេចចេញមកពីវិធានទូទៅ ដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញ ។ វាធ្វើនិយ័តកម្មទៅលើបញ្ហាដោយឡែក១ ដែលបញ្ញត្តិពីមុនពុំបានកំនត់ច្បាស់ ។

**ច.ឧបសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ** : វាមានអត្ថន័យគតិយុត្តិយ៉ាងសំខាន់ សំរាប់ឱ្យអង្គការរដ្ឋដំណើរការ ដូចជារដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ឧបសម្ព័ន្ធទី ១, ២, ៣ លំអិតទៅលើ**មាត្រា ៦** "ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។ ទង់ជាតិ ភ្លេងជាតិ មានកំណត់ក្នុងឧបសម្ព័ន្ធ ១, ២, និង ៣"។

- ឧបសម្ព័ន្ធ ៤ កំណត់នូវអត្ថន័យនៃមាត្រា ១៤
- ឧបសម្ព័ន្ធ ៥ កំណត់នូវអត្ថន័យនៃមាត្រា ៨២
- ឧបសម្ព័ន្ធ ៦ កំណត់នូវអត្ថន័យនៃមាត្រា ១១៩
- ឧបសម្ព័ន្ធ ៧ កំណត់នូវអត្ថន័យនៃមាត្រា ១០៦

## ៣. ភាសា និងរចនាបថនៃរដ្ឋធម្មនុញ្ញ

វាជាការប្រើប្រាស់នូវភាសាសំរាប់អត្ថបទនៃរដ្ឋធម្មនុញ្ញ ។ ចំពោះភាសាដែលគេប្រើប្រាស់ក្នុងរដ្ឋធម្មនុញ្ញ ជាពាក្យពេចន៍ដែលមានលក្ខណៈទូលាយ ឬក៏វាមានសទិសន័យនៃពាក្យនោះទៅនឹងពាក្យដែលមានក្នុងនីតិកម្មផ្សេង១ ដែលជាកិច្ចការមួយធ្វើឱ្យងាយស្រួលដល់អ្នកកិច្ចអនុវត្តគតិយុត្តិ។ នៅក្នុងបណ្តាប្រទេសអ៊ឺរ៉ុប ដែលកាន់ប្រព័ន្ធគតិយុត្តិរ៉ូម៉ាំង គឺវាអាចប្រតិបត្តិនូវពាក្យដែលប្រើប្រាស់នោះមានលក្ខណៈងាយស្រួល ប៉ុន្តែសំរាប់ប្រព័ន្ធគតិយុត្តិបែបអាល្លឺម៉ង់ រដ្ឋធម្មនុញ្ញរបស់គេត្រូវបាន

ប្រើប្រាស់ពាក្យសាំញ៉ាំដែលធ្វើឱ្យមានការលំបាកដល់អ្នកអាន ។ ហើយរដ្ឋធម្មនុញ្ញបណ្តាប្រទេសនេះផ្តត់ផ្តង់នូវគតិយុត្តិច្បាស់លាស់ (ចំ១) ។ ចំពោះអត្ថបទរដ្ឋធម្មនុញ្ញ នៃបណ្តាប្រទេសដែលមានប្រព័ន្ធគតិយុត្តិអង់គ្លោសាក់សុង វាមានភាពសាំញ៉ាំថែមទៀតមូលហេតុគឺវាមាន**ប្រព័ន្ធ និងរចនាបថផ្សេងៗ** ពីប្រព័ន្ធគតិយុត្តិកុងទីណង់តាល់ ។

រចនាបថនៃអត្ថបទរដ្ឋធម្មនុញ្ញ វាជាអត្ថបទដែលមានលក្ខណៈផ្ចិតផ្ចង់បំផុត ជាពិសេសនៅក្នុងលក្ខណៈមួយចំនួនដូចជាបុព្វកថា សេចក្តីប្រកាសអំពីសិទ្ធិ និងសេរីភាព ។ល។ ទាំងអស់នោះគេប្រើប្រាស់រចនាបថខ្ពស់បំផុត ។ រចនាបថរបៀបនេះ នៅក្នុងប្រទេសដែលប្រកាន់ប្រព័ន្ធគតិយុត្តិកុងទីណង់តាល់ក៏បានប្រព្រឹត្តតាមលក្ខណៈនេះដែរ ។

# គំនូសបំព្រួញនៃទំរង់រដ្ឋធម្មនុញ្ញ

(រូបទី ៣)



# រចនាសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញកម្ពុជា ២១ កញ្ញា ១៩៩៣ (រូបទី៤)




**សំគាល់ :**

- សញ្ញា * គឺជាច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ ១៩៩៤ ។
- ចំនួនលេខ គឺជាមាត្រានៃរដ្ឋធម្មនុញ្ញ ប៉ុន្តែមិនគ្រប់គ្រាន់ទេ អាចជាមូលដ្ឋានជួយដល់អ្នកមើលរដ្ឋធម្មនុញ្ញ។

# អត្ថបទទី ៥

## ការអនុម័ត ការផ្លាស់ប្តូរ និងការលប់ចោលនៃរដ្ឋធម្មនុញ្ញ

### ១. ការអនុម័តនៃរដ្ឋធម្មនុញ្ញ

ប្រវត្តិសាស្ត្រជាប់ពីរយឆ្នាំមកហើយរបស់**រដ្ឋធម្មនុញ្ញនិយម** (Constitutionalism) ដែលប្រវត្តិសាស្ត្រនោះបានជ្រើសរើសនូវមធ្យោបាយមួយចំនួន នៃការអនុម័តរដ្ឋធម្មនុញ្ញ ។ និន្នាការទូទៅក្នុងការវិវត្តរបស់ប្រវត្តិសាស្ត្រនោះ បានកំនត់លើការរីកឡើងនូវលទ្ធិប្រជាធិបតេយ្យភាវូបនីយកម្ម (Democratization) ជាលំដាប់ៗ និងអចិន្ត្រៃយ៍ដែលទាក់ទិនទៅនឹងអង្គការបោះឆ្នោត ។

ដូចនេះ មធ្យោបាយនៃការអនុម័តរដ្ឋធម្មនុញ្ញនេះមានលក្ខណៈដូចតទៅ :

**ក.មធ្យោបាយទាយជ្ជទាន** (Gift) : ជាមធ្យោបាយ ដែលរដ្ឋធម្មនុញ្ញត្រូវបានផ្តល់ដោយ**កិច្ចឯកតោភាគី**នៃប្រមុខរដ្ឋ (ព្រះរាជា Monarch) ។ មានន័យថា រដ្ឋធម្មនុញ្ញត្រូវបានបង្កើតឡើងដោយស្តេចដែលជាប្រមុខរដ្ឋ ដោយពុំចាំបាច់យល់ព្រមពីអ្នកណាក្រៅពីទ្រង់ឡើយ ។

ក្នុងមធ្យោបាយនេះ លក្ខណៈប្រជាធិបតេយ្យមានតិចតួចបំផុត ហើយមធ្យោបាយនៃការអនុម័តរដ្ឋធម្មនុញ្ញក្នុងរបៀបនេះ បានកើតមានតាំងពីការចាប់ផ្តើមដំបូង នៃសតវត្សរ៍កន្លងមក[១៩] ដែលជានិច្ចកាលមានឈ្មោះថា**ធម្មនុញ្ញ** (Charter) នៅក្នុងរបបគ្រប់គ្រងរបស់គេនាសម័យនោះ ។ ជាឧទាហរណ៍ ធម្មនុញ្ញរបស់**បារាំង** (Charter) ឆ្នាំ ១៨១៤ ដែលក្នុងនោះស្តេច[២០] **ល្វីស** (Louis) ទី XVIII បានផ្តល់ឱ្យប្រជាជនបារាំង ដោយឈរលើមូលដ្ឋានគ្រឹះមួយនៃអំណាចកម្មសិទ្ធិ ។ ចំពោះធម្មនុញ្ញរបៀបនេះ ថ្វីត្បិតតែស្តេចបារាំង ផ្តល់អំណាចកម្មសិទ្ធិជូនមកឱ្យពលរដ្ឋបារាំងច្រើនក៏ដោយ

---

[១៩] . ជាសតវត្សដែលចាប់ផ្តើកើតរដ្ឋធម្មនុញ្ញ គឺ ស.វ ទី XVII ។

[២០] . ជាស្តេចបារាំងក្នុងឆ្នាំ (១៧៥៥-១៨២៤) ។

ប៉ុន្តែសិទ្ធិភាគច្រើននៃការផ្តល់ទាំងនោះ គឺបានត្រឹមតែចង់បានភាពជឿជាក់ពីរាស្ត្រ និងដើម្បីពង្រឹងអំណាចស្តេចខ្លួនឯងតទៅទៀតតែប៉ុណ្ណោះ ។

ការអនុម័ត ដែលធ្វើឡើងដោយមានការសរសេរជាលាយល័ក្ខណ៍អក្សរ នូវ**កិច្ចឯកតោភាគី** ដោយផ្តល់សិទ្ធិ ឬជាមធ្យោបាយប្រជាភិថុតណាមួយនោះ សំរាប់បញ្ជោរដល់រាស្ត្រតែប៉ុណ្ណោះ តែតាមធាតុពិតរបស់វា ពុំមានកើតឡើងដូចអ្វីៗដែលបានសរសេរនោះទេ ។ តមកមាននៅឆ្នាំ ១៩១១ រដ្ឋធម្មនុញ្ញ**ម៉ូណាកូ, និងរដ្ឋធម្មនុញ្ញនៃប្រទេសជប៉ុន** ឆ្នាំ ១៨៨៩ ក៏អនុម័តបែបទាយជូទាននេះដែរ ។

គួររំលឹកថាការអនុម័តរបៀបនេះ ពុំបានធ្វើឡើងដោយ**ឆន្ទៈពហុភាគី**ទេ ។ តែធ្វើឡើងដោយ**ឯកតោភាគី** ហើយចារឹកលាយល័ក្ខណ៍អក្សរក្នុងបទដ្ឋានកិច្ច ឬកិច្ចឯកតោភាគីតាងនាមឱ្យឆន្ទៈពហុភាគី ។ រដ្ឋធម្មនុញ្ញដែលអនុម័តតាមបែបទាយជូទាននេះ កើតមាននៅក្នុងប្រទេសសង្គមនិយម ជាពិសេសក្នុងប្រទេសអតីតប្លុកសង្គមនិយម ។

**ខ.មធ្យោបាយសន្ធិសញ្ញា** (Treaty) : ការអនុម័តរដ្ឋធម្មនុញ្ញតាមរបៀបព្រមព្រៀងគ្នានេះ កំរជួបប្រទះនៅអតីតកាល ឬបច្ចុប្បន្នកាលណាស់ ។ ដោយសារការអនុម័តនេះត្រូវឈរលើស្មារតីនៃកំលាំងពហុភាគីរវាងព្រះរាជា និងអង្គការជ្រើសរើស ឬកំលាំងនយោបាយនានាជាអ្នកដែលមានឆន្ទៈរីកចំរើនតំណាងឱ្យពលរដ្ឋទូទៅ ។ លក្ខណៈរបៀបនេះ មាននៅអតីតប្រវត្តិសាស្ត្រនៃរដ្ឋធម្មនុញ្ញ**អាល្លឺម៉ង់** ឆ្នាំ ១៨១៩ គឺរដ្ឋធម្មនុញ្ញ**វូរតឹមបៀរក៍** (Württemberg) ។

មានរដ្ឋធម្មនុញ្ញខ្លះទៀត បានត្រូវរៀបចំឡើងដោយ**គណៈកម្មការចំរុះ** និងយល់ព្រមដោយ**អង្គការតំណាង**បោះឆ្នោត (កំលាំងនយោបាយផ្សេងៗ ឬគណៈបក្សនយោបាយ) និងព្រះរាជា ។ រដ្ឋធម្មនុញ្ញរបៀបនេះ មានដូចជាច្បាប់សំនៅរអង់គ្លេសមួយចំនួន ដែលអនុម័តដោយរដ្ឋសភា ក្នុងនោះមានច្បាប់ស្តីពីសិទ្ធិ ឆ្នាំ ១៦៨៩ និងច្បាប់ ស្តីពី**ការគ្រប់គ្រង** ឆ្នាំ ១៧០៩ ជាដើម ។

ធាតុជាច្រើននៃលក្ខណៈព្រមព្រៀងនេះ យើងបានជួបការបង្កើតរដ្ឋធម្មនុញ្ញបន្ទាប់ពីសង្គ្រាមលោកលើកទី **II** ដូចជាការផ្តល់ឯករាជ្យឱ្យទៅប្រទេសគីព្រួស (Gree: Kýpros) ដោយកិច្ចព្រមព្រៀង ក្រិច, តួរគី ឆ្នាំ ១៩៥៩ ដែលមានឈ្មោះថា "Zurich-London Treaty" ដែលធ្វើឡើងដោយ**ចក្រភពអង់គ្លេស**, ប្រទេសតួរគី, តំណាងក្រិច និង**សហគមន៍ក្រិចដីកោះ**។ ពេលនោះបានអនុម័តរដ្ឋធម្មនុញ្ញគីព្រួស ឆ្នាំ ១៩៦០ ដោយឈរលើកិច្ចព្រមព្រៀង ១១ កុម្ភៈ ១៩៥៩ នោះ។

**គ.មធ្យោបាយត្រឹះនៃសភាបញ្ញត្តិ ឬសភាធម្មនុញ្ញ** (Constituent Assembly) :មធ្យោបាយរបៀបនេះរៀបចំឡើងដោយការប្រជុំមួយ ដែលមានសមាសភាពតំណាងចំរុះនៃអង្គការរដ្ឋ ឬតំណាងប្រជាជន ដើម្បីអនុម័តប្រើប្រាស់លើច្បាប់គ្រឹះរបស់ខ្លួន ។ រដ្ឋធម្មនុញ្ញរបៀបនេះគឺអនុម័តឡើងដោយរដ្ឋសភា (សភាតំណាងរាស្ត្រ) ។ មធ្យោបាយរបៀបនេះកើតមាននៅសតវត្សរ៍ទី **XIX** ដែលរួមទាំងប្រជាមតិទៀតផងដែរ ។ គោលដៅនៃសភាបញ្ញត្តិនេះ គឺបំពេញភារកិច្ចមួយដើម្បីឱ្យកើតជារដ្ឋធម្មនុញ្ញពិតជាលើកដំបូង ។ តែសភាធម្មនុញ្ញនេះ អាចរំលាយទៅវិញបន្ទាប់ពីការបង្កើត ឬអនុម័តរដ្ឋធម្មនុញ្ញរួចហើយ ពីព្រោះថាភារកិច្ចរបស់អង្គការនេះបានបញ្ចប់ហើយ។ ដូចជាការអនុម័តរដ្ឋធម្មនុញ្ញដោយប្រជាមតិ គេត្រូវបង្កើតអង្គការតំណាងមួយ សំរាប់ធ្វើឱ្យដំណើរការនៃការសំរេចផលចំពោះភារកិច្ចរបស់គេ តែបន្ទាប់ពីកិច្ចការនោះបានត្រូវបញ្ចប់គេនឹងរំសាយ ឬរំលាយចោល ឬមួយគេអាចកំនត់ក្នុងបញ្ញត្តិនៃការរៀបចំអង្គការនោះ ដោយរំលាយជាលក្ខណៈស្វ័យប្រវត្តិ ។

ការអនុម័តរដ្ឋធម្មនុញ្ញតាមបែបសភាបញ្ញត្តិ (Constituent Assembly) មានជាធម្មតារដ្ឋសភារបស់ក្រិចឆ្នាំ ១៩៧៥ និងការអនុម័តរដ្ឋធម្មនុញ្ញចុងក្រោយរបស់**បារាំង** តាមលក្ខណៈសភាបញ្ញត្តិមាននៅឆ្នាំ ១៨៤៨ បន្ទាប់មកឆ្នាំ ១៩៤៦ ។ ការអនុម័តមានលក្ខណៈនេះដូចជាប្រទេស**ព័រទុយហ្គាល់** ឆ្នាំ ១៩៧៥-១៩៧៦, **ប៊ុលហ្គារី** និង**រ៉ូម៉ានី** ឆ្នាំ ១៩៩០-១៩៩១ និងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣។ លក្ខណៈសភាបញ្ញត្តិ គឺរដ្ឋធម្មនុញ្ញមានលក្ខណៈលទ្ធិប្រជាធិបតេយ្យ ច្រើនជាងការអនុម័តតាមមធ្យោបាយដទៃទៀត ។

សរុបទៅការអនុម័តលើរដ្ឋធម្មនុញ្ញមានលក្ខណៈផ្សេងៗគ្នា តាមប្រវិត្តិសាស្រ្តដែលបានរៀបរាប់ហើយក៏ដោយចុះ ក៏វាបញ្ជាក់នូវការវិវត្តនៃសង្គម និងជនជាតិនីមួយៗក្នុងការគ្រប់គ្រងនៃរដ្ឋរបស់គេ ។ ផ្ទុយទៅវិញ ការអនុម័តដែលធ្វើឡើងដោយរដ្ឋសភា ឬអង្គការតំណាងឱ្យឆន្ទៈក្រុមណាមួយ វាជាលក្ខណៈប្រជាធិបតេយ្យដ៏រឹងមាំ ប៉ុន្តែទោះជាការអនុម័តរបៀបនេះអាចសមស្របនឹងប្រជាធិបតេយ្យក៏ដោយចុះ ក៏នៅមានលក្ខណៈខ្លះៗដែលនាំឱ្យមានវិបត្តិដែរ ដូចជាការកែច្នៃខ្លះនៃរដ្ឋធម្មនុញ្ញដែលធ្វើឡើងដោយរដ្ឋាភិបាល ដោយរួមសហការជាមួយការផ្តល់អំណះអំណាងរបស់រដ្ឋសភា និងប្រជាជន។ អត្ថន័យត្រង់នេះដូចជាការធ្វើប្រជាមតិជាដើម គឺថាការអនុម័តលើរដ្ឋធម្មនុញ្ញដោយធ្វើប្រជាមតិនោះត្រូវបានរៀបចំឡើងផ្សេងៗគ្នា ព្រោះពេលខ្លះប្រជាមតិធ្វើឡើងដោយអនុម័តលើរដ្ឋធម្មនុញ្ញ រួមសហការកែច្នៃជាមួយរដ្ឋសភា ឬសភាបញ្ញត្តិ ប៉ុន្តែភាគីមួយទៀតនោះយើងត្រូវគិតដល់អំពីបញ្ហាការ**ធ្វើសេចក្តីព្រាងនៃរដ្ឋធម្មនុញ្ញ** ត្រូវធ្វើឡើងដោយភាគីណា ? គឺអាច**រដ្ឋាភិបាល ឬអាចសហការជាមួយអង្គការរដ្ឋផ្សេងៗ ឬរដ្ឋសភា** ? រីឯសេចក្តីព្រាងនៃការធ្វើប្រជាមតិក៏ដូចគ្នាដែរ ។ ព្រោះច្បាប់នៃប្រជាមតិត្រូវអនុម័តដោយសភាបញ្ញត្តិ ឬរដ្ឋសភា ដើម្បីឱ្យវាមានស្មារតីប្រជាធិបតេយ្យ ឬក៏ការធ្វើប្រជាមតិនោះប្រព្រឹត្តទៅដោយស្ងប់ស្ងៀម គ្មានអំពើហឹង្សា ដោយគ្មានការគៀបសង្កត់ ឬឥទ្ធិពលផ្សេងៗពីភាគីដទៃៗ ។ ជាឧទាហរណ៍ របៀបនេះដូចជាសេចក្តីព្រាងរដ្ឋធម្មនុញ្ញ**ពីរ** ដែលបានធ្វើឡើងនៅប្រទេស**បារាំង** ឆ្នាំ ១៩៤៦ (សាធារណៈទី ៤) ដែលក្នុងនោះសេចក្តីព្រាងរដ្ឋធម្មនុញ្ញទី ១ ត្រូវបានអ្នកបោះឆ្នោតជំទាស់ (ពលរដ្ឋ) ។ បន្ទាប់មកលក្ខណៈអនុម័តនេះមានការធ្វើប្រជាមតិដោយសភាបញ្ញត្តិ ឬក៏រដ្ឋសភា ក្នុងការអនុម័តរដ្ឋធម្មនុញ្ញ ដូចជា**អ៊ីតាលី** នៅឆ្នាំ ១៩៤៧, **ព័រទុយហ្កាល់** ១៩៧៦, **អេស្ប៉ាញ** ១៩៧៨ ។ល។

ផ្ទុយទៅវិញ ការបោះឆ្នោតតាមរបៀបប្រជាមតិខ្លះ ត្រូវបានរៀបចំឡើងដោយរដ្ឋាភិបាលតំណាងឱ្យរដ្ឋសភា ។ ការធ្វើរបៀបនេះ ច្រើនមាននៅក្នុងប្រទេសសង្គមនិយម ។ គឺថារដ្ឋធម្មនុញ្ញរៀបចំដោយ**ឧបករណ៍របស់បក្ស** ហើយធ្វើជាទំរង់**មួយយល់ព្រមដោយរដ្ឋសភា** ត្រង់នេះបញ្ជាក់ថា**រដ្ឋធម្មនុញ្ញលក្ខណៈប្រជាមតិ** ដែលប្រែក្លាយជា**ប្រជាសិទ្ធិ** (ការសំរេចដោយប្រជាជន

Plebiscite) ដោយការធ្វើរបៀបនេះត្រូវបោះឆ្នោតទុកចិត្តលើរដ្ឋាភិបាល គឺទុកចិត្តថ្នាក់ដឹកនាំបក្ស ដូចជារដ្ឋធម្មនុញ្ញឈីលី ១៩៨០ ស្ថិតក្នុងល័ក្ខខ័ណ្ឌផ្តាច់ការរបស់ឧត្តមសេនីយ៍**ពីណូសេរ** ។ រដ្ឋធម្មនុញ្ញ បារាំងឆ្នាំ ១៩៥៨ ធ្វើប្រជាមតិអនុម័តដោយស្ថិតក្នុងស្ថានភាពវិបត្តិនយោបាយដ៏ខ្លាំងបំផុត ។ ដោយឡែករដ្ឋធម្មនុញ្ញប្រទេសប៊ុលហ្គារី ១៩៧១, គុយបា ឆ្នាំ ១៩៧៦ បានអនុម័តឡើងក្នុងល័ក្ខខ័ណ្ឌនៃរបបផ្តាច់ការ ដែលពេលនោះសេរីភាពរបស់អ្នកបោះឆ្នោតត្រូវបានកំរិត ឬក៏គ្មានភាពជំរើសរបស់ម្ចាស់ឆ្នោត ។

## ២. ការផ្លាស់ប្តូរនៃរដ្ឋធម្មនុញ្ញ

ការផ្លាស់ប្តូរនៃរដ្ឋធម្មនុញ្ញវាប្រែប្រួល និងប្រព្រឹត្តទៅបានតាមស្ថានភាពនៃការវិវត្តសង្គម ដូចជា : កំលាំងនយោបាយ, របបគ្រប់គ្រង.....។ល។ ទាំងអស់នេះវាជះឥទ្ធិពលទៅលើច្បាប់កំពូល ដែលតំរូវចាំបាច់ធ្វើឱ្យមានការប្តូរផ្លាស់ សមស្របតាម**របបនយោបាយ** ឬក៏**ឆន្ទៈរបស់ប្រជាជន** ដែលរបបនោះកំពុងគ្រប់គ្រង ។ ការផ្លាស់ប្តូររដ្ឋធម្មនុញ្ញ គេសង្កេតឃើញជាទ្រឹស្តីធ្វើឡើងទៅលើមូលដ្ឋានគ្រឹះនៃរដ្ឋធម្មនុញ្ញ ដែលមានលក្ខណៈដូចជា :

**ក.រដ្ឋធម្មនុញ្ញបំរែបំរួល** : នេះគឺជាប្រភេទរដ្ឋធម្មនុញ្ញ ដែលបង្កើតមកមានលក្ខណៈប្រមូលផ្តុំ ឬមិនប្រមូលផ្តុំ ដោយសកម្មភាពរបស់វាពុំមានឥទ្ធិពលទៅលើសង្គមជាក់ស្តែងឡើយ ដែលលក្ខណៈនេះតំរូវឱ្យមានការផ្លាស់ប្តូរជាបន្ទាន់ ។ ជាទូទៅ បទបញ្ញត្តិនៃមាត្រាខ្លះរបស់ច្បាប់គ្រឹះចាត់ទុកជាបញ្ញត្តិស្លាប់ ព្រោះវាអាចផ្ទុយនឹងរបបនយោបាយ ឬក៏មិនអាចធ្វើសកម្មភាពបាន ។

ការផ្លាស់ប្តូរទាំងឡាយនៃរដ្ឋធម្មនុញ្ញ គេឱ្យឈ្មោះថា**រដ្ឋធម្មនុញ្ញបត់បែន** (Flexible Constitution) ដែលការផ្លាស់ប្តូរនោះសំរេចទៅបាន តាមវិធីនៃការ**អនុម័តច្បាប់ពិសេស ជាធម្មតាមួយតែប៉ុណ្ណោះ** ។ រាល់ច្បាប់ដែលអនុម័តនោះ ធ្វើឡើងដោយផ្ទុកនូវបទដ្ឋានធម្មនុញ្ញ (គេហៅថាច្បាប់ធម្មនុញ្ញ) ការផ្លាស់ប្តូរ ឬក៏ដាក់បន្ថែមទៅលើបញ្ញត្តិចាស់ ឬថ្មី ដែលបញ្ញត្តិនោះធ្វើនិយ័តកម្ម ឬមិនធ្វើនិយ័តកម្មដោយច្បាប់ធម្មតា ។ ការផ្លាស់ប្តូររដ្ឋធម្មនុញ្ញពុំមែនមានលក្ខណៈងាយស្រួលនោះទេ ព្រោះការផ្លាស់ប្តូររដ្ឋធម្មនុញ្ញគឺវាប្រព្រឹត្តទៅបានតាម**សណ្តាប់ធ្នាប់មួយច្បាស់**

**លាស់** ។ ការផ្លាស់ប្តូរតាមសណ្តាប់ធ្នាប់នេះ គេឃើញមាននៅប្រទេសអង់គ្លេស. អ៊ីស្រាអែល និង ញ៉ូស៊ីឡែន ប្រទេសទាំងនេះបានផ្លាស់ប្តូរច្បាប់គ្រឹះរបស់ខ្លួន**ដោយអន្លើៗ** រីឯប្រទេសខ្លះទៀតផ្លាស់ប្តូរជាផ្នែកៗតែម្តង ។ តែក៏មានប្រទេសខ្លះពុំបានអនុវត្តដែរ ដូចជាលក្ខន្តិកៈនៃព្រះរាជា ឆ្នាំ ១៨៤៨ របស់ស្តេច**ការលូ អាល់ប៊ែរត៍** នៃប្រទេស**អ៊ីតាលី**, រដ្ឋធម្មនុញ្ញ**ម៉ូណាកូ** ឆ្នាំ ១៩១១ ។ល។ គឺមានន័យថាស្តេចទាំងនោះពុំអនុវត្តត្រឹមត្រូវ តាមនីតិវិធីនៃការផ្លាស់ប្តូររដ្ឋធម្មនុញ្ញនោះទេ ដែលរដ្ឋធម្មនុញ្ញរបស់ប្រទេសនេះមានលក្ខណៈជាក្រមផងនោះ ។

**ខ.រដ្ឋធម្មនុញ្ញតឹងរ៉ឹង** : គឺជារដ្ឋធម្មនុញ្ញ ដែលច្បាប់តំរូវឱ្យផ្លាស់ប្តូរបានដោយមានល័ក្ខខ័ណ្ឌ ។ ចំពោះការផ្លាស់ប្តូររដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសខ្លះមាន**លក្ខណៈតឹងរ៉ឹង** និងតាមសណ្តាប់ធ្នាប់នៃនីតិវិធីមួយយ៉ាងហ្មត់ចត់បំផុត ។ ដូចជារដ្ឋធម្មនុញ្ញប្រទេសអ៊ីតាលី ដើម្បីធ្វើការផ្លាស់ប្តូររដ្ឋធម្មនុញ្ញបានត្រូវតែមានការពិភាក្សាជាប់គ្នា ២ ដង ក្នុងរដ្ឋសភាក្នុងរយៈពេលជាប់គ្នាមិនតិចជាង ៣ ខែទេ ហើយត្រូវមានការយល់ព្រមក្នុងការបោះឆ្នោតជាលើកទី ២ តំរូវឱ្យទទួលបានសំលេងគាំទ្រភាគច្រើនដាច់ខាតក្នុងសភានីមួយៗ ។ ប្រសិនបើសំលេងភាគច្រើនដាច់ខាតនោះពុំបានគាំទ្រ ២/៣ ក្នុងសភានីមួយៗទេ នោះតំរូវឱ្យមានការគាំទ្រ ១/៥ នៃសមាជិកសភាណាមួយក៏បាន ហើយបើទាក់ទិននឹងពលរដ្ឋតំរូវឱ្យមានអ្នកបោះឆ្នោតគាំទ្រយ៉ាងតិចចំនួន ៥០០.០០០ អ្នកបោះឆ្នោត ឬក៏តំរូវឱ្យមានការគាំទ្រ ៥ ក្រុមប្រឹក្សាតំបន់ ទើបអាចទាមទារឱ្យធ្វើប្រជាមតិក្នុងការផ្លាស់ប្តូររដ្ឋធម្មនុញ្ញបាន ។ រីឯប្រជាមតិនោះនឹងដាក់ឱ្យប្រជាជនបោះឆ្នោត ចាំបាច់ត្រូវតែមានការយល់ព្រមភាគច្រើននៃសំលេងបោះឆ្នោត ។ មានន័យថា លុះត្រាតែមានការគាំទ្រភាគច្រើនដាច់ខាតពីការបោះឆ្នោត ទើបចាត់ទុកការធ្វើប្រជាមតិនោះបានជោគជ័យ ។

ការផ្លាស់ប្តូររដ្ឋធម្មនុញ្ញមានលក្ខណៈតឹងរ៉ឹងមួយទៀត ដូចជារដ្ឋធម្មនុញ្ញ**កម្ពុជា** ១៩៩៣ **មាត្រា ១៥១** "ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់រដ្ឋធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភាតាមមតិភាគច្រើន ពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល"។ **មាត្រា ១៥២** "ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឱ្យធ្វើនៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦"។ **មាត្រា ៨៦** "ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ រដ្ឋសភា មានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាតិ ។

បើរដ្ឋសភាមិនអាចប្រជុំបានទេដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកំលាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

នៅពេលដែលប្រទេសជាតិឋិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ" ។ **មាត្រា ១៥៣** "ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ"។ នៅក្នុងពេលខ្លះនៃមាត្រាខាងលើនេះបានហាមឃាត់មិនឱ្យធ្វើការកែប្រែរដ្ឋធម្មនុញ្ញ ដោយស្ថានភាពនយោបាយ ឬក៏ព្រឹត្តិការណ៍ដែលកើតមាននាំឱ្យប៉ះពាល់ដល់របបគ្រប់គ្រង។ នៅក្នុងកាលៈទេសៈណាមួយ គេអាចធ្វើការកែតំរូវនូវមាត្រាខ្លះៗនៃរដ្ឋធម្មនុញ្ញបានដែរ ដែលគេច្រើនហៅថា**ធ្វើវិសោធនកម្មនៃរដ្ឋធម្មនុញ្ញ** ពីព្រោះតែមាត្រានៃរដ្ឋធម្មនុញ្ញនោះ វាពុំបានធ្វើនិយ័តកម្មទៅលើទំនាក់ទំនងណាមួយច្បាស់លាស់ក្នុងសង្គម ឬក៏បទដ្ឋាននៃមាត្រានោះធ្វើនិយ័តកម្មដែរ តែផ្តល់សិទ្ធិតិចពេកមិនសមស្របនឹងការវិវត្តន៍របស់សង្គម ។

ការផ្លាស់ប្តូរនៃរដ្ឋធម្មនុញ្ញមានលក្ខណៈតឹងរ៉ឹងនេះ វាជាបច្ច័យមួយសំរាប់ទប់ស្កាត់នូវអំពើទំនើងចិត្តនៃអ្នកដែលមានអំណាចជាន់ខ្ពស់ ដែលមានមុខងារក្នុងច្បាប់កំពូលនេះ ។ តែជាការមួយកាន់តែបញ្ជាក់ទៀតនោះ នៅក្នុងប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ ការសើរើរដ្ឋធម្មនុញ្ញគឺផ្អែកផ្តាក់ទៅលើ**គោលការណ៍ ២ យ៉ាង** ដែលសំខាន់គឺ : **ការផ្តើមគំនិតរបស់ប្រជាជន** និង**ការធ្វើប្រជាមតិ**ទៅលើការផ្តើមគំនិតទាំងនោះ ។ ការផ្តើមគំនិតរបស់ប្រជាជនពុំសូវមានច្រើនទេ គឺមាន

តិចតួចណាស់ ដូចមាត្រា ៧១ រដ្ឋធម្មនុញ្ញអ៊ីតាលីកំណត់ថា : លទ្ធភាពជាទំរង់មួយក្នុងទិដ្ឋភាពពង្រាងច្បាប់នៃការផ្តើមគំនិតរបស់ប្រជាជន តាមការសើរើនៃរដ្ឋធម្មនុញ្ញ គឺថាពង្រាងច្បាប់នោះអាចធ្វើឡើងបានដោយមានអ្នកបោះឆ្នោតមិនតិចជាង ៥០ ពាន់នាក់ឡើយ ដើម្បីគាំទ្រទៅលើគំនិតនោះ ទើបរដ្ឋសភានឹងលើកយកទៅពិនិត្យ ។ ចំណែកប្រទេសអូទ្រីស្តវិញ ការផ្តើមគំនិតសើរើរដ្ឋធម្មនុញ្ញតាមរយៈប្រជាជន តំរូវឱ្យមានអ្នកមានសិទ្ធិបោះឆ្នោតយ៉ាងតិច ១០០ ពាន់នាក់ ( មាត្រា ៤១ នៃច្បាប់គ្រឹះ) ។

នៅក្នុងការផ្លាស់ប្តូររដ្ឋធម្មនុញ្ញបែបតឹងរ៉ឹងនោះ សំរាប់ប្រទេសសហព័ន្ធតំរូវឱ្យមានការយល់ព្រមជាដំបូងពីសមាជិកសហព័ន្ធសិន ទើបមានការអនុញ្ញាតិយកទៅពិភាក្សាលើសំណើនោះ ដូចជាសហរដ្ឋអាមេរិក **ការកែតំរូវណាមួយនៃរដ្ឋធម្មនុញ្ញ** ចាត់ទុកថាបានទទួលជោគជ័យ លុះត្រាតែសំណើនោះមានការយល់ព្រមពីសមាជិកនៃសភានីមួយៗ ⅔ និងសភានីតិបញ្ញត្តិនៃរដ្ឋជាសមាជិកក្នុងចំនួន ¾ នៃចំនួនរដ្ឋទាំងអស់ គឺមាន ៣៨ រដ្ឋយ៉ាងតិច ។

ជាទូទៅ ក្នុងប្រទេសជាច្រើនការផ្លាស់ប្តូររដ្ឋធម្មនុញ្ញ ច្រើនធ្វើឡើងដោយមានការចូលរួមជាចាំបាច់បំផុតពីប្រមុខរដ្ឋ ពីព្រោះថា ជានិច្ចកាលប្រមុខរដ្ឋជាអ្នកប្រកាសនូវការធ្វើវិសោធនកម្មនោះ ។ នៅក្នុងលក្ខណៈខ្លះក៏មានបែបបទខុសពីនេះដែរ ដូចជាប្រទេសអ៊ីតាលី ប្រធានាធិបតីមិនអាចបញ្ជូនសេចក្តីព្រាងច្បាប់ទៅឱ្យរដ្ឋសភាពិនិត្យពិភាក្សាឡើងវិញបានទេ ត្រង់ចំនុចនេះបញ្ជាក់ថាគាត់ពុំបានចូលរួមឡើយ ។ ផ្ទុយទៅវិញប្រមុខរដ្ឋប្រទេសខ្លះ ដូចជាប៊ែលស៊ិក. ដាណឺម៉ាក. ហូឡង់ គាត់អាចបដិសេធមិនទទួលយល់ព្រមចុះហត្ថលេខា លើការប្រកាសអំពីច្បាប់នោះបាន តាមដំបូន្មានរដ្ឋាភិបាល ។

## ៣. ការលប់ចោលនៃរដ្ឋធម្មនុញ្ញ

ការលប់ចោលនៃរដ្ឋធម្មនុញ្ញ ពុំមានទាក់ទិននឹងការផ្លាស់ប្តូរ ឬក៏ចង់និយាយអំពី**រដ្ឋធម្មនុញ្ញតឹងរ៉ឹង** ឬក៏រដ្ឋធម្មនុញ្ញបំរែបំរួលនោះទេ ។

ប៉ុន្តែការលប់ចោលនៃរដ្ឋធម្មនុញ្ញ គឺជាការលប់ចោលក្នុងលទ្ធផលនៃការធ្វើបដិវត្តន៍ណាមួយនៃសង្គម ឬរដ្ឋនៅក្នុងប្រទេសនីមួយៗនោះ ។ ដោយឡែកច្បាប់ចាស់ទាំងឡាយដែលមានបទដ្ឋានរបស់វា ច្រើនតែធ្វើនិយ័តកម្មទៅលើទំនាក់ទំនងសង្គម ដោយការពារផលប្រយោជន៍មហាជន ឬក៏ពង្រីងលទ្ធិប្រជាធិបតេយ្យ នោះគេពុំអាចបង្កើតបទដ្ឋានថ្មីធ្វើការកែប្រែទៅលើបទដ្ឋានចាស់នោះឡើយ ដូចជា**មាត្រា ១៥៨** រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ចែងថា "ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានបទដ្ឋានថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទបញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ" ។ ចំនុចនៃមាត្រានេះបញ្ជាក់ថា រដ្ឋធម្មនុញ្ញកម្ពុជាពុំបាននិយាយត្រង់ទៅចំពោះច្បាប់គ្រឹះពីមុនៗដែលត្រូវលប់ចោលនោះទេ ។ ក៏ប៉ុន្តែរដ្ឋធម្មនុញ្ញខ្លះដែលមានពីអតីតកាល ហើយត្រូវបានសង្គមផ្លាស់ប្ដូរនោះ ការលុបចោលរដ្ឋធម្មនុញ្ញនោះត្រូវធ្វើឡើងទាំងស្រុងតែម្ដង គឺមានន័យថាត្រូវប្រើរដ្ឋធម្មនុញ្ញថ្មីជំនួសរដ្ឋធម្មនុញ្ញចាស់ គឺការផ្លាស់ប្ដូរគតិយុត្តិរបស់វា ដូចជា**មាត្រា ១៣៧** រដ្ឋធម្មនុញ្ញ***បែលសិក*** កំណត់ថា "រដ្ឋធម្មនុញ្ញ (ច្បាប់គ្រឹះ) ពីថ្ងៃទី ២៥ ខែសីហា ឆ្នាំ ១៨១៥ ត្រូវលប់ចោល" ។

សរុបទៅការលប់ចោលនៃរដ្ឋធម្មនុញ្ញ ឬច្បាប់គ្រឹះអាចធ្វើឡើងដោយទាំងស្រុង ឬដោយអន្លើៗទៅលើមាត្រា ឬក៏យ៉ាងណានោះ ត្រូវធ្វើឱ្យសមស្របនឹងតំរូវការជាក់ស្ដែង ប៉ុន្តែពុំមែនជាសកម្មភាពតាមទំនើងចិត្តរបស់អ្នកនយោបាយនោះទេ ។

## ការសន្និដ្ឋាន

ការអនុម័ត, ការផ្លាស់ប្ដូរ, ការលប់ចោលនៃរដ្ឋធម្មនុញ្ញ វាជាការវិវត្តន៍មួយនៃកំលាំងនយោបាយសង្គម ដើម្បីឆ្ពោះទៅរកស្ថេរភាពសង្គម សេដ្ឋកិច្ច នយោបាយ ។ ការវិវត្តន៍នេះវាបញ្ជាក់នូវតថភាពនៃប្រវត្តិសាស្ត្រសង្គម, រដ្ឋ, ច្បាប់, នៃសហគមន៍ជនជាតិនីមួយៗដែលមានក្នុងពិភពលោក ។

រដ្ឋធម្មនុញ្ញជាច្បាប់គ្រឹះសំរាប់ឱ្យច្បាប់ ឬបទដ្ឋានដទៃទៀតធ្វើសកម្មភាពស្របនឹងច្បាប់គ្រឹះនោះ ។ ដូចនេះ ដើម្បីផ្លាស់ប្តូរទៅលើច្បាប់គ្រឹះនេះ គឺពុំមែនពឹងផ្អែកទៅលើការប្រើកំលាំងណាមួយចេញពីកងកំលាំងប្រដាប់អាវុធនោះទេ ប៉ុន្តែការផ្លាស់ប្តូរវាបានដោយសន្តិវិធី គឺត្រូវពឹងផ្អែកពីកំលាំង**ប្រជាពលរដ្ឋភាគច្រើន** ហើយសេចក្តីផ្តើមគំនិតនោះត្រូវតែដាក់ជូនធ្វើ**ប្រជាមតិ**ពីពលរដ្ឋទូទៅ។ ប៉ុន្តែក្នុងកាលៈទេសៈខ្លះ ការផ្លាស់ប្តូរបញ្ញត្តិនៃរដ្ឋធម្មនុញ្ញធ្វើឡើងតាមរយៈអ្នកតំណាងពលរដ្ឋតែប៉ុណ្ណោះ ដោយអ្នកនយោបាយទាំងនោះយល់ថា ពួកគាត់ត្រូវបានប្រជាពលរដ្ឋគាំទ្ររួច ហើយដូចនេះពួកគាត់មានសិទ្ធិរុះរើច្បាប់គ្រឹះតាមចិត្តដែលខ្លួនយល់ឃើញ ។ ប៉ុន្តែអ្នកនយោបាយគួរយល់ថាការដែលប្រជាពលរដ្ឋគាំទ្រនោះ គឺចង់បានតំណាងរបស់ពលរដ្ឋទៅអនុវត្តតាមច្បាប់គ្រឹះ តែពុំមែនបោះឆ្នោតគាំទ្រតំណាងពលរដ្ឋ ដើម្បីឱ្យអ្នកនយោបាយទាំងនោះទៅរំលោយរដ្ឋធម្មនុញ្ញ ដោយគ្មានការផ្តើមគំនិតពីប្រជាជន តាមការកំនត់ចំនួនណាមួយនោះទេ ។

ដើម្បីទប់ស្កាត់នូវការរុះរើរដ្ឋធម្មនុញ្ញតាមទំនើងចិត្តនេះ ទើបប្រទេសមួយចំនួនប្រើប្រាស់ល័ក្ខខ័ណ្ឌតាមការផ្តើមគំនិតពីពលរដ្ឋភាគច្រើន (ឬចំនួនកំណត់ណាមួយពីសមាជិកសហព័ន្ធ) ហើយដាក់ឱ្យធ្វើប្រជាមតិទៅលើគំនិតនោះ ដូចជាប្រទេស : អ៊ីតាលី, សហរដ្ឋអាមេរិក, អូទ្រីស្ត, ស្វីស, ស៊ុយអែដ .....។ល។ ដែលប្រទេសទាំងនេះបានកំរិតយ៉ាងតឹងរ៉ឹង ក្នុង**ការសើរើ**ធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ដោយប្រើ**នីតិវិធី**ខុសៗគ្នាក្នុងការរៀបចំអនុម័តនៃសេចក្តីព្រាង និងការធ្វើសច្ចានុម័ត ឬប្រកាសឱ្យប្រើជាដើម ។

**អត្ថបទទី ៦**

# វគ្គិករណ៍ ឬចំណាត់ថ្នាក់នៃរដ្ឋធម្មនុញ្ញ

## ១. គោលការណ៍នៃការចាត់ថ្នាក់

រដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសក្នុងលោក គេអាចសំគាល់ឃើញនូវលំដាប់ថ្នាក់ជាច្រើន តាមប្រភេទនៃខ្លឹមសារ និងទ្រង់ទ្រាយរបស់វាដែលក្នុងនោះមាន :

**ក. គោលការណ៍ទំរង់ក្រៅនៃរដ្ឋធម្មនុញ្ញ** : ការចាត់ថ្នាក់របៀបនេះ រដ្ឋធម្មនុញ្ញគឺជាការកំណត់មួយនៃលំដាប់ថ្នាក់លើរដ្ឋធម្មនុញ្ញ នូវលក្ខណៈរដ្ឋធម្មនុញ្ញបែប**ប្រឌិត** ឬ**មិនប្រឌិត** ។ លក្ខណៈដ៏ធំទូលាយនៃសមាសធាតុ ( ធាតុផ្សំ) របស់រដ្ឋធម្មនុញ្ញបែបនេះ ច្រើនស្ថិតក្នុងវង្វង់នៃបញ្ហាទាំងឡាយដែលត្រូវធ្វើនិយ័តកម្មដោយរដ្ឋធម្មនុញ្ញក្នុងនោះគឺ សញ្ញាណទំរង់ក្រៅទាំងឡាយនៃច្បាប់ទាំងនោះ ( ច្បាប់គ្រឹះ) ដែលផ្តល់លទ្ធភាព និងធ្វើការចាត់ថ្នាក់លើរដ្ឋធម្មនុញ្ញ ( ច្បាប់គ្រឹះ) បាន ។ មានន័យថា គេពិនិត្យលើ**ទំរង់ក្រៅ**នៃរដ្ឋធម្មនុញ្ញ ។

គោលដៅសំខាន់បំផុតនៃការចាត់ថ្នាក់នោះ គឺចំណាត់ថ្នាក់**ធម្មនុញ្ញគតិយុត្តិ** ដែលបង្ហាញអំពីហេតុការណ៍ពិតណាមួយក្នុងសង្គម ហើយត្រូវមានសកម្មភាព តែជាការពិតគ្រាន់តែចែងត្រឹមត្រូវតាមច្បាប់គ្រឹះ ប៉ុន្តែមិនអនុវត្ត ។ ជាធម្មតាគេចាត់ទុករដ្ឋធម្មនុញ្ញគតិយុត្តិនេះ គ្រាន់តែជាឧបករណ៍មួយប៉ុណ្ណោះ ដែលឱ្យឈ្មោះថា**រដ្ឋធម្មនុញ្ញប្រឌិត** ឬ**រដ្ឋធម្មនុញ្ញមិនពិត**តែប៉ុណ្ណោះ ។ ពីព្រោះថារដ្ឋធម្មនុញ្ញប្រឌិតវាច្រើនតែបទដ្ឋានរបស់វាមានលក្ខណៈគតិយុត្តិភាគច្រើន តែធាតុពិតរបស់វាបទដ្ឋាននោះពុំបានយកទៅសមិទ្ធិ ឬក៏ពុំមានកើតឡើងក្នុងសង្គមរបស់គេឱ្យគ្រប់គ្រាន់នោះទេ ដែលត្រង់នេះបញ្ជាក់ថា វាគ្រាន់តែប្រឌិតបិទភ្នែកមហាជនតែប៉ុណ្ណោះ ។

ដូចនេះការចាត់ថ្នាក់តាមខ្លឹមសារនៃទំរង់រដ្ឋធម្មនុញ្ញនេះ វាស្តែងចេញឱ្យឃើញនូវភាពប្រឌិតច្បាប់មួយសំរាប់សង្គម ។

**ខ.គោលការណ៍ទំរង់ក្នុងនៃរដ្ឋធម្មនុញ្ញ** : នេះគឺជាការចាត់ថ្នាក់នៃរដ្ឋធម្មនុញ្ញ ដោយផ្អែកលើរចនាសម្ព័ន្ធ ឬការសាងសង់នូវលក្ខណៈផ្ទៃក្នុងនៃរដ្ឋធម្មនុញ្ញ ។ គោលដៅវាក្នុងលក្ខណៈនេះ គឺផ្អែកលើបណ្តុំនៃច្បាប់ទាំងឡាយ. រចនាសម្ព័ន្ធ និងទំរង់នៃរដ្ឋធម្មនុញ្ញ ។ ទោះបីជាមានការចាត់ថ្នាក់ទៅលើរដ្ឋធម្មនុញ្ញក៏ដោយ ក៏រដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗពុំមានលក្ខណៈដូចគ្នាតែមួយនោះទេ ពីព្រោះថាគោលដៅនៃរដ្ឋធម្មនុញ្ញគឺស្របនឹងរបបនយោបាយ ឬឆន្ទៈនៃបុគ្គលគ្រប់គ្រងរដ្ឋ និងប្រជាជននៃសម័យកាលនីមួយៗ ។

ការសិក្សាទៅលើរដ្ឋធម្មនុញ្ញភាគច្រើន គឺបង្ហាញថាបញ្ញត្តិមួយចំនួនធំក្នុងរដ្ឋធម្មនុញ្ញមួយ ពុំអាចអនុវត្តបាននៅក្នុងសង្គមជាក់ស្តែងឡើយ ។ នេះជាកត្តាមួយបង្ហាញថា រដ្ឋធម្មនុញ្ញនោះគ្រាន់តែបំរើឱ្យជាសំភារៈរបស់ពលរដ្ឋប៉ុណ្ណោះ រីឯការពិតនៃខ្លឹមសារទាំងនោះពុំបានប្រើប្រាស់ឡើយ ។ ការបន្លំភ្នែកដោយគ្រាន់តែចែងឱ្យបានល្អនៅក្នុងច្បាប់គ្រឹះនេះ ធ្វើឡើងតាមរូបភាពពីរគឺ ***រូបភាពផ្ទាល់ :*** គឺជាទិដ្ឋភាពមួយដែលរដ្ឋធម្មនុញ្ញបានចែងត្រង់ៗរួចហើយ តែអ្នកមានភារកិច្ចពុំរវីរវល់ ដូចជា**មាត្រា ១៤៨** នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំនត់ថា **ត្រូវមានសមាជជាតិម្តងក្នុងមួយឆ្នាំ** តែការអនុវត្តពិតនោះពុំបានធ្វើតាមមាត្រានេះឡើយ ។ ការបន្លំភ្នែកតាមរូបភាពទីពីរនេះ គឺជាទិដ្ឋភាពបែបអរូបី នូវរាល់សកម្មភាពរបស់អ្នកមានអំណាចរដ្ឋជាន់ខ្ពស់ ។ លក្ខណៈរបៀបនេះ គឺថ្វីត្បិតតែសកម្មភាពជាក់ស្តែង បានធ្វើតាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញហើយក៏ពិតមែន ប៉ុន្តែការសំរេចផលទៅលើខ្លឹមសារតាមបញ្ញត្តិនោះពុំបានលទ្ធផលច្រើនទេ ។ ជាឧទាហរណ៍ ដូចជា**មាត្រា ១២៨** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា **អំណាចតុលាការជាអំណាចឯករាជ្យ** ប៉ុន្តែអំណាចតុលាការនេះត្រូវប្រគល់ទៅឱ្យសាលាជំរះក្តីគ្រប់ផ្នែក និងគ្រាប់ជាន់ថ្នាក់ ។ ភាពពិតរបស់វាគេបានឃើញកើតមានតុលាការពិតប្រាកដមែន តែនីតិវិធីក្នុងការធ្វើឱ្យឯករាជ្យដាច់ចេញពីអំណាចដទៃ ក្នុងក្របខ័ណ្ឌនៃវិជ្ជាជីវៈនោះ សឹងតែពុំមានផលគ្រប់គ្រាន់ឡើយ ។ ត្រង់នេះបញ្ជាក់ថា **នីតិវិធីធ្វើឱ្យឯករាជ្យ** វាជារឿងមួយមានការលំបាកបំផុត ព្រោះអ្នកមានអំណាចរដ្ឋជាន់ខ្ពស់សុទ្ធតែចង់ធ្វើសកម្មភាពតាម

ច្បាប់ ដើម្បីឱ្យច្បាប់ការពារទៅពួកគេវិញដោយស្ងាត់ស្ងៀមបំផុត តែតាមការពិតគេកំពុងបំពានច្បាប់តាមលក្ខណៈអរូបីរួចទៅហើយ ។

នីតិវិធីដែលធ្វើឱ្យឯករាជ្យតាមច្បាប់ដែលបានចែងនេះហើយ ធ្វើឱ្យប្រទេសក្លាយជានីតិរដ្ឋពិតប្រាកដនោះ ។

ដូចនេះ គោលការណ៍សំខាន់ៗក្នុងការចាត់ថ្នាក់នៃរដ្ឋធម្មនុញ្ញ គឺសំដៅទៅលើលក្ខណៈប្រឌិត ឬមិនប្រឌិត ( រដ្ឋធម្មនុញ្ញពិត) តែប៉ុណ្ណោះ ។

## ២. រដ្ឋធម្មនុញ្ញបណ្ដោះអាសន្ន និងរដ្ឋធម្មនុញ្ញអចិន្ត្រៃយ៍

ជាទូទៅ ដោយយោងលើសកម្មភាពគតិយុត្តិដែលចូលជាធរមាននៃរដ្ឋធម្មនុញ្ញ ឬច្បាប់គ្រឹះទាំងឡាយរបស់រដ្ឋនៃប្រទេសគ្រប់សម័យកាលរហូតដល់បច្ចុប្បន្ននេះមក រដ្ឋធម្មនុញ្ញទាំងនោះច្រើនមានសកម្មភាពតាមការកំណត់**ថេរវេលា**ច្បាស់លាស់ ។ សកម្មភាព ឬអំពើទាំងនោះវាមានលក្ខណៈ**កំរិត** ឬ**គ្មានកំរិត**នៃថេរវេលានោះទេ មានន័យថាបើបទបញ្ញត្តិខ្លះ ឬបទបញ្ញត្តិទាំងមូលនៃរដ្ឋធម្មនុញ្ញដែលគេកំរិតឱ្យធ្វើសកម្មភាពតាមថេរវេលា នោះហៅថា**រដ្ឋធម្មនុញ្ញបណ្ដោះអាសន្ន** តែបើគេពុំកំរិតពេលវេលានោះគេហៅថា**រដ្ឋធម្មនុញ្ញអចិន្ត្រៃយ៍** ។

**ក.រដ្ឋធម្មនុញ្ញបណ្ដោះអាសន្ន** : ជារដ្ឋធម្មនុញ្ញដែលអនុម័តឡើងដោយឈរលើរយៈពេលកំនត់មួយ ឬហៅថាថេរវេលា ឬក៏រង់ចាំការមកដល់នៃព្រឹត្តិការណ៍កំណត់មួយ ។ ជាឧទាហរណ៍ ទៅលើលក្ខណៈនេះដូចជារដ្ឋធម្មនុញ្ញ**ថៃឡង់ដ៍** ឆ្នាំ១៩៥៩ ដោយក្នុងនោះរួមមាន ២០ មាត្រា ដែលមានលក្ខណៈបណ្ដោះអាសន្ន សំរាប់ឱ្យរដ្ឋធម្មនុញ្ញនោះធ្វើសកម្មភាព រហូតដល់មានការដាក់ចេញនូវពង្រាងរដ្ឋធម្មនុញ្ញអចិន្ត្រៃយ៍មួយដោយសភាបញ្ញត្តិ ( ជាសភាដែលបង្កើតមកសំរាប់បង្កើតច្បាប់គ្រឹះណាមួយ ហើយគេរំលាយវាទៅវិញ ឬហៅថា*សភាធម្មនុញ្ញ* Constituent Assembly) ។

**ខ.រដ្ឋធម្មនុញ្ញអចិន្ត្រៃយ៍** : ជារដ្ឋធម្មនុញ្ញដែលបទបញ្ញត្តិរបស់វាមានសកម្មភាព ពុំមានពេលកំណត់ណាមួយនោះទេ ។ គួរបញ្ជាក់ដែរថា រដ្ឋធម្មនុញ្ញដែលមានលក្ខណៈមិនកំណត់រយៈពេល ឬ

ហៅថា**រដ្ឋធម្មនុញ្ញអចិន្ត្រៃយ៍** នេះសកម្មភាព ឬអំពើរបស់វាច្រើនតែពុំបានធានានូវភាពយូរអង្វែង នៃរដ្ឋធម្មនុញ្ញនោះទេ ព្រោះបទដ្ឋានទាំងឡាយរបស់វា មិនបានធ្វើនិយ័តកម្មគ្រប់ជ្រុងជ្រោយនៃ ទំនាក់ទំនងសង្គមក្នុងបច្ចុប្បន្ន និងអនាគតកាលផងដែរ ។ ព្រោះថាមាត្រាខ្លះនៃរដ្ឋធម្មនុញ្ញចាស់អាច ទុកប្រើប្រាស់បាន ឬក៏បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញថ្មីបាន តែជួនកាលមាត្រាខ្លះទៀតដែលភាគច្រើននៃ រដ្ឋធម្មនុញ្ញចាស់នោះពុំអាចយកមកប្រើបាន ឬដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញថ្មីបានទេ ដូចជាក្នុងករណី **ផ្លាស់ប្តូររបបនយោបាយ**ជាដើម។ ផ្ទុយទៅវិញ ការមិនកំរិតពេលនៃសកម្មភាពរបស់រដ្ឋធម្មនុញ្ញ ឬ ហៅថា**រដ្ឋធម្មនុញ្ញអចិន្ត្រៃយ៍** នោះវាបញ្ជាក់នូវទំរង់ ឬ**ចេតនាផ្ទាល់របស់នីតិករ** ក្នុងពេលបង្កើត វាតែប៉ុណ្ណោះ ។ ជាឧទាហរណ៍នូវលក្ខណៈរបៀបនេះ រដ្ឋធម្មនុញ្ញនៃរដ្ឋជាច្រើននៅ**អាមេរិកឡាទីន** ដែលគេហៅថា "**រដ្ឋធម្មនុញ្ញលោតផ្លោះ** (Constitutional Leap-frog)" ដែលការប្តូរនៃរដ្ឋ ធម្មនុញ្ញជាច្រើនលើកច្រើនសារនោះ លេចចេញពីបាតុភូតរដ្ឋប្រហារយោធា ដូចក្នុងពាក់កណ្តាល ទស្សវត្សរ៍ ៦០ ប្រវត្តិសាស្ត្រនៃប្រទេសមួយចំនួន ដូចជា**បូលីវី** (Bolivia) មានរដ្ឋធម្មនុញ្ញចំនួន ២០ **កូឡុមប៊ី** ចំនួន ១១, **ហាយទី** ចំនួន ២៣ និង**វេណេស៊ុយអេឡា** ចំនួន ២២ ។ល។ នេះបញ្ជាក់ថា គ្រាន់តែរយៈពេលដ៏ខ្លីប៉ុណ្ណោះ ប្រទេសទាំងនេះបានផ្លាស់ប្តូររដ្ឋធម្មនុញ្ញចំនួនដ៏ច្រើនលើសលប់។ ប៉ុន្តែ យើងអាចដឹងរួចទៅហើយ រដ្ឋធម្មនុញ្ញភាគច្រើនលើសលុបនោះ បានកំណត់នូវ**ភាពមិនអាចផ្លាស់ ប្តូរបាន** តែគេអាចធ្វើការកែប្រែនូវបទដ្ឋាន ឬមាត្រាខ្លះៗ ដើម្បីឱ្យស្របទៅនឹងសភាពការណ៍ ក្នុងសង្គមរបស់គេ ។ ជាក់ស្តែងរដ្ឋធម្មនុញ្ញម៉ិកស៊ិកូ ឆ្នាំ ១៩១៧ រហូតមកដល់បច្ចុប្បន្ននេះបានធ្វើ វិសោធនកម្មដ៏ច្រើនលើសលុប ថែមទាំងអនុម័តរាប់រយដងទៀតផង ។ ក៏ប៉ុន្តែសំរាប់រដ្ឋធម្មនុញ្ញខ្លះ ទៀតបទដ្ឋានរបស់វាបានហាមប្រាមដាច់ខាត គឺមានន័យថាមិនអនុញ្ញាតិឱ្យមានការកែប្រែទៅលើ មាត្រានេះ ឬនោះបានទេ ។ តែទោះជាការហាមឃាត់យ៉ាងនេះក្តី ក៏យើងពុំអាចដឹងថាតើពេលខាង មុខ ឬកាលៈទេសៈណាមួយនោះវានឹងទៅជាយ៉ាងណានោះទេ ដូចជា**មាត្រា ៧** នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានចែងថា "ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាច ឡើយ ។

ព្រះមហាក្សត្រទ្រង់ជាប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ " ។

ប៉ុន្តែ**មាត្រា ១៧** បានកំរិតថា "ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញនេះ**មិនអាចសុំកែប្រែបានជាដាច់ខាត**"។ តែចំពោះរដ្ឋធម្មនុញ្ញក្រិច ឆ្នាំ ១៩៧៥ បានកំណត់នូវការបំរែបំរួលនៃរដ្ឋធម្មនុញ្ញទាំងមូលនៅវាក្យខ័ណ្ឌទី ៤ នៃ**មាត្រា ១២០** ថា "ការប្រតិបត្តិនៃបញ្ញត្តិទាំងឡាយរបស់រដ្ឋធម្មនុញ្ញ ត្រូវបានធានាដោយអ្នកស្នេហាជាតិក្រិចទាំងអស់ ដែលអ្នកទាំងនោះត្រូវបានផ្តល់អំណាចឱ្យប្រឆាំងរាល់មធ្យោបាយទាំងអស់នៃរាល់ការប៉ងប្រាថ្នា លុបចោលរដ្ឋធម្មនុញ្ញតាមវិធីប្រើកំលាំង"។

ឆន្ទៈរបស់នីតិករមួយទៀតបានសំដែងក្នុង**មាត្រា ១៥៣** រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ថា "ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ"។ និងបដិសេធតែម្តង តាមមាត្រា ១៥២ ក្នុងពេលដែលប្រទេសមានការវឹកវរ ។ លក្ខណៈអចិន្ត្រៃយ៍នៃរដ្ឋធម្មនុញ្ញនេះ បើសិនជាហាមឃាត់ខ្លាំងពេក ធ្វើឱ្យមានរដ្ឋប្រហារប្រើកំលាំងផ្លាស់ប្តូររដ្ឋធម្មនុញ្ញបានផងដែរ ។

## ៣. ចំណាត់ថ្នាក់តាមខ្លឹមសារ និងតាមលក្ខណៈគតិយុត្តិគ្រឹះនៃរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញមានគំរូច្រើនបែបច្រើនយ៉ាងណាស់ ហើយវាបង្ហាញនូវសញ្ញាណផ្សេងៗគ្នាទៀតផង ដែលសញ្ញាណទាំងនោះត្រូវបានកំនត់ដោយរដ្ឋធម្មនុញ្ញមួយច្បាស់លាស់ ។ ជាទូទៅ ចំណាត់ថ្នាក់នៃរដ្ឋធម្មនុញ្ញធ្វើឡើងតាមគោលការណ៍មួយចំនួនដែលទាក់ទិននឹង :

**ក.តាមរបបនយោបាយ** : រដ្ឋធម្មនុញ្ញនៃរដ្ឋទាំងឡាយនៅលើលោកយើងនេះ បានចារឹកដោយស្វ័យប្រវត្តិនូវគោលការណ៍គ្រឹះណាមួយ ដូចជា**របបប្រជាធិបតេយ្យ** (Democratic), របប**អំណាចនិយម** (Authoritarian) និងរបប**លិទ្ធិផ្តាច់ការ** (Totalitarian) ។ របបទាំងនេះតែងបានកំណត់

យកដោយផ្ទាល់ ឬប្រយោលក្នុងរដ្ឋធម្មនុញ្ញ ដើម្បីគ្រប់គ្រងប្រទេស ។ ការចង់បានរបបណាមួយនោះ វាអាស្រ័យនឹងការវិវត្តន៍នៃឆន្ទៈរបស់សមាជិកនៃសង្គមតែប៉ុណ្ណោះ ដោយឈរលើ :

**ក១. គោលការណ៍លទ្ធិប្រជាធិបតេយ្យ** : នេះគឺរដ្ឋធម្មនុញ្ញកំណត់នូវសិទ្ធិ និងសេរីភាព ដែលមានទំហំធំធេងក្នុងក្របខ័ណ្ឌជាក់លាក់ និងអនុញ្ញាតិឱ្យបង្កើតដោយសេរីនូវសកម្មភាព មានអាណត្តិច្បាស់លាស់ ។ ដូចមាត្រា ៥១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានចែងថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើប្រាស់អំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។

**ក២.គោលការណ៍អំណាចនិយម** : ចំពោះរដ្ឋធម្មនុញ្ញ ដែលមានចំណាត់ថ្នាក់ក្នុងលក្ខណៈអំណាចនិយមនេះបានត្រូវកំណត់ ឬហាមឃាត់ នូវសកម្មភាពទាំងឡាយនៃ**កំលាំងនយោបាយ** ឬរដ្ឋកំណត់ឱ្យមានបក្សនយោបាយតែមួយ ដូចជារដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសកាន់លទ្ធិសង្គមនិយមជាដើម ។ លក្ខណៈនៃគោលការណ៍នេះបានបិទបាំង ឬក៏បើកឡើងនូវការលប់ចោលទាំងស្រុងនូវការប្រកាសសិទ្ធិ និងសេរីភាពឱ្យមានទំហំធំធេងបាននោះទេ ។ ផ្ទុយទៅវិញក្នុងរបបកុម្មុយនីស្តរដ្ឋធម្មនុញ្ញរបស់គេបានកំណត់នូវសិទ្ធិ និងកាតព្វកិច្ចដែលជាលក្ខណៈប្រជាធិបតេយ្យដែរ តែធាតុពិតរបស់គេគឺពុំមានសកម្មភាពទេ គឺការសរសេរលើច្បាប់គ្រឹះនោះ គ្រាន់តែជាគោលដៅបិទបាំងសំរាប់លទ្ធិផ្តាច់ការរបស់គេតែប៉ុណ្ណោះ ។ ដូចនេះគោលការណ៍អំណាចនិយមកើតមានក្នុងរបបស្តេច ឬរបបសាធារណៈរដ្ឋនិយមខ្លះ ដូចជាប្រទេសអ៊ីរ៉ាក់ ជាដើម ប៉ុន្តែគោលការណ៍អំណាចនិយមនេះ**ពុំប្រកាន់យកលទ្ធិណាមួយជាគោល**នោះទេ គឺធ្វើតាមតែទំនើងចិត្តរបស់ថ្នាក់ដឹកនាំដែលជាប្រមុខរដ្ឋនៃបណ្តាប្រទេសសុក្រឹត្យណាមួយនោះតែប៉ុណ្ណោះ ។

**ក៣. គោលការណ៍នៃលទ្ធិផ្តាច់ការ** : ចំពោះគោលការណ៍នៃលទ្ធិផ្តាច់ការនេះ រដ្ឋធម្មនុញ្ញរបស់គេបានសរសេរនូវការបិទបាំង ឬក៏បានផ្តល់សិទ្ធិដែរ តែគ្មានសកម្មភាពទេ ឬគេអនុវត្តតាមមនោគមវិជ្ជានៃអ្នកណាម្នាក់ដែលបានដឹកនាំក្នុងសង្គមរបស់គេ ដោយប្រកាន់**យកលទ្ធិណាមួយ**ជាដាច់ខាតសំរាប់ជាត្រីវិស័យ ដូចជារបបកុម្មុយនីស្តដើរតាមលទ្ធិម៉ៅនិយម ឬសង្គមនិយម ។ល។

**ខ.តាមទំរង់គ្រប់គ្រង** : ទំរង់គ្រប់គ្រងនៃប្រទេសនីមួយៗ ត្រូវបានចារឹកដោយរដ្ឋធម្មនុញ្ញរបស់គេ ដើម្បីកំណត់នូវសណ្តាប់ធ្នាប់នៃការដាក់បញ្ចូល**មុខងារនៃប្រមុខរដ្ឋ** និងបែងចែកនូវទំរង់គ្រប់គ្រង**បែបរាជានិយម ឬប្រធានាធិបតីនិយម, ឬសាធារណរដ្ឋ** ។ល។ គឺទាំងអស់នេះហើយដែលវាអាស្រ័យទាំងស្រុងទៅលើទំរង់**របនាសម្ព័ន្ធ**គ្រប់គ្រងរដ្ឋ ក្នុងនោះមានដូចជា :

**ខ១. រដ្ឋឯកភូត** (Unitar State) : រដ្ឋរបៀបនេះ រដ្ឋធម្មនុញ្ញបានកំណត់ដែនដីរដ្ឋបាលរបស់ខ្លួនដែលស្ថិតនៅក្រោមរដ្ឋបាលកណ្តាល ដូចជារដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ **មាត្រា ៣** កំណត់ថា "ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន" ។ រីឯ**មាត្រា ១៤៥** "ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និងក្រុង ។

ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់" ។ **មាត្រា ១៤៦** "ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ" ។ និងពិសេសទៀតកំណត់នូវរបបគ្រប់គ្រងដូចជា**មាត្រា ១** "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជាជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ" ។ **មាត្រា ៥១** រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានបញ្ជាក់នូវវាក្យខ័ណ្ឌចុងក្រោយថា ".......អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។ **មាត្រា ១០** "របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។

ព្រះមហាក្សត្រទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរាជ្ជទាយាទ សំរាប់គ្រងរាជសម្បត្តិឡើយ" ។

**ខ២. រដ្ឋសហព័ន្ធ**(Federation) : រដ្ឋរបៀបនេះ រដ្ឋធម្មនុញ្ញបានកំណត់ទៅលើរដ្ឋទាំងឡាយដែលជាសមាជិករបស់ខ្លួន។ មានដូចជាប្រទេស**អាមេរិក** ប្រទេស**ប្រេស៊ីល អាល្លឺម៉ង់ ឥណ្ឌា រុស្ស៊ី អូទ្រីស្ត មិកសិក្ស** ។ល។ ដែលរដ្ឋជាសមាជិកនោះពុំមានឯករាជ្យដាច់ពីគ្នាបានទេ ។ ក្រៅពីនេះនៅមានរដ្ឋជាសមាគតរដ្ឋ (Confederation) ទៀតផង តែរដ្ឋរបៀបនេះកើតមានជាបណ្តោះអាសន្នតែប៉ុណ្ណោះ ។ រដ្ឋមានលក្ខណៈសមាគតរដ្ឋនេះ សមាជិករបស់វាសុទ្ធតែជារដ្ឋឯករាជ្យរៀងៗខ្លួន តែមានលក្ខណៈសមាហរណកម្មលើវិស័យសេដ្ឋកិច្ចតែប៉ុណ្ណោះ ។

## ៤. ចំណាត់ថ្នាក់ផ្សេងៗទៀត

យើងបានដឹងរួចមកហើយចំណាត់ថ្នាក់នៃរដ្ឋធម្មនុញ្ញ ប៉ុន្តែក៏មានចំណាត់ថ្នាក់ផ្សេងៗទៀតដែរ ដែលចំណាត់ថ្នាក់នោះអាស្រ័យនឹងសណ្តាប់ធ្នាប់នៃ**ការអនុម័តរដ្ឋធម្មនុញ្ញ** គឺរដ្ឋធម្មនុញ្ញដែលមានលក្ខណៈ**ទាយជ្ជទាន** និងលក្ខណៈ**ប្រជាជន** ។

រដ្ឋធម្មនុញ្ញដែលមានលក្ខណៈនៃការអនុម័តបែបទាយជ្ជទាននោះ គឺកើតមានក្នុងប្រទេសណេប៉ាល់ និងប្រទេសមួយចំនួន ដែលជាអតីតអាណានិគមចក្រភពអង់គ្លេស ។ រីឯចំណាត់ថ្នាក់រដ្ឋធម្មនុញ្ញតាមលក្ខណៈប្រជាជននោះ គឺយើងបានដឹងហើយ គឺជាលក្ខណៈប្រជាធិបតេយ្យពិតៗ ។

**ដូចនេះអត្ថន័យនៃរដ្ឋធម្មនុញ្ញ**, ដែលយើងបានសិក្សានូវសណ្តាប់ធ្នាប់ នៃការផ្លាស់ប្តូររដ្ឋធម្មនុញ្ញរួចហើយនោះគេបានចែកវាជាប្រភេទ : **បំរែបំរួល**, **តឹងរ៉ឹង**, និងចំរុះ រីឯក្នុងចំណោមប្រភេទតឹងរ៉ឹងនោះ ចែកជាប្រភេទតឹងរ៉ឹងពិសេស ដូចជានៅប្រទេសអាមេរិកជាដើម ។ រីឯទំរង់នៃរដ្ឋធម្មនុញ្ញ មានរដ្ឋធម្មនុញ្ញ**សំណេរ គ្មានសំណេរផងដែរ** ។

ទោះជាមានការចាត់ថ្នាក់បានខ្លះៗហើយក្តី ក៏រដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសទាំងអស់ក្នុងលោកយើងនេះ ពុំទាន់មានសណ្តាប់ធ្នាប់បង្កើតវាបានតាមក្របខ័ណ្ឌដូចៗគ្នានោះដែរ ពីព្រោះថាវាអាស្រ័យនឹងការវិវត្តនៃឆន្ទៈរបស់ប្រជាពលរដ្ឋ និងអ្នកនយោបាយ ។ នៅពេលខ្លះច្បាប់ចែងបានត្រឹមត្រូវ តែឆន្ទៈអ្នកនយោបាយពុំបានអើពើធ្វើសកម្មភាពតាមច្បាប់នោះឡើយ ។ នៅក្នុងល័ក្ខខ័ណ្ឌនេះ បើឆន្ទៈ

របស់ប្រជាពលរដ្ឋ ពុំពេញចិត្តនឹងទង្វើរបស់អ្នកនយោបាយ ចំពោះការអនុវត្តច្បាប់តំរូវឱ្យមានការជ្រើសរើស ឬក៏ពេលខ្លះអាចធ្វើឱ្យកំលាំងសង្គមត្រូវបរាជ័យ ចំពោះឆន្ទៈអ្នកនយោបាយក៏មានផងដែរ ។

ដូចនេះអ្នកនយោបាយ និងពលរដ្ឋត្រូវតែមានឆន្ទៈស្របគ្នាដោយយកច្បាប់ជាគោល ឬជាត្រីវិស័យទើបរដ្ឋនោះបញ្ជាក់ថា ជាប្រទេសថ្កុំថ្កើងគោរពច្បាប់គ្រឹះ ។

## អនុបធនទី ៧

# អត្ថន័យគ្រឹះទូទៅនៃឋានៈធម្មនុញ្ញគតិយុត្តិនៃមនុស្ស និងពលរដ្ឋ

## ១. សិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ

សិទ្ធិរបស់មនុស្សត្រូវបានពិចារណាយ៉ាងយកចិត្តទុកដាក់បំផុត ព្រោះវាជាមូលដ្ឋានគ្រឹះមួយដ៏ចាំបាច់នៃរដ្ឋធម្មនុញ្ញនិយម (Constitutionalism) ។ គំនិតដ៏សំខាន់ក្នុងន័យខាងលើនេះ គឺមានគោលដៅតែមួយគត់សំរាប់បង្កើតឱ្យមានរដ្ឋធម្មនុញ្ញ ដែលក្នុងនោះបានចារឹកនូវបទដ្ឋានជាក់លាក់ស្តីពីក្រុមអ្នកមានអំណាចរដ្ឋ ដើម្បីឱ្យពួកគេធ្វើសកម្មភាពក្នុងក្របខ័ណ្ឌជាក់លាក់[២១] ។

គំនិតអំពី**សេរីភាព** និង**ស្មើភាពគ្នា**របស់មនុស្សមានតាំងពីកំណើត ដែលពុំអាចផ្តាច់បាន (ច្បាប់ធម្មជាតិ) ដែលគំនិតទាំងនេះបានចារឹកក្នុងច្បាប់រដ្ឋធម្មនុញ្ញមួយចំនួន ដោយរដ្ឋធម្មនុញ្ញទាំងនោះបានអនុម័តឡើងក្នុងអំឡុងពេលបដិវត្ត នា**សតវត្សរ៍ទី** XVII-XVIII នៃបណ្តាប្រទេសមួយចំនួនដូចជានៅ**អង់គ្លេស អាមេរិក** និង**បារាំង** ជាដើម ។ ក្រោយមកទៀតក៏គ្មានរដ្ឋណាមួយ ដែលមានទំនោរកាន់លទ្ធិប្រជាធិបតេយ្យនោះអាចសរសេរក៏រិតណាមួយ អំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួនបានឡើយ ។ ទោះជាយ៉ាងណាក្តី ក៏សិទ្ធិមនុស្សត្រូវបានបន្សល់ទុកដោយ**ទំលាប់នយោបាយអាជ្ញាបញ្ញាមួយ** គឺថាវាបានប្រកាន់យកនូវទំរង់គតិយុត្តិមួយ ដែលបានក្លាយជាស្ថាប័នគ្រឹះមួយដ៏សំខាន់បំផុតនៃ**នីតិរដ្ឋធម្មនុញ្ញ** និងនៅចុងក្រោយបង្អស់ សិទ្ធិមនុស្សនេះបានក្លាយជាស្ថាប័នគ្រឹះមួយ (Institution) ដ៏ទូលាយនៃ**នីតិអន្តរជាតិ** (International law) ទៀតផង ។

---

[២១]. ពលរដ្ឋជាប្រភពនៃការបង្កើតច្បាប់គ្រឹះ (រដ្ឋធម្មនុញ្ញ) ។ សិទ្ធិ និងសេរីភាព របស់ពលរដ្ឋត្រូវបានកំណត់នៅក្នុងច្បាប់គ្រឹះនោះ រួមទាំងសកម្មភាពនានារបស់អ្នកនយោបាយ ឬអ្នកដឹកនាំរដ្ឋទៀតផង ។

គួរបញ្ជាក់ថា ពាក្យស្មើភាពគ្នាពុំមានលក្ខណៈដូចគ្នានោះទេ សំរាប់សមាជិកនៃសង្គម ។ យើងពិនិត្យមើលសង្គមពីរគឺ **សង្គមពលរដ្ឋ** និង**សង្គមនយោបាយ** ។ សមាជិកនៃសង្គមពលរដ្ឋ (មនុស្សទូទៅ) មនុស្សស្មើភាពគ្នាជាមួយនឹងអ្វីៗគ្រប់យ៉ាង ប៉ុន្តែសមាជិកនៃសង្គមនយោបាយគឺមានន័យថាសមាជិកនៃសង្គមគ្រប់គ្រងរដ្ឋ (អ្នកមានអំណាចរដ្ឋ) ដែលមនុស្សនោះស្មើភាពគ្នាចំពោះតែនរណាដែលសង្គមបានផ្តុកផ្តាក់ទៅរដ្ឋពិតប្រាកដមួយ នូវដែនកំនត់ណាមួយនៃរាល់សកម្មភាពរបស់ពួកគេ ។ ជាឧទាហរណ៍ បើលោក "ក" ជាតំណាងរាស្ត្រ គាត់មានសិទ្ធិរស់នៅ ឬក៏ស្មើភាពគ្នាចំពោះមុខច្បាប់ដូចពលរដ្ឋដទៃទៀតដែរ ប៉ុន្តែគាត់មានអភ័យឯកសិទ្ធិ និងកាតព្វកិច្ច និងករណីកិច្ចមិនដូចពលរដ្ឋដទៃទៀតឡើយ ។ ដូច្នេះហើយបានជានៅក្នុងរដ្ឋធម្មនុញ្ញត្រូវកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ថ្នាក់ដឹកនាំនៃរដ្ឋរបស់គេនីមួយៗ ។ នៅឆ្នាំ ១៧៨៩ ប្រតិវេទ៍បារាំង (Declaration) ទៅលើសិទ្ធិមនុស្ស និងពលរដ្ឋ ដែលមានខ្លឹមសារថា "**មនុស្សទាំងអស់កើតមក និងផ្ទុកនូវសេរីភាព និងស្មើភាពគ្នាចំពោះមុខច្បាប់ ។ ភាពផ្សេងៗគ្នាជាសាធារណៈ អាចបង្កើតនូវការពិចារណានៃផលប្រយោជន៍ទូទៅ .......... គោលដៅនៃរដ្ឋសម្ព័ន្ធភាពនីមួយៗផ្ទុកនូវការផ្តត់ផ្តង់នូវសិទ្ធិរបស់មនុស្សដែលពុំអាចបំបែកបានពីធម្មជាតិ (ច្បាប់ធម្មជាតិរបស់មនុស្ស) ទាំងអស់នោះមានសេរីភាព កម្មសិទ្ធិ, សន្តិសុខ, ទប់ស្កាត់នូវការជិះជាន់សង្កត់សង្កិន**" ។ ក្នុងរដ្ឋធម្មនុញ្ញជាច្រើនបានទុកដាក់សិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ តាមរូបមន្តជាច្រើន ដោយអាស្រ័យនឹងមាត្រាទាំងនោះ (មើលរូប ៥) ។ ដូចជាគេប្រើពាក្យថា "**រៀងរាល់**" "**ទាំងអស់**" "**គ្រប់មនុស្ស**" "**គ្មាននរណា**" "**គ្មាននរណាម្នាក់**" សំរាប់សិទ្ធិមនុស្ស។ រីឯសិទ្ធិរបស់ប្រជាពលរដ្ឋគេប្រើពាក្យថា "**ពលរដ្ឋទាំងអស់មានសិទ្ធិ**" "**ពលរដ្ឋនោះអាច**"។ល។ សិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ បានត្រូវចារឹកក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ តាម**មាត្រា ៣១** ថា "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទិនទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌ សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងច្បាប់" ។ និង**មាត្រា ៣២** "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវមានឡើយ" ។ **មាត្រា ៣៣** "ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិនិរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ" ។ **មាត្រា ៤៤** "ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវ័ន្តបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតំរូវឱ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌" ។ សិទ្ធិ និងសេរីភាពទាំងនេះបានកំណត់យ៉ាងជាក់លាក់ក្នុងរដ្ឋធម្មនុញ្ញ ដើម្បីការពារនូវរាល់ការបំពាននានាពីពួកអ្នកមានអំណាចរដ្ឋ ។

## ២. ប្រវត្តិសាស្ត្រនៃការវិវត្តន៍លើសិទ្ធិ និងសេរីភាព

ការវិវត្តន៍ជាប្រវត្តិសាស្ត្រចំពោះសិទ្ធិ និងសេរីភាពរបស់មនុស្ស អ្នកស្រាវជ្រាវបានចែកជាបីជំនាន់ (Generation) គឺ[២២] :

---

[២២]. Constitutional law of foreign Country. Page 68. M 1994 ។

**ក.ជំនាន់ទីមួយ** : គឺជាតួលេខដំបូង នៃការលេចចេញនូវប្រភពនៃរដ្ឋធម្មនុញ្ញនិយម ។ មានន័យថា ជារដ្ឋធម្មនុញ្ញដំដំបូងបំផុតដែលបានចារឹកនូវ**វិស័យមួយ** ដែលក្នុងនោះមានសញ្ញាណគ្រឹះក្នុងការកំណត់ក្រុមពីរគឺ**សិទ្ធិ** និង**សេរីភាព** ក្នុងល័ក្ខខ័ណ្ឌសង្គមពលរដ្ឋ និងសង្គមនយោបាយ ។ នេះគឺជាសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋ ដែលត្រូវបានចារឹកក្នុងរដ្ឋធម្មនុញ្ញ ដូចជារដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំនត់នៅក្នុង**មាត្រា ៣២** ថា "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ" ។ មាត្រានេះបញ្ជាក់នូវសិទ្ធិមនុស្ស រីឯមាត្រាបញ្ជាក់នូវសិទ្ធិ និងសេរីភាពពលរដ្ឋនោះ ដូចជា**មាត្រា ៣៣** "ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិនិរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ..........." ។ និងកំណត់ក្នុង**មាត្រា ៣៤** ថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត" ។

ផ្ទុយទៅវិញ សិទ្ធិ និងសេរីភាពក្នុង**សង្គមនយោបាយ** ដូចជាសិទ្ធិចូលរួមនិមិត្តកម្មនានាក្នុងសង្គមមានសេរីភាពនៃការនិយាយស្តី ឬក៏សំណើផ្សេងៗរបស់ពលរដ្ឋ បានកំណត់ក្នុង**មាត្រា ៣៥** ថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ, សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ពលរដ្ឋនឹងត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ "។ និងក្នុង**មាត្រា ៤០** បានកំណត់អំពីសិទ្ធិតាំងលំនៅដ្ឋានដោយបានចែងថា "សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរ អាចចេញទៅតាំងទីលំនៅនៅក្រៅប្រទេស ឬវិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅដ្ឋាន និងអាថ៌កំបាំងនៃការឆ្លើយតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទត្រូវបានធានា ។

ការឆែកឆេរលំនៅដ្ឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គល ត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់"។ រីឯការបញ្ចេញមតិ និងបោះពុម្ពត្រូវបានកំនត់ក្នុង**មាត្រា ៤១** "ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនាមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសាពត៌មានត្រូវរៀបចំឡើងដោយច្បាប់"។ ចំពោះសិទ្ធិធ្វើសកម្មភាពនយោបាយ បានកំណត់ក្នុង**មាត្រា ៤២** ថា "ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធិផលជាតិ និងសណ្តាប់ធ្នាប់សង្គម "។

ដូចនេះ ជំនាន់ទីមួយនេះ រដ្ឋនិមួយៗបានចារីកនូវ**តំលៃរបស់មនុស្ស** ដែលជា**ប្រភពនៃអំណាចគ្រប់គ្រងរដ្ឋ**ទាំងមូល ដោយចាត់ទុករដ្ឋជាទ្រព្យសំរាប់សមាជិកសង្គមទាំងមូល ពុំមែនជារបស់អ្នកណាម្នាក់ឡើយ (សំរាប់ជាតិនិមួយៗ) ។

**ខ.ជំនាន់ទីពីរ** : គឺក្នុងពាក់កណ្តាលសតវត្សរ៍ទី XX ក្នុងយុគនេះ រដ្ឋធម្មនុញ្ញបានកំណត់នូវ**សិទ្ធិ** និង**សេរីភាព** ទៅលើវិស័យ**សេដ្ឋកិច្ច. សង្គម** ដែលបានធានានូវផលប្រយោជន៍រួម ដូចជា

សិទ្ធិចំពោះការងារ ដែលផ្សារភ្ជាប់នូវការធានារ៉ាប់រងលើពលកម្មទាំងនេះ សិទ្ធិបង្កើតស្នាដៃ ដូចជា វិទ្យាសាស្ត្រ, វប្បធម៌..... ។ល។ ដូចជា**មាត្រា ៦៥** នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ចែងថា "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កំរិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហាន១ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប......"។ និង**មាត្រា ៦៧** ចែងថា "រដ្ឋអនុវត្តន៍កម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស......."។ និង**មាត្រា ៦៩** កំនត់ថា "រដ្ឋមានកាតព្វកិច្ចថែរក្សា និងពង្រីកវប្បធម៌ជាតិ ។

រដ្ឋមានកាតព្វកិច្ចការពារ និងពង្រីកភាសាខ្មែរឱ្យសមស្របនឹងសេចក្តីត្រូវការ ។

រដ្ឋមានកាតព្វកិច្ចថែរក្សា និងការពារប្រាសាទបុរាណវត្ថុ និងសិល្បៈបុរាណ និងកែលំអររមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ"។ ផ្នែកសេដ្ឋកិច្ចក្នុង **មាត្រា ៥៦** "ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះនឹងមានកំណត់ក្នុងច្បាប់"។ និង**មាត្រា ៣៦** បានកំណត់ថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នា នឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំនឹងការប្រព្រឹត្តិទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់"។ មាត្រា ៦០, ៦២, ៦៣, ៦១ ជាដើម ។ សិទ្ធិដែលបានកំណត់ក្នុងជំនាន់ទីពីរនេះ គឺផ្តល់លទ្ធភាពឱ្យពលរដ្ឋមាន**សិទ្ធិក្នុងការរកស៊ី និងកម្មសិទ្ធិ** ។

**ឥ.ជំនាន់ទីបី :** វាជាបញ្ហាទូទៅមួយ ដែលកើតមានក្នុងចុងពាក់កណ្តាលសតវត្សរ៍ទី XX ។ មុខងារសំខាន់ដែលចារឹកក្នុងរដ្ឋធម្មនុញ្ញ គឺ**បញ្ហាបរិស្ថានវិទ្យា** (Ecology) ជាពិសេសក្នុងរដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសដែលជឿនលឿនក្នុងសម័យយើងនេះ ។ ដោយសារមានបញ្ហាទាំងនេះ គេបានផ្តល់សិទ្ធិលើមធ្យោបាយសុខភាពដែលនៅជុំវិញខ្លួន. សិទ្ធិលើសារពតិមាន..........។ល។ ជាក់ស្តែងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់**មាត្រា ៧២** ថា "សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ និងព្យាបាលជំងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគ ដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។

រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ" ។ ក្នុង**មាត្រា ៧៤** "រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ" ។ និង**មាត្រា ៥៩** "រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ភោគោត្តសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល" ។ នៅក្នុងជំនាន់ទីបីនេះ រដ្ឋធម្មនុញ្ញបានផ្តល់លទ្ធភាពក្នុងការ**ការពារបរិស្ថាន** និង**សុខភាព** ដើម្បីជៀសវាងការបំពានពីអំពើល្មើសរបស់មនុស្សផ្សេងៗ ។

## ៣. សិទ្ធិ និងសេរីភាព

ពាក្យថាសិទ្ធិ និង**សេរីភាព** វាមានលក្ខណៈលំបាកនឹងញែកឱ្យដាច់ណាស់ ។ ប៉ុន្តែក្នុងកាលៈទេសៈខ្លះសិទ្ធិវាជាព្រំដែននៃសេរីភាព ។ រីឯសេរីភាពវាក៏ត្រូវមានច្បាប់សំរាប់កំណត់វាដែរ ដែល**មាត្រា ៣១** នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើម

កំណើត ជាតិឋានៈ សង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់" ។ តាមទ្រឹស្តីនៃនីតិសាស្ត្រ (Theory of law) បានកំណត់ថា **សិទ្ធិវាជាធាតុអត្តវិស័យ** ដែលផ្តល់ឱ្យអត្តា ឬបុគ្គលគ្រប់រូបសំរាប់ជា**ខ្នាតកំរិតនូវចរិត**នៃលទ្ធភាពរបស់បុគ្គល ។ ដូចជា**មាត្រាទី ២១** រដ្ឋធម្មនុញ្ញអ៊ីតាលី បានកំណត់ថា "ទាំងអស់គ្នាមានសិទ្ធិសំដែងគំនិតរបស់ខ្លួនដោយសេរី ដែលមានលក្ខណៈជាផ្ទាល់មាត់ ឬសរសេរ និងគ្រប់មធ្យោបាយផ្សេងៗទៀតនៃការបញ្ចេញគំនិត" ។ ដូចនេះសិទ្ធិជាទំហំនៃសេរីភាព ដែលបានកំណត់ដោយបទដ្ឋាននានារបស់រដ្ឋ ។ នៅប្រទេសខ្លះសិទ្ធិ និងសេរីភាពត្រូវបានកំរិតឱ្យមានសកម្មភាពតិច តែកាតព្វកិច្ចច្រើន ។

## ៤. សិទ្ធិ សេរីភាព និងភាតព្វកិច្ច

សិទ្ធិ, សេរីភាព វាជាវិន័យមួយដែលមានបណ្តាញទំនាក់ទំនងគ្នារវាងសិទ្ធិ និងសេរីភាពរបស់មនុស្ស និងពលរដ្ឋ ឯជ្រុងម្ខាងទៀតគឺកាតព្វកិច្ចរបស់វា ក្នុងទំនាក់ទំនងចំពោះមនុស្សផ្សេងទៀត ចំពោះសង្គម និងរដ្ឋ ។ កាតព្វកិច្ចវាជាទំរង់គតិយុត្តិមួយតាមទ្រឹស្តីនៃនីតិសាស្ត្រ គឺជា**ខ្នាតនៃចរិតចាំបាច់** ត្រង់នេះគឺថាមនុស្សត្រូវតែឋិតនៅក្រោមវិន័យកំរិតមួយ សំរាប់ក្នុងករណីប្រើប្រាស់សិទ្ធិ និងសេរីភាពរបស់គេ ពុំអាចគេចកែនូវទង្វើព្យសនកម្មចំពោះមនុស្សដទៃ ហើយក៏ពុំអាចធ្វើជាលក្ខណៈធម្មតាបានដែរ ក្នុងករណីមានព្យសនកម្មនោះ ។ ជាឧទាហរណ៍ **មាត្រា ១៣** វាក្យខ័ណ្ឌទី ១ រដ្ឋធម្មនុញ្ញស្លូវ៉ាគី ១៩៩២ កំណត់ថា "កាតព្វកិច្ចទាំងអស់អាចកំណត់បានត្រឹមតែនៅលើគ្រឹះមួយ នៃច្បាប់នៅក្នុងក្របខ័ណ្ឌទាំងឡាយរបស់វា ក្នុងករណីដែលប្រតិបត្តិនូវសិទ្ធិសំខាន់ៗ និងសេរីភាព" និង **មាត្រាទី ៤៩** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានសរសេរថា "ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។ ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់" ។

## ៥. មធ្យោបាយនាំចេញនៃរូបមន្តធម្មនុញ្ញក្នុងការសម្រិទ្ធិលើសិទ្ធិ សេរីភាព និងកាតព្វកិច្ច

ដោយសិទ្ធិ. សេរីភាព និងកាតព្វកិច្ចជាបណ្តាញប្រទាក់គ្នា នោះគេអាចចែកមធ្យោបាយនៃ**រូបមន្តធម្មនុញ្ញជាពីរផ្នែក** ដើម្បីងាយស្រួលរៀបចំយ៉ាងជាក់លាក់ ក្នុងការសំរេចឱ្យបាននូវសិទ្ធិ. សេរីភាព និងកាតព្វកិច្ច ។ មធ្យោបាយនោះគឺ**វិជ្ជមាន** និង**អវិជ្ជមាន** ។

**ក.មធ្យោបាយវិជ្ជមាន** : ជាមធ្យោបាយមួយដែលរដ្ឋធម្មនុញ្ញកំនត់ ឬក៏ផ្ទៀងផ្ទាត់ថាអត្តា (បុគ្គល) មានសិទ្ធិកិរិតច្បាស់លាស់ជាក់ស្តែងក្នុងកិរិតណាមួយ ។ លក្ខណៈរបៀបនេះមានច្រើនប្រភេទក្នុងការកិរិតទៅលើពលរដ្ឋទូទៅ ដូចជា**មាត្រា ៧៤** បានកំណត់ថា "រដ្ឋជួយឧបត្ថម្ភជនពិការ និងគ្រួសារយុទ្ធជនដែលបូជាជីវិតដើម្បីប្រទេសជាតិ" ។ ដូចនេះក្នុងមាត្រានេះប្រជាពលរដ្ឋ គឺជនពិការ និងគ្រួសារអ្នកដែលបាត់បង់ជីវិតក្នុងបុព្វហេតុជាតិមាតុភូមិ ដែលអាចមានសិទ្ធិទទួលយកការឧបត្ថម្ភពីរដ្ឋ។ ដូច្នេះមធ្យោបាយនេះ វាគួសបញ្ជាក់ត្រង់តែម្តងក្នុងមាត្រានៃច្បាប់គ្រឹះ ដើម្បីប្រើប្រាស់សិទ្ធិរបស់បុគ្គល ។ ប៉ុន្តែតាមគោលការណ៍នៃមធ្យោបាយនេះ ក៏ពុំមានលក្ខណៈគួសបញ្ជាក់ត្រង់ដែរ ដូចជាមាត្រា ២៤ វាក្យខ័ណ្ឌទី ១ រដ្ឋធម្មនុញ្ញរ៉ូម៉ានី បានកំណត់ស្រាប់ គឺថាពុំបានសរសេរពីពាក្យ**បុគ្គល**នៅក្នុងមាត្រានេះទេ ប៉ុន្តែអត្ថន័យរបស់វាគឺផ្តល់សិទ្ធិទៅឱ្យពលរដ្ឋក្នុងល័ក្ខខ័ណ្ឌណាមួយ រួចស្រេចទៅហើយ ។ មាត្រានេះបាននិយាយកាត់ដោយមិនបានប្រាប់នូវអត្តា ឬបុគ្គលទេ "សិទ្ធិចំពោះការការពារត្រូវបានធានា" ។ នេះជារូបមន្តមួយដែលធានាចំពោះមនុស្សគ្រប់រូប ហើយផ្តល់សិទ្ធិគ្រប់គ្រាន់តាមការកំណត់ដោយច្បាប់ ទៅលើទំហំនៃសកម្មភាពដែលបានផ្តល់នោះ ។

**ខ.មធ្យោបាយអវិជ្ជមាន** : ជាមធ្យោបាយដែលរដ្ឋធម្មនុញ្ញកិរិត ឬក៏ហាមឃាត់ទៅគ្រប់បុគ្គលអំពីសិទ្ធិ ឬសេរីភាព ។ នៅក្នុងលក្ខណៈនេះ រដ្ឋធម្មនុញ្ញបានកំនត់នូវសកម្មភាពដោយមធ្យោបាយជាច្រើនប្រភេទ ក្នុងនោះដូច**មាត្រា ៥៤** នៃរដ្ឋធម្មនុញ្ញកម្ពុជាបានសរសេរថា "ការផលិត. ការប្រើប្រាស់. ការរក្សាទុកអាវុធបរមាណូ. អាវុធគីមី ឬអាវុធវេត្រាណូ ត្រូវហាមឃាត់ជាដាច់ខាត" ។ ដូច្នេះមាត្រាខាងលើបានហាមឃាត់ទៅលើសកម្មភាពរបស់បុគ្គលទូទៅ ដែលជាពលរដ្ឋរបស់ខ្មែរ រីឯ**មាត្រា ៤៦** វាក្យខ័ណ្ឌទី ១ បានបង្ហាញថា "អំពើលក់ដូចមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម

និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់"។ ដូចនេះមធ្យោបាយ អវិជ្ជមាន ជាមធ្យោបាយមួយដែលបទដ្ឋានវាហាមឃាត់ទៅលើសកម្មភាពនានារបស់បុគ្គល ។

## ៦. ចំណាត់ថ្នាក់នៃសិទ្ធិ សេរីភាព និងកាតព្វកិច្ចរបស់ពលរដ្ឋ

ចំណាត់ថ្នាក់នៃសិទ្ធិ, សេរីភាព និងកាតព្វកិច្ច វាជាភារៈមួយនៃការអភិវឌ្ឍន៍ទៅលើ**ចរិតគតិយុត្តិ**[៦៣] និង**ប្រព័ន្ធគតិយុត្តិ**នៃប្រទេសនីមួយៗ ។ ដោយយោងទៅលើលក្ខណៈនេះ គេចែកចំណាត់ថ្នាក់វាដូចខាងក្រោម :

**ក.ចំណាត់ថ្នាក់ទូទៅ** : នេះជាចំណាត់ថ្នាក់តាមការបែងចែក**សិទ្ធិមនុស្ស** និង**សិទ្ធិរបស់ពលរដ្ឋ** (សេរីភាព និងកាតព្វកិច្ច) ដែលបានធ្វើឡើងសំដៅគ្រប់សមាជិកនៃសង្គម ឬរដ្ឋរបស់គេទាំងនោះ ។ សិទ្ធិ និងសេរីភាពទាំងនេះ ដូចជា : ការរស់នៅ, សេដ្ឋកិច្ច, នយោបាយ, អប់រំ ...... ។ល។ និងសិទ្ធិ ឬសេរីភាពដទៃទៀតរបស់បុគ្គល ដូចជា**មាត្រា ៣១** នៃរដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់"។

---

[៦៣]. ចរិតគតិយុត្តិ គឺជាសកម្មភាពនៃកិរិយាមាយាទរបស់ពលរដ្ឋ នៃរដ្ឋនីមួយៗ ក្នុងការសំដែងតាមផ្លូវច្បាប់ ឬការគិតតាមផ្លូវច្បាប់ ។

**ខ.ចំណាត់ថ្នាក់ដោយខ្សែក** : ជាចំណាត់ថ្នាក់តាម**លក្ខណៈរបស់បុគ្គល** (អត្តា) នូវសិទ្ធិ សេរីភាព និងកាតព្វកិច្ច ។ មានន័យថាការបែងចែកសិទ្ធិ សេរីភាព និងកាតព្វកិច្ចជាឯកត្តភាព (Individual) និងលក្ខណៈសមូហភាព (Collective)។ ពិតហើយសិទ្ធិឯកត្តបុគ្គលអាចបំពេញនាទីជាសមូហភាពបាន ប៉ុន្តែមានលក្ខណៈខុសពីសិទ្ធិសមាគម (Collective) ត្រង់ថាសិទ្ធិសមាគមពុំមាននាទីជាឯកត្តបុគ្គលបានទេ ឧទាហរណ៍**សិទ្ធិចំពោះកូដកម្ម** វាជាសិទ្ធិរួមគ្នាតែបើមានកូដកម្មឯកជនវាជាលក្ខណៈដើរកំសាន្ត តែពុំមែនកូដកម្មទេ ។ សិទ្ធិរបស់អត្តាក្នុងក្របខ័ណ្ឌឯកត្តភាព ដូចជា**មាត្រា ៣២** ចែងថា "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ..... "។ និង**មាត្រា ៣៣** "ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅប្រទេសក្រៅណាមួយឡើយ......."។ បញ្ហាដ៏ស្មុគស្មាញ ទាក់ទិននឹងសិទ្ធិសេរីភាពជាឯកត្តភាពនេះ ដូចជាការកែសំរួលលេខ II នៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិច បានបញ្ជាក់ថា "...... សិទ្ធិរបស់ពលរដ្ឋលើការរក្សានិងកាន់អាវុធ និងមិនត្រូវបានហាមឃាត់ឡើយ"។ ត្រង់ចំនុចនេះបង្ហាញថាអាវុធ គឺជា**ទ្រព្យ**ដែលអាចផ្ទុកផ្តាក់ទៅលើឯកត្តភាពបានតាម**ធម្មជាតិ**របស់វា ប៉ុន្តែសិទ្ធិនេះពុំបានបញ្ជាក់ថា តើជាសិទ្ធិមនុស្ស ឬសិទ្ធិពលរដ្ឋនោះទេ ។

ចំពោះសិទ្ធិសមូហភាព ប្រធាននៃសិទ្ធិរបៀបនេះរាប់បញ្ចូលបាន ដូចជាការងារសហគមនានា. សហជីព ។ល។ ដែលសិទ្ធិទាំងនេះតាមធម្មជាតិនៃទ្រព្យ (ច្បាប់ធម្មជាតិ) វានាំមកនូវសិទ្ធិទាំងនោះមាន**លក្ខណៈប្រភេទផ្សេងៗ**ពីគ្នានៃក្រុម**ភាគតិច** ។

ជាទូទៅ គេសង្កេតឃើញការកំនត់សិទ្ធិលើសមូហភាពនេះ មានប្រភេទផ្សេងៗដូចជា :

- **ក្រុមជាតិសាសន៍** : នៅក្នុងរដ្ឋនីមួយៗតែងមានជនជាតិខុសៗគ្នា ដែលក្រុមខ្លះមានចំនួនច្រើន រីឯក្រុមខ្លះទៀតមានចំនួនតិច ។ ដូចជានៅប្រទេសកម្ពុជា មានដើមកំនើតខ្មែរ. ចិន. កួយ. សំរែ. ព្នង........។ល។ ចំពោះសិទ្ធិនៃក្រុមរបស់ជាតិនីមួយៗនេះ មានលក្ខណៈផ្សេងៗពីគ្នា ប៉ុន្តែត្រូវគោរពសិទ្ធិរបស់ក្រុមជាតិភាគច្រើន ។ ប៉ុន្តែភាសា. លក្ខណៈពិសេសៗរបស់ក្រុមភាគតិចទាំងនោះត្រូវបានធានា. រក្សាទុកតាមក្រុមនីមួយៗរបស់គេ ។ ជាឧទាហរណ៍ ក្រុមជនដើមកំនើតខ្មែរ

មានភាសា, ទំនៀមទំលាប់ខ្មែរ តែមិនអាចបង្ខំឱ្យជនក្រុមភាគតិច ដូចជាវៀតណាម, ចិន អនុវត្តនូវទំនៀមទំលាប់របស់ក្រុមភាគច្រើនបានទេ ។ ដូចនេះ សិទ្ធិទាំងនេះរបស់អត្តានៃក្រុមនីមួយៗ ពិតជាមានភាពផ្សេងៗពីគ្នា ។

- **ក្រុមនយោបាយ ឬបន្ទុកច្រើន** : នៅក្នុងការអនុម័តធ្វើការងារអ្វីមួយតាមការប្រជុំគេតែងយកសំលេងភាគច្រើនឈ្នះសំលេងភាគតិច ជាឧទាហរណ៍ នៅរដ្ឋសភា ......។ តាម**មាត្រា ៩០** វាក្យខ័ណ្ឌទី ៨ បានចែងថា "រដ្ឋសភា បោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល" ។

ដូចនេះ សិទ្ធិសមូហភាពវាបញ្ជាក់នូវធម្មជាតិនៃទ្រព្យនោះ កើតឡើងក្នុងក្រុមមនុស្សភាគច្រើន ឬតិច ដែលច្បាប់កំនត់ឱ្យពុំមានភាពស្មើគ្នានោះទេ ។

**គ.ចំណាត់ថ្នាក់ពិសេស** : នេះជាចំណាត់ថ្នាក់តាមទ្រឹស្តី និងបំពេញបន្ថែមដែលចំណាត់ថ្នាក់តាមទ្រឹស្តីនេះ ជាភារៈមួយដែលត្រូវកំណត់យ៉ាងច្បាស់លាស់ ដូចជាសិទ្ធិចូលរួមក្នុងការគ្រប់គ្រងរដ្ឋវាជា**សិទ្ធិគ្រឹះ** ចំណែកសិទ្ធិបោះឆ្នោតដែលកើតចេញពីវានោះ គឺជាបាតុភូតទាំងឡាយដែលធ្វើសកម្មភាពតាមអត្ថន័យនៃសិទ្ធិមូលដ្ឋានគ្រឹះតែប៉ុណ្ណោះ ហើយគេហៅថា**សិទ្ធិបំពេញបន្ថែម** ។

សរុបទៅ អត្ថន័យនៃការចាត់ថ្នាក់តាមខ្លឹមសារនៃសិទ្ធិ សេរីភាព និងកាតព្វកិច្ចចែកជា**បីក្រុមសំខាន់ៗ** ដែលផ្អែកតាមចំណាត់ថ្នាក់ទាំងបីខាងលើនោះគឺ :

- **ក្រុមទីមួយ** : គឺជាការកំណត់សកម្មភាពរបស់**អត្តភាព** (ផ្ទាល់ខ្លួន) និងសកម្មភាព**ពលរដ្ឋ** (សញ្ជាតិ) ដែលទាក់ទិននឹងសង្គម ។ សិទ្ធិ សេរីភាព និងកាតព្វកិច្ចនៃក្រុមនេះវាបញ្ជាក់ដូចជាសិទ្ធិរស់នៅជាដើម ។ កាតព្វកិច្ចក្នុងមាត្រា ៤៧, សេរីភាព ៤២, ៤៣ និងតាម**មាត្រា ៣៨** កំណត់ថា "ច្បាប់ការពារមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ..........." ។ មាត្រានេះបញ្ជាក់ពីសិទ្ធិពលរដ្ឋ និងមាត្រា ៣២, ៣១ ....។ល។ វាកំណត់នូវករណីជាច្រើនទៀត ។

- **ក្រុមទីពីរ** : គឺជាការកំណត់សកម្មភាពនយោបាយរបស់បុគ្គល។ **សិទ្ធិ, សេរីភាព និងកាតព្វកិច្ចនៃនយោបាយ** ក្នុងក្រុមទីពីរនេះផ្សារភ្ជាប់នឹងការចូលរួមក្នុងការគ្រប់គ្រងសង្គម និងរដ្ឋ។

ដូចជាសិទ្ធិបោះឆ្នោត**មាត្រា ៣៤** "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត" ។ សេរីភាព និងការប្រមូលផ្តុំ ឬនិម្មិតកម្មសង្គមផ្សេងៗ ដូចក្នុង**មាត្រា ៤៩** "ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តន៏តាមបញ្ញត្តិច្បាប់" ។ និង**មាត្រា ៣៥** "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការត្រួតពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ" ។ និងមាត្រាដទៃទៀត ដែលទាក់ទិននឹងការកំណត់សកម្មភាពចូលរួមគ្រប់គ្រងសង្គម ។

- **ក្រុមទីបី** : គឺជាការកំណត់សកម្មភាពរបស់បុគ្គលលើវិស័យសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ **សិទ្ធិ សេរីភាព និងកាតព្វកិច្ច ក្នុងវិស័យសេដ្ឋកិច្ចសង្គម និងវប្បធម៌**នេះបានកំណត់ដូចជាសិទ្ធិលើពលកម្មជាដើម ។ តាម**មាត្រា ៣៦** បញ្ជាក់ថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នា នឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់សហជីព និងមានកំណត់ក្នុងច្បាប់" ។ មួយវិញទៀត កំណត់នូវសេរីភាពនៃផលិតផលការងារ ដូច **មាត្រា ៦០** កំណត់ថា "ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី ។ ការតំរូវឱ្យលក់ផលិតផលជូនរដ្ឋ ឬការយកភោគផល ឬទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ វៀរលែងតែក្នុងករណីដែលមានច្បាប់អនុញ្ញាតិ " ។ និងសិទ្ធិកម្មសិទ្ធិ **មាត្រា ៤៤** "ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតំរូវឱ្យធ្វើក្នុងករណីដែលច្បាប់បញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌" ។ រីឯសិទ្ធិលើការអប់រំ **មាត្រា ៦៥** "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ពលរដ្ឋក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កំរិត និងត្រូវចាត់វិធានការណ៍គ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានដល់ប្រជាពលរដ្ឋគ្រប់រូប........" ។ និងមានមាត្រាមួយចំនួនទៀត ដូចជា ៦១. ៦២. ៦៣ ............... ដែលកំណត់តាមខ្លឹមសារនៃក្រុមទីបីនេះ ។

## ៧. សមភាពនៃសិទ្ធិ សេរីភាព និងកាតព្វកិច្ច

សមភាពនៃសិទ្ធិ សេរីភាព និងកាតព្វកិច្ចជាការវិវត្តន៍មួយនៃដំណើរការលទ្ធិប្រជាធិបតេយ្យ ដែលប្រឆាំងនឹងរបបផ្តាច់ការក្នុងអតីតកាល ។ ទំរង់សមភាពដែលគេអាចសមិទ្ធិបានតាមរយៈនៃបទដ្ឋានទាំងឡាយ ហើយដែលបានចារឹកក្នុងរដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសផ្សេងៗ នៅលើពិភពលោក ។

**ប៉ុន្តែការតស៊ូឱ្យស្មើភាពគ្នាចំពោះមុខច្បាប់** ពុំមែនជាការងាយស្រួលនោះទេ ។ ដូចជាការប្រកាន់ពូជសាសន៍នៅ**សាធារណរដ្ឋអាហ្វ្រិកខាងត្បូង** ក្នុងអំឡុងទស្សវត្សទី៨០[២៤] និងនៅ**រ៉ូន់ដា** ជាដើម ។ មូលហេតុមួយចំនួនដូចជាសាសនា, អំបូរ, ដើមកំណើត, និងលក្ខណៈពិសេស១ដទៃទៀតនៃជនជាតិបានក្លាយជាប្រភពធ្វើឱ្យមានវិបត្តិ និងឆ្ពោះទៅរកការកែទំរង់សង្គម ដើម្បីឱ្យមានស្ថេរភាព ។ រាល់សកម្មភាពនៃការកែទំរង់ គេបានចារឹកនូវទំនាក់ទំនងទាំងនេះក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់កំពូលនៃប្រទេសរបស់គេ ។ ដូចជា**មាត្រា ៣១** រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ ។

**ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នានៅចំពោះមុខច្បាប់** មានសិទ្ធិសេរីភាព និងករណីយកិច្ច**ដូចគ្នាទាំងអស់ ដោយឥតប្រកាន់**ពូជសាសន៍ ពណ៌ សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់១ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងច្បាប់"។ និង**មាត្រា ៤៥** "ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវលុបបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ "។

---

[២៤]. នៅអាហ្វ្រិកខាងត្បូង ក្នុងពេលនោះជនជាតិស្បែកខ្មៅពុំមានសិទ្ធបោះឆ្នោត ឬធ្វើនយោបាយដើម្បីដឹកនាំប្រទេស ដូចពួកស្បែកសឡើយ ។

## ៨. ការកំរិតនៃសិទ្ធិ និងសេរីភាព

ការកំរិតនៃសិទ្ធិ និងសេរីភាព ជារូបមន្តនៃការសមិទ្ធិនូវបទដ្ឋានទាំងឡាយ ក្នុងទំនាក់ទំនងសង្គម ហើយដែលបទដ្ឋានទាំងនោះបានត្រូវចារឹកក្នុងច្បាប់គ្រឹះ ដូចជា**មាត្រា ៣១** វាក្យខណ្ឌចុងក្រោយនៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់ថា "ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់" ។ ការកំរិតនូវសិទ្ធិ និងសេរីភាព វានាំមកនូវស្ថេរភាពនៃទំនាក់ទំនងសង្គម និងធានាបាននូវប្រព័ន្ធគតិយុត្តិដ៏សុក្រឹត្យ ។ ប្រសិនបើសិទ្ធិ និងសេរីភាពពុំត្រូវបានកំរិតច្បាស់លាស់ទេ នោះនាំឱ្យកើតមានជាស្វ័យប្រវត្តិនូវភាពអានាធិបតេយ្យក្នុងប្រព័ន្ធគតិយុត្តិ ។

## ៩. ការធានាសិទ្ធិ និងសេរីភាព

ការធានាសិទ្ធិ និងសេរីភាព ជាទូទៅគេចែកជា**ពីរក្រុមធំៗ** គឺ**ការធានាផ្ទៃក្នុងរដ្ឋ** និង**ការធានាគតិយុត្តិអន្តរជាតិ** ដែលប្រភេទនីមួយៗត្រូវបំពេញតាមកាតព្វកិច្ចរបស់ខ្លួនយ៉ាងជាក់លាក់ ។

**ក.ការធានាផ្ទៃក្នុងរដ្ឋ** : ជានីតិវិធីមួយធ្វើឡើងតាមរយៈនៃការអនុវត្តន៍គតិយុត្តិ និងការសមិទ្ធិនៃច្បាប់ទាំងឡាយរបស់រដ្ឋផ្ទាល់ ដែលក្នុងនោះគេបានបង្កើតនូវស្ថាប័នគតិយុត្តិគ្រឹះមួយចំនួន ដូចជា **មាត្រា ១៣៦** រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ បានកំណត់ថា "ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា" ។ និង**មាត្រា ១២៨** កំណត់ថា "អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការធានារក្សាអនាគត និងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះត្រូវបានប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់" ។ និង **មាត្រា ៣៨** កំណត់ថា "ច្បាប់រ៉ាប់រង មិនឱ្យមានការរំលោភបំពានលើរូបរាង្គកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទំងន់ទ័ណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធធនាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដៃដល់អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ" ។និងមធ្យោបាយជាច្រើនទៀតដែលកំណត់សណ្តាប់ធ្នាប់ផ្ទៃក្នុង និងទំនាក់ទំនងសេដ្ឋកិច្ចសង្គមរបស់រដ្ឋ ។ល។

**ខ.ការធានាគតិយុត្តិអន្តរជាតិ** : នេះជាបទដ្ឋានដែលផ្ទុកក្នុងច្បាប់កំពូល ស្របនឹងបទដ្ឋានទាំងឡាយនៃធម្មនុញ្ញអន្តរជាតិ ស្តីពីការធានានូវសិទ្ធិ និងសេរីភាពមនុស្ស ដូចជា **មាត្រា ៣១** រដ្ឋធម្មនុញ្ញកម្ពុជាបានសរសេរនូវវាក្យខ័ណ្ឌដំបូងថា "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ ។

នៅមានបទដ្ឋានដ៏ច្រើនទៀតដែលកើតឡើងពីកិច្ចព្រមព្រៀង ដែលបទដ្ឋាននៃកិច្ចព្រមព្រៀងអន្តររដ្ឋនោះ វាធ្វើនិយ័តកម្មទៅលើទំនាក់ទំនង**ផ្ទៃក្នុងរដ្ឋ** ដោយធានាចំពោះអន្តរជាតិ ។ កិច្ចព្រមព្រៀងទាំងនេះមានក្នុងវិស័យច្បាប់សេដ្ឋកិច្ច, នយោបាយ, យោធា, សន្តិភាព......ជាដើម ។

## ១០. សញ្ជាតិ និងរបបជនបរទេស

**ក.និយមន័យនៃសញ្ជាតិ** : គឺជាទំហំសិទ្ធិ និងសេរីភាពដែលមនុស្សម្នាក់ ឬច្រើននាក់ប្រើប្រាស់នៅក្នុងរដ្ឋសុក្រឹត្យមួយ រួមទាំងទំហំនៃកាតព្វកិច្ចដែលត្រូវបានប្រកាសដោយរដ្ឋ ចំពោះមនុស្សនោះទៀតផង ដែលទំហំទាំងនោះវាស្ថិតក្នុងភាពអាស្រ័យដោយផ្ទាល់ពីវត្តមាន ឬអវត្តមាននូវសញ្ជាតិរបស់បុគ្គលនៃរដ្ឋសុក្រឹត្យនោះ ។ (**រូបទី ៦**)

សញ្ជាតិ (Nationality) គឺជាកំលាំងគតិយុត្តិស្ថិតស្ថេរមួយរបស់មនុស្ស ដោយផ្សារភ្ជាប់ជាមួយរដ្ឋរបស់ខ្លួន ( មនុស្ស ) ដែលកំលាំងគតិយុត្តិនោះកំណត់នូវលក្ខណៈនៃសិទ្ធិ និងកាតព្វកិច្ចយ៉ាងសាមញ្ញទៅលើប្រជាពលរដ្ឋ (Citizen) និងរដ្ឋ ក្នុងគ្រប់ល័ក្ខខ័ណ្ឌដែលបានបញ្ជាក់ក្នុងច្បាប់ ។

នៅក្នុងរបបទាសភាពពលរដ្ឋទាំងឡាយ វាមានលក្ខណៈគ្រាន់តែជាមនុស្សសេរី ប៉ុន្តែក្នុងសង្គមគហបតីវាកើតមាននូវស្ថាប័ននៃសញ្ជាតិ ( រាស្ត្រ ) ដែលពាក្យនេះផ្តុកផ្តាក់ចំពោះរាជា។ ដោយពឹងផ្អែកលើស្ថាប័ននៃសញ្ជាតិ ( រាស្ត្រ ) ក្នុងសម័យគហបតី ( របបអ្នកមាន ឬ Bourgeoisie) និងសម័យសក្តិភូមិ ( របបប្រកាន់វណ្ណៈ ឬ Feudalism) ស្ថាប័ននោះបានធ្វើការកែច្នៃដោយកំណត់នូវសិទ្ធិនៃសមាជិករបស់ខ្លួនក្នុងសង្គម ។

សម័យបច្ចុប្បន្នពាក្យថា "**រាស្ត្រ**" (People) គេប្រើប្រាស់ក្នុងរដ្ឋដែលមានស្តេចគ្រប់គ្រង (Monarch) ដូចជាប្រទេស**បែលសិក អេស្ប៉ាញ កម្ពុជា...**។ល។ ប៉ុន្តែក្រោយមកគេបានផ្លាស់ប្តូរពាក្យរាស្ត្រមកជាពលរដ្ឋវិញ (Citizen)។ រីឯពាក្យ "រាស្ត្រ" សំរាប់ប្រទេស**អង់គ្លេស** គឺសំដៅតែទៅលើពលរដ្ឋនៃរដ្ឋ ដែលបច្ចុប្បន្ន ឬអតីតជាប្រទេសអាណានិគមរបស់ខ្លួន រីឯពាក្យ "**ពលរដ្ឋ**" សំដៅលើមនុស្ស ឬបុគ្គល ដែលជាកម្មសិទ្ធិរបស់ប្រទេសអង់គ្លេសផ្ទាល់ ឬជនជាតិកំណើតអង់គ្លេស ។

នៅក្នុងភាសាមួយចំនួន និយមន័យសញ្ជាតិត្រូវបានកំណត់ន័យពីរ គឺភាពជាកម្មសិទ្ធិរបស់បុគ្គលចំពោះរដ្ឋពិតមួយ និងស្ថានភាពរបស់បុគ្គល (តំណាងក្នុងរដ្ឋ) ។ ដូចជាភាសា**អាល្លឺម៉ង់** "Staatsangehoerigkeit" មានន័យថាភាពជាកម្មសិទ្ធិរបស់រដ្ឋ និងពាក្យ "Buergerschft" មាន ន័យថាជា**សញ្ជាតិ** ។ ត្រង់នេះបញ្ជាក់ថា "**សញ្ជាតិ**" ***វាជាភាពកម្មសិទ្ធិតាមផ្លូវច្បាប់ និងនយោបាយរបស់បុគ្គលចំពោះរដ្ឋសុក្រឹត្យមួយ*** ។ សញ្ជាតិនេះវានាំមកនូវទំនាក់ទំនងអញ្ចមញ្ញរវាងរដ្ឋ និងបុគ្គល ដែលស្ថិតក្រោមអំណាចរបស់រដ្ឋ ដូចជារដ្ឋចែករំលែកឱ្យប្រជាពលរដ្ឋនូវសិទ្ធិការពារ និងបិទបាំងទ្រព្យពីការបំពានក្នុងរង្វង់ព្រំដែនរបស់ខ្លួន ប៉ុន្តែពលរដ្ឋប្រតិបត្តិដោយគ្មានល័ក្ខខ័ណ្ឌចំពោះច្បាប់ និងប្បញ្ញត្តិផ្សេងៗរបស់រដ្ឋ ដោយបំពេញនូវកាតព្វកិច្ចដែលបានកំណត់ដោយរដ្ឋ ។

***ភាពបណ្តុំនៃសិទ្ធិ និងកាតព្វកិច្ចនេះ បង្កើតនូវឋានៈនយោបាយគតិយុត្តិរបស់ប្រជាពលរដ្ឋ ដែលខុសពីពលរដ្ឋបរទេស និងបុគ្គលគ្មានសញ្ជាតិ*** ។

លក្ខណៈខាងលើនេះគឺចង់បញ្ជាក់ថា គ្រប់បុគ្គលដែលបានស្ថិតក្នុងទឹកដីនៃរដ្ឋពិតប្រាកដមួយពុំមែនសុទ្ធតែជាសញ្ជាតិរបស់រដ្ឋនោះទេ គឺមានសញ្ជាតិផ្សេងៗដែលហៅថា**ជនបរទេស** ។ ជនបរទេសនេះអាចជាពលរដ្ឋនៃរដ្ឋបរទេស (ពលរដ្ឋបរទេស) ឬបុគ្គលគ្មានកាន់សញ្ជាតិណាមួយ ។ បុគ្គលគ្មានសញ្ជាតិ ឬហៅថា**និបេតិជន** ដែលពាក្យក្រិចហៅថា (Apatric, Apolis) ចំពោះប្រទេសកម្ពុជា តាមបញ្ញត្តិដែលនិយាយពីសញ្ជាតិត្រូវបានគេកំណត់ក្នុងច្បាប់ស្តីអំពីសញ្ជាតិ ដែលអនុម័តនាថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៦ តែពុំបានកំណត់ក្នុងរដ្ឋធម្មនុញ្ញទេ ច្បាប់សញ្ជាតិរបស់ខ្មែរក៏ពុំបានកំណត់អំពីជន ឬបុគ្គលគ្មានសញ្ជាតិដែរ ។

**ខ.ការកាន់កាប់សញ្ជាតិ** : ជាទូទៅ ការកាន់កាប់សញ្ជាតិនីមួយៗ ត្រូវបានអនុម័តឡើងតាមមធ្យោបាយជាច្រើនដូចខាងក្រោម :

**ខ១. មធ្យោបាយពីកំណើត** : ជាមធ្យោបាយមួយដែលកាន់កាប់សញ្ជាតិតាមគោលការណ៍ពីរប្រភេទ គឺគោលការណ៍សញ្ជាតិ និងគោលការណ៍ដែនដី ។

**ខ.១.១. គោលការណ៍សញ្ជាតិ ឬហៅថាគោលការណ៍ឈាម** "Rights of Blood" : ជាគោលការណ៍មួយ ដែលកាន់សញ្ជាតិពីកំណើតតាមរយៈសិទ្ធិឈាមជ័ររបស់បុគ្គល ដូចជាកូនង៉ារ ដែលអាចកាន់កាប់សិទ្ធិលើឈាមជ័រពីកំណើត មានន័យថាអាចកាន់កាប់សញ្ជាតិឪពុក ឬម្តាយបាន មិនអាស្រ័យនឹងទីកន្លែងកំណើតរបស់កុមារនោះទេ ។ ត្រង់នេះបញ្ជាក់ថា កុមារកាន់កាប់សញ្ជាតិ តាមឪពុក ឬម្តាយរបស់គេ តាមគោលការណ៍ឈាម ។ លក្ខណៈដែលទទួលសញ្ជាតិរបៀបនេះ មាន ច្បាប់ប្រទេស**អូទ្រីស្ត ន័រវែស ហ្សាំងឡង់ អ៊ីតាលី** ។ល។

**ខ.១.២. គោលការណ៍ដែនដី ឬហៅថាគោលការណ៍ទីកន្លែង ឬ** Lexloci Domicilli : ជាគោលការណ៍ ដែលបុគ្គលទទួលបានសញ្ជាតិតាមទីកន្លែងកំណើតរបស់គេ ដោយពុំអាស្រ័យនឹង សញ្ជាតិឪពុក ឬម្តាយរបស់ពួកគេទេ ។ ដូចជាកូនង៉ារដែលកើតនៅលើទឹកដីប្រទេសណាមួយនោះ វានឹងទទួលបានសញ្ជាតិស្វ័យប្រវត្តិពីរដ្ឋដែលខ្លួនបានកើត ប្រសិនបើច្បាប់ប្រទេសនោះបានអនុញ្ញាតិ តែមិនអាស្រ័យនឹងសញ្ជាតិរបស់ឪពុក ឬម្តាយនោះទេ។ ច្បាប់របៀបនេះមានប្រទេស**អាមេរិក, ថៃ, កម្ពុជា, ប្រេស៊ីល** និងប្រទេសជាច្រើនទៀតនៅ**អាមេរិកឡាទីន** ។ ប៉ុន្តែក្រៅពីនេះមាន**គោលការណ៍ចំរុះដែរ** ដោយផ្តុំគោលការណ៍តាមឈាមជ័រ និងគោលការណ៍ទីកន្លែង ។ លក្ខណៈរបៀប នេះតាម**មាត្រាទី ៣០** រដ្ឋធម្មនុញ្ញ**មិកសិកូ** បានកំណត់ថា "បុគ្គលដែលកាន់សញ្ជាតិមិកស៊ិក បានពី កំណើតមាន :

១. រាល់កុមារដែលបានកើតនៅលើទឹកដីនៃសាធារណរដ្ឋ ដោយមិនគិតពីសញ្ជាតិឪពុក ម្តាយដែលមាន ។

២. រាល់កុមារដែលកើតនៅក្រៅប្រទេសពីឪពុក ម្តាយ សញ្ជាតិមិកស៊ិក ពីឪពុក សញ្ជាតិមិកស៊ិក ពីម្តាយសញ្ជាតិមិកស៊ិក ។

៣. រាល់កុមារដែលបានកើតលើនាវាយោធា ឬនាវាពាណិជ្ជកម្មរបស់មិកស៊ិក ឬក៏នៅ លើយន្តហោះ។ ក្រៅពីនេះមានច្បាប់ប្រទេស**អាមេរិក អង់គ្លេស បារាំង ឥណ្ឌា កម្ពុជា** ..... ។ល។

**ខ. មធ្យោបាយចូលសញ្ជាតិតាមការដាក់ពាក្យសុំ ឬហៅថាមធ្យោបាយសញ្ជាតូបនីយកម្ម** (Naturalization) : ជាទូទៅមធ្យោបាយសញ្ជាតូបនីយកម្ម វាកើតមានបន្ទាប់ពីជននោះបានរស់នៅលើរដ្ឋមួយ មានរយៈពេលកំណត់មួយច្បាស់លាស់ ។ មធ្យោបាយដែលអាចកាន់កាប់សញ្ជាតិរបៀបនេះមាន :

-តាមការស្នើសុំរបស់បុគ្គលដែលគ្មានសញ្ជាតិ ឬក៏បុគ្គលដែលមានបំណងផ្លាស់ប្តូរសញ្ជាតិ.

-ក្នុងពេលមានអាពាហ៍ពិពាហ៍រវាងពលរដ្ឋនៃរដ្ឋមួយ ជាមួយនឹងពលរដ្ឋនៃរដ្ឋមួយផ្សេងទៀត.

-ក្នុងពេលមានកូនចិញ្ចឹមនៃទារកដែលគ្មានសញ្ជាតិ ឬក៏មានសញ្ជាតិនៃរដ្ឋមួយផ្សេងទៀត ។

ការផ្តល់សញ្ជាតិក្នុងសណ្តាប់ធ្នាប់នៃសញ្ជាតូបនីយកម្ម ឬក៏បដិសេធន៍ក្នុងសំណូមពរនោះ គឺវាជាសិទ្ធិឯករាជ្យរបស់រដ្ឋសុក្រឹត្យ ដូចជា**មាត្រាទី ៧** ច្បាប់ស្តីពីសញ្ជាតិឆ្នាំ ១៩៩៦ របស់ប្រទេសកម្ពុជាបានកំណត់ថា "ជនបរទេសអាចសុំចូលសញ្ជាតិខ្មែរបាន ដោយសញ្ជាតូបនីយកម្ម ។ សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។ ទោះក្នុងករណីណាក៏ដោយ ពាក្យសុំត្រូវបានបដិសេធចោលបានតាមអំណាចឆន្ទានុសិទ្ធិ" ។ នៅពេលមានសញ្ជាតូបនីយកម្ម សញ្ជាតិត្រូវផ្តល់តាមសំណូមពរ ឬក៏យល់ព្រម (ពេលដែលមានអ្នកចិញ្ចឹមកូន) ផ្តល់កូនទៅបុគ្គលដែលពេញចិត្តក្នុងសណ្តាប់ធ្នាប់ឯកត្តភាពមួយ (ខ្លួនផ្ទាល់) ។ សញ្ជាតូបនីយកម្មត្រូវបំពេញដោយសេចក្តីសំរេចរបស់ស្ថាប័នផ្សេងៗ ដូចជា:មហាផ្ទៃ (ប្រទេសអាល្លឺម៉ង់) ដោយសេចក្តីសំរេចរបស់អង្គការតុលាការ (តុលាការជាន់ខ្ពស់អាមេរិក) និងតាមមធ្យោបាយជាច្រើនទៀត ដូចជាប្រទេសកម្ពុជាដោយគណៈរដ្ឋមន្ត្រីជាដើម ។

ច្បាប់នៃបណ្តាប្រទេសមួយចំនួន បានផ្តុកនូវការបដិសេធន៍ចំពោះការធ្វើសញ្ជាតូបនីយកម្មរបស់បុគ្គលតាមហេតុផលផ្សេងៗផងដែរ ដូចជា : នយោបាយ.សង្គម.សាសនា ។ល។ ប៉ុន្តែល័ក្ខខ័ណ្ឌមួយចំនួននៃសញ្ជាតូបនីយកម្មក៏ត្រូវបានផ្សព្វផ្សាយផងដែរ នូវការកំរិតផ្សេងៗ និងថេរវេលា

ច្បាស់លាស់នៃការរស់នៅក្នុងភូមិសាស្ត្រពិតប្រាកដមួយ ដូចជាប្រទេស**បារាំង** និង**អាមេរិក** ជនដែលអាចធ្វើសញ្ជាតូបនីយកម្មបាន ត្រូវស្ថិតនៅលើទឹកដីនៃប្រទេសទាំងនេះមានរយៈពេល ៥ ឆ្នាំ រីឯ**អង់គ្លេស** និង**នរវែស** ៧ ឆ្នាំ និងនៅប្រទេស**អេស្ប៉ាញ** ១០ ឆ្នាំ និង ៧ ឆ្នាំ ឬតិចជាងសំរាប់កម្ពុជា ( មាត្រា ៨ នៃច្បាប់សញ្ជាតិ) ។ វាក៏អាចមានល័ក្ខខ័ណ្ឌបន្ថែមទៀតដែរ ដូចជាចំណេះដឹងភាសានៃប្រទេសទាំងនោះមានអាយុកំរិតណាមួយ ឬក៏មានសីលធម៌ខ្ពស់ ។ល។ ដែលជាបច្ច័យបន្ធូរបន្ថយរយៈពេលក្នុងការចូលសញ្ជាតិ ។ សំរាប់សហរដ្ឋអាមេរិក ក្រៅពីពេលកំណត់នៃការរស់នៅ គឺនៅមានល័ក្ខខ័ណ្ឌចាំបាច់មួយទៀតក្នុងការធ្វើសញ្ជាតូបនីយកម្ម គឺអាយុ ១៨ ឆ្នាំចេះភាសាអង់គ្លេស មានការដាក់ពាក្យសុំចូលរស់នៅជាអចិន្ត្រៃយ៍ក្នុងសហរដ្ឋ មិនអាចជា "**សត្រូវចំពោះរបបគ្រប់គ្រងដែលមាន**" ហើយផ្តល់សច្ចាប្រណិធានចំពោះរដ្ឋធម្មនុញ្ញសហរដ្ឋ។ ប៉ុន្តែក៏មានប្រទេសខ្លះទៀត (ភាគច្រើន) កំណត់នូវសិទ្ធិរបស់ស្ត្រីថា នារីបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស មានសិទ្ធិរក្សានូវសញ្ជាតិរបស់ខ្លួន ឬក៏ក្នុងសណ្តាប់ធ្នាប់របស់ខ្លួន ដោយស្ម័គ្រចិត្តនៃការធ្វើសញ្ជាតូបនីយកម្ម អនុមត័យកតាមសញ្ជាតិប្តីជាដើម ។ល។ មធ្យោបាយសញ្ជាតូបនីយកម្មនេះ តាម**មាត្រាទី ៨** នៃច្បាប់សញ្ជាតិកម្ពុជា កំណត់ថា "ជនបរទេសដែលអាចសុំសញ្ជាតូបនីយកម្មបាន ត្រូវបំពេញល័ក្ខខណ្ឌដូចតទៅ :

១. មានលិខិតបញ្ជាក់ថាមានគំនិតមាយាទ និងសីលធម៌ល្អ ដែលចេញឱ្យដោយមេឃុំ ឬចៅសង្កាត់នៃទីលំនៅរបស់ខ្លួន ។

២. មានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលមានទោសពីបទព្រហ្មទណ្ឌណាមួយ ។

៣. មានលិខិតបញ្ជាក់ថា ជននោះមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់រយៈពេល ៧ ឆ្នាំ ដោយគិតពីថ្ងៃបានទទួលបណ្ណស្នាក់នៅ ដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ។

៤. មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំសញ្ជាតូបនីយកម្ម ។

៥. ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាងច្បាស់ថា ខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនាមទំលាប់ និងប្រពៃណីល្អរបស់ខ្មែរ ។

៦. មានបញ្ញា និងការយល់សម្បទា ដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬមានបន្ទុកដល់ជាតិ" ។ និងមានកំណត់ក្នុង**មាត្រា ៩** នៃច្បាប់ដដែលនោះថា "ចំពោះជនបរទេសណាកើតក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេលស្នាក់នៅជាប់ចំនួន ៧ ឆ្នាំ ដែលបានចែងក្នុងចំនុចទី ៣ មាត្រាទី ៨ នៃច្បាប់នេះត្រូវបន្ថយមកត្រឹម ៣ ឆ្នាំវិញ" ។ និងមានល័ក្ខខ័ណ្ឌជាច្រើនទៀត តាមការកំណត់របស់ច្បាប់នៃប្រទេសនីមួយៗ ដែលគេសង្កេតឃើញមធ្យោបាយនោះមាន :

**ខ.២.១. បុននីតិសម្បទា ឬហៅថាបុនសមាហរណកម្ម ឬការធ្វើឱ្យមានលក្ខណៈដូចដើមវិញនៃសញ្ជាតិ** (Reintegration of Citizenship) : មធ្យោបាយរបៀបនេះ សំរាប់បុគ្គលដែលបានកាន់សញ្ជាតិនៃរដ្ឋពិតប្រាកដមួយ ប៉ុន្តែបន្ទាប់មកដោយមូលហេតុណាមួយ បុគ្គលនោះក៏លាលែងសញ្ជាតិរបស់គេវិញ ហើយទៅចាប់យកសញ្ជាតិដើមរបស់គេ។ លក្ខណៈរបៀបនេះកំរជួបប្រទះណាស់ ព្រោះការចូលកាន់សញ្ជាតិតាមរបៀបនេះ ធ្វើឡើងមានលក្ខណៈងាយបំផុត ។ ជាឧទាហរណ៍ បុគ្គល "ក" ដើមកំនើតសញ្ជាតិខ្មែរ បន្ទាប់ពីគាត់រស់នៅបរទេសដោយមូលហេតុសង្គ្រាមច្រើនឆ្នាំ គាត់បានកាន់កាប់សញ្ជាតិបរទេសដែលគាត់រស់នៅដោយលាសញ្ជាតិខ្មែរ ប៉ុន្តែពេលប្រទេសខ្មែរមានសន្តិភាពគាត់ត្រឡប់មកវិញ ហើយលាសញ្ជាតិបរទេសចោលមកកាន់កាប់សញ្ជាតិខ្មែរឡើងវិញ ។

**ខ.២.២. ជំរើសសញ្ជាតិ** (Option of Citizenship) : នេះគឺជាមធ្យោបាយមួយដែលធ្វើឡើងនៅពេលទឹកដីណាមួយដាច់ចេញពីរដ្ឋមួយទៀត ហើយក៏ចូលទៅរដ្ឋមួយផ្សេងទៀត នោះគេផ្តល់សិទ្ធិជ្រើសរើសដល់អ្នករស់នៅ ក្នុងការទទួលយកសញ្ជាតិរបស់រដ្ឋថ្មី ឬក៏រក្សានូវសញ្ជាតិដើមដដែលរបស់គេក៏មាន ។ ជាឧទាហរណ៍ បុគ្គល "ក" កាន់កាប់សញ្ជាតិខ្មែររស់នៅខេត្តបាត់ដំបង ប៉ុន្តែនៅក្នុងស្ថានភាពមួយ ខេត្តបាត់ដំបងផ្តាច់ខ្លួនចេញទៅស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋថៃ នោះលោក

"ក" មានសិទ្ធិជ្រើសរើសយកសញ្ជាតិថៃ ឬខ្មែរ ដើម្បីទៅរស់នៅលើទឹកដីណាមួយក្នុង ចំណោមរដ្ឋពីរនេះ ។

**ច.ការបញ្ចប់សញ្ជាតិ** :សញ្ជាតិរបស់បុគ្គលម្នាក់ៗ ត្រូវបានបញ្ចប់តាមហេតុផលជាច្រើន ដូចជាការលាលែងពីសញ្ជាតិ ( ការបដិសេធន៍ពីសញ្ជាតិមួយ) ការបាត់បង់សញ្ជាតិ ការបាត់បង់សិទ្ធិសញ្ជាតិ (Disfranchisement) ការជ្រើសរើសសញ្ជាតិផ្សេងៗ និងតាមមូលហេតុផ្សេងៗទៀត ។ល។ ជាទូទៅ គេសង្កេតឃើញការបាត់បង់សញ្ជាតិតាមរូបភាពមួយចំនួន ដូចខាងក្រោម :

**ច១.ការលាលែងសញ្ជាតិ** : ជាកំលាំងមួយដែលធ្វើឡើងតាមការស្នើសុំរបស់ពលរដ្ឋ ឬពីការយល់ព្រមនៃនាទីណាមួយរបស់អង្គការរដ្ឋ ។ លក្ខណៈគ្រឹះនៃការលាលែងនេះត្រូវកំណត់ដោយច្បាប់ តែបើគ្មានការកំណត់ដោយច្បាប់ណាមួយនោះ ការស្នើសុំនេះពុំអាចធ្វើទៅបានឡើយ ។ ដូចជា**មាត្រា ១៨** ច្បាប់សញ្ជាតិកម្ពុជា ១៩៩៦ បានកំណត់ថា "ជនណាដែលមានសញ្ជាតិខ្មែរ ហើយមានអាយុ ១៨ ឆ្នាំយ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀត និងដោយគ្មានការបង្ខិតបង្ខំ ។ នីតិវិធី និងល័ក្ខខ័ណ្ឌនៃការសុំលះបង់សញ្ជាតិត្រូវកំណត់ដោយអនុក្រិត " ។

**ច២.ការបាត់បង់សញ្ជាតិ** : ការបាត់បង់សញ្ជាតិ កើតមានឡើងតាមក្រឹត្យក្រមស្វ័យប្រវត្តិលើហេតុផលនៃការប្រព្រឹត្តរបស់បុគ្គល ក្នុងអំពើទាំងឡាយដែលត្រូវបានកំណត់ ឬហាមឃាត់ដោយច្បាប់ ។ ជាឧទាហរណ៍ តាមលក្ខណៈរបៀបនេះ ដូចជាការធ្វើសេវាកម្មរបស់បុគ្គលនៃរដ្ឋមួយ ផ្តល់ឱ្យរដ្ឋបរទេសជាដើម ។ នៅក្នុងប្រទេសជាច្រើន ច្បាប់របស់គេបានកំណត់នូវការកាន់កាប់សញ្ជាតិជាស្វ័យប្រវត្តិខាងស្ត្រីបរទេស បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ជាមួយសញ្ជាតិនោះមក ។ តែពេលដែលបែកបាក់អាពាហ៍ពិពាហ៍ ពលរដ្ឋនោះនឹងត្រូវបោះបង់សញ្ជាតិដែលបានកំណត់ តាមករណីខាងលើនេះ ហើយកាន់កាប់សញ្ជាតិដើមបាន ។

**ឥ.ការបាត់បង់សញ្ជាតិបែបទណ្ឌកម្ម** : ការបាត់បង់សញ្ជាតិនេះវាជាទណ្ឌកម្មរបស់រដ្ឋ ដែលធ្វើឡើងតាមករិតមួយនៃចរិតមិនអត់អោន ។ ជានិច្ចកាលទំរង់ប្រភេទនេះច្រើនធ្វើឡើងជាលក្ខណៈមួយក្នុងទំនាក់ទំនង ដែលជាមធ្យោបាយសញ្ជាតូបនីយកម្មរបស់ពលរដ្ឋ និងថេរវេលាមួយដែលបន្ទាប់ពីមានសញ្ជាតូបនីយកម្ម។ តាម**មាត្រា១១** វាក្យខ័ណ្ឌ ២ រដ្ឋធម្មនុញ្ញ**អេស្ប៉ាញ** បានកំណត់ថា "គ្មានពលរដ្ឋអេស្ប៉ាញពីកំណើតណាមួយ នឹងត្រូវបានបាត់សិទ្ធិសញ្ជាតិរបស់ខ្លួនបានឡើយ" ។និងក្នុង**មាត្រា៣៣** រដ្ឋធម្មនុញ្ញកម្ពុជាកំនត់ថា "ប្រជាពលរដ្ឋខ្មែរមិនត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវបានកំណត់ក្នុងច្បាប់មួយ "។ លក្ខណៈសញ្ជាតូបនីយកម្មដែលអាចបាត់បង់សិទ្ធិសញ្ជាតិ ដូចជាច្បាប់ប្រទេស**អូទ្រីស្ត** ច្បាប់បានផ្តល់លទ្ធភាពនូវការបាត់បង់សិទ្ធិសញ្ជាតិចំពោះតែពលរដ្ឋមានសញ្ជាតូបនីយកម្ម ប៉ុន្តែបើសញ្ជាតូបនីយកម្មនោះមានរយៈពេល ៦ ឆ្នាំហើយនោះ ការបាត់បង់របៀបនោះត្រូវហាមឃាត់ ។

**ឃ.គ្មានសញ្ជាតិ និងពហុសញ្ជាតិ** :លក្ខណៈគ្មានសញ្ជាតិ (Person out of Citizenship) និងពហុសញ្ជាតិ អត្ថន័យទាំងពីរនេះពុំមានលក្ខណៈស្របគ្នានឹងគោលការណ៍នៃការកាន់កាប់ និងបញ្ចប់សញ្ជាតិដូចដែលបានរៀបរាប់ខាងដើម ដោយមានការកំណត់ក្នុងបណ្តាប្រទេសផ្សេងៗនោះទេ ។

បុគ្គលដែលគ្មានសញ្ជាតិ (Person out of Citizenship) គឺជាបុគ្គលទាំងឡាយណាដែលមិនអាចបង្ហាញភស្តុតាងនូវវត្តមានសញ្ជាតិផ្ទាល់លើរូបគេបាន ជាឧទាហរណ៍ដូចជាច្បាប់**អូទ្រីស្ត**បានបញ្ជាក់ថា "ទារកដែលបានរកឃើញនៅលើទឹកដីអូទ្រីស្តមានអាយុ ៦ ខែឡើង នឹងចាត់ទុកជាបុគ្គលគ្មានសញ្ជាតិ" ។ មួយវិញទៀត លក្ខណៈគ្មានសញ្ជាតិកើតមាននៅពេលដែលមានការបញ្ចប់សញ្ជាតិរបស់រដ្ឋមួយ ហើយកំពុងត្រៀមចូលសញ្ជាតិនៃរដ្ឋមួយទៀត ដែលបុគ្គលនោះកំពុងរស់នៅ (តាមច្បាប់ប្រទេសខ្លះមុននឹងចូលសញ្ជាតិមួយ ត្រូវលាលែងសញ្ជាតិដែលខ្លួនកំពុងមានសិន ទើបបុគ្គលនោះអាចកាន់កាប់សញ្ជាតិថ្មីបាន) ។

ចំពោះពហុសញ្ជាតិ គឺជាល័ក្ខខ័ណ្ឌមួយដែលបុគ្គលម្នាក់កាន់កាប់សញ្ជាតិពីរ (Double Citizenship) ឬច្រើន គឺមានន័យថាបុគ្គលម្នាក់មានកម្មសិទ្ធិចំពោះរដ្ឋពីរ ឬច្រើន ។ ឧទាហរណ៍ **មាត្រាទី ៤ វាក្យខ័ណ្ឌ ២** ច្បាប់សញ្ជាតិកម្ពុជា ឆ្នាំ ១៩៩៦ បានកំណត់ថា "ត្រូវបានសញ្ជាតិខ្មែរដោយកើតនៅព្រះរាជាណាចក្រកម្ពុជា :

ក- កូនដែលកើតពីឪពុក និងម្ដាយជាជនបរទេស ដែលកើត និងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា

ខ- កូនដែលកើតពីឪពុក និងម្ដាយដែលមិនស្គាល់ និងកូនទើបនឹងកើត ដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថាកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ" ។ ក្នុងនោះមានរដ្ឋធម្មនុញ្ញម៉ិកស៊ិកូ និងច្បាប់អូទ្រីស្ត ជាដើម ដែលមានលក្ខណៈកំណត់សញ្ជាតិបនីយកម្មនេះ ។ នៅក្នុងប្រទេសខ្លះអាចអនុញ្ញាតិឱ្យបុគ្គលម្នាក់មានសញ្ជាតិពីរបាន ឱ្យតែបុគ្គលនោះមានលក្ខណៈគ្រប់គ្រាន់តាមច្បាប់នៃប្រទេសមួយកំពុងរស់នៅ (Lex Domicilli) ។

**ង.របបជនបរទេស** : នៅក្នុងរដ្ឋកាន់លទ្ធិប្រជាធិបតេយ្យ ជនបរទេសទាំងអស់តាមឋានៈគតិយុត្តិរបស់ខ្លួនក្នុងមូលដ្ឋានគ្រឹះមួយ គឺស្មើភាពគ្នាដូចនឹងពលរដ្ឋរបស់រដ្ឋនោះដែរ (របបសញ្ជាតិរបស់រដ្ឋនោះ) ដែលត្រូវបានគូសបញ្ជាក់ក្នុងច្បាប់ទាំងឡាយដែលទាក់ទិន ។ ជាឧទាហរណ៍ **ជនបរទេសមិនអាចកោះហៅឱ្យចូលបំរើកងទ័ពបានទេ និងគ្មានសិទ្ធិបោះឆ្នោត ឬក៏គ្មានសិទ្ធិនៅទីកន្លែងណាដែលច្បាប់បានហាមឃាត់ ដែលទីតាំងនោះជាផលប្រយោជន៍ដ៏ប្រសើរ និងសំខាន់របស់រដ្ឋ** ។ ដូចជាវាក្យខណ្ឌ័ទី ១ មាត្រា ១៣ រដ្ឋធម្មនុញ្ញអេស្ប៉ាញ បាននិយាយថា "ជនបរទេសទាំងអស់ដែលស្ថិតនៅក្នុងប្រទេសអេស្ប៉ាញ ត្រូវប្រើប្រាស់សេរីភាពជាសាធារណៈ ដែលសេរីភាពនោះត្រូវបានធានាដោយផ្នែកមួយនៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន គឺថាល័ក្ខខ័ណ្ឌទាំងនោះត្រូវបានកំណត់ដោយកិច្ចព្រមព្រៀង និងច្បាប់" ។ ប៉ុន្តែរដ្ឋធម្មនុញ្ញម៉ិកស៊ិកូ **មាត្រា ២៣** បានហាមឃាត់គ្រប់ជនបរទេស គឺគ្រប់អន្តរាគមន៍របស់បរទេស ដែលជ្រៀតជ្រែកកិច្ចការនយោបាយប្រទេសត្រូវហាមឃាត់ ។ ប៉ុន្តែសំរាប់កម្ពុជាបានកំនត់ក្នុងច្បាប់អន្តោប្រវេសន្ត នា**មាត្រា ១៧** ថា "ជាគោលការណ៍ជនបរទេស

អាចធ្វើចរាចរបានដោយសេរី នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ក៏ប៉ុន្តែ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចដាក់បញ្ញត្តិហាមឃាត់ចរាចរជនបរទេស និងហាមឃាត់ជនបរទេសអន្តោប្រវេសន្ត ឬមិនមែនអន្តោប្រវេសន្តទាំងអស់មិនឱ្យចូល ឬស្នាក់អាស្រ័យនៅក្នុងតំបន់ ឬចាកចេញឆ្ងាយពីតំបន់ ឬកន្លែងណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា"។

**ច.ការភៀសខ្លួន ការនិរទេសពីប្រទេស ការធ្វើបត្យាបន័ចំពោះជនបរទេសនៃរដ្ឋមួយ** : នៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ រដ្ឋធម្មនុញ្ញរបស់គេបានកំណត់នូវការភៀសខ្លួន ការនិរទេស និងការធ្វើបត្យាបន័យ៉ាងច្បាស់លាស់ ។ ការភៀសខ្លួន ឬការជ្រកកោននៃជនបរទេសអាចទទួលយកបាន គឺអាស្រ័យនឹងច្បាប់នៃប្រទេសនោះ ដោយឈរលើមូលហេតុទាំងឡាយដែលទាក់ទិននឹងមូលហេតុផ្សេងៗដូចជា : បញ្ហាសាសនា បញ្ហានយោបាយ វិទ្យាសាស្ត្រ ។ល។

ការភៀសខ្លួន ដូចជា**មាត្រា ១០** វាក្យខណ្ឌទី ៣ រដ្ឋធម្មនុញ្ញអ៊ីតាលីបានកំណត់ថា "ជនបរទេស ដែលបានដកសិទ្ធិនៅប្រទេសរបស់ខ្លួន មានលទ្ធភាពប្រើប្រាស់សេរីភាពប្រជាធិបតេយ្យដែលធានាដោយរដ្ឋធម្មនុញ្ញអ៊ីតាលី គឺថាមានសិទ្ធិជ្រកកោននៅលើទឹកដីសាធារណរដ្ឋ ដោយប្រតិបត្តិរាល់ល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប"។ រីឯការនិរទេសចេញពីប្រទេស និងការធ្វើបត្យាបន័វាត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់ណាមួយពិតប្រាកដ ដូចជា**មាត្រា ៣៣** រដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ថា "ប្រជាពលរដ្ឋខ្មែរមិនត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវបានកំណត់ក្នុងច្បាប់"។

# គំនូសបំព្រួញ សិទ្ធិ និងកាតព្វកិច្ចរបស់មនុស្ស និងពលរដ្ឋ (រូបទី ៥)



# គំនូសបំព្រួញពលរដ្ឋក្នុងការតាំងនៅ និងការកាន់កាប់សញ្ជាតិ (រូបទី៦)



## អត្ថបទទី ៨

# អត្ថន័យនៃប្រព័ន្ធគ្រប់គ្រងសង្គម

## ១. និយមន័យ និងរចនាសម្ព័ន្ធនៃប្រព័ន្ធគ្រប់គ្រងសង្គម

ប្រព័ន្ធគ្រប់គ្រងរដ្ឋ ជាប្រព័ន្ធសុក្រឹត្យមួយនៃទំនាក់ទំនងសង្គម ដោយផ្សាភ្ជាប់ជាមួយនឹងប្រវត្តិសាស្ត្ររបស់រដ្ឋទាំងនោះ ។ ដូច្នេះនិយមន័យរួមនៃប្រព័ន្ធគ្រប់គ្រងសង្គម **គឺជាអង្គការគ្រប់គ្រងសង្គមមួយ ដែលកំរិតដោយល័ក្ខខ័ណ្ឌកំណត់មួយនៃផលិតកម្ម ការបែងចែក និងការដោះដូរផលិតផល ដោយកំណត់នូវល័ក្ខខ័ណ្ឌនៃលក្ខណៈពិសេសទាំងឡាយ សំរាប់ពុទ្ធិសង្គម និងប្រពៃណី ដោយមានទំនាក់ទំនងអញ្ញមញ្ញរបស់មនុស្ស ក្នុងការគ្រប់គ្រងនៃជីវភាពរបស់ពួកគេ ដែលនឹងត្រូវបានការពារដោយរដ្ឋ និងច្បាប់ ។**

ក្នុងនិយមន័យយើងឃើញថា ការដោះដូរ ការបែងចែក និងផលិតផលទាំងនេះវាជាប្រព័ន្ធមួយនាំឱ្យមានការកែប្រែសង្គម ។ ជាឧទាហរណ៍ បើប្រទេសកំពុងកាន់របបគ្រប់គ្រងមួយក្នុងសង្គម នៅពេលផលិតកម្មក្នុង**រដ្ឋរបស់គេមានការប្រែប្រួលនោះ ធ្វើឱ្យសង្គមជីវភាពរបស់រដ្ឋនោះក៏មានការប្រែប្រួលដែរ** ។ ផ្ទុយទៅវិញ បើកំរិតផលិតកម្មទាំងឡាយដែលវាជាមធ្យោបាយផ្គត់ផ្គង់ជីវិត នៃសមាជិកសង្គមពុំបានគាំពារដោយរដ្ឋ ឬច្បាប់ទេនោះ នៅពេលនេះប្រព័ន្ធគ្រប់គ្រងសង្គមក៏មានការផ្លាស់ប្តូរដែរ ។

ដូច្នេះយើងឃើញថា ប្រព័ន្ធគ្រប់គ្រងសង្គមវាស្ថិតនៅក្រោមអំពើរបស់រដ្ឋជាអចិន្ត្រៃយ៍ ដែលអំពើនោះត្រូវបង្កើតឡើងដោយសង្គម សំរាប់ការពារផលប្រយោជន៍ទូទៅរបស់ខ្លួន ដែលនៅក្នុងនោះគឺសំរាប់រក្សានូវប្រព័ន្ធគ្រប់គ្រងសង្គម ។ ប៉ុន្តែរដ្ឋ**កាន់កាប់ស្វ័យភាព** និងជានីច្ចកាលស្ថិតនៅជាមគ្គុទ្ទេសក៍នៃសង្គម កាលដែលផលប្រយោជន៍សង្គម ស្ថិតនៅក្រោមផលប្រយោជន៍នៃឧបករណ៍អំណាចរដ្ឋ ហើយដែលអំណាចនោះ ត្រូវបានផ្ទុកដោយមធ្យោបាយដ៏មានឥទ្ធិពលនៃការបង្ខិតបង្ខំ

មួយ (ច្បាប់) ។ ត្រង់នេះបញ្ជាក់កាន់តែច្បាស់ថា **ទំរង់នៃប្រព័ន្ធគ្រប់គ្រងសង្គមត្រូវកំណត់ដោយរដ្ឋយ៉ាងពិតប្រាកដ** ។

## ២. រចនាសម្ព័ន្ធនៃប្រព័ន្ធគ្រប់គ្រងសង្គម

រចនាសម្ព័ន្ធនៃប្រព័ន្ធគ្រប់គ្រងសង្គមកើតចេញពី**ស្ថាប័នគ្រឹះ ៤ សំខាន់ៗ** ដែលនាំមកនូវប្រព័ន្ធទាំងឡាយនៃទំនាក់ទំនងសង្គម ក្នុងភាពអាស្រ័យទាំងឡាយនៃជីវភាព ឬកិច្ចការសង្គម ។ ស្ថាប័នទាំងបួននោះគឺ :

-ទំនាក់ទំនងសេដ្ឋកិច្ច

-ទំនាក់ទំនងសង្គមកិច្ច

-ទំនាក់ទំនងវប្បធម៌

-ទំនាក់ទំនងនយោបាយ

ទំនាក់ទំនងទាំងបួននេះ ជាចំណាត់ថ្នាក់មួយសំរាប់សង្គមគ្រប់សម័យ ឬក៏មានលើសពីនេះទៅទៀតតាមការកំរិតនៃអ្នកសង្គមវិទូដែលយល់ឃើញ ។ ប៉ុន្តែផ្ទុយទៅវិញការកំណត់ទៅលើគោលការណ៍គ្រឹះសំខាន់ៗទាំងបួននេះ វាជាអាទិភាពចំបងក្នុងការអភិវឌ្ឍន៍សង្គមជាតិ និងធ្វើឱ្យមានការកែទំរង់នៃការគ្រប់គ្រងរដ្ឋ ។

**ក.ទំនាក់ទំនងសេដ្ឋកិច្ច :** វាជាប្រព័ន្ធមួយនៃទំនាក់ទំនងសេដ្ឋកិច្ច-សង្គម ដែលគេច្រើនហៅថា **ប្រព័ន្ធសេដ្ឋកិច្ច** ។ ស្ថាប័នធម្មនុញ្ញតិយុត្តិដែលវាធ្វើនិយ័តកម្ម ហើយមានទំនាក់ទំនងចំពោះប្រព័ន្ធសេដ្ឋកិច្ចគឺ : **កម្មសិទ្ធិការងារ** និងគោលការណ៍ផ្សេងៗទៀតដែលទាក់ទិននឹងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ល។ គោលការណ៍នេះបានកំណត់នៅមាត្រា ៤៤, ៣៦, ៥៦,៥៧, ៦០, ៦១, ៦២ ។ល។ ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។

**ខ.ទំនាក់ទំនងសង្គមកិច្ច :** វាជាប្រព័ន្ធមួយនៃទំនាក់ទំនងសង្គមដែលមានសកម្មភាព និងវិវត្តន៍ក្នុងសង្គមសុក្រឹត្យមួយ ។ ជាងនេះទៅទៀត គេអាចហៅថាជាទំនាក់ទំនងសាធារណៈ ដែលត្រូវកើតមាននៅក្នុងរដ្ឋពិតប្រាកដណាមួយ ។

នៅក្នុងរដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ បទដ្ឋានរបស់វា ( រដ្ឋធម្មនុញ្ញ) មានគោលដៅធ្វើនិយត័កម្មទៅលើទំនាក់ទំនងសង្គម ដោយឈរលើគ្រឹះមួយនៃជោគជ័យ **សន្តិភាព សង្គម សហប្រតិបត្តិការ** និង**ភាពជាដៃគូរ**នៃគ្រប់ស្រទាប់សង្គម ក្នុងផលប្រយោជន៍**សុខមាលភាពសាធារណៈ**។ ដូច**មាត្រា ៧២** នៃរដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ថា "សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ និងព្យាបាលជំងឺ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃ នៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។ រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ" ។និង**មាត្រា ៦៤** កំណត់ថា "រដ្ឋត្រូវការ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួល ការអប់រំប្រកបដោយគុណភាពនៅគ្រប់កំរិត និងត្រូវចាត់វិធានការណ៍គ្រប់បែបយ៉ាងជាជំហាន១ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡា ដែលជាសុខមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប" ។ ជាទូទៅ គេសង្កេតឃើញទំនាក់ទំនងសង្គមមានលក្ខណៈជាច្រើនប្រភេទ ដូចជា :

**ខ₁. ទំនាក់ទំនងរវាងពលកម្ម និងធន** : ក្នុងរដ្ឋធម្មនុញ្ញចាំបាច់ចារីកនូវបទដ្ឋាន ដែលធ្វើនិយត័កម្មទៅលើទំនាក់ទំនងពលកម្ម និងធនធាន ដូចជាក្នុង**មាត្រា ៣៦** រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា ។

ការងារមេផ្ទះ មានតំលៃស្មើគ្នានឹងកំរៃដែលបានមកពីការធ្វើការនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព និងមានកំណត់នៅក្នុងច្បាប់" ។

ក្នុងអត្ថន័យនៃទំនាក់ទំនងនេះ រដ្ឋធម្មនុញ្ញចង់កំរិតនូវមូលដ្ឋានគ្រឹះមួយស្ដីពី**និយោជិក** និង **និយោជក** ដែលទាក់ទិននឹងពលកម្ម និងធន ។ គឺវាកំណត់នូវតុល្យភាពនៃកំលាំងពលកម្ម (ដូចជាកម្មករ...) និងតំលៃលើពលកម្មទាំងនោះ ដែលមានម្ចាស់រោងចក្រជាប្រភពចំណាយ ។ ដូច្នេះការកំណត់ទៅលើធន និងពលកម្ម វាជាស្ថេរភាពមួយនៃជីវភាពសង្គមទាំងមូល ដោយជៀសបាននូវអំពើហឹង្សាដែលកើតមានក្នុងសង្គម ដោយសារតែមូលហេតុនៃអំពើកេងប្រវ័ញ្ចកំលាំងពលកម្មលើគ្នានោះ ។

**ខ២. ទំនាក់ទំនងអន្តរសញ្ជាតិ** : ជាងនេះទៅទៀត រដ្ឋធម្មនុញ្ញបានកំរិតនូវទំនាក់ទំនងដ៏ច្រើន មានន័យថាកំណត់នូវទំនាក់ទំនងទាំងឡាយដូចជា : **ជាតិពន្ធុ សាសនា ភាសា** និង**ពូជអំបូរ**។ល។ ដូចជា**មាត្រា ៣១** វាក្យខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់" ។ និង **មាត្រា ៤៣** "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ " ។

**ខ៣. ការលើកទឹកចិត្ត និងការគាំពារអាពាហ៍ពិពាហ៍ និងគ្រួសារ** : នេះគឺជាទំនាក់ទំនងមួយដែលរដ្ឋធម្មនុញ្ញបានចារឹកនូវលក្ខណៈនៃសមាជិកសង្គមគ្រួសាររបស់រដ្ឋនីមួយៗ គឺថាវាជារចនាសម្ព័ន្ធសង្គមសាធារណៈ ដែលកើតចេញពីផលិតកម្មមនុស្ស ឬក៏និយាយថាសង្គមគ្រួសារជាប្រភពក្នុងការបង្កើតសមាជិកសង្គមទាំងមូលរបស់រដ្ឋនីមួយៗ ។ តាមលក្ខណៈនេះដូច**មាត្រា ៤៥** វាក្យខណ្ឌទី ២ និងទី ៣ នៃរដ្ឋធម្មនុញ្ញកម្ពុជាកំណត់ថា "បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់ករណីទាំងអស់ពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់

និងតាមគោលការណ៍ស្មគ្រ័ចិត្ត ប្តីមួយប្រពន្ធមួយ"។ និងកំណត់ទៅលើភាពថ្លៃថ្នូរ និងភាពលើកទឹកចិត្តផ្សេងៗទៀត ដូចជា**មាត្រា ៤៦** នៃរដ្ឋធម្មនុញ្ញដែលបានចែងថា "អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់។

ត្រូវហាមឃាត់មិនឱ្យមានបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូនដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។ល។"

**៩៤. នយោបាយសេដ្ឋកិច្ចក្នុងវិស័យបរិស្ថាន ការថែរក្សាសុខភាព និងការផ្គត់ផ្គង់សង្គម :** បញ្ហាការពារបរិស្ថានជាបញ្ហាមួយដ៏ធំធេង ដែលរដ្ឋនៃប្រទេសនីមួយៗយកចិត្តទុកដាក់សំខាន់បំផុតក្នុងសម័យយើងនេះ ។ ដូចជា**មាត្រា ៥៩** នៃរដ្ឋធម្មនុញ្ញបានកំណត់ថា "រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគោត្តសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធាន ជលផល"។ រីឯសុខភាព និងផ្គត់ផ្គង់សង្គម តាម**មាត្រា ៧៣** "រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា ។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង"។ **មាត្រា ៧២** "សុខមាលភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ និងព្យាបាលជំងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃ នៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។

**ឥ₉. វិទ្យាសាស្ត្រ និងវប្បធម៌** : ជាមជ្ឈដ្ឋានមួយដែលរដ្ឋអាចផ្គត់ផ្គង់នូវការងារសំភារៈគ្រឹះក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ដូចជា**មាត្រា ៦៩** បានកំណត់ថា "រដ្ឋមានកាតព្វកិច្ចថែរក្សា និងពង្រីកវប្បធម៌ជាតិ ។

រដ្ឋមានកាតព្វកិច្ចការពារ និងពង្រីកភាសាខ្មែរឱ្យសមស្របនឹងសេចក្តីត្រូវការ ។

រដ្ឋមានកាតព្វកិច្ចថែរក្សា និងការពារប្រាសាទបុរាណវត្ថុ សិល្បៈបុរាណ និងកែលំអរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ" ។ និង**មាត្រា ៦៧** កំណត់ថា "រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើបរាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស......." ។ និងមានលក្ខណៈផ្សេងៗជាច្រើនទៀត។

**ឥ₁₀. សាសនា** : វាជាស្ថាប័នដ៏សំខាន់មួយនៃជីវភាពវប្បធម៌ ជំនឿសាសនារបស់សង្គម ។ ដូចជា**មាត្រា ៤៣** នៃរដ្ឋធម្មនុញ្ញបានកំណត់ថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងល័ក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ" ។

**ឃ. ទំនាក់ទំនងនយោបាយ** : ទំនាក់ទំនងនេះវាបង្កើតនៅក្នុងបណ្តុំរបស់ខ្លួន នូវប្រព័ន្ធនយោបាយមួយនៅក្នុងប្រទេស ។ ដូចនេះទំនាក់ទំនងនយោបាយ វាជាទំនាក់ទំនងដែលផ្សារភ្ជាប់ទៅមុខងារនៃអំណាចនយោបាយក្នុងសង្គម ដែលហៅថា**អំណាចរដ្ឋ** ។ ដើម្បីយល់ដឹងនូវអំណាចរដ្ឋ ជាជំហានដំបូងត្រូវស្គាល់អំពីអំណាចជាមុនសិន ដែលជាប្រភពដំបូងបង្អស់ ។

**អំណាច**គឺជាទំនាក់ទំនងសាធារណៈមួយ ដែលសំដែងនូវលក្ខណៈជាសមត្ថភាព និងមធ្យោបាយនៃមនុស្សមួយក្រុម ឬក៏ក្រុមណាមួយ (មានអំណាច) ទទួលជោគជ័យនូវអាទិភាពនៃឆន្ទៈរបស់ខ្លួន លើមនុស្ស ឬក៏ក្រុមដទៃផ្សេងទៀត (នៅក្រោមអំណាច) ។ រីឯ**អំណាចនយោបាយ**

គឺជាអំណាចនៃក្រុមកំណត់មួយរបស់មនុស្ស (អ្នកដឹកនាំ) ដែលបានប្រើប្រាស់ក្នុងករណីដែលមិនអាចអត់អោននូវរាល់មធ្យោបាយបង្ខិតបង្ខំ ។ ចំពោះអំណាចរបស់មនុស្ស មានអំណាចរបស់គ្រួសាររបស់អ្នកដឹកនាំ របស់ប្រធានក្រុម របស់ស្ថាប័នផ្សេងៗ ដូចនេះគេសង្កេតឃើញ**អំណាចរដ្ឋ**តាមរយៈរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ នូវមាត្រាមួយចំនួនដូចជា : **មាត្រា ១៣០** "គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ" ។ និង**មាត្រា ១៣១** "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា" ។ រីឯ**មាត្រា ១៣២** "ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ" ។ និងអំណាចនីតិបញ្ញត្តិកំណត់ក្នុងជំពូកទី ៧ និង ៨ ឯអំណាចនីតិប្រតិបត្តិបានកំណត់ក្នុងជំពូកទី ១០ នៃរដ្ឋធម្មនុញ្ញដដែលនោះ ។ នៅក្នុងទំនាក់ទំនងនយោបាយ គេសង្កេតឃើញមានលក្ខណៈជាច្រើនទៀតដូចជា :

**ឃ. វិវត្តន៍នយោបាយ** : វាជាបាតុភូតមួយកំណត់នូវសណ្តាប់ធ្នាប់នៃមុខងារ គ្រប់ប្រព័ន្ធនយោបាយ និងស្ថាប័នរបស់ប្រព័ន្ធនយោបាយនោះ ដែលរួមទាំងទំនាក់ទំនងអញ្ញមញ្ញរវាងស្ថាប័នទាំងនោះទៀតផង ។ ត្រង់នេះបញ្ជាក់នូវសកម្មភាពរបស់មនុស្ស ឬបុគ្គលដែលចង់ធ្វើនយោបាយដើម្បីគ្រប់គ្រងរដ្ឋ ដូចជាប្រទេសកម្ពុជា បុគ្គលនោះត្រូវតែជាសមាជិកសកម្មរបស់គណៈបក្សនយោបាយ (តាមច្បាប់បោះឆ្នោតតំណាងរាស្ត្រ) ។

ពាក្យថាវិវត្តន៍នយោបាយវាគ្របដណ្តប់ទៅរាល់ទំរង់ផ្សេងៗ ដូចជាមធ្យោបាយ និងនិន្នាការនៃកិច្ចការនយោបាយរបស់សាមី ឬអត្តាទាំងនោះ (សមាជិកនយោបាយទាំងឡាយ) ។ ប៉ុន្តែការវិវត្តន៍នយោបាយពុំមានលក្ខណៈដូចការវិវត្តន៍គតិយុត្តិទេ ព្រោះការវិវត្តន៍គតិយុត្តិវាមានអត្ថន័យពីរ :

**ទីមួយគឺ** : សកម្មភាពដែលកើតនៅក្នុងសណ្តាប់ធ្នាប់កំណត់មួយ (ច្បាប់)

**ទីពីរគឺ** : ប្រព័ន្ធបទដ្ឋានគតិយុត្តិនេះជាសកម្មភាពដែលធ្វើនិយ័ត មានន័យថាកំណត់នូវសណ្តាប់ធ្នាប់នៃការធ្វើឱ្យដំណើរការរបស់វា ( នីតិវិធី ) ។[២៥]

**ឃ₂.វប្បធម៌នយោបាយ និងវប្បធម៌គតិយុត្តិ** : ជាដំបូងវប្បធម៌នយោបាយ គឺជាកម្មវត្ថុ **នៃនយោបាយវិទ្យា** (Politology) ឯវប្បធម៌គតិយុត្តិ គឺជាកម្មវត្ថុនៃទ្រឹស្តីទូទៅនៃនីតិសាស្ត្រ ក្នុងន័យរបៀបនេះ ទំនាក់ទំនងមនោគមន៍ទាំងឡាយដែលជិតជាប់សំរាប់ជនជាតិនីមួយៗ នោះត្រូវបានចារឹកក្នុងរដ្ឋធម្មនុញ្ញរបស់គេ ។ ការចារឹកនូវចរិតរបស់មនុស្ស ដូចជាតថភាពនៃសិទ្ធិ និងសេរីភាពរបស់មនុស្ស ដែលគេបានចារឹកនៅក្នុងរដ្ឋធម្មនុញ្ញរបស់គេ វាជាសក្ខីកម្មបញ្ជាក់នូវភាពជឿនលឿន ឬអោនថយនៃជនជាតិក្នុងរដ្ឋ ឬសង្គមនីមួយៗទៅតាមសម័យកាល ។ វប្បធម៌នយោបាយវាបានអប់រំឱ្យសមាជិកសង្គម យល់ដឹងនូវផលប្រយោជន៍នៃការធ្វើនយោបាយ រីឯវប្បធម៌គតិយុត្តិវាអប់រំឱ្យមនុស្សស្គាល់នូវតំលៃនៃការគោរព និងអនុវត្តន៍ច្បាប់ ។

**ឃ₃.របបនយោបាយ** : វាជាប្រព័ន្ធមួយនៃការទទួលយកនូវវិធី ទំរង់ និងមធ្យោបាយនៃវត្តមានអំណាចនយោបាយ ( ឬអំណាចរដ្ឋ) ក្នុងសង្គម ។ របបនយោបាយវាមានលក្ខណៈច្រើនប្រភេទណាស់តាមរដ្ឋនីមួយៗ ដូចជារដ្ឋប្រជាធិបតេយ្យ អប្រជាធិបតេយ្យ.........។ល។ ការបញ្ជាក់លើបញ្ហានេះ ដូចជារដ្ឋធម្មនុញ្ញកម្ពុជា កំណត់នូវនយោបាយតាម**មាត្រា** ១ ថា "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

---

[២៥] . គ្រប់រដ្ឋដែលមានច្បាប់រួចហើយ ឬក៏បង្កើតច្បាប់មកហើយតែពុំមាននីតិវិធីគ្រប់គ្រាន់ ក្នុងការអនុវត្តទៅលើច្បាប់នោះទេ នោះលទ្ធផលរបស់វាបញ្ជាក់ថា **ការវិវត្តន៍គតិយុត្តិ**របស់រដ្ឋនោះ មានលក្ខណៈអន់ថយ ។

. ការអនុវត្តទៅលើច្បាប់បានជោគជ័យ ដោយប្រើនីតិវិធីគ្រប់គ្រាន់ វាអាស្រ័យទៅនឹងឆន្ទៈនៃអ្នកនយោបាយ និងពលរដ្ឋដែលលទ្ធផលវាតិច ឬច្រើន វាបញ្ជាក់នូវ**ការវិវត្តន៍នយោបាយ**របស់រដ្ឋនោះ ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រិត្យ អចិន្ត្រៃយ៍ និង មិនចូលបក្សសម្ព័ន្ធ"។ និងតាម**មាត្រា ១០** កំណត់ថា "របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។

ព្រះមហាក្សត្រ ទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទ សំរាប់គ្រងរាជសម្បត្តិ ឡើយ"។ និងបានកំណត់ក្នុង**មាត្រា ៥១** ថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិប តេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។

## ៣. ប្រព័ន្ធគ្រប់គ្រងសង្គម និងរដ្ឋធម្មនុញ្ញ (ច្បាប់គ្រឹះ)

ខ្លឹមសារនៃប្រព័ន្ធគ្រប់គ្រងសង្គម វាត្រូវបានកំណត់ដោយច្បាប់គ្រឹះ ឬរដ្ឋធម្មនុញ្ញរបស់រដ្ឋ នីមួយៗ ។ ព្រោះថារដ្ឋធ្វើសកម្មភាពទៅលើប្រព័ន្ធគ្រប់គ្រងសង្គម គឺធ្វើនិយ័តកម្មគតិយុត្តិទៅរាល់ ទំនាក់ទំនងសាធារណៈ ដូចជាការក៏រិត ឬកំណត់ប្រព័ន្ធទណ្ឌកម្មនៃបទដ្ឋានគតិយុត្តិ និងផ្តត់ផ្គង់នូវ ការសមិទ្ធិរបស់វា (ច្បាប់) ។ លើសពីនេះទៀត បទដ្ឋាននៃនីតិរដ្ឋធម្មនុញ្ញពង្រឹងនូវរចនាសម្ព័ន្ធគ្រប់ គ្រងសង្គម និងរដ្ឋ គឺវាបានបង្កើតនូវស្ថាប័ននៃរបបរដ្ឋធម្មនុញ្ញមួយជាក់លាក់ ។ នេះគឺជាស្ថាប័ន ប្រកបដោយរចនាសម្ព័ន្ធសំាញ៉ាំ ដែលដើរតួក្នុងនីតិរដ្ឋធម្មនុញ្ញ ។ របបរដ្ឋធម្មនុញ្ញ (ប្រព័ន្ធរដ្ឋ ធម្មនុញ្ញ ឬហៅថានិមិត្តកម្មរដ្ឋធម្មនុញ្ញ) ទាំងនោះរៀបចំឡើងពីស្ថាប័នជាច្រើនដូចជា : ស្ថាប័ននៃ អំណាចរដ្ឋ ដូច**មាត្រា ៥១** នៃរដ្ឋធម្មនុញ្ញកម្ពុជា បានចែងថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្ត របបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។ និងកំណត់ស្ថាប័ននៃប្រព័ន្ធនយោបាយ ដូចបានចែងក្នុង**មាត្រា ១** ថា "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រិត្យ អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ" ។ មួយវិញទៀត រដ្ឋធម្មនុញ្ញបានកំណត់ទៅលើស្ថាប័ននៃប្រព័ន្ធសេដ្ឋកិច្ច ដូច**មាត្រា ៥៦** បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់" ។

ចំពោះស្ថាប័ននៃប្រព័ន្ធសង្គមត្រូវបានកំណត់ក្នុង**មាត្រា ៦៦** នៃរដ្ឋធម្មនុញ្ញកម្ពុជា ថា "រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯករាជ្យនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើភាពគ្នាក្នុងការកសាងជីវិត" ។ និងក្នុង**មាត្រា ៧២** បានកំណត់ថា "សុខមាលភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺ និងព្យាបាលជម្ងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃ នៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។

រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ" ។ ក្រៅពីស្ថាប័នគ្រឹះទាំងនេះ នៅមានស្ថាប័នតូចៗតទៅទៀត ដូចជា**ស្ថាប័នប្រជាមតិ**[២៦] ដែលស្ថិតក្នុងស្ថាប័នរដ្ឋជាដើម ។ គំនិត

[២៦] . ស្ថាប័នប្រជាមតិ ជាស្ថាប័នគ្រឹះមួយសំរាប់ដោះស្រាយវិបត្តិនយោបាយធំៗ ក្នុងប្រទេស ព្រោះវាជាឆន្ទៈផ្ទាល់របស់ពលរដ្ឋជាអ្នកសំរេច ។
. រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ពុំបានកំណត់អំពីស្ថាប័នប្រជាមតិឡើយ ។

គ្រឹះសំខាន់ៗដែលកំណត់នូវ "ប្រព័ន្ធរដ្ឋធម្មនុញ្ញ" ឬហៅថា "និម្មិតកម្មធម្មនុញ្ញ" នៃរដ្ឋពិតប្រាកដមួយ នឹងទទួលបាននូវការពង្រឹងក្នុងរដ្ឋធម្មនុញ្ញរបស់គេ ដោយកំណត់សមាសធាតុនូវគោលការណ៍ជាច្រើននៃនិម្មិតកម្មធម្មនុញ្ញ ដែលប្រភេទ និងខ្លឹមសារទាំងនោះអាស្រ័យនឹងមជ្ឈដ្ឋាននៃទំនាក់ទំនងសង្គម ព្រោះថាគោលការណ៍ទាំងនោះវាត្រូវជាងនូវគំរូនៃរចនាសម្ព័ន្ធគ្រប់គ្រងសង្គម និងរដ្ឋ ។ ជាទូទៅគេអាចសង្កេតឃើញចំណាត់ថ្នាក់គោលការណ៍នៃនិម្មិតកម្មធម្មនុញ្ញទាំងនោះ មានចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម :

- គោលការណ៍ដែលកំណត់នូវប្រភពនៃអំណាចរដ្ឋ និងភាពជាកម្មសិទ្ធិរបស់វា (ចាត់ទុកពលរដ្ឋជាប្រភពអំណាច) ។
- គោលការណ៍ដែលពង្រឹងសាសនារបស់មនុស្សនៅក្នុងសង្គម និងរដ្ឋ និងការចូលរួមរបស់មនុស្សក្នុងការបំពេញភារកិច្ចនៃអំណាច (ផ្តល់លទ្ធភាពឱ្យពលរដ្ឋចូលរួមដឹកនាំ និងគ្រប់គ្រងសង្គម) ។
- គោលការណ៍ដែលផ្ទុកនៅក្នុងមជ្ឈដ្ឋាន ទំនាក់ទំនងគ្នារវាងអំណាច និងច្បាប់ (ច្បាប់ជាខ្នាតនៃអំណាច) ។
- គោលការណ៍ដែលសំដែងចេញនូវប្រភពនៃទំនាក់ទំនងសេដ្ឋកិច្ច និងសង្គម ទៅលើឥទ្ធិពលនៃអំណាច (ចាត់ទុកមនុស្សក្នុងសង្គមមានសកម្មភាព ជះឥទ្ធិពលលើអំណាច តាមរយៈការវិវត្តន៍ឆន្ទៈ) ។
- គោលការណ៍ដែលកំណត់គំរូទៅលើអង្គការគ្រប់គ្រងអំណាច (បុគ្គលដឹកនាំរដ្ឋគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើជាគំរូល្អដល់សាធារណៈជន) ។
- គោលការណ៍ដែលកំណត់នូវទំរង់រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ និងការចាប់ផ្តើមដំបូងនៃការបែងចែកនូវព្រំដែននៃអំណាច (ការកំណត់រដ្ឋជាទោល. ជាសហព័ន្ធ........។ល។ និងបែងចែកឱ្យដាច់ពីគ្នា ក្នុងការធ្វើសកម្មភាពចំពោះអំណាចនីមួយៗក្នុងរដ្ឋ) ។

**អត្ថបទទី ៩**

# ទំនាក់ទំនងសេដ្ឋកិច្ច

## ១. ប្រព័ន្ធសេដ្ឋកិច្ច

ប្រព័ន្ធទំនាក់ទំនងសេដ្ឋកិច្ចសាធារណៈ ដែលហៅថាប្រព័ន្ធសេដ្ឋកិច្ចនោះ **គឺជាទំនាក់ទំនងទាំងឡាយនៃកម្មសិទ្ធិ ផលិតកម្ម ការដោះដូរ ការចែកចាយ និងតំរូវការនៃទ្រព្យសម្បត្តិជាសម្ភារៈ និងស្មារតី** ។ ដោយយោងទៅលើនិយមន័យនេះ តាមមាត្រា **១៧០** នៃរដ្ឋធម្មនុញ្ញប្រេស៊ីល ដែលក្នុងនោះបានគូសបញ្ជាក់នូវគោលការណ៍ទាំងឡាយនៃប្រព័ន្ធសេដ្ឋកិច្ច ដោយវាបង្កើតឡើងនូវ**តំលៃនៃពលកម្មរបស់មនុស្ស និងការផ្តួចផ្តើមសេរី** ។ ក្នុងរដ្ឋធម្មនុញ្ញនេះបានកំណត់ថាការប្រតិបត្តិនូវរាល់គោលការណ៍ទាំងនេះ វាជាលក្ខណៈចាំបាច់បំផុតសំរាប់ផ្គត់ផ្គង់ទៅគ្រប់ៗគ្នា ដែលជាអាទិភាពដ៏ជោគជ័យមួយក្នុងតំរូវការនៃគតិយុត្តិសង្គម ។ គោលការណ៍ទាំងនោះមាន**អធិបតេយ្យជាតិ កម្មសិទ្ធិឯកជន មុខងារសង្គមនៃកម្មសិទ្ធិ ការប្រកួតប្រជែងសេរី ការការពារអ្នកប្រើប្រាស់ ការពារបរិដ្ឋាន កាត់បន្ថយនូវវិសមិតភាពសង្គម និងតំបន់ បើកទូលាយនូវការជួយសំរួលដល់សហគ្រាសប្រេស៊ីល ដែលមានដើមទុនជាតិ** ។

សរុបទៅ ដើម្បីងាយស្រួលក្នុងការយល់ដឹងស្ថាប័នធម្មនុញ្ញគតិយុត្តិ ឬក៏បទដ្ឋានធម្មនុញ្ញគតិយុត្តិ ដែលទាក់ទិននឹងប្រព័ន្ធសេដ្ឋកិច្ច យើងនឹងស្គាល់វាតាមលំដាប់ខ្លះៗដែលមាននៅក្នុងចំនុចបន្តបន្ទាប់ដូចខាងក្រោម :

**ក.កម្មសិទ្ធិ :** ទំហំ និងលក្ខណៈនិយ័តកម្មធម្មនុញ្ញគតិយុត្តិនៃរាល់ទំនាក់ទំនងកម្មសិទ្ធិ ត្រូវបានផ្លាស់ប្តូរជាប្រវត្តិសាស្ត្រជាប់ពីរយឆ្នាំមកហើយ[២៧] ។ ត្រង់នេះគឺចង់បញ្ជាក់នូវអត្ថន័យទៅលើកម្ម

[២៧] . នៅក្នុងសម័យបុព្វកាលនៃការកកើតមនុស្ស កម្មសិទ្ធិពុំទាន់កើតមាននៅឡើយទេ ប៉ុន្តែធម្មជាតិនៃកម្មសិទ្ធិវាកើតឡើងជាមួយនឹងមនុស្សដោយស្វ័យប្រវត្តិ ប៉ុន្តែការវិវត្តន៍នៃសង្គមមនុស្សធ្វើឱ្យមានការប់រែប្រួលទៅលើកម្មសិទ្ធិ ។

សិទ្ធិ ត្រូវបានគេប្រើប្រាស់ និងមានការផ្លាស់ប្តូរជាច្រើនរយឆ្នាំមកហើយ ដោយគេបានចារឹកវាតាមលក្ខណៈ ឬទំហំនៃវត្ថុដែលមានជារបស់បុគ្គល ឬរដ្ឋណាមួយនៃសម័យកាល ។ នៅក្នុងខ្លឹមសារនៃនីតិសាស្ត្រវាមានអត្ថន័យពីរយ៉ាង ដែលបញ្ជាក់ទៅលើកម្មសិទ្ធិគឺ : ទីមួយន័យទូលាយ ឬន័យទស្សនៈវិជ្ជា និងទីពីរជាន័យសុក្រិត្យ ។

**ក១. ន័យទីមួយ ឬន័យទស្សនវិជ្ជា** : "កម្មសិទ្ធិ" វាជាទំរង់មួយនៃការកាន់កាប់ទ្រព្យសម្បត្តិ ទំនាក់ទំនងទាំងឡាយរវាងមនុស្ស និងមនុស្ស តាមហេតុផលរបស់ពួកគេ ។ សិទ្ធិកម្មសិទ្ធិក្នុងន័យនេះអ្នកច្បាប់បុរាណរ៉ូម៉ាំងបានកំណត់ថា វាជា**សិទ្ធិកាន់កាប់ សិទ្ធិប្រើប្រាស់** និង**សិទ្ធិបែងចែកនូវទ្រព្យសម្បត្តិ** ឬវត្ថុពិតប្រាកដដែលមាននោះ ។

**ក២. ន័យទីពីរ ឬន័យសុក្រិត្យ** : ពាក្យថា "កម្មសិទ្ធិ" វាជាទ្រព្យសម្បត្តិ (វត្ថុ ឬទ្រព្យ) ។ ន័យទាំងពីរនេះបានត្រូវបញ្ជាក់ដោយ**មាត្រា ៥៨** នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ថា "ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេសសំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ ។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋនឹងត្រូវកំណត់ក្នុងច្បាប់" ។

យើងឃើញថា វាក្យខណ្ឌទីមួយបានបញ្ជាក់ថារដ្ឋជា**ម្ចាស់នៃកម្មសិទ្ធិ** ដូចនេះរដ្ឋមានសិទ្ធិបែងចែកកាន់កាប់ និងប្រើប្រាស់ ។ រីឯទ្រព្យសម្បត្តិជាវត្ថុពិតនោះ គឺដីធ្លី ក្រោមដី ភ្នំ............។ល។ ប៉ុន្តែនៅក្នុងរដ្ឋធម្មនុញ្ញក៏បានបញ្ជាក់នូវកម្មសិទ្ធិរបស់សមាជិកនៃរដ្ឋ (ពលរដ្ឋ) របស់គេដែរ ដូចជា **មាត្រា ៤៤** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ វាក្យខណ្ឌទីមួយបញ្ជាក់ថា "ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូលហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ......." ។ ប៉ុន្តែនៅវាក្យខណ្ឌទីពីរនៃមាត្រាដដែលនេះកំណត់ថា "កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់" ។

**ខ.លក្ខណៈនៃកម្មសិទ្ធិ** : វត្ថុ ឬទ្រព្យមួយដែលតាំងនៅលើទឹកដីណាមួយ មិនអាចគេចចេញបានពីកម្មសិទ្ធិរបស់អ្នកណាម្នាក់ ឬក្រុមណាមួយនោះបានឡើយ ។

ដោយយោងតាមអត្ថន័យនៃកម្មសិទ្ធិដែលរដ្ឋធម្មនុញ្ញបានកំណត់, ជាទូទៅមានលក្ខណៈរបស់ខ្លួនជា**ពីរប្រភេទ** គឺកម្មសិទ្ធិឯកជន និងកម្មសិទ្ធិសាធារណៈ ឬកម្មសិទ្ធិរដ្ឋ ។

**ខ១. កម្មសិទ្ធិឯកជន** : គឺជាទំហំសិទ្ធិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណៈដោយផ្ទាល់ខ្លួនទៅលើវត្ថុ ឬទ្រព្យសម្បត្តិណាមួយ ។

**ខ២. កម្មសិទ្ធិសាធារណៈ** : កម្មសិទ្ធិសាធារណៈវាមានលក្ខណៈ**ពុំអាចបែកដាច់**ពីគ្នាបានទេ ផ្ទុយទៅវិញកម្មសិទ្ធិឯកជនវា**បែកដាច់**ពីគ្នាបាន។ អត្តា ( ប្រធាន) នៃច្បាប់កម្មសិទ្ធិសាធារណៈមានដូចជា : **រដ្ឋសមាជិក**នៃសហព័ន្ធ ( រដ្ឋ ខេត្ត...។ល។), **ទឹកដីស្វយ័ត** ( តំបន់ ទីក្រុង សមាគមទីជនជាតិ ។ល។) និងក្នុងករណីខ្លះដូចជានិម្មិតកម្មសង្គម (បក្សនយោបាយក្រុមសាសនា ។ល។) ឧទាហរណ៍ បុគ្គលម្នាក់កាលដែលបានរស់នៅក្នុងទីក្រុងមួយនោះ គាត់ក្លាយជាកម្មសិទ្ធិករ ( ប្រធាននៃកម្មសិទ្ធិ) ដោយស្វយ័ប្រវត្តិ ចំពោះទ្រព្យសម្បត្តិសាធារណៈនៃទីក្រុងនោះ ប៉ុន្តែកាលដែលបានចេញពីទីក្រុង (ឈប់រស់នៅ) ដើម្បីទៅរស់នៅទីកន្លែងផ្សេង គាត់ក៏បាត់បង់ដោយស្វយ័ប្រវត្តិផងដែរ នូវសិទ្ធិ ( ប្រធាននៃនីតិ) ចាប់យកចំណែករបស់ខ្លួន ( សិទ្ធិ និងកាតព្វកិច្ច) ចំពោះទ្រព្យសម្បត្តិទីក្រុងនោះ ។ កម្មសិទ្ធិសាធារណៈនេះជានិច្ចកាលវាជាពួក ឬក្រុម (Group) ដែលជាអង្គការប្រមូលផ្តុំយ៉ាងពិតប្រាកដ ។

ភាពជាក្រុម ឬជាពួកនេះបញ្ជាក់នូវសំណូមពរយ៉ាងច្បាស់ថា **ស្មើរគ្នាសំរាប់គ្រប់ម្ចាស់កម្មសិទ្ធិ** នូវទំហំសិទ្ធិចំពោះទ្រព្យសម្បត្តិ ។ ប៉ុន្តែអត្តា ( ប្រធាន) នៃច្បាប់កម្មសិទ្ធិឯកជនវិញអាចមាននូវរាល់រូបវន្តបុគ្គល ឬនីតិបុគ្គល មានន័យថាកម្មសិទ្ធិឯកជនអាចចំលង ឬភ្ជាប់បានលក្ខណៈដោយផ្ទាល់ខ្លួន (Individual) ដូចជាគ្រួសារ ឬវង្សត្រកូល ក្រុម ពួក ។ល។ នៅក្នុងករណីនៃកម្មសិទ្ធិលក្ខណៈជាក្រុម ( កម្មសិទ្ធិសាធារណៈ) ទំហំសិទ្ធិទៅលើទ្រព្យសម្បត្តិទូទៅនៃម្ចាស់កម្មសិទ្ធិ ដោយ

ឡែក១អាចមាន**ភាពស្មើគ្នា** ឬ**មិនស្មើគ្នា** ដោយអាស្រ័យនឹងទំហំ ឬខ្នាតនៃចំណែកដែលបានដាក់ជាភាគហ៊ុន ឬក៏ល័ក្ខខ័ណ្ឌផ្សេង១ទៀត ។ គួររំលឹកថាលក្ខណៈសាធារណៈ ឬក៏ឯកជននៃកម្មសិទ្ធិត្រូវកំណត់ជារួមដោយ**ទំរង់ការ** (របប) **មួយយ៉ាងជាក់លាក់** (ច្បាប់) **នៃទ្រព្យសម្បត្តិ** (វត្ថុ) **ប៉ុន្តែមិនមែនកំណត់ដោយម្ចាស់កម្មសិទ្ធិនោះទេ** (បុគ្គលដោយឡែក ឬក៏សិទ្ធិសាធារណៈ) ។ ម្យ៉ាងវិញទៀត ការបំលាស់ទីទ្រព្យសម្បត្តិពីកម្មសិទ្ធិសាធារណៈឱ្យទៅជាកម្មសិទ្ធិឯកជន ត្រូវឆ្លងកាត់ទំរង់មួយហៅថា**ឯកជនភាវូបនីយកម្ម** (Privatization) ។ ដូចជាប្បញ្ញត្តិបន្ថែមលើវាក្យខណ្ឌទី ៣ នៃ**មាត្រា ៣៤** រដ្ឋធម្មនុញ្ញបារាំង **ឆ្នាំ** ១៩៥៨ កំណត់អំពីឯកជនភាវូបនីយកម្មនៃសហគ្រាស និងបំលាស់ទីទ្រព្យសម្បត្តិរបស់វាចេញពីកម្មសិទ្ធិសាធារណៈ ឆ្ពោះទៅកម្មសិទ្ធិឯកជនត្រូវកំណត់ដោយច្បាប់មួយ ។ នេះគឺបញ្ជាក់កាន់តែច្បាស់នូវភាពមួយនៃស្ថេរភាពសង្គម សេដ្ឋកិច្ច ដោយជៀសវាងបាននូវអំពើកេងប្រវ័ញ្ចពីទ្រព្យសម្បត្តិរដ្ឋ មកជាទ្រព្យសម្បត្តិឯកជន ។ ប៉ុន្តែប្រសិនបើគេបំលាស់ទីកម្មសិទ្ធិឯកជនមកជារបស់រដ្ឋវិញ ក៏ត្រូវតែធ្វើតាមរយៈច្បាប់ និងមានការទូទាត់តាមតំលៃទីផ្សារផងដែរ ដែលសកម្មភាពនេះគេឱ្យឈ្មោះថា**រដ្ឋភាវូបនីយកម្ម ឬជាតូបនីយកម្ម** (Nationalization) ។

ដោយយោងទៅលើភាពសាំញ៉ាំនៃកម្មសិទ្ធិនេះ ទើបរដ្ឋនីមួយ១កំណត់ឱ្យច្បាស់នូវប្រធាន**នៃកម្មសិទ្ធិឯកជន និងកម្មសិទ្ធិរដ្ឋ** ។ ចំពោះកម្មសិទ្ធិឯកជន ប្រធានរបស់វាគេអាចពិនិត្យយ៉ាងងាយស្រួល **ប៉ុន្តែប្រធាននៃកម្មសិទ្ធិរដ្ឋមានការលំបាកបំផុត** ពីព្រោះអ្នកទទួលគ្រប់គ្រងទៅលើកម្មសិទ្ធិនោះមានបុគ្គលច្រើនប្រភេទ ហើយពួកគេទាំងនោះហើយដែលទាញយកផលប្រយោជន៍ពីកម្មសិទ្ធិសាធារណៈទាំងនោះ ប៉ុន្តែពួកនោះពុំមានទទួលខុសត្រូវទេ នៅពេលច្បាប់ចោទទៅលើពួកគាត់ ។ ត្រង់ចំណុចនេះពួកអ្នកគ្រប់គ្រងទាំងនោះយល់ថា បើមានប្រយោជន៍ចំពោះទ្រព្យនោះគាត់ទាយកដាក់ជាកម្មសិទ្ធិរបស់គាត់តាមទ្រង់ទ្រាយដោយផ្ទាល់ ឬប្រយោល ប៉ុន្តែបើសិនជាមានការខាតបង់ ឬតំរូវឱ្យទទួលខុសត្រូវចំពោះមុខច្បាប់ គាត់ដោះសារថាទ្រព្យនោះជារបស់រដ្ឋ ដើម្បីយកប្រៀប ឬគេចចេញពីការទទួលខុសត្រូវ ។

ដើម្បីបញ្ជាក់ពីប្រធាននៃសិទ្ធិកម្មសិទ្ធិឱ្យបានច្បាស់លាស់ ដូចមាត្រា ៣ នៃច្បាប់កម្មសិទ្ធិរបស់រដ្ឋកាសាក់ស្ថាន ( រដ្ឋនៅអាស៊ីកណ្ដាល) ថ្ងៃទី ៩ ខែមេសា ឆ្នាំ ១៩៩៣ បានកំណត់អំពីប្រធាននៃកម្មសិទ្ធិថា :

"១.**ប្រធាននានានៃសិទ្ធិកម្មសិទ្ធិឯកជនមាន :** ពលរដ្ឋនៃសាធារណៈរដ្ឋកាសាក់ស្ថាន, ពលរដ្ឋបរទេស, បុគ្គលគ្មានសញ្ជាតិ និងរួមទាំងនិម្មិតកម្មសង្គមនានាដែលបង្កើតដោយពួកគេ ដូចជានីតិបុគ្គលនានាជាដើម ។

**២. សាធារណៈរដ្ឋកាសាក់ស្ថាន** : គឺជាប្រធានតែមួយគត់នៃសិទ្ធិកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ដែលទ្រព្យទាំងនោះស្ថិតនៅលើទឹកដីនៃសាធារណៈរដ្ឋ ។

**ក្នុងនាមសាធារណៈរដ្ឋកាសាក់ស្ថាន** ការប្រទានសិទ្ធិអំណាចចំពោះ**ការកាន់កាប់, ការប្រើប្រាស់** និង**ការចាត់ចែង**ទៅលើទ្រព្យសម្បត្តិរដ្ឋនោះ ត្រូវបំពេញភារកិច្ចដោយ**រដ្ឋសភានៃសាធារណៈរដ្ឋកាសាក់ស្ថាន** ។

រដ្ឋសភាកាសាក់ស្ថាន **អនុម័តនូវបទដ្ឋានកិច្ចទាំងឡាយ** ( ច្បាប់ ឬសេចក្ដីសំរេច) ដែលបទបញ្ញត្តិទាំងនោះ**ធ្វើនិយ័តកម្ម**ទៅលើទំនាក់ទំនងកម្មសិទ្ធិ ហើយ**ផ្ទេរសិទ្ធិអំណាចចំពោះការកាន់កាប់, ការប្រើប្រាស់** និងការចាត់ចែងនូវទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់រដ្ឋ **ទៅឱ្យគណៈរដ្ឋមន្ត្រី**នៃសាធារណៈរដ្ឋកាសាក់ស្ថាន **ដើម្បីបំពេញភារៈកិច្ចនៅក្នុងល័ក្ខខ័ណ្ឌនានា ដែលបានកំណត់ដោយច្បាប់** ។

**អង្គការតំណាង** ឬ**អង្គការអនុវត្តនានានៅមូលដ្ឋាន** តាមក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន ក្នុងការបំពេញនាទីនូវសិទ្ធិកាន់កាប់, **ប្រើប្រាស់** និងសិទ្ធិគ្រប់គ្រងចំពោះទ្រព្យសម្បត្តិទាំងនោះ ត្រូវបានប្រគល់ទៅឱ្យ**រដ្ឋបាលដែនដីមូលដ្ឋាន ដោយគណៈរដ្ឋមន្ត្រី**" ។

ដូចនេះ ការទទួលខុសត្រូវពិតជាមានលក្ខណៈសុក្រឹត្យបំផុត ចំពោះទ្រព្យសម្បត្តិរដ្ឋ ។

**ឥ.ការងារ** (Labour) ៖ អត្ថន័យនៃពាក្យការងារពុំមានលក្ខណៈដូចពាក្យធ្វើពលកម្ម ឬក៏សកម្មភាពនៃផលប្រយោជន៍សាធារណៈនោះទេ ។ លក្ខណៈពិសេសរបស់វាត្រង់ថាការងារវានាំមកនូវមធ្យោបាយផ្ទាល់សំរាប់ជីវិតរបស់មនុស្ស ដែលជាប្រភពនៃអត្ថិភាព (Existence) នៃជីវិត ។ ជាឧទាហរណ៍ អ្នកវិចិត្រករពីរនាក់បានគូសផ្ទាំងគំនូរជាច្រើន (បង្កើតផ្ទាំងគំនូរជាច្រើន) ។ នេះជាពលកម្មរបស់ពួកគេ ជាមុខរបររបស់ពួកគេ ជាវិជ្ជាជីវៈរបស់ពួកគេ ។ ប៉ុន្តែសំរាប់វិចិត្រករម្នាក់ៗក្នុងចំណោមអ្នកទាំងពីរនោះ ពួកគេមានគោលដៅតែមួយគត់ (គ្មានពីរ) ឬក៏ប្រភពគ្រឹះនៃមធ្យោបាយឆ្ពោះទៅរកភាពបង្កើតឱ្យមាន (Existence) នៃរូបភាពនោះ ។ ដើម្បីលាបពណ៌ដំបូងនៃផ្ទាំងគំនូរទាំងនោះវាជាការងារ ព្រោះគេមានវិជ្ជាជីវៈជាងគំនូរ (បង្កើតឱ្យមាន) ទីពីរ គឺធ្វើឱ្យវាមានរូបរាងឡើងតាមការសំដែងចេញរបស់សាមីជន គឺធ្វើសកម្មភាពគូសវាសវាជាពលកម្ម ។

ក្នុងរដ្ឋធម្មនុញ្ញ និងប្រភពទាំងឡាយនៃនីតិរដ្ឋធម្មនុញ្ញនាសតវត្សចុងក្រោយនេះ គេបានផ្តុកនូវការកើតចំពោះការធានាមួយ ដែលជំរុញ និងការការពារទៅលើការងាររបស់មនុស្ស ដូចជាវាក្យខណ្ឌទី ២ នៃមាត្រា ៤៨ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខមាលភាពរបស់កុមារ" ។ និងមានមាត្រាជាច្រើនទៀតដែលកំណត់អំពីការងារដូចជាមាត្រា ៣៦ ជាដើម ។

**ឈ.គោលការណ៍ធម្មនុញ្ញភាពនិយុត្តិលើកិច្ចការសេដ្ឋកិច្ច** ៖ គោលការណ៍នេះ គឺរដ្ឋធម្មនុញ្ញបានកំណត់តាមរយៈបទដ្ឋានរបស់ខ្លួន ទៅលើគោលការណ៍នៃការប្រើប្រាស់ទ្រព្យសម្បត្តិ (ធនធានជាតិ) ក្នុងផលប្រយោជន៍សាធារណៈ ដោយមិនអាស្រ័យនឹងម្ចាស់កម្មសិទ្ធិនោះទេ ។

ដើម្បីសំរេចផលទៅលើទិសដៅទាំងនេះ គឺត្រូវកំណត់ដោយយថាប្រភេទ[២៨] ច្បាស់លាស់ (Specific Character) នៃល័ក្ខខ័ណ្ឌទាំងឡាយរបស់ប្រទេសនីមួយៗ ។ ដោយយោងទៅលើគោលការណ៏ផ្សេងៗនោះគេអាចបន្ថយ ឬលុបចោលនូវលក្ខណៈណាមួយ ដែលលក្ខណៈទាំងនោះវាប៉ះពាល់ដល់ប្រវត្តិសាស្ត្រនៃប្រទេសរបស់គេ ។ ដូចជា**មាត្រា ៥៩** នៃរដ្ឋធម្មនុញ្ញកម្ពុជា កំណត់ថា "រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ដីធ្លី ទន្លេ អាកាស ភោគោត្តសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល" ។ ជាងនេះទៀត រដ្ឋធម្មនុញ្ញបានកំណត់នូវគោលការណ៏នៃកិច្ចការសេដ្ឋកិច្ច ដូចជា**មាត្រា ៥៦** បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ និងមានកំណត់ក្នុងច្បាប់" ។

ដោយប្រទេសខ្លះមានប្រវត្តិសាស្ត្រ និងទីតាំងរបស់ប្រទេសស្ថិតជាមូលដ្ឋានដោយឡែកៗពីគ្នា ដូចប្រទេសខ្លះជាប្រទេសឧស្សាហកម្ម ឬសំបូររ៉ែ រីឯប្រទេសខ្លះទៀតមានដី ក្នុងស្ថានភាពកសិកម្ម......។ល។ គោលការណ៏កសិកម្មមាន ដូចជា**មាត្រា ៦១** បានកំណត់ "រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេស កសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើនយោបាយ ទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន" ។ ជាពិសេសរដ្ឋជួយរកទីកន្លែងសំរាប់លក់ផលិតផលកសិកម្ម ដែលជាផលិតផលជាតិរបស់គេ ដូចជា**មាត្រា ៦២** បានកំណត់ថា "រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផលជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល" ។ មួយវិញទៀត រដ្ឋហាមឃាត់នូវការធ្វើសេដ្ឋកិច្ចផ្តាច់មុខ (Monopoly) ដែលជាតួនាទីដ៏សំខាន់នៃគោលការណ៏

---

[២៨]. ប្រទេសនីមួយៗមានធនធានធម្មជាតិខុសៗគ្នា ។ ការកំណត់បាននូវប្រភេទពិសេសៗ ខុសៗគ្នាទៅលើទ្រព្យទាំងនោះ គេឱ្យឈ្មោះថាជាយថាប្រភេទនៃទ្រព្យ ឬធន ។ ជាឧទាហរណ៏ ប្រទេសកម្ពុជាមានសមុទ្រ តែប្រទេសឡាវគ្មានសមុទ្រទេ ។ សមុទ្រប្រទេសកម្ពុជាសំបូរត្រី តែសមុទ្រប្រទេសថៃសំបូរបង្គារ ។ល។

ធម្មនុញ្ញភាពតិយុត្តិក្នុងវិស័យសេដ្ឋកិច្ចរបស់ប្រទេស ។ លើសពីនេះរដ្ឋបានការពារដល់អ្នកប្រើប្រាស់ ផលិតផល ដូចជា**មាត្រា ៦៤** "រដ្ឋហាមឃាត់ និងផ្តន្ទាទោសជាទម្ងន់ដល់ជនណាដែលនាំចូលផលិត ផលលក់ដូរគ្រឿងញៀន ទំនិញក្លែងក្លាយហួសរយៈពេលប្រើប្រាស់ ដែលប៉ះពាល់ដល់សុខភាព អាយុ ជីវិតរបស់អ្នកប្រើ" ។ និងមានគោលការណ៍ជាច្រើនទៀត ដែលទាក់ទិនទៅនឹងវិស័យសេដ្ឋកិច្ច ។

## ២. ប្រព័ន្ធហិរញ្ញវត្ថុ

ប្រព័ន្ធហិរញ្ញវត្ថុជាដៃគូរដ៏សំខាន់នៃប្រព័ន្ធសេដ្ឋកិច្ច ឬក៏ជាធាតុពិសេសរបស់ប្រព័ន្ធសេដ្ឋកិច្ច ពីព្រោះតាមរយៈយន្តកម្មនៃហិរញ្ញវត្ថុ. រដ្ឋអាចដោះស្រាយបាននូវបញ្ហាសេដ្ឋកិច្ចរបស់ខ្លួន ក្នុងល័ក្ខ ខ័ណ្ឌធម្មតាបានយ៉ាងងាយ ។ ដូចនេះពុំមែនជាបញ្ហាចៃដន្យនោះទេ យន្តកម្មហិរញ្ញវត្ថុវាជានិន្នាការ ឆ្ពោះទៅធ្វើនិយ័តកម្មទូទៅ នៃទំនាក់ទំនងហិរញ្ញវត្ថុក្នុងរដ្ឋធម្មនុញ្ញ ។

ទំនាក់ទំនងហិរញ្ញវត្ថុទាំងនោះមាន ដូចជាថវិកា ពន្ធដារ ជាពិសេសវាកំណត់នូវតួនាទីក្នុង វិស័យហិរញ្ញវត្ថុនេះចំពោះសមាជិកនៃរដ្ឋរបស់គេ ឬក៏ស្ថាប័នដែលមានសារៈសំខាន់ចំពោះការចាយ វាយ និងចំណាយផ្សេងៗ ។ ដូចជា**មាត្រា ៥៦** "ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រពន្ធ័សេដ្ឋកិច្ច ទីផ្សារ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ និងមានកំណត់ក្នុងច្បាប់" ។ និង**មាត្រា ៥៧** "ការយកពន្ធដារនឹងអាចធ្វើទៅបានលុះត្រាតែច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឱ្យ អនុវត្តតាមច្បាប់ ។

របបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់" ។ **មាត្រា ៩០** ក្នុងវាក្យ ខ័ណ្ឌទីពីរ កំណត់ថា "សភាអនុមត័ថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេ ខ្ចី ការសន្យាផ្នែកហិរញ្ញវត្ថុ បង្កើត កែប្រែ ឬលុបចោលពន្ធដារ" ។ ផ្ទុយទៅវិញតាមច្បាប់ស្តីពីប្រព័ន្ធ ហិរញ្ញវត្ថុកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់ក្នុង**មាត្រា ១** ថា "ច្បាប់ហិរញ្ញវត្ថុគ្រោង និងអនុញ្ញាត សំរាប់ឆ្នាំនីមួយៗនូវសំណុំនៃធនធាន និងបន្ទុកទាំងអស់របស់រដ្ឋក្នុងក្របខណ្ឌតំរង់ទិស និងគោលដៅ

របស់ជាតិក្នុងវិស័យសេដ្ឋកិច្ច និងសង្គម ហើយនិងគិតគូរដល់ការថែរក្សាតុល្យភាព ហិរញ្ញវត្ថុ និងរូបិយវត្ថុជាសារវន្ត............"។ និង **មាត្រា ២** កំណត់ថា "លក្ខណៈច្បាប់ហិរញ្ញវត្ថុរួមមាន :

១. ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងច្បាប់កែសំរួលនានា

២. ច្បាប់ទូទាត់នៃថវិកា"។

ដូចនេះ ប្រព័ន្ធហិរញ្ញវត្ថុត្រូវតែកំណត់ឱ្យបានច្បាស់លាស់ ព្រោះវាផ្សារភ្ជាប់នឹងប្រព័ន្ធសេដ្ឋកិច្ចក្នុងល័ក្ខខ័ណ្ឌនៃការទូទាត់. ចាយវាយ ឬក៏ផ្លាស់ប្តូរ ក្នុងការធ្វើចរាចរណ៍ក្រដាសប្រាក់ជាដើមរបស់ស្ថាប័នរដ្ឋ និងឯកជនសំរាប់កិច្ចការពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ។

ជាការពិតណាស់ ពលរដ្ឋជាប្រភពនៃអំណាច ហើយក៏ជាប្រភពនៃថវិការដ្ឋដែរ តាមរយៈនៃការយកពន្ធរបស់រដ្ឋទៅលើពួកគេ ក្នុងក្របខ័ណ្ឌនៃការធ្វើសកម្មភាពពាណិជ្ជកម្ម។ ប៉ុន្តែបើការកំណត់ប្រព័ន្ធចំណូលថវិកាមិនបានច្បាស់លាស់ ឬមិនមានសមភាព ឬតុល្យភាពទេ នោះធ្វើឱ្យរដ្ឋមានភាពក្រខ្សត់ រីឯបុគ្គលពោរពេញទៅដោយទ្រព្យសម្បត្តិ ។

**អត្ថបទទី ១០**

# ការសិក្សាអំពីរដ្ឋ

## ១. រដ្ឋមានលក្ខណៈជាទ្វីស្តី

ពាក្យថារដ្ឋគឺយើងបានស្គាល់ និងលឺស្ទើរតែគ្រប់ៗគ្នារួចទៅហើយ ។ តាមព្រះតំរិះរបស់ស្តេចបារាំង ព្រះនាមល្វីស (Louise) នាសតវត្សទី XIV ព្រះអង្គបានឱ្យអត្ថន័យសង្ខេបខ្លីទៅលើរដ្ឋថា "**រដ្ឋ គឺខ្ញុំ**" ពីព្រោះសម័យនោះរដ្ឋជាកម្មសិទ្ធិរបស់ស្តេច (របបរាជានិយមដាច់ខាត) ។ ប៉ុន្តែតាមការប្រើប្រាស់នៅក្នុងសង្គមបច្ចុប្បន្ន ពាក្យថារដ្ឋមានអត្ថន័យពីរគឺ :

⇨ **ន័យទីមួយ** : ជា "**ប្រទេស**" គឺការបង្កើតភូមិសាស្ត្រនយោបាយ ឬទីតាំងនយោបាយ ។

⇨ **ន័យទីពីរ** : ជាអង្គការនៃអំណាចនយោបាយ និងជាប្រព័ន្ធស្ថាប័ននៃអំណាច ឬការគ្រប់គ្រង ។

ដូចនេះដោយសរុបទៅលើអត្ថន័យទាំងពីរនៃរដ្ឋ យើងអាចសំគាល់បានថា រដ្ឋគឺ**ជាអង្គការនយោបាយដោយមានកំលាំងជំនួយ ក្នុងការបំពេញនាទីគ្រប់គ្រងទៅលើសង្គម** ។

ដោយយោងតាមអត្ថន័យជាទ្វីស្តីរបស់រដ្ឋ គេអាចសិក្សាទៅលើលក្ខណៈដែលជាមូលដ្ឋានគ្រឹះមួយចំនួនរបស់វាដូចខាងក្រោម :

**ក.មុខងារនៃរដ្ឋ** : មុខងាររដ្ឋជាទំហំនៃ*ភារកិច្ចទូទៅ* ដែលត្រូវបានបំពេញកិច្ចដោយឧបករណ៍នានា[២៩] របស់រដ្ឋក្នុងការគ្រប់គ្រង និងដឹកនាំប្រទេស ។ ដោយមុខងាររដ្ឋមានភាពទូលាយពេកនោះគេអាចចាត់ថ្នាក់នៃមុខងាររដ្ឋជាពីរធំៗ គឺ**មុខងារផ្ទៃក្នុង** និង**មុខងារផ្ទៃក្រៅ** (**មើលរូបទី ៧**) ។

---

[២៩] .មើលចំនុច "ង" នៃអត្ថបទនេះ ស្តីអំពីឧបករណ៍រដ្ឋ ។

**ក១. មុខងារផ្ទៃក្នុង** : គឺជាទិន្នាការមូលដ្ឋានគ្រឹះសំខាន់ៗ ដែលមុខងារនេះស្ថិតក្នុងក្របខណ្ឌនៃប្រទេសសុក្រឹត្យមួយ ហើយត្រូវបានកំណត់នូវលក្ខណៈ**នយោបាយផ្ទៃក្នុងរបស់រដ្ឋ**។ ជាទូទៅមុខងារផ្ទៃក្នុងនេះចែកជាលំដាប់ថ្នាក់មួយចំនួនដូចតទៅ :

**ក១.១. មុខងារនិយ័តកម្ម** : នេះជាមុខងារទាំងឡាយដែលរដ្ឋត្រូវគិតដល់**សិទ្ធិ ភាតព្វកិច្ច សេរីភាព**របស់ពលរដ្ឋ និងការប្រតិបត្តិនូវនិយត័ភាព និងសណ្តាប់ធ្នាប់គតិយុត្តិទាំងឡាយ ដូច**មាត្រា ទី ៣១** នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ កំណត់ថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិ សេរីភាពនេះត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់" ។ និងកំណត់ថែមទៀតនូវទំហំសិទ្ធិរបស់ពលរដ្ឋ នៃរដ្ឋធម្មនុញ្ញបានកំណត់ក្នុង**មាត្រាទី ៣២** ថា "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន"។ និង**មាត្រាទី ៦៥** "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡា ដែលជាសុខភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប.............."។

ចំពោះ**ការការពារទំរង់ផ្សេងៗនៃកម្មសិទ្ធិ** : មានដូចជា**មាត្រាទី ៤៤** "ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ឋិតនៅក្រោមការគាំពារនៃច្បាប់ ។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតំរូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌"។

ចំពោះ**ការការពារដល់បរិដ្ឋាន** : មានក្នុង**មាត្រាទី ៥៩** "រដ្ឋត្រូវរក្សាការពារបរិដ្ឋាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី អាកាស ខ្យល់ ភោគោតសាស្ត្រ ប្រពន្ធ័អេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និង ខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធាន ជលផល"។ សរុបទៅមុខងារការពារនេះមានទាំងសណ្តាប់ធ្នាប់សង្គម និងការពារទ្រព្យសម្បត្តិសង្គម ។

**ក១.២. មុខងារគ្រប់គ្រងសេដ្ឋកិច្ច : គឺជាមុខងារដែលបញ្ជាក់នូវតួនាទីរដ្ឋ ក្នុងការគ្រប់គ្រងលើផលិតកម្មសាធារណៈ, ការរីកចំរើនសេដ្ឋកិច្ច, តួនាទីក្នុងការបង្កើតលក្ខខ័ណ្ឌចាំបាច់នានា សំរាប់បង្កើតនូវទំរង់អត្តភាព** ។ ក្នុងមុខងារនេះចែកចេញជាច្រើនប្រភេទដូចជា :

**ក១.២.១.មុខងារសេដ្ឋកិច្ច :** មុខងារនេះមានលក្ខណៈជាច្រើនប្រភេទ ដែលធ្វើនិយ័តកម្មទៅលើទំនាក់ទំនងមួយចំនួនដូចខាងក្រោម :

⇨ **ការកែច្នៃនយោបាយសេដ្ឋកិច្ច** : តាមលក្ខណៈនេះដូចជា**មាត្រាទី ៥៦** នៃរដ្ឋធម្មនុញ្ញកម្ពុជាកំណត់ថា "ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះនឹងមានកំណត់ក្នុងច្បាប់"។ និង**មាត្រា ៥៧** "ការយកពន្ធដារនឹងអាចធ្វើទៅបានលុះត្រាតែមានច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់ ។ របបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់"។ ខ្លឹមសារនៃចំនុចនេះ គឺត្រូវការកែច្នៃនូវរាល់ផលិតផលនានាក្នុងស្រុកឱ្យមានតុល្យភាព និងបង្កឱ្យមានភាពងាយស្រួលដល់ចរាចរទំនិញទៅក្រៅប្រទេស ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយដែលមិនស្របគ្នានឹងអព្យាក្រឹត្យភាពរបស់ខ្លួនឡើយ ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតិឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតិឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងក្នុងក្របខណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជាសំភារៈយោធា អាវុធគ្រាប់រំសេវ ការហ្វឹកហ្វឺនកងកំលាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀតដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅក្នុងប្រទេស" ។

**ក២.១.២.កិច្ចការពារសេដ្ឋកិច្ចក្រៅប្រទេស និងសហប្រតិបត្តិការក្នុងវង្វង់មនុស្សធម៌ និងក្នុងវិស័យការពារធម្មជាតិ** ៖ នេះជាកិច្ចការដ៏ធំបំផុតមួយ និងសំាញ៉ាំ ដែលរដ្ឋនីមួយៗមានកាតព្វកិច្ចជួយគ្នាទៅវិញទៅមក នៅពេលដែលប្រទេសដ៏ទៃមានគ្រោះអាសន្ន ឬក៏ពួកពាណិជ្ជកររបស់ខ្លួនត្រូវបានគេបំពាន ឬគ្រោះថ្នាក់នៅក្រៅប្រទេស ។ ការការពាររបៀបនេះ វាជាកិច្ចសហការមួយប្រកបដោយលក្ខណៈមនុស្សធម៌ដ៏ពិតៗ ក្នុងគោលដៅជួយគ្នាពេលមានអាសន្ន ។

**ក២.២. មុខងារការពារប្រទេស ឬកងទ័ព** ៖ជាមុខងារមួយសំរាប់ឆ្លើយតបយ៉ាងប្រញាប់នូវរាល់តំរូវការរបស់ប្រទេស ដែលមានការគំរាមកំហែងពីប្រទេសដទៃ ។ ដូចជា**មាត្រាទី ៥២** "រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យអធិបតេយ្យភាព បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការការពារឯកភាពជាតិ រក្សាការពារទំនៀមទំលាប់ និងប្រពៃណីល្អរបស់ជាតិ ។ រាជរដ្ឋាភិបាល ត្រូវការពារនីត្យានុកូលភាពធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ....." ។ សូមសំគាល់ថា មុខងារផ្ទៃក្នុង និងមុខងារការបរទេសត្រូវបំពេញគ្នាទៅវិញទៅមកមិនអាចខ្វះបាន ។

**ខ.សន្ទស្សន៍នៃរដ្ឋ ឬសញ្ញាណសំគាល់នៃរដ្ឋ** : ជាទូទៅគេសង្កេតឃើញសញ្ញាណសំគាល់ទៅលើរដ្ឋមាន ៤ ប្រភេទសំខាន់ៗគឺ :[៣០]

១.ទឹកដី

២.ប្រជាជន

៣.អំណាចសាធារណៈ ឬអំណាចរដ្ឋ

៤.ការប្រមូលពន្ធ

**ខ₁. ទឹកដី** : ជាសញ្ញាណមួយរបស់រដ្ឋ ដើម្បីកំណត់នូវសង្គមមួយដែលមានដី ផ្ទៃក្រឡានៃភូគោល ( ដីគោក សមុទ្រ អាកាស) ព្រំប្រទល់ដែន និងរបប ( ប្រព្រឹត្តកម្ម) នៃអង្គការគ្រប់គ្រងផ្ទៃក្នុងរដ្ឋ តាមក្របខ័ណ្ឌនៃព្រំដែនរដ្ឋបាលនៃភូមិសាស្ត្រនោះ ។ ទាំងនេះហើយបញ្ជាក់ថា "**រដ្ឋ**" ពីព្រោះថាវាមានទីតាំងភូមិសាស្ត្រពិតប្រាកដ និងជាពិសេសវាមាន**អង្គការនៃអំណាចនយោបាយ** ( ប្រទេស) មានន័យថា មានអង្គការគ្រប់គ្រងអំណាចនយោបាយរបស់ប្រទេស ។ ដូច**មាត្រាទី ២** នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួន ដែលមានក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩"។ ដូចនេះភូមិសាស្ត្រវាជាធាតុមួយយ៉ាងសំខាន់ដែលមិនអាចខ្វះបាន ក្នុងការទទួលស្គាល់ទៅលើរដ្ឋមួយ ។

**ខ₂.ប្រជាជន** : នេះជាសមាសភាគ ឬ "**ភាពទំនាក់ទំនង**" ដែលផ្តុកផ្តាក់ទៅដល់មនុស្សក្នុងសង្គមពិត ឬរដ្ឋសុក្រិត្យមួយ ។ នៅក្នុង**ភាពជាពលរដ្ឋ**, លំដាប់ថ្នាក់ និងទំរង់នៃការផ្តល់ជូននូវសិទ្ធិជាពលរដ្ឋ, ការកាន់កាប់ជាពលរដ្ឋ, និងការបោះបង់ពីពលរដ្ឋ ។ល។ ទាំងអស់នោះវាជាធាតុចាំបាច់គ្រប់រដ្ឋត្រូវតែមានសមាជិកខ្លួន ដែលក្នុងនោះគឺពលរដ្ឋហើយត្រូវចារឹកនូវខ្លឹមសារពលរដ្ឋទាំងនោះ អំពីភាពជាកម្មសិទ្ធិរបស់រដ្ឋ ។ តាមលក្ខណៈនេះ រដ្ឋធម្មនុញ្ញបានកំណត់នៅ**មាត្រាទី ៣១** ថា

---

[៣០] .នៅក្នុងទ្រឹស្តីរដ្ឋ ការសរសេររបស់អ្នកនិពន្ធខ្លះមានតែបីទេ គឺពុំមានចំនុច "ការប្រមូលពន្ធនោះទេ" ព្រោះវាស្ថិតក្នុងអំណាចសាធារណៈរួចទៅហើយ ។

"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង**គោរពសិទ្ធិមនុស្ស** ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ......."។ និង **មាត្រាទី ៣៣** កំណត់ថា "**ប្រជាពលរដ្ឋខ្មែរ**មិនត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។ ការទទួលសញ្ជាតិត្រូវកំណត់ក្នុងច្បាប់"។

ដូចនេះ បើគេនិយាយថាកិច្ចការមួយ**តាមរយៈរដ្ឋ** គឺមានន័យថាស្មើនឹង "**តាមរយៈប្រជាជន**" ដែលកិច្ចការនោះនាំមកនូវភាពប្រមូលផ្តុំនៃមនុស្សទាំងពួង នៅក្នុងក្របខ័ណ្ឌនៃសង្គមរបស់ពួកគេ ហើយពួកទាំងនោះសំដែងចេញនូវលក្ខណៈជាឋានៈមួយ ដែលមានទិដ្ឋភាពជាសរីរាង្គនៃអធិបតេយ្យភាពនៅក្នុងសង្គមនៃពលរដ្ឋនោះ ។ ដូចនេះ ពលរដ្ឋវាជាធាតុផ្សំទីពីរដែលរស់នៅក្នុងសង្គមមួយក្នុងលក្ខណៈជារដ្ឋសុក្រឹត្យ ។

**ខ៣. អំណាចសាធារណៈ** : អត្ថន័យនៃអំណាចសាធារណៈ វាមានភាពផ្សេងៗគ្នាជាច្រើន ឬក៏តាមទំរង់នៃអំណាចនយោបាយ។ មានន័យថាអំណាចរដ្ឋជា**ឧបករណ៍ពិសេស**មួយ សំរាប់ដឹកនាំរដ្ឋតាមរយៈឥទ្ធិពលរបស់អំណាចនោះ ។ យើងបានដឹងហើយថា គ្រប់សង្គមមនុស្សរួមមានប្រជាជន គ្រប់ប្រជាជនមានសំភារៈគ្រឹះមួយមានលក្ខណៈជាសាធារណៈ ឬសមូហភាព[៣១] គឺទ្រព្យសម្បត្តិមានន័យថាគ្រប់មនុស្សត្រូវតែមានសំភារៈ ឬទ្រព្យសម្បត្តិ និងប្រភពនៃប្រាក់ចំណូលទាំងឡាយ ។ ដូចនេះមនុស្សម្នាក់ៗក៏មានអំណាចដែរ ដោយអំណាចនោះប្រមូលផ្តុំពីមនុស្សជាច្រើន ហើយមនុស្សទាំងនោះស្ម័គ្រចិត្តប្រគល់ទៅឱ្យតំណាងរបស់ពួកគេក្នុងការដឹកនាំ រីឯមនុស្សទាំងនោះប្រើប្រាស់អំណាចនោះតាមរយៈតំណាងរបស់ពួកគេទាំងនោះ ហើយដែលហៅថាអំណាចសាធារណៈ ។

[៣១] ក្នុងអត្ថន័យនេះ ពុំបកស្រាយលើប្រភេទនៃកម្មសិទ្ធិទេ ជាពិសេសទ្រព្យឯកជន ប៉ុន្តែការលើកមកនេះ គឺសំដៅប្រភពនៃការប្រមូលផ្តុំមនុស្សជាក្រុម ដើម្បីបង្កើតឱ្យមានអំណាចសាធារណៈ ហើយទីបំផុតជាអំណាចរដ្ឋ ។

ពាក្យថាសាធារណៈមានន័យថារដ្ឋ ដូចនេះអំណាចសាធារណៈ គឺជាអំណាចរដ្ឋនៅក្នុង **ល័ក្ខខ័ណ្ឌប្រជាធិបតេយ្យ** ផ្ទុយទៅវិញនៅក្នុង**ល័ក្ខខ័ណ្ឌអប្រជាធិបតេយ្យ** អំណាចរដ្ឋកើតមានលក្ខណៈផ្តាច់ការ ដោយអំណាចនោះពុំកើតឡើងតាមរយៈប្រជាជនទេ ជាពិសេស**អំណាចនីតិប្រតិបត្តិ** និង**អំណាចនីតិបញ្ញត្តិ**។ យើងពិនិត្យប្រភពនៃអំណាចតាម**មាត្រាទី ៥១** នៃរដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។ **អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ** ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា, ព្រឹទ្ធសភា, រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ"។ រីឯការកំណត់អំណាចរដ្ឋដែលកើតឡើងតាមរយៈប្រជាពលរដ្ឋនោះ ដូច**មាត្រា ៧៦** ក្នុងវាក្យខណ្ឌទី ២ បញ្ជាក់ថា "តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមនីតិវិធីជ្រើសរើសឆ្នោតជាសំងាត់"។ សរុបទៅអំណាចរដ្ឋជាធាតុសំខាន់បំផុតសំរាប់ទទួលស្គាល់ទៅលើរដ្ឋមួយ ដើម្បីគ្រប់គ្រង និងដឹកនាំសមាជិកសង្គមក្នុងទីតាំងភូមិសាស្ត្រពិតណាមួយ ។

**ខ៥. ការប្រមូលពន្ធ** : ការប្រមូលពន្ធជាគ្រឹះមួយយ៉ាងសំខាន់សំរាប់ថវិការដ្ឋ ដើម្បីឱ្យរដ្ឋមានលទ្ធភាពក្នុងសកម្មភាពនានា ឱ្យមានអត្ថិភាពនៃរដ្ឋមួយ ។ ត្រង់នេះបញ្ជាក់ថារដ្ឋមានសកម្មភាពបានលុះត្រាតែមានថវិកា ដូចនេះរដ្ឋត្រូវប្រមូលពន្ធពីសមាជិករបស់ខ្លួន ដើម្បីដាក់ចូលជាថវិការដ្ឋតាមក៏រិតពិតប្រាកដមួយ ។ **មាត្រាទី ៥៧** នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "ការយកពន្ធដារនឹងអាចធ្វើទៅបានលុះត្រាតែមានច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់ ។ របបគ្រប់គ្រងរូបិយវត្ថុត្រូវកំណត់ក្នុងច្បាប់"។ ដូចនេះ ការយកពន្ធគឺជាប្រភពមួយដើម្បីរកថវិកាជូនរដ្ឋ ក្នុងទិសដៅធ្វើសកម្មភាពទៅមុខ ក្នុងក្របខ័ណ្ឌរក្សាឱ្យបាននូវនិរន្តរភាពរដ្ឋ ។

**ច.អធិបតេយ្យនៃរដ្ឋ ឬអធិបតេយ្យភាពនៃរដ្ឋ** : អធិបតេយ្យភាពរដ្ឋ គឺមានន័យថារដ្ឋមានអំណាចគ្រប់គ្រងតែមួយ (រួម) ។ គេប្រើប្រាស់វាសំរាប់រដ្ឋ គឺក្នុងវង្វង់នៃកិច្ចការរដ្ឋ ឬកិច្ចការសាធារណៈ ឬកិច្ចស្វ័យសំរេច ។

ដូចនេះ អធិបតេយ្យភាពនៃរដ្ឋ **គឺជាភាពឯករាជ្យនៃអំណាចរដ្ឋទៅលើអំណាចដទៃផ្សេងទៀត (នយោបាយ និងមនោគមវិជ្ជា) ក្នុងប្រទេស និងក្រៅប្រទេស ដែលសំដែងចេញនូវសិទ្ធិពេញលេញដោយស្វ័យភាព និងដោះស្រាយការងាររបស់ខ្លួនដោយសេរី គ្មានការបញ្ជា ឬណែនាំពីរដ្ឋបរទេស ។** មាត្រាទី ១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជាជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ" ។ តាមលក្ខណៈនៃរដ្ឋអធិបតេយ្យបញ្ជាក់ថា ពលរដ្ឋជាសមត្ថភាពរបស់រដ្ឋសំរាប់បំពេញមុខងាររបស់ខ្លួន តាមរយៈកំលាំងដែលជាឧបករណ៍រដ្ឋ ។ ក្នុងខណៈនេះ អធិបតេយ្យភាពពុំមែនជាមូលដ្ឋានគ្រឹះនៃការប្រឆាំងនឹងអំពើនៃច្បាប់ណាមួយនោះទេ គឺសំរេចកិច្ចការដោយមានច្បាប់ជាបង្អែក ។

គេសង្កេតឃើញអធិបតេយ្យភាពនៃរដ្ឋ ឬកិច្ចស្វ័យសំរេចរបស់រដ្ឋមានពីរប្រភេទធំៗគឺ **កិច្ចស្វ័យសំរេចផ្ទៃក្នុង និងកិច្ចស្វ័យសំរេចផ្ទៃក្រៅនៃរដ្ឋ** ។

**ច១. កិច្ចស្វ័យសំរេចផ្ទៃក្នុង** : នេះជាសិទ្ធិពិសេស ពេញលេញលើនីតិកម្ម (Legislation) ឬបទដ្ឋានទាំងឡាយដើម្បីធ្វើនិយ័តកម្មទៅលើការគ្រប់គ្រង ឬសណ្តាប់ធ្នាប់សង្គម និងយុត្តាធិការ (Jurisdiction) នៃផ្ទៃក្នុងប្រទេសក្នុងក្របខណ្ឌនៃទឹកដីរដ្ឋរបស់ខ្លួន ។ ក្នុងន័យនេះរដ្ឋហ៊ានធ្វើអ្វីៗទាំងអស់ដើម្បីរក្សា និងការពារសណ្តាប់ធ្នាប់សាធារណៈ ដោយពុំមានរដ្ឋបរទេសណាមួយហ៊ានជ្រៀតជ្រែកកិច្ចការទាំងនេះបានឡើយ ។

**គ២.កិច្ចស្វ័យសំរេចផ្នែកខាងក្រៅ** : ជាស្វ័យភាព និងឯករាជ្យភាពក្នុងកិច្ចការក្រៅប្រទេស មិនអនុញ្ញាតិឱ្យមាននូវរាល់បទអន្តរាគមន៍ក្នុងកិច្ចការផ្ទៃក្នុង (ប្រទេស) នៃរដ្ឋដទៃ លើកលែងតែក្នុងករណីចាំបាច់ដែលបានកំណត់មួយចំនួនយ៉ាងច្បាស់លាស់ ដោយអនុម័ត និងពិភាក្សាតាមនីតិអន្តរជាតិ ហើយខណៈ និងអំពើទាំងឡាយនោះ ប្រព្រឹត្តិទៅក្នុងសណ្តាប់ធ្នាប់គតិយុត្តិមួយយ៉ាងតឹងរ៉ឹង ។ អត្ថន័យនេះដូចរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ក្នុង**មាត្រាទី ៥៥** ថា "សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹត្យភាព និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល" ។ ផ្ទុយទៅវិញ តាមសេចក្តីសំរេចរបស់អង្គការយុត្តាធិការអន្តរជាតិ ក្នុងកិច្ចការការពារសិទ្ធិមនុស្ស ការធ្វើឱ្យដំណើរការនៃកំលាំងនានា ក្នុងយុទ្ធសន្តិភាពតាមសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិ វាអាស្រ័យនឹង**លក្ខន្តិកៈសហប្រជាជាតិ** ។

អធិបតេយ្យភាពនៃរដ្ឋមួយ វាជាលក្ខណៈពិសេសនៃអំណាចរដ្ឋ ។ ប៉ុន្តែ**អធិបតេយ្យភាព** ឬ **សិទ្ធិស្វ័យសំរេច** ជាទូទៅមាន**បីប្រភេទ**សំខាន់ៗ គឺអធិបតេយ្យភាពរដ្ឋ អធិបតេយ្យភាពប្រជាជន និងអធិបតេយ្យភាពជាតិ ។

⇨ **អធិបតេយ្យភាពរដ្ឋ** : នេះជាសិទ្ធិស្វ័យសំរេចរបស់អំណាចរដ្ឋ ក្នុងក្របខណ្ឌកិច្ចការផ្ទៃក្នុង និងផ្ទៃក្រៅរបស់រដ្ឋ (មើលបំណកស្រាយខាងលើ) ។

⇨ **អធិបតេយ្យភាពប្រជាជន** : នេះគឺជាសិទ្ធិស្វ័យសំរេចរបស់ពលរដ្ឋទូទៅ ក្នុងក្របខណ្ឌនៃរដ្ឋណាមួយពិតប្រាកដ ។ នេះជាទំហំ ឬខ្លឹមសាររបស់វាផ្ទាល់តែម្តងនៃលទ្ធិប្រជាធិបតេយ្យ ដូចជាគ្រឹះនៃអំណាចប្រជាជន សិទ្ធិរបស់ប្រជាជនម្នាក់ៗ កំណត់នូវជោគវាសនារបស់ខ្លួន **តាមឆន្ទៈ**របស់ខ្លួន ។ អធិបតេយ្យភាពរបៀបនេះមានច្រើនប្រភេទណាស់ ដូចជាសិទ្ធិការពារខ្លួនតាមផ្លូវច្បាប់ សិទ្ធិលើជំនឿ សិទ្ធិលើការជ្រើសរើសតំណាង ឬអ្នកដឹកនាំរដ្ឋរបស់ខ្លួន...។ល។ ទាំងអស់នេះគឺសុទ្ធតែពលរដ្ឋជាអ្នកសំរេចតាមឆន្ទៈរបស់ពួកគេ ។ ដូចរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ក្នុង**មាត្រាទី ៣២** ថា "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន" ។ និង **មាត្រាទី ៤៣**

"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ ។ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងល័ក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ"។ និង**មាត្រាទី ៣៤** "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត..........។ល។"

⇨ **អធិបតេយ្យភាពជាតិ ឬសិទ្ធិអត្តភាព** : នេះជាសិទ្ធិស្វ័យសំរេចរបស់ពលរដ្ឋណាម្នាក់ ក្នុងការកាន់កាប់**សញ្ជាតិ** និងជាតិ (ប្រទេស) ដើម្បីរស់នៅដោយខ្លួនឯង ហើយទទួលរ៉ាប់រងនូវរាល់បញ្ហាជីវិតរបស់ខ្លួន និងសិទ្ធិនានានៅក្នុងព្រំដែននៃភាពស្វ័យកំណត់ទៅលើជាតិរបស់ខ្លួនម្នាក់ៗនោះ ដោយពុំមាននរណាសំរេចជំនួសខ្លួនបានឡើយ ឬហៅថាសិទ្ធិអត្តភាព ។

**ឃ.ប្រព័ន្ធនយោបាយ** : នេះគឺជាទំនាក់ទំនងនៃកិច្ចការនយោបាយក្នុងការចាប់យកអំណាចរដ្ឋដោយអាស្រយ័នឹងទំរង់គ្រប់គ្រងរដ្ឋ និងរបបនយោបាយ ។ កិច្ចការនយោបាយនៃសង្គមប្រជាធិបតេយ្យ សំខាន់គឺប្រមូលផ្តុំក្នុងរដ្ឋតែមួយ ក្នុងខណៈនេះវាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅហើយ កាលណាកើតមានក្នុងស្ថាប័នវិវត្តន៍ប្រជាធិបតេយ្យ (រដ្ឋប្រជាធិបតេយ្យ) ។ ត្រង់ចំណុចនេះបញ្ជាក់ថា បក្សនយោបាយមានសកម្មភាពយ៉ាងច្រើននៅក្នុងរដ្ឋ ឬក៏ពហុបក្ស ។ ប៉ុន្តែនៅក្នុងពេលនោះក៏កើតមានស្ថាប័ននយោបាយនៅក្រៅរដ្ឋដែរ ដូចជាគណៈបក្សនយោបាយ, បណ្តុំសាធារណៈ និងចលនាសង្គមសាធារណៈផ្សេងៗ មានអង្គការក្រៅរដ្ឋាភិបាល (ខាងពត៌មានឃោសនា និងការអប់រំ) និងមតិសាធារណៈ ។ល។ ទាំងនេះពុំមែនស្ថិតនៅក្នុងក្របខណ្ឌនៃរដ្ឋទេ ប៉ុន្តែវាជួយឱ្យមានសកម្មភាពឡើង ឬក៏ជាកាតាលីករក្នុងគោលដៅជួយដល់កិច្ចការរបស់រដ្ឋ និងកិច្ចការស្ថាប័នរបស់រដ្ឋ ឬក៏ជួយទៅគ្រប់កិច្ចការនយោបាយ ។ ឧទាហរណ៍ ដូចជាការបោះឆ្នោតតាមរយៈការឃោសនា តាមរយៈយន្តកម្មនៃមតិមហាជន ។ល។

**ដូចនេះប្រព័ន្ធនយោបាយជានិម្មិតកម្ម** (Formation) **សាធារណៈដែលមានលក្ខណៈមិនមែនរដ្ឋ** (**ក្រៅរដ្ឋាភិបាល**) **និងមានលក្ខណៈដោយនិម្មិតកម្មទាំងនោះ ចូលរួមធ្វើសកម្មភាពក្នុងកិច្ចការនយោបាយរបស់ប្រទេស ។ មាត្រាទី ៥១** "ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។ នៅគ្រប់ល័ក្ខខ័ណ្ឌនៃសង្គមប្រជាធិបតេយ្យ និម្មិតកម្មសាធារណៈពុំមែនមានលក្ខណៈគ្រប់គ្រាន់នោះទេសំរាប់ប្រព័ន្ធនយោបាយ គឺរដ្ឋត្រូវតែកំណត់ និងទទួលស្គាល់មានព្រំដែន (ច្បាប់-ចុះបញ្ជី) ទៅលើអង្គការទាំងនោះដោយជៀសវាងនូវបទល្មើសផ្សេងៗ ដែលអាចកើតមានជាយថាហេតុ ។ ដូចនេះនិម្មិតកម្មសង្គម ដូចជាមាត្រា ៣៥, ៣៦ នៃរដ្ឋធម្មនុញ្ញ វាជួយឱ្យប្រព័ន្ធនយោបាយមានលក្ខណៈសុក្រឹត្យនៅក្នុងសង្គមពិតៗ ។

**ង.ឧបករណ៍របស់រដ្ឋ** : នេះគឺជាសេវាកម្មទាំងឡាយដើម្បីធ្វើឱ្យរដ្ឋមានសកម្មភាព ។ បើសិនជារបបនយោបាយសំដែងនូវទំហំ ឬ "**ខ្លឹមសារ**" នៃអំណាចរដ្ឋនោះ មធ្យោបាយ ឬវិធីទាំងឡាយនៃអំណាចគ្រប់គ្រងរដ្ឋ ដែលមានលក្ខណៈប្រជាធិបតេយ្យនោះវាជា "**អង្គ ឬដងខ្លួន**" ឬជា "**ធាតុ**" ដែលបង្កើតបានជារដ្ឋពិតទាំងនោះ វាបញ្ជាក់នូវធាតុជាឧបករណ៍នៃអំណាចរដ្ឋ ឬឧបករណ៍រដ្ឋ ដូចជាមានអង្គការរដ្ឋ ស្ថាប័ន និងអង្គការផ្សេងៗទៀត ។ល។ ដែលអង្គការទាំងនេះវាជាធាតុយ៉ាងសកម្មក្នុងការចូលរួមគ្រប់គ្រងសង្គម ។(**មើលរូបទី ៨**)

ដូចនេះ អត្ថន័យទាំងឡាយនៃឧបករណ៍រដ្ឋវាគ្របដណ្តប់ទៅលើ"**ប្លុកពិតមួយ**" នៃរដ្ឋដោយផ្សារភ្ជាប់ទៅនឹងប្រភេទមួយចំនួនដូចខាងក្រោមគឺ :

- ឧបករណ៍រដ្ឋ ឬឧបករណ៍យន្តកម្មរដ្ឋ
- អង្គការរដ្ឋ និងចំណាត់ថ្នាក់នៃអង្គការរដ្ឋ
- និយោជករដ្ឋ ឬមន្ត្រីរដ្ឋការ
- សមត្ថកិច្ចរដ្ឋ

**៦. ឧបករណ៍រដ្ឋ ឬឧបករណ៍យន្តកម្មរដ្ឋ :** ឧបករណ៍រដ្ឋ ឬឧបករណ៍យន្តកម្មរដ្ឋ គឺជាប្រព័ន្ធនៃឋានានុក្រមអធិបតេយ្យដ៏សាំញ៉ាំមួយ ដោយកើតមាននូវគ្រប់អង្គការរដ្ឋ ស្ថាប័ន និងអង្គការគ្រប់គ្រងនានា ដើម្បីបំពេញតួនាទីក្នុងក្របខណ្ឌនៃ**ការងារប្រតិបត្តិ** ផ្អែកតាមការសមិទ្ធិនៃមុខងារអនុវត្តទៅលើទំនាក់ទំនងគ្រប់គ្រង ផ្គត់ផ្គង់ និងកិច្ចការអភិរក្សទាំងពួងរបស់រដ្ឋ ។ តាម**មាត្រាទី ១១៨** នៃរដ្ឋធម្មនុញ្ញបានកំណត់ទៅលើឧបករណ៍រដ្ឋថា "គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។ គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក"។ នេះគ្រាន់តែបញ្ជាក់ទៅលើឧបករណ៍រដ្ឋ នៃអង្គការរដ្ឋដែលមានអំណាចនីតិប្រតិបត្តិតែប៉ុណ្ណោះ ។ គេអាចសង្កេតឃើញថា **និយមន័យនៃ "ឧបករណ៍របស់រដ្ឋ"** និង**និយមន័យនៃ "យន្តកម្មរបស់រដ្ឋ"** តាមលក្ខណៈគ្រឹះមានអត្ថន័យដូចគ្នា ។ ពីព្រោះពាក្យថា "**យន្តកម្ម** Mechanism" សង្កត់ន័យទៅលើ**អធិបតេយ្យភាព**, ទៅលើ**ការងារ** និងទៅលើ**សេចក្តីប្រាថ្នា**នៃលទ្ធផលជាវិជ្ជមានទាំងពួង ដែលបានកើតមាននៅក្នុងសង្គម ឬរដ្ឋពិត១ ។

ដូចនេះ ឧបករណ៍របស់រដ្ឋវានាំមកនូវសិរីរាង្គតែមួយ (ឯកភូត) គត់ដោយសំរាប់បែងចែក (Dismember)ទៅលើអង្គការទាំងឡាយ ឬអង្គការគ្រប់គ្រង ឬប្លុក (Block) និងរហូតដល់អំណាចស្វ័យគ្រប់គ្រងមូលដ្ឋានទាំងឡាយ. ដោយរួមទាំងនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការទៀតផង ។ នៅក្នុងការបែងចែកនេះមានឋានានុក្រមរបស់ខ្លួនច្បាស់លាស់ ក្នុងនោះមានអង្គការរដ្ឋផ្សេង១ ដោយប្លុករបស់វាបំរើការពុំមានទីតាំងដូចគ្នានោះទេ នៅក្នុងយន្តកម្មរដ្ឋវាស្ថិតនៅក្នុងទំនាក់ទំនងអញ្ញមញ្ញដ៏សាំញ៉ាំ ដែលផ្សាភ្ជាប់នៅដើមដំបូងនៃការស្ថិតក្រោមបង្គាប់ "**ភាពនៅក្រោម ឱវាទ**" (Subor - dination) និង**ការសំរបសំរួល** (Coordination) ។ ជាងនេះទៅទៀត គេអាចចាត់ថ្នាក់ទៅលើអង្គការរដ្ឋ ដោយផ្អែកលើមូលដ្ឋានគ្រឹះនៃចំណាត់ថ្នាក់ពិសេស (Specific) និងមិនពិសេស។ ចំណាត់ថ្នាក់ពិសេស ឬបរិចិន្នការនៃអង្គការរដ្ឋក្នុងឧបករណ៍នោះ វាកាន់កាប់ (មាន) នូវសិទ្ធិអំណាចជាច្រើន ។ ក្នុងចំណោមនោះមានអង្គការគ្រប់គ្រង ស្ថាប័ន ដែលទាក់ទិនចំពោះ "**រដ្ឋ**" ជាដើម គឺមាន

ន័យថាថ្នាក់ពិសេសជាអង្គការរដ្ឋដែល **មានអំណាច** និងផ្នែកមិនពិសេស (ភាគមិនបរិច្ឆិន្នការ) ជាអង្គការ ឬស្ថាប័ន**គ្មានអំណាច** ដែលអនុវត្ត និងបំពេញនាទីក្នុងភារកិច្ច ដូចជាវិទ្យាសាស្ត្រ វប្បធម៌ សង្គម ប៉ុន្តែក្នុងចំនួននេះមិនមានការកាន់កាប់អំណាចអ្វីទេ ។ ត្រង់នេះបញ្ជាក់ថាឧបករណ៍រដ្ឋរួម **មានអំណាចផង និងគ្មានអំណាចផង** ។(**មើលរូបទី ៨**)

ទំហំ (ខ្លឹមសារ) នៃការងាររបស់ឧបករណ៍រដ្ឋ គឺជាការងារសំដៅគ្រប់ផ្នែកដែលមានសមាសភាព ដូចជាការងារអនុវត្តគ្រប់គ្រង ការងារដឹកនាំ ជាពិសេសក្នុងបរិវេណ (មជ្ឈដ្ឋាន) នៃកិច្ចការសង្គម ។ រីឯ**ទំរង់**នៃការងាររបស់ឧបករណ៍រដ្ឋ គឺអាស្រ័យលើវិធានការណាមួយដែលប្រើប្រាស់ទៅលើការអនុវត្តផ្លូវច្បាប់ទាំងពួង និងយន្តកម្មគតិយុត្តិទាំងឡាយ (ធ្វើឱ្យដំណើរការតាមនីតិវិធី) ។ ចំពោះទំរង់នៃការងាររបស់ឧបករណ៍រដ្ឋនេះមាន**ពីរប្រភេទ** គឺទំរង់គ្រប់គ្រងផ្ទាល់ និងទំរង់គតិយុត្តិ ។

**ង.១.១. ទំរង់គ្រប់គ្រងផ្ទាល់ ឬមិនផ្លាស់ប្តូរ :** ជាទំរង់មួយដែលពុំមានលក្ខណៈជាច្បាប់នោះទេ (ប្បញ្ញត្តិ) ប៉ុន្តែវាមានលក្ខណៈជាទំរង់ស្រាវជ្រាវទៅលើអនុសាសន៍ វិទ្យាសាស្ត្រ (Scientific Recommendation) ផ្តល់បទពិសោធន៍ ។ល។ ដូចជាស្ថាប័នកសិកម្ម, ស្ថាប័នគ្រប់គ្រងរ៉ែ ឧស្សាហកម្មជាដើម ។

**ង.១.២. ទំរង់គតិយុត្តិ :** ជាទំរង់មួយដែលមានលក្ខណៈប្បញ្ញត្តិ ហើយជាកាតព្វកិច្ចទូទៅសំរាប់គ្រប់អត្តា ឬបុគ្គល (Subject) ។ ជាទូទៅ លក្ខណៈគ្រឹះនៃគតិយុត្តិក្នុងការងាររបស់ឧបករណ៍រដ្ឋមានច្រើនប្រភេទ ដូចជា :

**ង.១.២.១. ទំរង់នីតិកម្ម ឬការបង្កើតច្បាប់ :** ជាការងារ (ភារកិច្ច) មួយដែលមានការរៀបចំនូវគំរោងទាំងពួងនៃបទដ្ឋាន ឬបទប្បញ្ញត្តិទាំងឡាយ ការអនុម័ត និងការបង្កើត (ឬក៏តាមទណ្ឌកម្ម តាមសុពលភាពច្បាប់ចំពោះប្បញ្ញត្តិ, បទដ្ឋាន) គឺថាកាលណាវា (កើត បាត់ ផ្លាស់ប្តូរ) នូវសុពលភាពនៃគ្រឹះគតិយុត្តិរបស់ការងារមនុស្សទាំងពួង និងអង្គការគ្រប់គ្រង ។

**៦.១.២.២. ទំរង់នីតិប្រតិបត្តិ** : ជាការងារ (ភារកិច្ច) មួយដែលធ្វើសមិទ្ធិលើបទដ្ឋានគតិយុត្តិទាំងឡាយ ដែលក្នុងនោះកាលណាគ្រប់អង្គការរដ្ឋ ប្រព្រឹត្តនូវសកម្មភាពជាឯកត្តបុគ្គលទៅលើទំនាក់ទំនងផ្សេងៗ ហើយឈរនៅលើគ្រឹះមួយគឺច្បាប់ ឬបទដ្ឋាននានាតាមករិតតួនាទី និងមុខងារសំរាប់ដោះស្រាយនូវបញ្ហានេះ ឬនោះ ដែលទាក់ទងនិងករណីពិតប្រាកដណាមួយក្នុងសង្គម ។ ទំរង់នេះ គ្រប់បុគ្គលដែលជាសមាសភាពនៃឧបករណ៍រដ្ឋ ត្រូវតែប្រតិបត្តិតាមច្បាប់ ។

**៦.១.២.៣. ទំរង់តុលាការ និងការពារ** : ជាភារកិច្ចដែលត្រួតពិនិត្យ និងតាមដានចំពោះការប្រតិបត្តិច្បាប់ ការដាក់ទោសទណ្ឌកម្មតាមផ្លូវច្បាប់ទៅលើជនទុច្ចរិត ការប្រមើលមើលនូវកិច្ចការនីតិវិធីក្នុងតុលាការ និងនៅក្នុងអង្គការយុត្តាធិការផ្សេងៗទៀត ដូចជាការអនុវត្តនៃសាលក្រមរបស់អង្គការយុត្តាធិការជាដើម ។ តាមលក្ខណៈនេះក្នុង**មាត្រាទី ១២៩** នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។ សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងៗខ្លួនចំពោះ នាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភា អំពីការដែលខ្លួនបានប្រព្រឹត្ត" ។

**៦.២. អង្គការរដ្ឋ និងចំណាត់ថ្នាក់នៃអង្គការរដ្ឋ** : អង្គការរដ្ឋជាអង្គការគ្រប់គ្រង ឬស្ថាប័នដែលអនុវត្ត (បំពេញកិច្ច) នូវរាល់ភារកិច្ចរដ្ឋ ហើយវាធ្វើកិច្ចការនោះសមស្របនឹងសិទ្ធិអំណាចដែលផ្តល់ឱ្យដោយច្បាប់ ។ អង្គការទាំងនេះមានដូចជាក្រសួង មន្ទីរ និងស្ថាប័នដទៃទៀត ។ល។ ដែលស្ថាប័ននីមួយៗមានមុខងារ ឬសមត្ថកិច្ចផ្សេងៗគ្នា ដូចរដ្ឋធម្មនុញ្ញបានកំណត់ក្នុង**មាត្រាទី ១៣០** ថា "គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ"។ ជាទូទៅ អង្គការរដ្ឋវាមានដូចជាស្ថាប័នគ្រប់គ្រងទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ ថវិកា..។ល។ ប៉ុន្តែគេអាចចាត់ថ្នាក់នៃអង្គការរដ្ឋជា**បីសំខាន់ៗ** គឺអង្គការនីតិប្បញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងអង្គការតុលាការ ។

**ង.២.១. អង្គការនីតិប្បញ្ញត្តិ** : ជាអង្គការដែលបង្កើត និងអនុម័តរាល់បទដ្ឋានកិច្ចគតិយុត្តិនានា ។ អត្ថន័យនៃអង្គការនេះមាន ដូចជា[៣២] "General Cortes បំពេញនាទីជាអំណាចនីតិប្បញ្ញត្តិរបស់រដ្ឋ អនុម័តថវិការដ្ឋ ត្រួតពិនិត្យការងាររដ្ឋាភិបាល និងមានសមត្ថកិច្ចផ្សេងទៀត ដែលកំណត់ដោយរដ្ឋធម្មនុញ្ញ ។" និងតាមរដ្ឋធម្មនុញ្ញកម្ពុជា ក្នុង**មាត្រាទី ៥១** កំណត់ថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ"។ និង**មាត្រា ៩០** បានកំណត់ថា "រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ......"។ និង**មាត្រា ៩៩** "ព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ .........."។

**ង.២.២. អង្គការនីតិប្រតិបត្តិ** : ជាអង្គការដែលអនុវត្តច្បាប់ និងធ្វើគំរោង ឬសំណើរច្បាប់។ កិច្ចការនេះផ្ទុកផ្តាក់ទៅរដ្ឋាភិបាល ដូច**មាត្រា ២០** នៃរដ្ឋធម្មនុញ្ញបារាំងបានកំណត់ថា "រដ្ឋាភិបាលកំណត់ និងដឹកនាំនយោបាយជាតិ ។ វាបញ្ជូនរដ្ឋបាល និងកំលាំងយោធា"។ និងរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ក្នុង**មាត្រា ១២៦** ថា "សមាជិកមួយរូប១នៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន"។ រីឯ**មាត្រា ៩៧** នៃរដ្ឋធម្មនុញ្ញអេស្ប៉ាញ នាឆ្នាំ ១៩៧៨ កំណត់ថា "រដ្ឋាភិបាលបំពេញតួនាទីក្នុងការដឹកនាំនៃនយោបាយផ្ទៃក្នុង និងការបរទេស រដ្ឋបាលស៊ីវិល យោធា និងការពាររដ្ឋដោយការធ្វើសមិទ្ធិលើអំណាច និងមុខងារប្រតិបត្តិអាស្រ័យនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ "។

**ង.២.៣.អង្គការតុលាការ** : ជាអង្គការស្វែងរកយុត្តធម៌ និងផ្សារភ្ជាប់ជាមួយស្ថាប័ន សន្តិសុខសណ្តាប់ធ្នាប់។ អង្គការនេះមានតួនាទីក្នុងការវិនិច្ឆ័យនៃរឿងក្តីទាំងឡាយ ដូចរដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ក្នុង**មាត្រាទី ១២៩** ថា "ការជំរះក្តីផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។

---

[៣២]. General Cortes ជាឈ្មោះរដ្ឋសភារបស់ប្រទេសអេស្ប៉ាញ មើលរដ្ឋធម្មនុញ្ញអេស្ប៉ាញ ឆ្នាំ ១៩៧៨ មាត្រា ៦៦ វាក្យខ័ណ្ឌទី ២ ។

មានតែចៅក្រមទេមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឹងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន" ។ យើងឃើញថា តាមខ្លឹមសារនៃបញ្ញត្តិទាំងនេះ ទោះបីចែកអំណាចជាបីដាច់ពីគ្នានោះក៏ដោយ ក៏**អង្គការរដ្ឋ**ពុំទាន់មានលក្ខណៈគ្រប់គ្រាន់ដែរ ដោយសារតែអង្គការរដ្ឋនោះ ត្រូវការចាំបាច់នូវសកម្មភាពតាមដានទៅក្នុងក្បាលម៉ាស៊ីនរដ្ឋ ដែលមានទំនាក់ទំនងផ្ទាល់ទៅអំណាចមូលដ្ឋាន ដើម្បីជួយដល់ប្រមុខនៃអំណាចធំៗរបស់រដ្ឋ ដូចជាបង្កើតនូវ :

-អាសនៈនៅក្នុងយន្តកម្មរបស់រដ្ឋ គឺស្ថាប័ននៃតំណាងប្រធានាធិបតី ( តួនាទី និងមុខងាររបស់វា) ។ ស្ថាប័ននេះជួយដល់ប្រមុខរដ្ឋ ដើម្បីសិក្សាលំអិតលើបញ្ហាអ្វីមួយ ហើយស្ថិតក្រោមបញ្ជាផ្ទាល់របស់ប្រមុខរដ្ឋ ។

-អង្គការត្រួតពិនិត្យ និងតាមដាន ដែលជាភ្នែកច្រមុះរបស់អង្គការនីតិប្បញ្ញត្តិ ។ ជាស្ថាប័នសំរាប់ផ្តល់នូវហេតុផលពិតជាក់ស្តែងជូនទៅស្ថាប័ននីតិបញ្ញត្តិ ក្រោយពីបានធ្វើកិច្ចការតាមបង្គាប់បញ្ជារបស់ប្រធានស្ថាប័ន ។

**ង៣. និយោជករដ្ឋ ឬមន្ត្រីរដ្ឋការ** : អង្គការរដ្ឋរៀបចំឡើងពីសមាសភាពនៃបុគ្គលផ្សេងៗ ដែលហៅថា**និយោជករដ្ឋ** មានន័យថាជាបុគ្គលិកដែលបំពេញកិច្ចការ ហើយទទួលបានប្រាក់បៀវត្សរបស់រដ្ឋនៅក្នុងអង្គការរដ្ឋ ហើយដែលយល់ព្រមតាមមុខងារបំរើការ និងស្ថិតនៅក្រោមវិន័យសេវាកម្ម ។

ស្ថានភាព សិទ្ធិ និងកាតព្វកិច្ចនៃនិយោជករដ្ឋត្រូវកំណត់ដោយច្បាប់ ហើយក៏ត្រូវអំពាវនាវឱ្យផ្តត់ផ្តង់ពួកគេនូវឋានៈមួយក្នុងរដ្ឋ ។ ទំហំ និងសណ្តាប់ធ្នាប់នៃការប្រើប្រាស់សិទ្ធិអំណាច ត្រូវកំណត់ដោយច្បាប់ ហើយភ្ជាប់ទៅនឹងឯកសារគតិយុត្តិពិសេស ។ មន្ត្រីរដ្ឋការ វាជានិយោជករដ្ឋដែលមានសិទ្ធិអំណាច និងសិទ្ធិអនុម័តសេចក្តីសំរេចនានាដោយស្វ័យគ្រប់គ្រង អាស្រ័យនឹងមុខងាររបស់គេក្នុងភារកិច្ច ។ ជាឧទាហរណ៍ បើប្រទេសដឹកនាំដោយប្រធានាធិបតីដែលជាប្រមុខរដ្ឋនោះ នោះប្រធានាធិបតីជាមន្ត្រីរដ្ឋជាន់ខ្ពស់បំផុត ។

**៦៤. សមត្ថកិច្ចនៃឧបករណ៍រដ្ឋ** : សមត្ថកិច្ចនេះគឺជាខ្លឹមសារ និងទំហំនៃសិទ្ធិអំណាចដែលអង្គការរដ្ឋមាន ដែលនៅក្នុងនោះមានមន្ត្រីរដ្ឋការ ភ្ជាប់ឈ្មោះក្នុងឯកសារគតិយុត្តិច្បាស់លាស់ ។ ជាទូទៅគេចែកសមត្ថកិច្ចនេះដាច់ពីគ្នាជាពីរប្រភេទ គឺសមត្ថកិច្ចទូទៅ និងសមត្ថកិច្ចពិសេស ។

**៦៤.១.សមត្ថកិច្ចទូទៅ** : ជាសមត្ថកិច្ចដែលសិទ្ធិអំណាចរបស់វាគ្របដណ្តប់ទៅលើ**គ្រប់បញ្ហា**ទាំងអស់ ដែលបញ្ហានោះទាក់ទិនទៅនឹងកម្មវត្ថុពិតប្រាកដមួយនៃដំណើរការរដ្ឋ ។ ក្នុងរដ្ឋធម្មនុញ្ញកម្ពុជា តាម**មាត្រាទី ១៤២** បានកំណត់ថា "**បទប្បញ្ញត្តិក្នុងមាត្រាណា** ដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា**មិនស្របនឹងរដ្ឋធម្មនុញ្ញ** មិនអាចយកទៅប្រកាសឱ្យប្រើ ឬយកទៅអនុវត្តបានឡើយ ......"។ និង**មាត្រា ៣** នៃច្បាប់ស្តីពីការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ ១៩៩៤ កំណត់ថា "រាជរដ្ឋាភិបាលដឹកនាំកិច្ចការទូទៅរបស់រដ្ឋ តាមកម្មវិធីនយោបាយ និងផែនការរដ្ឋ ដែលរដ្ឋសភាបានអនុម័ត "។

**៦៤.២. សមត្ថកិច្ចពិសេស** : ជាសមត្ថកិច្ចដែលបានភ្ជាប់ក្នុងឯកសារគតិយុត្តិពិតប្រាកដ គឺមានកំណត់ច្បាស់លាស់ទៅលើមុខងាររបស់ស្ថាប័ន និងបុគ្គលពិតប្រាកដ ។ ជាឧទាហរណ៍ ដូចជាក្រសួង និងស្ថាប័ននានា (ស្ថាប័នតុលាការ....)។ **មាត្រាទី ១៣៦** នៃរដ្ឋធម្មនុញ្ញកម្ពុជាកំណត់ថា "ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេច អំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា "។

## ២. លក្ខណៈជាទ្រឹស្តីនៃទំរង់រដ្ឋ

ទំរង់រដ្ឋ គឺជាអង្គការគ្រប់គ្រងនៃអំណាចរដ្ឋក្នុងប្រទេស ដែលសំដែងចេញនៅក្នុងទំរង់គ្រប់គ្រង និងក្នុងទំរង់រចនាសម្ព័ន្ធគ្រប់គ្រង ឬរចនាសម្ព័ន្ធដែនដីរដ្ឋ ។ ដោយឈរលើខ្លឹមសារនៃទ្រឹស្តីរបស់រដ្ឋ គេចែកទំរង់របស់វាជា**បីធំ១** គឺទំរង់គ្រប់គ្រងរដ្ឋ ទំរង់រចនាសម្ព័ន្ធដែនដីរដ្ឋ និងរបបនយោបាយ (**មើលរូបទី ៩**) ។

**ក.ទំរង់គ្រប់គ្រងរដ្ឋ :** នេះគឺជាអង្គការគ្រប់គ្រងនៃអំណាចជាន់ខ្ពស់ក្នុងរដ្ឋ ។ អំណាចជាន់ខ្ពស់នៅក្នុងរដ្ឋ គឺស្ថាប័នប្រមុខរដ្ឋ, **អំណាចនីតិបញ្ញត្តិ, រដ្ឋាភិបាល, ស្ថាប័នកណ្តាលនៃអង្គការប្រតិបត្តិ** និងស្ថាប័នគ្រប់គ្រងនានា (ឬអំណាចទី ៣ គឺអំណាចតុលាការ អង្គការយុត្តិធម៌ និងអង្គការស្វ័យគ្រប់គ្រងខេត្ត ក្រុង)។ ដូចនេះដើម្បីឆ្លើយទៅលើសំណួរស្តីពីទំរង់រដ្ឋ ត្រូវឆ្លើយនឹងសំណួរថា**អ្នកគ្រប់គ្រងក្នុងរដ្ឋ គឺពួកអ្នកមានអំណាចជាន់ខ្ពស់នោះឯង** ដែលគេហៅថា**ទំរង់គ្រប់គ្រងរដ្ឋ** ។ ជាទូទៅទំរង់គ្រប់គ្រងរដ្ឋចែកចេញជា**ពីរប្រភេទ**ធំៗ ដែលកើតមានពីអតីតកាលរហូតដល់សព្វថ្ងៃនេះ គឺទំរង់គ្រប់គ្រងរដ្ឋបែបរាជាធិបតេយ្យ និងទំរង់គ្រប់គ្រងរដ្ឋបែបសាធារណរដ្ឋ ។

**ក១. ទំរង់បែបរាជាធិបតេយ្យ** (Monarchy)[33] : ជាទំរង់គ្រប់គ្រងរដ្ឋដែលអំណាចជាន់ខ្ពស់នៅក្នុងរដ្ឋប្រមូលផ្តុំមុខងារ (កិច្ចការទាំងពួង) របស់ប្រមុខរដ្ឋ និងមុខងារដទៃទៀតនៃអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ ហើយកិច្ចការទាំងនោះផ្តុកផ្តាក់ទៅលើបុគ្គលតែមួយ គឺ**ព្រះរាជា** ដែលទំរង់គ្រប់គ្រងរដ្ឋបែបនេះប្រមុខរដ្ឋជាស្តេច ឬអ្នកមានត្រកូលក្សត្រដែលមានក្នុងរដ្ឋរបស់គេ ។ ប៉ុន្តែទំរង់រដ្ឋបែបរាជាធិបតេយ្យចែកជា**ពីរប្រភេទ**[៣៤] ផ្សេងទៀតដាច់ពីគ្នា គឺទំរង់រាជាធិបតេយ្យដាច់ខាត ឬទំរង់រាជាធិបតេយ្យមិនកំរិត និងទំរង់រាជាធិបតេយ្យបែបធម្មនុញ្ញ ឬទំរង់រាជាធិបតេយ្យកំរិត ។

**ក១.១.ទំរង់ដាច់ខាត ឬទំរង់មិនកំរិត :** ជាទំរង់មួយដែលអំណាចជាន់ខ្ពស់នោះមិនបានកំណត់ដោយច្បាប់ទេ ។ ក្នុងលក្ខណៈនេះ ព្រះរាជាជាអ្នកមានអំណាចក្នុងការដឹកនាំរដ្ឋាភិបាល ត្រួតពិនិត្យអង្គការតុលាការ និងអង្គការស្វ័យគ្រប់គ្រងមូលដ្ឋាន (ខេត្ត-ក្រុង) គឺមានន័យថាអំណាចទាំងអស់ជារបស់បុគ្គលស្តេច ។ សព្វថ្ងៃនេះមាននៅមជ្ឈិមបូព៌ា ឧទាហរណ៍ស្តេចអារ៉ាប់ប៊ីសាអូឌីតជាដើម។ រដ្ឋដែលមានទំរង់របៀបនេះ ពុំមានការបែងចែកអំណាចដាច់ពីគ្នានោះទេ ដូចជានីតិបញ្ញត្តិ, នីតិប្រតិបត្តិ និងតុលាការជាដើម ។

---

[៣៣]. ពាក្យថារាជាធិបតេយ្យចេញពីពាក្យក្រិចថា "Monos + Archos" គឺថា "Monos" មានន័យថាតែមួយ រីឯ "Archos" មានន័យថាអំណាច ។

[៣៤]. នៅក្នុងទ្រឹស្តីខ្លះ អ្នកនិពន្ធសរសេរជាបីប្រភេទ គឺទំរង់ទិ្វកភាព ឬរាជានិយម ប៉ុន្តែទំរង់នេះស្ថិតក្នុងទំរង់ធម្មនុញ្ញ ឬកំរិត ។

**ក.១.២. ទំរង់បែបធម្មនុញ្ញ ឬទំរង់គំរិត** : ជាទំរង់មួយដែលអំណាចទាំងអស់របស់ព្រះរាជាត្រូវបានកំណត់ដោយច្បាប់ជាពិសេស កំណត់ដោយរដ្ឋធម្មនុញ្ញ ។ វាប្រមូលផ្ដុំទៅលើមុខងារទាំងពួងរបស់ប្រមុខរដ្ឋ រីឯនីតិកម្មត្រូវដើរតួដោយអង្គការជ្រើសរើស (រដ្ឋសភា) ។ វាបង្កើតនូវអង្គការតុលាការឯករាជ្យ និងស្វ័យគ្រប់គ្រងខេត្ត-ក្រុង ដូចជាប្រទេសនៅអឺរ៉ុប **អង់គ្លេស ស៊ុយអែត** ។ល។ ទំរង់បែបធម្មនុញ្ញនេះអំណាចចែកដាច់ពីគ្នា រីឯប្រមុខរដ្ឋជាស្ដេចនោះមានអំណាចតិច ឬច្រើន ស្ថិតក្នុងល័ក្ខខ័ណ្ឌនៃច្បាប់បញ្ញត្តិ ។ ប៉ុន្តែក្នុងទំរង់បែបធម្មនុញ្ញនេះចែកជាពីរដាច់ពីគ្នា គឺទំរង់បែបទ្វិកភាព ឬរាជានិយម និងទំរង់បែបសភា ឬសភានិយម ។

**ក.១.២.១. ទំរង់ធម្មនុញ្ញបែបទ្វិកភាព ឬទំរង់រាជានិយម** : ជាទំរង់តំណាង ដែលក្នុងនោះព្រះរាជាមានសិទ្ធិបង្កើតរដ្ឋាភិបាល ចាត់ចែង និងទទួលខុសត្រូវចំពោះកិច្ចការនោះ ហើយមានសិទ្ធិវេតូ "Véto" និងសិទ្ធិមិនគំរិតនៃការរំសាយរដ្ឋសភា ។ ប៉ុន្តែទំរង់ទ្វិកភាពនេះគេច្រើនហៅថា**ទំរង់រាជានិយម** គឺមានន័យថាស្ដេចមានអំណាចច្រើន ប៉ុន្តែអំណាចនោះត្រូវបានចារឹកដោយច្បាប់ ពុំមែនតាមទំនើងចិត្តរបស់ស្ដេចទេ ។ ស្ដេចក្នុងក្របខ័ណ្ឌនេះព្រះអង្គជាព្រះប្រមុខរដ្ឋផង និងជាប្រមុខរដ្ឋាភិបាលផង ដូចជាប្រទេសស័រដានី, អូម៉ង់ ។ល។

**ក.១.២.២. ទំរង់ធម្មនុញ្ញបែបរដ្ឋសភា ឬទំរង់រាជានិយមអាស្រ័យសភា (សភាតំណាងរាស្ត្រ)** : នេះជាទំរង់មួយដែលក្នុងនោះប្រមុខរដ្ឋជាស្ដេច និងប្រមុខរដ្ឋាភិបាល ព្រមទាំងសមាជិករដ្ឋាភិបាល ទាំងអស់ទទួលខុសត្រូវចំពោះរដ្ឋសភានូវរាល់សកម្មភាពនៃមុខងាររបស់ខ្លួន តាមល័ក្ខខ័ណ្ឌសេវាកម្មឱ្យរដ្ឋ ។ ទំរង់នេះប្រមុខរដ្ឋាភិបាលត្រូវបានចាត់ចែងដោយប្រមុខរដ្ឋ ហើយមានការទុកចិត្តពីរដ្ឋសភា (យល់ព្រម) ។ ទំរង់នេះប្រមុខរដ្ឋជាក្សត្រ ពុំមានអំណាចដឹកនាំនយោបាយទេ តែត្រូវទទួលបន្ទុកដោយនាយករដ្ឋមន្ត្រី ទៅលើកិច្ចការនយោបាយ និងដឹកនាំប្រទេស ។

ព្រះរាជាមានសិទ្ធិជំទាស់ក្នុងករណីខ្លះដែលបានពិភាក្សា ឬកំណត់ដោយច្បាប់ ( ករណីរំសាយរដ្ឋសភា) ។ លក្ខន្តិកៈរបស់រាជាត្រូវបានកំណត់ ដូចជាសិទ្ធិសុំឱ្យរួចលើបទល្មើសមិនអាចដោះស្រាយដោយគ្មានការយល់ព្រមពីរដ្ឋសភាបាននោះទេ មានន័យថាស្តេចមានសិទ្ធិលើកលែងទោសមែន តែត្រូវមានការយល់ព្រមពីរដ្ឋសភា ។ ជាឧទាហរណ៍ មានប្រទេសមួយចំនួនដែលប្រកាន់ទំរង់រដ្ឋសភាដូចជា**អង់គ្លេស បែលស៊ិក នរវែស ស៊ុយអែត ជប៉ុន ថៃ កម្ពុជា** .....។ល។

**ក២. ទំរង់បែបសាធារណរដ្ឋ** : គឺជាទំរង់គ្រប់គ្រងរដ្ឋ ដែលក្នុងនោះអំណាចជាន់ខ្ពស់នៅក្នុងរដ្ឋត្រូវផ្ទុកផ្តាក់ទៅរដ្ឋសភា (សភាតំណាង) និងប្រធានាធិបតី ហើយប្រមុខនីតិប្រតិបត្តិ និងប្រមុខនីតិប្បញ្ញត្តិជាពលរដ្ឋសាមញ្ញ ( មិនមែនស្តេច) ដែលត្រូវបានជ្រើសតាំងឡើងតាមរយៈពលរដ្ឋទូទៅ។ ក្នុងទំរង់នេះមានអង្គការយុត្តិធម៌ឯករាជ្យ និងរដ្ឋអំណាចស្វ័យគ្រប់គ្រងខេត្ត-ក្រុង ជាដើម។ ពាក្យថាសាធារណរដ្ឋ គឺវាផ្សារភ្ជាប់នឹង**ប្រជាជន** ដែលចេញពីពាក្យឡាតាំងថា "Res publica" មានន័យថា "កិច្ចការសង្គម" ។ តាមលក្ខណៈទ្រឹស្តីរបស់រដ្ឋ គេសង្កេតឃើញទំរង់បែបសាធារណរដ្ឋនេះមាន**បីប្រភេទ** គឺសាធារណរដ្ឋបែបសភា សាធារណរដ្ឋបែបទ្វិកភាព ឬសាធារណរដ្ឋបែបប្រធានាធិបតីនិយម និងសាធារណរដ្ឋបែបចំរុះ ។

ប្រមុខរដ្ឋនៅក្នុងទំរង់នេះជាប្រធានាធិបតី ពុំមែនជាក្សត្រឡើយ ។

***ក២.១. ទំរង់សាធារណរដ្ឋបែបសភា*** : ជាទំរង់គ្រប់គ្រងរដ្ឋ ដែលក្នុងនោះរដ្ឋសភាមានឥទ្ធិពល (សិទ្ធិ) ខ្លាំងជាងប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល ។ រដ្ឋសភាជាសមាសភាពនៃបក្សនយោបាយ ដែលបន្ទាប់ពីបានជ្រើសរើសពីពលរដ្ឋរួចហើយត្រូវបង្កើតរដ្ឋាភិបាល ( អាចមានរដ្ឋាភិបាលឯកតោភាគី-បក្សតែមួយ ឬរដ្ឋាភិបាលចំរុះ) ហើយរដ្ឋាភិបាលនេះទទួលខុសត្រូវនូវភារកិច្ចរបស់ខ្លួនចំពោះមុខរដ្ឋសភា ។ ទំរង់នេះរដ្ឋាភិបាលជាអ្នកដឹកនាំកិច្ចការប្រតិបត្តិ ឯប្រមុខរដ្ឋដែលជាប្រធានាធិបតីគ្រាន់តែជាអ្នកតំណាងឱ្យអធិបតេយ្យភាពរដ្ឋតែប៉ុណ្ណោះ ហើយក្នុងករណីបាត់សេចក្តីទុកចិត្តភាគច្រើនពីរដ្ឋសភា នោះរដ្ឋាភិបាលនឹងចុះចេញពីតំណែង ។ ប្រធានាធិបតីមានសិទ្ធិអំណាចដូចព្រះរាជា ឬព្រះប្រមុខរដ្ឋក្នុងទំរង់គ្រប់គ្រងរាជាធិបតេយ្យអាស្រ័យសភាផងដែរ ។

**ក២.២. ទំរង់សាធារណរដ្ឋបែបប្រធានាធិបតីនិយម** : ជាទំរង់គ្រប់គ្រងរដ្ឋ ដែលក្នុងនោះប្រធានាធិបតីមិនត្រូវបានត្រួតពិនិត្យដោយផ្ទាល់ពីរដ្ឋសភាទេ ។ ប្រធានាធិបតីបង្កើតរដ្ឋាភិបាល ហើយរដ្ឋាភិបាលទទួលខុសត្រូវភារកិច្ចរបស់ខ្លួនចំពោះប្រធានាធិបតី។ ប្រធានាធិបតីមានសិទ្ធិរំលាយសភាតំណាងរាស្ត្រ ដូចជាប្រទេសមួយចំនួននៅអាស៊ី. អាមេរិកឡាទីន និងនៅអាហ្វ្រិក ។ នៅសហរដ្ឋអាមេរិក ប្រមុខរដ្ឋទោះបីមានអំណាចខ្លាំងពិតមែន **តែពុំមានសិទ្ធិរំលាយរដ្ឋសភានោះទេ រីឯរដ្ឋសភាក៏ពុំមានសិទ្ធិរំខានដល់រដ្ឋាភិបាលនោះដែរ** ។ លក្ខណៈនេះជាគំរូដ៏ល្អបំផុតរបស់ប្រព័ន្ធគ្រប់គ្រងបែបប្រធានាធិបតី និយម តាមទស្សនៈរបស់អាមេរិកកាំង ។ ប្រធានាធិបតីក្នុងទំរង់នេះមានសិទ្ធិអំណាចដូចព្រះរាជាក្នុងទំរង់រាជានិយម ឬរាជានិយមទ្វិកភាពដែរ ។

**ក២.៣. ទំរង់សាធារណរដ្ឋបែបចំរុះ** :ទំរង់នេះកើតពីទំរង់បែបរដ្ឋសភា និងទំរង់សាធារណរដ្ឋបែបប្រធានាធិបតី ។ គឺថាប្រធានាធិបតី និងរដ្ឋសភាចែកអំណាចស្មើគ្នាក្នុងការត្រួតពិនិត្យនូវការទទួលខុសត្រូវរបស់ខ្លួនទៅលើរដ្ឋាភិបាល ប៉ុន្តែប្រធានាធិបតីមានសិទ្ធិអំណាចច្រើនជាងក្នុងទំរង់សាធារណរដ្ឋបែបសភា តែតិចជាងក្នុងទំរង់សាធារណរដ្ឋបែបប្រធានាធិបតីនិយម ។ ទំរង់នេះបេក្ខភាពក្នុងរដ្ឋាភិបាលជំរើសចេញដោយប្រធានាធិបតី តែត្រូវទុកចិត្តដោយរដ្ឋសភា ឬក៏រដ្ឋសភាឱ្យសេចក្តីយល់ព្រមលើការចាត់តាំងសមាជិករដ្ឋាភិបាល ។ ប្រទេសដឹកនាំតាមបែបនេះ ដូចជា**បារាំង រូម៉ានី..... ជាដើម** ។

**ខ.ទំរង់រចនាសម្ព័ន្ធគ្រប់គ្រងដែនដីរដ្ឋ** : គឺជារចនាសម្ព័ន្ធរបស់រដ្ឋ និងជាចំណែកនៃរដ្ឋដែលគេហៅថារចនាសម្ព័ន្ធភាពជារដ្ឋ ( ដែលមានភាពជារដ្ឋ) ឬក៏លក្ខណៈដែលកើតមានជារដ្ឋ ។ ទំរង់នេះគេចែកលក្ខណៈរដ្ឋជា**បីប្រភេទ**ដាច់ពីគ្នា តាមការកើតមានពីអតីតកាលរហូតបច្ចុប្បន្ននេះ ។

**ខ១. រដ្ឋឯកភូត ឬរដ្ឋទោល** (Unitary State) : គឺជារដ្ឋតែមួយដែលចំណែកទាំងឡាយនៃរដ្ឋនោះ ( ក្រសួង-មន្ទីរ ខេត្ត តំបន់ ។ល។ ជាព្រំដែនរដ្ឋបាល ដែលដែនដីរដ្ឋបាលនោះគ្មានសិទ្ធិឯករាជ្យណាមួយទេ ។ នៅក្នុងមណ្ឌល ( អង្គភាព) នេះគ្មាននីតិកម្ម និងប្រព័ន្ធតុលាការណាមួយដាច់

ដោយឡែកទេ តែអង្គការគ្រប់គ្រងរដ្ឋបាល ឬក៏ករណីពិសេសនោះស្ថិតនៅក្រោមមជ្ឈិម ( កណ្តាល) ឬស្ថិតនៅក្នុងចំណុះពីរ ( មួយក្រោមមជ្ឈិម ទីពីរក្រោមអង្គការតំណាងមូលដ្ឋាន) ។ ខ្លឹមសារនៃរដ្ឋឯកភូត គឺគ្មានរដ្ឋជាសមាជិករបស់វាទេ ។ អង្គនីតិបញ្ញត្តិក្នុងន័យនេះ ពុំមានស្ថិតនៅតាមខេត្ត ក្រុង ដែលជាចំណុះរបស់រដ្ឋបាលកណ្តាលនោះទេ ។

រដ្ឋឯកភូត ដូចជាប្រទេស**កម្ពុជា ថៃ វៀតណាម** ។ តាម**មាត្រាទី ៣** នៃជំពូកទី ១ អំពីអធិបតេយ្យក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ សរសេរថា "ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន" ។ និង**មាត្រា ១៤៥** ថា "ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង ។ ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។ ក្រុងចែកជាខណ្ឌ ខណ្ឌចែកជាសង្កាត់" ។ រដ្ឋឯកភូតជារដ្ឋ**មានឯករាជ្យ និងមានអធិបតេយ្យភាពរដ្ឋ** ។ ដូចនេះរដ្ឋឯកភូតពុំមានរដ្ឋរណបវានោះទេ ។

**ខ២. រដ្ឋសហព័ន្ធ** (Federal State Or Federation) : គឺជារដ្ឋសន្ធានដែលផ្នែកទាំងឡាយរបស់វា ( រដ្ឋ ដីធ្លី ឬប្រទេស ។ល ។) ត្រូវកាន់កាប់នូវភាពជារដ្ឋ ( សញ្ញាណសំគាល់ និងអំណាចរបស់រដ្ឋ) ហើយដែលត្រូវបំពេញនាទីក្នុងកិច្ចការរក្សានូវបូរណៈភាពនៃរដ្ឋ និងក្នុងវត្តមាននៃអធិបតេយ្យ ។ រដ្ឋរបៀបនេះមានរដ្ឋជាសមាជិករបស់ខ្លួនច្រើន ដោយរដ្ឋនីមួយៗជាសមាជិកនោះ**ពុំមានឯករាជ្យ និងពុំមានអធិបតេយ្យរដ្ឋ**ទេ ។

**ឧទាហរណ៍** ១. សហរដ្ឋអាមេរិកជារដ្ឋសហព័ន្ធ ព្រោះសមាជិក (Subjects) ទាំងអស់ ( រដ្ឋសមាជិក) នៃសហព័ន្ធនេះមាននីតិកម្មរបស់ខ្លួន. មានប្រព័ន្ធតុលាការពិសេសរបស់ខ្លួន និងអង្គការរដ្ឋអំណាចនានា ។ ប៉ុន្តែសមាជិក (Subjects) ទាំងអស់នៃសហព័ន្ធនេះ**គ្មានសិទ្ធិសំរេចជាឯកតោភាគី អំពីការដកខ្លួនចេញពីរដ្ឋសន្ធាន** ( រដ្ឋសហព័ន្ធ) នោះទេ ។

ស្ថាប័នទាំងអស់នៃរដ្ឋសហព័ន្ធ ធ្វើសកម្មភាពនៅលើទឹកដីនៃសមាជិករបស់សហព័ន្ធទាំងនោះ ដែលផ្តត់ផ្តង់នូវមុខងារគ្រប់គ្រងនៃរដ្ឋសហព័ន្ធ ដូចជារដ្ឋឯកភូតដែរ តែពុំមានអធិបតេយ្យភាពរដ្ឋទេ ។ ដូចនេះរដ្ឋសហព័ន្ធមានសមាជិកដែលជារដ្ឋចំណុះ ដែលរដ្ឋជាសមាជិកទាំងនេះពុំមានសិទ្ធិបង្កើតកងទ័ព ឬក៏មានឯករាជ្យ និងអធិបតេយ្យភាពចេញពីសហព័ន្ធទេ ។

**ឧទាហរណ៍** ២. សហព័ន្ធនៅក្នុងល័ក្ខខ័ណ្ឌនៃអតីតសហភាពសូវៀត គ្រាន់តែជាសិប្បនិម្មិតតែប៉ុណ្ណោះ បើគិតតាមលក្ខណៈនៃរដ្ឋសហព័ន្ធ ពីព្រោះថា**រដ្ឋដែលជាសមាជិកមានសិទ្ធិចេញពីសមាសភាពសហព័ន្ធតាមចំណង់របស់រដ្ឋនីមួយៗ** ប៉ុន្តែធាតុពិតត្រូវបានបិតបាំង ដែលរដ្ឋសហព័ន្ធនោះមានសកម្មភាពជា**លក្ខណៈរដ្ឋឯកភូតទៅវិញ** ។

ជាការចាំបាច់ត្រូវពិនិត្យមើលថា នៅក្នុងរដ្ឋប្រជាធិបតេយ្យទំនើប (សហរដ្ឋអាមេរិក អាល្លឺម៉ង់) ការបែងចែកអំណាចរដ្ឋជា "**បីអំណាច**"។ រចនាសម្ព័ន្ធសហព័ន្ធជាមធ្យោបាយ**វិមជ្ឈការតូបនីយកម្ម** (Decentralization) និងការបែងចែកអំណាច ជាសញ្ញាណមួយផ្តល់សិទ្ធិអំណាចពីកណ្តាលទៅមូលដ្ឋានក្នុងការប្រមូលផ្តុំ (Concentration) នៃទំរង់សហព័ន្ធ ។

**ខ៣. សមាគតរដ្ឋ** (Confederate State Or Confederation) : គឺជា "**សន្ធានរដ្ឋនៃរដ្ឋ**" ដែលរដ្ឋនីមួយៗជាសមាជិកកាន់កាប់នូវអធិបតេយ្យភាពរដ្ឋ ។ ប៉ុន្តែសហព័ន្ធ (សន្ធាន) នេះពុំមែនជាសម្ព័ន្ធអន្តរនីតិនោះទេតែវាជាសម្ព័ន្ធរដ្ឋ (សន្ធានរដ្ឋ) ដែលប្រមូលផ្តុំ និងបំពេញនាទីរួមគ្នានៅលើជួរនិន្នាការនៃកិច្ចការរដ្ឋឯករាជ្យ ហើយសន្ធានរដ្ឋទាំងនេះមានគោលដៅការការពារប្រទេស, ធ្វើពាណិជ្ជកម្មក្រៅប្រទេស, កិច្ចការគយ, ប្រព័ន្ធចរាចរណ៍ឥណទាន និងការស្រាវជ្រាវរួមគ្នាក្នុងការរុករកធនធានធម្មជាតិជាដើម ។ រដ្ឋរបៀបនេះ ដូចជាការខិតខំប្រឹងប្រែងមួយរបស់ថ្នាក់ដឹកនាំនៃរដ្ឋនានានៅអតីតសហភាពសូវៀត បន្ទាប់ពីគេបានរំលាយចោលហើយបង្កើតនូវ "**សហគមរដ្ឋឯករាជ្យ**" (CIS) នៅឆ្នាំ ១៩៩១ វិច្ឆិកា-ធ្នូ ។ សព្វថ្ងៃនេះកំពុងកើតមាននៅសហភាពអឺរ៉ុប ។

សមាគតរដ្ឋនេះវាកើតមាននៅចុងសតវត្ស XVII នៅអាមេរិកខាងជើង និងនៅពាក់កណ្តាលសតវត្សទី XIX នៅអឺរ៉ុប ។ សូមបញ្ជាក់ថា រដ្ឋដែលជាសមាជិកនៃសមាគតរដ្ឋ**មានឯករាជ្យ** និង**មានអធិបតេយ្យភាពរដ្ឋ** និយាយដោយខ្លីសមាគតរដ្ឋកើតពីរដ្ឋឯកភូត (អាចមានរដ្ឋសហព័ន្ធ) ជាច្រើនចងសម្ព័ន្ធភាពគ្នា ដោយរដ្ឋទាំងនោះរក្សានូវឯករាជ្យ និងអធិបតេយ្យភាពនៃរដ្ឋនីមួយៗ ។

ការខិតខំនៃរដ្ឋឯករាជ្យនៅអឺរ៉ុប ក្នុងការបង្កើតឱ្យបានសហភាពអឺរ៉ុបមួយ ប្រសិនបើមានការសំរេចបាននូវ "**ផ្សាររួម**" (ចាយលុយរួម), ប្រព័ន្ធច្បាប់តែមួយ (តុលាការសហភាពអឺរ៉ុបនៅលុចសំបួរ)។ សហភាពអឺរ៉ុប ជាសញ្ញាណឆ្ពោះទៅបង្កើតសមាគតរដ្ឋយ៉ាងពិតប្រាកដ ។ ការបង្កើតសមាគតរដ្ឋពុំមែនជាការបង្ខិតបង្ខំទេ តែវាជាគោលការណ៍ស្ម័គ្រចិត្តនៃរដ្ឋឯករាជ្យ ។

តាមប្រវិត្តសាស្ត្របានបង្ហាញថាសមាគតរដ្ឋ[៣៥] បានកើតមាន ដូចជា**ហុងគ្រី - អូទ្រីស្ត** ដល់ឆ្នាំ ១៩១៨ រីឯសម្ព័ន្ធភាព**ស៊ុយអ៊ែដ** និង**ន័រវែស** ដល់ឆ្នាំ ១៩០៥, **សហរដ្ឋអាមេរិក** ពីឆ្នាំ ១៧៨១ រហូតដល់ ១៧៨៩, **ស្វីស** ក្នុងចន្លោះឆ្នាំ ១៨១៥ រហូត ១៨៤៨ ។ ប៉ុន្តែក្រោយមកកើតមានសមាគតរដ្ឋឈ្មោះ**សេណេ - ហ្គាមប៊ីយ៉ា** នៅឆ្នាំ ១៩៨២ (កើតពីប្រទេសពីរនៅអាហ្វ្រិកខាងលិច គឺ**សេណេហ្គាល់** និង**ហ្គាមប៊ី**) ប៉ុន្តែរំលងរយៈពេលប៉ុន្មានឆ្នាំក្រោយមកក៏រំលាយទៅវិញ ។ មួយវិញទៀត សមាគតរដ្ឋអារ៉ាប់ដែលកើតឡើងពីរដ្ឋ**អេស៊្ប៉ុព** និង**ស៊ើរី** ក្នុងឆ្នាំ ១៩៥៨ ក៏បានរំលាយនៅឆ្នាំ ១៩៦១ ដែរ ។ ការដែលបែកបាក់សមាគតរដ្ឋនេះវាខុសពីរដ្ឋសហព័ន្ធ ព្រោះសមាជិកទាំងអស់របស់គេបង្កើតកិច្ចព្រមព្រៀងមួយ ដោយ**ផ្តល់នូវលក្ខណៈចេញ និងចូលតាមបំណង** ។

**ឆ.របបនយោបាយ** (Political Regime) : គឺជាចំណុះនៃអំណាចដែលសំដែងចេញនៅក្នុងមធ្យោបាយ និងវិធាននានានៃអំណាចគ្រប់គ្រង ដែលគេសង្កេតឃើញក្នុងលក្ខណៈរបស់វានោះ គឺជារបបប្រជាធិបតេយ្យ ឬអប្រជាធិបតេយ្យ ។

កាលណាគេនិយាយពីរបបនយោបាយ គឺពុំមែននិយាយអំពីទំរង់រដ្ឋសភា, ប្រធានាធិបតី, សាធារណរដ្ឋ ឬក៏រាជានិយមនោះទេ តែគេនិយាយពី**វត្តមាននៃអំណាច, អំពីមធ្យោបាយ និងវិធាននានានៃការចាប់យកអំណាច** (**មានអំណាច**) គឺគេប្រើពាក្យថាអំណាចប្រជាធិបតេយ្យ, អំណាចអប្រជាធិបតេយ្យជាដើម ។ ន័យរបស់ "**របបនយោបាយ**" វាគ្របដណ្តប់មិនត្រឹមតែរដ្ឋប៉ុណ្ណោះទេ ថែមទាំងប្រព័ន្ធនយោបាយទាំងអស់ទៀតផង មានន័យថាអ្វីៗទាំងអស់របស់សង្គម

---

[៣៥] . Federation in Foreign Country, M-1993

(សំដៅលើការចាប់យកនៃអំណាចរដ្ឋ) ។ ដូចនេះសង្គមប្រជាធិបតេយ្យ ជាសង្គមដែលមានរបប នយោបាយប្រជាធិបតេយ្យ ។ ចំពោះសង្គមអប្រជាធិបតេយ្យមានរបបនយោបាយផ្តាច់ការ (អាជ្ញាព្រឹត្តិ ឬសមស្តនិយម) ។ ជាទូទៅរបបនយោបាយចែកជាពីរសំខាន់ៗ គឺរបបប្រជាធិបតេយ្យ និងរបបអប្រជាធិបតេយ្យ ។

**ក១. របបប្រជាធិបតេយ្យ** : គឺជារបបមួយរបស់រដ្ឋ ដែលនៅក្នុងនោះអង្គការមានអំណាច មានអាណត្តិរបស់ប្រជាជន (ប្រជាជនជាអ្នកឱ្យ) សំរាប់គ្រប់គ្រងរដ្ឋនោះ ។ អង្គការកណ្តាលសំខាន់ៗ ត្រូវបានបោះឆ្នោតដោយប្រជាជន ដូចជារដ្ឋសភា ប្រមុខរដ្ឋ....។ ចំណុះ និងព្រំដែននៃអំណាចរបស់អង្គការនិមួយៗត្រូវកំណត់ដោយច្បាប់ ។ នៅក្នុងសង្គមបែបនេះច្បាប់ជាបរមានុភាព (ភាពខ្ពស់ជាងគេ) និងមានឯករាជ្យភាពនៃអង្គការតុលាការ ពលរដ្ឋទាំងអស់ត្រូវបានការពារដោយតុលាការ (ខាងផ្នែកយុត្តិធម៌), មានការបែងចែកអំណាច (អំណាចនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ) ។

**ក២. របបនយោបាយអប្រជាធិបតេយ្យ** : ជារបបដែលអំណាចរបស់អង្គការរដ្ឋជាន់ខ្ពស់ គ្មានអាណត្តិរបស់ប្រជាពលរដ្ឋទេ ។ ក្នុងរបបអប្រជាធិបតេយ្យនេះមានប្រភេទរដ្ឋមួយចំនួន ដែលមានឈ្មោះដូចជា :

**ក២.១. រដ្ឋសមស្តនិយម** : គឺជារដ្ឋដែលនៅក្នុងនោះរដ្ឋបាលគ្រប់គ្រង បង្កើតឡើងនៅលើជំហានដំបូងបង្អស់នៃអំណាច ដែលពុំបានកំណត់ដោយច្បាប់ណាមួយទេ គឺវាប្រកាន់**អំណាចផ្តាច់ការ** (Authoritarianism) ។ វាមានលក្ខណៈប្រហាក់ប្រហែលនឹងរដ្ឋអាជ្ញាព្រឹត្តិដែរ គឺពុំមានការបែងចែកអំណាច និងអំណាចតុលាការពុំមានឯករាជ្យ បំពេញកំលាំងសង្កត់សង្កិនទៅលើអត្តភាព (ភាពជាបុគ្គល) ។ រដ្ឋរបៀបនេះ ចាត់ទុកអំណាចជាបរមានុភាពនៃច្បាប់ ឬច្បាប់ជាឧបករណ៍នៃអំណាច ។

**ក២.២. រដ្ឋអាជ្ញាព្រឹត្តិ** : គឺជារដ្ឋប្រកាន់**លទ្ធិផ្តាច់ការ** (Totalitarianism) ។ របបនយោបាយរបៀបនេះ អំណាចរដ្ឋមិនមានអាណត្តិរបស់ពលរដ្ឋឡើយ ទោះបីជាមានការកំណត់ដោយច្បាប់ហើយក៏ដោយ តែការអនុវត្តតាមទំនើងចិត្តរបស់បុគ្គលមានអំណាចជាន់ខ្ពស់ ជាពិសេសប្រើអាជ្ញាយោធា និងរដ្ឋបាល ដូចជាប្រទេសប្រកាន់របបសង្គមនិយមជាដើម ។

## ៣. លក្ខណៈគតិយុត្តិនៃរដ្ឋ

**ក.អត្ថន័យនៃរដ្ឋជាស្ថាប័នគតិយុត្តិមួយ** : គោលការណ៍នេះរដ្ឋជាស្ថាប័ននយោបាយមួយ ។ លក្ខណៈគតិយុត្តិនៃរដ្ឋ ឬរដ្ឋជាស្ថាប័នគតិយុត្តិមួយ មានន័យថារដ្ឋទាំងនោះត្រូវចារិកក្នុងច្បាប់កំពូលណាមួយច្បាស់លាស់។ ពាក្យប្រើថា**រដ្ឋ** ជាភាសា**អង់គ្លេស** "State", **បារាំង** "État", **អាល្លឺម៉ង់** "Staat", **អេស្ប៉ាញ** "Estado", **រ៉ូម៉ានី** "Stat", **ប៉ូឡូញ** "Penstwo", **ហុងគ្រី** "Alam" និងពាក្យផ្សេងៗទៀតដែលមានន័យថា "**រដ្ឋ**" នេះទៅតាមភាសានៃជនជាតិក្នុងប្រទេសនីមួយៗ ។ ប៉ុន្តែនៅពេលខ្លះគេបានប្រើពាក្យ "**រដ្ឋ**" និង "**ប្រទេស**" មានន័យតែមួយក្នុងការកំណត់នូវទំរង់គ្រប់គ្រងរដ្ឋពិតប្រាកដមួយ និងមធ្យោបាយនៃការគ្រប់គ្រងសង្គម ដូចជា**មាត្រាទី ១** រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់ថា "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ" ។

ដូចនេះពាក្យថារដ្ឋមានន័យពីរ **ទីមួយ**វាមានលក្ខណៈជា "**ប្រទេស**" មានន័យថា**វាជានិមិត្តកម្មភូមិសាស្ត្រនយោបាយ**. ដូចរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ កំណត់ដោយ**មាត្រាទី ២** ថា "បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់នៅក្នុងផែនទី ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩" ។ **ន័យទីពីររបស់វាគឺជាអង្គការគ្រប់គ្រងនៃអំណាចនយោបាយ និងប្រព័ន្ធនៃស្ថាប័នអំណាចទាំងនោះ** ដូចជា**មាត្រា ៥១** បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។ អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។ ជាពិសេសទៀតបានកំណត់ទៅលើស្ថាប័នប្រមុខរដ្ឋ ដូចជា :

**មាត្រាទី ៧** កំណត់ថា "ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រ ទ្រង់ជាប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ"។ និង**មាត្រាទី ១០** "របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។

ព្រះមហាក្សត្រ ទ្រង់ឥតមានព្រះរាជអំណាច ចាត់តាំងព្រះរាជទាយាទសំរាប់គ្រងរាជ្យសម្បត្តិឡើយ "។ ចំពោះការកំនត់នូវស្ថាប័នអំណាចធំៗរបស់រដ្ឋ មានដូចជា :

**អំណាចនីតិប្បញ្ញត្តិ** : តាមវាក្យខណ្ឌទី ១ នៃ**មាត្រា ៩០** បានកំណត់ថា "រដ្ឋសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន......"។ និង**មាត្រា ៩៩** បានកំណត់ក្នុងវាក្យខ័ណ្ឌទីមួយថា "ព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ........"។

**អំណាចនីតិប្រតិបត្តិ** : តាម**មាត្រា ១១៨** វាក្យខណ្ឌទី ១ បានកំណត់ថា "គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា "។

**អំណាចតុលាការ**: តាម**មាត្រា១២៨**បានកំណត់ថា "អំណាចតុលាការជាអំណាចឯករាជ្យ។

អំណាចតុលាការធានារក្សាអនាគត និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។ អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់"។ និងមានស្ថាប័នគតិយុត្តិមួយទៀត ដែលប្រើប្រាស់អំណាចដោយប្រយោល **សំរាប់ត្រួតពិនិត្យលើគោលការណ៍គតិយុត្តិរបស់សកម្មភាពនៃអំណាចជាន់ខ្ពស់មួយចំនួន** ដូចជា**មាត្រា ១៣៦** បានកំណត់ថា "ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញមាន

សិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទិននឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា" ។

**និយមន័យនៃរដ្ឋ គឺជាអង្គការគ្រប់គ្រងឯករាជ្យទឹកដីនយោបាយ នៃអំណាចសាធារណៈ ដែលរៀបចំដោយឧបករណ៍ពិសេស (Special) ក្នុងទិសដៅទាំងឡាយនៃការបំពេញមុខងារផ្គត់ផ្គង់ គ្រប់គ្រង ថែរក្សា និងមានមធ្យោបាយធ្វើនូវរាល់ការបង្គាប់បញ្ជារបស់ខ្លួនដោយកាតព្វកិច្ចចាំបាច់សំរាប់ប្រជាជននៃប្រទេសខ្លួន ។**

នៅក្នុងរដ្ឋដែលកាន់លទ្ធិប្រជាធិបតេយ្យ រដ្ឋធម្មនុញ្ញបានកំណត់នូវមុខងាររបស់រដ្ឋដែលត្រូវអនុវត្ត ហើយនៅក្នុងនោះគេសង្កេតឃើញមានមុខងារគ្រឹះសំខាន់ៗមួយចំនួនដូចខាងក្រោម :

**ក₁.មុខងារនយោបាយរដ្ឋ** : មុខងារនេះវាផ្គត់ផ្គង់នូវលក្ខខណ្ឌនៃសកម្មភាពរបស់ស្ថាប័ននយោបាយ និងសង្គមសាធារណៈផ្សេងៗទៀត។ អង្គការរដ្ឋទាំងអស់កាលដែលបានសមិទ្ធិលើមុខងារទាំងនេះរួចមក អង្គការទាំងនោះចាប់យកក្នុងក្របខណ្ឌ ដើម្បីទប់ស្កាត់នូវការលេចឡើងនៃបាតុភូតហាយនភាពសង្គម (Destruction) ដូចក្នុង**មាត្រា ៣៧** បញ្ជាក់ថា "សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធីត្រូវយកមកអនុវត្តនៅក្នុងក្របខណ្ឌនៃច្បាប់"។ និងក្នុង**មាត្រា ១២៩** ចែងថា "ការជំនុំជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន"។ និង**មាត្រា ១៣០** "គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ "។

**ក₂. មុខងារសេដ្ឋកិច្ចរបស់រដ្ឋ** : វាជាមុខងារមួយដែលបានសំដែងក្នុងទំរង់នៃការធ្វើនិយ័តកម្មលើទំនាក់ទំនងសេដ្ឋកិច្ច ហើយរួមទាំងអនុភាព (មានឥទ្ធិពល) ផ្សេងៗដូចជា : ជាតូបនីយកម្ម (Nationalization) និងឯកជនភាវូបនីយកម្ម (Privatization)។ ក្នុងមុខងារនេះ ដូចជា**មាត្រា ៥៦** បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះនឹងមានកំណត់ក្នុងច្បាប់"។ និង**មាត្រា ៥៧** "ការយកពន្ធដារនឹងអាចធ្វើទៅបានលុះត្រាតែមានច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់ ។

របបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់"។

**ក៣. មុខងារសង្គមរបស់រដ្ឋ** : មុខងារនេះសំដៅទៅលើកម្មវិធីរបស់រដ្ឋ លើ**បញ្ហានិម្មិតកម្ម**ផ្សេងៗ ដូចជា**សុខមាលភាពផ្គត់ផ្គង់សង្គម ជំរុញ** និង**អភិវឌ្ឍវប្បធម៌** ។ល។ លើសពីនេះទៀតរដ្ឋកំណត់នូវនិយត័កម្មរវាងការងារ និងមូលធនក្នុងទិសដៅគេចចេញនូវទំនាស់ទាំងឡាយរបស់សង្គម។ មុខងារនេះ ដូចជា**មាត្រា ៧២** បានកំណត់ថា "សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ ។ ប្រជារាស្ត្រក្រីក្រ ត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។ រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ"។ និងមានមាត្រាមួយចំនួនទៀត ។

**ក៤. មុខងារមនោគមវិជ្ជារបស់រដ្ឋ** : ជាមុខងារដែលមានគោលដៅ**អប់រំដល់សង្គមមនុស្ស**ក្នុងលក្ខណៈ**មនុស្សធម៌ វប្បធម៌......អប់រំ** ។ល។ មុខងារនេះដូចជា**មាត្រា ៦៦** កំណត់ថា "រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើៗគ្នាក្នុងការកសាងជីវិត"។

នៅក្នុងរដ្ឋនីមួយៗ គេតែងតែមានគោលនយោបាយច្បាស់លាស់ ក្នុងការអប់រំប្រជាពលរដ្ឋរបស់ពួកគេឱ្យមានមោទនភាព អំពីជាតិរបស់ខ្លួនទៅលើការយល់ដឹង និងប្រពៃណី ឬវប្បធម៌ល្អៗពីអតីតកាលរហូតដល់បច្ចុប្បន្ន ។ សកម្មភាពនៃការសំដែងនូវចរិតលក្ខណៈនៃការអប់រំនោះ ត្រូវបានរដ្ឋចារឹកនៅក្នុងច្បាប់គ្រឹះ ដោយបង្ហាញសាធារណៈនូវលក្ខណៈល្អរបស់រដ្ឋ ។ មោទនភាពទៅលើលក្ខណៈរដ្ឋទាំងនេះមានដូចជា : រដ្ឋមានលក្ខណៈជាសង្គម (Social State) រដ្ឋមានលក្ខណៈប្រជាធិបតេយ្យ (Democratic State) រដ្ឋមានលក្ខណៈច្បាប់ ឬនីតិរដ្ឋ (Rule of Law) និងរដ្ឋទំនើប (Fashionable State) ជាដើម ។ល។

**ក៤.១. រដ្ឋមានលក្ខណៈជាសង្គម** (Social State) : លក្ខណៈនៃរដ្ឋរបៀបនេះ គឺថារដ្ឋបំរើឱ្យសាធារណៈ និងជំរុញមិនឱ្យមានការជ្រៀងគ្នានៃសង្គមរស់នៅ ។ មានន័យថាដោះស្រាយរាល់បាតុភូតដែលនាំឱ្យកើតវិបត្តិក្នុងសង្គមនៃរដ្ឋរបស់គេ ដូចជា**មាត្រា ៣** វាក្យខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញអ៊ីតាលី ឆ្នាំ ១៩៤៧ បានកំណត់ថា "ភារកិច្ចនៃសាធារណរដ្ឋ គឺលុបបំបាត់ចោលនូវឧបសគ្គនៃសណ្តាប់ធ្នាប់សេដ្ឋកិច្ច និងសង្គមដែលរាំរាំខានដល់ការអភិវឌ្ឍន៍ទូទៅនៃអត្តភាពមនុស្ស និងរំខានដល់ការចូលរួមដ៏សកម្ម និងប្រកបដោយសមត្ថភាពនៃគ្រប់ការងារក្នុងអង្គការនយោបាយ សេដ្ឋកិច្ច សង្គមរបស់ប្រទេស កាលដែលវាបានកើតនូវសេរីភាព និងសមត្ថភាពនៃពលរដ្ឋ" ។

សរុបទៅរដ្ឋដែលមានលក្ខណៈសង្គម គឺវាបានប្រកាសនូវ**ការធានា**នៃរដ្ឋធម្មនុញ្ញ **ក្នុងសិទ្ធិសេដ្ឋកិច្ចសង្គម និងសេរីភាព**ដែលអាស្រ័យនឹង**ភាតព្វកិច្ច** ។ ការសង្កេតលើគោលការណ៍សេដ្ឋកិច្ច ដូចមាត្រា **៥៦** រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ កំណត់ថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់" ។ និង**មាត្រា ៥៧** "ការយកពន្ធនឹងអាចធ្វើទៅបានលុះត្រាតែមានច្បាប់អនុញ្ញាត ។

ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់ ។

របបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់" ។ រីឯ**គោលការណ៍សិទ្ធិ និងសេរីភាព តាមមាត្រា ៣១** វាក្យខ័ណ្ឌទី ២ បញ្ជាក់ថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវបានប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់" ។ និង**មាត្រា ៦៥** ចែងថា "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនូវគ្រប់កំរិត និងត្រូវចាត់វិធានការណ៍គ្រប់បែបយ៉ាងជាជំហ៊ានៗ ដើម្បីឱ្យការអប់រំនេះបានដល់ប្រជាពលរដ្ឋគ្រប់រូប " ។ និងមានគោលការណ៍ផ្សេងៗទៀត ។ល។

ដូចនេះ រដ្ឋដែលមានលក្ខណៈជាសង្គម គឺរដ្ឋធម្មនុញ្ញបានផ្តល់សិទ្ធិយ៉ាងទូលាយទៅលើសេរីភាព និងល័ក្ខខ័ណ្ឌនានានៃអត្តភាព ។

**ក៤.២. រដ្ឋមានលក្ខណៈច្បាប់ ឬនីតិរដ្ឋ** (Rule of Law) : លក្ខណៈនៃរដ្ឋរបៀបនេះ គឺសំដៅទៅរាល់សេចក្តីសំរេចទាំងឡាយ នៃអង្គការមានអំណាចគ្រប់គ្រងរដ្ឋគ្រប់ជាន់ថ្នាក់ ធ្វើសកម្មភាពដោយមានច្បាប់ជាបង្អែក ។ ព្រោះថានេះ ដើម្បីជៀសវាងនូវសកម្មភាពណាមួយរបស់អ្នកមានសិទ្ធិអំណាចរដ្ឋ ធ្វើសកម្មភាពគ្មានព្រំដែនទៅលើអ្នកដទៃ ។ សកម្មភាពទាំងនេះទាក់ទិននឹងអង្គការនៃអំណាចរបស់រដ្ឋ ដូចជា**មាត្រា ៣៨** វាក្យខណ្ឌទី ៣ បានកំណត់ថា "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់"។ និង**មាត្រា ៩៤** "រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋសភា នឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា"។ និង**មាត្រា ១២៧** "ការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រីនឹងត្រូវកំណត់ក្នុងច្បាប់មួយ"។ និង**មាត្រា ១២៩** "ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជាពលរដ្ឋខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន" ។

**ក៤.៣. រដ្ឋមានលក្ខណៈប្រជាធិបតេយ្យ** (Democratic State) : លក្ខណៈនៃរដ្ឋដែលកាន់លទ្ធិប្រជាធិបតេយ្យ ធ្វើឡើងដោយចារឹកខ្លឹមសាររបស់វាក្នុងជំពូកជាច្រើននៃរដ្ឋធម្មនុញ្ញ ដូចជាល័ក្ខខ័ណ្ឌណាខ្លះដែលអាចមានតថភាពនៃបទដ្ឋាន និងគោលការណ៍ទាំងឡាយអំពីសិទ្ធិ និងសេរីភាពអំពីអង្គការគ្រប់គ្រងអំណាចរដ្ឋ..........។ល។ ជាឧទាហរណ៍**មាត្រា១** បានចែងថា "ប្រទេសកម្ពុជាជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ"។ រីឯ **មាត្រា ៣១** "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិ សេរីភាពនេះត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់"។ និង **មាត្រា ៥១** បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។ អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ"។ ដូចនេះរដ្ឋមានលក្ខណៈប្រជាធិបតេយ្យ វាកំណត់នូវប្រភពនៃអំណាចរដ្ឋ កើតឡើងតាមរយៈប្រជាពលរដ្ឋបោះឆ្នោតជូន ។

**ក៤.៤.រដ្ឋអាណាចក្រ ឬរដ្ឋគ្មានសាសនា ឬរដ្ឋទំនើប** : លក្ខណៈនៃរដ្ឋរបៀបនេះ រដ្ឋធម្មនុញ្ញកំណត់យ៉ាងច្បាស់នូវការបែងចែក (Seperation) នៃ**អង្គការសាសនា** (Church) ដាច់ចេញពីរដ្ឋ ដូចជា : សីមាពន្ធ (ការកំរិតព្រំដែន Demarcation) នៃសកម្មភាពទាំងឡាយរបស់**រដ្ឋ** និង**សាសនា** ។ ការកំរិតរបៀបនេះមាននៅក្នុងប្រទេសដែលកាន់**សាសនាគ្រឹស្ត** ដូចជាប្រទេសអ៊ីតាលី ជាដើម ។ តាម **មាត្រា ៧** នៃរដ្ឋធម្មនុញ្ញប្រទេសអ៊ីតាលីកំណត់ថា "រដ្ឋ និងនិកាយសាសនាកាតូលិកមិនអាស្រ័យគ្នាទេ និងមានឯករាជ្យក្នុងកម្មសិទ្ធិ ចំពោះរាល់តែអ្នកណាដែលស្ថិតក្នុងក្របខណ្ឌ ឬក៏មជ្ឈដ្ឋាននៃស្ថាប័នទាំងពីរនោះ (រដ្ឋ និងអង្គការសាសនាកាតូលិក)។ ទំនាក់ទំនងស្ថាប័ន

ទាំងពីរនោះធ្វើនិយ័តកម្មដោយ**កតិកាសញ្ញាឡាតេរ៉ាន់**[៣៦] ទាំងឡាយដែលបានចុះហត្ថលេខា នៅឆ្នាំ ១៩២៩ និងបានពិភាក្សាឡើងវិញជាអន្លើៗនៅឆ្នាំ ១៩៨៤ ។ ការផ្លាស់ប្តូរនៃកតិកាសញ្ញាទាំងនោះ ត្រូវបានធ្វើឡើងដោយភាគីទាំងពីរព្រមព្រៀងគ្នា ហើយពុំត្រូវបានទាមទារតាមនីតិវិធីទាំងឡាយ នៃការសើរើពិភាក្សាឡើងវិញតាមបែបបទធម្មនុញ្ញទេ ។ ត្រង់នេះបញ្ជាក់ថា រដ្ឋអាណាចក្រពុំមានយកស្ថាប័នសាសនាដាក់បញ្ចូលជាមួយទេ ។

លក្ខណៈរដ្ឋអាណាចក្រ វាពុំធ្វើឱ្យមានឧបសគ្គដល់អង្គការសាសនានោះទេ ប៉ុន្តែផ្តល់ផលប្រយោជន៍ទាំងឡាយក្នុងការផ្គត់ផ្គង់ និងការធានារ៉ាប់រងសិទ្ធិនៃក្រុមសាសនាភាគតិច ថែមទាំងជួយទៅអង្គការសាសនា និងសមាគមន៍សាសនានោះទៀតផង ដូចជាសំភារៈ និងថវិការដ្ឋជាដើម ។ ភាពប្រឈមមុខគ្នានៃរដ្ឋអាណាចក្រនេះ គឺកើតមានដូចជា**រដ្ឋទេវាធិបតេយ្យ**(Theocratic State)ដែលក្នុងនោះអំណាចរដ្ឋជាកម្មសិទ្ធិ ឬក៏ផ្ទុកផ្តាក់ទៅលើឋានានុក្រមអង្គការសាសនា (Ecelesiastical Hierarchy) ។ រដ្ឋដែលមានលក្ខណៈទេវាធិបតេយ្យ បានកើតមាននៅមុនឆ្នាំ១៩២១នៅ**ម៉ុងហ្គោលី** និងបច្ចុប្បន្ននៅ**វ៉ាទីកង់** ។ ជាទូទៅរដ្ឋរបៀបនេះ កំរកើតមានណាស់នៅលើពិភពលោក ពីព្រោះរដ្ឋនេះគេជឿទៅលើកំលាំងក្រៅខ្លួន គឺព្រះអាទិទេព ។

នៅពេលខ្លះអាចជួបប្រទះនូវ**រដ្ឋសម្មាធម្មិក**[៣៧] (Clerical State) ។ រដ្ឋរបៀបនេះពុំមានលក្ខណៈដូចទៅនឹងអង្គការសាសនានោះទេ (Church) ព្រោះថាអង្គការសាសនាពេលខ្លះស្ថាប័នកំណត់ទាំងឡាយត្រូវបានកំរិតដោយ**គំរូមួយ** តាមរយៈលក្ខណៈនីតិកម្មដែលមាន**ឥទ្ធិពលទៅលើនយោបាយរដ្ឋ** ។ រីឯរដ្ឋសម្មាធម្មិកវិញ គេត្រូវការការអប់រំនៅសាលាជាសណ្តាប់ធ្នាប់ចាំបាច់មួយ

---

[៣៦]. ជាកិច្ចព្រមព្រៀងមួយដែលចុះហត្ថលេខាដោយរដ្ឋអ៊ីតាលី និងរដ្ឋវ៉ាទីកង់ ( អង្គការសាសនា) នៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ១៩២៩ ។ ក្នុងសន្ធិសញ្ញានេះមានដូចជាអនុសញ្ញាស្តីពីហិរញ្ញវត្ថុ និងអនុរូបសញ្ញា ( Concordat ជាកិច្ចព្រមព្រៀងតាមផ្លូវតុលាការរវាងអ្នកធនក្ស័យ និងពួកម្ចាស់បំណុលទៅតាមលក្ខណៈផ្សេងៗ) ។ កិច្ចព្រមព្រៀងទាំងនេះបានបញ្ចប់នូវ "បញ្ហារ៉ូម" ព្រោះវាបានទទួលស្គាល់បង្កើតនូវរដ្ឋឯករាជ្យវ៉ាទីកង់ ស្ថិតក្នុងទីកដីក្រុងរ៉ូម ។

[៣៧]. ជារដ្ឋដែលដឹកនាំតាមលក្ខណៈនៃបុព្វជិតច្រើន ។

រួមទាំងការសិក្សាទៅលើសិទ្ធាន្តសាសនា (Church Dogma ការមានៈទៅលើសាសនា ឬការងប់ងល់នឹងសាសនា) ផងដែរ ។ លក្ខណៈរបៀបនេះ គឺមានដូចជាប្រទេសអ៊ីរ៉ង់ ជាដើម ។

**ខ.គោលការណ៍ធម្មនុញ្ញគតិយុត្តិទាំងឡាយនៃផ្នែកនយោបាយផ្ទៃក្នុងរបស់រដ្ឋ** : គោលការណ៍ទាំងនេះស្ថិតក្នុងទិដ្ឋភាពបណ្តុំ ដែលធ្វើឡើងដោយរូបមន្តមួយក្នុងរដ្ឋធម្មនុញ្ញ។ វាពិតជាកំរណាស់ក្នុងការអនុវត្តន៍ឱ្យបានល្អដោយអ្នកមានអំណាចរដ្ឋនោះ ប៉ុន្តែភាគច្រើននៃរដ្ឋធម្មនុញ្ញសម័យទំនើប វាត្រូវតែកំរិតដោយខ្នាតមួយច្បាស់លាស់ នៃភារកិច្ចសុក្រឹត្យទាំងឡាយរបស់**នយោបាយរដ្ឋ** (អំណាចសាធារណៈ ឬអំណាចនយោបាយ) ដែលក្នុងនោះផ្សារភ្ជាប់នឹងស្ថាប័នផ្សេងៗ ដូចជាសិទ្ធិមនុស្សជាដើម ។ តាម**មាត្រា ៣១** "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ....."។ នៅក្នុងគោលការណ៍នយោបាយនេះ រដ្ឋធម្មនុញ្ញត្រូវតែកំណត់នូវមូលដ្ឋានសំខាន់ៗ ដែលទាក់ទិនទៅនឹង**គ្រឹះទាំងឡាយនៃប្រព័ន្ធគ្រប់គ្រងសង្គម** : ដូចជា**មាត្រា ៥១** បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជាអនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។ អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ"។ និង**មាត្រា ១៣៦** "ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានា ការការពារគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចលើករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា"។ និង**មាត្រា ៩០** បានកំណត់ថា "រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន"។ **មាត្រា ៥២** "រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារ

ឯករាជ្យ អធិបតេយ្យ បូរណៈភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ រក្សាការពារទំនៀមទំលាប់ និងប្រពៃណីល្អរបស់ជាតិ ។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ សន្តិសុខ សាធារណៈ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាពចំពោះជីវភាពរស់នៅ និងសុខមាលភាពរបស់ប្រជាពលរដ្ឋ"។ និង**មាត្រា ២៥** "ព្រះមហាក្សត្រ ទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅមកប្រចាំ ព្រះរាជាណាចក្រកម្ពុជា"។ **មាត្រា ២១** "តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ ស៊ីវិល និងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព ។

តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ"។ និងមានមាត្រាដទៃទៀត ដូចជាមាត្រាទី ៩៩ ជាដើម បានកំណត់ទៅលើស្ថាប័នគ្រឹះនៃអំណាចរដ្ឋ ដែលទាក់ទិននឹងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ ។

**ខ. គោលការណ៍ធម្មនុញ្ញគតិយុត្តិទាំងឡាយនៃនយោបាយក្រៅប្រទេសរបស់រដ្ឋ** : នេះជាគោលការណ៍ដ៏ទូលាយ ដែលត្រូវបានបទដ្ឋានធម្មនុញ្ញនៃរដ្ឋនីមួយៗរបស់គេបញ្ញត្តិយ៉ាងច្បាស់លាស់។ គោលការណ៍របៀបនេះ ត្រូវបានសុះសាយបន្ទាប់ពីបញ្ចប់សង្គ្រាមលោកលើកទី II មក ។ ដូចជា **មាត្រា ១១** រដ្ឋធម្មនុញ្ញអ៊ីតាលី បានកំណត់ថា"ប្រទេសអ៊ីតាលី បដិសេធនូវសង្គ្រាមដែលជាឧបករណ៍មួយ ដែលធ្វើវិទ្ធង្សនាចំពោះសេរីភាពនៃប្រជាពលរដ្ឋ និងជាមធ្យោបាយនៃដំណោះស្រាយទំនាស់អន្តរជាតិ......."។ ក្នុង**មាត្រា ៥៣** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ កំណត់ថា "ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹត្យ អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ ព្រះរាជាណាចក្រកម្ពុជា រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើពិភពលោក ។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាជាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយដែលមិនស្របនឹងអព្យាក្រឹត្យភាពរបស់ខ្លួនឡើយ ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជាសំភារៈយោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកំលាំងប្រដាប់អាវុធ និងជំនួយផ្សេងទៀតដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស"។ រីឯ**មាត្រា ៥៥** កំណត់ថា"សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹត្យភាព និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល"។ ជាពិសេសទៀតនោះ**មាត្រា ៣១** បានកំណត់នូវវាក្យខណ្ឌទី ១ ថា "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ......"។ ដូចនេះគោលការណ៍នានាដែលកំណត់អំពីនយោបាយក្រៅប្រទេសរបស់រដ្ឋ ត្រូវបានធ្វើឡើងតាមមូលដ្ឋានគ្រឹះជាច្រើន ដែលទាក់ទិនទៅនឹងសកម្មភាពផ្ទៃក្នុង ។

**ឃ. គោលការណ៍ធម្មនុញ្ញគតិយុត្តិទាំងឡាយទៅលើអង្គការគ្រប់គ្រងរដ្ឋ** : ជាទូទៅគេបានឃើញថា រដ្ឋបានធ្វើសកម្មភាពជាសំខាន់តាមរយៈប្រព័ន្ធគ្រប់គ្រងនៃអង្គការនានា និងស្ថាប័ន ឬក្រសួង មន្ទីរនានា ដែលស្ថិតនៅក្នុងបណ្តុំរបស់ខ្លួន គឺការបង្កើតនូវយន្តកម្មរដ្ឋមួយ ។ ប្រព័ន្ធគ្រប់គ្រងនៃអង្គការទាំងឡាយនោះមានដូចជា :

**ឃ₁. អង្គការរដ្ឋ** : គឺជាបុគ្គល ឬក៏ក្រុមបុគ្គលដែលបានរៀបចំបែងចែកដោយច្បាប់ ឱ្យទទួលនូវសេចក្តីសំរេចជា**អាជ្ញា** ឬហៅថា**អាជ្ញាសំរេច** (សេចក្តីសំរេចដែលមានលក្ខណៈអំណាច) ។ អង្គការរដ្ឋនោះមានរដ្ឋសភា, ប្រធានាធិបតី, តុលាការ, អភិបាលនៃរដ្ឋអំណាចមូលដ្ឋាន..............។ល។ (មើលរូបទី ៨)

**ឃ₂. ស្ថាប័នរដ្ឋបាល** : គឺជាក្រុមបុគ្គលដែលបានរៀបចំ និងបែងចែកដោយច្បាប់ដែរ តែ**មិនទទួលយកបាននូវអាជ្ញាសំរេចទាំងឡាយ** តាមទំនាក់ទំនងមួយទៅចំពោះបុគ្គលផ្សេងណាម្នាក់ទៀតបានឡើយ ។ ពេលខ្លះវាបានបំរើប្រជាជន (ដូចជាសាលារដ្ឋ) ឬក៏បំរើរដ្ឋជាទូទៅ ឬក៏បំរើឱ្យអង្គការដោយឡែកៗរបស់រដ្ឋ ដូចជា (កងទ័ព នគរបាល..........) ។

មុខងារនៃអង្គការរដ្ឋ និងស្ថាប័នរដ្ឋកើតមានតាមរយៈ**សេចក្តីសំរេច** និង**សកម្មភាពនៃមន្ត្រីរដ្ឋការ** ដែលបានបែងចែកដោយច្បាប់ទៅលើសិទ្ធិអំណាចផ្ទាល់ខ្លួនទាំងឡាយ ។ នៅក្នុងភាពអាស្រ័យពីសណ្តាប់ធ្នាប់នៃការទទួលយក (អនុម័ត) នៃអាជ្ញាសំរេចទាំងឡាយរបស់អង្គការរដ្ឋទាំងអស់អាចកើតមាននៅលើគោលការណ៍ទាំងឡាយ នៃការចាត់ចែងឯកភាពមួយ (Unified Management) ដូចជាក្រសួង ឬក៏គោលការណ៍នៃភាពសហប្រតិបត្តិ និងគណៈរដ្ឋមន្ត្រី ឬក្រុមប្រឹក្សារដ្ឋមន្ត្រី ជាដើម........។ល។

ដូចនេះនិយ័តកម្មធម្មនុញ្ញទៅលើយន្តកម្មរដ្ឋ នៃបណ្តារដ្ឋកាន់លទ្ធិប្រជាធិបតេយ្យ វាចាំបាច់ត្រូវតែយន្តកម្មទាំងនោះប្រកាន់យកគោលការណ៍ចាំបាច់ខ្លះៗ ដូចតទៅ :

⇨ **គោលការណ៍អធិបតេយ្យជាតិ** : គោលការណ៍នេះ ប្រភពនៃអំណាចទាំងអស់គឺជាប្រជាជន ។ អំណាចរបស់ប្រជាជននោះជាលទ្ធិប្រជាធិបតេយ្យ ។ អំណាចវាបំពេញនាទីក្នុងទំនាក់ទំនងតំណាង និងដោយផ្ទាល់ ។ ដូចជា**មាត្រា ៥១** បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជាអនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។

ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។ អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។ អំណាចទាំងនេះ ត្រូវបានប្រជាជនប្រើប្រាស់តាមរយៈអង្គការតំណាងរបស់ខ្លួន (ការបោះឆ្នោតប្រជាមតិ) ។ នៅក្នុងមាត្រា ៥១ នេះក៏មានគោលការណ៍បែងចែកអំណាចដែរ ។ គួររំលឹកថា គោលការណ៍បែងចែកអំណាចជាបង្អែកនៃគំនិតរបស់ទស្សនៈវិទូបុរាណក្រិច ឈ្មោះ **អារីស្តូត** ប៉ុន្តែវាបានទទួលជោគជ័យទៅលើទស្សនៈនេះនៅសតវត្សទីXVIII ក្នុងការកែច្នៃឱ្យកើតមានរបស់លោក **ម៉ុងតេស្គ្យេ** អ្នកទស្សនៈវិទូបារាំង ។ យោងតាមទស្សនៈរបស់គាត់ថា "**មានសេរីភាព មានន័យថាមានសិទ្ធិធ្វើអ្វីៗទាំងអស់ ដែលមិនត្រូវបានហាមឃាត់ដោយច្បាប់ទាំងពួង ហើយអាចផ្តត់ផ្តង់បាននូវសកម្មភាពនេះមានតែរដ្ឋប៉ុណ្ណោះ ដែលរដ្ឋនោះអំណាចរបស់វាត្រូវបានចែកជា ៣ គឺ អំណាចនីតិប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និងអំណាចតុលាការ ។**"

ដោយយោងទៅលើការបែងចែកអំណាចនេះ វាកើតមានការបែងចែកអំណាចដ៏ម៉ឺងម៉ាត់មួយ ដែលធ្វើឡើងដោយរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកនៅ មាត្រា I បានកំណត់ថា "អំណាចតុលាការត្រូវបំពេញភារកិច្ចដោយតុលាការកំពូលសហរដ្ឋ និងតុលាការតាមលំដាប់ថ្នាក់បន្តបន្ទាប់ ដែលត្រូវបានកំរិតដែនសមត្ថកិច្ចដោយរដ្ឋសភា (Congress)" ។

⇨ **ឧបករណ៍រដ្ឋ** : វាជាសកម្មភាពភាគច្រើននៃអង្គការរដ្ឋ ដែលកើតចេញនូវមន្ត្រីជំនាញ ឬក៏អង្គការរដ្ឋនោះត្រូវបានបំរើដោយសេវាករ (មន្ត្រីរដ្ឋការ) ទាំងឡាយ ។ អង្គការដែលជាឧបករណ៍រដ្ឋនោះមានដូចជា : ក្នុងស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ និងអង្គការផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកិច្ចការរបស់រដ្ឋ (**មើលរូបទី ៨**) ។

**៦.ឋានៈធម្មនុញ្ញគតិយុត្តិនៃអង្គការរដ្ឋ** : នេះជាស្ថាប័នមួយនៃអង្គការរដ្ឋ និងអង្គការស្វ័យគ្រប់គ្រង ដែលបានធ្វើនិយត័កម្មដោយបទដ្ឋានកិច្ចគតិយុត្តិទាំងឡាយ (ច្បាប់) ក្នុងការបង្កើតនូវឋានៈគតិយុត្តិរបស់វា គឺទីតាំងដែលមានច្បាប់ជាបង្អែក ។ ឋានៈធម្មនុញ្ញគតិយុត្តិនេះវាជាស្ថាប័នគតិយុត្តិ

មួយ ដែលមានរចនាសម្ព័ន្ធស្មុគស្មាញបំផុត ដូចជាអង្គការរដ្ឋដែលមានទំនាក់ទំនងចំពោះអង្គការស្វ័យគ្រប់គ្រងមូលដ្ឋាន និងមន្ត្រីរបស់គេជាដើម ។

ឋានៈធម្មនុញ្ញគតិយុត្តិនៃអង្គការទាំងនោះកំណត់នូវ :

**៦.១. ចំណាត់តាំងសង្គមរបស់អង្គការរដ្ឋ ឬប្រព័ន្ធអង្គការទាំងឡាយ** : លក្ខណៈនេះសំដែងចេញនូវភារកិច្ចរបស់អង្គការទាំងនោះ ដូចជា**មាត្រា ៩០** នៃរដ្ឋធម្មនុញ្ញកម្ពុជា ក្នុងវាក្យខណ្ឌទីមួយបានកំណត់ថា "រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ" ។ និងវាក្យខណ្ឌទីពីរបានកំណត់ថា "រដ្ឋសភាអនុមត័ថវិកាជាតិ ផែនការរដ្ឋឱ្យសេចក្ដីយល់ព្រម........។ល។" ទាំងនេះកំណត់នូវភារកិច្ចរបស់វា ។

**៦.២. ការកំណត់នូវសមត្ថកិច្ចរបស់អង្គការរដ្ឋ ឬសិទ្ធិ និងកាតព្វកិច្ច** : នេះវាជាមុខងារសុក្រិត្យរបស់អង្គការទាំងនោះ ។ សមត្ថកិច្ចទាំងនេះមានធាតុជាច្រើនដូចជា :

**៦.២.១.ខាងផ្នែកនីតិកម្ម** : តាម**មាត្រា ៩០** "រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ" ។ នៅក្នុងផ្នែកនេះកំណត់នូវការបង្កើតច្បាប់ ឬបទដ្ឋានកិច្ចគតិយុត្តិខ្ពស់របស់ស្ថាប័ននីតិបញ្ញត្តិ ។

**៦.២.២.សណ្ដាប់ធ្នាប់ និងនីតិកម្មរបស់អង្គការរដ្ឋ** : វាជាសណ្ដាប់ធ្នាប់នៃការបង្កើតស្ថាប័ននីមួយៗរបស់រដ្ឋ ។ ដូចជា**មាត្រា ៧៦** "រដ្ឋសភាមានសមាជិកជាតំណាងយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសំងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត ។

អង្គការរៀបចំការបោះឆ្នោតបែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត" ។ ដូចនេះ ខ្លឹមសាររបស់វាគឺដើម្បីបង្កើតអង្គការមួយរបស់រដ្ឋតាមលក្ខណៈផ្លូវច្បាប់ និងយុត្តិធម៌ ។

**៦.៣. សណ្តាប់ធ្នាប់ និងការងារនៃអង្គការរដ្ឋ** : គឺជានីតិវិធី ឬទំរង់ការរបស់រដ្ឋ ។ វាបញ្ជាក់នូវដំណើរការនៃនីតិប្បញ្ញត្តិ ឬក៏ចំណាត់តាំងផ្សេងៗរបស់វា ។ ដូចជា**មាត្រា ៨៧** "ប្រធានរដ្ឋសភា ដឹកនាំអង្គប្រជុំរបស់រដ្ឋសភាទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយដែលរដ្ឋសភា បានអនុម័តរ៉ាប់រងការងារអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា ។

ក្នុងករណីដែលប្រធានរដ្ឋសភា មានធុរះមិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជំងឺ បំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី" ។ និង**មាត្រា ១៣៧** "ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក ៩ រូប ដែលទទួលអាណត្តិ ៩ ឆ្នាំ ។ សមាជិកក្រុមប្រឹក្សារដ្ឋធម្មនុញ្ញចំនួន ១ ភាគ ៣ ត្រូវផ្លាស់ថ្មីក្នុងរយៈពេល ៣ ឆ្នាំម្តង ។ សមាជិក ៣ រូបត្រូវតែងតាំងដោយព្រះមហាក្សត្រ ៣ រូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយ ៣ រូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ប្រធាន ត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានមានសំលេងឧត្តមានុភាពក្នុងករណីបែកសំលេងជា ២ ស្មើគ្នា" ។ និង**មាត្រា ៩៨** "រដ្ឋសភាអាចទំលាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទំលាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញ្ញត្តិបន្ទោសតាមសំលេងឆ្នោត ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញ្ញត្តិបន្ទោសរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកយកមកពិភាក្សាបាន" ។ **មាត្រា ១១៩** "តាមសេចក្តីស្នើពីប្រធានដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជន ១ រូបក្នុងចំណោមតំណាងរាស្ត្រ គណៈបក្សដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះនាំសហការីដែលជាតំណាងរាស្ត្រ ឬសមាជិកគណៈបក្សតំណាងនៅក្នុងរដ្ឋសភា ដែលត្រូវផ្តួរ

ផ្តល់ឱ្យកាន់តំណែងផ្សេងៗនៅក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល" ។ រីឯក្នុង **មាត្រា ២១** "តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព ។

តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ" ។

**ង.២.៤.ភារកិច្ចទទួលខុសត្រូវនៃអង្គការរដ្ឋ** : ជាធាតុមួយដែលអង្គការរដ្ឋត្រូវទទួលខុសត្រូវចំពោះអង្គការផ្សេងៗ និងចំពោះពលរដ្ឋ ។ តាម **មាត្រា ១៣៦** "ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការការពារគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចលើករណីវិវាទកម្មដែលទាក់ទងនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា" ។ និង **មាត្រា ១២៨** "អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការធានារក្សាអនាគត និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់" ។ **មាត្រា ១២២** "សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល មិនអាចយកសំអាងនៃសេចក្តីបង្គាប់ដោយលាយល័ក្ខអក្សរ ឬដោយវាចា អំពីនរណាមួយដើម្បីដោះសារឱ្យរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ" ។

# គំនូសបំព្រួញនៃការសិក្សាអំពីរដ្ឋ (រូបទី ៧)




* សំគាល់ : ក្នុងផ្នែកទ្រឹស្តីនៃការកកើតរដ្ឋ ពុំបានបកស្រាយក្នុងសៀវភៅនេះឡើយ ។

# គំនូសបំព្រួញនៃការចាត់ថ្នាក់លើអង្គការរដ្ឋ (រូបទី ៨)



# គំនូសបំព្រួញនៃទំរង់រដ្ឋ (រូបទី ៩)



# អត្ថបទទី ១១

# បក្សនយោបាយ និងប្រព័ន្ធបក្ស

## ១. និយមន័យ និងខ្លឹមសារនៃបក្សនយោបាយ

ពាក្យថា "**បក្ស**" មានដើមកំណើតពីពាក្យឡាតាំង "Pars" មានន័យថា "**ផ្នែក**"។ រីឯពាក្យនយោបាយចេញពីពាក្យក្រិចថា "Politika" មានន័យថាបុរី ឬក៏ការងារសង្គម ព្រោះវាកើតចេញពីពាក្យក្រិចដែលថា "Polis" ស្មើនឹងរដ្ឋ ឬបុរី ។ **ដូចនេះបក្សនយោបាយ គឺជាផ្នែកមួយយ៉ាងសកម្ម និងប្រមូលផ្តុំនៃកំលាំងសង្គម ដោយបានបង្រួបបង្រួមផលប្រយោជន៍ទូទៅក្នុងគោលដៅ ឬក៏គំនិតទាំងឡាយសំដៅព្យាយាមចាប់យកអំណាច ឬក៏ធ្វើជាគំរូដំណោះស្រាយមួយដ៏មានឥទ្ធិពលទៅលើការបំពេញកិច្ចរបស់បក្សនយោបាយនោះ** ។ **ប៉ុន្តែតាមមាត្រា ២** នៃច្បាប់គណៈបក្សនយោបាយកម្ពុជា ១៩៩៧ បានកំណត់ថា "គណៈបក្សនយោបាយ គឺជាក្រុមមនុស្សដែលមានគំនិត និងឆន្ទៈស្របគ្នា ហើយរួបរួមដោយស្មគ្រ័ចិត្តតាមកិច្ចសន្យា បង្កើតឡើងនូវអង្គការមួយមានលក្ខណៈអចិន្ត្រៃយ៍ និងស្វ័យភាព ដើម្បីចូលរួមក្នុងឆាកនយោបាយជាតិ តាមរបបប្រជាធិបតេយ្យសេរីពហុបក្ស ដោយការបោះឆ្នោតដោយសេរី និងយុត្តិធម៌ស្របតាមការកំណត់របស់រដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ពន្ធ័ជាធរមាន"។ យើងអាចសង្កេតឃើញជាប្រវត្តិសាស្ត្ររបស់បក្សទាំងនោះ បានកើតមានតាំងពីសម័យបុរាណក្រិច, បុរាណរ៉ូម និងនៅក្នុងសម័យយុគ្គកណ្តាលទៀតផង ប៉ុន្តែរបបគ្រប់គ្រងរដ្ឋក្នុងសម័យទាំងនោះ វាកើតមានត្រឹមតែសញ្ញាណប្រជាធិបតេយ្យតែប៉ុណ្ណោះ ។ ក្នុងល័ក្ខខ័ណ្ឌទាំងនេះ បក្សវាអាចសំដែងចេញនូវផលប្រយោជន៍សង្គមដែរ ។ ដោយឈរលើបញ្ហាទាំងនោះ (ផលប្រយោជន៍សង្គម) បក្សធ្វើសកម្មភាពក្នុងក្របខណ្ឌ័មួយជាលក្ខណៈ**គូរប្រជែង** (Rival) នៃបក្សផ្សេងៗ ។ ដូចនេះនៅគ្រប់ល័ក្ខខ័ណ្ឌនៃរបបគ្រប់គ្រងសង្គម **វត្តមានបក្សនយោបាយពុំអាចមានលក្ខណៈស្របគ្នាបានទេ** (មានការប្រឈមមុខ) ។ រីឯការសង្កេត

ក្រោយមកទៀត តាមការវាយតំលៃជារួមបក្សនយោបាយទាំងអស់ក្នុង**សម័យទំនើប** វាបង្កើតឡើងតាមលក្ខណៈនៃបក្សនយោបាយពីមុនដែរ ដែលបក្សទាំងនោះ**តំណាងឱ្យប្រជាជន** គឺវាជា**ប្រព័ន្ធមួយនៃអំណាចតាមរយៈប្រជាជន ដែលបំពេញភារកិច្ចតាមរយៈតំណាងជ្រើសរើស** ។ គេអាចកំណត់ការលេចរូបរាងនៃកិច្ចការសង្គមនៅ ក្នុងបក្សបង្រួបបង្រួមដំបូងបង្អស់ គឺធ្វើឡើងដោយជ្រុងពីរ **ទីមួយគឺភាគីរាជា** និង**សក្តិភូមិ** (Feudalism) ឯជ្រុងម្ខាងទៀត គឺជា**ភាគីអ្នកការពារសមភាព** និង**នយោបាយសេរី** ។ មានន័យថាភាគីម្ខាងគាំទ្ររបបរាជានិយម និងម្ខាងទៀតគាំទ្ររបបសាធារណរដ្ឋនិយម ។

បក្សនយោបាយទាំងអស់ដើរតួយ៉ាងសំខាន់នៅក្នុងកិច្ចការសង្គម និងរដ្ឋដែលវាជាសមាសភាគ (Component) សំខាន់បំផុតនៃ**ប្រព័ន្ធនយោបាយ** ព្រោះថាប្រព័ន្ធនយោបាយជា**ប្រព័ន្ធមួយនៃស្ថាប័នទាំងឡាយក្នុងការងារគ្រប់គ្រង និងការងាររដ្ឋ** ។ ដូចមាត្រា ៥១ វាក្យខណ្ឌមួយនៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស"។ ដោយផ្សារភ្ជាប់នឹងការតស៊ូរវាងគ្នានឹងគ្នា ចំពោះការដោះស្រាយបញ្ហា**អំពីអំណាចនយោបាយ** គឺអំពីកម្មសិទ្ធិរបស់វា (អំណាចនយោបាយ) **អំពីការប្រើប្រាស់មធ្យោបាយ** និង**ទំរង់**ទាំងឡាយនៃការធ្វើសមិទ្ធិរបស់អំណាចរដ្ឋដោយមានភាគីជាច្រើន នោះគេអាចសង្កេតឃើញនូវសមាសភាគនៃគណៈបក្សទាំងឡាយនោះមានដូចជា :

**ក.ភាគីនៃបក្សនយោបាយ** : គឺជាសមាសភាពនៃបក្សនីមួយៗដែលចូលរួមក្នុងការបោះឆ្នោតដើម្បីទទួលយកអំណាចរដ្ឋតាមរយៈសំលេងឆ្នោតរបស់ពលរដ្ឋ ។ ជាទូទៅការបោះឆ្នោតគាំទ្រចំពោះបេក្ខជនក្នុងអង្គការរដ្ឋទាំងឡាយ វាត្រូវរៀបចំឡើងតាមការចូលរួមពីបក្សនយោបាយជាច្រើន ក្នុងប្រទេសតាមរយៈអ្នកបោះឆ្នោត (Voter) ជាអ្នកជ្រើសរើស ។ ច្បាប់បោះឆ្នោតកម្ពុជា ឆ្នាំ ១៩៩៧ បានកំណត់ក្នុង**មាត្រា ៣៣** ថា "ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

១- មានសញ្ជាតិខ្មែរពីកំណើត ។

២- មានអាយុម្ភៃប្រាំ (២៥) ឆ្នាំឡើងទៅ គិតទៅដល់ថ្ងៃបោះឆ្នោត ។

៣- មានសិទ្ធិបោះឆ្នោត ។

៤- ស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា យ៉ាងតិចមួយ (១) ឆ្នាំគិតទៅដល់ថ្ងៃបោះឆ្នោត ។

៥- មានការតែងតាំងពីគណៈបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត។" ដូចនេះ ដើម្បីបំពេញនាទីជាសមាសភាពនៃបេក្ខជនក្នុងបក្សនយោបាយ ក្នុងការចូលរួមប្រលងប្រណាំងចាប់យកអំណាចរដ្ឋ ត្រូវមានកត្តាជាច្រើននៃបេក្ខភាពបក្សនយោបាយ ។

**ខ.ខ្លឹមសារនៃបក្សនយោបាយ** : ខ្លឹមសារនៃបក្សនយោបាយ គឺជាការកំណត់មុខងារ និងទិសដៅនៃគោលការណ៍របស់បក្សនយោបាយនីមួយៗក្នុងការចូលរួមបោះឆ្នោត ។ ក្នុង**មុខងារ** និង**ទិសដៅ**ទាំងឡាយនៃបក្សនយោបាយពិតជាមានប្រភេទផ្សេងៗគ្នា ដោយឈរលើលក្ខណៈគ្រឹះនៃបក្សនីមួយៗដែលបង្កើតមកដំបូង ។ ដូចជា**បក្សប្រជាធិបតេយ្យ** វាមានគោលដៅផ្ដត់ផ្គង់នូវប្រសិទ្ធិភាពនៃមុខងារគ្រប់គ្រងទៅគ្រប់ប្រព័ន្ធនយោបាយរបស់ប្រទេស ។ ប៉ុន្តែទោះជាបក្សនីមួយៗមានគោលដៅ និងមុខងារខុសគ្នាក៏ដោយ ក៏បក្សនោះត្រូវមាន**ចរិតរួម**មួយដែរ ដែលមានច្បាប់ជាអ្នកកំណត់ ដូចជា**មាត្រា ៦** ច្បាប់គណៈបក្សនយោបាយកម្ពុជា ១៩៩៧ កំណត់ថា "គ្រប់គណៈបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយដូចខាងក្រោមនេះ :

១- ធ្វើឱ្យមានអបគមន៍ដែលនាំឱ្យអន្តរាយដល់ឯកភាពជាតិ និងបូរណភាពដែនដី ។

២- ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យសេរីពហុបក្ស ដោយប្រើប្រាស់មធ្យោបាយហឹង្សាក្នុងគោលបំណងដណ្ដើមអំណាច ។

៣- បង្កើតកំលាំងប្រដាប់អាវុធ" ។ ជាការពិតណាស់**ខ្លឹមសារនៃបក្សនយោបាយធំបំផុតគឺសំរាប់ធ្វើឱ្យមានការបោះឆ្នោតនៅគ្រប់ស្រទាប់សង្គម ស្ថេរភាពការគ្រប់គ្រងសង្គម** ។ល។ គោលដៅទាំងនោះជាបំណងរបស់ប្រជាធិបតេយ្យ ។ តាមច្បាប់គណៈបក្សដែលបានកំណត់ក្នុង

**មាត្រា ១០** ថា "គណៈបក្សនយោបាយនីមួយៗត្រូវរៀបចំលក្ខន្តិកៈ និងគោលនយោបាយសំខាន់ៗ ជាលាយល័ក្ខអក្សរ ដែលមានចំណុចសំខាន់ៗយ៉ាងតិចណាស់ដូចខាងក្រោមនេះ :

**ក. លក្ខន្តិកៈត្រូវមាន :**

១- ឈ្មោះជាអក្សរពេញ អក្សរកាត់ និងសញ្ញាសំគាល់ ។

២- អាស័យដ្ឋាននៃទីស្នាក់ការកណ្តាល ។

៣- កាលបរិច្ឆេទនៃការបង្កើតគណៈបក្សនយោបាយ ។ កាលបរិច្ឆេទគណៈបក្សនយោបាយនេះមិនត្រូវជាន់លើថ្ងៃបុណ្យជាតិ និងអន្តរជាតិ ។

៤- វិធានស្តីពីការបញ្ចូលជាសមាជិកភាព និងការបណ្តេញចេញពីសមាជិក ។

៥- សិទ្ធិ និងភារកិច្ចរបស់សមាជិក ។

៦- រចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមបន្តបន្ទាប់ ។

៧- សមត្ថកិច្ចនៃអង្គការនានារបស់គណៈបក្សនយោបាយ ។

៨- បែបបទនៃការជ្រើសរើសនិងដកហូតមុខងាររបស់សមាជិកគណៈកម្មាធិការនាយក។

៩- ការកំណត់អំពីការប្រជុំសាមញ្ញនៃអង្គការនានារបស់គណៈបក្សនយោបាយ ។

១០- ចំនួនសមាជិកចាំបាច់ "កូរ៉ុម" ដែលត្រូវចូលរួមក្នុងអង្គប្រជុំនៃអង្គការនានារបស់គណៈបក្សនយោបាយ ដើម្បីឱ្យអង្គប្រជុំនោះយកជាការបាន ។

១១- ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់គណៈបក្សនយោបាយ ។

១២- វិធានស្តីពីការរំលាយគណៈបក្សនយោបាយ និងការចាត់ចែងទ្រព្យសម្បត្តិរបស់គណៈបក្សនយោបាយនៅពេលត្រូវរំលាយ ។

១៣- វិធានស្តីពីការធ្វើវិសោធនកម្មលក្ខន្តិកៈគណៈបក្សនយោបាយ ។

**ខ. គោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗត្រូវចែងអំពីគោលដៅ និងវត្ថុបំណងរបស់គណៈបក្សនយោបាយ**" ។ តាមមាត្រានេះបញ្ជាក់កាន់តែច្បាស់នូវសណ្តាប់ធ្នាប់នៃការងាររបស់បក្សនយោបាយនីមួយៗ ក្នុងការកំណត់មុខងារនៃសមាជិករបស់ខ្លួនក្នុងសកម្មភាពរបស់បក្ស ។

**ច.មុខងារនៃបក្សនយោបាយ** : មុខងារនៃបក្សនយោបាយ គឺជាការកំរិតនៃសកម្មភាពរបស់បក្សនយោបាយនីមួយៗក្នុងក្របខណ្ឌនៃលក្ខន្តិកៈរបស់បក្ស និងស្របតាមរបបនយោបាយរបស់រដ្ឋ។ មុខងារនេះត្រូវបានកំណត់ក្នុងមាត្រា ១០ នៃច្បាប់បោះឆ្នោតកម្ពុជា ១៩៩៣ រួចទៅហើយ។ មុខងារនេះវាជាទិន្នាការដែលឆ្ពោះទៅរកសកម្មភាពរបស់ខ្លួន ក្នុងល័ក្ខខ័ណ្ឌនៃភារកិច្ចចាំបាច់របស់បក្ស ។ មុខងារទាំងនោះមាន :

**ច១. ការកែច្នៃនូវកម្មវិធីនយោបាយ** : នេះគឺជាវិធីសាស្ត្រ និងមធ្យោបាយគ្រប់គ្រងរបស់បក្សក្នុងការធ្វើឱ្យមានការវិវត្តទៅលើកម្មវិធីនានារបស់បក្ស ។ ជាការបង្កើតនូវគណៈកម្មាការ ក្រុមប្រឹក្សាសង្គម ក្រុមគណៈកម្មាធិការ .............. ។ល។ ការកើតនូវលក្ខណៈរបៀបនេះបាន កាលណាបក្សនយោបាយមានលក្ខណៈពុំប្រក្រតី ឬមានសកម្មភាពទៅលើបក្សផ្សេងៗពុំមានឥទ្ធិពល ឬក៏មានឥទ្ធិពល ។ ឧទាហរណ៍ក្នុងអណត្តិមុនគណៈបក្ស A មានអាសនៈ **២០** ក្នុងសភាតំណាងរាស្ត្រ តែអាណត្តិថ្មីនេះ គណៈបក្ស A មានអាសនៈ **៥០** នេះបញ្ជាក់ថា**ការកែច្នៃកម្មវិធីនយោបាយ** ។

**ច២. ការបំរែបំរួលនូវក្បាលម៉ាស៊ីនដឹកនាំបក្ស** : គឺការធ្វើឱ្យមានសមាជិកថ្មី និងបេក្ខជនថ្មីក្នុងការឈរឈ្មោះ ក្នុងការដឹកនាំបក្សនយោបាយ ។ នេះជាគោលដៅនយោបាយមួយដើម្បីឱ្យមានប្រជាធិបតេយ្យក្នុងគណៈបក្សសំរាប់អ្នកដឹកនាំបក្ស គឺធ្វើយ៉ាងណាឱ្យសមាសភាពដឹកនាំបក្សត្រូវប្រែប្រួលសមស្របតាមសមត្ថភាពរបស់បេក្ខភាពដឹកនាំ ។

**ច៣. ការបង្កើត និងត្រួតពិនិត្យ** : មុខងារពិសេសនេះ គឺចូលរួមរបស់បក្សក្នុងការបង្កើត និងត្រួតពិនិត្យចំពោះសកម្មភាពនៃអង្គការមានអំណាចរដ្ឋ ។ ត្រង់នេះគឺចង់បញ្ជាក់នូវសិទ្ធិរបស់បក្សនយោបាយក្នុងការឃ្លាំមើលសកម្មភាពខុសឆ្គងទាំងឡាយរបស់រដ្ឋអំណាច ឬអង្គការរដ្ឋផ្សេងៗដែលផ្ទុយនឹងច្បាប់រដ្ឋ ។

**ច៤. ការចូលរួមរបស់បក្ស** : បក្សអាចចូលរួមដោះស្រាយទំនាស់ក្នុងសង្គម គឺចូលរួមក្នុងការជ្រើសរើសទៅលើបុគ្គលិករដ្ឋ ឬរដ្ឋការរបស់រដ្ឋ ។ នេះគឺមានន័យថាបក្សនយោបាយត្រូវតែចូលរួមដោះស្រាយទំនាស់សង្គមតាមរយៈការចូលប្រលូកបោះឆ្នោត ដើម្បីចាប់យកអំណាចរដ្ឋតាមរយៈពលរដ្ឋ ។ តែពុំមានន័យថា បុគ្គលិករដ្ឋ ឬមន្ត្រីរាជការសុទ្ធតែជាសមាជិកនៃបក្សនោះទេ ។

**៥៤. មុខងារសមាហរណកម្មជាតិ (បង្រួបបង្រួមជាតិ)** : នេះជាភារកិច្ចមួយរបស់បក្សនយោបាយប្រកាន់យកភាពរួបរួមស្រុះស្រួលក្នុងជាតិទាំងមូល ក្នុងគោលដៅឯកភាពជាតិដោយប្រឆាំងនូវនយោបាយផ្ដាច់ទឹកដី និងការប្រកាន់ពូជសាសន៍ ។

**៥៦. មុខងារបណ្ដុះមនោគមវិជ្ជា** : មុខងារនេះគឺអប់រំដល់សមាជិក និងឃោសនាដល់អ្នកដែលមិនមែនសមាជិកឱ្យយល់ដឹងពីបក្សរបស់ខ្លួន ។ នេះជាបំណងរបស់បក្សក្នុងការដណ្ដើមយកនូវសមាជិកពីមហាជនសំរាប់ពង្រីកនូវទ្រង់ទ្រាយរបស់បក្ស ។

**៥៧.មុខងារទំនាក់ទំនង** : មុខងារនេះវាសំដៅឱ្យមហាជនទាំងជាតិ និងអន្តរជាតិចូលរួមគាំទ្រទាំងផ្នែកស្មារតី និងសំភារៈ។ ដើម្បីកំណត់នូវសណ្ដាប់ធ្នាប់នៃអង្គការនយោបាយរបស់បក្សនីមួយៗ ក្នុងក្របខ័ណ្ឌនៃមុខងារទំនាក់ទំនង ជាដំបូងត្រូវកំណត់អង្គការនយោបាយដូចច្បាប់គណបក្សកម្ពុជា ១៩៩៧ បានកំណត់ថា "អង្គការដឹកនាំរបស់គណៈបក្សនយោបាយនីមួយៗ ត្រូវមានយ៉ាងតិចដូចខាងក្រោម :

- មហាសន្និបាត ឬសមាជ ឬអង្គការសមមូល ។
- ក្រុមប្រឹក្សាជាតិ ឬគណៈកម្មាធិការកណ្ដាល ឬអង្គការសមមូល។
- គណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូល ។
- គណៈកម្មាធិការអាជ្ញាកណ្ដាល ឬគណៈកម្មាកាធិការត្រួតពិនិត្យ ឬគណៈកម្មាធិការវិវាទ ឬអង្គការសមមូល។" ជាងនេះទៅទៀតគណៈបក្សនយោបាយ និងសមាជិករបស់ខ្លួនត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ មិនជ្រៀតជ្រែកកិច្ចការរបស់គណៈបក្សផ្សេងៗក្នុងគ្រប់រូបភាព ដូច**មាត្រា ៧១** ច្បាប់បោះឆ្នោតកម្ពុជា ១៩៩៧ បានកំណត់ទៀតថា "គណៈបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវជៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណៈបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

គ្រប់គណៈបក្សនយោបាយ និងបេក្ខជនទាំងអស់មិនត្រូវរំញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភតំរាមកំហែង អំពើហឹង្សា ឬបំភិតបំភ័យទៅលើបុគ្គលគណៈបក្សនយោបាយដទៃទៀតឡើយ"។ រីឯមុខងារទំនាក់ទំនងវាផ្តោតទៅលើបញ្ហាហិរញ្ញវត្ថុ ដែលបានមកពីការចូលរួមរបស់ជាតិ និងអន្តរជាតិ ឬក៏សប្បុរសជន ប៉ុន្តែមានល័ក្ខខ័ណ្ឌដូច**មាត្រា ២៧** ច្បាប់គណៈបក្សនយោបាយដដែលបញ្ជាក់ថា "ចាត់ទុកជាហិរញ្ញវត្ថុរបស់គណៈបក្សនយោបាយ ចំណូលដែលបានមកពី :

១-វិភាគទាន ឬភាគទានរបស់សមាជិក ។

២-ចំណូលផ្សេងៗរបស់គណៈបក្សនយោបាយដែលបានមកពីការធ្វើអាជីវកម្មស្របច្បាប់។

៣-ប្រាក់ពីថវិការបស់រដ្ឋតាមការកំណត់ដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ ។

៤-អំណោយរបស់ក្រុមហ៊ុនឯកជនខ្មែរ ឬសប្បុរសជនខ្មែរ ។

៥-ទ្រព្យសម្បត្តិរបស់គណៈបក្សនយោបាយ"។ និង**មាត្រា ២៧** កំណត់ថា "រដ្ឋអាចផ្តល់ប្រាក់ពីថវិកាជាតិស្មើៗគ្នាដល់គ្រប់គណៈបក្សនយោបាយ សំរាប់តែប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

គណៈបក្សនយោបាយដែលមិនបានទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៣% នៃសន្លឹកឆ្នោតបានការសរុបទូទាំងប្រទេស ឬមិនបានទទួលអាសនៈមួយនៅក្នុងរដ្ឋសភា គណៈបក្សនយោបាយនោះត្រូវសងប្រាក់នោះគ្រប់ចំនួនមករដ្ឋវិញក្នុងរយៈពេលបីខែយ៉ាងយូរ ចាប់ពីថ្ងៃប្រកាសលទ្ធផលជាស្ថាពរនៃការបោះឆ្នោត"។ និង**មាត្រា ២៩** កំណត់ថា "គណៈបក្សនយោបាយត្រូវបានហាមឃាត់មិនឱ្យទទួលវិភាគទាន ទោះជាតាមរូបភាពណាក៏ដោយពីស្ថាប័នរដ្ឋ សមាគមអង្គការក្រៅរដ្ឋាភិបាល សហគ្រាសសាធារណៈ វិទ្យាស្ថានសាធារណៈ ឬក្រុមហ៊ុនបរទេសលើកលែងតែករណីដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ"។ **ការកំណត់លើហិរញ្ញវត្ថុនេះ ដើម្បីជាប្រយោជន៍នៃមុខងារទំនាក់ទំនងជាតិ និងអន្តរជាតិរបស់គណៈបក្សនយោបាយទាំងឡាយនៃប្រទេសនីមួយៗ ។**

## ២. ចំណាត់ថ្នាក់សង្គម-នយោបាយរបស់បក្ស

នេះគឺជាប្រភេទនៃបក្សនយោបាយដែលកើតមានក្នុងសង្គមពិតប្រាកដ ដោយបក្សទាំងនោះមានលក្ខណៈខុស១គ្នា ក្នុងទំរង់នៃការសំដែងចេញនូវផលប្រយោជន៍សង្គម ។

ប្រភេទនៃនយោបាយសង្គម សំរាប់ការចាត់ថ្នាក់នៃបក្សទាំងនោះវាបង្ហាញថា **តើផលប្រយោជន៍សង្គមអ្វីខ្លះដែលបក្សត្រូវសំដែងចេញ ? តើទិសដៅណាខ្លះបានចោទនៅពីមុខខ្លួន និងមធ្យោបាយណាខ្លះរបស់បក្សដែលទទួលបានជោគជ័យ ក្នុងការសំដែងចេញចំពោះផលប្រយោជន៍សង្គម ?**។ ជាទូទៅបក្សនយោបាយដែលបានកើតឡើងមុនសតវត្សទី XIX នៅក្នុងប្រទេសរីកចំរើនមួយចំនួនលើពិភពលោក ច្រើនតែជា**បក្សនយោបាយកំពុងគ្រប់គ្រងប្រទេស**ដែលមានលក្ខណៈជា**បក្សគហបតីឯកទិភាព** (ផ្តាច់មុខ) ជាពិសេសក្រោយសង្គ្រាមលោកលើកទី II បក្សដែលមានលក្ខណៈផ្តាច់មុខនេះកើតមានរូបរាងយ៉ាងច្បាស់ ក្នុងបណ្តាប្រទេសមួយចំនួនលើពិភពលោក ជាពិសេសក្នុងប្រទេសដែលប្រកាន់របបសង្គមនិយម ។

រៀងរាល់បក្សនយោបាយនៃប្រទេសនីមួយ១ តែងមានគោលដៅ និងមុខងារផ្សេង១គ្នា ដោយប្រកាន់**ជំហរ** និង**ទស្សនៈ**ទៅតាមមាគ៌ារបស់បក្សនីមួយ១ ដែលមានលក្ខណៈសមស្របតាមឆន្ទៈប្រជាជន និងការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចនៃសម័យកាល ។ ដូចនេះចំណាត់ថ្នាក់នៃបក្សក្នុងប្រទេសនីមួយ១មាន : **បក្សនិយមឆ្វេង**, **បក្សនិយមស្តាំ**, **បក្សនិយមកណ្តាល**។ ចំណាត់ថ្នាក់នេះកើតមានបន្ទាប់ពី**បដិវត្តន៍បារាំង** ដែលពេលនោះអ្នកអភិរក្សនិយម**ប្រកាន់ស្តាំ** រីឯភាគីកែទំរង់**ប្រកាន់ឆ្វេង** ។ ប៉ុន្តែក៏មានបក្សខ្លះដែលប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យដែរ ដែលគេហៅថា **បក្សរ៉ាឌីកាល់** (អាចមានបក្សរ៉ាឌីកាល់និយមឆ្វេង និងបក្សរ៉ាឌីកាល់និយមស្តាំ) ។ គេអាចសង្កេតឃើញមាន**បក្សកំហឹង**ដែលមានលក្ខណៈក្រៅច្បាប់ ឬហៅថាបក្ស**អច្ចន្តិកនិយម** (បក្សដែលចូលចិត្តក្នុងគំនិតបះបោរផ្សេង១ ឬហៅថា Extremist) ដែលនៅក្នុងនោះសំបូរដោយពួក**សកម្មជន** ។ បក្សរបៀបនេះច្រើនតែធ្វើអំពើភេវរកម្មផ្សេង១ ព្រោះថាបក្សមានលក្ខណៈ**ជាតិនិយមប្រកាន់ពូជសាសន៍**....... ។ល។

## ៣. ចំណាត់ថ្នាក់អង្គការគ្រប់គ្រងនៃបក្សនយោបាយ

ការចាត់ថ្នាក់ទៅលើអង្គការគ្រប់គ្រងនៃបក្សនយោបាយ គឺធ្វើឡើងតាមគោលការណ៍គ្រឹះនៃច្បាប់ដែលបានកំណត់ទៅលើបក្សទាំងនោះ ដោយអាស្រ័យនឹងសកម្មភាពផ្ទៃក្នុងរបស់បក្សតាមក្របខ័ណ្ឌនៃអង្គការគ្រប់គ្រង ។

ទោះបីជាអង្គការគ្រប់គ្រងនៃបក្សនយោបាយ បង្កើតមកមានលក្ខណៈផ្សេងៗគ្នាក៏ដោយ ក៏ចំណាត់ថ្នាក់អង្គការគ្រប់គ្រងនៃបក្សនយោបាយទាំងនោះ គេអាចចាត់ថ្នាក់វាជាក្រុមផ្សេងពីគ្នាបានដែរ ។ ដូចនេះចំណាត់ថ្នាក់**អង្គការគ្រប់គ្រង** នៃបក្សនយោបាយចែកជា**ពីរក្រុម**សំខាន់ គឺ**បក្សនីត្យានុកូល** (Legal Party) និង**បក្សអនីត្យានុកូល** (Illegal Party) ។

**ក.បក្សនយោបាយនីត្យានុកូល** (Legal Party) : នេះគឺជាបក្សនយោបាយដែលមានសមាសភាពរបស់ខ្លួនប្រកបដោយលក្ខណៈច្បាប់ត្រឹមត្រូវ តាមបែបបទសណ្ដាប់ធ្នាប់គតិយុត្តិ ។ ជានិច្ចកាលបក្សនយោបាយរបៀបនេះ ធ្វើឡើងដោយមានចំនួនសមាជិកច្បាស់លាស់ និងប្រកាន់យកនូវវិន័យ និងអង្គការគ្រប់គ្រងរបស់គេយ៉ាងខ្ជាប់ខ្ជួន ។ ដូច**មាត្រា ២០** ច្បាប់គណៈបក្សនយោបាយកំណត់ថា "គណៈបក្សនយោបាយត្រូវបំពេញបែបបទ និងល័ក្ខខ័ណ្ឌដូចខាងក្រោម :

១- ពាក្យសុំចុះបញ្ជីគណៈបក្សនយោបាយត្រូវមានហត្ថលេខារបស់ប្រធានគណៈបក្សនយោបាយ ។

២- ឈ្មោះជាអក្សរពេញ និងអក្សរកាត់ និងសញ្ញាសំគាល់របស់គណៈបក្សនយោបាយ ។

៣- អាស័យដ្ឋាននៃទីស្នាក់ការកណ្ដាលរបស់គណៈបក្សនយោបាយ ។

៤- ច្បាប់ដើមនៃលក្ខន្តិកៈគណៈបក្សនយោបាយចំនួនពីរច្បាប់ ។

៥- បទបញ្ជាផ្ទៃក្នុងរបស់បក្សនយោបាយប្រសិនបើមាន ។

៦- គោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗរបស់គណៈបក្សនយោបាយ ។

៧- សេចក្ដីថ្លែងការណ៍ជាលាយល័ក្ខអក្សររបស់គណៈបក្សនយោបាយ ស្ដីពីការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្ដីពីគណៈបក្សនយោបាយ និងបទប្បញ្ញត្តិផ្សេងៗជាធរមាន និងគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស ។

៨- បញ្ជីឈ្មោះដោយមានអាយុ អាស័យដ្ឋាន និងស្នាមមេដៃរបស់សមាជិកទាំង ៤០០០ នាក់ ដោយមានបញ្ជាក់លេខបណ្ណ័សមាជិកគណៈបក្ស និងកាលបរិច្ឆេទនៃការចូលសមាជិកភាពគណៈបក្សនយោបាយ ។

៩- ជីវប្រវត្តិសង្ខេបរបស់ប្រធាន ឬស្ថាបនិកចំនួន ៣ នាក់ យ៉ាងតិចក្នុងមួយច្បាប់ដោយមានបិទរូបថតទំហំ ៤ គុណនឹង ៦ ។

១០-សេចក្ដីប្រកាសអំពីគណនីធនាគារនៅធនាគារ ក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា" ។

ក្រុមបក្សរបៀបនេះមាន**រចនាសម្ព័ន្ធ**ច្បាស់លាស់ និងការពិភាក្សាដោះស្រាយដោយផ្អែកលើមធ្យោបាយផ្សេងៗរបស់លក្ខន្តិកៈបក្ស ។ សមាជិករបស់បក្សត្រូវតែបង់ប្រាក់ប្រចាំខែ ឬប្រចាំឆ្នាំយ៉ាងហោចណាស់ក៏ ០.១ % នៃប្រាក់ចំណូលម្នាក់ដែរ បក្សរបៀបនេះមានច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសជឿនលឿន។ បក្សដែលមានលក្ខណៈនីត្យានុកូលនេះមានភាពយូរអង្វែង និងជាប្រវត្តិសាស្ត្ររបស់បក្សទៀតផង ។

**ខ.បក្សនយោបាយអនីត្យានុកូល** (Illegal Party) : នេះគឺជាបក្សនយោបាយដែលមានលក្ខណៈជាបណ្ដោះអាសន្នតែប៉ុណ្ណោះ ។ បក្សទាំងនេះ**គ្មានវត្តមាន**នូវចំនួនសមាជិកភាពរបស់គេទេ ប៉ុន្តែវាមានបណ្ដាញទ្រទ្រង់ទ្រាយបក្សជាមួយនឹងភាគីរបស់គេ ។ បក្សរបៀបនេះពុំមានឯកសារស្ដីពីកម្មសិទ្ធិបក្សរបស់ខ្លួនទេពុំមានការបង់ប្រាក់ ហើយក៏គ្មានការសន្យាគោរពនូវកាតព្វកិច្ចណាមួយចំពោះបក្សដែរ ( ដូចជាវិន័យ និងការគ្រប់គ្រង) ។ លក្ខណៈនៃបក្សរបៀបនេះ គឺថាអ្នកបោះឆ្នោតឱ្យបក្សមួយក្នុងពេលមានការបោះឆ្នោតតែប៉ុណ្ណោះ មានន័យថាគេប្រមូលគ្នាដើម្បីឈរនៅខាងបក្សណាមួយដែលគេនិយមប៉ុណ្ណោះ ។ ឧបករណ៍នៃបក្សរបៀបនេះ បង្កើតឡើងពីសមាសភាពនៃ**អ្នកជំនាញ** និង**អ្នកសកម្មជនផ្សេងៗ** ដើម្បីដឹកនាំក្នុងពេលយុទ្ធនាការបោះឆ្នោត ។ បក្សទាំងនេះវាកើតមានតាមអាទិភាពមួយគឺ**ចលនាបោះឆ្នោត** ។ បក្សរបៀបនេះអាចកើតមាននៅក្នុងរដ្ឋសភា ដែលគេហៅថា**បក្សសភាបំបែក** (Fraction) ។ គោលដៅនៃបក្សបំបែកនេះ គឺធ្វើឡើងដើម្បីប្រមូលផ្ដុំកំលាំងក្នុងសភា

ដើម្បីប្រឆាំង ឬគាំទ្រទៅលើគំនិតធំៗណាមួយដែលត្រូវដោះស្រាយ តាមរយៈ**សំលេងបោះឆ្នោត**។ លក្ខណៈរបៀបនេះ គេប្រទះឃើញនៅបណ្តាប្រទេសរីកចំរើនជាច្រើន ។ បក្សដែលមានលក្ខណៈរបៀបនេះ មានផលប្រយោជន៍ក្នុងពេលមានការប្រឆាំងក្នុងរដ្ឋសភា ( មើលការរបៀងនៃសមាជិករដ្ឋសភា ក្នុងចំនុច ២ នៃអត្ថបទ ១៥) ។

## ៤. ស្ថាប័ននាវូបនីយកម្មនៃបក្សនយោបាយ និងនិយ័តកម្មធម្មនុញ្ញគតិយុត្តិ

នេះគឺជាបក្សនយោបាយទាំងឡាយ ដែលបង្កើតមកដោយឈរលើគោលការណ៍គ្រឹះនៃច្បាប់រដ្ឋ ( រដ្ឋធម្មនុញ្ញ) ។ ភាពស្មុគស្មាញនៃ**ទំរង់នីតិវិធី**ទាំងឡាយរបស់ការងារបក្សនយោបាយ ត្រូវដោះស្រាយតាមស្ថាប័នគតិយុត្តិរបស់វា ជាពិសេសមានច្បាប់គ្រឹះជាបង្អែក ឬហៅថា**ស្ថាប័នធម្មនុញ្ញគតិយុត្តិ**នៃបក្សនយោបាយ ។ ជាការពិតណាស់គណៈបក្សនយោបាយនីមួយៗ ត្រូវបានចារឹកឡើងដោយលក្ខណៈ**គ្រឹះពីរ**ក្នុងការវិវត្តន៍នៃទំនាក់ទំនង ដែលឈរលើគោលការណ៍គតិយុត្តិគឺ :

**ក.រដ្ឋធម្មនុញ្ញភាវូបនីយកម្ម** (Constitutionalization) : នេះគឺជាខ្លឹមសារនៃបក្សនយោបាយដែលបង្កើតវាតាមការផ្តល់សិទ្ធិ ដោយបានចារឹកក្នុងរដ្ឋធម្មនុញ្ញនូវកម្មវត្ថុទូទៅ នៃបក្សនយោបាយក្នុងប្រទេសនីមួយៗ ។ នេះមានន័យថា**អាទិភាពឋានៈ** និង**គោលការណ៍**របស់បក្សនយោបាយមាននៅក្នុងរដ្ឋធម្មនុញ្ញ ដូច**មាត្រា ៤២** នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមកការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម" ។ ដូចនេះគណៈបក្សដែលមានលក្ខណៈធម្មនុញ្ញភាវូបនីយកម្ម គឺកាលណារដ្ឋធម្មនុញ្ញត្រូវបានចារឹកនូវខ្លឹមសារទូលាយ ទៅលើការបង្កើតគណៈបក្សនយោបាយពីសមាសភាពពលរដ្ឋទូទៅ ។

**ខ.ស្ថាប័នភាវូបនីយកម្មគតិយុត្តិ** (Legal Institutionalization) : នេះគឺជាខ្លឹមសារនៃបក្សនយោបាយ ដែលបង្កើតមកស្របតាមច្បាប់មួយដែលត្រូវបានកំណត់ច្បាស់លាស់ ក្នុងបែបបទនៃការ

ធ្វើសមិទ្ធិនៃបទដ្ឋានទាំងឡាយរបស់រដ្ឋធម្មនុញ្ញ ។ នេះមានន័យថាវាជាលទ្ធផលដែល**ឋានៈគតិយុត្តិ**របស់បក្សត្រូវបានកំណត់ដោយច្បាប់ដោយឡែក១ ដូចជា**មាត្រា ៩** ច្បាប់គណៈបក្សនយោបាយកម្ពុជាបានកំណត់ថា "ប្រជាពលរដ្ឋខ្មែរចំនួនយ៉ាងតិច ៨០ នាក់ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិផ្តើមបង្កើតគណៈបក្សនយោបាយមួយបាន ដោយគ្រាន់តែជូនដំណឹងជាលាយល័ក្ខអក្សរទៅក្រសួងមហាផ្ទៃ ។ ក្រសួងមហាផ្ទៃត្រូវឆ្លើយតបជាលាយល័ក្ខអក្សរ ថាបានទទួលសេចក្តីជូនដំណឹងនេះក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ ។ បើហួសការកំណត់ ១៥ ថ្ងៃនេះ ត្រូវចាត់ទុកថាបានទទួលសេចក្តីជូនដំណឹងនេះ ។

គណៈបក្សនយោបាយដែលទើបផ្តើមបង្កើត ត្រូវធ្វើការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការបណ្តោះអាសន្នដែលមានសមាជិកយ៉ាងតិច ៧ រូប ហើយដែលម្នាក់ៗមានអាយុយ៉ាងតិច ២៥ ឆ្នាំ សំរាប់រៀបចំបែបបទ និងបំពេញល័ក្ខខ័ណ្ឌនៃការសុំចុះបញ្ជីគណៈបក្សនយោបាយ តាមការកំណត់ដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះដើម្បីទទួលសុពលភាព ។ ទោះបីមិនទាន់ទទួលសុពលភាពក៏ដោយ ក្នុងរយៈពេលនេះគណៈបក្សនយោបាយអាចលើកផ្លាកនៅទីស្នាក់ការរបស់ខ្លួនបាន"។ គួរបញ្ជាក់ថា ក្នុងស្ថាប័នភាវូបនីយកម្មគតិយុត្តិវាធ្វើនិយត័កម្មគតិយុត្តិរបស់បក្សនយោបាយ នូវធាតុទាំងឡាយដូចជា :

ε₁. និយមន័យនៃបក្សនយោបាយកំណត់ទីតាំង និងតួនាទីបក្សក្នុងប្រព័ន្ធនយោបាយ និងក្នុងយន្តកម្មរដ្ឋ ។

ε₂. ល័ក្ខខ័ណ្ឌ និងសណ្តាប់ធ្នាប់នៃការបង្កើត និងបញ្ចប់នូវបក្សនយោបាយ ។

ε₃. តំរូវការចំពោះមនោគមវិជ្ជា និងកម្មវិធីច្បាស់លាស់របស់បក្ស ។

ε₄. តំរូវការនូវការបង្កើតអង្គការគ្រប់គ្រង និងសណ្តាប់ធ្នាប់នៃការងារ ។

ε₅. គ្រឹះសេដ្ឋកិច្ច-ហិរញ្ញវត្ថុរបស់បក្ស ។

ε₆.ទំនាក់ទំនងជាមួយអំណាចសាធារណៈជារួម គឺចូលរួមក្នុងការបោះឆ្នោតក្នុងកិច្ចការអង្គការរបស់រដ្ឋ និងអង្គការតំណាងស្វ័យគ្រប់គ្រងមូលដ្ឋាន ។

ដូចនេះក្នុងអត្ថន័យនៃ**ស្ថាប័នភាវូបនីយកម្មគតិយុត្តិ** គឺពឹងផ្អែកលើច្បាប់ដោយឡែក ដែលធ្វើនិយតកម្មលើការបង្កើតបក្សនយោបាយនោះ ។ **មាត្រា ២៣** នៃច្បាប់គណៈបក្សនយោបាយកំណត់ថា "ក្នុងករណីពិនិត្យឃើញថា សំណុំឯកសាររបស់គណៈបក្សនយោបាយណាមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណៈបក្សនយោបាយ និងច្បាប់នានាជាធរមានក្រសួងមហាផ្ទៃត្រូវធ្វើលិខិតឆ្លើយតបស្តីពីការយល់ព្រមឱ្យចុះបញ្ជី ផ្ញើជូនទៅសាមីគណៈបក្សនយោបាយនោះវិញ ដោយភ្ជាប់ជាមួយនូវលក្ខន្តិកៈមួយច្បាប់ ដែលមានចារបញ្ជាក់កាលបរិច្ឆេទនៃការចុះបញ្ជីគណបក្សនយោបាយ ដោយមានចុះហត្ថលេខា និងត្រារបស់ក្រសួងមហាផ្ទៃ"។ និង**មាត្រា ២៨** "រដ្ឋអាចផ្តល់ប្រាក់ពីថវិកាជាតិស្មើៗគ្នាដល់គ្រប់គណៈបក្សនយោបាយ សំរាប់តែប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

គណៈបក្សនយោបាយណាដែលមិនបានទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៣% នៃសន្លឹកឆ្នោតបានការសរុបទូទាំងប្រទេស ឬមិនបានទទួលអាសនៈមួយក្នុងសភា គណៈបក្សនយោបាយនោះត្រូវសងប្រាក់នោះគ្រប់ចំនួនមករដ្ឋវិញក្នុងរយៈពេល ៣ ខែយ៉ាងយូរចាប់ពីថ្ងៃប្រកាសលទ្ធផលជាស្ថាពរនៃការបោះឆ្នោត"។ **មាត្រា ២៩** "គណៈបក្សនយោបាយត្រូវបានហាមឃាត់មិនឱ្យទទួលវិភាគទានទោះជាតាមរូបភាពណាក៏ដោយ ពីស្ថាប័នរដ្ឋ សមាគម អង្គការ ក្រៅរដ្ឋាភិបាល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ វិទ្យាស្ថានសាធារណៈ ឬក្រុមហ៊ុនបរទេសលើកលែងតែករណីដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ"។ **មាត្រា៣៣** "គណៈបក្សនយោបាយអាចរំលាយខ្លួន បន្ទាប់ពីបានធ្វើការជំរះបញ្ជី និងចាត់ចែងទ្រព្យសម្បត្តិរបស់គណៈបក្សនយោបាយ។ គណៈបក្សនយោបាយត្រូវជូនដំណឹងជាលាយល័ក្ខអក្សរពីការរំលាយនេះដល់ក្រសួងមហាផ្ទៃភ្លាម ដើម្បីលុបឈ្មោះគណៈបក្សនយោបាយនោះចេញពីបញ្ជីគណៈបក្សនយោបាយ"។ **មាត្រា ៣១** "គណៈបក្សនយោបាយដែលបានចុះបញ្ជីគណៈបក្សនយោបាយរួចហើយ ត្រូវធ្វើរបាយការណ៍មកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។ របាយការណ៍ត្រូវចុះហត្ថលេខាដោយប្រធានគណៈបក្សនយោបាយ និងហិរញ្ញិក ។

របាយការណ៍នេះត្រូវមានខ្លឹមសារ និងឯកសារដូចខាងក្រោម :

១- សកម្មភាពសំខាន់ៗរបស់គណៈបក្សនយោបាយ ។

២- តារាងតុល្យភាពដែលបង្ហាញនូវប្រាក់ចំណូល និងប្រាក់ចំណាយប្រចាំឆ្នាំតាមប្រភេទ។ តារាងតុល្យភាពនេះ ត្រូវរៀបចំឡើងដោយគណនេយ្យរបស់គណៈបក្សនយោបាយ ។

៣- បញ្ជីតុល្យការគណនីរបស់គណៈបក្សនយោបាយនៅក្នុងធនាគារ ។

៤- បញ្ជីតុល្យការនៃទ្រព្យសម្បត្តិទាំងអស់ រាប់បញ្ចូលទាំងទ្រព្យសម្បត្តិជាកម្មសិទ្ធិ ឬផល កំរៃក្នុងជំនួញ និងបំណុលរបស់គណៈបក្សនយោបាយ" ។ ជារួមបក្សនយោបាយដែលត្រូវបានកំណត់ ដោយច្បាប់មួយ នោះវាមានលក្ខណៈសម្បត្តិជាច្រើនដើម្បីគណៈបក្សនយោបាយគោរពតាម ។

## ៥. ប្រព័ន្ធបក្សនយោបាយ

នៅក្នុងប្រទេសដែលប្រកាន់របបប្រជាធិបតេយ្យ វាតែងតែបង្កើតឱ្យមានបក្សជាច្រើនដើម្បី ចូលរួមក្នុងការបោះឆ្នោតនានា ហើយដែលបក្សទាំងនោះមានទំនាក់ទំនងគ្នាយ៉ាងសាំញ៉ាំ ក្នុងក្រប ខ័ណ្ឌសង្គម ។

ដូចនេះប្រព័ន្ធបក្សនយោបាយ គឺជា**ស្ថាប័ននយោបាយ**មួយដែលវាបញ្ជាក់នូវអង្គការគ្រប់ គ្រងនយោបាយរបស់សង្គម និងជ្រុងមួយទៀត ស្ថាប័ននយោបាយនោះត្រូវកំណត់ទំនាក់ទំនងទាំង ឡាយរវាងបក្សទាំងអស់ និងរដ្ឋ រីឯជ្រុងផ្សេងទៀតត្រូវកំណត់**ទំនាក់ទំនងអញ្ញមញ្ញ**របស់បក្ស ជា មួយធាតុសង្គមផ្សេងៗនៃប្រព័ន្ធបក្ស និងពលរដ្ឋទាំងឡាយ ។ គួរបញ្ជាក់ថាប្រព័ន្ធបក្សវាផ្សារភ្ជាប់ ទៅនឹង**ប្រពៃណីជាតិជាប្រវត្តិសាស្ត្រ** ផ្សារភ្ជាប់នឹង**វិធី**ទាំងឡាយនៃអាទិភាពអំណាចគ្រប់គ្រង ។ ជាឧទាហរណ៍ នៅបណ្តាប្រទេសមួយចំនួនបក្សនយោបាយតាមផ្លូវច្បាប់ត្រូវបានហាមឃាត់ ដូចជា ប្រទេស***ស៊ូដានី សហភាពអារ៉ាប់អេមីរ៉ាត*..........** ។ល។ មានន័យថាគណៈបក្សមិនត្រូវបាន អនុញ្ញាតិឱ្យបង្កើតនៅក្នុងប្រទេសទាំងនោះឡើយ ។

ដោយយោងទៅលើគណៈបក្សនយោបាយនៃប្រទេសនីមួយៗ គេចែក**ប្រព័ន្ធនយោបាយ** តាមប្រភេទដូចខាងក្រោម :

**ក. ប្រព័ន្ធពហុបក្ស** : ប្រព័ន្ធនេះមានលក្ខណៈប្រលងប្រជែងយកអាសនៈនៅរដ្ឋសភា ដោយមានការចូលរួមពីគណៈបក្សជាច្រើន ។

ដូចនេះប្រព័ន្ធពហុបក្ស គឺជាការចូលរួមនៃបក្សនយោបាយជាច្រើននៅក្នុងប្រទេសមួយ នៅពេលដែលមានការតស៊ូដណ្តើមសន្លឹកឆ្នោតក្នុងការចាប់យកអំណាច និងបក្សនយោបាយទាំងនោះនឹងមានវាសនាចូលរួមបង្កើតរដ្ឋាភិបាល ។ ដូច**មាត្រា ៥១** នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់របស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។ រីឯ**មាត្រា ១៩៩** "តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភាព្រះមហាក្សត្រទ្រង់ចាត់តាំងវរជន ១ រូប ក្នុងចំណោមតំណាងរាស្ត្រគណៈបក្សដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬសមាជិកគណៈបក្សតំណាងនៅក្នុងរដ្ឋសភា ដែលត្រូវផ្តល់ឱ្យកាន់តំណែងផ្សេងៗនៅក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល" ។ តាមមាត្រានេះបញ្ជាក់ថា គណៈបក្សដែលមានសំលេងគាំទ្រក្នុងរដ្ឋសភា ដែលបានមកតាមរយៈការបោះឆ្នោតជាសកលមានសិទ្ធិចូលរួមបង្កើតរដ្ឋាភិបាលរបស់ប្រទេស ។ តាម**មាត្រា ២** ច្បាប់បោះឆ្នោតកម្ពុជាបានកំណត់ថា "ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវអនុវត្តតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស" ។ នៅក្នុងប្រព័ន្ធពហុបក្សវាមានលក្ខណៈផ្សេងៗគ្នា ដូចជានៅប្រទេស**អ៊ីតាលី ដាណឺម៉ាក ប៊ែលស៊ិក** គឺថាប្រទេសទាំងនោះជាធម្មតាច្រើនតែបង្កើតរដ្ឋាភិបាលចំរុះរបស់រដ្ឋគេ ។ ដូចនេះប្រព័ន្ធពហុបក្សអាចមាន :

**ក១. ប្រព័ន្ធពហុបក្សដែលបក្សមួយមានលក្ខណៈលប់** : លក្ខណៈរបៀបនេះដូចជាប្រព័ន្ធបក្សនៅប្រទេស**ជប៉ុន** (គណៈបក្សប្រជាធិបតេយ្យមានលក្ខណៈលប់) និងប្រទេស**ម៉ិកស៊ិក** (គណៈបក្សស្ថាប័នបដិវត្តមានលក្ខណៈខ្លាំងជាងគេ) ជាដើម ។ ប្រព័ន្ធបក្សក្នុងន័យនេះ គឺសំដៅក្នុងប្រទេសមួយ គណៈបក្សនយោបាយខ្លះមានលក្ខណៈ ឬឥទ្ធិពលលើគណៈបក្សដទៃទៀតក្នុងក្របខណ្ឌនៃការគាំទ្រ តាមរយៈ**សំលេងប្រជាពលរដ្ឋ** ។

**ក២. ប្រព័ន្ធពហុបក្សដែលមានលក្ខណៈជាប្លុក** : នេះគឺជាការចូលរួមបង្កើតជាក្រុមបក្សនយោបាយ ដើម្បីផ្តុំគ្នានៅក្នុងប្លុកតែមួយ ។ លក្ខណៈរបៀបនេះកើតមាននៅប្រទេសបារាំង ចាប់ពីទសវត្ស ៦០ ។ ប្រព័ន្ធបក្សរបៀបនេះ គឺប្រមូលផ្តុំបក្សជាច្រើនឱ្យស្ថិតក្នុងប្លុកផ្សេងៗគ្នា ក្នុងគោលដៅដណ្តើមយកសំលេងគាំទ្រ ។

**ខ.ប្រព័ន្ធនៃចំនួនបក្សដែលចារឹកដោយច្បាប់មួយ** : ប្រព័ន្ធរបៀបនេះច្រើនកើតមានចំពោះប្រទេសកំពុងអភិវឌ្ឍន៍ តែវាជាការវិនិច្ឆ័យមួយដែលមានលក្ខណៈ**បណ្តោះអាសន្ន** និង**អន្តរកាលតែប៉ុណ្ណោះ** ។ គេបង្កើតវាដើម្បីប្រមូលផ្តុំកំលាំងនយោបាយ ក្នុងគោលដៅប្រឆាំងនឹងគណៈបក្សនយោបាយផ្សេងៗទៀត ដែលបង្កើតមកមិនសមតាមបំណងរបស់គណៈបក្សពួកគេ ។

លក្ខណៈរបៀបនេះ វាជា**ប្រព័ន្ធទ្វេភាគីបក្សសិប្បនិម្មិត**មួយ ដែលបានកើតមាននៅឆ្នាំ ១៩៦៦-១៩៧៩ នៅប្រទេស**ប្រេស៊ីល** និង**ប្រព័ន្ធត្រីភាគីបក្សសិប្បនិម្មិត**នៅឆ្នាំ ១៩៧៦-១៩៩០ របស់ប្រទេស**សេណេហ្គាល់** ។ រីឯប្រព័ន្ធទ្វេភាគីសំរាប់ប្រទេសកម្ពុជាកកើតមានដែរ នូវលក្ខណៈទ្វេ ឬត្រីភាគីបក្សសិប្បនិម្មិតនេះក្នុងឆ្នាំ ១៩៩៧-៩៨ ។

**គ.ប្រព័ន្ធទ្វេភាគីបក្ស** : វាជាវត្តមាននូវពហុបក្សដែរ ប៉ុន្តែក្នុងនោះវាមានទំនោរទៅរកអំណាច និងបង្កើតនូវរដ្ឋាភិបាលមួយដោយធ្វើឡើងតែគណៈបក្សពីរ ក្នុងចំណោមបក្សដែលមាននោះ ។សំរាប់ប្រទេសកម្ពុជា បានកំណត់ប្រព័ន្ធនេះក្នុងច្បាប់គណៈបក្សនយោបាយឆ្នាំ ១៩៩៧ តាម**មាត្រា ៣៦** ថា "គណៈបក្សនយោបាយអាចប្រកាសរួមបញ្ចូលគ្នា ជាមួយគណៈបក្សនយោបាយផ្សេងទៀត បាន

តាមការកំណត់របស់លក្ខន្តិកៈ ។ ក្នុងករណីដែលលក្ខន្តិកៈមិនបានចែង ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាតគណៈបក្សនយោបាយ ។

ក្រសួងមហាផ្ទៃត្រូវលុបឈ្មោះគណៈបក្សនយោបាយ ដែលបានប្រកាសរួមបញ្ចូលគ្នានោះចេញពីបញ្ជីគណៈបក្សនយោបាយ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីការរួមបញ្ចូលនោះ"។ និង **មាត្រា ៣៧** "គណៈបក្សនយោបាយ**អាចធ្វើសម្ព័ន្ធភាពទ្វេភាគី ឬពហុភាគីជាមួយគ្នាបានដោយសេរី** តាមសេចក្តីសំរេចរបស់គណៈបក្សនយោបាយនីមួយៗ"។

ដូចនេះប្រព័ន្ធនយោបាយនៃប្រទេសនីមួយៗ និម្មិតឡើងមានលក្ខណៈផ្សេងៗគ្នាក្នុងក្របខណ្ឌនៃទំនាក់ទំនងរបស់បក្សនយោបាយទាំងនោះដែលជាអាទិភាព ។

**អត្ថបទទី ១២**

# អត្ថន័យនៃទំរង់គ្រប់គ្រង និងរបបរដ្ឋ

## ១. និយមន័យនៃទំរង់គ្រប់គ្រង

ទំរង់គ្រប់គ្រងគឺជាប្រព័ន្ធនៃនិម្មិតកម្ម (ការបង្កើត) និងទំនាក់ទំនងគ្នាទៅវិញទៅមករបស់ប្រមុខរដ្ឋ របស់អង្គការរដ្ឋជាន់ខ្ពស់ទាំងអស់នៃអំណាចនីតិបញ្ញតិ និងអំណាចនីតិប្រតិបត្តិ ។ ទំរង់គ្រប់គ្រង វាគ្របដណ្តប់ជាប្រវត្តិសាស្រ្តទៅលើដំណើរវិវត្តន៍នៃការតស៊ូ និងសហប្រតិបត្តិការទៅវិញទៅមករបស់កំលាំងនយោបាយ និងសង្គមដោយសមស្របតាមប្រភេទនៃសង្គមសាធារណៈ ។ ទំរង់គ្រប់គ្រងនេះ វាជាអត្ថន័យគ្រឹះសំរាប់ធ្វើការសិក្សាទៅលើនិយ័តកម្មធម្មនុញ្ញគតិយុត្តិ ដូចជា**មុខងារគ្រប់គ្រងរដ្ឋ និងអង្គការគ្រប់គ្រងរដ្ឋ** ។ ទាំងនេះពុំមែនជាបញ្ហាអរូបីយនោះទេ តែវាជាវិទ្យាសាស្រ្តនៃទ្រឹស្តីមួយគឺអធិបតេយ្យភាព និងលទ្ធិប្រជាធិបតេយ្យដែលគេបានចារិកក្នុងរដ្ឋធម្មនុញ្ញ ដើម្បីកំណត់នូវប្រព័ន្ធអង្គការនៃអំណាចរដ្ឋរបស់រដ្ឋនីមួយៗ ។ ក្នុងអត្ថន័យនេះ ដូចជាវាក្យខ័ណ្ឌទីបី **មាត្រា ៥១** រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់ថា " អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញតិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។ និងវាក្យខ័ណ្ឌទី ១ នៃ**មាត្រាទី ៩០** បានកំណត់ថា "រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ............." ។ រីឯ**មាត្រា ១២១** បានកំណត់ថា "សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួន ចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្តិ" ។ រីឯ**មាត្រា ១៣០** បានកំណត់ថា "គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ" ។ និង**មាត្រា ៩៩** បានកំណត់ថា "ព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ......." ។

## ២. ចំណាត់ថ្នាក់នៃទំរង់គ្រប់គ្រងរដ្ឋ

ចំណាត់ថ្នាក់នៃទំរង់គ្រប់គ្រង **គឺជាការកំណត់នូវសណ្ដាប់ធ្នាប់មួយនៃមុខងារប្រមុខរដ្ឋ** ។ ដោយយោងទៅលើការគ្រប់គ្រងរដ្ឋនីមួយៗ ដែលគេបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ជាទូទៅចំណាត់ថ្នាក់នៃទំរង់គ្រប់គ្រងមានទំរង់គ្រឹះពីរសំខាន់ៗ គឺទំរង់គ្រប់គ្រងបែបរាជាធិបតេយ្យ និងបែបសាធារណៈរដ្ឋ ( ពតិមានពិស្ដារក្នុងចំណុច ៤ និង ៥ ) ភាពខុសគ្នានៃសាធារណរដ្ឋ និងរាជាធិបតេយ្យត្រូវបានកំណត់ដោយទំនាក់ទំនងមួយនៃសិទ្ធិអំណាចរបស់អំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិដែលត្រូវបានបែងចែករវាងប្រមុខរដ្ឋ, រដ្ឋសភា និងរដ្ឋាភិបាល ។ អស់រយៈពេលជាច្រើនមកហើយការវិវត្តន៍នៃសង្គមតាមលក្ខណៈរាជាធិបតេយ្យ ដែលប្រកាន់នូវវណ្ណៈសក្តិភូមិនោះត្រូវបានធ្វើបដិវត្តបំផ្លាញចោល ដើម្បីបង្កើតនូវទំរង់គ្រប់គ្រងបែបសាធារណរដ្ឋ ។ ប៉ុន្តែនៅប្រទេសខ្លះបានរលាយបាត់របបរាជា ហើយក៏បង្កើតរបបសាធារណរដ្ឋ ហើយបន្ទាប់មកលុបរបបសាធារណរដ្ឋធ្វើជារបបរាជាធិបតេយ្យវិញដោយអាស្រ័យនឹងអន្តរកាលវែង ឬខ្លី នៃការគ្រប់គ្រងបែបសាធារណរដ្ឋ ។ ដូចជានៅប្រទេសអេស្ប៉ាញ រាជាធិបតេយ្យបានត្រូវផ្តួលរំលំនៅឆ្នាំ ១៩៣១ រីឯនៅឆ្នាំ ១៩៤៧ របបផ្តាច់ការហ្វាស៊ីសហ្វ.ហ្វ្រង់កូ បានដឹកនាំបែបសាធារណរដ្ឋ ប៉ុន្តែពេលមួយនោះស្តេចហួន.ការលូស ទី I បានឡើងសោយរាជ្យបន្ទាប់ពីមរណៈភាពរបស់ហ្វ.ហ្វ្រង់កូ នាឆ្នាំ ១៩៧៥ ហើយនៅឆ្នាំ ១៩៧៨ ក៏លទ្ធិប្រជាធិបតេយ្យចាប់ផ្តើមការពារយ៉ាងសកម្មប្រឆាំងលើពួកហ្វាស៊ីស ។ នៅប្រទេសកម្ពុជា របបរាជាធិបតេយ្យបានរំលាយក្នុងឆ្នាំ ១៩៧០ ហើយក៏ដឹកនាំប្រទេសតាមបែបសាធារណរដ្ឋ ។ ក្រោយពីរបបនយោបាយ ៣ ជំនាន់នៃការគ្រប់គ្រងបែបសាធារណរដ្ឋ ( របបសាធារណរដ្ឋខ្មែរ, របបកម្ពុជាប្រជាធិបតេយ្យ និងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ) បានត្រូវរំលាយហើយក៏បង្កើតជារបបរាជាធិបតេយ្យជាលើកទីពីរឡើងវិញ នៅឆ្នាំ ១៩៩៣ បន្ទាប់ពីមានការបោះឆ្នោតជាសកលទូទាំងប្រទេស ក្រោមការត្រួតពិនិត្យរបស់អ៊ុនតាក់ ( អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិ ) ។ ប៉ុន្តែលើសពីនេះទៅទៀតនោះ, បច្ចុប្បន្ននេះគេបានកំណត់នូវទំរង់គ្រប់គ្រងរដ្ឋក្នុងប្រទេសនីមួយៗមានលក្ខណៈប្លែកៗ ដោយពុំឈរលើគោលការណ៍ណាមួយច្បាស់លាស់ទេ ។ ជាក់ស្តែងដូចជានៅ

ប្រទេសម៉ាឡេស៊ី បច្ចុប្បន្ននេះតើគេអាចកំណត់ទំរង់គ្រប់គ្រងរដ្ឋតាមបែបសាធារណរដ្ឋ ឬក៏បែបរាជាធិបតេយ្យ ? គឺថាចំណែកខ្លះនៃសមាជិកសហព័ន្ធប្រកាន់យកទំរង់គ្រប់គ្រងបែបរាជានិយម ឯចំណែកខ្លះទៀតនៃសមាជិកសហព័ន្ធប្រកាន់យកបែបសាធារណរដ្ឋ ។ ក្នុងនោះប្រមុខរដ្ឋសហព័ន្ធតំណាងអភិបាលកំពូល ដែលគេហៅឈ្មោះរបស់វាជាភាសាម៉ាឡេថា យ៉ាន់ឌី-ប៉េរ-តួនអាហ្គុញ មានន័យថាស្តេចជាប្រមុខរដ្ឋ ដែលត្រូវបានជ្រើសរើសដោយស្តេចទាំងអស់ (រដ្ឋដែលជាសមាជិកសហព័ន្ធដឹកនាំបែបរាជានិយម) ដែលជាសមាជិកសហព័ន្ធក្នុងអណត្តិពេល ៥ ឆ្នាំ លក្ខណៈនេះប្រហាក់ប្រហែលនឹងសហរដ្ឋអារ៉ាប់ អេមីរ៉ាត ដែរ ។ ព្រោះថាប្រមុខរដ្ឋបែបរាជាធិបតេយ្យត្រូវតែជាស្តេច ។ ប៉ុន្តែដោយយោងលើលក្ខណៈទាំងនេះគេអាចនិយាយថា វាជារដ្ឋដែលគ្រប់គ្រងតាមរាជាធិបតេយ្យក្នុងលក្ខណៈជ្រើសរើស ឬរាជាធិបយេត្យជ្រើសរើស ។ រីឯប្រទេសកម្ពុជាវិញ ក្រោយពីបាត់បង់នូវរបបរាជាធិបតេយ្យនាទសវត្ស ៧០ ហើយរបបសាធារណរដ្ឋក៏បានដឹកនាំប្រទេសរហូតដល់ឆ្នាំ ១៩៩៣ ទើបមានរបបរាជាធិបតេយ្យ មាននវត្តមានជាលើកទី ២ ដោយមានការបោះឆ្នោតជាសកលក្រោមកិច្ចចាត់ចែងដោយអង្គការសហប្រជាជាតិ ឆ្នាំ ១៩៩៣ ។ ហើយដោយយោងលើរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានកំណត់ប្រមុខរដ្ឋត្រូវតែជាស្តេច ឯស្តេចត្រូវជ្រើសតាំងតាមទំរង់មួយនៃអំបូរស្តេចដូច**មាត្រា ១៤** វាក្យខ័ណ្ឌទីមួយបានកំណត់ថា "ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះវង្សានុវង្សខ្មែរ ដែលមានព្រះជន្មាយុយ៉ាងតិច ៣០ ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ អង្គដួង ឬព្រះមហាក្សត្រនរោត្តម ឬក៏ព្រះមហាក្សត្រស៊ីសុវត្ថិ ......" ។ រីឯការជ្រើសរើសពុំអាចធ្វើតាមចំណង់របស់ព្រះមហាក្សត្រឡើយ ដូច**មាត្រា ១០** បានកំណត់ថា "របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។ ព្រះមហាក្សត្រទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទសម្រាប់គ្រងរាជសម្បត្តិឡើយ....." ។ តែការជ្រើសរើសនោះធ្វើឡើងដោយក្រុមប្រឹក្សារាជសម្បត្តិ ដែល**មាត្រា ១៣** បានសរសេរថា "ក្នុងរយៈវេលាប្រាំពីរថ្ងៃយ៉ាងយូរព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិរួមមាន :

- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្តេចព្រះសង្ឃរាជគណមហានិកាយ និងគណៈធម្មយុត្តិកនិកាយ
- អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃព្រឹទ្ធសភា
- អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃរដ្ឋសភា

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ នឹងមានកំណត់ក្នុងច្បាប់មួយ" ។ ចំពោះអាណត្តិរបស់ប្រមុខរដ្ឋគឺមួយជីវិត ដូច**មាត្រា ៧** បានកំណត់ស្រាប់ "ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រមិនអាចរំលោភបំពានបានឡើយ" ។

## ៣. ទំរង់ការរដ្ឋ ឬរបបរដ្ឋ

របបរដ្ឋវាជាទ្រង់ទ្រាយគ្រប់គ្រងមួយ ដែលនាំមកនូវគំរូគតិយុត្តិនៃទំរង់ទាំងឡាយ រវាងអង្គការរដ្ឋកំពូលៗ ។ តថភាពរបស់របបរដ្ឋ គឺជាសណ្តាប់ធ្នាប់នៃមុខងារគ្រប់គ្រង និងអន្តរសកម្ម (Interaction) ដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់គ្រឹះ ។ ក្នុងលក្ខណៈរបៀបនេះ ប្រទេសខ្លះមានគំរូរដ្ឋធម្មនុញ្ញរបៀបនេះ ឬនោះ ដែលអាចមានប្រទេសដ៏ទៃទៀតយកជាគំរូ ឬក៏គេចចេញបើសិនមានបញ្ហាតាមគំរូរបៀបនោះ ។ របបរដ្ឋ គឺវាមានអត្ថន័យស្របនឹងរបបនយោបាយនៃរដ្ឋនិមួយៗ ហើយដែលអ្នកនឹងយល់ដឹងតាមចំណុចទី ៤ និងទី ៥ ។ ប៉ុន្តែជាទូទៅរបបរដ្ឋវាអាស្រ័យទៅនឹងរបបនយោបាយពីរ គឺអប្រជាធិបតេយ្យ និងប្រជាធិបតេយ្យ ដូចដែលបានបញ្ជាក់ក្នុងអត្ថបទស្តីពីរដ្ឋរួចហើយ ។

## ៤. រាជាធិបតេយ្យ (Monarchy)

**ក. អត្ថន័យរាជាធិបតេយ្យ** : ពាក្យថារាជាធិបតេយ្យចេញពីពាក្យក្រិចថា "Monarchia" មានន័យថា "អំណាចតែមួយ" គឺមានន័យទូលាយតាមទំរង់គ្រប់គ្រងរដ្ឋថា "**អំណាចកំពូលរដ្ឋប្រមូលផ្តុំក្នុងដៃនៃប្រមុខរដ្ឋម្នាក់តែប៉ុណ្ណោះ គឺក្នុងដៃព្រះរាជា** ឬក៏ផ្តល់ជូនទៅឱ្យអ្នកស្នងរាជតាមវង្សត្រកូល ។ ដូចនេះពាក្យថា "Monarchia" មកពី "Mono" ប្រែថាមួយ រីឯ "Archia" ប្រែថាអំណាច ។ (**មើលរូបទី ៩**)

ដោយសារស្ថាប័នរាជាធិបតេយ្យដែលកើតមានក្នុងសម័យរ៉ូម និងរហូតមកដល់បច្ចុប្បន្ននេះ វាចង់រក្សានូវរបបរបស់ខ្លួន ដែលធ្វើឱ្យរបបរាជាធិបតេយ្យនេះមានទំរង់ផ្សេងៗគ្នាជាច្រើន ដោយអាស្រ័យនឹងការវិវត្តន៍នៃសង្គម ជាពិសេសផ្នែកសេដ្ឋកិច្ច, នយោបាយ ។ល។ ជាពិសេសទៀតនោះមានការប្រែប្រួលយ៉ាងខ្លាំង ចាប់ពីក្រោយសង្គ្រាមលោកលើកទីពីរ ។ ទាំងនេះគេសង្កេតឃើញជាទូទៅ ទំរង់គ្រប់គ្រងបែបរាជាធិបតេយ្យមានលក្ខណៈរាជាធិបតេយ្យដាច់ខាត និងរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដែលក្នុងរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ឬរាជាធិបតេយ្យក៏រឹតនេះមានពីរប្រភេទទៀត គឺរាជាធិបតេយ្យទិកភាព និងរាជាធិបតេយ្យបែបសភា ។ ប៉ុន្តែទោះជារបបរាជាធិបតេយ្យមានច្រើនប្រភេទក៏ដោយ វាក៏ជាហេតុផលមួយនៃការបញ្ជាក់នូវឥទ្ធិពលនៃលទ្ធិប្រជាធិបតេយ្យ ដែលគេបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសរបស់គេរៀងៗខ្លួន ដូចជា**មាត្រា ៧** វាក្យខ័ណ្ឌមួយ រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់ថា "ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ"។ និងវាក្យខ័ណ្ឌទី ៣ បានកំណត់ទៀតថា "អង្គព្រះមហាក្សត្រមិនអាចរំលោភបំពានបានឡើយ"។ រីឯវាក្យខ័ណ្ឌទី ១ **មាត្រា ៨** បានកំណត់ថា "ព្រះមហាក្សត្រព្រះអង្គជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តភាពជាតិ"។ ក្នុងមាត្រានេះវាហាក់ដូចជាមានលក្ខណៈប្រហែលនឹង**មាត្រាទី ១** នៃរដ្ឋធម្មនុញ្ញជប៉ុន ឆ្នាំ ១៩៤៦ កំណត់ថា "រាជាធិរាជ ឬអធិរាជ (Emperor) ជានិមិត្តរូបនៃរដ្ឋ និងឯកភាពជាតិ, ឋានៈរបស់គាត់ត្រូវកំណត់ដោយឆន្ទៈប្រជាជនដែលបានផ្ទុកផ្តាក់នូវអំណាចឯករាជ្យ"។ ដូចនេះ ដើម្បីយល់ដឹងនូវលក្ខណៈខុសគ្នានៃរបបរាជាធិប

គេយ៉ សិក្សាតាមប្រភេទផ្សេងៗរបស់វាក្នុងការកំនត់តួនាទី និងមុខងាររបស់ប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល ដែលប្រទេសខ្លះប្រកាន់ពីអតីតៈរហូតដល់បច្ចុប្បន្ននេះ ។

**៩. រាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ឬរាជាធិបតេយ្យកំរិត** : គឺជាទំរង់គ្រប់គ្រងរដ្ឋមួយដែលប្រមុខរដ្ឋដឹកនាំប្រទេសដោយស្តេច ហើយដែលសកម្មភាពនៃស្តេចជាប្រមុខនោះត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ ។ រាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនេះមានពីរប្រភេទ គឺរាជាធិបតេយ្យទ្វិកភាព និងរាជាធិបតេយ្យអាស្រ័យសភា ។

**៩.១. រាជាធិបតេយ្យទ្វិកភាព ឬរាជានិយម** : វាជាទំរង់ដំបូងក្នុងការកំរិតអំណាចរបស់ស្តេចដែរដែលមានចរិកក្នុងរដ្ឋធម្មនុញ្ញ គឺវាមានការបែងចែកអំណាចនីតិបញ្ញត្តិចេញពីអំណាចនីតិប្រតិបត្តិ ។ គេសង្កេតឃើញថាអំណាចនីតិបញ្ញត្តិត្រូវប្រគល់ឱ្យរដ្ឋសភា ក្នុងគោលការណ៍ដែលសភានេះបោះឆ្នោតដោយរាស្ត្រ ឬផ្នែកកំណត់ណាមួយ (សមាជិក) របស់រដ្ឋនោះ ។ រីឯអំណាចនីតិប្រតិបត្តិប្រគល់ឱ្យទៅព្រះរាជា ដែលអាចបំពេញកិច្ចការរដ្ឋាភិបាលរបស់អំណាចនោះដោយផ្ទាល់ ឬក៏តាមការចាត់តាំងដោយស្តេច ។ ប៉ុន្តែក្នុងទំរង់របៀបនេះគេអាចនិយាយថាជាទំរង់រាជានិយម ពីព្រោះស្តេចមានសិទ្ធិអំណាចច្រើនជាងគេ ដូចគ្នានឹងប្រមុខរដ្ឋក្នុងទំរង់បែបប្រធានាធិបតីនិយមដែរ ។ ដូចនេះ ទំរង់រាជាធិបតេយ្យទ្វិកភាព គឺជាទំរង់ដែលប្រមុខរដ្ឋជាស្តេចដើរតួជាប្រមុខរដ្ឋផង និងជាប្រមុខរដ្ឋាភិបាលផង ហើយជាពិសេសនោះប្រមុខរដ្ឋមានសិទ្ធិរំលាយសភាជាន់ទាប ឬសិទ្ធិ Véto ទៅលើសេចក្តីសំរេចរបស់សភា ។

ក្នុងទំរង់របៀបនេះ ជួនកាលស្តេចជានិច្ចកាលប្រើប្រាស់សិទ្ធវេតូដាច់ខាត(Absolute Véto) ចំពោះច្បាប់ទាំងឡាយដែលអនុម័តដោយសភា គឺថាគាត់មិនប្រគល់ឱ្យប្រើប្រាស់ ឬមិនយល់ព្រមទៅលើច្បាប់នោះឱ្យចូលជាធរមាន (ពាក្យ Véto ជាពាក្យឡាតាំងមានន័យថា ឃាត់ ឃាំង, ជំទាស់, បដិសេធន៍) ។ លើសពីនេះទៀតនោះ ព្រះរាជាជាទំលាប់បង្កើតនូវក្រឹត្យវិសាមញ្ញទាំងឡាយ ដែលជាសុពលភាពផ្លូវច្បាប់ខ្ពស់ (កំលាំងគតិយុត្តិខ្ពស់) និងពិសេសទៀតនោះ **បើទំរង់រាជាធិបតេយ្យនិយមស្តេចអាចរំលាយសភាចោល នោះធាតុពិតនៃរបបរាជាធិបតេយ្យទ្វិកភាពអាស្រ័យរដ្ឋធម្មនុញ្ញនេះវាជារាជាធិបតេយ្យដាច់ខាតទៅវិញ** ។ ជាឧទាហរណ៍ ដូចជាប្រទេសហ្សកដាន

(Jordan) បន្ទាប់ពីរំលាយសភានៅឆ្នាំ ១៩៧៥ (រាជាធិបតេយ្យដាច់ខាត) ហើយបោះឆ្នោតសភាបន្តបន្ទាប់ឡើងវិញ រហូតដល់ឆ្នាំ ១៩៨៩ ក្លាយជារាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ។ ចំពោះរដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះព្រះរាជា ពុំមែនចំពោះសភាទេ ។

**ខ២. រាជាធិបតេយ្យបែបសភា** (Parliamentarian Monarchy) : នេះគឺជាទំរង់គ្រប់គ្រងមួយដែលមានអាទិភាពនៅក្នុងរដ្ឋជឿនលឿន ដោយក្នុងនោះជាប្រទេសដែលបានឆ្លងផុតពីរបបគ្រប់គ្រងបែបកសិកម្មកឹតទាប ឆ្ពោះទៅកាន់ឧស្សាហកម្មធុនធ្ងន់ ។ ការប្រកបយករបបនេះ ដូចជាប្រទេសកាណាដា, អូស្ត្រាលី, ជប៉ុន, ដាណឺម៉ាក, ចក្រភពអង់គ្លេស, ហូឡង់ ។ល។ របបនេះប្រកាន់យកគោលការណ៍ "**បរមានុភាពនៃសភា**" (Supremacy of Parliament) ចំពោះអំណាចនីតិប្រតិបត្តិ គឺសំដៅយកសភាជាអំណាចកំពូលខ្ពស់ជាងអំណាចផ្សេងៗ។ បរមានុភាព (ភាពខ្ពស់បំផុត) នៃសភានេះ វាសំដែងចេញត្រង់ថារដ្ឋាភិបាលជានិច្ចកាលចាត់តាំងដោយព្រះរាជា ដែលត្រូវតែទទួលសេចក្ដីទុកចិត្តពីរដ្ឋសភា (សភាតំណាងរាស្ត្រ) ។ តាមលក្ខណៈនេះ ដូចជា**មាត្រា ១១៩** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "តាមសេចក្ដីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណៈបក្សដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះនាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណៈបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្ដូវផ្ដងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។

មុនចូលកាន់តំណែងគណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៦" ។ ក្នុងទំរង់បែបនេះព្រះរាជាគ្រងតែរាជសម្បត្តិ ប៉ុន្តែមិនគ្រប់គ្រងអំណាចទេ ដូច**មាត្រាទី ៧** នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រមិនអាចទរណារំលោភបានឡើយ" ។ រីឯសិទ្ធិវីតូរបស់ព្រះរាជាក្នុងទំនាក់ទំនងច្បាប់ទាំងឡាយត្រូវផ្ទុកផ្ដាក់ទៅសភា ។ គឺថាការប្រឆាំងរបស់ស្ដេចទៅលើច្បាប់ទាំងឡាយមិនអាចធ្វើទៅកើតដោយឯកឯងបានឡើយ គឺត្រូវផ្អែកលើមតិរបស់សភា ដូចជា**មាត្រា ២៦** នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្ដលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្ដរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា"។ ព្រោះថាព្រះមហាក្សត្រធ្វើសកម្មភាពតាមច្បាប់កំពូល ដូច**មាត្រា ១** បានកំណត់ថា "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស.........."។

សញ្ញាណពិសេសមួយទៀតនៃរបបរាជានិយមអាស្រ័យសភា គឺការទទួលខុសត្រូវផ្អែកនយោបាយរបស់រដ្ឋាភិបាល ចំពោះសភាតំណាងរាស្ដ្រនូវសកម្មភាពរបស់ខ្លួន ដូច**មាត្រា ១២១** បានកំណត់ថា "សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូប១នៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភា អំពីការដែលខ្លួនបានប្រព្រឹត្ដ"។ ក្នុងករណីខ្លះទៀត បើសិនជាសភាតំណាងរាស្ដ្រមិនទុកចិត្ដរដ្ឋាភិបាល ដោយសារសកម្មភាពរបស់រដ្ឋាភិបាលមានលក្ខណៈខុសឆ្គង នោះអាចបោះឆ្នោតទំលាក់បាន ដូច**មាត្រា ១២៦** បានកំណត់ថា "សមាជិកមួយរូប១នៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមដែលខ្លួនបានប្រព្រឹត្ដក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះ និងក្នុងករណីធ្វើខុសជាទម្ងន់ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្ដឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសំរេចក្នុងរឿងនេះដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល"។ រីឯ**មាត្រា ៩៨** កំណត់ថា "រដ្ឋសភាអាចទំលាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទំលាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោសតាមសម្លេងឆ្នោត ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន" ។ ប៉ុន្តែនៅពេលខ្លះទំនាស់អាចកើតមានរវាងអង្គការនីតិបញ្ញត្តិ និងអង្គការនីតិប្រតិបត្តិ នោះត្រូវផ្ទុកផ្ដាក់ទៅព្រះមហាក្សត្រជាអ្នកសំរេច ក្នុងល័ក្ខខ័ណ្ឌនៃការព្រមព្រៀងពីស្ថាប័នទាំងពីរ ដូច **មាត្រា ៧៨** បានកំណត់ថា "នីតិកាលរបស់រដ្ឋសភា មានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទំលាក់ពីរដងក្នុងរយៈពេល ១២ ខែ ។

ក្នុងករណីនេះព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។

ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មីនឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ ថ្ងៃយ៉ាងយូរចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក ។

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានភារកិច្ចដឹងនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដ៏ទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើររបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសំរេចដោយមតិយល់ព្រមពីភាគបីយ៉ាងតិច នៃចំនួនសមាជិករដ្ឋសភាទាំងមូល" ។ គួរចំណាំថារាល់ទំនាស់រវាងអង្គការរដ្ឋកំពូល១ ( អង្គការនីតិបញ្ញត្តិ និងអង្គការនីតិប្រតិបត្តិ) ត្រូវតែដោះស្រាយតាមរយៈប្រជាជន ( អាចធ្វើតាមរយៈប្រជាមតិ) ។

**ឥ. រាជាធិបតេយ្យដាច់ខាត** (Absolute Monarchy) : ជាទំរង់រដ្ឋដែលប្រមុខរដ្ឋជាស្ដេចពុំមានកំនត់ច្បាស់ទៅលើសកម្មភាពរបស់គាត់ឡើយ ។ រាជាធិបតេយ្យដាច់ខាត សំរាប់ប្រទេសដែលប្រកាន់របបអាជ្ញានិយមតែប៉ុណ្ណោះ ប៉ុន្តែសំរាប់រាជាធិបតេយ្យទុកដដែល វាជាទំរង់ដំបូងបំផុតដែលឈានទៅរកទំរង់រាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញពិតប្រាកដ **ទោះជាវាស្ថិតនៅក្នុងអន្តរកាល**

**នៃរាជាធិបតេយ្យផ្តាច់ខាតក៏ដោយ** ។ នៅក្នុងទំរង់នេះ អំណាចរបស់ស្តេចពុំត្រូវបានកំរិតដោយច្បាប់ទេ គឺមានន័យថាអំណាចទាំងបីជារបស់ស្តេច ដូចជាសហភាពអារ៉ាប់ ជាដើម ។

ដូចនេះទំរង់រាជាធិបតេយ្យដាច់ខាត កើតមានសំរាប់ប្រទេសដែលប្រកាន់យករបបនយោបាយបែបអាជ្ញានិយម ( យកអំណាចជាធំ ) ឬរបបនយោបាយមានលក្ខណៈអប្រជាធិបតេយ្យ ។

**៥. សាធារណរដ្ឋ** ( Republic )

**ក. អត្ថន័យនៃសាធារណរដ្ឋ** : ពាក្យថាសាធារណៈរដ្ឋចេញពីឡាតាំងថា “Respublica” មានន័យថាកិច្ចការសង្គម ឬកិច្ចការសាធារណៈ ។ (**មើលរូបទី ៩**)

ដូចនេះទំរង់គ្រប់គ្រងបែបសាធារណរដ្ឋ គឺជាទំរង់គ្រប់គ្រង់មួយ ដែលទំរង់នេះបង្ហាញនូវលក្ខណៈជំរើសប្រមុខរដ្ឋ ដែលជានិច្ចកាលគេហៅថាប្រធានាធិបតី ។ ពាក្យថាប្រធានាធិបតីចេញពីពាក្យឡាតាំងថា “Praesidens” មានន័យថា "**អ្នកដែលអង្គុយពីមុខ**" ។ ទោះជារបបគ្រប់គ្រងបែបសាធារណៈរដ្ឋនេះកើតមកក្រោយរបបរាជាធិបយេត្យហើយក៏ដោយ ក៏ទំរង់នោះពុំមានលក្ខណៈដូចគ្នានោះទេ ។ ដោយយោងទៅលើមុខងារគ្រប់គ្រងរដ្ឋបែបទំរង់សាធារណៈរដ្ឋនេះ គេសង្កេតឃើញថាមានច្រើនប្រភេទដែលកំពុងកើតមានពីអតីតមកដល់បច្ចុប្បន្ននេះ ។

ប្រភេទទាំងនេះមាន : សាធារណរដ្ឋទ្វិកភាព ( ប្រធានាធិបតីនិយម ), សាធារណរដ្ឋបែបសភា, សាធារណរដ្ឋបែបចំរុះ ឬពាក់កណ្តាលប្រធានាធិបតី និងប្រភេទផ្សេងទៀត ។

**ខ. សាធារណរដ្ឋទ្វិកភាព ឬប្រធានាធិបតីនិយម** : ទិសដៅសំខាន់គឺការកំណត់លើមុខងារប្រមុខរដ្ឋ ។ ទំរង់គ្រប់គ្រងសាធារណបែបប្រធានាធិបតីនិយម គួររំលឹកដល់ទំរង់គ្រប់គ្រងរាជាធិបតេយ្យបែបទ្វិកភាព គឺថាបើប្រទេសដែលមានប្រមុខរដ្ឋជាស្តេច ហើយគាត់ជាប្រមុខរដ្ឋផងជាប្រមុខរដ្ឋាភិបាលផង នោះគេហៅថារាជាធិបតេយ្យទ្វិកភាព ឬជារបបនិយមស្តេច ប៉ុន្តែបើប្រមុខរដ្ឋជាមនុស្សសាមញ្ញដែលជ្រើសតាំងដោយប្រជាពលរដ្ឋ ហើយបុគ្គលប្រមុខរដ្ឋនោះជាប្រមុខរដ្ឋ និងជាប្រមុខរដ្ឋាភិបាលនៃរដ្ឋនោះ គេហៅថាសាធារណៈរដ្ឋបែបទ្វិកភាព ឬប្រទេសនិយមប្រធានាធិបតី ដូចជាសហរដ្ឋអាមេរិក ............. ជាដើម ។ល។

លក្ខណៈពិសេសរបស់វាទៅលើការបែងចែកអំណាចនោះ គឺអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ នៅក្នុងទំរង់សាធារណរដ្ឋបែបប្រធានាធិបតីនិយម វាកើតឡើងដោយផ្ទាល់ពីប្រជាជន ហើយមានអាណត្តិច្បាស់លាស់ ។ ប្រមុខនៃអំណាចនីតិប្រតិបត្តិជាប្រធានាធិបតីដែលបានជ្រើសរើសដោយប្រជាជន ហើយដែលមុខងាររបស់វាសមាមាត្រទៅនឹងមុខងាររបស់ប្រមុខរដ្ឋ ។ រដ្ឋាភិបាលដែលជាទំលាប់ ហាក់ដូចជាអង្គការសហការីរបស់ប្រធានាធិបតីនោះពុំមានកើតទេ ប៉ុន្តែរដ្ឋមន្ត្រីទាំងអស់ត្រូវស្ថិតក្រោមបញ្ជារបស់ប្រធានាធិបតីតាមផ្នែក១ ។ ពិសេសទៀតប្រធានាធិបតីមានសិទ្ធតែងតាំងចៅក្រមទៀតផង (ចៅក្រមតុលាការកំពូល) ។

សញ្ញាណពិសេសនៃរបបសាធារណរដ្ឋបែបប្រធានាធិបតីនិមយ គឺអវត្តមាននូវការទទួលខុសត្រូវរបស់អំណាចនីតិប្រតិបត្តិ ក្នុងការដឹកនាំនយោបាយចំពោះមុខរដ្ឋសភា ។ ប៉ុន្តែបើប្រមុខអំណាចនីតិប្រតិបត្តិអនុវត្តបំពានច្បាប់ខ្លាំងពេកនោះ រដ្ឋសភានឹងបណ្តេញចោលតាមនីតិវិធីពិសេសមួយ គឺអឹមពិជ្ជមិន "Impeachment" (ករណីសហរដ្ឋអាមេរិកជាដើម) ។

និយាយរួមទៅទំរង់សាធារណរដ្ឋបែបប្រធានាធិបតីនិយម គឺអំណាចរបស់ប្រមុខរដ្ឋ ឬប្រមុខអំណាចនីតិប្រតិបត្តិមានឥទ្ធិពលជាងអំណាចនីតិបញ្ញត្តិ គឺថាប្រធានាធិបតីអាចបញ្ឈប់នូវសកម្មភាពនៃអង្គការនីតិបញ្ញត្តិបាន ។ លក្ខណៈបៀបនេះដូចជាប្រទេសអាមេរិក (មានតែការចែងដោយច្បាប់ ប៉ុន្តែពុំដែលកើតមានទេ) និងប្រទេសមួយចំនួនទៀតនៅអាមេរិកឡាទីន ។ ដូចនេះទំរង់គ្រប់គ្រងសាធារណរដ្ឋបែបទ្វិកភាព ឬហៅថារបបនិយមប្រធានាធិបតី និងទំរង់គ្រប់គ្រងរាជាធិបតេយ្យបែបទ្វិកភាព ឬហៅថារាជាធិបតេយ្យនិយមស្តេចមានលក្ខណៈប្រហែលគ្នា ព្រោះប្រមុខរដ្ឋមានសិទ្ធិធំធេងក្នុងកិច្ចការរបស់ខ្លួន ទាក់ទិននឹងអំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ។

**ខ៍. សាធារណរដ្ឋបែបសភា** (Parliamentarian Republic) : គឺជាទំរង់គ្រប់គ្រងដែលមានទំរង់ទំនាក់ទំនងដូចគ្នានឹងប្រភេទនៃទំរង់គ្រប់គ្រងរាជាធិបតេយ្យបែបសភាដែរ គឺថាបញ្ហាសំខាន់គេផ្តោតទៅលើប្រមុខរដ្ឋ និងរដ្ឋាភិបាលទទួលខុសត្រូវចំពោះរដ្ឋសភា។ ប្រមុខរដ្ឋដែលជាប្រធានាធិបតីពុំមានសកម្មភាពអ្វីក្រៅពីនិមិត្តរូបនៃឯកភាពជាតិរបស់រដ្ឋប៉ុណ្ណោះ ។

សញ្ញាណគ្រឹះសំខាន់ៗរបស់វាគឺសាធារណរដ្ឋបែបសភា និងរាជាធិបតេយ្យបែបសភា ដូចគ្នាត្រង់ថានយោបាយរបស់រដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះរដ្ឋសភា ។ ជានិច្ចកាលភាពទទួលខុសត្រូវទំរង់បែបនេះប្រព្រឹត្តិទៅដោយសាមគ្គីភាព គឺថាការមិនទុកចិត្តចំពោះសមាជិកម្នាក់របស់រដ្ឋាភិបាល ជាពិសេសប្រមុខរដ្ឋរបស់គេ នោះគេនឹងរំលាយរដ្ឋាភិបាលទាំងមូល ។ ក្នុងករណីរំលាយរដ្ឋាភិបាលនេះអាចទាមទារពីប្រធានាធិបតីនូវការរំលាយរដ្ឋសភាដែរ (សភាតំណាងរាស្ត្រ) ។ ប្រទេសដែលកាន់ទំរង់គ្រប់គ្រងសាធារណរដ្ឋបែបសភាមានច្រើនណាស់ដូចជា អាល្លឺម៉ង់, ហុងគ្រី, អ៊ីតាលី, ឥណ្ឌា, ឆែក, អេស្តូនី, ស្លូវ៉ាគី, ស្វីស, អូទ្រីស្ត ។ល។

**៩-២. សាធារណរដ្ឋចំរុះ ឬបែបពាក់កណ្តាលប្រធានាធិបតី:** នេះគឺជាទំរង់គ្រប់គ្រងដែលគេកំនត់យកសញ្ញាណទាំងឡាយនៃសាធារណៈបែបសភា និងសាធារណបែបប្រធានាធិបតីមកកត់សំគាល់ ។

ដូចជារដ្ឋធម្មនុញ្ញបារាំង ឆ្នាំ ១៩៥៨ បញ្ជាក់ថា : ប្រធានាធិបតីជ្រើសរើសដោយពលរដ្ឋទាំងអស់ និងដឹកនាំរដ្ឋាភិបាល, នេះបញ្ជាក់នូវលក្ខណៈទំរង់គ្រប់គ្រងសាធារណរដ្ឋបែបប្រធានាធិបតី ប៉ុន្តែក្នុងខណៈនោះរដ្ឋាភិបាល ដែលត្រូវបានចាត់តាំងដោយប្រធានាធិបតី ត្រូវតែមានសេចក្តីទុកចិត្តពីសភាតំណាងរាស្ត្រ ដែលត្រង់នេះមានលក្ខណៈជាទំរង់គ្រប់គ្រងសាធារណរដ្ឋបែបសភា ។ ជាមួយគ្នានេះដែរ ប្រធានាធិបតីអាចរំលាយសភាចោលបានតាមឆន្ទានុសិទ្ធរបស់ខ្លួន ដែលលក្ខណៈនេះពុំមានចូលក្នុងទំរង់ណាមួយ ក្នុងចំណោមទំរង់គ្រប់គ្រងបែបសាធារណរដ្ឋទេ ។

ប៉ុន្តែ នៅក្នុងប្រទេសខ្លះប្រធានាធិបតីជ្រើសរើសដោយប្រជាជន នេះបញ្ជាក់នូវលក្ខណៈសាធារណរដ្ឋបែបប្រធានាធិបតី ដែលជាធម្មតាអំណាចដ៏សំបើមបានប្រគល់ទៅឱ្យគាត់ ប៉ុន្តែបែរជាសកម្មភាពជាក់ស្តែងពុំមានទេវិញ គឺប្រធានាធិបតីមាន "**អំណាចស្លាប់**" ឬហៅថា "**អំណាចដេកលក់**" ។ លក្ខណៈនេះប្រមុខរដ្ឋគ្រាន់តែជាតំណាងនៃឯកភាពជាតិ ឯកសកម្មភាពជាក់ស្តែងគឺប្រមុខរដ្ឋាភិបាលជាអ្នកដឹកនាំ ដែលទំរង់នេះមានលក្ខណៈជាសាធារណរដ្ឋបែបសភា ដូចជាប្រទេសអូស្ត្រាលី ថ្វីត្បិតតែប្រទេសនេះប្រមុខរដ្ឋជាស្តេចចក្រភពអង់គ្លេសក៏ពិតមែន ប៉ុន្តែត្រូវមានតំណាងមួយជំនួសស្តេច ដែលតំណាងនោះធ្វើឡើងតាមសំណូមពររបស់ប្រមុខរដ្ឋាភិបាលអូស្ត្រាលី, ចំពោះ

ប្រទេសអៀរឡង់ ប្រមុខរដ្ឋជាប្រធានាធិបតីតែពុំមែនបោះឆ្នោតដោយសភាទេ គឺប្រធានាធិបតីបោះឆ្នោតដោយពលរដ្ឋទូទៅ ។ លក្ខណៈគ្រប់គ្រងបែបចំរុះនេះមាននៅប្រទេសមួយចំនួនទៀត ដែលទើបនឹងផ្តួលរំលំរបបផ្តាច់ការ គេបង្កើតទំរង់គ្រប់គ្រងសាធាណរដ្ឋបែបចំរុះដែរ ដែលក្នុងនោះរដ្ឋាភិបាលពឹងផ្អែកលើភាគច្រើនរបស់សភា. ហើយប្រធានាធិបតីរបស់គេបោះឆ្នោតដោយពលរដ្ឋទូទៅ ដូចជាប្រទេសព័រទុយហ្គាល់. ប៉ូឡូញ. ប៊ុលហ្គារី. ស្លូវេនី ។ល។

សរុបទៅទំរង់គ្រប់គ្រងសាធារណរដ្ឋបែបនេះមានលក្ខណៈសាំញ៉ាំច្រើនជាងគេ តែវាមានប្រសិទ្ធភាព ឬគ្មានប្រសិទ្ធភាពក្នុងការគ្រប់គ្រង វាអាស្រ័យនឹងស្ថេរភាពសង្គមទាំងមូលរបស់រដ្ឋនោះតែប៉ុណ្ណោះ ។

# អត្ថបទទី ១៣

# ការជ្រើសរើស ឬការបោះឆ្នោត និងការកោះហៅ

## ១. អត្ថន័យ និងមុខងារសង្គមនៃការជ្រើសរើស

នៅក្នុងនីតិរដ្ឋធម្មនុញ្ញពាក្យថាជំរើស ( Choice) គឺជានីតិវិធីមួយនៃការបង្កើតឱ្យមានអង្គការរដ្ឋទាំងឡាយ ឬក៏ការបង្កឱ្យមានសិទ្ធិ-អំណាចទៅលើមន្ត្រីនានា ដែលនីតិវិធីនេះត្រូវបានបំពេញនាទីដោយការសម្រុះសម្រួល (Mediation) តាមរយៈសំលេងបោះឆ្នោតរបស់បុគ្គលមានសិទ្ធិអំណាចក្នុងល័ក្ខខ័ណ្ឌមួយ ។ ល័ក្ខខ័ណ្ឌនេះវាមានអត្ថន័យដោយផ្ទាល់ថា បុគ្គលម្នាក់ដែលត្រូវបានគេប្រគល់សិទ្ធិអំណាចនោះ អាចទាមទារនូវអាណត្តិរបស់ខ្លួនក្នុងសណ្តាប់ធ្នាប់កំរិតមួយ ដែលមានបេក្ខជនចាប់ពីពីរឡើងទៅ ( មានន័យថា អណត្តិនីមួយៗត្រូវមានបេក្ខជនឈរឈ្មោះចាប់ពីពីរនាក់ឡើង) ។

តាមនិយមន័យខាងលើយើងឃើញថា វាអាចមានភាពខុសគ្នានៃជំរើស និងចំណាត់តាំងក្នុងការបង្កើតអង្គការរដ្ឋ និងបង្កើតឱ្យមានសិទ្ធិអំណាចសំរាប់បុគ្គលម្នាក់ៗក្នុងករណីខ្លះនោះ គឺមានន័យថាប្រមុខរដ្ឋមានសិទ្ធិជ្រើសរើស ឬចាត់តាំងបុគ្គលរូបណាមួយឱ្យមានតំណែងបាន ដោយមិនចាំបាច់ត្រូវការនូវសេចក្តីយល់ព្រមពីអង្គការ ឬបុគ្គលណាក្នុងអំណាចជាន់ខ្ពស់ឡើយ ( ដូចជាក្នុងការគ្រប់គ្រងរដ្ឋតាមបែបអប្រជាធិបតេយ្យ) ។ អង្គការផ្សេងៗនៃអំណាចសាធារណជាច្រើន ដែលបង្កើតមកតាមរយៈការសំរុះសំរួលនៃជំរើស ដូចជា : រដ្ឋសភា, ប្រមុខរដ្ឋ, ពេលខ្លះមានប្រមុខរដ្ឋាភិបាល, អង្គការតុលាការ, ( ករណីតុលាការកំពូល) និងអង្គការគ្រប់គ្រងមូលដ្ឋានជាដើម ។ល។

ជំរើសទាំងឡាយអាចធ្វើឡើងយ៉ាងទូលាយ ដោយប្រើប្រាស់សំរាប់បង្កើតអង្គការប្រមូលផ្តុំសង្គម ប៉ុន្តែជំរើសនេះពុំស្ថិតក្នុងល័ក្ខខ័ណ្ឌទាំងឡាយនៃនិយ័តកម្មធម្មនុញ្ញគតិយុត្តិទេ ព្រោះវាគ្រាន់តែជាតម្រូវការនូវការគ្រប់គ្រងមួយឱ្យមានលក្ខណៈជាខ្សែបណ្តោយតែប៉ុណ្ណោះ ( ពីអំណាចកណ្តាលទៅមូលដ្ឋាន) ។ ជាពិសេសទៀតនោះ មុខងារសង្គមនៃជំរើស ( ការជ្រើសរើស) វាមានលក្ខណៈធំទូលាយណាស់សំរាប់លទ្ធិប្រជាធិបតេយ្យ និងស្ថេរភាពសង្គមនៅក្នុងការគ្រប់គ្រងផ្ទៃក្នុងរបស់ប្រទេស

ទីមួយៗ ដោយយោងទៅលើអត្ថន័យ និងខ្លឹមសារដែលមានទំនាក់ទំនងទៅនឹងសង្គមយ៉ាងដូចច្នេះ ទើបជំរើសមានមុខងារដូចតទៅ :

**ក. ការជ្រើសរើសធ្វើឱ្យអំណាចមានភាពត្រឹមត្រូវតាមច្បាប់ ឬធម្មានុរូប** (Legitimize): នេះជាគោលការណ៍តាមរយៈនៃការសំរុះសំរួលរបស់គេនោះ គឺប្រជាជនជាអ្នកកំណត់នូវអ្នកតំណាងរបស់ខ្លួន និងចែករំលែកនូវអាណត្តិរបស់គេ ដោយឈរលើការបំពេញកិច្ចនៃសិទ្ធិឯករាជ្យ ។ ត្រង់ចំណុចនេះត្រូវបានសមិទ្ធិដោយសិទ្ធិពិសេសមួយ **គឺសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ** ដូចជាសេចក្តីប្រកាសជាសកល ( Declaration) របស់អង្គការសហប្រជាជាតិ នៅឆ្នាំ ១៩៤៨ ក្នុង**មាត្រា ២១** វាក្យខ័ណ្ឌ ៣ បានកំណត់ថា "ឆន្ទៈរបស់ប្រជាជនត្រូវតែជាមូលដ្ឋានគ្រឹះនៃអំណាចរបស់រដ្ឋាភិបាល. ឆន្ទៈនេះត្រូវតែស្ថិតនៅក្នុងការសំដែងរបស់ខ្លួន ក្នុងអំឡុងពេលជ្រើសរើស និងគ្មានការក្លែងបន្លំ (Falsify) ដែលត្រូវធ្វើឡើងជាសាកល និងតាមសមភាពនៃច្បាប់បោះឆ្នោត តាមវិធីបោះឆ្នោតដោយសំងាត់ ឬក៏តាមរយៈការសំរុះសំរួលនៃទំរង់ផ្សេងៗទៀត ដែលផ្តល់ផ្តល់បាននូវសេរីភាពនៃការបោះឆ្នោត" ។ ដោយផ្អែកលើសេចក្តីប្រកាសនេះ ប្រទេសទាំងអស់ដែលជាសមាជិកនៃអង្គការដ៏ធំនោះ ( អង្គការសហប្រជាជាតិ) បានជ្រើសយកសេចក្តីប្រកាសនេះមកធ្វើជាគោលការណ៍ដ៏សំខាន់ នៃមូលដ្ឋានច្បាប់គ្រឹះរបស់ប្រទេសខ្លួន ដូច**មាត្រា ៧៦** វាក្យខ័ណ្ឌទី ២ រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំនត់ទៅលើអំណាចនីតិបញ្ញត្តិថា "តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសាកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតសំងាត់" ។ និង**មាត្រា ៧៨** វាក្យខ័ណ្ឌទីមួយបានកំណត់នីតិកាលរបស់សភា និងអាណត្តិថា "នីតិកាលរបស់រដ្ឋសភាមានកំនត់ ៥ ឆ្នាំ ហើយផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែ........." ។ ដូចនេះ ការជ្រើសរើសដែលធ្វើឱ្យអំណាចមានលក្ខណៈជាច្បាប់ និងត្រឹមត្រូវនោះគឺធ្វើឡើងតែចំពោះអំណាចនីតិបញ្ញត្តិ ឬអំណាចនីតិប្រតិបត្តិទេ ក្នុងក្របខ័ណ្ឌនៃការបោះឆ្នោតដោយសេរី និងសកល ។ ប៉ុន្តែអំណាចតុលាការ ( អង្គការតុលាការ) គេពុំអាចធ្វើឡើងតាមរយៈការបោះឆ្នោតទេ តែតាមរយៈការចាត់តាំងពីប្រមុខរដ្ឋ ឬក៏ពីរដ្ឋសភា ប៉ុន្តែមិនអាចបដិសេធន៍នូវភាពមិនស្របច្បាប់បាននោះទេ ពីព្រោះថាដោយការប្រព្រឹត្តិនោះតាមរយៈនៃច្បាប់កំពូល ( រដ្ឋធម្មនុញ្ញ) រីឯអំណាច

នីតិបញ្ញត្តិនោះត្រូវតែបោះឆ្នោតជាសាកល និងសេរីជាចាំបាច់ ។ ដូចនេះអំណាចដែលកើតឡើងតាមរយៈបោះឆ្នោត វាមានលក្ខណៈសំរុះសំរួលក្នុងជាតិសាសន៍មួយដ៏មានប្រសិទ្ធិភាព ជាពិសេសស្ថេរភាពសង្គមនយោបាយ ។

**ខ. ការជ្រើសរើសបំរើចំពោះបរិធាន** (Barometer) **នៃកិច្ចការនយោបាយ :** ត្រង់នេះគឺចង់និយាយអំពីការជ្រើសរើស ឬការបោះឆ្នោត វាជាវិធានមួយនៃការវាស់ស្ទង់ទៅលើកិច្ចការនយោបាយ របស់បក្សនយោបាយក្នុងប្រទេសនីមួយៗពីការគាំទ្ររបស់រាស្ត្រ ។ វាជាការវិវត្តន៍មួយដែលគ្របដណ្តប់ទៅរាល់ផលប្រយោជន៍នៃកំលាំងនយោបាយផ្សេងៗ ដូចជាទស្សនៈកម្មវិធីគ្រឹះ (Party Platform)........ជាដើម ។ ដូចនេះលទ្ធផលទាំងឡាយនៃការជ្រើសរើសនោះ វាផ្តល់នូវតម្លៃមួយយ៉ាងវិជ្ជមាននៃកំរិត (ខ្ពស់-ទាប) ណាមួយយ៉ាងសុក្រឹត្យ និងមានឥទ្ធិពលទៅលើអារម្មណ៍នៃអ្នកបោះឆ្នោត. ឬក៏និន្នាការនៃកិច្ចការនយោបាយផ្សេងទៀត ។

## ២. ប្រភេទ ឬទិដ្ឋភាពនៃការជ្រើសរើស (ប្រភេទនៃការបោះឆ្នោត)

ការជ្រើសរើស ឬការបោះឆ្នោតប្រព្រឹត្តទៅតាមលក្ខណៈច្រើនប្រភេទណាស់ ប៉ុន្តែនៅក្នុងល័ក្ខខ័ណ្ឌនេះលើកមកជំរាបជូននូវទិដ្ឋភាព (Aspect) ខ្លះៗដែលជាមូលដ្ឋានគ្រឹះនៃទ្រឹស្តីនីតិសាស្ត្រប៉ុណ្ណោះ ។

**ក. ទិដ្ឋភាពផ្ទាល់នៃការជ្រើសរើស** : ជាប្រភេទនៃការបោះឆ្នោត ដែលក្នុងនោះពលរដ្ឋទូទៅជាអ្នកដោះស្រាយដោយផ្ទាល់ ។ ប្រភេទនេះការបោះឆ្នោតធ្វើឡើងដោយផ្ទាល់ពីប្រជាពលរដ្ឋ ចំពោះការជ្រើសរើសសភាជាន់ទាប (សភាតំណាងរាស្ត្រ) ។ ប៉ុន្តែក្នុងពេលខ្លះក៏កើតមានក្នុងការជ្រើសរើសសភាជាន់ខ្ពស់ដែរ (ព្រឹទ្ធសភា) ដូចជានៅអាមេរិក និងអ៊ីតាលីជាដើម ដែលសមាជិកព្រឹទ្ធសភាមួយចំនួនអាចត្រូវបានជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋ ។ ការកើតមានដោយផ្ទាល់ផងដែរ ក្នុងការជ្រើសរើសប្រធានាធិបតី នៃបណ្តាប្រទេសដែលកាន់ទំរង់គ្រប់គ្រងសាធារណរដ្ឋបែបប្រធានាធិបតីនិយម និងទំរង់គ្រប់គ្រងសាធារណរដ្ឋបែបចំរុះ ។ល។ ចំពោះពត៌មានពិស្តារសូមអានគោលការណ៍បោះឆ្នោត ។

**ខ. ទិដ្ឋភាពប្រយោលនៃការជ្រើសរើស** : ការបោះឆ្នោតរបៀបនេះ ពុំមែនប្រជាពលរដ្ឋទូទៅជាអ្នកដោះស្រាយទេ តែអ្នកជាប់ឆ្នោតដំបូង (Elector) ជាអ្នកដោះស្រាយ ដូចជាតំណាងរាស្ត្រជាដើម ។ការបោះឆ្នោតដោយប្រយោល ជាធម្មតាធ្វើឡើងក្នុងការជ្រើសរើសសភាជាន់ខ្ពស់( ព្រឹទ្ធសភា) ប្រធានាធិបតី ( នៅទំរង់គ្រប់គ្រងសាធារណរដ្ឋបែបសភា), រដ្ឋាភិបាល, តុលាការ ។ល។ គួរបញ្ជាក់ថា ការបោះឆ្នោតរបៀបនេះគឺធ្វើឡើងជាដំណាក់ទី ២ ឬទី ៣ តាមរយៈតំណាងរបស់ប្រជាជន ។ ទិដ្ឋភាពនៃការបោះឆ្នោតនេះពុំធ្វើឡើងដោយពលរដ្ឋផ្ទាល់ទេ ។

**គ. ទិដ្ឋភាពសាកលនៃការជ្រើសរើស** : ជាទិដ្ឋភាពមួយដែលធ្វើឡើងដោយករណីខ្លះ ក្នុងការអំពាវនាវឱ្យចូលរួមនូវគ្រប់គ្នានៃអ្នកបោះឆ្នោតក្នុងប្រទេស (ដូចជាការជ្រើសរើស ឬបោះឆ្នោតសំរាប់សភាជាន់ទាប ឬសំរាប់រដ្ឋដែលមានរដ្ឋសភាតែមួយ ឬសំរាប់ព្រឹទ្ធសភា ឬសំរាប់ប្រធានាធិបតី) ផងដែរ ។ ការបោះឆ្នោតរបៀបនេះធ្វើឡើងនៅទូទាំងប្រទេស ។

**ឃ. ទិដ្ឋភាពអន្លើនៃការជ្រើសរើស** : នេះគឺជាការបោះឆ្នោតយកសំលេង ដែលធ្វើឡើងបានកាលណាវាត្រូវបំពេញបន្ថែម ចាំបាច់នូវសមាសភាពនៃសមាជិករដ្ឋសភា នូវវត្តមានដំបន្ទាន់ដោយឡែករបស់តំណាងរាស្ត្រ ។ មួយវិញទៀត ទិដ្ឋភាពជ្រើសរើសរបៀបនេះហៅថាទិដ្ឋភាពបំពេញបន្ថែម ។ ទិដ្ឋភាពនេះសំរាប់ជ្រើសរើសនូវសមាជិកដើម្បីបង្គ្រប់ចំនួន ឬបន្ថែម ( ជ្រើសរើសតំណាងរាស្ត្រ) ។

**ង. ទិដ្ឋភាពជាតិនៃការជ្រើសរើស** : ទិដ្ឋភាពនេះប្រព្រឹត្តទៅកាលណាគេធ្វើការបោះឆ្នោតនៅគ្រប់ទីកន្លែងនៃប្រទេស ។ ការបោះឆ្នោតរបៀបនេះ មានលក្ខណៈដូចគ្នានឹងទិដ្ឋភាពសកលដែរ ។

**ច. ទិដ្ឋភាពតំបន់ និងទិដ្ឋភាពមូលដ្ឋាននៃការជ្រើសរើស** : កិច្ចការនេះគឺការបោះឆ្នោតជ្រើសរើសអង្គការមួយសំរាប់គ្រប់គ្រងមូលដ្ឋាន ឬគេហៅថាទិដ្ឋភាពរដ្ឋបាល ( ដែនដី) ។

**ឆ. ទិដ្ឋភាពលំដាប់លំដោយ និងទិដ្ឋភាពមិនលំដាប់លំដោយនៃការបោះឆ្នោត** : ជាទិដ្ឋភាពមួយដែលទាក់ទិនទៅនឹងការជ្រើសរើស ឬបោះឆ្នោតសភា ។ ការបោះឆ្នោតតាមលំដាប់លំដោយគឺធ្វើឡើងតាមនីតិកាលរបស់ខ្លួន ដែលមានអាណត្តិកំណត់ក្នុងរដ្ឋធម្មនុញ្ញ ឬក៏នៅក្នុងច្បាប់ ឬក៏មានចំណាត់តាំងក្នុងករណីដែលបានចប់អាណត្តិរបស់សភា ។ រីឯទិដ្ឋភាពមិនលំដាប់លំដោយនោះ គឺជា

ការបោះឆ្នោត ឬជ្រើសរើសដែលធ្វើឡើងជាវិសាមញ្ញ គឺពុំគោរពតាមភាពលំដាប់លំដោយទេ ដូចជាក្នុងពេលរំលាយសភាមុនអាណត្តិជាដើម ។

## ៣. សាមយិកភាព ឬភាពទៀងទាត់នៃការជ្រើសរើស ឬបោះឆ្នោត

លក្ខណៈនេះគឺជាថេរវេលាមួយ ឬក៏នីតិកាលមួយរបស់សភា ដែលបានគោរពនូវអាណត្តិរបស់ខ្លួនតាមការកំនត់របស់ច្បាប់ និងធ្វើការជ្រើសរើសឡើងវិញដោយទៀងទាត់ ។ ដូចនេះភាពទៀងទាត់នៃការបោះឆ្នោតត្រូវបានកំណត់ដោយច្បាប់ តាមថេរវេលានៃសិទ្ធិ-អំណាចរបស់អង្គការបោះឆ្នោត ជាឧទាហរណ៍ដូចជាច្បាប់បោះឆ្នោតកម្ពុជា ឆ្នាំ ១៩៩៧ បានកំណត់នូវ **មាត្រា ៣** ថា "ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើង ៥ ឆ្នាំម្តង នៅថ្ងៃអាទិត្យនៃសប្តាហ៍ទី ៨ មុនដំណាច់ឆ្នាំទី ៥ នៃនីតិកាលរបស់រដ្ឋសភា លើកលែងតែក្នុងស្ថានភាពណាមួយដូចខាងក្រោម :

- ក្នុងករណីប្រធានស័ក្តិ ដែលចាំបាច់ត្រូវលើកថ្ងៃបោះឆ្នោត ។

- ក្នុងករណីដែលរដ្ឋសភាត្រូវរំលាយមុនផុតអាណត្តិ ។ ក្នុងករណីនេះការបោះឆ្នោតជ្រើសរើសរដ្ឋសភាថ្មីត្រូវប្រព្រឹត្តទៅក្នុងរយៈពេល ៦០ ថ្ងៃយ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភា ។

- ក្នុងករណីដែលរដ្ឋសភាត្រូវបានប្រកាសឱ្យបន្តនីតិកាលរបស់ខ្លួន ស្របតាមវាក្យខ័ណ្ឌទី ៥ មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ" ។

ប៉ុន្តែនៅពេលខ្លះក៏គេអាចពន្យាពេលនៃអាណត្តិនេះបានដែរ ដោយយកលេសទៅលើវិបត្តិប្រទេសជាតិ ឬក៏មានសង្គ្រាម ជួនកាលក៏គេអាចធ្វើការបោះឆ្នោតដោយយកសំលេង ២/៣ ក្នុងសភាដើម្បីសំរេចលើបញ្ហាបន្តអាណត្តិសភានេះ ដោយផ្អែកលើច្បាប់គ្រឹះនៃប្រទេសនីមួយៗផងដែរ ។ ជាងនេះទៅទៀត គេសង្កេតឃើញប្រទេសដែលទំរង់គ្រប់គ្រងសាធារណរដ្ឋបែបប្រធានាធិបតី រដ្ឋសភាពុំសូវមានលទ្ធភាពក្នុងការបន្តអាណត្តិរបស់ខ្លួនបានទេ ទោះជាប្រទេសប្រឈមនឹងវិបត្តិក៏ដោយ ដូចជានៅឆ្នាំ ១៩៤៤ សហរដ្ឋអាមេរិកនៅតែមានលទ្ធភាពបោះឆ្នោត ដែលពេលនោះពិភពលោករងពីសង្គ្រាមលោកលើកទី II ។ ប៉ុន្តែអ្នកវិភាគខ្លះបាននិយាយថា ភាពទៀងទាត់នៃការបោះឆ្នោតនៅសហរដ្ឋ ក្នុងពេលមានសង្គ្រាមលោកលើកទី ២ នោះ គឺមកពីប្រទេសនេះពុំបានទទួលរងនូវការឈ្លានពានពីសត្រូវខ្លាំងក្លានោះទេ ។

ភាពទៀងទាត់នៃការបោះឆ្នោតនេះ តាមរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ **មាត្រា ៧៨** បាន កំណត់ថា " នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មី ចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណី ដែលរាជរដ្ឋាភិបាលត្រូវបានទំលាក់ពីរដងក្នុងរយៈ ១២ ខែ ។

ក្នុងករណីនេះ ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពី នាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។

ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មីនឹងប្រព្រឹត្តិទៅក្នុងរយៈពេល ៦០ ថ្ងៃ យ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក ។

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោត កើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហា ក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃ ចំនួនសមាជិករដ្ឋសភាទាំងមូល" ។ ដូចនេះភាពទៀងទាត់នៃការបោះឆ្នោត វាជាលទ្ធផលមួយនៃ សកម្មភាពរបស់អង្គការរដ្ឋកំពូល ក្នុងការការពារលទ្ធិប្រជាធិបតេយ្យ និងច្បាប់របស់ប្រទេសខ្លួន ជា ពិសេសទៀតនោះវាបង្ហាញនូវស្ថេរភាពសង្គម, សេដ្ឋកិច្ច, នយោបាយ ។ល។

## ៤. ប្រព័ន្ធបោះឆ្នោត ( Electoral Systems)

ពាក្យថាប្រព័ន្ធបោះឆ្នោតគេប្រើក្នុងអក្សរសាស្ត្រ វាមានអត្ថន័យពីរគឺ : ន័យជាអត្ថនោម័ត និងន័យជាសត្យានុម័ត ។

- **ន័យអត្ថនោម័ត :** ប្រព័ន្ធបោះឆ្នោតគឺជាទំនាក់ទំនងសណ្តាប់ធ្នាប់សង្គមសាធារណៈ ដែល ផ្សារភ្ជាប់នឹងការជ្រើសរើសនៃអង្គការទាំងឡាយរបស់អំណាចសាធារណៈ ហើយទំនាក់ទំនងនោះ រៀបចំនូវសណ្តាប់ធ្នាប់នៃការបោះឆ្នោត ។ តាមលក្ខណៈមូលដ្ឋានគ្រឹះ ក្នុងអត្ថន័យនៃប្រព័ន្ធនេះវាធ្វើ

និយ័តកម្មដោយរដ្ឋធម្មនុញ្ញគតិយុត្ត និងមានពេលខ្លះវាក៏ត្រូវធ្វើនិយ័តកម្មដោយបទដ្ឋានខាងក្រៅខ្លះដែរ ដូចជាបទដ្ឋានសហប្រតិបត្តិការនៃការប្រមូលផ្តុំជាសាធារណៈ ដែលចូលរួមក្នុងការបោះឆ្នោត (ដូចជាលក្ខន្តិកៈ និងឯកសារផ្សេងៗទៀតរបស់បក្សនយោបាយ) ។

- **ន័យសត្យានុម័ត :** ប្រព័ន្ធបោះឆ្នោតគឺជាមធ្យោបាយនៃការបែងចែក (កំណត់) ទៅលើអាណត្តិតំណាងរាស្ត្រ (ការទទួលនូវសិទ្ធតំណាងរាស្ត្រ) រវាងបេក្ខជនទាំងអស់ដោយអាស្រ័យនឹងលទ្ធផលនៃសំលេងអ្នកបោះឆ្នោត ឬក៏បុគ្គលមានសិទ្ធិអំណាចផ្សេងៗទៀត ។

**ចំណាំ :** ពាក្យថាអាណត្តិចេញពីពាក្យឡាតាំងថា "Mandatum" មានន័យថាផ្តល់ជូន. ទុកចិត្ត ។ ដូចនេះវាមានន័យថា :

**ទីមួយ :** វាជាឯកសារដែលគេបានផ្តល់សេចក្តីទុកចិត្ត នូវអំណាចសំរាប់តាំងខ្លួនជាអ្នកមានភារៈអ្វីមួយ ។

**ទីពីរ :** នៅក្នុងច្បាប់រដ្ឋ វាគឺជាឯកសារដែលផ្តល់សេចក្តីទុកចិត្តនូវភាពត្រឹមត្រូវ តាមច្បាប់នៃសិទ្ធិអំណាចរបស់តំណាងរាស្ត្រ (គេចារិកនូវសិទ្ធិអំណាចនៅក្នុងឯកសារច្បាប់មួយច្បាស់លាស់) ។ ដូចនេះ ដើម្បីយល់ដឹងនូវប្រព័ន្ធបោះឆ្នោត យើងនឹងសិក្សាវាក្នុងលក្ខណៈជាន័យសត្យានុម័ត ឬក៏ហៅថាន័យ **មានកំរិត** (Limited) ដែលអត្ថន័យនៃប្រព័ន្ធនេះមានលំដាប់ថ្នាក់ផ្សេងៗគ្នា ។ គួកត់សំគាល់ផងដែរថា នៅលើពិភពលោកយើងនេះ ការដឹកនាំប្រទេសដែលធ្វើឡើងតាមរយៈការជ្រើសរើសប្រមុខដឹកនាំប្រទេស ឬក៏អង្គការអំណាចកំពូលៗ គេតែងជ្រើសរើសតាមប្រព័ន្ធបោះឆ្នោតប្លែកៗពីគ្នាជាច្រើន ដោយឈរលើគោលការណ៍ទាំងនោះ ទើបប្រទេសនីមួយៗបានប្រកាន់យកប្រភេទនៃប្រព័ន្ធបោះឆ្នោតមួយចំនួន តាមការវិវត្តន៍នៃប្រវត្តិសាស្ត្រក្នុងការបោះឆ្នោតជ្រើសរើសតំណាងស្ថាប័នអំណាចធំៗក្នុងប្រទេសនីមួយៗនោះ គេសង្កេតឃើញមានប្រព័ន្ធបោះឆ្នោតធំៗបីគឺៈ ប្រព័ន្ធបោះឆ្នោតភាគច្រើន ឬប្រព័ន្ធឯកត្តនាម (Majority System), ប្រព័ន្ធបោះឆ្នោតសមាមាត្រ (Proportional System), និងប្រព័ន្ធបោះឆ្នោតចំរុះ (Mixed System) ។

**ក. ប្រព័ន្ធភាគច្រើន ឬប្រព័ន្ធឯកត្តនាម** (Majority System) : ប្រព័ន្ធបោះឆ្នោតរបៀបនេះ គឺជាប្រព័ន្ធបោះឆ្នោតកើតឡើងដំបូងបង្អស់ជាប្រវត្តិសាស្ត្រ ដែលគេប្រកាន់យកគោលការណ៍សំឡេង **ភាគច្រើន** ដែលពាក្យបារាំងថា "Majorité" គឺថាបេក្ខជនទាំងអស់ដែលគិតថាបានជ្រើសរើស គឺបេក្ខជនទាំងនោះមានសំលេងភាគច្រើនរបស់អ្នកបោះឆ្នោត ។ ប្រព័ន្ធនេះមានវ័យចំណាស់ជាងគេ ដែលមានប្រទេសជាង ៨៣ អនុវត្តន៍តាមប្រព័ន្ធឯកត្តនាម ( គូលេខឆ្នាំ ១៩៩៤) ។

ដោយយោងទៅលើប្រព័ន្ធភាគច្រើននេះ គេសង្កេតឃើញមានប្រភេទច្រើនទៀតដែលអាស្រ័យនឹងមណ្ឌលបោះឆ្នោត (Constituency) ដែលជាទូទៅមណ្ឌលបោះឆ្នោតនៅក្នុងប្រព័ន្ធនេះមានពីរប្រភេទ គឺមណ្ឌលដែលមានអាសនៈមួយ (Single-member Constituency) និងមណ្ឌលពហុអាសនៈ (Multi-member Constituency) ។ ដូចនេះភាពខុសគ្នានៃប្រព័ន្ធភាគច្រើននេះ ចែកជាពីរក្រុមគឺ :

**ក១. ក្រុមទីមួយ: មណ្ឌលដែលមានអាសនៈមួយ ឬមណ្ឌលឯកត្តនាម** (Single-member Constituency): គឺជាមណ្ឌលដែលមានកៅអីតែមួយគត់ សំរាប់ការបោះឆ្នោតក្នុងមណ្ឌលទាំងមូល ។ មានន័យថា ក្នុងមណ្ឌលមួយនេះទោះជាបេក្ខជនប៉ុន្មានក៏ដោយ តែត្រូវមានវាសនាតែម្នាក់ប៉ុណ្ណោះ សំរាប់យកជាតំណាងបានបន្ទាប់ពីបោះឆ្នោត ។ ប្រព័ន្ធភាគច្រើនក្នុងមណ្ឌលលក្ខណៈរបៀបនេះមានបីប្រភេទគឺ[៣៨] : (**មើលរូបទី ១០**)

**ក១.១. ប្រព័ន្ធឯកត្តនាមធម្មតា** (Simple majority or "first-Past-the-post") : គឺជាប្រព័ន្ធមួយដែលបេក្ខជនម្នាក់បានទទួលសំលេងលើសគេទាំងអស់ នៃចំនួនសំលេងគួរប្រជែងដទៃ ។ ប៉ុន្តែក្នុងករណីខ្លះ លទ្ធផលនៃការបោះឆ្នោតនោះមិនអាចយកជាការបានទេ បើសិនជាចំនួនសំលេងនៃបេក្ខជន ២ នាក់ ឬលើសពីនេះទទួលសំលេងស្មើគ្នា. ក្នុងករណីនេះអង្គការនីតិបញ្ញត្តិជាអ្នកដោះស្រាយវាសនា។ ប្រព័ន្ធនេះមានការប្រើប្រាស់ក្នុងចក្រភពអង់គ្លេសផងដែរ ។ ប្រព័ន្ធភាគច្រើនធម្មតានេះ គឺគេចាប់រាប់យកចំនួនសំលេងចាប់ពី ២៥ ភាគរយ នៃសំលេងទាំងអស់របស់បេក្ខជនក្នុងមណ្ឌល

[៣៨]. Electoral System, World-Wide Comparative Study, Page 6 ។

នីមួយៗ។ មានប្រទេសជាច្រើនក្នុងពិភពលោកបានប្រើប្រាស់ ដូចជាបណ្តាប្រទេសដែលជាសហគមន៍ (Commonwealth) របស់ចក្រភពអង់គ្លេសជាដើម ។ ចំពោះប្រទេសមួយចំនួន ដូចជា (Gabon, Congo, Camoros) ប្រើប្រព័ន្ធនេះក្នុងទឹកទីពីរ (Second round) ។

**ក.១.២. ប្រព័ន្ធឯកត្តនាមដាច់ខាត** (Absolute Majority) : ប្រព័ន្ធភាគច្រើនដាច់ខាតនេះ គឺជាប្រព័ន្ធដែលបេក្ខជនម្នាក់បានទទួលសំលេងឆ្នោតលើសគេ គឺមានន័យថាលើសពីពាក់កណ្តាល នៃ **ចំនួនទាំងអស់** (ចាប់ពីលើសពាក់កណ្តាលឡើងទៅ)។ ប្រព័ន្ធនេះមានប្រើនៅប្រទេស Congo, Comoros,France,ដែលវាអាចប្រើជាមួយគ្នាបន្ទាប់ពីប្រព័ន្ធឯកត្តនាមធម្មតា(Simple Majority) ព្រោះវាអាចមានសល់បេក្ខជនប្រជែងលើសពីមួយរូប (Run-off Election) ដែលមានសំលេងច្រើន ក្នុងលទ្ធផលនៃការបោះឆ្នោតនៅទឹកទីមួយ ។ គេប្រើនៅប្រទេស Belarus, Haiti, Macedonia, Moldova, Ukraine. ផងដែរ ។

ពាក្យថាចំនួនទាំងអស់ដែលបានប្រើនៅខាងលើវាមានន័យបីយ៉ាង ដោយអាស្រ័យទៅនឹង ការកំណត់នៃច្បាប់របស់ប្រទេសនីមួយៗ គឺន័យនីមួយៗនោះមាន :

- ចំនួនទាំងអស់ ឬចំនួនសរុប : ជាចំនួនដែលអ្នកបោះឆ្នោតបានចុះឈ្មោះ (លក្ខណៈ របៀបនេះកំរមានជួបប្រទះណាស់)។
- ចំនួនទាំងអស់ ឬចំនួនសរុប : មានន័យថាជាចំនួនសំលេងដែលបានបោះឆ្នោត។
- ចំនួនសរុប ឬចំនួនទាំងអស់ : មានន័យថាជាចំនួនសំលេងដែលបានការ ។ អញ្ចឹង ហើយបានជាក្នុងច្បាប់បោះឆ្នោតគេត្រូវលំអិតអំពីចំនួននេះឯង ព្រោះជៀសវាងនូវការប្រឈមមុខ គ្នា បន្ទាប់ពីដំណើរការបោះឆ្នោតរួច ។

**ក.១.៣. ប្រព័ន្ធឯកត្តនាមដែលមានលក្ខណៈជំរើស** (Alternative or Preferential) : នេះ គឺជាប្រព័ន្ធមួយ ដែលក្នុងនោះបេក្ខជនទាំងឡាយណាដែលបានទទួលនូវលក្ខណៈសម្បត្តិគ្រប់គ្រាន់ ភាគច្រើននៃសំលេងឆ្នោតទាំងអស់ ត្រូវបានគេយកមកធ្វើការជ្រើសរើស ។ លក្ខណៈសម្បត្តិគ្រប់ គ្រាន់ភាគច្រើន ឬលក្ខណៈភាគច្រើនណានោះត្រូវបានគេកំណត់ក្នុងច្បាប់យ៉ាងច្បាស់លាស់ ឬក៏នៅ ក្នុងករណីដែលត្រូវធ្វើឱ្យមានសំលេងភាគច្រើនដាច់ខាតកើនឡើងចំពោះបេក្ខជន ។ ប្រព័ន្ធនេះបាន

ទទួលលទ្ធផលតិចតួចជាងប្រព័ន្ធភាគច្រើនដាច់ខាត ព្រោះគេពុំសូវយកវាមកប្រើទេ ។ វិធីនេះមានភាពសាំញ៉ាំច្រើនបំផុតដែលអាចមានភាពទំនាស់គ្នាទៀតផង ។ ចំពោះប្រព័ន្ធដែលប្រកាន់លក្ខណៈសំលេងជ្រើសរើស (Alternative Vote) នេះ គឺថាប្រទេសទាំងឡាយដែលប្រកាន់លក្ខណៈនេះតំរូវឱ្យអ្នកបោះឆ្នោត (Voters) ត្រូវកំណត់នូវបំណងប្រាថ្នារបស់គេនៅលើសន្លឹកឆ្នោតទាំងអស់របស់ពួកគេនៅពេលទៅបោះឆ្នោត ។ អ្នកបោះឆ្នោតសរសេរនៅលើសន្លឹកឆ្នោតនៅផ្នែកខាងក្រោយ បើដាក់លេខមួយមានន័យថាជំរើសតែម្តងគត់សំរាប់គេ និងសរសេរបៀបនេះជាលេខ ២.៣. ជាបន្តបន្ទាប់តាមការពេញចិត្តរបស់អ្នកបោះឆ្នោត ទៅលើបេក្ខជនឈរឈ្មោះ ។ កាលបើសន្លឹកឆ្នោតទាំងអស់នោះបានបូកសរុបលទ្ធផលរួច. ហើយគ្មានបេក្ខជនណាមួយបានទទួលសំលេងច្រើនដាច់ខាត នោះបេក្ខជនដែលមានសំលេងគាំទ្រតិចជាងគេត្រូវលប់ចោល រីឯបេក្ខជនទាំងឡាយណាដែលមានសំលេងគាំទ្រភាគច្រើន ដោយប្រហាក់ប្រហែលនោះនឹងត្រូវមានសិទ្ធិរាប់ឡើងវិញតាមសន្លឹកឆ្នោត ។ សន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតនោះនឹងត្រូវរាប់ឡើងវិញជាបន្តបន្ទាប់ ដោយអាស្រ័យនឹងការជំរើសចាប់ពីសំលេងគាំទ្រពាក់កណ្តាលឡើងទៅនៃសំលេងសរុបទាំងនោះ ។ ការរាប់នេះធ្វើបានតែក្នុងល័ក្ខខ័ណ្ឌដែលអ្នកបោះឆ្នោតណាសរសេរតែលេខ ១ គឺសន្លឹកឆ្នោតនោះពុំអាចយកទៅរាប់លើកទី ២ ឬទីបន្តបន្ទាប់បាននោះទេ ។ ការធ្វើរបៀបនោះ បន្តធ្វើរហូតដល់អ្នកឈ្នះទទួលបានសំលេងលើសពីពាក់កណ្តាលនៃសំលេងសរុបទាំងអស់ ។ ប្រព័ន្ធនេះបានប្រើប្រាស់សំរាប់ការបោះឆ្នោតនៅសភាជាន់ទាប (សភាតំណាងរាស្ត្រ) របស់ប្រទេសអូស្ត្រាលី នៅឆ្នាំ ១៩១៨ ។

**ក₂.ក្រុមទីពីរ : មណ្ឌលពហុនាម** (Multi-member constituency) : ប្រព័ន្ធភាគច្រើនដែលប្រើប្រាស់តាមលក្ខណៈមណ្ឌលពហុនាម ឬពហុអាសនៈនេះមានពីរប្រភេទខុសៗគ្នា ដែល ប្រទេសជាង ៣០ នៅលើពិភពលោកនិយមប្រើនោះគឺ :

**ក₂.₁. ប្រព័ន្ធសំលេងភាគច្រើនក្នុងមណ្ឌលពហុនាម** (Multi-member constituency Majority Vote): ប្រព័ន្ធរបៀបនេះ ប្រព្រឹត្តិទៅនៅពេលដែលបេក្ខជនទាំងអស់ប្រលងប្រជែងគ្នាជាលក្ខណៈដោយឡែក។ ប្រព័ន្ធរបៀបនេះអ្នកបោះឆ្នោតទាំងអស់សរសេរឈ្មោះ (គូសឈ្មោះ) បេក្ខជនទាំងនោះដែលត្រូវគេជ្រើសរើសនៅលើសន្លឹកឆ្នោតនោះ ប៉ុន្តែពុំសរសេរឈ្មោះឱ្យលើសពីចំនួនដែល

មានចុះក្នុងបញ្ជីនោះទេ ។ បេក្ខជនទាំងឡាយណាដែលបានទទួលចំនួនសំលេងច្រើនជាងគេ នោះត្រូវបានជាប់ឆ្នោត ។ និងបេក្ខជនជាប់លេខ ២ ឬលេខបន្តនោះ គឺពិនិត្យតាមចំនួនសំលេងពីខ្ពស់បំផុតមកជាបន្តបន្ទាប់ ។

**ក₂.₂. ប្រព័ន្ធសំលេងគណៈបក្ស** (Party-List Vote) : ប្រព័ន្ធនេះវាកើតមានកាលណាបេក្ខជនទាំងនោះប្រមូលជាក្រុម ដោយផ្តុំជាកំលាំងនយោបាយដោយឡែក១ពីគ្នា ក្នុងមណ្ឌលមួយ (Political affiliations) ។ ពេលដែលប្រព័ន្ធនេះ បានត្រូវប្រើប្រាស់ជាមួយសំលេងភាគច្រើនមួយ (a majority vote) គឺមានន័យថាបក្សនយោបាយណាដែលមានសំលេងភាគច្រើន ត្រូវបានទទួលកៅអីក្នុងមណ្ឌលនោះ ។ ការបោះឆ្នោតរបៀបនេះ ធ្វើឡើងតាមរយៈឆន្ទៈផ្ទាល់របស់ពលរដ្ឋទៅលើគណៈបក្ស ពុំមែនធ្វើទៅលើបុគ្គលទេ ។

**ខ. ប្រព័ន្ធសមាមាត្រ ឬប្រព័ន្ធតំណាងសមាមាត្រ** (Proportional Representation System): នេះជាប្រព័ន្ធបោះឆ្នោតមួយ ដែលកើតក្រោយប្រព័ន្ធបោះឆ្នោតតាមបែបឯកត្តនាម (Majority System) ប៉ុន្តែក៏វាមានការរីកចំរើនខ្លាំងដែរ ដែលប្រព័ន្ធនេះបានចូលរួមបកស្រាយដំបូងបំផុត (ដំណើរការ) នៅប្រទេសប៊ែលស៊ិក (Belgium) ឆ្នាំ១៨៨៩ ហើយសព្វថ្ងៃមានប្រទេសប្រហែល ៥៧ កំពុងអនុវត្តន៍ ។ ប្រព័ន្ធនេះមានប្រភេទគ្រឹះសំខាន់១ពីរគឺ : ប្រព័ន្ធបញ្ជីបក្សនយោបាយ (Party List System) និងប្រព័ន្ធផ្ទេរសំលេងឆ្នោតម្នាក់ (Single transferable Vote System) ។ (មើលតារាងទី ៣ ជាឧទាហរណ៍ សំរាប់ Single Transferable Vote System) ។

**ខ₁. ប្រព័ន្ធបញ្ជីបក្ស** : នេះគឺជាប្រព័ន្ធមួយដែលមាននៅក្នុងមណ្ឌលបោះឆ្នោតមួយ (An Electoral district) ដោយអ្នកបោះឆ្នោតទាំងអស់ (Voters) ត្រូវជ្រើសរើសតំណាងរបស់ខ្លួន ដែលអ្នកតំណាងទាំងអស់នោះជាបេក្ខជននានា ហើយត្រូវបានបញ្ជូនមកដោយគណៈបក្សផ្សេង១ ដើម្បីប្រលងប្រជែងក្នុងការបោះឆ្នោត ។ កាលដែលសំលេងឆ្នោតបានត្រូវសរុបរួចមក បក្សនីមួយ១មានសិទ្ធិទទួលយកកៅអីទៅតាមភាគនៃការគាំទ្ររបស់សំលេងពលរដ្ឋមកពីគណៈបក្សខ្លួន ស្របតាមចំនួនដែលមានអាសនៈសរុបនៅក្នុងអង្គនីតិបញ្ញត្តិ ។

ប៉ុន្តែក្នុងប្រព័ន្ធបញ្ជីបក្សនេះ វាជាសិទ្ធិមួយរបស់បក្សនយោបាយផងដែរ ដែលក្នុងនោះ**មេបក្ស**ជាអ្នកចាត់តាំងលើបុគ្គលផ្សេងៗឱ្យឈរបេក្ខជន ដើម្បីធ្វើជាតំណាងឱ្យបក្សនោះក្នុងការចូលទៅកាន់តំណែងជាតំណាងរាស្ត្រ ដែលមានពេលខ្លះក៏មានការអាក់អន់ចិត្តពីអ្នកបោះឆ្នោត ឬក៏ម្ចាស់សន្លឹកឆ្នោតខ្លះពុំស្គាល់តំណាងរបស់ខ្លួនទៀតផង ។ ដោយមានការប្រឈមបែបនេះ ក្នុងប្រព័ន្ធបក្សរបៀបនេះ គេសង្កេតឃើញមានគោលការណ៍ពីរសំរាប់កំណត់ទៅលើអ្នកបោះឆ្នោត និងគណៈបក្សគឺ:

**ទីមួយ :** អ្នកបោះឆ្នោតទាំងអស់ (Voters) មានជំរើសតែមួយគត់ ( មានសំលេងមួយ) ក្នុងចំណោមបេក្ខជនទាំងអស់ ប៉ុន្តែបេក្ខជនទាំងនោះត្រូវតែមានចំនួនតែម្នាក់គត់ មកពីគណៈបក្សនីមួយៗ ។ ផ្ទុយទៅវិញ បើមានបេក្ខជនច្រើននាក់បញ្ជូនមកពីគណៈបក្សនីមួយៗនោះ បេក្ខជនត្រូវតែរៀបតាមលំដាប់លេខរៀងឱ្យបានច្បាស់លាស់ ហើយបញ្ជូនមកគណៈកម្មការទទួលបន្ទុកកិច្ចការបោះឆ្នោតឱ្យបានមុនពេលដំណើរការបោះឆ្នោត ដោយមានទាំងបិទរូបថតនៅតាមមណ្ឌលទាំងនោះទៀតផង ។

**ទីពីរ :** អ្នកបោះឆ្នោតទាំងអស់ត្រូវបានអនុញ្ញាតឱ្យមានជំរើសជាច្រើនរបស់គេ ទៅលើគណបក្ស ឬក៏ហៅថាមានលក្ខណៈដូចជាចំរុះ (Panachage) ផងដែរ ។ នៅក្នុងលក្ខណៈនេះមានបេក្ខជនជាច្រើន ដែលមកពីគណៈបក្សនីមួយៗ ។ ជាទូទៅគោលការណ៍គ្រឹះនៃប្រព័ន្ធបញ្ជីបក្ស (Party List System)នេះ អនុវត្តមានតាមមូលដ្ឋានគ្រឹះមួយគឺបក្សនយោបាយទាំងអស់ ត្រូវបែងចែកកៅអីតាមរយៈសំលេងឆ្នោតរបស់រាស្ត្រដែលបក្សទាំងនោះបានទទួល ។ ត្រង់ចំណុចនេះបញ្ជាក់ថា ការទទួលបានអាសនៈនៅក្នុងអង្គនីតិបញ្ញត្តិរបស់បក្សនីមួយៗ គឺអាស្រ័យនឹងភាគរយនៃការគាំទ្រក្នុងមណ្ឌលនីមួយៗ ។

ដូចនេះការបែងចែកកៅអី (Seat Allocation) ក្នុងប្រព័ន្ធបញ្ជីបក្សមានពីរករណីគឺ : ប្រព័ន្ធសំណល់ធំ (Largest Remainder System) និងប្រព័ន្ធមធ្យមភាគខ្ពស់ (Highest Average System) ( **មើលរូបទី ១០**) ។

**៩.១. ប្រព័ន្ធសំណល់ធំ** (Largest Remainder System) : ក្នុងប្រព័ន្ធនេះជំហានដំបូងត្រូវកំណត់ចំណែកកូតា (quota) ឬក៏កំរិតនៃចំនួនសំលេង (Threshold of votes) ដែលបក្សនីមួយៗត្រូវទទួលក្នុងមួយកៅអី (a seat) ។ ឧទាហរណ៍ សំលេងឆ្នោតសំរាប់បក្សនីមួយៗគឺបានបែងចែក ដោយចំនួនកំរិតទៅលើការជ្រើសរើសកំណត់មួយយ៉ាងជាក់លាក់ (Electoral quota)[៣៩] ឬហៅថាកូតាជ្រើសរើស ឬហៅថាចំនួនសំលេងជ្រើសរើស ។ នៅក្នុងការជ្រើសរើសតាមកូតានេះមានវិធី ៦ យ៉ាងខុសៗគ្នា[៤០] គឺ :

**៩.១.១. វិធីទីមួយ :** កូតាធម្មតា ឬហៅថាកូតាហែរ (Simple or Hare quota): នៅឆ្នាំ ១៨៥៥ វិធីនេះបានត្រូវមេធាវីអង់គ្លេសម្នាក់ឈ្មោះ Thomas Hare បង្កើតឡើងដោយ ប្រើរូបមន្ត X : Y (X ជាចំនួនសំលេងឆ្នោតសរុបនៃសំលេងបានការ ដែលបានបោះនៅក្នុងមណ្ឌលមួយ, Y ជាចំនួនកៅអីដែលមានក្នុងមណ្ឌលមួយ) ។ ការប្រើរូបមន្តនេះ គេធ្វើឡើងតាមមណ្ឌលបោះឆ្នោតនីមួយៗដែលមានកំណត់ក្នុងប្រទេស ។ ឧទាហរណ៍ក្នុងមណ្ឌលបោះឆ្នោតមួយមាន ៥ កន្លែង ដែលត្រូវអង្គុយ និងមាន ៤០០០០ សំលេងដែលបានបោះ, ដូចនេះចំនួនកូតា (quota) នឹងស្មើ ៨០០០ សំលេង ។ ដោយប្រើរូបមន្ត $quota = \frac{X}{Y} = \frac{40000}{5} = 8000$ មានន័យថាមួយកៅអី ត្រូវការចាំបាច់នូវ ៨០០០ សំលេងយ៉ាងតិចរបស់អ្នកបោះឆ្នោត ដើម្បីបានអាសនៈមួយនៅសភា (មើលតារាងទីមួយ ជំហានទីមួយ) ។នៅក្នុងវិធីកូតាហែ (Hare quota) គេប្រើរូបមន្ត $Harequota = \frac{Votes}{Seats}$ ។

**៩.១.២. វិធីទីពីរ :** កូតាហាស៊ិនបាច់ប៊ីស្ហូ (Hagenbach-Bischoff quota) គឺ $\frac{Votes}{Seats+1}$ នេះជារូបមន្តរបស់សាស្ត្រាចារ្យអង់គ្លេស ( Hagenbach-Bischoff) ក្នុងឆ្នាំ ១៨៨៨ គឺប្រើរូបមន្ត X : (Y+1) ឬរូបមន្ត : $\frac{Votes}{Seats+1}$ ។ មានន័យថាចំនួនសំលេងឆ្នោតបានការ ដែល

---

[៣៩]. Electoral quota គឺជាចំនួនសំលេងឆ្នោតតិចបំផុតដែលចាំបាច់សំរាប់ជ្រើសរើសបេក្ខជនម្នាក់ឱ្យទទួលអាសនៈមួយក្នុងអង្គការនីតិបញ្ញត្តិ ។

[៤០]. Electoral System.World-wide comparative study.Page 9 ។

បានបោះសរុបក្នុងមណ្ឌលមួយយកមកចែកនឹងចំនួនកៅអី ហើយបន្ថែមមួយឯកតាទៅលើចំនួនកៅអីដែលប្រើក្នុងមណ្ឌលបោះឆ្នោតមួយ (a constituency) ។ គេប្រើនៅប្រទេស Malta, Austria, Greece, Luxembourg, និង Switzerland ។ ដូចនេះរូបមន្តកូតាហាស៊ិនបាច់ប៊ីស្កហ្វ គឺ : quota $= \frac{Votes}{Seats+1}$ ។

**ខ១.១.៣. វិធីទីបី** : កូតាដ្រូព (Droop quota). ជារូបមន្តដែលប្រើក្នុងមណ្ឌលបោះឆ្នោតមួយដែរ ប៉ុន្តែមានវិធីផ្សេងពីលោកហាស៊ិនបាច់ប៊ីស្កហ្វ គឺថាលោក Droop បានបង្កើតរូបមន្តនៅឆ្នាំ ១៨៦៨ ជាជនជាតិអង់គ្លេសដែរ ។ គេប្រើនៅប្រទេសអៀរឡង់ (Ireland), ហើយរូបមន្តរបស់លោកដ្រូបគឺ : Droop quota $= \left[\frac{Votes}{Seats+1}\right] + 1$ ។ រូបមន្តនេះ គឺលោកដ្រូបថែមមួយឯកតាលើលទ្ធផលនៃវិធីរបស់ហាស៊ីនប៊ិចប៊ីស្កហ្វ ។

**ខ១.១.៤. វិធីទីបួន** : កូតាអ៊ិមពីរីយ៉ាល (Imperiali quota). រូបមន្តនេះជារបស់ជនជាតិអ៊ីតាលី គឺថាយកចំនួនសំលេងឆ្នោតសរុបចែកនឹងចំនួនកៅអី ដោយបន្ថែមពីរឯកតាទៅលើចំនួនកៅអីក្នុងមណ្ឌលមួយគឺ : Imperiali quota $= X : Y + 2 or \frac{Votes}{Seats+2}$ ។ កូតាប្រភេទនេះគេប្រើនៅប្រទេសអ៊ីតាលី ។

**ខ១.១.៥. វិធីទីប្រាំ** : កូតាទ្វេភាព (Double quotient). នេះជាកូតាមួយដែលគេអាចទទួលយកបាន តាមការធ្វើប្រតិបត្តិការមួយដោយមានពីរដំណាក់កាល (a two-stage operation) ។ ដំណាក់ទីមួយគឺកូតាទីមួយ (First electoral quotient): កូតានេះត្រូវមើលបញ្ជីបក្សណាដែលទទួលសំលេងដ៏ច្រើនហួសប្រមាណ ដែលមានចំនួនកំណត់មួយច្បាស់លាស់ក្នុងការបែងចែកកៅអី គឺមានន័យថាយកតែបក្សណាដែលមានសំលេងគាំទ្រលើសពីចំនួនកូតា សំរាប់មួយកៅអីដែលបានគណនារួចពីដំបូង ។ រីឯកូតាទីពីរ (a second electoral quotient) គឺយកសំលេងដែលសល់របស់បក្សនីមួយៗដែលបានគណនារួចពីដំណាក់ទីមួយនោះធ្វើជាកូតាលើកទី ២ ។ ក្នុងជំហានទីពីរនេះ បើមានគណៈបក្សណាមានសំលេងច្រើនចាត់ទុកថាបានកៅអីជាបន្តបន្ទាប់ រហូតដល់អស់អាសនៈក្នុងមណ្ឌល

នោះ។ (ចូរពិនិត្យមើលតារាងទីមួយ ជំហានទីពីរ)។ គេប្រើកូតានេះនៅប្រទេស Bolivia, Costa Rica, Ecuador ។

**ខ១.១.៦.វិធីទីប្រាំមួយ :** ចំនួនដូចគ្នាតែមួយ ឬហៅថាកូតាឯកភាព (Uniform quotient). នេះជាចំនួនកូតាមួយដែលគេកំណត់នៅមុនពេលដំណើរការបោះឆ្នោត ប្រសើរជាងក្រោយពេលបោះឆ្នោត ដោយការកំណត់ចំនួននោះមិនអាស្រ័យនឹងចំនួនណាមួយ ឬក៏ទំហំមណ្ឌលបោះឆ្នោតទេ។ គឺថាត្រូវកំណត់យកកូតាមួយជាមុនសិន ហើយប្រើវានៅគ្រប់មណ្ឌលបោះឆ្នោតទូទាំងប្រទេស ។ ការកំណត់កូតាជាមុននេះ ជាការប្រថុយមួយរបស់បក្សដែលចូលរួមក្នុងការបោះឆ្នោត ។ កូតារបៀបនេះពុំសូវមានការប្រើប្រាស់ទេ ។

**ខ១.២. ប្រព័ន្ធមធ្យមភាគខ្ពស់** (Highest Average System) : ប្រព័ន្ធមធ្យមភាពខ្ពស់នេះគឺគេយកសំឡេងឆ្នោតនៃគណៈបក្សនីមួយៗ មកចែកនឹងមេចែកដែលគេព្រមព្រៀងជាមុន ។ ដោយយោងតាមមេចែកខុសៗគ្នានោះ ទើបប្រព័ន្ធមធ្យមភាគខ្ពស់នេះធ្វើឡើងតាមទស្សនៈបីប្រភេទខុសៗគ្នាគឺ :

**ខ១.២.១. ប្រព័ន្ធមធ្យមភាគខ្ពស់តាមទស្សនៈហុនដ៍** (The Highest Average System d' Hondt version) : លោក Victor d' Hondt ជាសាស្ត្រាចារ្យ បានសំណូមពរនូវទស្សនៈរូបមន្តរបស់គាត់ នាឆ្នាំ ១៨៨២ គឺថាគាត់ប្រើរូបមន្តនោះដោយយកសំលេងឆ្នោតទាំងអស់របស់បក្សនីមួយៗ ហើយចែកវាទាំងនោះនឹងចំនួន ១ ; ២ ; ៣ ; ៤ ; .......... ជាបន្តបន្ទាប់ ។ល។ គេប្រើនៅប្រទេសអាល្លឺម៉ង់, បែលស៊ិច, ប៉ូឡូញ, អាសង់ទីន, (មើលតារាងទី ២ និងទី ៦) ។

ដូចនេះ $\text{Hond't} = \dfrac{Votes(Party)}{1;2;3;4;5;.......}$

**ខ១.២.២. ប្រព័ន្ធមធ្យមភាគខ្ពស់តាមបែប** Sainte-Lague និង Saint-Lague Modified versions : ប្រព័ន្ធទាំងពីរគឺ Sainte-Lague និង Saint-Lague Modified Systems បានប្រើខុសពីរូបមន្ត d' Hondt System។ ក្នុងនោះគឺប្រព័ន្ធ Saint-Lague Systems: ត្រូវយកសំលេង

ឆ្នោតសរុបរបស់បក្សនីមួយៗ ចែកនឹងចំនួនសេស ១ ; ៣ ; ៥ ; ៧ ............។ល។ (មើលតារាងទីបួន)។ មានប្រើនៅប្រទេស Norway, Poland (ចំនួនកៅអីភាគខ្លះ)។ ដូចនេះតាមរូបមន្ត

$$\text{Saint - Lague} = \frac{Votes(Party)}{1;3;5;7;.........}$$

**ខ១.២.៣. ប្រព័ន្ធមធ្យមភាគខ្ពស់បែប** Saint-Lague Modified Systems : គឺត្រូវយកភាគបែងជាចំនួន (១.៤) ជំនួសកន្លែង ១ វិញគឺ division នឹងមាន : (១.៤) ;៣;៥;៧........។ល។ (មើលតារាងទី ៥) មានប្រើនៅប្រទេស Denmark, Sweden ។ Saint-Lague ជាអ្នកប្រាជ្ញបារាំងម្នាក់ដែលសំណូមពរឱ្យប្រើរូបមន្តនេះនៅឆ្នាំ ១៩១០ ។ ដូចនេះការប្រើរូបមន្តបែបទស្សនះ

$$\text{Saint - Lague Modified} = \frac{Votes(Party)}{(1,4);3;5;7;9;....}$$

**ខ២. ប្រព័ន្ធផ្ទេរសំលេងឆ្នោត** (Single Transferable Vote Systems) រឺអក្សរកាត់ (S.T.V) : ភាពខុសគ្នាចំពោះប្រព័ន្ធបញ្ជីបក្ស (Party List System) គឺថា (S.T.V.) ជាប្រព័ន្ធមួយដែលបញ្ជាក់នូវចំនួនបេក្ខជនម្នាក់ៗ (Individual Candidate) យ៉ាងច្បាស់លាស់ជាងតាមបក្សនយោបាយនីមួយៗទៅទៀត ។ មានន័យថាគេគិតចំនួនសំលេងចំពោះបេក្ខជនដែលឈរឈ្មោះតំណាងរាស្ត្រនៃមណ្ឌលបោះឆ្នោត (បើគណៈបក្សណាទទួលបានមួយអាសនះហើយ គណៈបក្សនោះគេបញ្ឈប់រាប់តទៅទៀតហើយ) ។ ប្រព័ន្ធនេះគឺអ្នកបោះឆ្នោតទាំងអស់ក្នុងមណ្ឌលមួយ មានសិទ្ធិជ្រើសរើសរបស់ពួកគេក្នុងចំណោមបេក្ខជនទាំងអស់នោះ ដោយសរសេរឈ្មោះនៃបេក្ខជននៅលើសន្លឹកឆ្នោត និងសញ្ញាលើកទី ១.២.៣.........។ល។ ពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់. ជំហានទីមួយដោយដាក់វាតាមប្រភេទនៃជំរើសលើកទីមួយ ។ ក្នុងខណៈរបៀបនេះជាការគួរអាចប្រកាសនូវបេក្ខជនដែលបានត្រូវជ្រើសរើសនោះ (បេក្ខជនម្នាក់ត្រូវតែទទួលសំលេងខ្ពស់ជាងគេ ក្នុងចំណោមសំលេងឆ្នោតទាំងអស់ដែលបានរាប់លើកទីមួយ)។ បេក្ខជនទាំងអស់ដែលទទួលសំលេងខ្ពស់ (សំលេងខ្ពស់នានាបន្ទាប់ពីសំលេងដែលជាប់ឆ្នោត) ក្នុងរយៈពេលជំហានដំបូងនៃការរាប់ចំនួនដំបូងត្រូវបានប្រកាសឱ្យរាប់ឡើងវិញជាបន្តបន្ទាប់ ដោយអាស្រ័យនឹងសញ្ញាដែលគេ (អ្នកបោះឆ្នោត) បានដាក់លើសន្លឹកនោះចំពោះជំរើសលើកទីពីរ ឬទីបន្តបន្ទាប់ ។ ជំហានទីពីរនៃការរាប់ចំនួន ដោយ

ទាក់ទិននឹងសញ្ញាណជំរើស (១,២,៣.........) នៃចំនួនឆ្នោតដែលច្រើនបំផុត (These "Surplus" ballots) ។ បេក្ខជនទាំងអស់ដែលបានបំពេញនូវតំរូវការនោះ ត្រូវបានប្រកាសជាប់ឆ្នោតហើយ និងសំលេងដែលច្រើនបំផុត (Surplus Votes) ដែលត្រូវបានធ្វើ ។ ការធ្វើរបៀបនេះបន្តរហូតដល់គ្រប់កៅអីដែលមាន ។ នៅក្នុងប្រព័ន្ធ S.T.V. នេះ ក្នុងមណ្ឌលមួយមានគណៈបក្សច្រើនមែន ប៉ុន្តែគណៈបក្សនីមួយៗអនុញ្ញាតិឱ្យបេក្ខជនឈរតំណាងតែមួយប៉ុណ្ណោះ ។ ចំណែកអ្នកទៅបោះឆ្នោតទាំងអស់ធ្វើឡើងតែម្តងគត់ គ្រាន់តែពួកអ្នកទាំងនោះមានសិទ្ធិជំរើសច្រើន ឬតិចលើក តាមការកំណត់របស់អង្គការបោះឆ្នោត ។

ជាឧទាហរណ៍គេអាចប្រើប្រព័ន្ធ S.T.V. (មើលតារាងទី ៣) តាមរយៈរូបមន្ត Droop quota ក្នុងកិច្ចការនៃមណ្ឌលបោះឆ្នោតមួយមាន ៣ កៅអី និងមានសំលេងសរុប ១០០០ ដូចនេះអ្នកដែលឈ្នះត្រូវមានសំលេង :

Droop quota $= \frac{Votes}{Seats+1} + 1 = \frac{1000}{3+1} + 1 = \frac{1000}{4} + 1 = 250 + 1 = 251$ សំលេង ។ ប្រព័ន្ធ S.T.V ប្រើសំរាប់បោះឆ្នោតនៅព្រឹទ្ធសភាអូស្ត្រាលី, Malta និងសាធារណរដ្ឋអៀរឡង់ (Ireland) ។ ប្រព័ន្ធ S.T.V នេះមានលក្ខណៈខុសពីប្រព័ន្ធឯកត្តនាម ព្រោះប្រព័ន្ធ S.T.V ត្រូវប្រើរូបមន្ត Droop quota តែប្រព័ន្ធឯកត្តនាម (Majority System) ដែលមានលក្ខណៈមណ្ឌលឯកត្តនាម បែប Alternative វាពុំត្រូវការកូតាទេ ។

**ឥ. ប្រព័ន្ធចំរុះ** (Mixed System) : ប្រព័ន្ធនេះមានប្រហែលប្រទេស ៣០ និយមប្រើ ។ នៅក្នុងបណ្តាប្រទេសខ្លះដើម្បីបានផលចំណេញ និងធ្វើឱ្យមានស្ថេរភាពក្នុងសង្គមរបស់គេ និងធ្វើឱ្យលទ្ធផលនៃការបោះឆ្នោតពុំមានអាក់អន់ចំពោះបក្ស ឬក៏អ្នកនយោបាយក្នុងប្រទេសរបស់គេនោះ គេបង្កើតច្បាប់ដើម្បីជាគោលការណ៍រួមក្នុងការអនុវត្តទៅលើប្រព័ន្ធចំរុះ ។ ប្រព័ន្ធចំរុះនេះគឺថាលេចចេញមកពីផ្សំធាតុគ្នានៃប្រព័ន្ធឯកត្តនាម និងប្រព័ន្ធសមាមាត្ររួមបញ្ចូលគ្នា ជាឧទាហរណ៍ពីឆ្នាំ ១៩៤០ នៅអាល្លឺម៉ង់ មានការបោះឆ្នោតដោយប្រើប្រព័ន្ធចំរុះក្នុងពេលជ្រើសរើសសភាជាន់ទាប (Bundestag) ឬសភាតំណាងរាស្ត្រ ។ គឺថាចំនួនតំណាងរាស្ត្រពាក់កណ្តាលត្រូវជ្រើសរើសតាមប្រព័ន្ធឯកត្តនាម

**ក១. ការគណនា :** តាមរូបមន្ត $q = \frac{V}{S} = \frac{20000}{4} = 5000$ សំលេង

ដូចនេះជំហានទីមួយ : $A = \frac{8200}{5000} = 1$ កៅអីនិងសល់ ៣២០០ សំលេង នៅជំហានទីពីរ គឺកៅអីទី ① ។

$B = \frac{6100}{5000} = 1$ កៅអីនិងសល់ ១១០០ សំលេង នៅជំហានទីពីរ គឺកៅអីទី ② ។

$C = \frac{3000}{5000} = 0$ កៅអីនិងសល់ ៣០០០ សំលេង នៅជំហានទីពីរ

$D = \frac{2700}{5000} = 0$ កៅអីនិងសល់ ២៧០០ សំលេង នៅជំហានទីពីរ

ដោយសារតែគេគិតតាមសំណល់ធំ ហើយគណនាតាមជំហានដំបូងអស់តែពីរកៅអីប៉ុណ្ណោះ តែនៅសល់កៅអីពីរទៀត ដូចនេះយើងសង្កេតឃើញថា :

ដោយសារតែកៅអីសល់តែ ២ ហើយសំណល់ដែលធំនៅក្នុងជំហានទីពីរ គឺគណៈបក្ស A និង C គឺ : A = 3200, C = 3000

ដូចនេះ A ត្រូវបាន១ កៅអីបន្ថែមទៀត គឺកៅអីទី ③ រីឯ C បានមួយកៅអី គឺកៅអីទី ④ ។ ចំណែកឯកៅអីតាមការគណនាជំហានទីពីររបស់ D ក្នុងល័ក្ខខ័ណ្ឌនៃកូតាថ្មីនោះពុំអាចទាញយកពីគេបានទេ ព្រោះសំណល់របស់ D ក្នុងជំហានទីពីរមានតែ ២៧០០ ប៉ុណ្ណោះ ប៉ុន្តែបើមានកៅអីសល់មួយទៀតនោះ ទើប D អាចទទួលបាន ។

សរុបមកការអនុវត្តរូបមន្តសំណល់ធំ ឬសំណល់ច្រើននេះ វាជាការជូនរង្វាន់មួយដល់គណៈបក្សទន់ខ្សោយផងដែរ ដូចជាគណៈបក្ស C ជាដើម ។

**ក២. ការបកស្រាយ** : តាមឧទាហរណ៍ក្នុងតារាងទីមួយនៃជំហានទីមួយឃើញថា : ប្រសិនបើមួយហៀរកូតា (Hare quota) មានសំលេង ៥០០០ ដែលត្រូវទទួលបានមួយកៅអីនោះយើងឃើញថាគណៈបក្ស A និង B បានទទួលមួយកៅអីម្នាក់ តែនៅសល់សំលេង និងសល់កៅអីពីរទៀត ។ នៅជំហានទីពីរសំណល់កន្លែងខ្លះទៀត (Any Remaining Seats) នឹងត្រូវបែងចែកសំរេចឱ្យ

បានដោយឈរលើគោលការណ៍គ្រឹះនៃបក្សណាមួយ (Wich Party) ឬក៏គណៈបក្សទាំងឡាយ (Parties) ដែលមានសំលេងចំនួនច្រើន (Higest) ដែលបានសល់បន្ទាប់ពីកូតាដែលមានពីជំហានលើកទីមួយ ។ ជំហានទីពីរនេះ គឺត្រូវយកចំនួនឆ្នោតសរុបនៃបក្សនីមួយៗ ដែលបានសល់ពីការគណនាតាមកូតា នៅជំហានទីមួយដែលនាំឱ្យមានសំណល់សំលេង ព្រមទាំងចំនួនកៅអីនៅជំហានទីពីរ ។ ប៉ុន្តែសំលេងរបស់គណៈបក្សដែលពុំមានគ្រប់តាមកូតានៅជំហានទីមួយ ត្រូវចាត់ទុកជា quota សំរាប់យកជាសំលេងកៅអីនៅជំហានទីពីរ ។ ក្នុងសំណល់ជំហានទីពីរនេះត្រូវពិនិត្យមើលតាមលក្ខណៈចំនួនធំនៃសំលេងឆ្នោត (Largest number of Votes) ។ ផ្ទុយទៅវិញ បើជំហានទីមួយបានគណនារួចហើយពុំមានសល់កៅអីទេនោះ គេពុំអាចយកមកធ្វើនៅជំហានទីពីរទេ ទោះបីជាគណៈបក្សខ្លះពុំបានក៏ដោយ ។

- តាមតារាងនេះបញ្ជាក់ថាមានតែបក្ស A និង B ទេ ដែលសំរេចតាមកូតាបោះឆ្នោត (Electoral quota) ដូចនេះមានពីរកៅអីក្នុងចំណោម ៤ កៅអី ត្រូវបានចែកដោយផ្ទាល់ក្នុងជំហានទីមួយ ។ កៅអីទីមួយ ① បានទៅ A និងកៅអីទីពីរ ② បានទៅ B ក្នុងល័ក្ខខ័ណ្ឌនៃកូតា q=5000 សំលេងក្នុងជំហានទី ១ ។

- ក្នុងជំហានទីពីរកៅអីទីបី ③ ត្រូវបានទៅបក្ស A បន្ទាប់ពីវាមានកូតាក្នុងសំណល់ធំ (Largest number of Votes Remaining)។ បក្សដែលមានចំនួនសំណល់ធំទីពីរ (Second Largest number of remaindes Votes) គឺបក្ស C ដែលបានកៅអីទីបួន ④ ក្នុងកៅអីចុងក្រោយ ។ ក្នុងជំហានទីពីរនេះ គេចាត់ទុកសំណល់ធំក្រោយពីគណនារួចពីជំហានទីមួយ ធ្វើជាកូតានៅជំហានទីពីរ ។ ដូចនេះប្រព័ន្ធសំណល់ទូលាយ (The Largest remaindes System) គឺជាការឱ្យរង្វាន់ដល់គណៈបក្ស C តាមចំនួនឆ្នោតតិចតួច បន្ទាប់ពីគណៈបក្សដែលបានសំលេងច្រើនចុងក្រោយក្នុងជំហានទីមួយ ។

- ចំពោះគណៈបក្សដែលពុំមានកូតានៅជំហានទីមួយ នោះសំលេងរបស់បក្សនោះចាត់ទុកជាសំណល់ (Remainder) នៅជំហានទីពីរ ឬហៅថាកូតាទីពីរ (Double quotient)។ ការអនុវត្តតាមរូបមន្តនេះមានប្រយោជន៍សំរាប់គណៈបក្ស ដែលមានសំលេងគាំទ្របង្គួរបន្ទាប់ពីគណៈបក្សធំៗ។

**ខ. ការអនុវត្តន៍លើប្រព័ន្ធមធ្យមភាគខ្ពស់** ( The Higest Average System) : មណ្ឌលបោះឆ្នោត ១ មានកៅអី ៤. មានសំលេងសរុប ២០ ០០០ សំលេង ដោយបែងចែកកៅអីតាម

រូបមន្ត d' Hondt divisors (Four-member constituency, 20 000 Votes, division by d' Hondt divisors.)

**តារាងទី ២**

| បក្ស Party | សំលេង Votes | មេចែក : ១ Divisors:1 | មេចែក : ២ Divisors:2 | មេចែក : ៣ Divisors: 3 | សរុបកៅអី Total Seats |
|---|---|---|---|---|---|
| A | ៨ ២០០ | ៨ ២០០[1] | ៤ ១០០[3] | ២ ៧៣៣ | ២ |
| B | ៦ ១០០ | ៦ ១០០[2] | ៣ ០៥០[4] | ២ ០៣៣ | ២ |
| C | ៣ ០០០ | ៣ ០០០ | ១ ៥០០ | ១ ០០០ | ០ |
| D | ២ ៧០០ | ២ ៧០០ | ១ ៣៥០ | ៩០០ | ០ |
| សរុប Total | ២០០០០ | | | | ៤ |

**ខ១. បកស្រាយ :** ក្នុងតារាងទីពីរនេះបង្ហាញនូវលទ្ធផលខ្លះៗពីតារាងទីមួយ ដោយប្រើរូបមន្ត d' Hondt Higest Average System. ដើម្បីចែកកៅអី។ តាមតារាងឧទាហរណ៍ទី ២ ឃើញថា ចំនួនសំលេងឆ្នោតទាំងអស់ដែលបានទទួលដោយបក្សនីមួយៗ ត្រូវយកមកចែកតាមមេចែកហុងដ៏ d' Hondt divisors (១; ២; ៣....) ។ ក្រោយពីយកសំលេងឆ្នោតរបស់បក្សនីមួយៗ ចែកវានឹងមេចែកនោះមក ត្រូវបានបំពេញកន្លែងទាំងបួន ដោយគិតផលចែកនៃប្រភាគនោះជាកូតានៃមេចែកនីមួយៗ បើផលចែកណាដែលធំជាងគេនឹងទទួលបានកៅអីទីមួយ និងជាបន្តបន្ទាប់តាមផលចែកពីធំមកតូច ។

គណៈបក្ស A ជាមួយនឹងចំនួនកូតាខ្ពស់ (Higest quotient) គឺសំលេង ៨២០០ ដែលឈ្នះបានកៅអីដំបូង[1] បន្ទាប់ចែកនឹងមេចែក ១ និងកូតាទីបីមាន ៤១០០ សំលេង (Third higest quotient) ដែលជាកៅអីទី[3] បន្ទាប់ពីចែកនឹង ២ ។ រីឯគណៈបក្ស B ជាកូតាខ្ពស់លំដាប់ទីពីរមាន

សំលេង ៦១០០ (Second Higest quotient) ដែលទទួលកៅអី[2] បន្ទាប់ពីចែកនឹង ១ និងវាទទួលបានកូតា quotient ចំនួន ៣០៥០ សំរាប់កៅអីទី[4] ចុងក្រោយនោះបន្ទាប់ពីវាចែកនឹង ២ ។

គណៈបក្ស C និង D ហេតុអ្វីក៏មិនទទួលបាន? ពីព្រោះសំលេងរបស់គណៈបក្សទាំងពីរពុំមានកូតាខ្ពស់ទេ ម្យ៉ាងទៀតក៏ពុំមានសល់អាសនៈផងដែរ បន្ទាប់ពីធ្វើការចែកវានឹងមេចែកបន្តបន្ទាប់ ។

ម្យ៉ាងទៀតប្រព័ន្ធនេះគេអាចចែកកៅអីបាន លុះត្រាតែផលចែករវាងសំលេងបក្សនីមួយៗជាមួយនឹងមេចែកបន្តបន្ទាប់មាន**មធ្យមភាគធំ** ទើបអាចមានលទ្ធភាព ។

វិធីចែកនឹងមេចែកជាបន្តបន្ទាប់រហូតដល់អស់កៅអី ដោយពិនិត្យលើ quota នៃផលចែកក្នុងមេចែកនីមួយៗតាមគណៈបក្ស ។

តាមរូបមន្ត d'Hondt មានផលប្រយោជន៍ច្រើនចំពោះបក្សនយោបាយដែល**មានសំលេងច្រើន ប៉ុន្តែឧទាហរណ៍ខាងលើនេះ ពុំចង្អុលបង្ហាញអំពីរូបមន្តទៅលើភាពទូលាយនៃភាពសមាមាត្រនោះទេ** (a Large measure of proportionality)។ **យើងអាចឃើញនូវលក្ខណៈសមាមាត្រដ៏ប្រសើរជាងនេះ តាមការប្រៀបធៀបក្នុងតារាងទី ៤, ទី ៥, ទី ៦**។ យើងពិនិត្យតាមរូបមន្តសំណល់ធំនៃតារាងទី ១ នោះគណៈបក្ស C បានមួយកៅអីផងដែរ ប៉ុន្តែតាមរូបមន្ត**មធ្យមភាគធំនៃទស្សនៈហុងដ៏** គណៈបក្ស C ពុំមានទទួលកៅអីទេ ។ ត្រង់ចំណុចនេះហើយបានបញ្ជាក់ថា ពុំមានលក្ខណៈសមាមាត្រដែលសរុបលទ្ធផល A បាន ២ កៅអី និង B បាន ២ កៅអី ។

**ខ. ការអនុវត្តន៍ប្រព័ន្ធផ្ទេរសំលេងឆ្នោត** (Single Transferable Vote System) : មណ្ឌលបោះឆ្នោតមួយមាន ៣ កៅអី, មានចំនួន ១០០០ សំលេង និងមាន ៥ បេក្ខជនមកពីគណៈបក្សនីមួយៗ ដោយបែងចែកកៅអីតាមគោលការណ៍ប្រើប្រព័ន្ធ S.T.V. (Three-member constituency, 1000 Votes, five candidates (S.T.V. System)។ នៅក្នុងប្រព័ន្ធ S.T.V នេះប្រើ quota Droop ដូចនេះយើងបាន : $Droopquota = \frac{Votes}{Seat+1} + 1 = 251$

**តារាងទី ៧**

| បេក្ខជន Candidats | គណៈបក្ស Party | រាប់លើកទី១ 1-st Count: | រាប់លើកទី២ 2-nd Count: | រាប់លើកទី៣ 3-rd Count: | រាប់លើកទី៤ 4 -th Count: |
|---|---|---|---|---|---|
| A | V | 175 | + 10 = 185 | + 100 = 285 | - 34 = 251* |
| B | W | 200 | + 3 = 203 | + 31 = 234 | + 8 = 242 |
| C | X | 150 | + 1 = 151 | - 151 = 0 | = 0 |
| D | Y | 270 | - 19 = 251 | = 251 | = 251* |
| E | Z | 205 | + 5 = 210 | + 20 = 230 | + 26 = 256* |
| សរុប ៥ នាក់ | ៥ គណៈបក្ស | 1 000 | 1 000 | 1 000 | 1000 |
| សញ្ញា * ប្រកាសឆ្នោត | | | | | |

**ឥ៦. សំគាល់**

-សញ្ញាផ្កាយបញ្ជាក់ថាបេក្ខជនជាប់ឆ្នោត ។

-ក្នុងប្រព័ន្ធនេះទោះគណៈបក្សណាបានសំលេងច្រើនក៏ដោយ ក៏ទទួលបានតែមួយកៅអីប៉ុណ្ណោះ ឱ្យតែចំនួននោះលើស ឬស្មើចំនួនកូតាដែលបានគណនា ។

-អ្នកបោះឆ្នោតមានសិទ្ធិជ្រើសរើសបេក្ខជន តាមចំណង់នៃចំនួនលើកដែលបានកំណត់ ។

-គណៈបក្សមួយ ត្រូវចាត់តែបេក្ខជនម្នាក់គត់មកឈរឈ្មោះក្នុងមណ្ឌលមួយ ។

-ការបោះឆ្នោតធ្វើឡើងតែម្តងគត់ រីឯការចាត់ទុកការបោះឆ្នោតលើកទីពីរ និងបន្តបន្ទាប់ វាអាស្រ័យទឹងសញ្ញាដែលបានគូសនៅលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត ។

- អ្នកបោះឆ្នោតមានតែមួយសំលេងក្នុងមួយលើក១ ។

**ឥ២.បំណកស្រាយ** : ក្នុងប្រព័ន្ធ S.T.V គេប្រើរូបមន្តដ្រូបកូតា $Droopquota = \frac{Votes}{Seat+1} + 1$, តាមឧទាហរណ៍ក្នុងតារាងទី ៣ ខាងលើ គឺមណ្ឌលបោះឆ្នោតមួយមានបីកៅអី ហើយសំលេងបានការសរុប ១០០០. ។ ដូចនេះចំនួនសំលេងតំរូវសំរាប់ឈ្នះអាចមាន : $Droopquota = \frac{Votes}{Seat+1} + 1 = \frac{1000}{4} + 1 = 250 + 1 = 251 = 1$ ត្រង់នេះបញ្ជាក់ថាកូតាដែលឈ្នះរបស់បុគ្គលម្នាក់ៗត្រូវមានសំលេងយ៉ាងតិច ២៥១ សំលេង (quota)។ នៅតារាងទីបី បានបង្ហាញអំពីការគណនាទៅលើលទ្ធផលបោះឆ្នោតតាមប្រព័ន្ធ S.T.V ។ ការរាប់លើកទី ១ បេក្ខជន D បានទទួលសំលេង ២៧០ លើសចំនួនកំណត់មួយ (Threshold) ដែលមានត្រឹមតែ ២៥១ សំលេង ដោយក្នុងនោះបេក្ខជន D មានចំនួនលើស ១៩ សំលេង "Surplus 19" ដូចនេះបេក្ខជន D ត្រូវបានប្រកាសជាប់ឆ្នោតដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់រាប់នៅលើកក្រោយទៀតឡើយ ។ ចំពោះការរាប់លើកទី ១ នេះ បេក្ខជន B បាន ២០០ សំលេង ដែលជាសំលេងលំដាប់លេខ ៣ បន្ទាប់ពីបេក្ខជន E មាន ២០៥ សំលេង ។ ចំនួនសំលេងលើសនោះ (Surplus Votes) នឹងត្រូវគណនារាប់ជាថ្មីម្តងទៀត ដោយអាស្រ័យនឹង**សញ្ញាណជំរើសនៃសន្លឹកឆ្នោត** ដែលពួកអ្នកបោះឆ្នោតសរសេរលើក្រដាសឆ្នោត ដោយយកតែបេក្ខជនណាពុំទាន់បានជាប់ឆ្នោត ។ ក្រោយពីបានរាប់ឡើងវិញតាមសញ្ញាណនៃសន្លឹកឆ្នោត ដូចមានក្នុងចន្លោះទីពីរនោះបញ្ជាក់ថាការរាប់លើកទី ២ ។ បន្ទាប់ពីការរាប់លើកទីពីររួចមកគ្មានបេក្ខជនណាក្រៅពី D ឈានដល់ចំនួនខ្ពស់បំផុត (Threshold) តាម quota ដែលបានកំណត់នោះទេ ។ ការរាប់លើកទីបីយើងសង្កេតឃើញថាបេក្ខជន C ដែលមានសំលេងតិចជាងគេនៅក្នុងការរាប់លើកទី ១ និងកើនបានតែ ១ សំលេងក្នុងការរាប់លើកទី ២ នោះនឹងទទួលបានសន្លឹកឆ្នោតទាំងអស់របស់គេ ក្នុងការរាប់លើកទីបីស្មើនឹងសូន្យ ព្រោះបេក្ខជននេះពុំមានការគាំទ្រពីអ្នកបោះឆ្នោត រហូតដល់ទៅ ១៥១ សំលេង ។ ក្នុងករណីនៃការរាប់លើកទី ៣ នេះ បេក្ខជន A បានទទួល ២៨៥ សំលេង ខ្ពស់ជាងគេត្រូវបានជាប់ឆ្នោត បន្ទាប់ពីគាត់បានទទួល ១៧៥ សំលេង រាប់លើកទីមួយនិងកើន ១០ សំលេង ការរាប់លើទីពីរនិង ១០០ សំលេង កើនក្នុង ការរាប់លើកទីបី ។

ដោយសារចំនួនអាសនៈនៅសល់មួយទៀត នោះយើងត្រូវគណនាជាលើកទីបួន ដោយអាស្រ័យនឹងសញ្ញាទាំងនោះគេសង្កេតឃើញបេក្ខជន A មានសំលេងលើស ៣៤ (Surplus-34) ដែលបានប្រកាសឆ្នោតលើកទី ៣ នោះ ពុំត្រូវបានរាប់ទេ ព្រោះបេក្ខជន A ជាប់ឆ្នោតតាំងពីលើកទី ៣ រួចហើយ ។ ប៉ុន្តែបេក្ខជន E បានកើនសំលេង ២៦ ទៀត សរុប (Threshold Votes) ស្មើនឹង ២៥៦ សំលេង បន្ទាប់ពីការរាប់លើកទី ១ មាន ២០៥ សំលេង. រាប់លើកទី ២ កើនបាន ៥ សំលេង និងលើកទីបីកើន (Surplus) បាន ២០ សំលេង និងលើកទី ៤ កើនបាន ២៦ សំលេង ។ ដូចនេះ បេក្ខជន E ទទួលបានជាប់ឆ្នោតបន្ទាប់ពីបានគណនាលើកទី ៤ ។

សរុបទៅ បន្ទាប់ពីបានគណនាជាបន្តបន្ទាប់បេក្ខជន D ជាប់ឆ្នោតបន្ទាប់ពីការរាប់លើកទីមួយ និង A បានជាប់ឆ្នោតក្នុងការរាប់លើកទីបី និងបេក្ខជន E ជាប់ឆ្នោតក្នុងការរាប់លើកទីបួន រីឯបេក្ខជន B ដែលមានសំលេង ២០០ ក្នុងការរាប់លើកទី ១ នោះ បែរជាធ្លាក់ទៅវិញ ។

ដូចនេះ ប្រព័ន្ធនេះមានលក្ខណៈសមាមាត្រដោយពុំអាចកត់ទុកជាមុនបានឡើយ ព្រោះវាអាស្រ័យនឹងសញ្ញាទាំងឡាយរបស់ម្ចាស់ឆ្នោត (ពលរដ្ឋ) នៃមណ្ឌលនីមួយៗ គឺថាអ្នកបោះឆ្នោតអាចផ្លាស់ប្តូរការគាំទ្ររបស់ពួកគេទៅលើបេក្ខជន តាមសញ្ញាណនៃចំនួនលើកដែលបានកំណត់លើសន្លឹកឆ្នោត ។

## ៦. ការអនុវត្តន៍ក្នុងការប្រៀបធៀបលើប្រព័ន្ធមធ្យមភាគខ្ពស់

ប្រព័ន្ធមធ្យមភាគខ្ពស់ ឬធំ (The Higest Average System) អាចអនុវត្តតាមទស្សនៈបីប្រភេទខុសៗគ្នា ដោយមានការព្រមព្រៀងជាមុនរបស់គណៈបក្សនៅក្នុងមណ្ឌលមួយ ដែលទស្សនៈទាំងនោះមាន : Saint-Lague Version; Saint-Lague Modified Version and d'Hond ។ **នៅក្នុងទស្សនៈទាំងបីនេះ យើងធ្វើការពិសោធន៍ទៅលើមណ្ឌលបោះឆ្នោតតែមួយគត់ ដោយមានគណៈបក្ស និងសំលេងគាំទ្រដូចគ្នាសុទ្ធសាធ ។**

ឧទាហរណ៍ នៅក្នុងមណ្ឌលបោះឆ្នោតមួយមាន ៥ កៅអីដែលត្រូវបំពេញ និងមានសំលេងឆ្នោតសរុបចំនួន ២០០ 000 សំលេង ។ លទ្ធផលកូតាធម្មតា Hare quota = 200 000 : 5 = 40 000 ។ ក្នុងមណ្ឌលនោះមាន ៤ គណបក្សដែលគណៈបក្សនីមួយៗបានទទួលគឺ : A = 86 000, B = 56 000, C = 38 000, D = 20 000 ។ យើងដឹងថា 1 quota = 40 000 សំលេង ដូចនេះយើងពិនិត្យតាមទស្សនៈនីមួយៗដូចតទៅ ដើម្បីបញ្ជាក់ថាតើទស្សនៈណាមានលក្ខណៈសមាមាត្រជាងគេ ។

**ក. ករណីទីមួយ : ប្រើរូបមន្ត** Saint –Lague Versions: (1;3;5;7...)

ប្រព័ន្ធមធ្យមភាគខ្ពស់ (Higest Average System)

**តារាងទី ៤**

| បក្ស Party | សំលេង Votes | មេចែកនឹង ១ Divisors: 1 | មេចែកនឹង ៣ Divisors: 3 | មេចែកនឹង៥ Divisors: 5 | សរុបកៅអី Total Seats |
|---|---|---|---|---|---|
| A | ៨ ៦000 | ៨ ៦000① | ២៨ ៦៦៦④ | ១៧ ២00 | ២ |
| B | ៥៦ 000 | ៥៦ 000② | ១៨ ៦៦៦ | ១១ ២00 | ១ |
| C | ៣៨ 000 | ៣៨ 000③ | ១២ ៦៦៦ | ៧ ៦00 | ១ |
| D | ២0 000 | ២0 000⑤ | ៦ ៦៦៦ | ៤ 000 | ១ |
| សរុប Total | ២00 000 | ៤ | ១ | | ៥ |

តាមតារាងទី ៤ ខាងលើនេះ កៅអី ៥ ត្រូវបានបំពេញគឺគណៈបក្ស A បានទទួលកៅអីពីរ គឺកៅអីទី ① និងទី ④ នៅក្នុងការចែកនឹង ១ និង ៣ ។ រីឯគណៈបក្ស B បានទទួលកៅអីចំនួនមួយ គឺកៅអីទី ② បន្ទាប់ពីចែកនឹងមេចែក ១ ហើយកៅអីទី ③ ត្រូវបានគណៈបក្ស C បន្ទាប់ពីចែកនឹង ១ និងនៅទីបញ្ចប់កៅអីទី ⑤ បានទៅគណៈបក្ស D បន្ទាប់ពីចែកនឹង ១ ។ ដូចនេះការគណនាតាមរូបមន្តមធ្យមភាគធំក្នុងទស្សនៈ Saint Lague ត្រូវបានអាសនៈទៅគណៈបក្សចុងក្រោយផងដែរ ។ ដោយគិតតាមមធ្យមភាគធំ បន្ទាប់ពីយកសំលេងរបស់គណបក្សនីមួយៗចែកនឹងមេចែកពី ១ ដល់

៥ នោះឃើញថា : ចំនួនផលចែកក្នុងតារាងមានពីខ្ពស់ទៅទាប គឺ ៨៦ ០០០ ទៅ ២០ ០០០ សំលេង ដែលទទួលបានកៅអីតាមលំដាប់ពីកៅអីទី ①,②,③,④ និងទី ⑤ ។

**ខ. ករណីទីពីរ :រូបមន្ត** Saint Lague Modified Version : ( 1;4;3;5;7...) :

តាមតារាងទី ៥ ដោយគណនាតាមទស្សន Saint Lague Modified Version : ( 1,4;3; 5;7...) នៃប្រព័ន្ធមធ្យមភាគធំជំផែល ដោយយកមណ្ឌលបោះឆ្នោតពីតារាងទី ៤ នោះ យើងនឹងពិនិត្យឃើញថា :

- គណៈបក្ស A បានពីរកៅអីដដែល គឺកៅអីទី ① និងទី ③ ដូចការគណនាតាមតារាងទី ៤ ដែរ គ្រាន់តែខុសគ្នាត្រង់ថាក្នុងតារាងទី ៤ កៅអីទី ④ បានទៅគណៈបក្ស A ។

- គណៈបក្ស B តាមតារាងទី ៥ ទទួលបានកៅអីដល់ទៅពីរ គឺកៅអីទី ② និងទី ⑤ ដែលកើនមួយកៅអីទៀត ផ្ទុយពីតារាងទី ៤ ដែលគណៈបក្សនេះបានទទួលតែមួយកៅអីប៉ុណ្ណោះ គឺកៅអី ទី ② ក្នុងតារាងទី ៤ ។

- គណៈបក្ស C បានទទួលមួយកៅអីដដែល ប៉ុន្តែជាកៅអីទី ④ ផ្ទុយពីតារាងទី ៤ ដែលបានកៅអីទី ③ ។

- គណៈបក្ស D ក្នុងតារាងទី ៥ ពុំបានទទួលកៅអីមួយទេ ដែលផ្ទុយស្រឡះពីតារាងទី ៤ គឺគណៈបក្សនេះបានមួយកៅអីផងដែរ គឺកៅអីទី ⑤ ។

ដូចនេះតាមទស្សន: Saint Lague Modified គណៈបក្សតូចតាចដែលមានសំលេងគាំទ្រតិចនឹងគ្មានសំណាងបានអាសនៈនៅរដ្ឋសភានោះទេ ។

ផ្ទុយទៅវិញគណៈបក្សដែលមានសំលេងគាំទ្រច្រើន វានឹងស្រូបបានកៅអីកាន់តែច្រើនថែមទៀត ដែលលក្ខណៈនេះហើយធ្វើឱ្យភាពជាសមាមាត្រនោះមានលក្ខណៈតិចតួចណាស់ ។

**តារាងទី ៥**

| គណៈបក្ស Party | សំលេង Votes | មេចែកនឹង Divisors: 1.4 | មេចែកនឹង Divisors: 3 | មេចែកនឹង Divisors: 5 | សរុបកៅអី Total Seats |
|---|---|---|---|---|---|
| A | ៨៦ 000 | ៦១ ៤២៨① | ២៨ ៦៦៦③ | ១៧ ២00 | ២ |
| B | ៥៦ 000 | ៤0 000② | ១៨ ៦៦៦⑤ | ១១ ២00 | ២ |
| C | ៣៨ 000 | ២៧ 000④ | ១២ ៦៦៦ | ៧ ៦00 | ១ |
| D | ២0 000 | ១៤ ២៨៥ | ៦ ៦៦៦ | ៤ 000 | 0 |
| សរុប Total | ២00 000 | ៣ | ២ | | ៥ |

**ឆ. ករណីទីបី : រូបមន្ត** d'Hondt Version: ( 1;2;3;4;5...) : នៅក្នុងតារាងទី ៦ នេះយើងគណនាតាមទស្សនៈហុងដ៍ ដោយយកមណ្ឌលបោះឆ្នោតពីតារាងទី ៤ និងទី ៥ ដែលបានគណនារួចមកហើយនោះ យើងពិនិត្យក្នុងតារាងទី ៦ នេះឃើញថា :

- គណៈបក្ស A បានបីកៅអី គឺកៅអីទី ①, ទី ③, និងទី ⑤, ដែលតាមទស្សនៈនៃតារាងទាំងពីរខាងដើម ( តារាងទី ៤ និងទី ៥ ) គណៈបក្ស A បានតែ ២ កៅអីប៉ុណ្ណោះ គឺកៅអីទី ① និងទី ④ ក្នុងតារាងទី ៤ និងកៅអីទី ① និងទី ③ ក្នុងតារាងទី ៥ ។

- គណៈបក្ស B តាមតារាងទី ៤ បានមួយកៅអី គឺកៅអីទី ② ហើយតារាងទី ៥ បានទទួល ២ កៅអី គឺកៅអីទី ② និងទី ⑤ ប៉ុន្តែនៅតារាងទី ៦ គណៈបក្ស B ទទួលបានតែមួយកៅអីប៉ុណ្ណោះ គឺកៅអីទី ② ។

- គណៈបក្ស C តាមតារាងទី ៤ បានទទួលមួយកៅអី គឺកៅអីទី ③ តែនៅតារាងទី ៥ ទទួលបាន ១ កៅអីដដែល គឺកៅអីទី ④ ហើយនៅតារាងទី ៦ នេះ នៅតែទទួលបានកៅអីមួយដដែល គឺកៅអីទី ④ ។

- ចំពោះគណៈបក្ស D តាមតារាងទី ៤ ទទួលបានមួយកៅអី គឺកៅអីទី ③ ហើយតារាងទី ៥ ទទួលបានសូន្យកៅអី ហើយនៅតារាងទី ៦ នេះក៏ទទួលបានសូន្យដដែល ។

ដូចនេះតាមតារាងទី ៦ បង្ហាញថា គណៈបក្សដែលមានសំលេងច្រើន កាន់តែទទួលកៅអីបានច្រើន ហើយគណៈបក្សតូចតាចកាន់តែរងគ្រោះ គឺគ្មានវាសនានឹងទទួលអាសនៈឡើយ ។

**តារាងទី ៦**

| បក្ស Party | សំលេង Votes | មេចែក: ១ Divisors: 1 | មេចែក: ២ Divisors: 2 | មេចែក: ៣ Divisors: 3 | មេចែក: ៤ Divisors: 4 | មេចែក:៥ Divisors:5 | សរុបកៅអី Total Seats |
|---|---|---|---|---|---|---|---|
| A | ៨ ៦000 | ៨ ៦000① | ៤៣ 000③ | ២៨ ៦៦៦⑤ | ២១ ៥00 | ១៧ ២00 | ៣ |
| B | ៥៦ 000 | ៥៦ 000② | ២៨ 000 | ១៨ ៦៦៦ | ១៤ 000 | ១១ ២00 | ១ |
| C | ៣៨ 000 | ៣៨ 000④ | ១៩ 000 | ១២ ៦៦៦ | ៩ ៥00 | ៧ ៦00 | ១ |
| D | ២០ 000 | ២០ 000 | ១០ 000 | ៦ ៦៦៦ | ៥ 000 | ៤ 000 | 0 |
| សរុប Total | ២00 000 | ៣ | ១ | ១ | | | ៥ |

ដូចនេះតាមការប្រើទស្សនៈទាំងបីខាងលើ (តារាងទី ៤, ទី ៥, ទី ៦.) បានកំណត់ថាក្នុងមណ្ឌលបោះឆ្នោតមួយមានការប្រែប្រួលកៅអីតាមរូបមន្តផ្សេងៗគ្នា ប៉ុន្តែយើងអាចកំណត់បានថា មានតែទស្សនៈ Saint-Lague1;3;5.. (តារាងទី ៤) **ទេដែលអនុវត្តក្នុងមណ្ឌលបោះឆ្នោតមួយមានលក្ខណៈសមាមាត្រ** ព្រោះវាបានចែកកៅអីទៅគ្រប់គណៈបក្ស គឺមានន័យថាគណៈបក្សដែលមានសំលេងគាំទ្រតិចជាងគេក៏បានកៅអីដែរ ។ ចំណែកទស្សនៈ d'Hondt (តារាងទី៦) និងទស្សនៈ Saint-Lague Modified (តារាងទី ៥) វាមានផលចំណេញតែគណៈបក្សទាំងឡាយណាដែលទទួលសំលេងច្រើនតែប៉ុណ្ណោះ ។ ចំពោះទស្សនៈហុងដឺ តាមតារាងទី ៦ ធ្វើឱ្យគណៈបក្សឈ្នះឆ្នោតកាន់តែមានលទ្ធភាពខ្ពស់ក្នុងការទទួលកៅអី ។

## ៧. នីតិបោះឆ្នោត និងសិទ្ធិបោះឆ្នោត

ច្បាប់បោះឆ្នោត និងសិទ្ធិបោះឆ្នោតជាទូទៅពុំមានអត្ថន័យដូចគ្នានោះទេគឺ :

- នីតិបោះឆ្នោត : គឺជាប្រព័ន្ធមួយនៃបទដ្ឋានកិច្ចគតិយុត្ត (អាចថាធម្មនុញ្ញគតិយុត្ត) ដែលធ្វើនិយ័តកម្មទៅរាល់ទំនាក់ទំនងសង្គម ដោយផ្សារភ្ជាប់នឹងជំរើសទាំងឡាយ (Choices) ទៅលើអង្គការនានារបស់រដ្ឋ និងអង្គការស្វយ័តគ្រប់គ្រងមូលដ្ឋាន ។ នីតិបោះឆ្នោតក្នុងន័យនេះមានមូលដ្ឋានពីរ **គឺទីមួយវាជាច្បាប់** និងទី**ពីរវាជាសិទ្ធិ** ព្រោះវាជាមូលដ្ឋានគ្រឹះមួយក្នុងចំណោមមូលដ្ឋាន

គ្រឹះគតិយុត្តិទាំងឡាយនៃនីតិរដ្ឋធម្មនុញ្ញ ដែលក្នុងនោះកើតមានបទដ្ឋានដោយឡែកៗនៃសាខានីតិសាស្ត្រមួយចំនួនទៀតផង ដូចជាបទដ្ឋាននៃនីតិការងារ, នីតិរដ្ឋប្បវេណី, នីតិព្រហ្មទ័ណ្ឌ, នីតិវិធីតុលាការ.........។ល។ ជាដើម ដែលបានបញ្ញត្តិនៅក្នុងបទដ្ឋានទាំងនោះ ។ ការសិក្សាទៅលើខ្លឹមសារនៃនីតិបោះឆ្នោត ក្នុងអត្ថបទនេះគឺសំដៅទៅលើខ្លឹមសារជាទ្រឹស្តី ឬសិទ្ធិបោះឆ្នោត គឺពុំបានសិក្សាទៅលើច្បាប់ ឬបញ្ញត្តិស្តីពីការបោះឆ្នោតនោះឡើយ (Law on Election) ។

- សិទ្ធិបោះឆ្នោត (Electoral Rights) : វាគឺជាការធានារ៉ាប់រងដោយរដ្ឋនូវសមត្ថភាពចំពោះពលរដ្ឋ អំពីការចូលរួមក្នុងរាល់ការជ្រើសរើសទៅលើអង្គការរដ្ឋនានា និងអង្គការស្វ័យគ្រប់គ្រងមូលដ្ឋាន ។ សិទ្ធិនេះវាកំណត់ចំពោះបុគ្គលម្នាក់ៗ ដែលចូលរួមយ៉ាងសកម្មក្នុងកិច្ចដោយផ្ទាល់ ឬប្រយោល ។ ដើម្បីស្គាល់នូវខ្លឹមសារគ្រឹះនៃសិទ្ធិបោះឆ្នោត ចូរពិនិត្យនូវគោលការណ៍ខ្លះៗដូចខាងក្រោម :

**ក. គោលការណ៍នៃសិទ្ធិបោះឆ្នោត** (Principles of Electoral Rights) :គោលការណ៍នៃសិទ្ធិបោះឆ្នោតនេះត្រូវបានកំណត់តាមល័ក្ខខ័ណ្ឌមួយចំនួនដូចតទៅ :

**ក១. និយមន័យ និងអត្ថន័យ** : គោលការណ៍នៃសិទ្ធិបោះឆ្នោត គឺជាល័ក្ខខ័ណ្ឌដែលកំណត់ទៅលើសិទ្ធិទាំងឡាយ មានដូចជាការទទួលស្គាល់, ការធ្វើសមិទ្ធិ, ការប្រតិបត្តិ នៅក្នុងជំរើសនានា ហើយដែលសិទ្ធិទាំងនោះកើតឡើងតាមរយៈនៃការសំដែងឆន្ទៈដ៏សកម្មរបស់ប្រជាពលរដ្ឋ ។ ដូចនេះគោលការណ៍សិទ្ធិបោះឆ្នោតត្រូវបានកំណត់ដោយ**ច្បាប់បោះឆ្នោត** នៃប្រទេសនីមួយៗនៅលើពិភពលោក ដែលមានគោលការណ៍គ្រឹះធំៗជាច្រើន ។

**ក២. គោលការណ៍បោះឆ្នោតជាសាកល** : នេះជាគោលការណ៍មួយដែលមានន័យថាសិទ្ធិបោះឆ្នោត (សិទ្ធិបោះឆ្នោតដ៏សកម្ម ឬអ្នកមានសិទ្ធិបោះឆ្នោត) ទាំងនោះត្រូវទទួលស្គាល់ដោយគ្រប់មនុស្សពេញវ័យ (adult) និងគ្រប់ពលរដ្ឋដែលមានលក្ខណៈគ្រប់គ្រាន់ខាងផ្លូវចិត្ត ឬសតិបញ្ញា ។ ប៉ុន្តែនៅក្នុងកិច្ចអនុវត្តជាក់ស្តែង ពុំសូវមានជោគជ័យតាមលក្ខណៈទ្រឹស្តី ឬច្បាប់កំណត់នោះទេ ។ សិទ្ធិរបៀបនេះមានលក្ខណៈដូចជា :

**ក៦.១. សិទ្ធិអ្នកបោះឆ្នោត** : គឺជាបុគ្គលដែលរដ្ឋធម្មនុញ្ញ និងច្បាប់ទទួលស្គាល់អំពីសិទ្ធិបញ្ចេញសំលេង ។ អ្នកបោះឆ្នោតភាគច្រើនជាពលរដ្ឋទូទៅរបស់ប្រទេសសុក្រឹត្យមួយ ។

**ក៦.២. ស្ថានីយ៍បោះឆ្នោត ឬអង្គភាពបោះឆ្នោត** (Electorate or Polling Station) : គឺជាបណ្តុំនៃអ្នកបោះឆ្នោតរួមគ្នារបស់ប្រទេស ឬក៏ដែនដីកំណត់មួយ ។ គឺថាអ្នកបោះឆ្នោតចូលរួមតាមទីកន្លែងក្នុងប្រទេស ។

**ក៦.៣. គុណវុឌ្ឍិជ្រើសរើស** (Voting Qualification) : គឺជាក្រុមបុគ្គលដែលរដ្ឋធម្មនុញ្ញ និងច្បាប់បោះឆ្នោតទទួលស្គាល់ទៅលើលក្ខណៈសម្បត្តិមួយចំនួន។ មានន័យថាសិទ្ធិរបស់បុគ្គលទាំងនោះចំពោះការជ្រើសរើស ត្រូវបានកំណត់ដោយល័ក្ខខ័ណ្ឌពិសេសជាច្រើន ( ដូចជាអាយុ, ដើមកំណើត.... សញ្ជាតិ........) ។ តាមការស្រាវជ្រាវរបស់សហភាពអន្តររដ្ឋសភា (Inter-Parliamentary Union) នាឆ្នាំ ១៩៩២ ក្នុង ចំណោម ១៨៦ រដ្ឋដែលមាន ១០៩ រដ្ឋកំណត់អាយុចាប់ពី ១៨ ឆ្នាំឡើងទៅមានសិទ្ធិចូលរួមបោះឆ្នោត និងរដ្ឋមួយចំនួនតូចកំណត់អាយុចាប់ពី ១៩ ដល់ ២១ ឆ្នាំឡើងទៅ ប៉ុន្តែមាន ៤ ប្រទេសដែលមានសិទ្ធិបោះឆ្នោតចាប់ពីអាយុ ១៦ ឆ្នាំឡើងទៅ គឺប្រទេសប្រេស៊ីល, គុបា, អ៊ីរ៉ង់, នីហ្គារ៉ាហ្គ័រ ។

ចំពោះបុគ្គលដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជន (Candidate) ឱ្យគេបោះឆ្នោតមកខ្លួននោះ ត្រូវបានកំណត់តាមច្បាប់នៃប្រទេសនីមួយៗដែរ ។ បេក្ខជនរបៀបនេះប្រលងប្រណាំងក្នុងការចូលរួមដឹកនាំប្រទេស ជាពិសេសក្នុងរដ្ឋាភិបាល និងរដ្ឋសភា ។ ជាធម្មតាបេក្ខជនដែលឈរឈ្មោះជានិច្ចកាល **ត្រូវមានអាយុច្រើន** ។ តាមការស្រាវជ្រាវរបស់សហភាពអន្តររដ្ឋសភា (Inter-Parliamentary Union) ដដែលបានសំគាល់ឃើញថា[៤១] មាន ៣៤ រដ្ឋប្រកាន់យកបេក្ខជនដែល មានអាយុ ១៨ ឆ្នាំ និងមាន ៩២ ប្រទេសប្រកាន់យកអាយុ ២១ ឆ្នាំ និង ៣៩ ប្រទេសដែលប្រកាន់យកអាយុ ២៥ ឆ្នាំ ។ សំរាប់ប្រទេសគីណេ អេក្វាទ័រ (Equotorial Guinea) នៅអាហ្វ្រិក កណ្តាល ប្រកាន់យកអាយុ ៤៥

[៤១]. Electoral System, a world-wide comparative study, Library of Parliament, Canada,8 Juil 1993

ឆ្នាំ និង ៣០ ឆ្នាំ នៅអេស៊ីប (Egypt), ហ្សកដានី (Jordan), គុយវ៉ែត (Kuwait), និងតូគី ។ និងមានប្រទេសពីរដែលប្រកាន់យកអាយុខ្ពស់បំផុត គឺតាមច្បាប់នៃរដ្ឋទាំងនោះបញ្ជាក់ថា បេក្ខជនត្រូវមានអាយុ ៤៥ និង ៦០ ឆ្នាំ ក្នុងប្រទេស Equatorial guinea និង ២៦ ទៅ ៧៥ ឆ្នាំ នៅសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ ( កូរ៉េខាងជើង ) ។ ក្នុងគោលការណ៍ជាសាកលនេះ តាមរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់មាត្រា ៧៦ ថា "រដ្ឋសភា មានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

អង្គការរៀបចំការបោះឆ្នោតបែបបទ និងការប្រព្រឹត្តិទៅនៃ ការបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត" ។ និងមាត្រា ៣៤ បញ្ជាក់ថា " ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត" ។ ដោយយោងតាមរដ្ឋធម្មនុញ្ញនៃប្រទេសមួយចំនួន វាកំណត់នូវសិទ្ធិបោះឆ្នោតក្នុងល័ក្ខខ័ណ្ឌនៃសិទ្ធិបោះឆ្នោត ឬគុណវុឌ្ឍន៍ជំរើស (Voting qualification) តាមលក្ខណៈមួយចំនួនដូចខាងក្រោម ៖

**ក₂.៣.១. ការកំរិតទីលំនៅ** (Settled Life) : នេះគឺជាការកំណត់សិទ្ធិបោះឆ្នោតមួយដោយឈរលើគោលការណ៍នៃការរស់នៅរបស់បុគ្គលនោះ នៅក្នុងប្រទេសពិតប្រាកដមួយ ឬក៏នៅក្នុងទីកន្លែងណាមួយដែលមានរយៈពេលកំណត់ ។ ឧទាហរណ៍ : នៅប្រទេស**បារាំង**សំរាប់ការបោះឆ្នោតរាល់ការជំរើសផ្សេងៗ បុគ្គលត្រូវរស់នៅក្នុងប្រទេសនេះមានរយៈពេល ៦ ខែ គិតមកដល់ថ្ងៃធ្វើប័ណ្ណបោះឆ្នោត (ក្នុងទីកន្លែង ខេត្ត ឬឃុំណាមួយ). នៅប្រទេស**ណូវែលសេឡង់** រយៈពេល ៣ ខែ (ត្រូវការរស់នៅលើទឹកដីនៃមណ្ឌលបោះឆ្នោត) ។ គោលដៅសំខាន់នៃគោលការណ៍នេះ គឺសំរាប់ប្រឆាំងនឹងបុគ្គលដែលគ្មានទីលំនៅជាអចិន្ត្រៃយ៍ និងធ្វើឱ្យបាត់បង់នូវចំនួនពលរដ្ឋ ។ ចំពោះប្រទេសកម្ពុជា ពុំត្រូវបានកំណត់រយៈពេលនោះទេ គឺគ្រាន់តែថែងថាបានរស់នៅក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អាចឈរឈ្មោះឱ្យគេបោះឆ្នោតបាន (ច្បាប់បោះឆ្នោតឆ្នាំ ១៩៩៧ មាត្រា ៣៣ បន្ទាប់ពីធ្វើវិសោធនកម្ម ដែលប្រកាសឱ្យប្រើថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០០២) ច្បាប់នេះកាលអាណត្តិទី ២ ឆ្នាំ ១៩៩៨ បានកំណត់ក្នុងមាត្រា ៣៣ នេះថា បេក្ខជនមានសិទ្ធិឈរឈ្មោះត្រូវមានរយៈពេលមួយឆ្នាំ ក្រោយពីមករស់នៅជាអចិន្ត្រៃយ៍នៅកម្ពុជា ។

**ក₂.៣.២. ការកំរិតសញ្ជាតិ** (Citizen) : នេះគឺជាការកំរិតសញ្ជាតិរបស់ប្រទេសនីមួយៗ តែពុំកំរិតនូវរយៈពេលនោះទេ ។ ដូចជាវាក្យខ័ណ្ឌទីមួយផ្នែកទី ២ និងវាក្យខ័ណ្ឌទី ៣ នៃផ្នែកទី ៣ **មាត្រា I** រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ឆ្នាំ ១៧៨៧ បានកំណត់ថា សមាជិកតំណាងរាស្ត្រសហព័ន្ធអាចឱ្យគេជ្រើសរើសបាន គឺបុគ្គលណាដែលជាពលរដ្ឋអាមេរិកមិនតិចជាង ៧ ឆ្នាំ. ឯសមាជិកព្រឹទ្ធសភាមិនតិចជាង ៩ ឆ្នាំ ។ ប៉ុន្តែសំរាប់ប្រទេសអាស្សង់ទីន បន្ទាប់ពីទទួលសញ្ជាតូបនីយកម្ម រយៈពេល ៣ ឆ្នាំ ទើបមានសិទ្ធិបោះឆ្នោត ។ សំរាប់ប្រទេសកម្ពុជាការកំរិត**ទីលំនៅ** និង**ការកំរិតសញ្ជាតិ**ត្រូវបានកំណត់ដោយច្បាប់បោះឆ្នោតឆ្នាំ ១៩៩៧ តាម**មាត្រា ៣៣** ថា "ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

១- មានសញ្ជាតិខ្មែរពីកំណើត ។

២- មានអាយុ ២៥ ឆ្នាំ ឡើងទៅ គិតទៅដល់ថ្ងៃបោះឆ្នោត ។

៣- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

៤- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥- មានការតែងតាំងពីគណៈបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត" ។ និងច្បាប់ដដែលក្នុង **មាត្រា ៥០** កំណត់ថា

"ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួនក្នុងពេលបោះឆ្នោត ។ ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោតប្រជាពលរដ្ឋត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

- មានសញ្ជាតិខ្មែរ ។
- មានអាយុ ១៨ ឆ្នាំ ឡើងទៅគិតដល់ថ្ងៃបោះឆ្នោត ។
- មានទីលំនៅក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវបោះឆ្នោត ។
- មិនត្រូវឋិតនៅក្នុងស្ថានភាពជាប់ពន្ធនាគារ ។
- ពុំមែនជាជនវិកលចរិត ឬស្ថិតនៅក្រោមអាណាព្យាបាល ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញបទបញ្ជា និងនីតិវិធី ដើម្បីអនុវត្តជាក់ស្តែងនូវវាក្យខ័ណ្ឌទីមួយនៃមាត្រានេះ" ។

**ក.២.៣.៣. ការកំរិតនូវទ្រព្យសម្បត្តិ** (Property) : នេះគឺជាការកំរិតទៅលើបុគ្គលដែលមានទ្រព្យសម្បត្តិ ឬក៏កំរិតទៅលើទំហំនៃការបង់ពន្ធ ។ ត្រង់នេះគឺមានន័យថាបុគ្គលដែលពុំមានទ្រព្យសម្បត្តិគ្រប់គ្រាន់ពុំអាចចូលរួមក្នុងការគ្រប់គ្រងរដ្ឋបានទេ ។ ការកំរិតរបៀបនេះមានពីសម័យបុរាណនៃវណ្ណៈអភិជនខ្លះ ប៉ុន្តែក្រៅពីការកំរិតបែបនេះនៅមានការកំរិតផ្សេងៗទៀត ដូចជាការកំណត់នូវភេទ កំរិតការអប់រំ ( ប្រទេស**ប្រេស៊ីល** ,មាត្រា ១៤ រដ្ឋធម្មនុញ្ញ ១៩៨៨ កំណត់ថាអនក្ខរ

ភាពមិនអាចឈរឈ្មោះបានទេ) ការកំរិតនូវសាសនាដូចជាប្រទេសអ៊ីរ៉ង់ បុគ្គលដែលពុំកាន់សាសនាអ៊ីស្លាម មិនអាចឈរឈ្មោះបានទេ ។

**ក₂.₃.₄. ការកំរិតនូវសីលធម៌** (Morality) : ដូចជាប្រទេស**ហូឡង់** (Netherlands) បុគ្គលដែលឪពុកម្តាយបានកាត់កាលចោលពុំមានសិទ្ធិបោះឆ្នោតទេ។ នៅប្រទេស**ម៉ិកសិក្ក** បុគ្គលមិនអាចបោះឆ្នោតបានទេ បើសិនជាបុគ្គលនោះប្រើប្រាស់គ្រឿងស្រវឹង......។ គោលដៅនៃការកំរិតនេះគឺកំណត់ភាពថ្លៃថ្នូររបស់មនុស្សក្នុងសង្គម ។ មិនអាចមានសិទ្ធិបោះឆ្នោតទេចំពោះបុគ្គលណា ដែលមានទណ្ឌកម្មតាមសាលក្រមតុលាការ តាមវាក្យខ័ណ្ឌទីមួយនៃ**មាត្រាទី ៣** ច្បាប់ចក្រភពអង់គ្លេសស្តីអំពីរដ្ឋសភា ១៩៨៣ កំណត់ថា "បុគ្គលណាដែលស្ថិតនៅក្នុងពន្ធធនាគារ ដែលបុគ្គលនោះស្ថិតក្នុងការអនុវត្តនៃសាលក្រមតុលាការ នោះមិនអាចមានសិទ្ធិបោះឆ្នោតបានទេនូវរាល់ការជ្រើសរើសសភា ឬក៏ជ្រើសរើសអង្គការស្វ័យគ្រប់គ្រងមូលដ្ឋាន" ។ ចំពោះការកំរិតសីលធម៌នេះ នៅប្រទេសកម្ពុជាត្រូវបានកំណត់ដោយច្បាប់បោះឆ្នោតឆ្នាំ ១៩៩៧ នៅមាត្រា ៣៣. ៣៤. ៥០ ។

**ក₂.₃.₅. ការកំរិតនូវសិទ្ធិសកម្ម និងអកម្ម** (Active and Passive) : ជាការកំរិតទៅលើលក្ខណៈពិសេស១ ដែលគេហៅថា**វិសមិតភាព** (Incompatibility ឬហៅថាអ្នកដែលមានតំណែងខ្លះមិនអាចមានតំណែងត្រួតគ្នាបាន ។

ការកំរិតរបៀបនេះ គឺបុគ្គលមិនអាចមានសិទ្ធិបោះឆ្នោតបានទេ ក្នុងករណីដែលបុគ្គលនោះមានមុខងារកំណត់ច្បាស់លាស់ (ប្រសិនបើបានកាន់កាប់ និងបន្តការកាន់កាប់) ដូចច្បាប់បោះឆ្នោតកម្ពុជាឆ្នាំ ១៩៩៧ បានកំណត់នៅ**មាត្រា ៣៤** ថា "គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ :

១- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកំលាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ ក្នុងមុខតំណែង និងបព្វជិតសាសនា ឬ

២- ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

៣- ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬ

៤- ជនវិកលចរិត ឬជនដែលឋិតនៅក្រោមអាណាព្យាបាល ដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

៥- ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ

៦- សមាជិកនៃគណកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬ

៧- សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ

៨- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ" ។

ចំពោះបុគ្គលដែលមានអាណត្តិណាមួយ (ប្រសិនបើបានកាន់កាប់អាណត្តិ និងបន្តរក្សាអាណត្តិ) ឬក៏បំពេញកិច្ចការកិរិតណាមួយ ដូច **មាត្រា ៧៩** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ កំណត់ថា "អាណត្តិនៃសមាជិករដ្ឋសភា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា" ។ រដ្ឋធម្មនុញ្ញដដែលនេះកំណត់ **មាត្រា ១២០** ថា "មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្មហើយ និងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ" ។ និង **មាត្រា ១៣៩** "មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាព នឹងមុខងារសមាជិកព្រឹទ្ធសភា, សមាជិករដ្ឋសភា, សមាជិករាជរដ្ឋាភិបាល, ចៅក្រមក្នុងតំណែង, ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណៈបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព" ។

សរុបទៅ សិទ្ធិបោះឆ្នោតសកម្ម : គឺជាសិទ្ធិចូលរួមក្នុងការជ្រើសរើសសមាជិកទាំងឡាយនៃអង្គការរដ្ឋបាលផ្សារភ្ជាប់នឹងសំលេងឆ្នោត។ ដែលជាធម្មតាគេហៅថា "សិទ្ធិបោះឆ្នោត" សិទ្ធិនេះមានទាំងសិទ្ធិឈរឈ្មោះ និងសិទ្ធិជ្រើសរើស ។

សិទ្ធិបោះឆ្នោតអកម្ម ជាសិទ្ធិដែលអាចក្លាយជាអ្នកឈរឈ្មោះឱ្យគេបោះឆ្នោត ក្នុងការជ្រើសរើសអង្គការរដ្ឋទាំងឡាយស្ថិតក្នុងល័ក្ខខ័ណ្ឌណាមួយពិតប្រាកដ ។ ព្រោះថាក្នុងពេលខ្លះបុគ្គលដែលមានតំណែងណាមួយ មិនអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសខ្លួនជាតំណាងរាស្ត្រ ឬកាន់កាប់មុខងារណាមួយបានទេ ។ សិទ្ធិនេះវាមានលក្ខណៈទៅនឹងពាក្យវិសមិតភាព ដូចជាវាក្យខ័ណ្ឌទី ១ **មាត្រា ៣** ច្បាប់បោះឆ្នោតកម្ពុជាបានកំណត់ថា "កងយោធពលខេមរភូមិន្ទក្នុងមុខតំណែងមិនអាចឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្របានទេ" ។

**ក៣.គោលការណ៍ចូលរួមសេរីនៅគ្រប់ការបោះឆ្នោត ឬការជ្រើសរើស និងសំលេងចាំបាច់**

**ក៣.១.គោលការណ៍សេរី** : គោលការណ៍នេះវាផ្សារភ្ជាប់នឹងសិទ្ធិបោះឆ្នោតជាសកម្ម ។ គោលការណ៍នៃជំរើសសេរី ឬគោលការណ៍សេរីក្នុងការចូលរួមបោះឆ្នោត វាមានន័យថាអ្នកបោះឆ្នោតផ្ទាល់ជាអ្នកដោះស្រាយ ចូលរួមនៅក្នុងពេលដំណើរការបោះឆ្នោត ថាតើគាត់យល់ព្រម ឬក៏អត់ ? ហើយតើការចូលរួម ឬមិនចូលរួមនោះស្ថិតក្នុងល័ក្ខខ័ណ្ឌបែបណា ?។ ត្រង់នេះបញ្ជាក់ថា គាត់មានសិទ្ធិសេរីក្នុងការជ្រើសរើសទៅលើបេក្ខជនដែលបានឈរឈ្មោះ ។

**ខ៣.២.សំលេងចាំបាច់** : ចំពោះសំលេងចាំបាច់ ឬហៅថាវ៉ូតុមចាំបាច់ដែលពាក្យឡាតាំងហៅថា (Votum) មានន័យថាឆន្ទៈ ឬបំណងពាក្យនេះវាមានន័យពីរក្នុងការបោះឆ្នោតគឺ :

**ទីមួយ :** ជាមតិដែលសំដែងក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដោយឱ្យសេចក្តីយល់ព្រម ឬមិនយល់ព្រម. ទុកចិត្ត ឬមិនទុកចិត្ត ។

**ទីពីរ :** គឺពហុវ៉ូតុម (Plural Votum) គឺជាសណ្តាប់ធ្នាប់មួយ ដែលយល់ព្រមឱ្យអ្នកបោះឆ្នោតប្រកាន់យកសំលេងពីរ ឬលើសពីពីរ ក្នុងរាល់ការជ្រើសរើស ។ មានន័យថាអ្នកបោះឆ្នោតក្នុងន័យទីពីរនេះជាវ៉ូតុមចាំបាច់បំផុត ឬគេកំណត់នូវកាតព្វកិច្ចគតិយុត្តរបស់អ្នកបោះឆ្នោត ក្នុងការចូលរួមជ្រើសរើស ដូចច្បាប់បោះឆ្នោតកម្ពុជា ឆ្នាំ ១៩៩៧ បានកំណត់ក្នុង**មាត្រា ៩៤** ថា "អ្នកបោះ

ឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតតែមួយសន្លឹក **និងតែមួយដងគត់** ដោយត្រូវទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់ ។

អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបោះឱ្យគណៈបក្សនយោបាយណាមួយដែលខ្លួនពេញចិត្ត ដោយគូសសញ្ញាយកតែគណៈបក្សនយោបាយមួយ និងមិនត្រូវកែ ដូរ ឬបន្ថែមបន្ថយទេ ។ របៀបបោះឆ្នោតលំអិតផ្សេងទៀត ត្រូវកំណត់ដោយគណៈកម្មការជាតិរៀបចំការបោះឆ្នោត ។ ហើយបើអ្នកបោះឆ្នោតនោះពុំគោរពនូវកាតព្វកិច្ចចាំបាច់នេះទេ ត្រូវទទួលទណ្ឌកម្មផ្សេងៗ ។ ដូច**មាត្រា ៤៨** នៃរដ្ឋធម្មនុញ្ញ**អ៊ីតាលី ឆ្នាំ**១៩៤៧ ដែលប្រកាន់គោលការណ៍សេរី និងសកលនេះបានកំណត់ថា "ការបោះឆ្នោតប្រព្រឹត្តទៅដោយបុគ្គល និងស្មើភាពដោយសេរី និងសំងាត់ ។ ការបំពេញករណីកិច្ចនេះបានត្រូវធ្វើឡើងដោយករណីកិច្ចពលរដ្ឋ" ។ នៅក្នុងប្រទេសអ៊ីតាលី អ្នកដែលបំពានទៅលើករណីកិច្ចនេះត្រូវទទួលទណ្ឌកម្មសីលធម៌ ឯនៅ**អូស្ត្រាលី**ជាកពិន័យ. រីឯនៅប្រទេស**ក្រិច** និង**តួគីដកសេរីភាព** ។

**ក៤. គោលការណ៍ស្មើភាពនៃការបោះឆ្នោត** : គោលការណ៍នេះ គឺសំរាប់កំណត់នូវលទ្ធភាពស្មើគ្នានៃអ្នកបោះឆ្នោតម្នាក់ លើលទ្ធផលមួយនៃគ្រប់ការជ្រើសរើស ។ នេះជាបាតុភូតគ្រឹះសំខាន់បំផុត ដែលរដ្ឋធម្មនុញ្ញជាអ្នកធានានូវសមត្ថភាពនៃពលរដ្ឋ ។

ដូចនេះភាពស្មើគ្នា (Equality) នៃសិទ្ធិបោះឆ្នោត គឺជាវត្តមាននៃចំនួនសំលេងរបស់អ្នកជ្រើសរើសនីមួយៗ ។ គោលការណ៍នេះ នៅអឺរ៉ុបខាងលិចគេប្រកាន់គោលជំហរមួយគឺ : "មនុស្សម្នាក់មានសំលេងមួយ ឬមួយសំលេង" ប៉ុន្តែពេលខ្លះដោយវាអាស្រ័យនឹងប្រព័ន្ធបោះឆ្នោត សំលេងទាំងនោះនឹងអាចមានលើសពីមួយ គឺមានន័យថាអ្នកបោះឆ្នោតអាចមានសំលេងច្រើនបាន ។ ដូចជាការបោះឆ្នោតសភាតំណាងរាស្ត្រនៅអាល្លឺម៉ង់ (ខេត្តបាវ៉ារី) និងនៅប៉ុលហ្គារី ដែលក្នុងនោះអ្នកបោះឆ្នោតមានសំលេង ២ (ពីរសំលេង) ប៉ុន្តែការបោះឆ្នោតជ្រើសរើសអង្គការស្វ័យគ្រប់គ្រងមូលដ្ឋាននៅបាវ៉ារី (អាល្លឺម៉ង់) អ្នកបោះឆ្នោតមានសិទ្ធិដល់ទៅ ៣ សំលេង ។ ការកំណត់របៀបខាងលើនេះមានលក្ខណៈទៅនឹងពហុវូតុម (Plural Votum) មានន័យថាពហុសំលេង ប៉ុន្តែសំរាប់ចក្រភពអង់គ្លេស ការបោះឆ្នោតសភាតំណាងរាស្ត្រមុនឆ្នាំ ១៩៤៨ គេកំណត់សំលេងនៃអ្នកបោះឆ្នោតតាមខណៈជាច្រើន គឺតាមទីកន្លែងនៃ**កម្មសិទ្ធអចលនទ្រព្យ**របស់អ្នកបោះឆ្នោត (មិនគិតពីទីកន្លែងនៃ

ការរស់នៅ) តាមទីកន្លែងនៃសកលវិទ្យាល័យ (គឺមានន័យថាអ្នកបោះឆ្នោតណាដែលបានបញ្ចប់សកលវិទ្យាល័យ) និងតាមករណីជាច្រើនទៀត ។ បច្ចុប្បន្នមានប្រទេសខ្លះ ដូចជារដ្ឋមួយចំនួននៅអូស្ត្រាលី និងនូវែលសេឡង់ សិទ្ធិបោះឆ្នោតក្នុងការជ្រើសរើសអភិបាលក្រុង ត្រូវកំណត់តាមទី**កន្លែងស្ថិតនៅនៃអចលនទ្រព្យ**។ ប៉ុន្តែការប្រកាន់លក្ខណៈនេះ ដែលគេគិតថាជាគោលការណ៍នៃពហុវូតុម (Plural Votum) ដែរ នោះពិតជាមានការខុសឆ្គង ក្នុងករណីនៃការបោះឆ្នោតជ្រើសរើសអង្គការរដ្ឋកំពូលផ្សេងៗទៀត ប៉ុន្តែវាជាលក្ខណៈកំនត់ទីតាំងនៃអ្នកបោះឆ្នោតទៅវិញ ។

**ក៥. គោលការណ៍បោះឆ្នោតដោយផ្ទាល់ និងប្រយោល** : គោលការណ៍នេះវាប្រព្រឹត្តិទៅបានដោយអាស្រ័យនឹងការង្កើតនៃអង្គការបោះឆ្នោតមួយ ដែលត្រូវបានកំណត់ដោយច្បាប់បោះឆ្នោតនៃប្រទេសនីមួយៗ ។ គោលការណ៍នោះមានលក្ខណៈមួយចំនួនដូចខាងក្រោម :

**ក៥.១. គោលការណ៍បោះឆ្នោតដោយផ្ទាល់** (Direct Vote) : វាជាសិទ្ធិនៃអ្នកបោះឆ្នោតម្នាក់ (Voter) ធ្វើការជ្រើសរើសដោយផ្ទាល់ក្នុងការបោះឆ្នោតជ្រើសរើសអង្គការរដ្ឋ ឬមុខតំណែងណាមួយ ។ គោលការណ៍នេះ ភាគច្រើនប្រើប្រាស់ក្នុងការបោះឆ្នោតសភាតំណាងរាស្ត្រ ដូច**មាត្រា** ៩៤ នៃច្បាប់បោះឆ្នោតកម្ពុជាបានកំណត់ក្នុងវាក្យខ័ណ្ឌទីមួយថា "អ្នកបោះឆ្នោតម្នាក់មានសិទ្ធិបោះឆ្នោតតែមួយសន្លឹក និងតែមួយដងគត់ ដោយត្រូវទៅ**បោះឆ្នោដោយខ្លួនឯង**"។ ប៉ុន្តែមានករណីខ្លះក៏ប្រព្រឹត្តិទៅក្នុងការជ្រើសរើសសភាជាន់ខ្ពស់ (ព្រឹទ្ធសភា) ដែរ ដូចជានៅ**សហរដ្ឋអាមេរិក**, **អ៊ីតាលី**, **ប៉ូឡូញ**, បោះឆ្នោតជ្រើសរើសប្រធានាធិបតីនៅ**ម៉ិចស៊ិក្ស**, **អូទ្រីស្ត**, **ប៉ុលហ្គារី** ។ ការបោះឆ្នោតដោយផ្ទាល់នេះមានធ្វើសឹងតែគ្រប់ប្រទេស ក្នុងការជ្រើសរើសអង្គការស្វ័យគ្រប់គ្រងមូលដ្ឋាន។

**ក៥.២. គោលការណ៍បោះឆ្នោតដោយប្រយោល** (Indirect Vote)**ឬគោលការណ៍បោះឆ្នោតច្រើនលំដាប់** (Electon by Several Stages) : គោលការណ៍នេះមានន័យថាអ្នកបោះឆ្នោតជ្រើសរើសសមាជិកគណៈបោះឆ្នោត (Electoral College) ពីមណ្ឌលនីមួយៗរបស់គេ ដែលបន្ទាប់មកសមាជិកនៃគណៈបោះឆ្នោតទាំងនោះក្លាយជាអ្នកជ្រើសរើសបន្តទៀត ។ សមាជិកនៃគណៈបោះឆ្នោតនោះអាចជាអង្គការរដ្ឋ ឬអង្គការស្វ័យគ្រប់គ្រងមូលដ្ឋានដែលមានលំដាប់ថ្នាក់ តាមទំនាក់ទំនងចំពោះកិច្ចការបោះឆ្នោត ។

ការបោះឆ្នោតដោយប្រយោលអាចមានពីរ ឬច្រើនដំណាក់ ប៉ុន្តែទោះជាមានលក្ខណៈនេះក៏ដោយ នៅដំណាក់ទី ៣ ឬទី ៤ កំរមានជួបប្រទះណាស់ ។ ការបោះឆ្នោតពីរដំណាក់ប្រព្រឹត្តិទៅក្នុងការជ្រើសរើសប្រធានាធិបតីសហរដ្ឋអាមេរិក ព្រឹទ្ធសភាឥណ្ឌា និងមានលក្ខណៈបីលំដាប់ គឺមាននៅក្នុងការបោះឆ្នោតសភាចិនប្រជាមានិត ដែលមួយផ្នែកធំអនុវត្តតាមការបោះឆ្នោតដោយប្រយោលបីលំដាប់ថ្នាក់ ។ ការបោះឆ្នោតដោយប្រយោលពីប្រជារាស្ត្រ ដូចជាការជ្រើសរើសនាយកដ្ឋមន្ត្រីធ្វើឡើងតាមរយៈតំណាងរាស្ត្រ (សំរាប់ប្រទេសកម្ពុជា) ។ ការបោះឆ្នោតដោយប្រយោល ជាការបោះឆ្នោតតាមរយៈតំណាងរបស់ពលរដ្ឋ តែពុំមែនតាមរយៈការជ្រើសរើសដោយផ្ទាល់ពីពលរដ្ឋនោះទេ។

**គ៦. គោលការណ៍បោះឆ្នោតសំងាត់** (Secret ballot) : នេះជាគោលការណ៍ដែលមិនរាប់បញ្ចូលនូវការប្រតិបត្តិត្រួតពិនិត្យ ដោយការសំដែងឆន្ទៈរបស់អ្នកបោះឆ្នោតទេ តែជាគោលការណ៍សំដែងឆន្ទៈដោយសំងាត់របស់អ្នកបោះឆ្នោត ។ គោលការណ៍នេះក៏នៅតែធានានូវសេរីភាពពេញលេញក្នុងការសំដែងឆន្ទៈដែរ ។ ការអនុវត្តន៍នូវគោលការណ៍សំងាត់នេះ គឺអ្នកបោះឆ្នោតបំពេញនៅលើប័ណ្ណបោះឆ្នោត ឬសន្លឹកឆ្នោត ឬក៏តាមរយៈម៉ាស៊ីនដែលអាចធ្វើទៅបានស្ថិតក្នុងបន្ទប់ពិសេសមួយ ឬក៏ក្នុងប្រអប់ឆ្នោត ឬក៏នៅក្នុងការិយាល័យមួយ. ហើយដាក់ប័ណ្ណដែលបានបំពេញនោះទៅក្នុងប្រអប់ឆ្នោត ឬក៏នៅក្នុងទិដ្ឋភាពដ៏សាំញ៉ាំ គេដាក់ប័ណ្ណនោះទៅក្នុងស្រោមសំបុត្រ ។ ក្នុងដៃអ្នកបោះឆ្នោតមានតែស្រោមសំបុត្រមួយគត់ ដែលគាត់ដាក់វាទៅក្នុងប្រអប់ឆ្នោត បន្ទាប់មកគាត់ក៏ចាកចេញ ។ ប៉ុន្តែមានករណីខ្លះអ្នកបោះឆ្នោតមិនចង់ជ្រើសរើសនោះ ក៏គេដាក់ស្រោមសំបុត្រនោះដោយគ្មានបំពេញនូវប័ណ្ណបោះឆ្នោតទេ ហើយក៏ដាក់វាទៅក្នុងប្រអប់ឆ្នោតដែរ ។ ប៉ុន្តែតាមច្បាប់គាត់ត្រូវតែធ្វើ ។ គួររំលឹកថា ការបោះឆ្នោតសំងាត់នេះជាប្រវត្តិសាស្ត្ររបស់ខ្លួន គឺការជ្រើសរើសអង្គការរដ្ឋដែរ ។ ការបោះឆ្នោតសំងាត់នេះបានកំណត់នៅឆ្នាំ ១៧៨៩ នៅប្រទេសបារាំង ប៉ុន្តែការអនុវត្តជាក់ស្តែងចាប់ពីឆ្នាំ ១៨៧១ ។ រីឯនៅចក្រភពអង់គ្លេសចាប់អនុវត្តន៍ពីឆ្នាំ ១៨៧២ ។ ប៉ុន្តែគោលការណ៍សំងាត់នេះវាមានភារកិច្ចច្បាស់លាស់ ដូចបទបញ្ញាផ្ទៃក្នុងរដ្ឋសភាកម្ពុជា ១៩៩៣ បានកំណត់ក្នុង**ប្រការ ៤០** ថា "វិធីបោះឆ្នោតសំងាត់ត្រូវតែប្រើក្នុងការជ្រើសតាំងការសំដែង ការទុកចិត្ត និងការអនុម័តញ្ញត្តិបន្ទោស ។

ការអនុម័តច្បាប់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ អាចប្រព្រឹត្តិដោយវិធីបោះឆ្នោតសំងាត់ដែរ" ។ ប៉ុន្តែវាក្យខ័ណ្ឌទី ២ នៃ**មាត្រា ៧៦** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានបញ្ញត្តិទៅលើគោលការណ៍បោះឆ្នោតសំងាត់ក្នុងការជ្រើសរើសតំណាងរាស្ត្រថា "... តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល, ដោយសេរី, ដោយស្មើភាព, ដោយចំពោះ និងតាម**វិធីជ្រើសរើសឆ្នោតជាសម្ងាត់**" ។

**ខ.ដំណើរការបោះឆ្នោត** (Electoral Process) :

**ខ₁.និយមន័យ** : ដំណើរការបោះឆ្នោត គឺជាសកម្មភាពមួយដែលត្រូវបានកំណត់ដោយច្បាប់ និងបទដ្ឋានទូទៅផ្សេងៗទៀត ក្នុងការកើតទៅលើសកម្មភាពនៃបេក្ខភាព, អង្គការនានា និងការគ្រប់គ្រង ឬក៏ក្រុមពួកតាមរយៈការរៀបចំ និងការប្រព្រឹត្តិទៅនៃការបោះឆ្នោតជ្រើសរើសក្នុងអង្គការរដ្ឋ និងអង្គការគ្រប់គ្រងមូលដ្ឋាន ។ សកម្មភាពទាំងនោះត្រូវបានកំណត់ដោយធាតុសំខាន់ៗ តាមលំដាប់ថ្នាក់ដូចតទៅ :

**ខ₁.₁. ចំណាត់តាំងបោះឆ្នោត** : នេះគឺជាលំដាប់មួយដែលមានការកំណត់នូវកាលបរិច្ឆេទនៃការបោះឆ្នោត ។ ក្នុងច្បាប់បោះឆ្នោតកម្ពុជា ឆ្នាំ ១៩៩៧ បានកំណត់ក្នុង**មាត្រា ៣** ថា " ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងប្រាំឆ្នាំម្តង នៅថ្ងៃអាទិត្យនៃសប្តាហ៍ទី ៨ មុនដំណាច់ឆ្នាំទី ៥ នៃនីតិកាលរបស់រដ្ឋសភា" ។ ការកំណត់ថ្ងៃច្បាស់លាស់សំរាប់ធ្វើការបោះឆ្នោតជាសកល ដើម្បីជ្រើសរើសសភាតំណាងរាស្ត្រនោះនៅក្នុងប្រទេសខ្លះ ច្រើនយកថ្ងៃដែលពុំធ្វើការងារ ឬក៏ថ្ងៃសំរាកណាមួយ ដូចជាវាក្យខ័ណ្ឌទី ៣ មាត្រា ២៦ ច្បាប់គ្រឹះរបស់**អូទ្រីស្ត** បានកំណត់ថា ថ្ងៃបោះឆ្នោតនៃក្រុមប្រឹក្សាជាតិ (សភាតំណាងរាស្ត្រ) ត្រូវធ្វើនៅថ្ងៃអាទិត្យ ឬថ្ងៃសំរាកណាមួយ ។ តាមច្បាប់បោះឆ្នោតកម្ពុជា បានកំណត់នូវរយៈពេលក្នុងដំណើរការបោះឆ្នោត តាម**មាត្រា ៨៥** ច្បាប់កម្ពុជា ថា "ការបោះឆ្នោតត្រូវធ្វើតែមួយថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោង ៧ : ០០ ព្រឹក រហូតដល់ម៉ោង ១៥ : ០០ លើកលែងតែមានសេចក្តីសំរេចផ្សេងពីនេះ របស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះគ្រប់គ្នាហើយ គណៈកម្មការការិយាល័យបោះឆ្នោត អាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោង (១៥ : ០០) ។

ប្រធានការិយាល័យបោះឆ្នោតត្រូវប្រកាសបិទការបោះឆ្នោតនៅម៉ោងដប់ប្រាំ (១៥:០០) ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោត មិនត្រូវអនុញ្ញាតិឱ្យចូលក្នុងបរិវេណខាងក្នុងក្រោយម៉ោងដប់ប្រាំ (១៥ : ០០) ឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោងដប់ប្រាំ (១៥ : ០០) ហើយអាចអនុញ្ញាតិឱ្យបោះឆ្នោត គឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុង នៅម៉ោងដប់ប្រាំ (១៥ : ០០)" ។ ដូចនេះការ ចាត់តាំងនូវកាលបរិច្ឆេទក្នុងនោះវាជាធាតុមួយបង្ហាញពីស្ថេរភាព និងនីតិរដ្ឋរបស់ប្រទេសនីមួយៗ ។

**៩.១.២. មណ្ឌលបោះឆ្នោត** ( Electoral district) : គឺជាដែនដីរួមគ្នាមួយដែលបង្រួបបង្រួមពលរដ្ឋ (Citizen) សំរាប់ធ្វើការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រក្នុងអង្គការតំណាងនានា របស់រដ្ឋ និងអង្គការស្វ័យគ្រប់គ្រងមូលដ្ឋាន ។ មណ្ឌលបោះឆ្នោតគេអាចបែងចែកតាមលក្ខណៈពិសេសនៃទំរង់រចនាសម្ព័ន្ធដែនដីរបស់គេ ដូចជាតំបន់, ខេត្ត, ក្រុង ។ល។ ដូចច្បាប់បោះឆ្នោតកម្ពុជា ១៩៩៧ បានកំណត់ក្នុង**មាត្រា ៥** ថា "តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅ ជាសាកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសំងាត់ ។

ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រខេត្ត ក្រុង ដោយយកខេត្ត ក្រុងជាមណ្ឌលបោះឆ្នោត" ។ ប៉ុន្តែបើក្នុងករណីមណ្ឌលបោះឆ្នោតទាំងនោះពុំមានបង្កើត នោះប្រទេសទាំងមូលចាត់ទុកជាមណ្ឌលបោះឆ្នោតរួមតែមួយ ។ ការបង្កើតមណ្ឌលបោះឆ្នោតវាមានភាពផ្សេងៗគ្នា ទៅតាមប្រទេសនីមួយៗដែលគេនិយម អញ្ចឹងហើយបានជាការបង្កើតមណ្ឌលបោះឆ្នោតគេត្រូវកំណត់ដោយច្បាប់ណាមួយ ឬក៏កំណត់ក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសរបស់គេ ។ គោលការណ៍នៃការបង្កើតមណ្ឌលបោះឆ្នោតនោះមានដូចជា :

- ការគិតតាមចំនួនប្រជាជនទៅនឹងចំនួនកៅអីនៅសភាតំណាងរាស្ត្រ ។
- ការគិតតាមចំនួនតំណាងរាស្ត្រដែលឈរឈ្មោះក្នុងមណ្ឌលនីមួយៗ ឬក៏និយាយថាតើមានប្រជាជនចាប់ពីប៉ុន្មាននាក់ឡើងទៅទើបមានអ្នកឈរឈ្មោះ ឧទាហរណ៍ក្នុងមណ្ឌលមួយមានប្រជាជនពី ១០០ ពាន់នាក់ និង ២០០ ពាន់នាក់ ត្រូវមានតំណាងរាស្ត្រម្នាក់ ។ និងមានគោលការណ៍

ផ្សេងៗទៀតដោយស្របនឹងចំនួនប្រជាជន និងចំនួនកៅអីតំណាងរាស្ត្រ ។ សូមបញ្ជាក់ថាការគិតចំនួនពលរដ្ឋនេះពុំមានន័យដូចការគិតចំនួនអ្នកមានសិទ្ធិបោះឆ្នោតទេ ពីព្រោះក្នុងមណ្ឌលខ្លះមានប្រជាជនច្រើន តែអ្នកមានសិទ្ធិបោះឆ្នោតតិច ។ ដោយឡែកច្បាប់កម្ពុជា បានកំនត់របៀបគណនាទៅលើចំនួនតំណាងរាស្ត្រនៃមណ្ឌលមួយ ឱ្យមានភាពសមាមាត្រទៅនឹងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ដូចជាច្បាប់កម្ពុជា ១៩៩៧ កំណត់ក្នុង**មាត្រា** ៩ ថា "ក្នុងការរកចំនួនអាសនៈថ្មីរបស់រដ្ឋសភា ត្រូវគណនាតាមរូបមន្តដូចខាងក្រោម ដោយមិនគិតចំនួនសល់ :

$$\frac{\text{ប}_{\text{ម}}}{\text{ច}_{\text{ម}}} = \text{ផ}$$

- $\text{ប}_{\text{ម}}$ : ជាចំនួនប្រជាពលរដ្ឋខ្មែរនៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចុងក្រោយកន្លងមកនេះ ។
- $\text{ច}_{\text{ម}}$ : ជាចំនួនអាសនៈក្នុងរដ្ឋសភាបច្ចុប្បន្ន ។
- ផ : ជាផលចែកប្រភាគដោយពុំគិតចំនួនសល់ ។

$$\frac{\text{ប}_{\text{ប}}}{\text{ផ}} = \text{ចថ}$$

- $\text{ប}_{\text{ប}}$ : ជាចំនួនប្រជាពលរដ្ឋខ្មែរបច្ចុប្បន្ន ។
- ចថ : ជាចំនួនអាសនៈថ្មីដោយពុំគិតចំនួនសល់ ។

ក្នុងការរកចំនួនអាសនៈតាមខេត្ត ក្រុង ត្រូវគណនាតាមរូបមន្តដូចខាងក្រោម :

$$\frac{\text{ប}}{\text{ផ}} = \text{ច}$$

- ប : ជាចំនួនប្រជាពលរដ្ឋខ្មែរក្នុងខេត្ត ក្រុង ។
- ផ : ផលចែកប្រភាគដែលបានមកពីការគណនាខាងលើ ។
- ច : ជាចំនួនអាសនៈថ្មីក្នុងខេត្ត ក្រុង ដោយពុំគិតចំនួនសល់ " ។

និង**មាត្រា១០** នៃច្បាប់ដដែលបានកំនត់ថា "ចំពោះខេត្ត ក្រុងណាដែលមានប្រជាពលរដ្ឋតិចជាងផលចែកប្រភាគក៏ត្រូវមានអាសនៈមួយដែរ ។ ចំពោះអាសនៈដែលនៅសល់ គណៈកម្មការកំណត់អាសនៈរដ្ឋសភាអាចធ្វើសំណើបន្ថែមអាសនៈទៅខេត្ត ក្រុង ដោយផ្អែកតាមស្ថានភាពភូមិសាស្ត្រ សង្គម

និងសេដ្ឋកិច្ច ។" ចំពោះការបែងចែកអាសនៈរបស់គណៈបក្សនៅតាមមណ្ឌល ត្រូវធ្វើឡើងតាមការគណនាដោយប្រើរូបមន្ត**មធ្យមភាគធំ** (តាមទ្រឹស្តីហៅថាសំណល់ធំ) តាមកូតា $q = \frac{V}{S+1}$ (q គឺជាមធ្យមភាគធំបំផុត. V ជាចំនួនសំលេងបានការរបស់បក្សនីមួយៗ. S គឺជាចំនួនកៅអីដែលបក្សនីមួយៗបានទទួល ។ ការកំណត់រូបមន្តនេះត្រូវបានលំអិតដោយមាត្រា ១១៨ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលធ្វើវិសោធនកម្មថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២។**មាត្រា ១១៨** ចែងថា:

**ក.** "ក្រោយពីបណ្តឹងតវ៉ាត្រូវបានសម្រេចជាស្ថាពរ និងក្រោយពីបានទទួលលទ្ធផលនៃការបោះឆ្នោតទាំងអស់ រួមទាំងលទ្ធផលនៃការបោះឆ្នោតដែលត្រូវធ្វើសាជាថ្មី ប្រសិនបើមានគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាផ្លូវការលទ្ធផលនៃការបោះឆ្នោត ហើយកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយនីមួយៗ តាមមណ្ឌលនីមួយៗ ដោយគិតតាមចំនួនសន្លឹកឆ្នោតបានការ ។

ការបែងចែកអាសនៈតាមខេត្ត ក្រុង ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដោយផ្អែកលើចំនួនអាសនៈក្នុងខេត្ត ក្រុង និងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង តាមជំហានទាំងឡាយដូចខាងក្រោម :

**ជំហានទី ១** : កំណត់ចំនួនកូតាដែលតម្រូវឱ្យគណបក្សនយោបាយណាមួយទទួលអាសនៈមួយ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបនៅក្នុងខេត្ត ក្រុង មកចែកនឹងចំនួនអាសនៈសរុបក្នុងខេត្ត ឬក្រុង តាមរូបមន្តដូចខាងក្រោមនេះ និងត្រូវអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់ខេត្ត ក្រុងនីមួយៗ :

$$\text{ក}_{\text{ត}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}}$$

ក្នុងនោះ :

- $\text{ក}_{\text{ត}}$ : តាងឱ្យកូតាជាផលចែក ដោយមិនគិតសំណល់ចែក ។
- $\text{ស}_{\text{ស}}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុង ។

- $\textbf{អ}_{\text{ស}}$ : តាងឱ្យចំនួនអាសនៈសរុបតាមមណ្ឌលខេត្ត ក្រុង ។

**ជំហានទី ២ :** កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួលនៅក្នុងខេត្ត ក្រុង ។

រូបមន្តដូចខាងក្រោមត្រូវអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់គណបក្សនយោបាយនីមួយៗ ដែលបានចូលរួមនៅក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុង :

$$\textbf{អ}_{\text{ឆ}} = \frac{\textbf{ស}_{\text{ប}}}{\textbf{ក}_{\text{ត}}}$$

ក្នុងនោះ :

- $\textbf{អ}_{\text{ឆ}}$ : ជាផលចែកដោយមិនគិតសំណល់ចែក តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗ មានសិទ្ធិបានទទួលមុនពេលធ្វើប្រមាណវិធី ចាំបាច់ណាមួយក្នុងជំហានទី ៣ ។
- $\textbf{ស}_{\text{ប}}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឱ្យគណបក្សនយោបាយណាមួយនៅក្នុងខេត្ត ក្រុង ។
- $\textbf{ក}_{\text{ត}}$ : តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី ១ ។

បន្ទាប់ពីគណនា គ្រប់គណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងខេត្ត ក្រុងក្នុងជំហានទី ២ ប្រសិនបើគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈត្រូវសម្រេចកំណត់យកតែម្តង ។

ក្នុងករណីមានអាសនៈនៅសល់ ត្រូវបន្តបែងចែកបន្ទាប់ពីធ្វើការគណនាសម្រាប់គណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុង អាសនៈដែលនៅសល់ទាំងនេះត្រូវកំណត់ទៅតាមរបៀបដែលបានកំណត់ក្នុងជំហានទី ៣ ។

**ជំហានទី ៣ :** អាសនៈដែលនៅសល់ ត្រូវបែងចែកឱ្យគណបក្សនយោបាយនីមួយៗ មានសិទ្ធិបានទទួលនៅក្នុងខេត្ត ក្រុង ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត។ រូបមន្តដូចខាងក្រោមត្រូវអនុវត្តដាច់ដោយឡែកពីគ្នាសម្រាប់គណបក្សនយោបាយនីមួយៗដែលបានចូលរួមក្នុងការបោះឆ្នោតតាមខេត្ត ក្រុង :

$$ម_ឧ = \frac{ស_ប}{អ_ឧ + ១}$$

ក្នុងនោះ :

- $ម_ឧ$ : តាងឱ្យមធ្យមភាគខ្ពស់បំផុត ។
- $ស_ប$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការដែលបានបោះឱ្យគណបក្សនយោបាយមួយ ។
- $អ_ឧ$ : តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យគណបក្សនយោបាយមួយ ។

ក្នុងករណីដែលនៅសល់អាសនៈចំនួនមួយដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្ត ក្នុងជំហានទី ៣ សម្រាប់គណបក្សនយោបាយដែលមានលក្ខណៈសម្បត្តិទាំងអស់ អាសនៈនោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ក្នុងករណីដែលនៅសល់អាសនៈច្រើនជាងមួយដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទី ៣ ហើយអាសនៈចំនួនមួយត្រូវបែងចែកទៅឱ្យគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត ។ បន្ទាប់មកត្រូវអនុវត្តរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ $អ_ឧ$ ចំនួន ១ ចំពោះគណបក្សនយោបាយដែលបានទទួលអាសនៈចំនួនមួយក្នុងការអនុវត្តរូបមន្តលើកទីមួយ ។ ដូច្នេះចំនួនអាសនៈចំនួនមួយត្រូវផ្តល់ឱ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។ ក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកអាសនៈម្តងមួយអាសនៈជាបន្តបន្ទាប់ រហូតដល់អស់អាសនៈដែលនៅសល់ ។

**៩.** ការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រត្រូវអនុលោមទៅតាមបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងអនុវត្តតាមលំដាប់លេខរៀងដូចមានចែងក្នុងមាត្រា ៣៨ ថ្មី នៃច្បាប់នេះ ។

**១០.** ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតមានអ្នកជាប់ឆ្នោតទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពតំណាងរាស្ត្រ បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនោះត្រូវបានប្រកាសថាជាប់ឆ្នោតជាតំណាងរាស្ត្ររបស់សាមីគណបក្សនយោបាយ ។

**ឃ.** ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយមានបេក្ខជនមិនគ្រប់គ្រាន់ ដោយមូលហេតុដូចមានចែងក្នុងចំណុច **គ** នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលដប់បួន (១៤) ថ្ងៃ ក្រោយពីបានទទួលសំណើ ។

បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៣៣ ថ្មី មាត្រា ៣៤ ថ្មី មាត្រា ៣៥ ថ្មី មាត្រា ៣៦ ថ្មី មាត្រា ៣៨ ថ្មី មាត្រា ៤១ ថ្មី មាត្រា ៤២ ថ្មី មាត្រា ៤៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ក្នុងករណីគណបក្សនយោបាយណាមួយមិនបានអនុវត្តតាមពេលវេលាកំណត់ខាងលើ ឬមិនបានកែលំអការខ្វះខាតដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។

**ង.** ក្នុងករណីគណបក្សនយោបាយណាមួយបានទទួលអាសនៈមួយ ឬច្រើន នៅក្នុងរដ្ឋសភា ប៉ុន្តែគណបក្សនយោបាយនោះបានប្រកាសបោះបង់ចោលអាសនៈរបស់ខ្លួន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងបេក្ខជននៃគណបក្សនយោបាយនោះដែលបានប្រកាសថាជាប់ឆ្នោតរួចហើយ មិនមានសុពលភាព និងមិនមានគុណសម្បត្តិតទៅទៀតបានឡើយ ។

ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ ទៅឱ្យគណបក្សនយោបាយផ្សេងដែលទទួលបានអាសនៈក្នុងខេត្ត ក្រុងជាមួយ តាមជំហានទាំងឡាយដូចខាងក្រោម ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់អាសនៈ :

**ជំហានទី ១ :** កំណត់កូតាដែលតម្រូវឱ្យគណបក្សនយោបាយបានទទួលមួយអាសនៈតាមរូបមន្តដូចខាងក្រោម :

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}}$$

ក្នុងនោះ :

- $\textbf{ភា}_{\text{ត}}$ : តាងឱ្យកូតាជាផលចែកដោយមិនគិតសំណល់ចែក ។

- $\textbf{ស'}_{\text{ស}}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យគណបក្សនយោបាយទាំងអស់ដែលទទួលអាសនៈក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុង ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឱ្យគណបក្សនយោបាយដែលបោះបង់អាសនៈនៅក្នុងខេត្ត ក្រុង ។

- $\textbf{អា}_{\text{ប}}$ : តាងឱ្យអាសនៈដែលបានបោះបង់ចោលនៅក្នុងខេត្ត ក្រុង ។

**ជំហានទី ២** : កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួល តាមរូបមន្តដូចខាងក្រោម :

$$\textbf{អា}_{\text{ន}} = \frac{\textbf{ស}_{\text{ប}}}{\textbf{ភា}_{\text{ត}}}$$

ក្នុងនោះ :

- $\textbf{អា}_{\text{ន}}$ : តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុងខេត្ត ក្រុងបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទី ៣ ។

- $\textbf{ស}_{\text{ប}}$ : តាងឱ្យសន្លឹកឆ្នោតបានការសរុបបោះឱ្យគណបក្សនយោបាយមួយក្នុងខេត្ត ក្រុង ។

- $\textbf{ភា}_{\text{ត}}$ : តាងឱ្យចំនួនកូតាដែលបានកំណត់ក្នុងជំហានទី ១ ។

បន្ទាប់ពីបានគណនាក្នុងជំហានទី ២ គ្រប់គណបក្សនយោបាយដែលទទួលបានអាសនៈក្នុងខេត្ត ក្រុង លើកលែងតែគណបក្សនយោបាយដែលបោះបង់អាសនៈក្នុងខេត្ត ក្រុង ក្នុងករណីគ្មាននៅសល់អាសនៈដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីគណនាក្នុងជំហានទី ២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៅទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងជំហានទី ៣ ។

**ជំហានទី ៣ :** អាសនៈដែលនៅសល់ត្រូវបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តដូចខាងក្រោម :

$$ម'_{ឌ} = \frac{ស_{ប}}{អ'_{ឌ}+១}$$

ក្នុងនោះ :

- **$ម'_{ឌ}$** : តាងឱ្យមធ្យមភាគខ្ពស់បំផុត ។

- **$ស_{ប}$** : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យគណបក្សនយោបាយមួយក្នុងខេត្ត ក្រុង ។

- **$អ'_{ឌ}$** : តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យទៅគណបក្សនយោបាយមួយ ។

វិធីសាស្ត្រដូចមានចែងក្នុងវាក្យខ័ណ្ឌទី ៩ និងវាក្យខ័ណ្ឌទី ១០ ចំណុច **ក** នៃមាត្រានេះ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទី ៣ និងការគណនាជាបន្តបន្ទាប់ទៀត ។

**ខ.** ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នា ដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឱ្យគណបក្សណាមួយបាន អាសនៈនោះត្រូវផ្តល់ជូនទៅគណបក្សនយោបាយដែលទទួលបានចំនួនសន្លឹកឆ្នោតបានការខ្ពស់ជាងគេ ។ ក្នុងករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នាទៀតនោះ អាសនៈដែលនៅសល់នោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយតាមការចាប់ឆ្នោត ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**គ.** ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុច **ឃ** នៃមាត្រានេះ ។

**៨.** ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច **ក** នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលនីមួយៗជាបន្តបន្ទាប់ ។

**ឃ.** មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើសេចក្ដីរាយការណ៍ជូនគ្រប់តំណាងគណបក្សនយោបាយដែលចូលរួមបោះឆ្នោត នូវចំនួនសន្លឹកឆ្នោតសរុបដែលបានបោះពុម្ព ចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងចំនួនសន្លឹកឆ្នោតដែលនៅសល់ ។

**ខ្ស.៣. ស្ថានីយ៍បោះឆ្នោត ឬការិយាល័យបោះឆ្នោត** (Polling Station) : គឺជាដែនដីរួមគ្នាមួយដែលបង្រួបបង្រួមអ្នកបោះឆ្នោតទាំងអស់ ក្នុងកន្លែងរួមមួយសំរាប់ធ្វើការបោះឆ្នោត ។ ស្ថានីយ៍បោះឆ្នោតទាំងនេះវាជាលក្ខណៈបច្ចេកទេសមួយដែលគ្រប់គ្រង និងបង្កើត វាពុំមែនដោយច្បាប់ទេ តែដោយឋានានុក្រមនៃច្បាប់ដូចជាបទបញ្ជា និងនីតិវិធីផ្សេងៗរបស់ក្រសួងមហាផ្ទៃ ឬក៏ស្ថាប័នមានសមត្ថកិច្ច ។ ស្ថានីយ៍បោះឆ្នោតនេះនៅប្រទេសអ៊ីតាលីគេចែកជាសិកស្យុង (Section) ដែលមានអ្នកបោះឆ្នោតចាប់ពី ៥០០ ដល់ ២០០០ នាក់ ។ សំរាប់ស្រុកខ្មែរបានកំណត់ក្នុងច្បាប់បោះឆ្នោត ១៩៩៧ នៃមាត្រា ៤៦ ថា ក "ការិយាល័យបោះឆ្នោតនីមួយៗត្រូវមានប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតយ៉ាងច្រើន ៧០០ នាក់ ។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវប្រមូលផ្ដុំដោយភូមិទាំងមូល និងត្រូវបង្កលក្ខណៈឱ្យសមាជិកទាំងអស់របស់គ្រួសារក្នុងភូមិនោះ បានទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។

ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយ មានចំនួនអ្នកបោះឆ្នោតលើសពី ៧០០ នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះទៅក្នុងការិយាល័យបោះឆ្នោតដែលជិតបំផុត ក្នុងឃុំ-សង្កាត់ជាមួយ ។

ខ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិជ្រើសយកបរិវេណ ឬអគារតែមួយធ្វើជាការិយាល័យបោះឆ្នោត សំរាប់ការិយាល័យបោះឆ្នោតពីរ ឬច្រើន ប្រសិនបើមិនធ្វើឱ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តិទៅនៃការបោះឆ្នោត ។

• ការិយាល័យបោះឆ្នោតជាច្រើនដែលតាំងនៅបរិវេណ ឬអគារតែមួយនោះត្រូវរៀបចំឱ្យស្ថិតនៅដាច់ដោយឡែកពីគ្នា ។

• ការិយាល័យបោះឆ្នោតនីមួយៗដែលតាំងនៅបរិវេណ ឬអគារតែមួយនោះត្រូវគ្រប់គ្រងឱ្យដាច់ចេញពីគ្នា និងខុសពីការិយាល័យបោះឆ្នោតផ្សេងទៀតទៅតាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត"។ ចំពោះ**មាត្រា ៤៥ ថ្មី** បានចែងថា "គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសំរេចបង្កើតការិយាល័យបោះឆ្នោតមួយ ឬច្រើន សំរាប់ឃុំ-សង្កាត់ នីមួយៗ ស្របតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវទទួលខុសត្រូវតំបន់មួយដែលបានកំណត់ ។

ការិយាល័យបោះឆ្នោត និងតំបន់ ដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវស្ថិតនៅក្នុងព្រំប្រទល់ឃុំ-សង្កាត់របស់ខ្លួន"។

**៩.១.៤. អង្គការបោះឆ្នោត** (Electoral organs) : ជាអង្គការដឹកនាំនៃគ្រប់ដំណើរការបោះឆ្នោត ។ អង្គការទាំងនេះមាន : គណៈកម្មការ, ការិយាល័យផ្សេងៗ ឬក៏ផ្នែកសំរបសំរួលដល់ការពិនិត្យបោះឆ្នោត ។ល។ ដោយអាស្រ័យនឹងទំរង់គ្រប់គ្រងនៃដែនដី គេអាចបង្កើតអង្គការបោះឆ្នោតនេះដូចជា : អង្គការកណ្តាល, អង្គការមណ្ឌល, និងអង្គការស្ថានីយ៍ ដូច**មាត្រា ១១** ច្បាប់បោះឆ្នោតដដែលនេះបានកំណត់ថា "ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវគ្រប់គ្រងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានគណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ដើម្បីធានាអនុវត្តការងាររបស់ខ្លួន"។ ចំណែកសមាសភាពនៃអង្គការទាំងនោះត្រូវរៀបចំតាមច្បាប់ច្បាស់លាស់ ដូច**មាត្រា ១៣** ច្បាប់បោះឆ្នោតបានកំណត់ថា "គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាពដូចតទៅ :

| | |
|---|---|
| - ឥស្សរជនខ្មែរមួយរូប | ប្រធាន |
| - ឥស្សរជនខ្មែរមួយរូប | អនុប្រធាន |
| - ឥស្សរជនខ្មែរបីរូប | សមាជិក |

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសមត្ថភាពខាងនយោបាយ បទពិសោធន៍ក្នុងការងារ និងមានកេរ្តិ៍ឈ្មោះល្អ ។

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងតិច ៧ ខែ មុនថ្ងៃបោះឆ្នោត តាមសំណើរបស់គណៈរដ្ឋមន្ត្រី ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានភារកិច្ចដាក់ជូនគណៈរដ្ឋមន្ត្រីនូវសេចក្តីព្រាង សមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យ៉ាងតិច ៩ ខែ មុនថ្ងៃបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិជ្រើសរើសបុគ្គលិកតាមការចាំបាច់សំរាប់ដំណើរការបោះឆ្នោត និងមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ"។ សូមបញ្ជាក់ថាតួនាទីនិងឋានៈនៃអង្គការបោះឆ្នោតមានជាច្រើនទៀត ដែលកំណត់ដោយច្បាប់បោះឆ្នោតក្នុង**មាត្រា ៣០** បានកំណត់ថា "ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋមន្ត្រី ។ សមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុសិទ្ធិស្មើនឹងរដ្ឋលេខាធិការ ។ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអគ្គនាយកក្រសួង"។

ដូចនេះ យើងឃើញថាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាអង្គការកណ្តាល រីឯគណៈកម្មការខេត្ត-ក្រុង ជាអង្គការមណ្ឌល និងគណៈកម្មការឃុំ-សង្កាត់ ជាអង្គការស្ថានីយ៍ ។

**៩.៤. ការចុះបញ្ជីអ្នកបោះឆ្នោត** ( Registration Roll) : ការចុះបញ្ជីវាជាល័ក្ខខ័ណ្ឌមួយចាំបាច់នៃការបំពេញភារកិច្ចរបស់អ្នកបោះឆ្នោត ដោយបានកំណត់នូវសិទ្ធិបោះឆ្នោត ដែលក្នុងនោះរួមទាំងកំណត់បុគ្គលក្នុងបញ្ជីអ្នកបោះឆ្នោតទៀតផង ។

ការចាប់ផ្ដើមចុះបញ្ជីអ្នកបោះឆ្នោត គឺជាការកំណត់មុនពេលបោះឆ្នោតទៅលើអត្តភាពដែលមានសិទ្ធិបោះឆ្នោត គឺមានន័យថាមានតែមនុស្សនេះ ឬនោះទេដែលអាចមានសិទ្ធិកាន់ប័ណ្ណបោះឆ្នោត (Voting bulletin) ។ តាមលក្ខណៈទ្រឹស្ដីដែលបានពិនិត្យទៅលើការចុះបញ្ជីបោះឆ្នោត តាមប្រព័ន្ធបញ្ជីអ្នកបោះឆ្នោត[៤២] មានពីរប្រព័ន្ធ ដែលប្រព័ន្ធនីមួយៗមានលក្ខណៈជាសាធារណៈ (កាតព្វកិច្ច) ឬក៏បុគ្គល (ស្ម័គ្រចិត្ត) ។

**ខ១.៩.១. ប្រព័ន្ធទីមួយ** : នេះគឺជាប្រព័ន្ធមួយ ដែលការចុះបញ្ជីអ្នកបោះឆ្នោតប្រកាន់យកល័ក្ខខ័ណ្ឌពីរផ្សេងគ្នាគឺ :

- **ល័ក្ខខ័ណ្ឌទីមួយ** : ការចុះបញ្ជីតាមចំនួនប្រជាជន និងតាមការបំលាស់ទីរបស់ប្រជាជន ដូចជានៅ**អាល្លឺម៉ង់. ស៊ុយអ៊ែដ. ស្វីស.** ។ ក្នុងប្រទេសទាំងនេះអំណាចសាធារណៈមានពត៌មានច្បាស់លាស់ ស្ដីអំពីបុគ្គលទាំងឡាយដែលរស់នៅលើទឹកដីកាន់កាប់មួយ ។ ល័ក្ខខ័ណ្ឌនេះ បើបុគ្គលណាពុំមានចុះក្នុងបញ្ជីរស់នៅរបស់អាជ្ញាធរមូលដ្ឋានច្បាស់លាស់ទេ នោះមិនអនុញ្ញាតិចុះក្នុងបញ្ជីអ្នកបោះឆ្នោតបានឡើយ ។

- **ល័ក្ខខ័ណ្ឌទីពីរ** : គឺអវត្តមាននូវការចុះបញ្ជីទៅលើប្រជាជនបំលាស់ទីទាំងបង្ហំ ដូចជានៅ**ចក្រភពអង់គ្លេស. កាណាដា** ។ លក្ខណៈរបៀបនេះ គឺការចុះបញ្ជីត្រូវធ្វើឡើងក្នុងពេលកំណត់មួយច្បាស់លាស់ ។ នៅក្នុងល័ក្ខខ័ណ្ឌនេះ បើបុគ្គលណាបំលាស់ទីពុំសមស្របតាមពេលកំនត់ណាមួយដែលតំរូវឱ្យចុះបញ្ជីបោះឆ្នោត បុគ្គលនោះមិនអាចមានសិទ្ធិបោះឆ្នោតបានទេ ។

**ខ១.៩.២. ប្រព័ន្ធទីពីរ** : គឺអ្នកបោះឆ្នោតត្រូវមកកន្លែងស្នាក់ការ ដោយភ្ជាប់មកនូវឯកសារដែលត្រូវចុះបញ្ជីសំរាប់ចូលរួមការបោះឆ្នោត ។ ដូចជាប្រទេស**អាមេរិក. បារាំង. កម្ពុជា**.......... ។ រីឯបញ្ជីអ្នកបោះឆ្នោតក្នុងប្រព័ន្ធនេះធ្វើឡើងតាមស្ថានីយ៍បោះឆ្នោត ឬក៏ស្នាក់ការរបស់គេ ពុំមែនធ្វើដូចប្រព័ន្ធទីមួយទេ ។ ចំពោះប្រទេសកម្ពុជាច្បាប់បោះឆ្នោត ១៩៩៧ **មាត្រា ៤៨** ថ្មី បានកំណត់ថា "គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឱ្យមានបញ្ជីបោះឆ្នោតសំរាប់ការិយាល័យបោះ

[៤២] .Carlson R. J Voter Rigistration Systems in Canada and Western Europe.N.Y 1974. Page 1 ។

ឆ្នោតនីមួយៗ ដែលបង្កើតឡើងតាមបទបញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៤៥ ថ្មី និងមាត្រា ៤៦ ថ្មី នៃច្បាប់នេះ ( ច្បាប់វិសោធនកម្ម ) ។

បញ្ជីបោះឆ្នោតតាមការិយាល័យនីមួយៗ ត្រូវកំណត់ចូលក្នុងសៀវភៅបញ្ជីមួយ ហើយរក្សាទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ តាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ ៩០ ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនអាណត្តិ បញ្ជីបោះឆ្នោតត្រូវយកបញ្ជីបោះឆ្នោតដែលមានសុពលភាពចុងក្រោយ ទុកជាផ្លូវការ ហើយត្រូវផ្សព្វផ្សាយបញ្ជីនេះយ៉ាងតិច ៥០ ថ្ងៃ មុនថ្ងៃបោះឆ្នោត" ។ រីឯមាត្រា ៥៤ ថ្មី បានកំណត់ថា "ក ដើម្បីចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋត្រូវទៅបង្ហាញខ្លួននៅសាលាឃុំ សង្កាត់របស់ខ្លួន ឬទីកន្លែងណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ពេលបង្ហាញខ្លួនប្រជាពលរដ្ឋត្រូវ :

- បង្ហាញអត្តសញ្ញាណរបស់ខ្លួនដល់ស្មៀនឃុំ សង្កាត់ ។
- មានសិទ្ធិបោះឆ្នោតស្របតាមមាត្រា ៥០ ថ្មី នៃច្បាប់នេះ ។
- មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់ ។

ក្នុងករណីដែលមានប្រជាពលរដ្ឋដែលទទួលមរណភាព ដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោត ដែលបានផ្លាស់ទីលំនៅចេញទៅឃុំ សង្កាត់ផ្សេង ស្មៀនឃុំ សង្កាត់ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋទាំងនោះដាក់ក្នុងបញ្ជីមួយដោយឡែក ហើយក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៤៩ ថ្មី នៃច្បាប់នេះ ស្មៀនឃុំ សង្កាត់ត្រូវលុបឈ្មោះប្រជាពលរដ្ឋទាំងនោះចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ក្នុងឃុំ សង្កាត់របស់ខ្លួន ។

ចំពោះប្រជាពលរដ្ឋដែលមិនបានចុះឈ្មោះពីមុនមក ដែលទើបដល់អាយុត្រូវបោះឆ្នោត ដែលបានផ្លាស់ទីលំនៅចូលថ្មី ស្មៀនឃុំ សង្កាត់ ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋទាំងនោះដាក់ក្នុងបញ្ជីមួយដោយឡែក ហើយក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋទាំងនោះត្រូវបំពេញល័ក្ខខ័ណ្ឌសម្រាប់ការចុះឈ្មោះ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ និងវាក្យខ័ណ្ឌទី ២ នៃមាត្រានេះ ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាឃុំ សង្កាត់អាចចាត់ឱ្យធ្វើការចុះឈ្មោះចល័ត ស្របតាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ខ ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយដូចខាងក្រោម :

- លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។
- អត្តសញ្ញាណប័ណ្ណដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជា ដោយមានបិទរូបថតជាសំគាល់ ។
- សៀវភៅគ្រួសារ ។

ប្រជាពលរដ្ឋដែលមកបង្ហាញខ្លួន អាចកំណត់អត្តសញ្ញាណរបស់ខ្លួនបាន ដោយការធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីររូបក្នុងឃុំ សង្កាត់នោះ ធ្វើឡើងនៅចំពោះមុខមេឃុំ ចៅសង្កាត់ ឬចំពោះមុខជំទប់ ចៅសង្កាត់រង ក្នុងករណីមេឃុំ ចៅសង្កាត់អវត្តមានដោយបញ្ជាក់ថា អ្នកសុំចុះឈ្មោះនោះពិតជាមនុស្សដូចដែលសាមីខ្លួនបានបញ្ជាក់អះអាងមែន រួចហើយត្រូវយកលិខិតបញ្ជាក់នោះមកបង្ហាញស្មៀនឃុំ សង្កាត់ភ្លាម ដើម្បីបំពេញបែបបទចុះឈ្មោះបោះឆ្នោត ។

គ ដើម្បីបញ្ជាក់ថាខ្លួនជាប្រជាពលរដ្ឋខ្មែរ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយក្នុងចំណោមឯកសារដូចខាងក្រោម :

- លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលបានផ្តល់ឱ្យ អនុលោមទៅតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ៣៦ អនក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៩៦ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

- អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

- ឆាយារបស់ព្រះសង្ឃ ។

- ភស្តុតាងដែលបង្ហាញថា ឈ្មោះរបស់អ្នកសុំចុះឈ្មោះមាននៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ និងសៀវភៅបញ្ជីបោះឆ្នោតរបស់ឃុំ សង្កាត់ ។

- សំបុត្រកំណើតដែលមានបញ្ជាក់ពីសញ្ជាតិខ្មែរ ។

- លិខិតបញ្ជាក់ថាជាប្រជាពលរដ្ឋខ្មែរ ដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជា ។

- លិខិតបញ្ជាក់ឯកសារ ឬសេចក្តីសម្រេចស្ថាពររបស់តុលាការ ដែលបញ្ជាក់ថាឪពុក ឬម្តាយរបស់អ្នកសុំចុះឈ្មោះជាប្រជាពលរដ្ឋខ្មែរ និងឯកសារដែលបង្ហាញថាអ្នកសុំចុះឈ្មោះគឺជាកូនរបស់ឪពុក ឬម្តាយនោះ ។

- ឯកសារជាផ្លូវការបង្ហាញថា អ្នកសុំចុះឈ្មោះកើតនៅក្នុងប្រទេសកម្ពុជា ហើយឪពុក និងម្តាយបរទេសរបស់ជននោះក៏កើត និងរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជាដែរ និងឯកសារជាផ្លូវការដែលបង្ហាញថា អ្នកសុំចុះឈ្មោះគឺជាកូនរបស់ឪពុក និងម្តាយនោះ ។

**ឃ** ដើម្បីបញ្ជាក់ថាខ្លួនមានអាយុយ៉ាងតិច ១៨ ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយដូចខាងក្រោម :

- ឯកសារណាមួយដូចមានចែងក្នុងមាត្រា ៥៤ ថ្មី ខ និង គ នៃច្បាប់នេះ ដែលមានបញ្ជាក់ពីអាយុ ឬថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកសុំចុះឈ្មោះ ឬលិខិតធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីរ (២) រូប ក្នុងឃុំ សង្កាត់នោះ ធ្វើឡើងចំពោះមុខមេឃុំ ចៅសង្កាត់ ដោយបញ្ជាក់ថាអ្នកសុំចុះឈ្មោះនោះពិតជាមានអាយុ ១៨ ឆ្នាំ យ៉ាងតិច គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រប្រាកដមែន ។

**ង** ដើម្បីបញ្ជាក់ថាខ្លួនពិតជាមានទីលំនៅនៅក្នុងឃុំ សង្កាត់ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយដូចខាងក្រោម :

- ឯកសារទាំងឡាយដូចមានចែងក្នុងមាត្រា ៥៤ ថ្មី ខ គ និង ឃ នៃច្បាប់នេះ ហើយដែលបញ្ជាក់ថា អ្នកសុំចុះឈ្មោះពិតជាមានទីលំនៅនៅក្នុងឃុំ សង្កាត់នោះប្រាកដមែន ឬលិខិតបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់ ថាសាមីខ្លួនពិតជាមានទីលំនៅនៅក្នុងឃុំ សង្កាត់នោះប្រាកដមែន ។

ច ក្នុងករណីដែលប្រជាពលរដ្ឋមានឯកសារគ្រប់គ្រាន់ត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា ៥៤ ថ្មី ខ គ ឃ និង ង នៃច្បាប់នេះ ស្មៀនឃុំ សង្កាត់ ត្រូវ :

- ចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត ។

- កត់ឈ្មោះប្រជាពលរដ្ឋនោះចូលក្នុងសៀវភៅបញ្ជីបោះឆ្នោត ។

- ចេញបង្កាន់ដៃបញ្ជាក់អំពីការចុះឈ្មោះជូនសាមីខ្លួន ។

- បញ្ជាក់ប្រាប់ប្រជាពលរដ្ឋ អំពីការិយាល័យបោះឆ្នោតដែលប្រជាពលរដ្ឋនោះត្រូវទៅបោះឆ្នោត ។

ចំពោះប្រជាពលរដ្ឋណាដែលមានឈ្មោះក្នុងសៀវភៅបញ្ជីបោះឆ្នោតរួចហើយ ស្មៀនឃុំ សង្កាត់គ្រាន់តែពិនិត្យភស្តុតាងនៃការចុះឈ្មោះរបស់ជននោះ ប្រសិនបើជននោះមិនស្ថិតក្នុងករណីណាមួយ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ៣ មាត្រា ៥៤ ថ្មី ក នៃច្បាប់នេះ ស្មៀនឃុំ សង្កាត់ ត្រូវធ្វើបច្ចុប្បន្នភាពឈ្មោះរបស់ជននោះចូលក្នុងបញ្ជីបោះឆ្នោត" ។ និងមាត្រា ៦៣ ថ្មី បានកំណត់ថា "បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ហើយការប្តឹងតវ៉ាទៅនឹងការចុះឈ្មោះត្រូវបានដោះស្រាយរួចរាល់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យបិទផ្សាយជាសាធារណៈបញ្ជីបោះឆ្នោតដំបូងនៅសាលាឃុំ សង្កាត់ និងទីតាំងណាមួយក្នុងឃុំ សង្កាត់ តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ ស្តីពីគណបក្សនយោបាយមានសិទ្ធិសុំបញ្ជីបោះឆ្នោតថតចម្លងនេះបានដោយបង់ថ្លៃ ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ" ។

**ខ.៦.ការជ្រើសរើសឱ្យឈរឈ្មោះ** (The Nomination of Candidates) :នេះជាលំដាប់ថ្នាក់មួយសំរាប់កំណត់ដំណើរការបោះឆ្នោត គឺមានន័យថាការកំរិតនូវវង្វង់បុគ្គលក្នុងចំនួនមួយ ដែល

នឹងត្រូវជ្រើសរើសជាប្រធានាធិបតី, តំណាងរាស្ត្រ, សមាជិកព្រឹទ្ធសភា, អភិបាលអំណាចមូលដ្ឋាន និងជំរើសផ្សេងៗទៀត។ មានមធ្យោបាយមួយចំនួនក្នុងការកំណត់នៃការជ្រើសរើសឱ្យឈរឈ្មោះគឺ:

**ខ.១.៦.១.ការធ្វើឱ្យមានជាបេក្ខភាពដោយខ្លួនឯង** : ការធ្វើរបៀបនេះ គឺបុគ្គលដែលមានបំណងឈរឈ្មោះត្រូវធ្វើសេចក្តីសុំមួយទៅការិយាល័យរបស់រដ្ឋ ដែលមាននាទីក្នុងកិច្ចការនោះ។ ដូចជាប្រទេសបារាំង អ្នកដែលមានបំណងឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ដោយគ្រាន់តែដាក់ពាក្យសុំទៅការិយាល័យខេត្ត (Prefecture) ដែលបញ្ជាក់នូវនាមត្រកូល, មុខរបរ ថ្ងៃខែឆ្នាំកំណើតតែប៉ុណ្ណោះ ។

**ខ.១.៦.២. ការធ្វើឱ្យមានបេក្ខភាពដោយក្រុមអ្នកបោះឆ្នោត** : ការធ្វើរបៀបនេះគឺបុគ្គលពឹងផ្អែកលើសំលេងគាំទ្ររបស់អ្នកបោះឆ្នោត ដែលមានចំនួនមនុស្សកំណត់មួយ។ ដូចជានៅប្រទេសបែលស៊ិក ដើម្បីក្លាយជាបេក្ខជនតំណាងរាស្ត្របានត្រូវមានហត្ថលេខាពីប្រជាជន (អ្នកមានសិទ្ធិបោះឆ្នោត) ចាប់ពី ២០០ ដល់ ៥០០ នាក់ ឬក៏មានតំណាងរាស្ត្រមិនតិចជាង ៣ នាក់ ដែលមានអាណត្តិបញ្ចប់នោះសំរាប់គាំទ្រ ។

**ខ.១.៦.៣. ការធ្វើឱ្យមានបេក្ខភាពដោយបក្សនយោបាយ ឬក៏កំលាំងសង្គម** : ការធ្វើរបៀបនេះគឺសំដៅយកគណៈបក្សនយោបាយជាអ្នកចាត់ចែងបេក្ខជន ដោយផ្អែកតាមគោលការណ៍នៃប្រព័ន្ធបោះឆ្នោតដែលបានកំណត់ ។ ដូចជា**ហ្វាំងឡង់, អាល្លឺម៉ង់, ជប៉ុន, កម្ពុជា** ....... ។ តាម**មាត្រា ៣៣ ថ្មី** ច្បាប់បោះឆ្នោតកម្ពុជា ១៩៩៧ បានកំណត់ថា "ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

១. មានសញ្ជាតិខ្មែរពីកំណើត ។

២. មានអាយុ ២៥ ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត ។

៣. មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

៤. មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មានការតែងតាំងពីគណៈបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត" ។

**៩.១.៧. យុទ្ធនាការឃោសនាបោះឆ្នោត** (Election Compaign) : នេះគឺជាលំដាប់ថ្នាក់មួយនៃដំណើរការបោះឆ្នោត ។ យុទ្ធនាការនេះនឹងត្រូវកំណត់ថាតើបុគ្គលណាមួយ ឬបក្សនយោបាយណានឹងត្រូវទទួលបាននូវការបោះឆ្នោតគាំទ្រពីអ្នកបោះឆ្នោត ។ យុទ្ធនាការនេះគណៈបក្ស ឬបុគ្គលដែលឈរឈ្មោះត្រូវកំណត់គោលដៅច្បាស់លាស់ ដូចច្បាប់បោះឆ្នោតកម្ពុជា ១៩៩៧ **មាត្រា ៧០** កំណត់ថា "ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណៈបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួន ជូនអ្នកបោះឆ្នោតដើម្បីយកទៅពិភាក្សា និងត្រិះរិះពិចារណា" ។ ក្រៅពីនេះក្នុងច្បាប់បោះឆ្នោតនោះនៅមានមាត្រា ៧១. ៧២. ៨១. ៨២. ដែលកំណត់ក្នុងការឃោសនាបោះឆ្នោតនេះដែរ ។

**៩.១.៨. ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងសរុបលទ្ធផល** : នេះគឺជាលំដាប់ថ្នាក់មួយទៀតនៃដំណើរការបោះឆ្នោត ។ លក្ខណៈនេះគេសង្កេតឃើញ :

**៩.១.៨.១. ការបោះឆ្នោត** : វាត្រូវធ្វើក្នុងកំរិតណាមួយពិតប្រាកដ (រយៈពេល) ដូចច្បាប់បោះឆ្នោតកម្ពុជាបានកំណត់ក្នុង**មាត្រា ៨៥ ថ្មី** ថា "ការបោះឆ្នោតត្រូវធ្វើតែមួយថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោងប្រាំពីរ (៧:០០) ព្រឹក រហូតដល់ម៉ោងដប់ប្រាំ (១៥:០០) លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានបោះគ្រប់គ្នាហើយ គណៈកម្មការការិយាល័យបោះឆ្នោតអាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោងដប់ប្រាំ (១៥:០០) ។

ប្រធានការិយាល័យបោះឆ្នោត ត្រូវប្រកាសបិទការបោះឆ្នោតនៅម៉ោងដប់ប្រាំ (១៥:០០) ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោត មិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណខាងក្នុងក្រោយម៉ោងដប់ប្រាំ (១៥:០០) ឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោងដប់ប្រាំ(១៥:០០)ហើយអាចអនុញ្ញាតឱ្យបោះឆ្នោតគឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុង នៅម៉ោងដប់ប្រាំ (១៥:០០) ។

**៩.១.៨.២. ការកំណត់នូវអ្នកទទួលខុសត្រូវ** : ការកំណត់របៀបនេះ វាជាបន្ទុករបស់អង្គការបោះឆ្នោតតាមច្បាប់បោះឆ្នោតកម្ពុជា ដូច**មាត្រា ៤** បានកំណត់ថា "ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់នេះ" ។ ក្រៅពីនេះមានមាត្រាជាច្រើនទៀត ដែលបានកំណត់មុខងារទទួលខុសត្រូវលើការបោះឆ្នោត ដូចជាមាត្រា ១៦. ៨៧. ១០១. ១០២. ១០៤.... ។ល។

**៩.១.៨.៣. ការកំណត់នៃការរាប់សន្លឹកឆ្នោត** : នេះជាភារកិច្ចរបស់អង្គការបោះឆ្នោតដែរក្នុងការអនុវត្តនូវនីតិវិធីនៃការរាប់សន្លឹកឆ្នោត ដូចជាច្បាប់បោះឆ្នោតកម្ពុជា កំណត់ក្នុង**មាត្រា ១០៣** ថា "គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវរាប់ចំនួនសន្លឹកឆ្នោតដែលមាននៅក្នុងហិបឆ្នោត ហើយផ្ទៀងផ្ទាត់ចំនួននេះជាមួយចំនួនអ្នកដែលបានមកបោះឆ្នោត ដែលរាប់ឃើញក្នុងបញ្ជីបោះឆ្នោត។ ក្នុងករណីដែលសន្លឹកឆ្នោតក្នុងហិបឆ្នោត មានចំនួនខុសគ្នានឹងចំនួនអ្នកបោះឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ឱ្យរាប់ឡើងវិញ ។ ប្រសិនបើចំនួនខុសគ្នានៅមានដដែល ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចុះក្នុងកំនត់ហេតុ។ បន្ទាប់មកប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ឱ្យរាប់សន្លឹកឆ្នោត ដោយអនុលោមតាមបទបញ្ជា និងនីតិវិធី" ។ ក្រៅពីមាត្រានេះមានមាត្រាជាច្រើន ដូចជាមាត្រាទី ១០៤. ១០៥ ថ្មី. ១០៦. បានកំណត់នូវលក្ខណៈនេះ។

## ៤. ការអំពាវនាវ ឬកោះហៅ (Recall) ឬហៅថាការបញ្ចប់អាណត្តិមុនពេលកំណត់

វាជាស្ថានភាពមួយប្រឈមនឹងការបោះឆ្នោត ព្រោះថាវាជាមធ្យោបាយមួយដើម្បីបញ្ឈប់នូវអំណាចមុនអាណត្តិក្នុងអង្គការជ្រើសរើសមួយ ឬក្នុងមុខងារទទួលតំណែង ។ ការធ្វើរបៀបនេះទៅបានដោយផ្អែកលើរបបគ្រប់គ្រងប្រទេសបែបប្រជាធិបតេយ្យ (មានច្បាប់ជាបង្អែក) ឬតាមបែបអប្រជាធិបតេយ្យ (មានអំណាចជាបង្អែក) ។ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ កំណត់នៅ**មាត្រា ៧៨** ថា "នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទំលាក់ពីរដងក្នុងរយៈ ១២ ខែ ។

ក្នុងករណីនេះព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា"។ ជាទូទៅគោលការណ៍នៃការបញ្ចប់អាណត្តិមុនពេលកំណត់នេះគេពុំយកមកអនុវត្តទេ ព្រោះវាជាអំពើប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ (សូមអានពតិមានពិស្តារ ក្នុងចំណុចគោលការណ៍នៃអាណត្តិអាជ្ញាបញ្ជាក្នុងអត្ថបទទី ១៥) ។

## ៩. ប្រជាមតិ (Referendum)

**ក. និយមន័យ និងមុខងារសង្គមនៃប្រជាមតិ :** ពាក្យថា "ប្រជាមតិ" ចេញមកពីពាក្យឡាតាំងថា "Referendum" មានន័យថា "អ្វីៗនោះត្រូវតែសហយោបល់" ដូចនេះប្រជាមតិគឺជាការបញ្ចេញសំលេងរបស់អ្នកជ្រើសរើស ដែលធ្វើឡើងដោយឆន្ទៈផ្ទាល់របស់ពលរដ្ឋ ទៅលើសេចក្ដីសំរេចរបស់រដ្ឋ ឬក៏សេចក្ដីសំរេចនៃអំណាចមូលដ្ឋាន ។

ភាពផ្សេងគ្នានៃការធ្វើជំរើសតាមរយៈសំលេងបោះឆ្នោត និងប្រជាមតិ គឺថា**ប្រជាមតិវាផ្ដល់នូវកំលាំងគតិយុត្តិខ្ពស់មែន ប៉ុន្តែពុំមែនសំរាប់ជាអាណត្តិរបស់បុគ្គលណាម្នាក់ទេ**[៤៣] តែ**វាផ្ដល់នូវកំលាំងគតិយុត្តិសំរាប់ដំណោះស្រាយលើបញ្ហាអ្វីមួយ** ។ ប្រសិនបើការប្រតិបត្តិមួយតាមល័ក្ខខ័ណ្ឌដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញ ឬក៏ច្បាប់ក្នុងការធ្វើប្រជាមតិនោះ ការអនុម័តតាមវិធីនេះជាការសំរេចមួយ ដែលគេគិតថាជាការសំរេចរបស់ប្រជាជន ហើយកំលាំងគតិយុត្តិរបស់វានោះសឹងតែទាំងអស់ទៅហើយ ដែលមានកំរិតខ្ពស់ជាងកំលាំងគតិយុត្តិនៃច្បាប់ទាំងឡាយ ដែលអនុម័តឡើងដោយរដ្ឋសភា ។ ការដោះស្រាយដោយធ្វើប្រជាមតិ អាចអនុម័តឡើងដោយផ្ទាល់នូវចំលើយអវិជ្ជមាន ឬវិជ្ជមាន (យល់ព្រម ឬបដិសេធន៍) របស់អ្នកជ្រើសរើស (ពលរដ្ឋ) ទៅលើសំណួរដែលបានដាក់ ឬក៏ការធ្វើដោយផ្ទាល់នូវជំរើសរវាងមតិផ្សេងៗទៀតក្នុងការសំរេចចិត្ត ។

ការបញ្ចេញសំលេងរបស់អ្នកជ្រើសរើសមានឈ្មោះផ្សេងទៀតថា **ប្រជាសិទ្ធិ ឬសេចក្ដីសំរេចរបស់រាស្ត្រ** ដែលចេញពីពាក្យឡាតាំងថា "Plebiscitum"។ ភាពខុសគ្នារវាងប្រជាសិទ្ធិ (Plebiscite) និងប្រជាមតិ (Referendum) ក្នុងកំលាំងគតិយុត្តិពុំមានទេ គឺវាមានន័យដូចគ្នា ។

---

[៤៣] . នៅក្នុងប្រទេសខ្លះ ដែលពុំប្រកាន់យកគោលការណ៍ច្បាប់ និងពុំប្រកាន់លិទ្ធិប្រជាធិបតេយ្យច្រើន តែបំពានទៅលើការធ្វើប្រជាមតិនេះ ដើម្បីបន្តអាណត្តិគ្រប់គ្រងរបស់ខ្លួនតទៅមុខទៀត ដូចជាប្រធានាធិបតីប៉ាគីស្ថាន ធ្វើប្រជាមតិឆ្នាំ ២០០២ ជាដើម ។

ប៉ុន្តែនៅពេលខ្លះប្រជាមតិ និងប្រជាសិទ្ធិមានរចនាបថផ្សេងគ្នា (Style) គឺមានន័យថាប្រជាមតិត្រូវបានគេឱ្យឈ្មោះថាប្រជាសិទ្ធិតាមសំនួរ ឬបញ្ហាសំរាប់ប្រទេសមួយ ឬតំបន់មួយ ។ ជាឧទាហរណ៍ដូចជាការសំរេចលើបញ្ហាស្តីពីកម្មសិទ្ធិរដ្ឋដែលមានព្រំដែនទំនាស់គ្នា អំពីទំរង់គ្រប់គ្រង អំពីអ្នកដឹកនាំប្រទេស ។ល។ ប្រជាមតិធ្វើបែបនេះជាទូទៅគេហៅថា**ប្រជាសិទ្ធិ** ។ ប៉ុន្តែសំរាប់ប្រទេសខ្លះគេយកប្រជាមតិជាដំណោះស្រាយមួយសំរាប់អំណាចសាធារណៈ ដូចជា**មាត្រា ១១** រដ្ឋធម្មនុញ្ញបារាំង ឆ្នាំ ១៩៥៨ កំណត់ថាប្រធានាធិបតីសាធារណរដ្ឋតាមសំណូមពររបស់រដ្ឋាភិបាល ក្នុងពេលប្រជុំសភាពេញអង្គ (សភាតំណាងរាស្ត្រ) ឬក៏តាមសំណូមពររួមគ្នានៃសភាទាំងពីរ អាចរៀបចំធ្វើប្រជាមតិបាននូវគ្រប់សេចក្តីព្រាងច្បាប់ ដែលទាក់ទិននឹងអង្គការគ្រប់គ្រងនៃអំណាចសាធារណៈ ដោយសេចក្តីព្រាងច្បាប់នោះយល់ព្រមជាសាកល ។ មានន័យថាសេចក្តីព្រាងច្បាប់នោះ អាចយកទៅអនុម័តយល់ព្រមពីប្រជាជន ។ ប៉ុន្តែអត្ថន័យរបស់វាក្នុងមាត្រាខាងលើនេះ វាប្រឆាំងគ្នានឹងចរិតតំណាងរបស់រាស្ត្រ ដែលជាលក្ខណៈមួយពុំអាចនឹងងាយទទួលយកបាននោះទេ ។

សរុបទៅប្រជាមតិត្រូវធ្វើក្នុងគោលការណ៍ដោះស្រាយបញ្ហាសង្គម និងរដ្ឋដែលមានល័ក្ខខ័ណ្ឌដូចខាងក្រោម :

**ទីមួយ :** ការធ្វើប្រជាមតិត្រូវតែមានភាពច្បាស់លាស់ សំរាប់ពន្យល់ដល់អ្នកជ្រើសរើស (ដំណោះស្រាយនយោបាយ ឬដំណោះស្រាយអ្វី?)

**ទីពីរ :** មុនពេលធ្វើប្រជាមតិត្រូវបំភ្លឺតាមរយៈមធ្យោបាយឃោសនា ដល់អ្នកជ្រើសរើសក្នុងហេតុការណ៍ដោយស្ម័គ្រចិត្ត ឬពុំស្ម័គ្រចិត្ត ។

**ខ. សិទ្ធិចូលរួមក្នុងការធ្វើប្រជាមតិ :** អ្នកដែលមានសិទ្ធិចូលរួមក្នុងគ្រប់ប្រជាមតិ គឺជាបុគ្គលទាំងឡាយណាដែលកាន់កាប់សិទ្ធិបោះឆ្នោតសកម្ម ( មានសិទ្ធិបោះឆ្នោត, មានសិទ្ធជ្រើសរើស) ។ សិទ្ធិរបៀបនេះបានកំនត់ក្នុងវាក្យខ័ណ្ឌទី ២ **មាត្រា ៣៤** នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត" ។ (សំរាប់ប្រទេសកម្ពុជា ពុំបានកំណត់អំពីការធ្វើប្រជាមតិទេ) គួរកំណត់ចំណាំផងដែរ នូវការបញ្ចេញសំលេងក្នុងការធ្វើប្រជាមតិដោយយកគោលការណ៍ "**ស្មើភាព**" គឺមានន័យថាអ្នកជ្រើសរើសម្នាក់ៗមានសិទ្ធិបញ្ចេញសំឡេងដូចគ្នា ។

**ឆ. កម្មវត្ថុនៃប្រជាមតិ** : កម្មវត្ថុនៃប្រជាមតិ គឺជាគោលដៅចុងក្រោយនៃការដោះស្រាយបញ្ហា (សំណួរ) ដែលផ្តុកផ្តាក់ទៅលើសេចក្តីសំរេចមួយដោយផ្ទាល់ពីសំលេងប្រជារាស្ត្រ ។ ដោយយោងទៅលើកម្មវត្ថុនៃប្រជាមតិនោះ គេចែកប្រជាមតិជាពីរប្រភេទធំៗគឺ : **ប្រជាមតិជ្រើសរើស** និង **ប្រជាមតិចាំបាច់** ។

**ឆ១. ប្រជាមតិជ្រើសរើស ឬហៅថាប្រជាមតិមិនចាំបាច់** (Optional Referendum) : គឺជាប្រជាមតិមួយដែលអាចធ្វើ ឬក៏អាចនិយាយថាធ្វើក៏បានពុំធ្វើក៏បាន ។ ការចាត់តាំងធ្វើប្រជាមតិរបៀបនេះ វាអាស្រ័យនឹងឆន្ទានុសិទ្ធិនៃអង្គការដែលមានសមត្ថកិច្ចចាត់តាំងប្រជាមតិ ឬក៏វាអាស្រ័យនឹងវត្តមាននៃការកើតបែបណាមួយដោយច្បាប់ ឬរដ្ឋធម្មនុញ្ញ ។

កម្មវត្ថុនៃប្រជាមតិជំរើសនោះអាចមានរឿងរាល់សំណួរ (បញ្ហា) ដូចជាសេចក្តីព្រាងនៃការសំរេចចិត្តរបស់រដ្ឋ ឬអំណាចស្វ័យគ្រប់គ្រងលើកលែងតែបញ្ហា ឬសំនួរណា និងសេចក្តីព្រាងច្បាប់ណាដែលត្រូវបានហាមឃាត់ដោយច្បាប់ ឬរដ្ឋធម្មនុញ្ញក្នុងការធ្វើប្រជាមតិ ។ ក្នុងករណីនេះ តាម**មាត្រា ៨៩** វាក្យខ័ណ្ឌទីពីរដល់ទី ៤ រដ្ឋធម្មនុញ្ញ**សហព័ន្ធស្វីស**ឆ្នាំ ១៨៧៤ បានកំណត់ថាច្បាប់របស់សហព័ន្ធទាំងអស់ និងក្រិត្យរបស់សហព័ន្ធដែលមានអត្ថន័យទូទៅ អាចដាក់វាអនុម័តជាលក្ខណៈ ប្រជាមតិដែលក្នុងនោះរួមទាំងសន្ធិសញ្ញាអន្តរជាតិផងដែរ ។ តាមលក្ខណៈនៃមាត្រានេះយើងឃើញថា រឿងរាល់បញ្ហាដែលកើតមានគេយកវាទៅធ្វើប្រជាមតិជាតិរបស់គេ ដែលជាសមត្ថកិច្ចរបស់សហព័ន្ធ ។ ត្រង់ចំណុចនេះកម្មវត្ថុនៃប្រជាមតិពុំបានកើតទេ តែបែរជាផ្តល់ឱ្យយ៉ាងទូលាយទៅវិញ។ ប៉ុន្តែសំរាប់ប្រទេសខ្លះគេអាចកំណត់នូវកម្មវត្ថុសំរាប់ធ្វើប្រជាមតិបាន ដូចជា**មាត្រា ៧៥** វាក្យខ័ណ្ឌទីពីររដ្ឋធម្មនុញ្ញ**អ៊ីតាលី** បានកំណត់ថាច្បាប់ព្រាងទាំងឡាយស្តីពីពន្ធដារ, ថវិកា, លើកលែងទោស និងសុំខមាលទោស, អំពីសិទ្ធិអំណាចលើការធ្វើសច្ចាប័ននៃរាល់សន្ធិសញ្ញាអន្តរជាតិ មិនអនុញ្ញាតិយកទៅធ្វើប្រជាមតិបានឡើយ ។

**ឆ២. ប្រជាមតិចាំបាច់** (Binding Referendum) : នេះគឺជាការធ្វើប្រជាមតិមួយដែលពុំអាចគេចបាន ព្រោះវាជាដំណោះស្រាយចុងក្រោយនៃបញ្ហាប្រឈមមុខ ។ ប្រជាមតិរបៀបនេះ គេធ្វើឡើងកាលណាសេចក្តីសំរេចលើបញ្ហាកើតមួយពុំត្រូវបានអនុម័តជោគជ័យ ។ ជាឧទាហរណ៍ លើ

អត្ថន័យខាងលើនេះ ការធ្វើប្រជាមតិចាំបាច់មួយនៃការដោះស្រាយភាពខ្វែងគំនិតគ្នា រវាងអំណាចនៃអង្គការធម្មនុញ្ញក្នុងនោះតាមចំនុចទីមួយ **មាត្រា ១២០** រដ្ឋធម្មនុញ្ញស៊ុយអែតដែលបានកំណត់ថា ប្រសិន បើសភាតំណាងរាស្ត្រធ្វើសេចក្តីសំរេច អំពីការពិនិត្យរួមឡើងវិញណាមួយនៃរដ្ឋធម្មនុញ្ញ រីឯព្រឹទ្ធសភាពុំយល់ព្រមតាមការកែប្រែនោះឡើយ ក្នុងករណីនេះបញ្ហានៃការកែប្រែរដ្ឋធម្មនុញ្ញនោះនឹងត្រូវដាក់ធ្វើប្រជាមតិ ។

សរុបទៅ ប្រជាមតិណាដែលគេធ្វើឡើងសំរាប់ដោះស្រាយបញ្ហាអំពីការអនុម័ត ឬក៏ការផ្លាស់ប្តូររដ្ឋធម្មនុញ្ញគេឱ្យឈ្មោះថាប្រជាមតិរដ្ឋធម្មនុញ្ញ រីឯប្រជាមតិណាដែលធ្វើឡើងសំរាប់ដោះស្រាយបញ្ហាការលុបច្បាប់ចោលទាំងស្រុង ឬដោយអន្លើៗនោះគេហៅថាប្រជាមតិបដិសេធន៍ ឬរាស្ត្រវេតូ ។

**ឃ. ការផ្តើមគំនិត និងការចាត់តាំងប្រជាមតិ** : សិទ្ធិអំណាចក្នុងការចាត់តាំងប្រជាមតិធម្មតាត្រូវផ្ទុកផ្តាក់ទៅប្រមុខរដ្ឋ ឬក៏ប្រមុខរដ្ឋសភា ជាងនេះទៅទៀតគឺផ្ទុកផ្តាក់ទៅអង្គការទាំងពីរនោះក៏មានផងដែរ ។ អង្គការទាំងនេះ ធ្វើការកិរតបែងចែកសមត្ថកិច្ចនោះតាមការផ្តើមគំនិតរបស់ខ្លួន ឬក៏តាមការផ្តើមគំនិតពីសមាជិកផ្សេងៗទៀតដែលមានសិទ្ធិ ដូចជារដ្ឋាភិបាល ក្រុមតំណាងរាស្ត្រ អង្គការរដ្ឋមូលដ្ឋាន រឺក៏ក្រុមអ្នកបោះឆ្នោត ( ប្រជារាស្ត្រដែលមានសិទ្ធិបោះឆ្នោត)។ តាម**មាត្រា ៧៥** វាក្យខ័ណ្ឌទីមួយ រដ្ឋធម្មនុញ្ញ**អ៊ីតាលី** បានកំណត់ថា ដើម្បីធ្វើប្រជាមតិទៅលើការលប់ច្បាប់ចោលដោយអន្លើៗ ឬទាំងស្រុងនោះចាំបាច់ត្រូវមានអ្នកគាំទ្រ ( អ្នកមានសិទ្ធិបោះឆ្នោត) ចំនួនប្រាំរយពាន់នាក់ ឬក៏ប្រាំតំបន់ ។

**ង. ការគ្រប់គ្រងនៃប្រជាមតិ** : ការគ្រប់គ្រងប្រជាមតិ វាគឺជាហេដ្ឋារចនាសម្ព័ន្ធមួយសំរាប់គ្រប់គ្រងទៅលើផ្នែកទាំងឡាយ ដូចជាបញ្ជីអ្នកបោះឆ្នោត, អង្គភាព ឬមណ្ឌលបោះឆ្នោត, គណៈកម្មការ, និងអង្គការផ្សេងៗទៀតដែលបង្កើតក្នុងការរៀបចំប្រជាមតិ ដូចជាយុទ្ធនាការបំភ្លឺផ្សេងៗទៅលើអ្នកបោះឆ្នោតនូវរាល់បញ្ហាផ្សេងៗ ដែលជាកម្មវត្ថុនៃប្រជាមតិ ។ ក្នុងបណ្តាប្រទេសជាច្រើនគេអាចកំណត់អង្គការគ្រប់គ្រងក្នុងការធ្វើប្រជាមតិ ដោយយកច្បាប់បោះឆ្នោតមកអនុវត្ត ដូចជា**មាត្រា ១១** នៃរដ្ឋធម្មនុញ្ញ**អេស្ប៉ាញ** បានកំណត់ថា ដំណើរការប្រជាមតិធ្វើឡើងបានដោយស្ថិតក្រោមច្បាប់បោះឆ្នោត គឺមានន័យថារាល់អ្វីៗដែលអាចអនុវត្តបាន ដោយទាក់ទិននឹងច្បាប់នោះ ( ច្បាប់បោះឆ្នោត) ។

**ខ. រូបមន្តនៃប្រជាមតិ** : សំណួរទាំងឡាយ ( បញ្ហា) ដែលត្រូវបានលើកឡើងសំរាប់ធ្វើប្រជាមតិ មានកំណត់ក្នុងរូបមន្តផ្សេងៗគ្នា ។ ជាទូទៅមានរូបមន្តពីរប្រភេទធំៗ ដែលបានសុះសាយគឺ :

**ខ₁. ប្រភេទទីមួយ** : ជាប្រភេទដែលមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងសំណួរបោះឆ្នោត ( បញ្ហាជំរើស) ។ ការធ្វើរបៀបនេះ គឺគេលើកយកបញ្ហាពិតណាមួយទៅសួរយោបល់រាស្ត្រ ថាយល់ព្រម ឬក៏ជំទាស់ ដោយគ្រាន់តែដាក់សំណួរថា**គាំទ្រ ឬប្រឆាំង** ។

**ខ₂. ប្រភេទទីពីរ** : ប្រភេទជំរើសរបស់រាស្ត្រ ( អ្នកបោះឆ្នោត) ។ ការធ្វើរបៀបនេះ គឺមានសំណួមពរទៅអ្នកជ្រើសរើសពីរ ឬបីយោបល់ ( ទស្សនៈ) **ដើម្បីឱ្យជ្រើសរើសយកណាមួយដែលគេពេញចិត្ត** ។ ការធ្វើរបៀបនេះមានលក្ខណៈបង្ខំច្រើន ។

**គ. ការកំណត់លទ្ធផលប្រជាមតិ** : នេះគឺជាដំណើរការចុងក្រោយ ក្នុងការកំណត់នូវសំណួរ ( បញ្ហា) ដែលគេចង់បានក្នុងការធ្វើប្រជាមតិ ។ ការចាត់ទុកថាជាលទ្ធផលបានការលើប្រជាមតិណាមួយគេត្រូវកំណត់វាក្នុងច្បាប់ ឬក៏ក្នុងរដ្ឋធម្មនុញ្ញជាគោល ។ ប្រជាមតិខ្លះចាត់ទុកជាលទ្ធផល គឺលុះត្រាតែគេយកសំលេងភាគច្រើនដាច់ខាតនៃអ្នកចូលរួម ឬអ្នកមានសិទ្ធិបោះឆ្នោត ឬអ្នកដែលបានចុះបញ្ជី ។ល។ ប៉ុន្តែសំរាប់ប្រទេសខ្លះចាត់ទុកជាបានការលើប្រជាមតិ លុះត្រាតែលទ្ធផលវាមានសំលេងគាំទ្រពីរភាគបីនៃសំលេងដែលបានបោះឆ្នោត ។

**ឃ. ហេតុផលគតិយុត្តិនៃប្រជាមតិ** : នេះជាហេតុផលមួយ ពុំមែនជាប្រជាមតិមានលក្ខណៈពិគ្រោះយោបល់ទេ តែជាលក្ខណៈសំរេចមួយយ៉ាងពិតប្រាកដ ។ ដោយផ្អែកលើហេតុផលនោះ គេថាវាជាសេចក្តីសំរេចចុងក្រោយដែលមានតំណាងគតិយុត្តិខ្ពស់ រីឯបញ្ហាមួយទៀតនោះ គឺថាតើយើងមានលទ្ធភាព ឬអត់ក្នុងការផ្លាស់ប្តូរទៅលើសេចក្តីសំរេច ឬការកែប្រែច្បាប់ទាំងនោះតាមរយៈធ្វើប្រជាមតិ ។

# គំនូសបំព្រួញនៃប្រព័ន្ធបោះឆ្នោត (រូបទី ១០)



# អត្ថបទទី ១៤

## អំណាចនីតិបញ្ញត្តិ ឬអំណាចរបស់រដ្ឋសភា

**១. និយមន័យ មុខងារសន្លមទូទៅនៃរដ្ឋសភា** (Definition/General Function) ពាក្យរដ្ឋសភាជាភាសាអង់គ្លេសថា "Parliament" ដែលពាក្យកំណើតរបស់ប្រទេសអង់គ្លេស ចាប់ពីសតវត្សទី[៤៤] XIII កាលនោះអំណាចរបស់ស្តេចបានកំរិតដោយការប្រជុំនៃពពួកគហបតីធំៗ និងពួកតំណាងដែនដី ។ បន្ទាប់មកក៏ចាប់កើតមានជាហូរហែរតាមបែបផែនខាងលើនេះ ដូចជានៅប្រទេស**ប៉ូឡូញ**, **ហុងគ្រី**, **បារាំង**, **អេស្ប៉ាញ** និងប្រទេសជាច្រើនទៀត ។ល។ ចំពោះពាក្យរដ្ឋសភាចេញពីភាសាបារាំងតាមរយៈកិរិយាស័ព្ទ (Parler) មានន័យថា "**និយាយ**" ដូចនេះយើងអាចសំគាល់បានថា រដ្ឋសភាជា**កន្លែងជជែក** ។

**តើអ្វីដែលទាក់ទងនឹងទស្សនៈរបស់រដ្ឋសភា នៅក្នុងយន្តកម្មរដ្ឋ និងមុខងាររបស់វា?** ទាំងនេះគឺជាភារកិច្ចរបស់ពួកអ្នកទ្រឹស្តីមួយចំនួន (Theorists) នៃការបែងចែកអំណាច ដូចជាលោក **ឡក ជុន** (Loake ១៦៣២-១៧០៤ គឺជាអ្នកទស្សនៈវិទូបែបសំភារៈនិយមរបស់អង់គ្លេស) និងលោក**ម៉ុងតេស្គ្យេ** (Montesquieu ១៦៨៩-១៧៥៥ អ្នកច្បាប់ និងទស្សនៈវិទូបារាំង) ។ លោកទាំងពីរនេះបានកំណត់តួនាទីរបស់រដ្ឋសភាដែលមានប្រៀបនោះ គឺថាជា**មុខងារនីតិបញ្ញត្តិ** ដូចលោក **រ៉ូស្សូ-ស៊ាន់ស៊ាក់** (Rousseau ១៧១២-១៧៧៨ ទស្សនៈវិទូបារាំង) ដែរ ដែលនិយមចូលចិត្តមិនបែងចែកនូវអធិបតេយ្យភាពនៃអំណាចកំពូលនេះទេ គាត់បានបង្កើតនូវ**កំរិតឯកភាពតែមួយគត់នៃអំណាចកំពូល** ។ នៅក្នុងទស្សនៈអ្នកប្រាជ្ញទាំងនេះបានបង្ហាញថា **រដ្ឋសភាជាអង្គតែមួយគត់ដែលមានអំណាចខ្ពស់បំផុតនៅក្នុងរដ្ឋ** ។ ដោយសារតែរដ្ឋសភាមានអំណាចខ្ពស់នេះហើយ ទើបអំណាចនីតិបញ្ញត្តិមានសិទ្ធិត្រួតពិនិត្យទៅលើអំណាចនីតិប្រតិបត្តិ ។ នោះគឺយើងមិនពិបាកយល់ទេថាគំនិតទាំងនោះស្ថិតនៅក្នុងទំរង់គ្រប់គ្រងរដ្ឋមួយបែបរាជាធិបតេយ្យ ឬប្រធានាធិបតីបែបសភា ។

---

[៤៤]. Constitutional Law of Foreign Country. Part-II. M-1994. Page 95 ។

ដូចនេះរដ្ឋសភា **គឺជាតំណាងអង្គការរដ្ឋទាំងមូលមានមុខងារសំខាន់តែមួយគត់ ដែលស្ថិតនៅក្នុងប្រព័ន្ធនៃការបែងចែកអំណាច, មានទាំងក្នុងការសមិទ្ធិអំណាចនីតិបញ្ញត្តិ** ។ មុខងាររបស់វាគឺអនុម័តច្បាប់, ថវិការដ្ឋ និងត្រួតពិនិត្យទៅលើការប្រតិបត្តិរបស់រដ្ឋសភា ។ ការដែលប្រព្រឹត្តបែបនេះទៅបាន គឺតិច ឬច្រើន វាអាស្រ័យទៅនឹងទ្រង់ទ្រាយនៃការគ្រប់គ្រង ឬទំរង់គ្រប់គ្រង, នោះគឺរដ្ឋសភា ក៏ធ្វើការត្រួតពិនិត្យចំពោះអំណាចនីតិប្រតិបត្តិដែរ ឧទាហរណ៍រដ្ឋធម្មនុញ្ញ **អេស្ប៉ាញ ឆ្នាំ ១៩៧៨ មាត្រា ៦៦** បានកំណត់ថា "ហ្សែនណេរ៉ាលកូតែស (General Cortes)[៤៥] បំពេញតួនាទីអំណាចនីតិបញ្ញត្តិរបស់រដ្ឋ, អនុម័តយល់ព្រមនូវរាល់ថវិការបស់រដ្ឋ, ត្រួតពិនិត្យការងាររដ្ឋាភិបាល និងមានសមត្ថកិច្ចផ្សេងៗទៀត ដែលរដ្ឋធម្មនុញ្ញធ្វើការញែកសមត្ថកិច្ចនោះ" ។ រដ្ឋធម្មនុញ្ញកម្ពុជា **ឆ្នាំ១៩៩៣ មាត្រា ៩០** បានកំណត់ថា "រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើតកែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តិទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តរាជរដ្ឋាភិបាលតាមមតិភាគច្រើន ពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល" ។ ពិតហើយថានៅលើការជាក់ស្តែង រដ្ឋសភាតែងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋាភិបាលជាទំងន់ បើទោះជាប្រទេសនីមួយៗខិតខំពង្រីកអំណាចកំពូលនេះ ហើយបានចារិកដោយ

---

[៤៥]. ជាឈ្មោះរដ្ឋសភានៃប្រទេសអេស្ប៉ាញ ។

រដ្ឋធម្មនុញ្ញក៏ដោយ ។ ការងាររបស់រដ្ឋសភា គឺត្រូវពិនិត្យដោយធម្មនុញ្ញយុត្តិធម៌ដែលមានអង្គការនីតិរដ្ឋធម្មនុញ្ញ ឬតុលាការធម្មនុញ្ញជាស្ថាប័នកំពូលសំរាប់ពិនិត្យមើលការអនុវត្តទាំងឡាយ ដែលទាក់ទិននឹងបទដ្ឋានធម្មនុញ្ញគតិយុត្តិ (ធម្មនុញ្ញភាព) ។ ប៉ុន្តែបើស្ថាប័នតុលាការធម្មនុញ្ញពុំបានអើពើទេ នោះធ្វើឱ្យស្ថាប័នទាំងពីរ (នីតិប្រតិបត្តិ និងនីតិបញ្ញត្តិ) ចេះតែបំពានច្បាប់គ្រឹះជានិច្ច ។

## ២. **បុព្វចរិតតំណាងនៃរដ្ឋសភា** (Representative Character)

នេះមានន័យថារដ្ឋសភាបើពិចារណាទៅ ដូចជា**អ្នកបញ្ចេញ** (Exponent) ឬ**អ្នកនាំផ្លូវនៃផលប្រយោជន៍រួម និងជាអ្នកសំដែងឆន្ទៈទូទៅរបស់ប្រជាជន** ។ ដូចមាត្រា **៧៧** រដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ថា "តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជនខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ" ។ ដូចនេះការយល់ឃើញនូវទស្សនាការ (បដិសន្ធិ) នៃតំណាងជាតិ ឬប្រជាជនដែលបានកើតមានរួចមកហើយក្នុងសតវត្សទី XVIII និងទី XIX ហើយដែលមានលេចចេញនូវគោលការណ៍មួយចំនួនដូចខាងក្រោម[៨៦] :

**ក. កំណត់ដោយច្បាប់** : តំណាងជាតិត្រូវធ្វើប្រតិស្ថានដោយរដ្ឋធម្មនុញ្ញ មានន័យថាត្រូវកំណត់ដោយច្បាប់កំពូលរបស់ប្រទេស ។

**ខ. ពលរដ្ឋជាបុគ្គលចំលងអធិបតេយ្យភាព** : ប្រជាជាតិ (ប្រជាជន) គឺជាអ្នកចំលង (Carrier) អធិបតេយ្យភាពឱ្យអំណាចសភាធ្វើសមិទ្ធិក្នុងនាមអំណាចនីតិបញ្ញត្តិ (ក្នុងសៀវភៅខ្លះគេបង្ហាញថាការឱ្យអំណាចធ្វើសមិទ្ធិអធិបតេយ្យភាព ប៉ុន្តែនេះយ៉ាងហោចណាស់ក៏ពុំទាន់ត្រឹមត្រូវដែរ) ។ ប្រជាជនជាធាតុផ្តល់សិទ្ធិអំណាចឱ្យរដ្ឋសភាសំរាប់ធ្វើសមិទ្ធិអំណាចនីតិបញ្ញត្តិ ប៉ុន្តែពុំមែនផ្តល់អធិបតេយ្យភាពទៅឱ្យអំណាចនីតិបញ្ញត្តិនោះទេ ។

---

[៨៦]. Constitutional Law of Foreign Country. Part-II. M-1994. Page 97 ។

**ឆ. ការជ្រើសរើសតំណាង** : ជាមួយនឹងទិសដៅនេះ ប្រជាជនត្រូវជ្រើសរើសតំណាងរបស់ខ្លួននៅក្នុងរដ្ឋសភា ដូចជាតំណាងរាស្ត្រ ឬតំណាងព្រឹទ្ធសភា ឬតំណាងអ្វីផ្សេងទៀត។ មានន័យថាដើម្បីឱ្យអំណាចនីតិបញ្ញត្តិមានលក្ខណៈប្រជាជនក្នុងការអនុម័តច្បាប់. នោះប្រជាជនត្រូវជ្រើសរើសតំណាងរបស់ខ្លួន សំរាប់ចំលងសិទ្ធិអំណាចពីពួកគេទៅអំណាចកំពូល ។

**ឃ. ភាពជាតំណាងរបស់ពលរដ្ឋ** : សមាជិករដ្ឋសភា គឺជាតំណាងគ្រប់ប្រជាជនគឺមិនមែនសំរាប់តែអ្នកណាដែលបោះឆ្នោតឱ្យគាត់នោះទេ ពីព្រោះថាវាមិនអាស្រ័យនឹងអ្នកបោះឆ្នោតទេ ។ មានន័យថាតំណាងរាស្ត្រម្នាក់មិនមែនជាតំណាងតែមណ្ឌលដែលខ្លួនបានឈរឈ្មោះនោះទេ គឺតំណាងឱ្យពលរដ្ឋទូទៅ ។ ដោយយោងទៅលើលក្ខណៈនេះលោក **ឡេអូន-ឌុគី** (Duguit Leon អ្នកច្បាប់បារាំង ១៨៥៩-១៩២៨)[៤៧] បានសរសេរថា "***រដ្ឋសភាមានអាណត្តិតំណាងរបស់ប្រជាជន***" ក្នុងករណីនេះលេចចេញនូវទំនាក់ទំនងនៃការតំណាង តាមការពិពណ៌នារបស់រដ្ឋធម្មនុញ្ញ ដែលមានទស្សនៈមួយរវាងប្រជាជាតិ និងសភាជាតិទូទៅ ។ ទំនាក់ទំនងនោះគឺអាណត្តិ (Mandate) មានន័យថាការផ្តល់ឱ្យ និងការតំណាង (Representation) ។ កន្លះសតវត្សក្រោយមកលោកម៉ាសែលប្រ៊ិល្វ[៤៨] ជាអ្នកនីតិរដ្ឋធម្មនុញ្ញដែលបានសរសេរថា "**ការសំដែងឆន្ទៈរបស់អ្នកបោះឆ្នោត នឹងត្រូវកំណត់ដោយការជ្រើសរើសរបស់បុគ្គលនេះ ឬនោះ ហើយមិនមែនបង្ខំដោយឥទ្ធិពលណានោះទេទៅលើស្ថានភាពនៃ អ្នកជ្រើសរើស ។ ឆន្ទៈនោះត្រូវកំណត់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់**"។ ដូចនេះពាក្យថាអាណត្តិបានត្រូវសុះសាយតាំងពីក្នុងឆ្នាំ ១៧៨៩ ជាយុទ្ធសាស្ត្រ ។ ក្នុងអត្ថន័យនោះបញ្ជាក់ថា : អាណត្តិមានន័យថា **ឱ្យសិទ្ធិ, វេលា** និង**តំណាង** មានន័យថាជាសេចក្តីទុកចិត្តរបស់ប្រជាជន គឺជ្រើសរើស ។

---

[៤៧]. Constitutional Law of Foreign Country, Part-II, M-1994, Page 98 ។

[៤៨]. អ្នកនីតិរដ្ឋធម្មនុញ្ញបារាំង. Constitutional Law of France, M-Ed-1957, Page 436 ។

ដូចនេះឆន្ទៈរបស់រដ្ឋសភាគឺជាឆន្ទៈរបស់ពលរដ្ឋដែរ ប៉ុន្តែសំរាប់ប្រទេសដែលមានសភាពីរ ដូចជាសភាតំណាងរដ្ឋជាសភា តំណាងឱ្យដែនដី (ព្រឹទ្ធសភា) ពុំមែនជាសភាតំណាងរាស្ត្រទេ[៤៩] ។ បទពិសោធន៍ជាសកលបង្ហាញថា រដ្ឋសភាកាលណាសំដែងជាអ្នកតំណាងពិតប្រាកដរបស់ពលរដ្ឋ, ពេលនោះក្នុងអាទិភាពរបស់វាមានការប្រមូលផ្តុំបក្សនយោបាយធំៗរបស់រាស្ត្រ ដោយបានបញ្ចេញនូវប្រយោជន៍គ្រប់ស្រទាប់សង្គម ។

ដូចនេះបុព្វចរិតតំណាង គឺជាលក្ខណៈដំបូងបំផុតនៃការផ្តល់សិទ្ធិអំណាចរបស់ពលរដ្ឋ ទៅស្ថាប័ននីតិបញ្ញត្តិតាមរយៈតំណាងរបស់ខ្លួននៅទីនោះ ។

## ៣. លក្ខណៈរូបធម៌នៃសមត្ថកិច្ចរបស់រដ្ឋសភា (General Characteristic of Competence)

ដើម្បីឱ្យរដ្ឋសភា បានសំរេចជោគជ័យនូវរាល់មុខងារទូទៅរបស់ខ្លួនចំពោះសង្គម នោះរដ្ឋធម្មនុញ្ញបានចែកនូវអំណាចដ៏ចាំបាច់បំផុត ជាមួយនឹងមុខងារនៃសមត្ថកិច្ចរបស់វា ។ ដោយអាស្រ័យទៅនឹងចំណុះនៃសមត្ថកិច្ចធម្មនុញ្ញគតិយុត្ត,គេសង្កេតឃើញសមត្ថកិច្ចនៃរដ្ឋសភាមានពីរប្រភេទធំៗគឺ:

**ក. សមត្ថកិច្ចគ្មានព្រំដែន** (Unlimited Competence) : គឺជាសមត្ថកិច្ចរបស់រដ្ឋសភា ដែលពុំត្រូវបានកំណត់ច្បាស់លាស់ទៅលើកម្មវត្ថុណាមួយពិតប្រាកដនោះទេ ។ សមត្ថកិច្ចនេះពុំបានកំណត់ទៅលើកម្មវត្ថុណាមួយទេ គឺទុកចំហរ (ទូទៅ) ។ នៅប្រទេសជាច្រើនដោយអាស្រ័យនឹងការគ្រប់គ្រងដោយរដ្ឋសភា (ទំរង់គ្រប់គ្រង) ដូចជារដ្ឋសភាអង់គ្លេសដែលក្នុងនោះមានទស្សនៈថា "រដ្ឋសភាអាចធ្វើអ្វីៗបានទាំងអស់ ក្រៅពីការបំលែងធាតុស្រីឱ្យទៅជាប្រុស និងត្រលប់វិញ" ទន្ទឹមនឹងនេះអ្នករដ្ឋធម្មនុញ្ញល្បីៗរបស់អង់គ្លេស (Constitutionalist អ្នកដែលសិក្សាស្រាវជ្រាវខាងរដ្ឋធម្មនុញ្ញ) បានចាប់អារម្មណ៍រួចទៅហើយថា : ការកកើតឡើងនូវមគ្គុទ្ទេសក៍ដំបូងបំផុតរបស់សភាដែលមគ្គុទ្ទេសក៍នោះ (Leadership) បានកំណត់មូលដ្ឋានមួយចំនួនដូចខាងក្រោម[៥០] :

---

[៤៩]. នៅក្នុងប្រទេសខ្លះសភាជាន់ខ្ពស់ ឬព្រឹទ្ធសភាមានអំណាចដូចសភាជាន់ទាបដែរ ដោយវាអាស្រ័យនឹងឆន្ទៈផ្ទាល់ ឬប្រយោជន៍របស់ពលរដ្ឋក្នុងការបង្កើតអង្គការនោះ ។

[៥០]. Constitutional Law of Foreign Country, Part II, M-1994, Page 101 ។

**ក១. មគ្គុទ្ទេស្កនៃនីតិកម្ម** : មូលដ្ឋាននេះរដ្ឋសភា មានភារកិច្ចដំបូងបំផុតក្នុងការធ្វើច្បាប់នានា។ មានន័យថាគ្មានអ្នកណាម្នាក់ក្រៅពីរដ្ឋសភា មានសិទ្ធិបង្កើតច្បាប់ទាំងឡាយបានទេ. ហើយច្បាប់ទាំងនោះមានឥទ្ធិពល ឬកំលាំងច្បាប់ខ្លាំងជាងបទបញ្ញតិ ឬបទដ្ឋានកិច្ចរបស់អង្គការអំណាចដទៃផ្សេងទៀតរបស់រដ្ឋ ។

**ក២. សំរេចក្នុងការចាយវាយ** : រដ្ឋសភាមានសិទ្ធិអះអាងទៅលើថវិការដ្ឋ (ចំណូល-ចំណាយ) និងកំណត់ពន្ធដារ ។ល។ នៅក្នុងមូលដ្ឋាននេះបញ្ជាក់ថាមានតែរដ្ឋសភាប៉ុណ្ណោះ ដែលមានសិទ្ធិសំរេចឱ្យរដ្ឋទាំងមូលធ្វើការចាយវាយ រឺកំណត់តំលៃផ្សេងៗទៅលើពន្ធនានា ។

**ក៣. ភាពទទួលខុសត្រូវ** : នេះជាការទទួលខុសត្រូវជាសហគមន៍ (រួម) របស់រដ្ឋាភិបាលចំពោះមុខរដ្ឋសភា ។ នៅក្នុងមូលដ្ឋាននេះរដ្ឋសភាទទួលខុសត្រូវរួមចំពោះពលរដ្ឋទូទៅ ។ នៅក្នុងករណីនេះសមាសភាពនៃអង្គការរដ្ឋនានា ត្រូវតែមានភារកិច្ចទទួលខុសត្រូវចំពោះរដ្ឋសភា ជាពិសេសអំណាចនីតិប្រតិបត្តិ ។

**ក៤. ដើរតួជាចៅក្រម** : វាជាសិទ្ធិធ្វើអំណះអំណាងរកយុត្តិធមិ ។ ត្រង់ចំណុចនេះចង់បញ្ជាក់ថារដ្ឋសភាជាអង្គការដែលមាន**អំណាចខ្ពស់បំផុត** ដូចនេះរាល់ការសំរេចរបស់អង្គការនេះពិតជាគ្មានស្ថាប័នណាមួយហានជំទាស់ឡើយ ។ ឧទាហរណ៍ : រដ្ឋធម្មនុញ្ញជប៉ុន **ឆ្នាំ ១៩៤៦ មាត្រាទី ៤១** បានកំណត់ថា : "រដ្ឋសភាជាអង្គការខ្ពស់បំផុតរបស់អំណាចរដ្ឋ. ហើយជាអង្គការតែមួយគត់របស់រដ្ឋ"។ តាមខ្លឹមសារនៃមាត្រានេះបានបង្ហាញថា សមត្ថកិច្ចគ្មានព្រំដែនរបស់រដ្ឋសភាវាច្រើនកើតមាននៅក្នុងប្រទេសដែលមានទំរង់គ្រប់គ្រងបែបរាជាធិបតេយ្យក៏រិត ឬបែបសាធារណរដ្ឋសភានិយម ។

**ខ. សមត្ថកិច្ចមានព្រំដែន** (Limited Competence) : សមត្ថកិច្ចមានព្រំដែននៃរដ្ឋសភា គឺជាសមត្ថកិច្ចដែលត្រូវបានកំណត់ដោយច្បាប់គ្រឹះយ៉ាងជាក់លាក់ ទៅលើ**កម្មវត្ថុណាមួយពិតប្រាកដ** ។ សមត្ថកិច្ចនេះចែកជា: សមត្ថកិច្ចកំណត់ពេលលេញ ឬជាសមត្ថកិច្ចជាក់លាក់ និងសមត្ថកិច្ចទាក់ទិន។

**ខ. សមត្ថកិច្ចជាក់លាក់** : គឺជាសមត្ថកិច្ចរបស់រដ្ឋសភា ដែលត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ ទៅលើ**កម្មវត្ថុណាមួយពិតប្រាកដ** ។ ដូចជារដ្ឋធម្មនុញ្ញបារាំង មាត្រា[៥១] ទី ៣៤. ៣៥ និង ៤៩ កំណត់យ៉ាងច្បាស់លាស់នូវបញ្ហាទាំងឡាយដែលក្នុងនោះ គឺរដ្ឋសភាអាចអនុម័តនូវរាល់ច្បាប់ និង សេចក្តីសំរេចផ្សេងៗ. ប៉ុន្តែគ្រប់បញ្ហាដែលសេសសល់ដទៃ មានន័យថាកម្មវត្ថុនៃអំណាចនិយ័តកម្ម (សិទ្ធិបង្កើតបទដ្ឋានកិច្ច) ត្រូវបានផ្ទុកផ្តាក់ទៅថ្នាក់ដឹកនាំសំខាន់ៗរបស់រដ្ឋាភិបាល ដូចជាក្រឹត្យ. អនុក្រឹត្យ........ ។ល។ ជាការពិតណាស់នៅផ្នែកបញ្ចប់នៃមាត្រាទី ៣៤ នៃរដ្ឋធម្មនុញ្ញបារាំងបានកំណត់លទ្ធភាពលំអិត និងបំពេញបន្ថែមលើស្ថានភាពនៃមាត្រានេះប្រព្រឹត្តទៅដោយច្បាប់កំណត់មួយ ។ ដូចវាក្យខ័ណ្ឌទី ២ នៃ**មាត្រាទី ៣៧** រដ្ឋធម្មនុញ្ញបារាំង កំណត់ថាច្បាប់មួយអាចផ្លាស់ប្តូរបានដោយក្រឹត្យរដ្ឋាភិបាលដែលចុះហត្ថលេខាដោយប្រធានាធិបតី. នោះប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញកំណត់ថា ច្បាប់ដែលបានបង្កើតតាមបញ្ហា ឬសំណួរមួយនោះជា**កម្មវត្ថុ**ដែលគួរឱ្យរដ្ឋាភិបាលជាអ្នកមានសិទ្ធិក្នុងការផ្លាស់ប្តូរវានោះ ។

យើងអាចជួបសមត្ថកិច្ចជាក់លាក់របស់រដ្ឋសភា នៅបណ្តាប្រទេសតតីយលោកជាច្រើនដូចជា : សេណេហ្គាល់ និងអតីតប្រទេសអាណានិគមរបស់បារាំង ដែលគេទាំងនោះអនុម័តប្រើនូវគំរូរដ្ឋធម្មនុញ្ញបារាំងដោយភ្ជាប់ជាមួយនូវ "កំណត់ជាក់លាក់" រហូតដល់សមត្ថកិច្ចនីតិកម្ម (សមត្ថកិច្ចធ្វើច្បាប់) របស់រដ្ឋសភាទៀតផង ។ ដូចជា**មាត្រា ៩០** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ កំណត់ថា "រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំនត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

---

[៥១]. Constitution of France 1958 ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តិទៅដោយមតិភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើន ពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល"។ តាមរដ្ឋធម្មនុញ្ញដដែលក្នុង**មាត្រា ៩៨** កំណត់ថា "រដ្ឋសភាអាចទំលាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទំលាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញ្ញត្តិបន្ទោសតាមសំលេងឆ្នោតពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកយកមកពិភាក្សាបាន"។ ដូចនេះសមត្ថកិច្ចជាក់លាក់របស់រដ្ឋសភាជាសមត្ថកិច្ចដែលបានចារិកក្នុងរដ្ឋធម្មនុញ្ញ កំណត់ពី**លទ្ធភាពនានាដែលអំណាចនីតិបញ្ញត្តិអាចមានទៅលើទំនាក់ទំនងសាធារណៈជាឯកតោភាគី ។**

**ខ២.សមត្ថកិច្ចទាក់ទិន :** សមត្ថកិច្ចទាក់ទិនរបស់រដ្ឋសភា គឺជាសមត្ថកិច្ចដែលពុំត្រូវបានសំរេចកិច្ចការតែពីភាគីរដ្ឋសភាជាឯកតោភាគីនោះទេ តែត្រូវសេចក្ដីសំរេចនោះមានការចូលរួមយល់ព្រម ឬបដិសេធពីភាគីផ្សេងៗទៀតនៃអំណាចរដ្ឋ ។

សមត្ថកិច្ចនេះមានសំរាប់រដ្ឋសហព័ន្ធ (Federation) និងរដ្ឋឯកភូតវិមជ្ឈការ[៥២] (Decentralization) គឺថារដ្ឋរបៀបនេះសមត្ថកិច្ចនៃអំណាចមជ្ឈិម ( កណ្ដាល) ត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ ឬបទដ្ឋានកិច្ចទាំងឡាយនៃសមាសភាពរបស់សហព័ន្ធ ឬក៏បែបអាជ្ញាធរដែនដីដទៃទៀត ក្នុងនោះរដ្ឋសភាមានសមត្ថភាពតែត្រឹមក្របខ័ណ្ឌដែលគេបានកំណត់នោះតែប៉ុណ្ណោះ ។ សមត្ថកិច្ចទាក់ទិនរបស់សភា គឺមានន័យថាកិច្ចការណាមួយដែលត្រូវបានសំរេច ត្រូវមានការចូលរួមពីអង្គការនៃអំណាចរដ្ឋផ្សេងៗទៀត ។ ឧទាហរណ៍ៈការធ្វើវិសោធនកម្ម**មាត្រាទី** X នៃរដ្ឋធម្មនុញ្ញសហរដ្ឋឆ្នាំ ១៧៨៧

---

[៥២] . រដ្ឋឯកភូតវិមជ្ឈការ គឺជារដ្ឋទោលដែលអំណាចកណ្ដាលត្រូវបានរំលែកទៅឱ្យរដ្ឋអំណាចមូលដ្ឋានមានសិទ្ធិសំរេចលើកិច្ចការមួយចំនួនក្នុងដែនដីរដ្ឋបាលរបស់ខ្លួនតាមគោលការណ៍នៃច្បាប់ រីឯអ្នកដឹកនាំនៃដែនដីរដ្ឋបាលទាំងនោះត្រូវមានការជ្រើសរើសតាមរយៈបោះឆ្នោតក្នុងដែនដីរបស់គេ ។

កំណត់ថា[៩៣] "អំណាចទាំងអស់មិនត្រូវបានផ្ទេរដោយរដ្ឋធម្មនុញ្ញសហរដ្ឋទេ ហើយក៏មិនត្រូវបានហាមឃាត់ដោយរដ្ឋធម្មនុញ្ញនោះដែរ សំរាប់ធ្វើសមិទ្ធិរដ្ឋទាំងអស់រក្សាអំណាចទាំងនោះ គឺអាស្រ័យនឹងរដ្ឋទាំងអស់ និងប្រជាពលរដ្ឋទាំងមូល"។ **មាត្រា ៩២** រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិនឹងត្រូវចាត់ទុកជាអាសារសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ"។ ដូចនេះសមត្ថកិច្ចទាក់ទិនតាមមាត្រានេះបានបញ្ជាក់នូវសមត្ថកិច្ចនីតិកម្មរបស់រដ្ឋសភា ដែលទាក់ទិននឹងអង្គការផ្សេងៗទៀតរបស់រដ្ឋ ។

## ៤. សមត្ថកិច្ចនីតិកម្មនៃរដ្ឋសភា (Legislative Competence)

គឺជាខ័ណ្ឌ (បណ្តុំ) នៃអំណាចទាំងអស់ក្នុងបែបជែនអនុម័តច្បាប់ទាំងពួង ដែលសមត្ថកិច្ចនោះបង្កើតនូវភាគសំខាន់មួយនៃសមត្ថកិច្ចរបស់រដ្ឋសភា និងការធ្វើសមិទ្ធិរបស់រដ្ឋសភាដែលជាមុខងារចំបងបំផុត ។ ក្នុងន័យនេះគឺចង់និយាយអំពីការអនុម័តច្បាប់ គឺមិននិយាយអំពីការបង្កើតច្បាប់នោះទេ ដែលនៅក្នុងនោះមានអង្គការក្រៅរដ្ឋសភាចូលរួមយ៉ាងច្រើន រួមទាំងប្រមុខរដ្ឋទៀតផង ។ សមត្ថកិច្ចនេះបានកំណត់ក្នុង**មាត្រាទី ៩០** នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ក្នុងវាក្យខ័ណ្ឌទី ១ ថា "រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ" និង**មាត្រា ៩២** វាក្យខ័ណ្ឌទី ១ កំណត់ថា "ការអនុម័តទាំងឡាយរបស់រដ្ឋសភា......"។ និង**មាត្រា ៩៣** វាក្យខ័ណ្ឌទី ១ កំណត់ថា "ច្បាប់ដែលរដ្ឋសភាបានអនុម័ត......."។ ជាឧទាហរណ៍វាក្យខ័ណ្ឌទី ១ នៃ**មាត្រា ២៦** រដ្ឋធម្មនុញ្ញក្រិច ឆ្នាំ ១៩៧៥ កំណត់នូវការចូលរួមពីអង្គការក្រៅរដ្ឋសភា ចំពោះការអនុម័តច្បាប់ថា "អំណាចនីតិបញ្ញតិត្រូវធ្វើសមិទ្ធិដោយសភាតំណាងរាស្ត្រ និងប្រធានាធិបតីសាធារណៈរដ្ឋ[៩៤]"។ ត្រង់ចំណុចនេះប្រធានាធិបតីតំណាងឱ្យអង្គការក្រៅរដ្ឋសភា ។

---

[៩៣]. Constitution and Legislative Acts. United State of America. Ed-Progress. M-1993. Page 42 ។

[៩៤]. Constitution of Greece 1975 ។

ជាការពិតហើយដូចជាប្រទេសអង់គ្លេស និងអតីតប្រទេសអាណានិគមអង់គ្លេស ប្រមុខរដ្ឋគ្រាន់តែជាចំណែកតូចមួយរបស់រដ្ឋសភាតែប៉ុណ្ណោះ បើប្រៀបទៅនឹងរដ្ឋសភាផ្សេងទៀតនៃបណ្ដាប្រទេសលើពិភពលោក ។ នៅក្នុងអត្ថន័យនេះវាបង្ហាញថា បើទោះបីរដ្ឋសភាផ្សំឡើងពីសមាសភាពផ្សេងៗក៏ដោយ ក៏សមាសភាពនៃអង្គការទាំងនោះមិនមានអំណាចដូចរដ្ឋសភាបានឡើយ ដូចជារដ្ឋសភាអង់គ្លេស កើតឡើងពីសមាសភាពមហាក្សត្រ, សភាជាន់ខ្ពស់ (Lord), សភាជាន់ទាប ។ល។ តាមយោបល់របស់លោក **ម៉ុងតេស្គ្យ** និងលោក **រូស្សូ** បានបង្កើតមត្តទ្វេសដ៏ខ្ពស់របស់ច្បាប់ គឺត្រង់ថា "**បទបញ្ញត្តិទាំងនេះជាឆន្ទៈទូទៅរបស់ប្រជាពលរដ្ឋ ហើយធ្វើនិយ័តកម្មទៅលើទំនាក់ទំនងសាធារណៈប្រកបដោយលក្ខណៈមាំទាំពិសេស និងមានបែបបទត្រឹមត្រូវទៀតផង**"។ ពេលនោះគេបានចែកទិដ្ឋភាពជាពីរនៃនិយមន័យរបស់ច្បាប់ ដោយយោងលើបញ្ហានៃនីតិកម្មរបស់សមត្ថកិច្ចរដ្ឋសភា គឺលោក **ដ្យូគី** បានសរសេរនៅឆ្នាំ ១៩០១[៥៥] ថា :

**ក. ទីមួយ : "ទិដ្ឋភាពទៀងទាត់"** (មានទំរង់ច្បាស់លាស់) : គឺរាល់ការកំណត់ណាដែលបានបង្កើតឡើងដោយអង្គការមួយដែលស្ថិតនៅក្នុងប្រទេសមួយពិតប្រាកដ. ហើយពិនិត្យទៅដូចជាអ្នកសំដែងដោយផ្ទាល់នៃឆន្ទៈអធិបតេយ្យភាពរបស់ពលរដ្ឋ ។ ច្បាប់ដែលមានលក្ខណៈរបៀបនេះ គឺវាសំដែងនូវឆន្ទៈទូទៅរបស់ពលរដ្ឋ ដែលចាំបាច់ណាស់ក្នុងការបង្កើតវាត្រូវមានការចូលរួមពីប្រជាពលរដ្ឋ តាមរយៈតំណាងរបស់ពួកគេ ។

**ខ. ទីពីរ : "ទិដ្ឋភាពសំភារៈ"** : គឺគ្រាន់តែបទបញ្ញត្តិដែលតាមអាទិភាពរបស់ខ្លួន គឺជាច្បាប់មិនអាស្រ័យនឹងអង្គការរដ្ឋដែលបង្កើតច្បាប់នោះទេ ។ ទិដ្ឋភាពទីពីរនេះ គឺសំដៅទៅលើបទដ្ឋានកិច្ចទាំងឡាយដែលបានអនុម័តដោយអង្គការរដ្ឋ រួចហើយចាត់ទុកជាច្បាប់សំរាប់អនុវត្តជាទូទៅ ក្នុងក្របខ័ណ្ឌនៃកម្មវត្ថុដែលបានកំណត់ដោយបទដ្ឋានកិច្ចទាំងនោះ ។

---

[៥៥]. Constitutional Law of Foregn Country, PartII, M-1994, Page 105 ។

ជាធម្មតាសមត្ថកិច្ចនីតិកម្មនៃរដ្ឋសភា គឺមានលក្ខណៈពុំដូចគ្នាទេ សំខាន់គឺឈរលើគោលការណ៍នៃសេរីភាព និងឯកភាពផ្ទៃក្នុងរបស់ជាតិ ។ ដូចនេះសមត្ថកិច្ចនីតិកម្មរបស់រដ្ឋសភា ជាសមត្ថកិច្ចអនុម័តច្បាប់ ដោយមានការចូលរួមពីអង្គការផ្សេងៗក្នុងស្មារតីសេរីភាព និងឯកភាពជាតិនៃផ្ទៃក្នុងប្រទេស ។

## ៥. សមត្ថកិច្ចហិរញ្ញវត្ថុរបស់រដ្ឋសភា (Financial Competence)

សមត្ថកិច្ចហិរញ្ញវត្ថុរបស់រដ្ឋសភា គឺជាសមត្ថកិច្ចមួយដែលមានជាចាំបាច់សំរាប់ប្រទេសជាតិទាំងមូលក្នុងការកំរិតចំណូល-ចំណាយប្រចាំឆ្នាំ ជាពិសេសទៀតនោះគឺការកំរិតពន្ធដារ និងបទដ្ឋានមួយចំនួនដែលទាក់ទិន និងនិយ័តកម្មទៅលើទំនាក់ទំនងថវិការដ្ឋ ។ គឺថាសិទ្ធិអំណាចរបស់រដ្ឋសភាធ្វើអំណះអំណាងលើបញ្ជីសារពើភ័ណ្ឌ ចំណូល និងចំណាយរបស់រដ្ឋ ហើយរួមទាំងមានការកំណត់នូវពន្ធទាំងពួងទៀតផង ( បាននិយាយខាងដើមខ្លះៗហើយ ) ។ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ **មាត្រា ៩០** កំណត់ថា "រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញតិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំនត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។ រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល .......... " ។

បញ្ជីសារពើភ័ណ្ឌចំណាយ - ចំណូលរបស់រដ្ឋ គឺជាថវិការដ្ឋដែលអនុម័តដោយរដ្ឋសភារៀងរាល់ឆ្នាំ ។ ក្នុងនោះបញ្ជាក់នូវការប៉ាន់ប្រមាណ នៃការប្រើប្រាស់ផ្នែកហិរញ្ញវត្ថុទាំងអស់របស់រដ្ឋ និងចំណូលទាំងអស់ដែលជាសេចក្តីត្រូវការចាំបាច់សំរាប់បិទបាំង ឬប៉ះប៉ូវទៅលើសេចក្តីត្រូវការ ឬការប្រើប្រាស់ទាំងឡាយ ។ កាលដែលបានអំណះអំណាងលើថវិកាមករដ្ឋសភា កំណត់ទៅរដ្ឋាភិបាលលើការចំណាយធនធានរដ្ឋ ដោយស្របទៅនឹងការប៉ាន់ប្រមាណក្នុងក្របខ័ណ្ឌ ដែលរដ្ឋាភិបាលមិនចាំបាច់ឱ្យទទួលនូវកាតព្វកិច្ចប្រមូលចំណូលចាំបាច់ផ្សេងៗ សំរាប់ផ្គត់ផ្គង់ចំណូលរបស់រដ្ឋនៃទំហំកំរិតពន្ធដារ និងចំណូលដទៃទៀត ។ សូមបញ្ជាក់ផងដែរ នៅបណ្តាប្រទេសកាន់របបផ្តាច់ការទំរង់ថវិកា

រដ្ឋមិនបង្ហាញរាល់សកម្មភាពទេ ផ្ទុយទៅវិញជាភារកិច្ចមួយបញ្ជាក់ដើម្បីបិទបាំង អំពីមតិសាធារណៈក្នុងប្រទេស និងសហគមន៍ពិភពលោកមកលើប្រទេសរបស់ខ្លួន ។

ជាទំលាប់នៅក្នុងសមត្ថកិច្ចនេះ រដ្ឋសភាទាំងមូលរួមបញ្ចូលនូវការសំអាងនៃគណនី ( ប្រាក់ចេញ-ចូល) របស់រដ្ឋាភិបាលអំពីការប្រតិបត្តិថវិកា ។ ឧទាហរណ៍[៥៦] វាក្យខ័ណ្ឌទីមួយ **មាត្រាទី ៩០** នៃរដ្ឋធម្មនុញ្ញជប៉ុន សរសេរថា "គណនីចុងក្រោយអំពីចំណាយរបស់រដ្ឋ និងចំណូលត្រូវធ្វើអធិការកិច្ចរៀងរាល់ឆ្នាំរបស់ក្រុមប្រឹក្សាអធិការកិច្ច មានតំណាងដោយខុទ្ទកាល័យធ្វើជូនក្នុងចន្លោះពេលនៃគណនីនោះ (ការិយបរិច្ឆេទ Accounting Period) ។ សូមបញ្ជាក់ថា ក្រុមប្រឹក្សាអធិការកិច្ចជាអង្គការត្រួតពិនិត្យមួយខាងផ្នែកហិរញ្ញវត្ថុរបស់រដ្ឋសភា ដោយប្រទេសនីមួយៗបានបង្កើតវាហើយមានឈ្មោះខុសៗគ្នាទៅតាមប្រទេស ។

ជាមួយគ្នានោះវាសឹងតែជារួមទៅហើយ ច្បាប់ទាំងអស់ដែលកំណត់នូវប្រព័ន្ធពន្ធដារត្រូវផ្ដុកផ្ដាក់ឱ្យអង្គការថ្នាក់ក្រោមបន្តបន្ទាប់នៃអំណាចសាធារណៈ មានសិទ្ធិកំណត់នូវកំរិតពន្ធច្បាស់លាស់ ( អត្រា និងប្រភេទ) និងការប្រមូលប្រាក់ចំណូលផ្សេងៗនៅក្នុងក្របខ័ណ្ឌច្បាប់ ដែលបានពិនិត្យរួចជាស្រេចនោះ ។ ដូចរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ក្នុង **មាត្រា ៥៧** ថា "ការយកពន្ធដារនឹងអាចធ្វើទៅបានលុះត្រាតែមានច្បាប់អនុញ្ញាត្តិ ។ ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់ ។ របបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់ " ។

## ៦. សច្ចាប័ន និងអប្បដិបត្តិកម្មនៃសន្ធិសញ្ញាអន្តរជាតិរបស់រដ្ឋសភា

នេះគឺជាសមត្ថកិច្ចវិជ្ជមាន ឬអវិជ្ជមានមួយ អំពីស្ថាប័ននីតិបញ្ញត្តិសំរាប់ផ្ដល់សេចក្ដីទុកចិត្តរវាងទំនាក់ទំនងផ្ទៃក្នុងប្រទេស និងក្រៅប្រទេសរបស់រដ្ឋនីមួយៗ ។ សមត្ថកិច្ចរបៀបនេះមាន :

---

[៥៦]. Constitution of Japan 1945 ។ នៅប្រទេសអង់គ្លេសរដ្ឋសភាមានសិទ្ធិកំណត់ពន្ធដារនា ស.វ ១៣ និងអនុម័តច្បាប់ដែលទាក់ទិននឹងសមត្ថកិច្ចហិរញ្ញវត្ថុនា ស.វ ១៥ ឯនៅបារាំងរដ្ឋសភាមានសិទ្ធិកំណត់ពន្ធដារនា ស.វទី ១៦ និងអនុម័តច្បាប់ ដែលទាក់ទិននឹងសមត្ថកិច្ចហិរញ្ញវត្ថុ នា ស.វទី ១៨ ។

**ក. សច្ចាប័ន** (Ratification) : គឺជាកិច្ចយល់ព្រមចុងក្រោយរបស់រដ្ឋ នៅលើការចុះហត្ថលេខានៃរាល់សន្ធិសញ្ញាមួយ. ដែលត្រូវបានសំដែងចេញនៅក្នុងទំរង់កំណត់ច្បាស់លាស់ តាមរយៈឆន្ទៈរបស់រាស្ត្រនៅក្នុងរដ្ឋសភា ។ ឧទាហរណ៍ ដូចជាសន្ធិសញ្ញាទ្វេភាគ ត្រីភាគី .... ចតុភាគី ... ។ល។

**ខ. អប្បបិបត្តិកម្ម** (Denunciation) : គឺជាការបញ្ចេញនូវឆន្ទៈជំទាស់របស់រដ្ឋទៅលើសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងណាមួយតាមរយៈរដ្ឋសភា ដោយមានការស្នើឡើងពីរដ្ឋាភិបាល។ ពេលខ្លះសន្ធិសញ្ញាអន្តរជាតិទាំងនេះ ពីពេលមួយទៅពេលមួយ ចេះតែក្លាយទៅជាភាពបំពានទៅលើសណ្តាប់ធ្នាប់គតិយុត្តិរបស់រដ្ឋ ដែលជាភាគីនៃកិច្ចព្រមព្រៀង ហើយធ្វើឱ្យភាគីណាមួយធ្វើការបដិសេធន៍ ឬរុះរើឡើងវិញទៅលើសន្ធិសញ្ញានោះ ។ ប៉ុន្តែក្នុងពេលចុងក្រោយនេះ នៅក្នុងសហគមន៍ពិភពលោកបានអះអាងយ៉ាងម៉ឺងម៉ាត់ នូវគោលការណ៍អាទិភាពនៃកិច្ចព្រមព្រៀងអន្តរជាតិ ចាត់ទុកដូចជាច្បាប់ផ្ទៃក្នុងរបស់រដ្ឋម្ចាស់ហត្ថលេខីដែរ។ ការចាត់ទុកកិច្ចព្រមព្រៀងអន្តរជាតិជាប្រភពនៃច្បាប់របស់រដ្ឋ ត្រូវបានប្រទេសមួយចំនួនចារឹកខ្លឹមសារនៅក្នុងរដ្ឋធម្មនុញ្ញ ឬក៏ច្បាប់គ្រឹះរបស់គេរៀង១ខ្លួន ជាពិសេសប្រទេសជឿនលឿន ។ ដោយសារតែវាត្រូវបានចាត់ទុកជាប្រភពនៃច្បាប់ផ្ទៃក្នុងនោះ ទើបតំរូវឱ្យស្ថាប័ននីតិបញ្ញត្តិនៃរដ្ឋទាំងនោះធ្វើសច្ចាប័ន ឬក៏អប្បដិបត្តិកម្មទៅលើសន្ធិសញ្ញាទាំងនោះ ដើម្បីចារឹកនូវឆន្ទៈរបស់រាស្ត្រ ។ ឧទាហរណ៍ : បទដ្ឋានទាំងឡាយនៃគ្រឹះច្បាប់អាល្លឺម៉ង់ ឆ្នាំ ១៩៤៩ មាត្រាទី ២៥ និងច្បាប់រដ្ឋធម្មនុញ្ញសហព័ន្ធអូទ្រីស្ត ឆ្នាំ ១៩២០ បោះពុម្ពឆ្នាំ ១៩២៩ វាក្យខ័ណ្ឌ ១ **មាត្រាទី ៩** បានសរសេរថា "រាល់នីតិបទដ្ឋានអន្តរជាតិទាំងឡាយ ត្រូវចាត់ទុកដូចជាផ្នែក ឬជាចំណែកមួយនៃច្បាប់សហព័ន្ធ"។ រីឯប្រទេសកម្ពុជា ពុំបានចែងដោយផ្ទាល់ទៅលើបទដ្ឋានជាអន្តរជាតិនោះទេ ប៉ុន្តែរដ្ឋធម្មនុញ្ញបានបញ្ជាក់ថារដ្ឋសភាជាអ្នកយល់ព្រម ឬលប់ចោលនូវរាល់កិច្ចព្រមព្រៀងអន្តរជាតិបានដែរ ។ តាមរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ **មាត្រា ៩០** បានកំណត់ថា "រដ្ឋសភា ជាអង្គការដែលមានអំណាចនីតិបញ្ញតិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល........"។ ជាការពិតណាស់ **មាត្រាទី ៥៥** រដ្ឋធម្មនុញ្ញបារាំងសរសេរថា[៩៧] "សន្ធិសញ្ញាទាំងឡាយ ឬកិច្ចព្រមព្រៀងទាំងឡាយដែលត្រូវបានយល់ព្រមសច្ចានុម័តរួចហើយ ត្រូវតែចាត់ទុកជាច្បាប់ចាប់ពីពេលបោះផ្សាយវាចូលជាធរមាន ហើយដែលមានកំលាំងគតិយុត្តិកើនខ្លាំងឡើង១នៃច្បាប់ផ្ទៃក្នុងទាំងពួងនោះ ក្រោមល័ក្ខខ័ណ្ឌនៃការប្រើប្រាស់សន្ធិសញ្ញានេះ ឬកិច្ចព្រមព្រៀងរបស់ភាគីផ្សេងទៀត" ។ ត្រង់មាត្រានេះបញ្ជាក់នូវកំលាំងគតិយុត្តិរបស់កិច្ចព្រមព្រៀងអន្តរជាតិ ដែលត្រូវអនុវត្តដូចជាច្បាប់ផ្ទៃក្នុងរបស់ប្រទេសនីមួយៗដែលជាម្ចាស់ហត្ថលេខីដែរ ។

ដូចនេះដោយឃើញថា រដ្ឋធម្មនុញ្ញរបស់ប្រទេសមួយចំនួនបានសរសេរយ៉ាងសុក្រិត្យ នូវអាទិភាពនៃសន្ធិសញ្ញាអន្តរជាតិ ទៅលើករណីនៃការផុសចេញអំពីភាពប្រឈមមុខគ្នា រវាងសន្ធិសញ្ញាអន្តរជាតិ និងច្បាប់ផ្ទៃក្នុងនៃប្រទេសដែលបានរ៉ាយរ៉ាប់រួចមកហើយនោះ ពេលខ្លះក៏មានការទាមទារទៅវិញទៅមកដែរ ព្រោះជួនកាលសន្ធិសញ្ញានោះពុំត្រូវបានអនុវត្ត ឬក៏បំពានដោយភាគីម្ខាងទៀត ។ វាជាការពិតណាស់ហើយថា អ្នកប្រើប្រាស់ច្បាប់ផ្តល់នូវសេចក្តីពេញចិត្តទៅលើសន្ធិសញ្ញាអន្តរជាតិ នោះត្រូវតែបញ្ជាក់ថាសន្ធិសញ្ញានោះត្រូវអនុវត្តដោយភាគីម្ខាងទៀតដែរ ទើបជាការត្រឹមត្រូវ ឬក៏ហ៊ានទទួលខុសត្រូវចំពោះសន្ធិសញ្ញានោះ ។ គួរនិយាយផងដែរថាការរំលាយ ឬការចុះហត្ថលេខាលើសន្ធិសញ្ញា គឺវាតែងតែប៉ះពាល់ដល់ច្បាប់ផ្ទៃក្នុងរបស់ប្រទេស។ ដូចនេះដើម្បីជៀសចេញនូវបាតុភូតនេះ ត្រូវមានការចូលរួមរបស់រដ្ឋសភា ( ម្តងម្កាលធ្វើប្រជាមតិដោយផ្ទាល់ជាមួយប្រជាជន) ក្នុងការដោះស្រាយបញ្ហាអំពីការចុះសន្ធិសញ្ញា ឬរំលាយនៃសន្ធិសញ្ញាអន្តរជាតិ ។

## ៧. ចំណាត់ថ្នាក់ប្រជាមតិរបស់រដ្ឋសភា (Classification of Referendum)

ចំណាត់ថ្នាក់ប្រជាមតិរបស់រដ្ឋសភា គឺជាភារកិច្ចមួយរបស់រដ្ឋសភាដែលប្រមើលមើលទៅលើការចាំបាច់ណាមួយ ក្នុងការដោះស្រាយបញ្ហាកំណត់ពិតប្រាកដដែល បញ្ហានោះត្រូវបានកំណត់លំដាប់ថ្នាក់ទៅលើកម្មវត្ថុនៃការធ្វើប្រជាមតិដោយច្បាប់កំពូលពិតប្រាកដ ។

[៩៧]. Constitution of France 1958 ។

នៅក្នុងបណ្ដាប្រទេសជាច្រើន បានអនុវត្តប្រជាមតិក្នុងការដោះស្រាយនៃបញ្ហាផ្សេងៗ ជាច្រើននៃជីវភាពរដ្ឋ (កិច្ចការរដ្ឋ) ក្នុងនោះរួមមាន : ការអនុម័ត, ការផ្លាស់ប្ដូរ និងការលុបចោលនៃច្បាប់ទាំងពួងទៀតផង ដោយប្រើមធ្យោបាយនៃប្រជាមតិនេះ ។ នោះគឺជាលទ្ធផលនៃការសំដែងចេញនូវឆន្ទៈរបស់ប្រជាពលរដ្ឋ ដោយមិនអាស្រ័យពីកម្មវត្ថុរបស់វាទេ, ហើយសឹងតែជាទូទៅទៅហើយ គេបានចាត់ទុកប្រជាមតិថាជា**ប្រភពនៃច្បាប់**មួយដែរ (មើល**អត្ថបទទី ១៣** ចំណុច ៩) ។ ជាឧទាហរណ៍ : **មាត្រា ៨០** និងវាក្យខ័ណ្ឌទី ១ នៃ**មាត្រា ៨៧** រដ្ឋធម្មនុញ្ញរបស់សាធារណៈរដ្ឋ**ក្រូអាទី** ឆ្នាំ ១៩៩០ សរសេរថា "សភាតំណាង (សភាតំណាងរាស្ត្រ) ចាត់តាំងប្រជាមតិតាមកម្មវត្ថុនៃសមត្ថកិច្ចរបស់ខ្លួន (មានចាត់តាំងប្រជាមតិចំពោះប្រធានាធិបតី .....)" ។ ហើយមានរដ្ឋធម្មនុញ្ញប្រទេសដទៃទៀត ដែលបានចែងក្នុងការធ្វើប្រជាមតិតាមសមត្ថកិច្ចរបស់វានោះ ដូចជាមាត្រា ៧៣, ៧៨, នៃរដ្ឋធម្មនុញ្ញ**គុយបា** និងមាន**មាត្រា ៦៣** រដ្ឋធម្មនុញ្ញនៃ**សាធារណរដ្ឋណាមីប៊ី** ឆ្នាំ ១៩៩០ ក៏បានអនុញ្ញាតិឱ្យធ្វើប្រជាមតិផងដែរ ។ រីឯសំរាប់ប្រទេសកម្ពុជាវិញរដ្ឋធម្មនុញ្ញ ពុំបានអនុញ្ញាតិឱ្យធ្វើប្រជាមាតិក្នុងការដោះស្រាយបញ្ហាធំៗរបស់រដ្ឋ តាមរយៈឆន្ទៈផ្ទាល់របស់រាស្ត្រនោះទេ ។

## ៨. ការបង្កើតអង្គការរដ្ឋ និងស្ថាប័ននានារបស់រដ្ឋសភា

នេះគឺជាសមត្ថកិច្ចមួយរបស់រដ្ឋសភា ក្នុងការបង្កើតស្ថានប័ននានារបស់រដ្ឋ ដែលសមត្ថកិច្ចនោះត្រូវបានកំណត់ដោយច្បាប់កំពូល ឬច្បាប់ដទៃទៀត ។ ក្នុងន័យនេះគឺគ្រាន់តែបញ្ជាក់នូវការចូលរួមរបស់រដ្ឋសភាក្នុងការជ្រើសរើសតែប៉ុណ្ណោះ ដូចជាការចាត់តាំង ឬការជ្រើសរើសនៃមន្ត្រីរដ្ឋ ឬក៏ចូលរួមក្នុងនីតិវិធីទាំងនោះ ។ នេះគឺជាអំណាចមួយដែលបានកំណត់យ៉ាងធំធេង និងផ្សេងៗគ្នាដោយរដ្ឋធម្មនុញ្ញ ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់រដ្ឋសភានៃប្រទេសនានា ។ ជាទូទៅយើងអាចសង្កេតឃើញនូវសមត្ថកិច្ចរបស់រដ្ឋសភាចូលរួមក្នុងការបង្កើតស្ថាប័ន ឬយល់ព្រមលើមន្ត្រីរដ្ឋជាន់ខ្ពស់មានដូចខាងក្រោម :

**ក. ទីមួយ : ការជ្រើសរើស ឬចំណាត់តាំងតាមចំណង់របស់ខ្លួន :** ឧទាហរណ៍ "រដ្ឋសភាផែកជ្រើសរើសប្រធានាធិបតីសាធារណៈរដ្ឋ ក្នុងសម័យប្រជុំពេញអង្គនៃសភាទាំងពីរ"។ តាមវាក្យខ័ណ្ឌទី ២ មាត្រាទី ៥៤ នៃរដ្ឋធម្មនុញ្ញឆែក ១៩៩២ ។ ការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ៣ នាក់ពីរដ្ឋសភា ( កថាខ័ណ្ឌទីបី មាត្រា ១៣៧ នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣) ។

**ខ. ទីពីរ : ការជ្រើសរើស ឬចំណាត់តាំងតាមការបញ្ជូនដោយអង្គការដទៃ ឬមន្ត្រីរាជការរដ្ឋ** ឧទាហរណ៍ "រដ្ឋសភាជាតិស្វ៊ីស ជ្រើសរើសចៅក្រមតាមការស្នើសុំរបស់រដ្ឋាភិបាល"។ ( វាក្យខ័ណ្ឌទី ១ នៃមាត្រា ១៤៥ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩២ ។ តាមកថាខ័ណ្ឌចុងក្រោយនៃ**មាត្រា ៥** ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រីកម្ពុជា ឆ្នាំ ១៩៩៤ កំណត់ថា "សមាជិករាជរដ្ឋាភិបាលទាំងអស់ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយពីបានសេចក្តីអនុម័តទុកចិត្តពីរដ្ឋសភា"។

**គ. ទីបី : ការបង្កើតអង្គការទូទៅ ដោយមិនកំណត់នូវអ្នកដឹកនាំរបស់អង្គការនោះ :** ឧទាហរណ៍ "រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើន ពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ( មាត្រា ៩០ វាក្យខ័ណ្ឌទី ៨ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣)" រីឯមាត្រា ១១៩ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ដដែល បានកំណត់ថា "តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល"។

**ឃ. ទីបួន : ការបង្កើតអង្គការជាមួយនឹងការជ្រើសរើស ឬការចាត់តាំងថ្នាក់ដឹកនាំរបស់អង្គការនោះ :** ឧទាហរណ៍បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា កម្ពុជាបានកំណត់ក្នុង**ប្រការ ២** ថា "នៅពេលបើកសម័យប្រជុំលើកទីមួយនៃនីតិកាលនីមួយៗ រដ្ឋសភាត្រូវជ្រើសតាំងប្រធាន និងអនុប្រធានទាំងពីររបស់រដ្ឋសភា"។

**ង. ទីប្រាំ :ការជ្រើសរើស ឬការចាត់តាំងត្រឹមតែថ្នាក់ដឹកនាំនៃអង្គការមួយ ឬអនុប្រធានរបស់អង្គការនោះ :** ឧទាហរណ៍ "សភាមានសិទ្ធជ្រើសរើស និងចាត់តាំងប្រធានតុលាការមជ្ឈឹម ឯសល់ពីនោះនៃសមាសភាពរបស់វាត្រូវបានជ្រើសរើស និងចាត់តាំងដោយក្រុមប្រឹក្សាអចិន្ត្រៃយ៍នៃ

រដ្ឋសភា"។ (វាក្យខណ្ឌទី ៨ មាត្រា ៧៦ និងវាក្យខណ្ឌទី ៩ នៃមាត្រា ៨៧ រដ្ឋធម្មនុញ្ញកូរ៉េខាងជើង) ។

**ខ. ទីប្រាំមួយ : ការបង្កើតផ្នែកមួយនៃអង្គការ ឬស្ថាប័នមួយ** : ឧទាហរណ៍ "ក្នុងចៅក្រមទាំង ៩ នាក់ នៃតុលាការធម្មនុញ្ញរ៉ូម៉ានី មាន ៣ រូប ចាត់តាំងដោយសភាតំណាងរាស្ត្រ និង ៣ ទៀតដោយព្រឹទ្ធសភា" (វាក្យខណ្ឌទី ២ នៃមាត្រា ១៤០ រដ្ឋធម្មនុញ្ញរ៉ូម៉ានី ឆ្នាំ ១៩៩១) និង**មាត្រា ១៣៧** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំនត់ថា "ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង ។ សមាជិកបីរូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានមានសំលេងឧត្តមានុភាពក្នុងករណីបែកសំលេងជាពីរស្មើគ្នា" ។

**គ. ទីប្រាំពីរ : ការចូលរួមរបស់រដ្ឋសភា នៅក្នុងសមាសភាពនៃសហការីដ៏ច្រើនបំផុតដែលបង្កើតអង្គការមួយ ឬជ្រើសរើសប្រធានាធិបតី** : ឧទាហរណ៍ : "សភាអាល្លឺម៉ង់ប៊ុនឌិស្តាគ (Bundestag) បានកំណត់ការជ្រើសរើសប្រធានាធិបតីសហព័ន្ធ ត្រូវតែចូលរួមសហការនៃសភាទាំងពីរ" (មាត្រាទី ៥៤ រដ្ឋធម្មនុញ្ញសហព័ន្ធ ១៩៤៩) ។

**ឃ.ទីប្រាំបី : ការចូលរួមរបស់រដ្ឋសភា នៅក្នុងសមាសភាពនៃសហការីដ៏ច្រើនបំផុតដែលបង្កើតអង្គការមួយ ឬចាត់តាំងមន្ត្រីរដ្ឋ** : ឧទាហរណ៍ "ប្រមុខរដ្ឋាភិបាលត្រូវចាត់តាំងដោយស្តេច តែត្រូវមានការទុកចិត្តភាគច្រើនដាច់ខាតពីសមាជិកព្រឹទ្ធសភា" (វាក្យខណ្ឌ ៣ មាត្រា ៩៩ រដ្ឋធម្មនុញ្ញអេស្ប៉ាញ) ។

គួរនិយាយផងដែរថា គោលការណ៍ខាងលើទាំងប៉ុន្មាននេះ មានការប្រព្រឹត្តិទៅនៅប្រទេសជាច្រើនទៀតដែលមានលក្ខណៈផ្សេងពីគ្នា ដោយអាស្រ័យនឹងទំរង់គ្រប់គ្រងបែបរាជាធិបតេយ្យ និងសាធារណរដ្ឋ (**សូមអានអត្ថបទទី ១៦** ស្តីពីប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល) ។

ជាក់ស្តែងរដ្ឋសភាទាំងឡាយ ដោយគួបផ្សំនឹងទំរង់គ្រប់គ្រងរដ្ឋនោះ គឺសឹងតែជាទូទៅវាចូលរួមក្នុងការបង្កើតអំណាចតុលាការ ដូចជាផ្នែកទី ២ **មាត្រា** II[៥៨] នៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកសរសេរថា "សិទ្ធិរបស់ប្រធានាធិបតី ចាត់តាំងចៅក្រមនៃតុលាការកំពូលតាមការឱ្យដំបូន្មាន និងការយល់ព្រមពីព្រឹទ្ធសភា"។ ការរៀបរាប់ខាងលើនេះ គ្រាន់តែជាសញ្ញាណនៃការចូលរួមរបស់រដ្ឋសភា ក្នុងការជ្រើសរើសអង្គការរដ្ឋផ្សេងៗតែប៉ុណ្ណោះ ។

## ៩. ការត្រួតពិនិត្យរបស់រដ្ឋសភាចំពោះការងារអង្គការរដ្ឋ, ស្ថាប័ន និងមន្ត្រីរាជការ

ការត្រួតពិនិត្យរបស់រដ្ឋសភាទៅលើអង្គការផ្សេងៗរបស់រដ្ឋ និងសមាជិកទាំងឡាយរបស់អង្គការទាំងនោះគឺជាភារកិច្ចមួយរបស់រដ្ឋសភា ចាំបាច់សំរាប់ត្រួតពិនិត្យទៅលើកិច្ចអនុវត្តច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ ។ វាជាមុខងារមួយ និងមានការកំណត់ដោយការត្រួតពិនិត្យ និងក៏រឹតយ៉ាងជាក់លាក់លើអំណាច ដោយរដ្ឋសភាមិនអាស្រ័យនឹងទំរង់គ្រប់គ្រងទេ ហើយអំណាចនោះលាតត្រដាងទៅលើទំហំនៃទិន្នន័យមុខងារ ( មុខងារដែលមានក្នុងរដ្ឋនីមួយៗ) ។អំណាចនោះបានទទួលនូវការសំដែងរបស់ខ្លួនក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់ ឬក៏នៅក្នុងសេចក្តីបញ្ញាផ្សេងៗ ឬក៏នៅក្នុងទិដ្ឋភាពនៃវិធីនិយ័តកម្មគតិយុត្តិផ្ទាល់ មានជាឧទាហរណ៍ : វាក្យខ័ណ្ឌ ១១ **មាត្រា ៨៥** រដ្ឋធម្មនុញ្ញស្វីសឆ្នាំ ១៨៧៤[៥៩] សរសេរថា "រដ្ឋសភាជាមុខងារត្រួតពិនិត្យខ្ពស់បំផុត ចំពោះរដ្ឋបាលសហព័ន្ធ និងយុត្តិធម៌សហព័ន្ធ"។បុន្តែសំរាប់រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ **មាត្រា ១២១** កំណត់ថា "សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត"។ និង**មាត្រា ១២៦** "សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

---

[៥៨]. Constitution of United State 1787 ។

[៥៩]. Constitutional Law of Foreign Country, Part II, M-1994, Page 117 ។

ក្នុងករណីនេះ និងក្នុងករណីធ្វើខុសជាទម្ងន់ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភា សំរេចក្នុងរឿងនេះដោយវិធីបោះឆ្នោតជាសំងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល" ។ និង **មាត្រា ៩៧** "គណៈកម្មការទាំងឡាយរបស់រដ្ឋសភាអាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺ អំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន " ។

តាមមាត្រាទាំងបីខាងលើនៃរដ្ឋធម្មនុញ្ញកម្ពុជា ពុំបានសរសេរដោយផ្ទាល់ថា រដ្ឋសភាមានសិទ្ធិត្រួតពិនិត្យទេ ប៉ុន្តែវាបានសរសេរអំពីភាពទទួលខុសត្រូវចំពោះរដ្ឋសភា ។

## ១០. សិទ្ធិ-អំណាចនៃរដ្ឋសភានៅក្នុងវិស័យការពារ និងសន្តិសុខសង្គម

នេះគឺជាសិទ្ធិ-អំណាចមួយដែលរដ្ឋសភាហ៊ានអាកាត់ទៅលើកិច្ចការនានា ដែលមានភាពពុំប្រក្រតីនៅក្នុងប្រទេស ឬក៏ត្រូវបានបំពានពីពួកបរទេស ។ លក្ខណៈទាំងនោះ មានដូចជារដ្ឋសភាមានសិទ្ធិជារួមគឺប្រកាសសង្គ្រាម ឧទាហរណ៍ : **មាត្រា ៣៥** រដ្ឋធម្មនុញ្ញបារាំងបញ្ជាក់ថា "ការប្រកាសសង្គ្រាមត្រូវអនុញ្ញាតិដោយរដ្ឋសភា[៦០] " ។ ប៉ុន្តែនៅក្នុងរដ្ឋធម្មនុញ្ញនេះពុំបានបញ្ជាក់ថា តើអ្នកណាជាអ្នកប្រកាសនោះទេ ប៉ុន្តែចៅក្រមក្នុងរឿងនោះគឺពិតជាប្រធានាធិបតី ។ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ **មាត្រា ២៤** បានកំណត់ថា "ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតី នៃឧត្តមក្រុមប្រឹក្សាការពារជាតិដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រ ទ្រង់ប្រកាសសង្គ្រាមក្រោយអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា" ។ និង **មាត្រា ២២** បញ្ជាក់ថា "នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិឋិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី. ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា" ។ តាមរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ការប្រកាសសង្គ្រាមគឺផ្តុកផ្តាក់ដោយអំណាចរដ្ឋសភា (Congress) ផ្នែកទី ៨ មាត្រា I ។ រដ្ឋសភានៃប្រទេសខ្លះពុំ

[៦០] . Constitutional Law of Foreign Country. Part II. M-1994. Page 117 ។

មែនគ្រាន់តែប្រកាសសង្គ្រាមប្រឆាំងនឹងសត្រូវនោះទេ តែថែមទាំងការពារប្រឆាំងនូវរាល់អសន្តិសុខផ្ទៃក្នុងប្រទេសរបស់ខ្លួនទៀតផង ដូចជារដ្ឋធម្មនុញ្ញប្រទេសហុងគ្រី និងប្រទេសកម្ពុជា...... ។ល។

## ១១. សិទ្ធិ-អំណាចតុលាការរបស់រដ្ឋសភា

នេះគឺជាសិទ្ធិ - អំណាចរបស់រដ្ឋសភាក្នុងការចោទប្រកាន់ ឬក៏បង្កើតគណៈកម្មការអង្កេតស្រាវជ្រាវមួយ ទៅលើបញ្ហាដ៏សំខាន់ដែលទាក់ទិននឹងអំណាចកំពូលរបស់រដ្ឋ ។ អំណាចរបៀបនេះនៅក្នុងគោលការណ៍មិនមែនបែបបទរបស់រដ្ឋសភានោះទេ គ្រាន់តែមានន័យថាជាសំណល់ដែលចេញមកពីប្រព័ន្ធនៃការបែងចែកអំណាចប៉ុណ្ណោះ ។ ប៉ុន្តែយើងអាចជួបនូវអំណាចតុលាការ (សិទ្ធិតុលាការ) នៃរដ្ឋសភា ដែលជាផ្នែកមួយរបស់ប្រទេសខ្លះតែប៉ុណ្ណោះ។ ជាលក្ខណៈប្រវត្តិសាស្ត្របានបង្ហាញរួចហើយ ថាសិទ្ធិអំណាចតុលាការកើតឡើងនៅរដ្ឋសភា គឺក្នុងពេលដែលរដ្ឋសភាតស៊ូដើម្បីកំណត់ព្រំដែននៃអំណាចមហាក្សត្រ ក្នុងទំរង់គ្រប់គ្រងបែបរាជានិយមខ្លះ គឺនៅក្នុងក្របខ័ណ្ឌមួយ ឬក៏ក្នុងរង្វង់យុត្តិធម៌ ។ គួរដឹងដែរថាគណៈកម្មការអង្កេតស្រាវជ្រាវរបស់រដ្ឋសភា ដែលមានភារៈការងារក្នុងក្របខ័ណ្ឌត្រួតពិនិត្យនយោបាយក្នុងរដ្ឋាភិបាល ហើយឆ្ពោះទៅធ្វើការចោទប្រកាន់ក្នុងបទព្រហ្មទណ្ឌទៀតផង ។ គណៈកម្មការរបៀបនេះ វាប្រហាក់ប្រហែលជាមួយអង្គការឯកទេសទាំងឡាយនៃការអង្កេតស្រាវជ្រាវ ដែលមានកើតក្នុងប្រទេសជាច្រើននៃប្រព័ន្ធអង្គការអំណាចតុលាការ ។ ជាឧទាហរណ៍ក្នុង **មាត្រា ៨២** នៃរដ្ឋធម្មនុញ្ញអ៊ីតាលី និយាយអំពីគណៈកម្មការអង្កេតតាមដានទាំងឡាយ ដែលបង្កើតដោយសភាទាំងអស់នៃរដ្ឋសភា សំរាប់ធ្វើការអង្កេត-ស្រាវជ្រាវនូវរាល់រឿងទាំងឡាយដែលជាផលប្រយោជន៍សាធារណៈនោះ បាននិយាយថា[៦១] "គណៈកម្មាការអង្កេតតាមដានធ្វើការសិក្សា និងការសើរើទាំងអស់ជាមួយសិទ្ធិ-អំណាច និងការកំរិតទាំងអស់នេះជាអំណាចតុលាការ" (ឃ្លាទី ២ នៃផ្នែកទី ២) ។ មិនមែនម្តងម្កាលនោះទេ សិទ្ធិធ្វើការចោទប្រកាន់ចំពោះមុខអង្គការតុលាការទាំងអស់ នូវការប្រឆាំងមន្ត្រីរដ្ឋការជាន់ខ្ពស់ៗនោះបានត្រូវអនុញ្ញាតិដោយរដ្ឋសភា ឧទាហរណ៍ :

[៦១]. Constitution of Italy, Constitutional Law of Foreign Country, Part II, M-1994, Page 120 ។

**មាត្រា ១០៣** នៃរដ្ឋធម្មនុញ្ញប៊ុលហ្គារី សរសេរថា "រដ្ឋសភាធ្វើការចោទប្រកាន់ប្រឆាំងនឹងប្រធានាធិបតី និងអនុប្រធានាធិបតីក្នុងបទក្បត់ជាតិ ឬរំលោភរដ្ឋធម្មនុញ្ញ បន្ទាប់ពីរឿងនោះលើកយកទៅពិភាក្សា វែកញែកដោយតុលាការធម្មនុញ្ញ។" រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ **មាត្រា ១២៦** បានចែងថា "សមាជិកមួយរូប១នៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះ និងក្នុងករណីធ្វើខុសជាទំងន់ ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភា សំរេចក្នុងរឿងនេះដោយវិធីបោះឆ្នោតជាសំងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល" ។

ក្នុងប្រទេសមួយចំនួននីតិវិធីមួយបែបទៀតមានឈ្មោះថា "**អីមពីជ្ជមិន**"(Impeachment) (ការកោះហៅមកកាត់ទោសដោយរដ្ឋសភា) ដែលប្រព្រឹត្តជាធម្មតាទៅហើយ គឺធ្វើឡើងចំពោះមន្ត្រីរដ្ឋការដែលប្រព្រឹត្តបទល្មើសក្នុងតំណែងរបស់ខ្លួនដ៏ខ្ពស់ក្នុងអំណាចរដ្ឋនោះ គឺសភាជាន់ទាបធ្វើការចោទប្រកាន់ ឯសភាជាន់ខ្ពស់ជាអ្នកកាត់ទោស ហើយអាចដាក់ទណ្ឌកម្មដោយពិនិត្យលក្ខណៈល្បាយ (រួម) ពីមុខតំណែង នោះបន្ទាប់ពីមានការធ្វើ ឬកាត់ទោសជាធម្មតាតាមបែបតុលាការ ។ ត្រង់នេះមានន័យថា នីតិវិធីធ្វើទៅបានចំពោះមន្ត្រីរដ្ឋដែលប្រើប្រាស់តំណែងនៃមុខងាររបស់ខ្លួន ដោយមានអភ័យឯកសិទ្ធិកំរិតច្បាស់លាស់ ដែលទាក់ទិននឹងការកាត់ទោសធម្មតាតាមបែបតុលាការ ដូចជាប្រធានាធិបតី, រដ្ឋមន្ត្រី, ចៅក្រម ។ល។ ឧទាហរណ៍ : វាក្យខ័ណ្ឌទី ៥ នៃផ្នែកទី ២ មាត្រាទី I រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក សរសេរថា "សិទ្ធិពិសេសនៃការបណ្តេញចេញត្រូវផ្ទុកផ្តាក់ទៅសភាតំណាងរាស្ត្រ" រីឯវាក្យខ័ណ្ឌទី ៦ នៃផ្នែកទី ៣ មាត្រាដដែលនោះសរសេរថា "សិទ្ធិពិសេសដឹកនាំជាលក្ខណៈតុលាការតាមនីតិវិធីពិសេស (Impeachment) នោះត្រូវផ្ទុកផ្តាក់ទៅព្រឹទ្ធសភា" ។ ការជាក់ស្តែងគឺស៊ីងតែគ្មានសកម្មភាពបែបនេះទេ ។ នៅក្នុងប្រទេសជាច្រើនទៀត រដ្ឋសភាមានសិទ្ធិប្រកាសនូវការលើកលែងទោសនោះគឺពុំមែនសិទ្ធិតុលាការនោះទេ ប៉ុន្តែវាផ្សារភ្ជាប់ជាមួយអង្គការរដ្ឋទាំងពូងរបស់វា ។ ការលើកលែងទោសនោះ គឺមានន័យថាការឱ្យសេរីភាពទាំងស្រុង ឬក៏ចំណែកខ្លះពីទណ្ឌកម្ម

របស់បុគ្គលដែលទទួលបទព្រហ្មទណ្ឌ តាមការចោទប្រកាន់នៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនេះ ។ សូមចាំថាការលើកលែងទោស (Amnesty) និងការសុំខមាលទោស (Pardon) ចំពោះពិរុទ្ធជន និងជនជាប់ការចោទប្រកាន់ក្នុងបទល្មើសមានលក្ខណៈពុំដូចគ្នាទេ គឺត្រង់ថាការសុំខមាលទោស គឺជារឿងមួយដែលកើតចេញជាលក្ខណៈឯកជន ដោយធ្វើឡើងដោយបុគ្គលថ្នាក់ក្រោម រីឯការលើកលែងទោសធ្វើឡើងពីបុគ្គល ឬស្ថាប័នអំណាចជាន់ខ្ពស់ ។ ដូច **មាត្រា ៩០** បានកំណត់ថា "រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ" ។ និង **មាត្រា ២៧** "ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស" ។

ដូចនេះសិទ្ធិ-អំណាចរបស់រដ្ឋសភា ដែលមានលក្ខណៈតុលាការនេះ គឺជាសិទ្ធិវិនិច្ឆ័យ ឬចោទប្រកាន់ទៅលើបុគ្គលដែលមានអំណាចរដ្ឋ ហើយបំពេញមុខងារខ្ពស់ៗក្នុងរដ្ឋ ។

## ១២. ការផ្ទេរសិទ្ធិ-អំណាចរបស់រដ្ឋសភា

នេះគឺជាការបន្ទេរសិទ្ធិ - អំណាចរបស់រដ្ឋសភាក្នុងវិស័យនីតិកម្មខ្លះ ដែលត្រូវបានកំណត់ដោយច្បាប់កំពូល ក្នុងកម្មវត្ថុពិតប្រាកដមួយនៃទំនាក់ទំនងសង្គមទៅលើបន្ទេរនីតិកម្ម (Delegated Legislation) ។

នៅក្នុងបណ្តាប្រទេសជាច្រើន រដ្ឋសភាជាធម្មតាពុំដែលផ្ទេរអំណាចទៅឱ្យអង្គការរដ្ឋផ្សេងៗដទៃបានទេ ព្រោះថាវាជាអង្គការអនុម័តនូវរាល់សេចក្តីសំរេចទាំងឡាយ និងជាអ្នកត្រួតពិនិត្យទៀតផង ។ ប៉ុន្តែនៅក្នុងប្រទេសខ្លះរដ្ឋសភាអាចផ្ទេរអំណាចនោះទៅឱ្យរដ្ឋាភិបាល ។ ដូចនេះជារួមទៅសិទ្ធិ-អំណាចនីតិបញ្ញត្តិ និងរដ្ឋាភិបាលកាលដែលបានទទួលវាហើយ គឺវាធ្វើសមិទ្ធិ ឬបំពេញមុខការមួយនូវបន្ទេរនីតិកម្ម ( ការទទួលមុខងារជាអ្នកបង្កើតច្បាប់តែក្នុងក្របខ័ណ្ឌផ្ទេរសិទ្ធិ) ។ ឧទាហរណ៍ : **មាត្រា ៨២** នៃរដ្ឋធម្មនុញ្ញអេស្ប៉ាញ "រដ្ឋសភាផ្ទេរសិទ្ធ-អំណាចទៅឱ្យរដ្ឋាភិបាលបង្កើតបទដ្ឋានទាំងឡាយ មានថាមពលច្បាប់ ( សុពលភាពរបស់ច្បាប់) តាមការកំណត់បញ្ហា ( កម្មវត្ថុ) ឬសំនួរពិតប្រាកដមួយ ដែលបទដ្ឋានទាំងនោះមិនអាចជាកម្មវត្ថុនៃច្បាប់គំរិតដទៃទៀតបានឡើយ" ។ ការធ្វើរបៀបនេះទៅបានគេត្រូវបង្កើតប្រតិភូនីតិកម្ម ( ប្រតិភូនីតិបញ្ញត្តិ) ចាំបាច់ និងត្រូវជាសន្ធានកម្ម

(ការដឹកនាំសំរុះសំរួល) នៃច្បាប់គ្រឹះ ។ ដូចជាកាលណាកម្មវត្ថុនេះជាការបង្កើត ឬឧប្បត្តិកជាអត្ថបទច្រើននៅក្នុងទិដ្ឋភាព ឬប្រភេទមាត្រាទាំងឡាយ ឬក៏ជាសន្ទានកម្មនៃច្បាប់ធម្មតាដូចជា : ការប្រមូលផ្តុំ ឬការបណ្តុំនៃអត្ថបទនីតិកម្មផ្សេងៗគ្នាឱ្យនៅក្នុងប្រព័ន្ធតែមួយ ។ ប្រតិភូនេះនឹងបញ្ចេញនូវលក្ខណៈក្នុងទំរង់មួយតាមសំនួរច្បាស់លាស់ និងព្រមជាមួយនោះមានការកំរិតកាលបរិច្ឆេទសំរាប់ធ្វើសមិទ្ធិទៀតផង ។ ប្រតិភូនេះអះអាងថាបានធ្វើការសម្រេចបាច់ កាលណារដ្ឋាភិបាលបោះផ្សាយជាសាធារណៈនូវបទដ្ឋានដែលទាក់ទិននោះ។ ប៉ុន្តែក៏មិនត្រូវគិតថាប្រតិភូនេះអនុញ្ញាតិឱ្យមានភាពស្ងាត់ស្ងៀម (សភាពការងារ) ឬក៏មិនកំណត់រយៈពេលនោះបានទេ ។ ការបង្កើតប្រតិភូពីរដ្ឋសភាទៅចូលរួមក្នុងការធ្វើច្បាប់នេះ គឺដើម្បីឱ្យបទដ្ឋាននោះមានកំលាំងគតិយុត្តិ ដូចច្បាប់ធម្មតាថ្វីត្បិតតែរដ្ឋាភិបាលមានសិទ្ធិក្នុងការធ្វើច្បាប់ (អនុម័ត) ពិតមែនក៏ដោយ ដូចជា**មាត្រា ៧៦** រដ្ឋធម្មនុញ្ញអ៊ីតាលី បញ្ជាក់ថា រដ្ឋាភិបាលមាននាទីធ្វើច្បាប់ដែរ តាមល័ក្ខខ័ណ្ឌនៃច្បាប់ រីឯ**មាត្រា ៧៧** បានកំនត់នូវវាក្យខ័ណ្ឌទី ២១ ថា "រដ្ឋាភិបាលមិន អាចបង្កើតក្រឹត្យនានាឱ្យមានកំលាំងគតិយុត្តិ ដូចច្បាប់ធម្មតាបាននោះទេ បើសិនជាពុំមានប្រតិភូសភាចូលរួមនោះទេ ។ ប៉ុន្តែរដ្ឋសភាអាចផ្តល់សិទ្ធិ-អំណាចដល់បុគ្គលខ្លះក្នុងករណីចាំបាច់ ដូចជារដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ **មាត្រា ៨៧** បានកំណត់ថា "ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយដែលរដ្ឋសភាបានអនុម័តរ៉ាប់រងការងារអនុវត្តន៍បទបញ្ជាផ្ទៃក្នុងរបស់សភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា ។ ក្នុងករណីដែលប្រធានរដ្ឋសភាមានធុរៈមិនអាចបំពេញមុខងារបានដោយហេតុមកពីមានជំងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូបត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស" ។ ប៉ុន្តែមាត្រានេះពុំមែនមានលក្ខណៈបន្ទេរនីតិកម្មទេ តែមានលក្ខណៈបន្ទេរសមត្ថកិច្ចនៃមុខងាររបស់ប្រមុខនៃអំណាចនីតិបញ្ញត្តិតែប៉ុណ្ណោះ ។

## ១៣. អាទេសកម្ម ឬការយកមកជំនួសនៃរដ្ឋសភា (Substituion of Parliament)

អាទេសកម្មនៃរដ្ឋសភា គឺជាល័ក្ខខ័ណ្ឌមួយដែលត្រូវបានកំណត់ដោយច្បាប់កំពូលរបស់រដ្ឋ ក្នុងកាលៈទេសៈណាមួយដែលរដ្ឋសភាត្រូវបានដើរតួជំនួសដោយអង្គការនីតិប្រតិបត្តិ ដែលក្នុងករណីនេះអង្គការនោះពុំមាននាទីបំពេញការងារនីតិកម្មទេ ។ ក្នុងករណីនេះមានន័យថា ជាបញ្ហាសំខាន់ដែលចង់និយាយនោះ គឺការសមិទ្ធិនៃសមត្ថកិច្ចរបស់រដ្ឋសភាផ្តល់ទៅអង្គការរដ្ឋដទៃទៀត គឺមិនមែននៅក្នុងលទ្ធផលនៃការផ្ទេរអំណាចក្នុងករណីណាមួយរបស់រដ្ឋសភានោះទេ តែវាជាលក្ខណៈផ្ទាល់នៅលើគ្រឹះមួយនៃអធិបញ្ញាធម្មនុញ្ញ ។ រដ្ឋធម្មនុញ្ញប្រជាធិបតេយ្យ ជាទូទៅច្រើនតែពិភាក្សាលើលទ្ធភាពមួយនៃអាទេសកម្មរបស់រដ្ឋសភា ឱ្យទៅអង្គការដទៃទៀតរបស់រដ្ឋនោះត្រង់ថា ជាធម្មតាមានត្រឹមតែក្នុងករណីនៃការកកើតឡើងនូវ**ស្ថានភាពវិសាមញ្ញណាមួយតែប៉ុណ្ណោះ** ។ ជាទូទៅការធ្វើអាទេសកម្មនៃរដ្ឋសភាច្រើនផ្តល់សិទ្ធិទៅឱ្យរដ្ឋាភិបាល គឺរដ្ឋាភិបាលបំពេញការងារជានីតិអាទេសកម្មតែម្តង ឬហៅថាអាទេសកម្មគតិយុត្តិ ( ការផ្តល់សិទ្ធិឱ្យតាមផ្លូវច្បាប់ ) ។ ឧទាហរណ៍ : **មាត្រា ១០២** ស្វីស[៦២] ចំនុចទី ១១ សរសេរថា : ក្រុមប្រឹក្សាសហព័ន្ធ ( រដ្ឋាភិបាល ) នៅក្នុងគ្រប់ករណីចាំបាច់បំផុតកាលណារដ្ឋសភាសហព័ន្ធមិនធ្វើការប្រជុំបាន ( តាមករណីហេតុការណ៍ណាមួយ ) នោះរដ្ឋាភិបាលអាចអំពាវនាវទៅកងទ័ព ហើយមានសិទ្ធិចាត់ចែងទ័ពទាំងនោះទៀតផង ។ ប្រសិនបើចំនួនមនុស្សលើសពី ២០០០ នាក់ ត្រូវបានអំពាវនាវ ឬក៏ពួកគេទាំងនោះប្រដាប់ដោយអាវុធនៅរង់ចាំលើសពី ៣ សប្តាហ៍ នោះរដ្ឋាភិបាលសហព័ន្ធត្រូវតែកោះហៅយ៉ាងប្រញាប់**ទៅរដ្ឋសភា** ឬក៏តាមចំណុចទី ៩ នៃមាត្រា ៨៥ រដ្ឋាភិបាលមានសិទ្ធិចាត់កំលាំងទ័ពសហព័ន្ធយ៉ាងរហ័ស ក្នុងគោលដៅចាត់វិធានការសំរាប់សន្តិសុខខាងក្រៅ និងខាងក្នុងដើម្បីថែរក្សានូវឯករាជ្យ និងអព្យាក្រឹត្យរបស់ប្រទេស ( ចំនុចទី ៦ និងទី ៧ នៃមាត្រា ៨៥ ) ។

---

[៦២] Constitutional law of foreign Country, Part II, M-1994, Page 127 ។

ចំពោះប្រទេសខ្លះទៀត ទោះបីជាស្ថានភាពក្នុងប្រទេសមានភាពមិនប្រក្រតីក៏ដោយ ក៏អំណាចរបស់រដ្ឋសភា ពុំអាចត្រូវបានជំនួសដោយអង្គការណាមួយដែរ ប៉ុន្តែរដ្ឋសភា ត្រូវពុះពារបន្តអាណត្តិរបស់ខ្លួនតទៅទៀត ដូចជារដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ **មាត្រា ៧៨** កំណត់នៅវាក្យខ័ណ្ឌទី ៥ និងទី ៦ ថា "ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើររបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល" ។ ត្រង់ចំនុចនេះបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាពុំអាចដើរតួជារដ្ឋសភាបានទេ បើទោះបីជារដ្ឋសភាពុំអាចប្រជុំបានដោយស្ថានការណ៍ណាក៏ដោយ ។

## ១៤. នីតិរដ្ឋសភា (Parliamentary Law)

នេះគឺជាប្រព័ន្ធមួយនៃបទដ្ឋានធម្មនុញ្ញគតិយុត្តិទាំងឡាយ ដែលធ្វើនិយ័តកម្មទៅលើឋានៈនៃរដ្ឋសភា (Status) និងទំនាក់ទំនងផ្ទៃក្នុង ផ្ទៃក្រៅរបស់រដ្ឋសភា (កិច្ចក្រៅរដ្ឋសភា) ។ ប្រភពសំខាន់ៗនៃនីតិរដ្ឋសភា គឺបទដ្ឋានទាំងឡាយនៃរដ្ឋធម្មនុញ្ញ បទដ្ឋានទាំងនោះធ្វើនិយ័តកម្មទៅលើផ្នែកផ្សេងៗ ដោយឡែកៗនៃការគ្រប់គ្រង និងសកម្មភាពរបស់រដ្ឋសភា (បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា) ។ ប្រភពមួយទៀតដូចជានិយ័តកម្ម (បទបញ្ញត្តិផ្សេងៗ) របស់រដ្ឋសភាដែលកិច្ចការនោះ (បទបញ្ញត្តិផ្សេងៗ) បានផ្ទុកនូវការធ្វើនិយ័តកម្មដ៏ពិស្តារសំខាន់ៗ ទៅលើទំនាក់ទំនងផ្ទៃក្នុងរដ្ឋសភា និងផ្ទៃក្រៅ គឺបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។ នៅមានប្រភពមួយទៀត គឺសេចក្តីសំរេចរបស់រដ្ឋសភា ឬហៅថាអាទិភាពរបស់រដ្ឋសភា ក្នុងនោះរួមទាំងសេចក្តីសំរេចរបស់ប្រមុខរដ្ឋសភា ក៏ចាត់ទុកជាប្រភពនៃនីតិរដ្ឋសភាដែរ ។ គួរកត់សំគាល់ថា បើប្រទេសមួយរដ្ឋសភាមានតែសភាទោលនោះ ការអនុម័តទាំងឡាយលើបទបញ្ញត្តិផ្សេងៗគេហៅថាជា**ច្បាប់** ព្រោះអនុម័តដោយសភាតំណាងរាស្ត្រ ប៉ុន្តែបើប្រទេសមួយរដ្ឋសភាមានពីរសភា (សភាតំណាងរាស្ត្រ និងសភាតំណាងសមាជិកសហព័ន្ធ ឬព្រឹទ្ធសភា) នោះការអនុម័តទាំងឡាយរបស់ព្រឹទ្ធសភាមានឈ្មោះថានិយ័តកម្ម (Regulation) ឬ

ព្រឹទ្ធសភាធ្វើ**និយ័តភាព** (Regularity) ។ ដូចនេះសិទ្ធិអនុម័តលើនិយ័តកម្ម ឬក៏បទបញ្ញត្តិផ្សេងៗជា ភារៈមួយដែលកំណត់ដោយរដ្ឋធម្មនុញ្ញ ដូចជា**មាត្រា ៦៤** រដ្ឋធម្មនុញ្ញប្រទេសអ៊ីតាលីកំណត់ថា "សភានីមួយៗ (សភាតំណាងរាស្ត្រ និងព្រឹទ្ធសភា) អនុម័តនូវនិយ័តកម្ម (បញ្ញត្តិ និងច្បាប់) បានដោយមតិភាគច្រើនដាច់ខាត នៃសមាជិករួមក្នុងសមាសភាពរបស់សភានីមួយៗ" ។ ដូចនេះសកម្មភាពទាំងអស់របស់សភាក្នុងការបង្កើតច្បាប់ ឬហៅថាកិច្ចរបស់សភាដែលជាប្រភពនៃច្បាប់ ដូចជា រដ្ឋធម្មនុញ្ញ, ច្បាប់ធម្មតា, សេចក្តីសំរេច, ការប្រកាស...... ទាំងនោះធ្វើឡើង ឬអនុម័តឡើងដោយរដ្ឋសភា ។

**អត្ថបទទី ១៥**

# រចនាសម្ព័ន្ធនៃរដ្ឋសភា និងអង្គការគ្រប់គ្រងរដ្ឋសភា

## ១. រចនាសម្ព័ន្ធនៃរដ្ឋសភា និងការគ្រប់គ្រងសភា (Structure of Parliament and Organization of Chamber)

ជាធម្មតារដ្ឋសភានៅក្នុងបណ្ដាប្រទេសនីមួយៗតែងមានរចនាសម្ព័ន្ធ និងអង្គការគ្រប់គ្រងរបស់វាជានិច្ច ទោះជាប្រទេសនោះស្ថិតក្នុងលក្ខណៈជារដ្ឋឯកភូត (Unitary State) ឬក៏រដ្ឋសហព័ន្ធ (Federation) ក៏ដោយ ។ ជាទូទៅ រដ្ឋសភានៃបណ្ដាប្រទេសមួយចំនួនរចនាសម្ព័ន្ធរបស់វាមានលក្ខណៈពីរប្រភេទគឺ : សភាតំណាងរាស្ត្រ (សភាជាន់ទាប) និងសភាជាន់ខ្ពស់ (ព្រឹទ្ធសភា) ដែលការបង្កើតវានោះអាស្រ័យនឹងទំរង់រចនាសម្ព័ន្ធគ្រប់គ្រងដែនដី (**មើលរូបទី ១១**)។

**ក. សភា** (Chambers) : វាគឺជាកន្លែង ឬឈ្មោះនៃស្ថាប័នតំណាងមួយដែលគេប្រើប្រាស់ក្នុងបណ្ដាប្រទេសមួយចំនួន សំដៅក្នុងស្ថាប័នជាន់ខ្ពស់របស់រដ្ឋ ។ ជាឧទាហរណ៍ដូចជាសភាជាន់ខ្ពស់ ឬហៅថាសភាតំណាងរដ្ឋ (Upper Chamber), សភាជាន់ទាប ឬសភាតំណាងរាស្ត្រ (Lower Chamber), ប៉ុន្តែសំរាប់ប្រទេសអង់គ្លេសសភាជាន់ខ្ពស់គេប្រើពាក្យ “House of Lords” ឬហៅថាព្រឹទ្ធសភា ដែលជាសភាតំណាងពួកគហបតីធំៗ រីឯសភាជាន់ទាប “House of Commons” ឬហៅថាសភាតំណាងរាស្ត្រ ។ ដូចនេះប្រទេសអង់គ្លេស**រដ្ឋសភា**របស់គេមានពីរសភាគឺ : **សភាជាន់ទាប និងសភាជាន់ខ្ពស់** ។

ជាទូទៅរដ្ឋសភា (Parliament) ជាប្រវត្តិសាស្ត្រវាកើតចេញ ឬក៏វាកកើតឡើងពីសភាមួយ (Chamber) ឬសភាច្រើន (Chambers) យើងតែងជួបប្រទះនូវរដ្ឋសភាដែលមានសភាមួយ ឬពីរ ប៉ុន្តែរដ្ឋសភាដែលមានសភាលើសពីពីរយើងកំរជួបប្រទះណាស់ ។ ជាឧទាហរណ៍ រដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋអាហ្វ្រិកខាងត្បូងដែលចូលជាធរមាននៅឆ្នាំ ១៩៨៤ បានកំណត់ថារដ្ឋសភារបស់គេមានសភាបី ដែលសភាទាំងនោះបានបង្កើតឡើងដោយយកគោលការណ៍ប្រកាន់ពូជសាសន៍គឺៈ សភា

ជាន់ខ្ពស់ (ជ្រើសរើសពីពួកស្បែកស), សភាតំណាងរាស្ត្រ (ជ្រើសរើសពីពណ៌ផ្សេងៗ) និងសភាប្រតិភូ (ជ្រើសរើសពីពួកជនជាតិដើម ឥណ្ឌា) ។ យើងអាចសង្កេតទៅលើរដ្ឋសភានៃរដ្ឋដែលជាសហព័ន្ធវាកើតឡើងពីសភាពីរ (Bicameralism) ដែលក្នុងនោះសភាជាន់ខ្ពស់តំណាងឱ្យសមាជិករបស់សហព័ន្ធ (Federation) ដូចជា**សហរដ្ឋអាមេរិក, អាល្លឺម៉ង់, ប្រេស៊ីល, មិកស៊ិក, អូស្ត្រាលី, រុស្ស៊ី** ......។ល។ រីឯសភាជាន់ទាបតំណាងឱ្យពលរដ្ឋទូទៅក្នុងសហព័ន្ធទាំងមូល ។ នៅក្នុងរដ្ឋឯកភូតមួយចំនួនដែលរដ្ឋសភារបស់គេមានសភាពីរដែរ (Bicameral System) នោះសភាជាន់ខ្ពស់បង្កើតមកសំរាប់តំណាងឱ្យដែនដីនយោបាយរបស់ប្រទេស ដូចជា**អ៊ីតាលី, អេស្ប៉ាញ, បារាំង, ប៉ូឡូញ, ជប៉ុន** ....... ។ល។ ប៉ុន្តែរដ្ឋឯកភូត (Unitary State) ដែលមានចំនួនជាងពាក់កណ្តាលនៅអឺរ៉ុប រដ្ឋសភាគេមានសភាតែមួយប៉ុណ្ណោះ (Unicameral System) ដូចជាប្រទេស**ហ្វាំងឡង់, ស៊ុយអ៊ែដ, ដាណឺម៉ាក, ហុងគ្រី, ប៊ុលហ្គារី**....... ។ល។

**ខ. ការបង្កើតរដ្ឋសភា** : ការបង្កើតរដ្ឋសភានៃប្រទេសនីមួយៗពុំមាន លក្ខណៈដូចគ្នានោះទេ គឺវាអាស្រ័យនឹងភាពសំរុះសំរួលនៃឯកភាពជាតិតែប៉ុណ្ណោះ ។ ជាក់ស្តែងដូចជាប្រទេសកម្ពុជាតាមរដ្ឋធម្មនុញ្ញ ១៩៩៣ បានកំណត់បង្កើតរដ្ឋសភាតែមួយប៉ុណ្ណោះ គឺសភាតំណាងរាស្ត្រហៅថា "រដ្ឋសភា" ប៉ុន្តែក្រោយពីបោះឆ្នោតឆ្នាំ ១៩៩៨ ក្នុងអាណត្តិទីពីរ គណបក្សដែលមានតំណាងក្នុងរដ្ឋសភាយល់ព្រមធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ១៩៩៣ ដោយបានបង្កើតឱ្យមានសភាពីរនៅក្នុងរដ្ឋសភានៃប្រទេសកម្ពុជា គឺសភាជាន់ទាបហៅថា "រដ្ឋសភា" រីឯសភាជាន់ខ្ពស់ហៅថា "ព្រឹទ្ធសភា" ។

**ខ១. សភាជាន់ទាប** (Lower Chamber) : ការបង្កើតសភាសំរាប់រដ្ឋនៃប្រទេសនីមួយៗមានលក្ខណៈមួយឈរលើគោលការណ៍ ឬក៏វិន័យមួយច្បាស់លាស់ "ច្បាប់" ។ ដូចនេះរាល់សភាជាន់ទាប ឬរដ្ឋដែលមានសភាតែមួយ (Unicameral) ដែលគេហៅថាជាសភាតំណាងរាស្ត្រនោះ វាជានិច្ចកាលបង្កើតឡើងដោយលក្ខណៈពិសេសតាមវិធីជ្រើសរើស (បោះឆ្នោត) **ដោយផ្ទាល់ និងជាសាកល** ។ ជាឧទាហរណ៍ដូចជា**មាត្រា ៧៦** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ក្នុងវាក្យខ័ណ្ឌទីមួយ និងទីពីរថា "រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសាកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសំងាត់ ............" ។

សភាជាន់ទាប ឬសភាតំណាងរាស្ត្រនេះអាណត្តិរបស់វាមានរយៈពេល ៤ ឬ ៥ ឆ្នាំប៉ុណ្ណោះ ដូច **មាត្រា ៧៨** រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ក្នុងវាក្យខ័ណ្ឌទីមួយថា "នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលរដ្ឋសភាថ្មីចូលកាន់តំណែង" ។ ប៉ុន្តែយើងអាចជួបប្រទះនូវថេរវេលាដ៏ខ្លីបំផុតដែរ ដូចជាសភាតំណាងរាស្ត្រប្រទេសអាមេរិកមានរយៈពេលតែ ២ ឆ្នាំប៉ុណ្ណោះ ដែលបោះឆ្នោតដោយប្រជាជននៃរដ្ឋដោយឡែក១ ។ ដូចនេះសភាជាន់ទាបកើតឡើងពីឆន្ទៈផ្ទាល់របស់រាស្ត្រ ហើយតំណាងឱ្យពលរដ្ឋទូទៅនៅក្នុងរដ្ឋនោះ ។

**ខ₂. សភាជាន់ខ្ពស់** (Upper Chamber) : ចំពោះបញ្ហានេះការប្រតិបត្តិមានភាពផ្សេង១គ្នាយ៉ាងច្រើនក្នុងការបង្កើតនូវសភាជាន់ខ្ពស់នោះ ។ ដូចជានៅចក្រភពអង់គ្លេស សភាជាន់ខ្ពស់ (House of Lords) ដែលក្នុងនោះសមាជិកមួយចំនួនធំត្រូវបាន**ចាត់តាំង**ដោយស្តេច ឬក៏ចូលកាន់តំណែងនោះតាមរយៈ**ការស្នងត្រកូល** ។ សភានេះជាសភាដែលតំណាងឱ្យពួកគហបតីធំ១ ចក្រភពអង់គ្លេសសឹងតែជាប្រទេសតែមួយគត់ ដែលសភាជាន់ខ្ពស់របស់គេចាត់តាំងដោយប្រមុខរដ្ឋ ឬក៏ជាទូទៅសមាសភាពនៃសភានោះបង្កើតឡើងដោយការចាត់តាំង ឬតាមការស្នង ។ ហើយរយៈពេលនៃអាណត្តិរបស់សភានោះពុំបានកំណត់ទេ ។

ជាទូទៅ ប្រទេសដែលសភាជាន់ខ្ពស់របស់គេដែលសមាជិករបស់វា ត្រូវចាត់តាំងទាំងស្រុងនោះមានដូចជាប្រទេស : **ថៃ** ( សមាជិកព្រឹទ្ធសភា ២៧០ ចាត់តាំងដោយព្រះរាជារយៈពេល ៦ ឆ្នាំ) **ប្រទេសហ្ស៊កដានី** (Jordan), **ហ្សាម៉ៃការ** (Jamaica ជារដ្ឋឯករាជ្យស្ថិតក្នុងសហគមន៍ចក្រភពអង់គ្លេសប្រមុខរដ្ឋ គឺស្តេចចក្រភពអង់គ្លេសជាអ្នកចាត់តាំងសមាជិកព្រឹទ្ធសភា), **ប្រទេសបារបាដូស** (Barbados ជារដ្ឋឯករាជ្យមួយស្ថិតក្នុងសហគមន៍ចក្រភពអង់គ្លេស សមាជិកព្រឹទ្ធសភាមាន ២១ នាក់), **ប្រទេសប៊ែលលីស** (Belize ជារដ្ឋឯករាជ្យមួយក្នុងសហគមន៍ចក្រភពអង់គ្លេស សមាជិកព្រឹទ្ធសភា ៨ នាក់), ។ល។ ប៉ុន្តែមានប្រទេសមួយចំនួន សមាជិកព្រឹទ្ធសភារបស់គេភាគខ្លះត្រូវបានចាត់តាំងដោយមេដឹកនាំគណៈបក្សប្រឆាំង ដូចជាប្រទេសប៊ែលលីស និងហ្សាម៉ៃការជាដើម ។

ចំពោះប្រទេសកម្ពុជា សមាជិកព្រឹទ្ធសភាកើតឡើងដោយចាត់តាំងផង និងបោះឆ្នោតអសកលផង ដូចជាវាក្យខ័ណ្ឌទី ៣ នៃមាត្រា ៩៩ រដ្ឋធម្មនុញ្ញ ១៩៩៣ បានកំនត់ថា "សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ" ។ រីឯចំនួនរបស់វាមិនលើសពាក់កណ្ដាលនៃសមាជិកសភាតំណាងរាស្ត្រនោះទេ ។ ចំពោះចំនួនសមាជិកដែលត្រូវចាត់តាំងគឺ ២ នាក់ ដោយព្រះមហាក្សត្រ ហើយ ២ នាក់ទៀត ជ្រើសតាំងដោយរដ្ឋសភា (សភាតំណាងរាស្ត្រ) រីឯសល់ពីនោះត្រូវជ្រើសតាំងតាមការបោះឆ្នោតអសកល (មាត្រា ១០០) ។ ចំពោះអាណត្តិនៃព្រឹទ្ធសភាមានរយៈពេល ៦ ឆ្នាំ (មាត្រា ១០២) ។

ចំពោះប្រទេសដែលមានទំរង់រចនាសម្ព័ន្ធដែនដីជាសហព័ន្ធវិញ សភាជាន់ខ្ពស់របស់គេក៏រៀបចំឡើងមានលក្ខណៈផ្សេងៗដែរ ដូចជាប្រទេស**ម៉ាឡេស៊ី** សមាជិកព្រឹទ្ធសភា ៦៩ នាក់ ក្នុងនោះមាន ៤៣ នាក់ត្រូវបានចាត់តាំង ប៉ុន្តែសំរាប់ប្រទេស**អាល្លឺម៉ង់** សភាជាន់ខ្ពស់របស់គេឈ្មោះប៊ុនដេស្រាត (Bundesrat) ដែលសមាជិករបស់សភានេះ រៀបចំឡើងពីសមាជិករបស់រដ្ឋាភិបាលនៃសមាជិកនីមួយៗរបស់សហព័ន្ធ[៦៣] ។ ក្នុងករណីមានការផ្លាស់ប្ដូរសមាជិករដ្ឋាភិបាលនៃរដ្ឋ (Land) ណាមួយជាសមាជិកនោះ ក៏ត្រូវផ្លាស់ប្ដូរបេក្ខភាពជាសមាជិកក្នុងសភាជាន់ខ្ពស់ (Bundesrat) ជាស្វ័យប្រវត្តិដែរ ។ សភាជាន់ខ្ពស់នៃបណ្ដាប្រទេសមួយចំនួនទៀត ដែលសមាជិករបស់គេភាគខ្លះបោះឆ្នោត**ដោយផ្ទាល់** ដូចជាសហរដ្ឋ**អាមេរិក**, **ស្វីស**, **អ៊ីតាលី**, ..... ។ នៅក្នុងប្រទេសអ៊ីតាលីប្រធានាធិបតីអាចចាត់តាំងពលរដ្ឋ ៥ នាក់[៦៤] ដែលមានស្នាដៃក្នុងវិស័យសង្គម, វិទ្យាសាស្ត្រ, អក្សរសាស្ត្រ និងសិល្បៈ វប្បធម៌ឱ្យក្លាយជាសមាជិកព្រឹទ្ធសភាមួយជីវិត ។ រីឯរៀងរាល់អតីតប្រធានាធិបតីរបស់អ៊ីតាលី មានសិទ្ធិជាសមាជិកព្រឹទ្ធសភាមួយជីវិត បើសិនជាគាត់មិនបដិសេធទេ ។

---

[៦៣]. សហព័ន្ធអាល្លឺម៉ង់រដ្ឋជាសមាជិករបស់សហព័ន្ធមានឈ្មោះថា "ប្រទេស" ឬ Land ដែលរដ្ឋនីមួយៗ នោះមានរដ្ឋធម្មនុញ្ញ,មានរដ្ឋាភិបាលរបស់ខ្លួន ។ សមាជិករបស់សហព័ន្ធមាន១៦ ប្រទេស ឬ ១៦ Land ។

[៦៤]. Constitutional Law of Foreign Country.M-1994.Page 135 ។

ចំពោះការបង្កើតសភាជាន់ខ្ពស់ ដែលសមាជិករបស់គេបង្កើតឡើងតាមរយៈការបោះឆ្នោតដោយប្រយោល (តាមរយៈតំណាង ឬសហការី) ក៏មានភាពផ្សេងៗគ្នាខ្លាំងណាស់ដែរ ពីព្រោះថាសឹងតែជាទូទៅការធ្វើររបៀបនេះ (បង្កើតសមាជិកព្រឹទ្ធសភា) ពុំគ្រាន់តែកំណត់ដោយរដ្ឋធម្មនុញ្ញនោះទេ គឺថែមទាំងកំណត់ដោយច្បាប់បោះឆ្នោតទៀតផង ។

ចំពោះអាណត្តិរបស់សភាជាន់ខ្ពស់ ជាធម្មតាវាមានរយៈពេលវែងជាងអាណត្តិរបស់សភាជាន់ទាប ។ នៅមានប្រទេសមួយចំនួនទៀត ក្នុងការបង្កើតសភាជាន់ខ្ពស់តាមរយៈការបោះឆ្នោតប្រព័ន្ធចំរុះ ។ លក្ខណៈនេះមាននៅប្រទេសប៊ែលស៊ិក[៦៥] គឺមួយចំណែកបោះឆ្នោតផ្ទាល់នៅក្នុងខេត្ត. មួយផ្នែកបោះឆ្នោតដោយក្រុមប្រឹក្សាតំណាងខេត្ត និងមួយចំណែកទៀតចាត់តាំងដោយសមាជិកព្រឹទ្ធសភាដែលបានជ្រើសរើស ។

**ឥ. ការរំលាយរដ្ឋសភា** (Dissolution of Parliament) : ការរំលាយរដ្ឋសភា (សំដៅយកសភាជាន់ទាប) គឺជាភារកិច្ចមួយដែលមានការប្រឈមមុខគ្នារវាងអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ។ ក្នុងករណីនេះដើម្បីដោះស្រាយឱ្យមានភាពប្រក្រតីឡើងវិញ គេអាចជ្រើសរើសសភាមុនអាណត្តិ ដែលពឹងផ្អែកទៅលើអ្នកបោះឆ្នោតទាំងអស់របស់ប្រទេស។ ការចាត់តាំងជ្រើសរើសរដ្ឋសភាថ្មីនេះ គឺជាផលដ៏ចាំបាច់មួយសំរាប់ដោះស្រាយទំនាស់ ។ ចំពោះការរំលាយរដ្ឋសភាតាមរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ បានកំណត់**មាត្រា ៧៨** ថា "នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទំលាក់ពីរដងក្នុងរយៈ១២ ខែ។

ក្នុងករណីនេះព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។

ក្នុងរយៈពេលនេះ រាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ ។

---

[៦៥]. Constitutional Law of Foreign Country.M-1994.Page 136 ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើររបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល" ។ ប៉ុន្តែនៅក្នុងមាត្រានេះយក**រដ្ឋាភិបាល**ធ្វើជាលេសថា "វៀរលែងតែក្នុងករណីរដ្ឋាភិបាលត្រូវបានទំលាក់ពីរដងក្នុងរយៈពេល ១២ ខែ" ។ រីឯមាត្រា ៩៨ ជាអ្នកកំណត់នូវការទំលាក់រដ្ឋាភិបាល ដូចក្នុងល័ក្ខខ័ណ្ឌនៃមាត្រា ៧៨ ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភាក្រោយពីបានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។ ផ្ទុយទៅវិញបើវិភាគទៅលើមាត្រា ៩៨ រដ្ឋសភាមានសិទ្ធិទំលាក់រដ្ឋាភិបាលតាមល័ក្ខខ័ណ្ឌយល់ព្រមពីនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា ដែលត្រូវធ្វើឡើងដោយព្រះមហាក្សត្រ បើតាមមាត្រា ៧៨ ប៉ុន្តែបើពិនិត្យលើលក្ខណៈតក្កវិជ្ជានៃច្បាប់វិញ បញ្ជាក់ថាទោះជាក្នុងកាលៈទេសៈណាក៏ដោយ ក៏ព្រះមហាក្សត្រពុំអាចរំលាយរដ្ឋសភាបានដែរ តាមមាត្រាទាំងពីរនោះ ។ លើសពីនេះទៀតទំនាស់ពុំអាចកើតមានឡើយរវាងអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ។

**ឃ. ប្រព័ន្ធសភាទ្វេភាព** (Bicameral System) : ដោយយោងទៅលើការអនុវត្តន៍ជាប្រវត្តិសាស្ត្រនៃរដ្ឋសភា ក្នុងបណ្តាប្រទេសមួយចំនួននៅលើលោកនេះ ឃើញថាវាមានភាពខុសគ្នាជាគន្លឹះពីរនៃប្រព័ន្ធទ្វេសភាដែលប្រទេសនីមួយៗមាន. គឺមានន័យថាក្នុងប្រទេសនីមួយៗដែលនិយម ឬមានសភាពីរ (Bicameral) នោះគេចាត់តាំងជាពីរក្រុម ឬប្រព័ន្ធពីរខុសគ្នាគឺ : **ប្រព័ន្ធសភាជាន់ខ្ពស់ខ្សោយ និងសភាជាន់ខ្ពស់ខ្លាំង** ។

**ឃ១.សភាជាន់ខ្ពស់ខ្សោយ** (Upper Chamber without power) : ក្នុងករណីនេះសភាជាន់ខ្ពស់របស់គេគ្មានអំណាច ឬក៏ថាមានអំណាចខ្សោយ ។ សភាជាន់ខ្ពស់ដែលមានអំណាចខ្សោយនេះគឺជាសកម្មភាពនៃការលើកពេល ឬលើកវារកាល (Postpone) នូវរាល់ការអនុម័តណាមួយទៅលើសេចក្តីសំរេចរបស់សភាជាន់ទាប ទោះព្រម ឬមិនព្រមក្តី ក៏ពុំមានលទ្ធភាពប្រឆាំងដែរ ។ ជាទូទៅការកើតមានជាលក្ខណៈក្នុងករណីនេះ គឺសំដៅចំបងបំផុតក្នុងដំណើរការនីតិកម្ម (Legislative Process) ឬក៏ក្នុងពង្រាងនីតិកម្មផ្សេងៗ (Legislative Draft) ។ ក្នុងលក្ខណៈនេះតាមវាក្យខ័ណ្ឌទី

មួយ មាត្រា ១ នៃច្បាប់ (Act) ស្តីពីរដ្ឋសភាឆ្នាំ ១៩១១.មាត្រា ១ នៃច្បាប់ (Act) ស្តីពីការផ្លាស់ប្តូរច្បាប់ (Act) ស្តីពីរដ្ឋសភាឆ្នាំ ១៩១១ របស់ប្រទេសអង់គ្លេសបានបញ្ជាក់ថា : សភាជាន់ខ្ពស់ (House of Lords) នៃរដ្ឋសភាអង់គ្លេសអាចបញ្ឈប់សកម្មភាពក្នុងការអនុម័ត នូវសេចក្តីព្រាងច្បាប់ទាំងឡាយដោយសភាជាន់ទាប (House of Commons) មិនលើសពីមួយឆ្នាំឡើយ តែបើពង្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ នោះរយៈពេលអនុម័តមិនឱ្យលើសពីមួយខែទេ ។ ប៉ុន្តែករណីខ្លះទៀតពង្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ ឬទាក់ទិននឹងថវិកាត្រូវឡាយព្រះហស្តលេខាពីព្រះរាជា ដោយពុំចាំបាច់យល់ព្រមពីសភាជាន់ខ្ពស់ឡើយ ឱ្យតែសភាជាន់ទាបបានអនុម័តរួច ។ ដូចនេះយើងឃើញថាសភាជាន់ខ្ពស់ត្រូវបានកំរិតដោយច្បាប់មួយយ៉ាងតឹងរ៉ឹងក្នុងល័ក្ខខ័ណ្ឌផ្សេងៗ ដែលសភាជាន់ទាប និងប្រមុខរដ្ឋកំណត់សកម្មភាពវាទៅវិញ ។ សូមបញ្ជាក់ថាប្រទេសអង់គ្លេសមុខងាររដ្ឋសភា (សភាទាំងពីរ) អនុម័តច្បាប់ដូចគ្នា. តំណាងរាស្ត្រ និងសមាជិករដ្ឋាភិបាលជាអ្នកផ្តួចផ្តើមធ្វើច្បាប់. រាល់ពង្រាងច្បាប់អាចបញ្ជូនទៅសភាទាំងពីរឱ្យពិភាក្សា ប៉ុន្តែជាទំលាប់ធម្មតាគេបញ្ជូនទៅពិភាក្សាក្នុងសភាជាន់ទាប (House of Commons) ជាមុនសិន បន្ទាប់មកបញ្ជូនទៅសភាជាន់ខ្ពស់ (House of Lords) ។ ពង្រាងច្បាប់មួយដែលអនុម័តយល់ព្រមដោយសភាជាន់ទាបត្រូវបញ្ជូន (To bring in a bill) ទៅសភាជាន់ខ្ពស់ ក្រៅពីប្រទេសអង់គ្លេសនៅមានប្រទេសប៉ូឡូញ ........... ។ល។ ក៏មានទំរង់នីតិកម្មប្រហាក់ប្រហែលគ្នាផងដែរ ។

**ឃ.សភាជាន់ខ្ពស់ខ្លាំង ឬមានអំណាច** (Powerful Upper Chamber) : វាគឺជាលក្ខណៈមួយដែលកើតមានទៅលើសភាជាន់ខ្ពស់ កាលណារាល់សេចក្តីសំរេចដែលធ្វើឡើងដោយរដ្ឋសភាដោយគ្មានការយល់ព្រមពីសភាជាន់ខ្ពស់នោះពុំអាចយកជាការបានទេ ។ ក្នុងលក្ខណៈនេះមានអត្ថន័យនៃវាក្យខ័ណ្ឌទីពីរ **មាត្រា** ១ នៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកឆ្នាំ ១៧៨៧ បានបញ្ជាក់ថា គ្មានពង្រាងច្បាប់ណាមួយ (Bill) ក្លាយជាច្បាប់ (Law) បានទេ ប្រសិនបើពង្រាងច្បាប់នោះមិនបានអនុម័តដោយសភាទាំងពីររបស់សហរដ្ឋ (Congress)[៦៦] ។ ជាងនេះទៅទៀត**មាត្រា ៧០** រដ្ឋធម្មនុញ្ញអ៊ីតាលីកំណត់យ៉ាងច្បាស់ថា "មុខងារនីតិបញ្ញត្តិត្រូវបំពេញរួមគ្នាដោយសភាទាំងពីររបស់រដ្ឋ" ។

---

[៦៦]. Congress គឺជាឈ្មោះរដ្ឋសភា (ព្រឹទ្ធសភា Senate និង សភាតំណាងរាស្ត្រ House of Representatives) នៃសហរដ្ឋអាមេរិក ។

ក្រៅពីប្រព័ន្ធទាំងពីរខាងលើយើងអាចជួបប្រទះដែរ នូវប្រព័ន្ធចំរុះនៃសភាជាន់ខ្ពស់ដែលវាពឹងផ្អែកលើព្រឹត្តិការណ៍ ឬករណីណាមួយដែលមានលក្ខណៈជាល្បាយ ។ គឺមានន័យថាវាត្រូវមានអន្តរាគមន៍ពីស្ថាប័នអំណាចណាមួយ ដូចជានៅប្រទេសបារាំងជាដើម ក្នុង **មាត្រា ៤៥** និង **មាត្រា ៤៦** នៃរដ្ឋធម្មនុញ្ញបានបញ្ជាក់នូវខ្លឹមសារជាល្បាយស្រាប់ទៅហើយថា : ពង្រាងច្បាប់មួយដែលឆ្លងកាត់សភាតំណាងរាស្ត្រ (National Assembly) និងព្រឹទ្ធសភា (Senate) ពុំអាចទទួលដល់ទីដៅចុងក្រោយបានទេ ( ត្រង់នេះបញ្ជាក់ថាព្រឹទ្ធសភាមានកំលាំង ឬមានអំណាចខ្លាំង) ប្រសិនបើរដ្ឋាភិបាលមិនចូលរួមតាមការទាមទារណាមួយ ដែលសេចក្តីសំរេចចុងក្រោយមួយនោះត្រូវអនុម័តដោយសភាជាន់ទាប (National Assembly) ( នៅឃ្លាចុងក្រោយនេះបញ្ជាក់ថា វាមិនទាក់ទងទៅនឹងពង្រាងនៃច្បាប់កំណត់ណាមួយទេ ដែលជាប់ទាក់ទិន ឬទាក់ទិនទៅនឹងព្រឹទ្ធសភា តែវាជាការយល់ព្រមរបស់ព្រឹទ្ធសភានៅក្នុងគ្រប់ករណី. ត្រង់ចំណុចនេះបញ្ជាក់ថាព្រឹទ្ធសភាមានអំណាចខ្សោយ) ។ ដូចគ្នានេះដែរ នៅសហព័ន្ធអាល្លឺម៉ង់ពង្រាងច្បាប់មួយដែលអនុម័តឡើងដោយសភាជាន់ទាប (Bundestag) ហើយភ្លាមនោះក៏បញ្ជូនទៅសភាជាន់ខ្ពស់ (Bundesrat) ។ ប្រសិនបើសភាជាន់ខ្ពស់នេះពុំយល់ព្រមនោះ សភាជាន់ខ្ពស់អំពាវនាវឱ្យមានគណៈកម្មការសំរបសំរួលមួយ ដែលមានសមាជិកមកពីសភាទាំងពីរ ។ ប្រសិនគណៈកម្មការនេះសំណូមពរឱ្យមានការផ្លាស់ប្តូរណាមួយ ទៅលើការអនុម័តពង្រាងច្បាប់នោះ គណៈកម្មការនេះបញ្ជូនពង្រាងច្បាប់នោះ ទៅឱ្យសភាជាន់ទាបធ្វើការពិនិត្យឡើងវិញជាលើកទីពីរ ( ត្រង់នេះបញ្ជាក់ថាសភាជាន់ខ្ពស់មានកំលាំងខ្លាំង) ។ នោះពង្រាងច្បាប់ដែលនេះត្រូវបានសភាជាន់ទាបអនុម័តជាលើកទីពីរ រីឯសភាជាន់ខ្ពស់អាចបដិសេធន៍បានក្នុងរយៈពេលមួយសប្តាហ៍ទៅលើពង្រាងច្បាប់នោះ ។ ពេលនោះពង្រាងច្បាប់ត្រូវបញ្ជូនមកសភាជាន់ទាបជាលើកទី ៣ តែប្រសិនបើសមាជិកភាគច្រើននៃសភាជាន់ទាបបោះឆ្នោតយល់ព្រមទៅលើវានោះ នោះពង្រាងច្បាប់ក្លាយជាច្បាប់ ( ត្រង់នេះបញ្ជាក់នូវភាពខ្សោយនៃសភាជាន់ខ្ពស់) ។

**៦. ការដឹកនាំសភា** (Leadership of Chamber):សភានីមួយៗនៃរដ្ឋសភា (Parliament) ជាធម្មតាដឹកនាំដោយប្រធាន (Chairman) (**មើលរូប ១២**) ។ បើរដ្ឋសភាមានតែមួយ ឬសភាទោល (Unicameral) នោះប្រធាននៃសភាទោលនោះមានឈ្មោះថាជាប្រធានរដ្ឋសភា (Leader of

Parliament)។ ប៉ុន្តែនៅពេលខ្លះប្រធានសភាមួយក្នុងចំណោមសភាទាំងពីរ (Bicameral System) ក្លាយជាប្រធានរដ្ឋសភារួមបានដែរ (សភាជាន់ទាប និងសភាជាន់ខ្ពស់) ជាឧទាហរណ៍ដូចជាវាក្យខ័ណ្ឌ **ទី ២ មាត្រា ១៤១** រដ្ឋធម្មនុញ្ញកូឡុមប៊ីកំណត់ថា : សំរាប់ពេលប្រជុំរួមគ្នានៃសភាទាំងពីរ (រដ្ឋសភា Congress), នោះប្រធានព្រឹទ្ធសភា និងប្រធានសភាតំណាងរាស្ត្រ (សភាជាន់ទាប) ក្លាយជាប្រធាន និងអនុប្រធាននៃរដ្ឋសភា (Cognress)។ នៅក្នុងបណ្តាប្រទេសប្រើប្រព័ន្ធគតិយុត្តិអង់គ្លោសាក់សុង (Anglo-Saxon family) ច្រើនហៅប្រធានសភាជាន់ទាប ឬប្រធានសភាតំណាងរាស្ត្រ ថាស្ពីគ័រ "Speaker" មានន័យថាជា "**អ្នកនិយាយ**" ។ ចំពោះប្រទេសកម្ពុជារាល់ការប្រជុំសភា ត្រូវដឹកនាំដោយប្រធាន ឬប្រធានស្តីទីជំនួសក្នុងករណីប្រធានអវត្តមាន តែបើសិនជាប្រធាន ឬអនុប្រធានលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្មរដ្ឋសភា ឬសភាតំណាងរាស្ត្រ (National Assembly) ត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។ ភារកិច្ចរបស់ប្រមុខរដ្ឋសភាយោងតាម**ប្រការទី ៨** នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាកម្ពុជា ២៨ តុលា ១៩៩៣ បានកំណត់ថា "ប្រធានរដ្ឋសភាមានមុខការដូចតទៅនេះ :

ក- ធានាការប្រព្រឹត្តិទៅនៃរដ្ឋសភាឱ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ

ខ- ដឹកនាំអង្គប្រជុំនៃរដ្ឋសភា

គ- បើក និងលើកពេលប្រជុំនៃរដ្ឋសភា

ឃ-ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំនៃរដ្ឋសភា

ង- ញ៉ាំងឱ្យប្រព្រឹត្តិតាមបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

ច- រក្សាការពារសណ្តាប់ធ្នាប់ក្នុងរដ្ឋសភា

ឆ- តំណាងរដ្ឋសភាក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ ប៉ុន្តែតាម**ប្រការទី ១៤** បានកំណត់ក្នុងការដឹកនាំរដ្ឋសភា ដោយមានលេខាធិការដ្ឋានដែលជាសេនាធិការផ្ទាល់របស់រដ្ឋសភាថា "រដ្ឋសភាមានអគ្គលេខាធិការដ្ឋានមួយ ទទួលបន្ទុកខាងការរៀបចំធ្វើកំណត់ហេតុរបស់រដ្ឋសភា និងរបស់គណៈកម្មការនានា ។

អគ្គលេខាធិការដ្ឋាននេះ ទទួលរ៉ាប់រងផងដែរនូវគ្រប់កិច្ចការរដ្ឋបាលរបស់រដ្ឋសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅរដ្ឋសភា"។ ចំពោះការប្រជុំដែលធ្វើឡើងដោយសភាទាំងពីរ ប្រទេសកម្ពុជាហៅថា "*សមាជរដ្ឋសភា និងព្រឹទ្ធសភា*" រីឯការដឹកនាំនៃការប្រជុំនោះពុំបានកំនត់នៅឡើយទេ គឺត្រូវបង្កើតច្បាប់ផ្សេងមួយទៀត ដូចមាត្រា ១១៦ និង ១១៧ នៃរដ្ឋធម្មនុញ្ញបានកំនត់ស្រាប់ ។

**ច. គណៈកម្មការនៃរដ្ឋសភា** (Commision of Parliament) : គណៈកម្មការនៃរដ្ឋសភាគឺជាអង្គការជំនួយគ្រឹះទាំងឡាយដែលកើតឡើងពីសមាជិកសភា និងធ្វើសកម្មភាព (បំរើការ) តាមសភា (Chamber) ក្នុងក្របខ័ណ្ឌនៃអំណាចរបស់ខ្លួន ។ ចំណាត់ថ្នាក់ទៅលើពាក្យថាគណៈកម្មការនេះមានច្រើនប្រភេទណាស់ក្នុងការបង្កើតវានោះ ដោយអាស្រ័យលើមូលដ្ឋានគ្រឹះផ្សេងៗគ្នា ។ ការប្រើពាក្យ "គណៈកម្មាការ" (Commission) ឬពាក្យ "គណៈកម្មាធិការ" (Committee) ពាក្យទាំងពីរនេះគេប្រើនៅក្នុងរដ្ឋសភា ដោយអាស្រ័យនឹងជាតិរបស់គេនីមួយៗ ពីព្រោះនៅក្នុងរដ្ឋសភារបស់គេអាចបង្កើត "គណៈកម្មាធិការ" ឬក៏ "គណៈកម្មការ" ។ ផ្ទុយទៅវិញពាក្យទាំងពីរនេះតាមន័យអក្សរសាស្ត្រពុំមានលក្ខណៈដូចគ្នាទេ គឺថាពាក្យ "គណៈកម្មាធិការ" គឺវាបង្កើតមកជាអចិន្ត្រៃយ៍ ហើយពុំអាចរលាយបានដោយឯកឯងនោះទេ តែពាក្យ "គណៈកម្មាការ" វាបង្កើតមកជាបណ្តោះអាសន្ន តែបន្ទាប់ពីបញ្ចប់ការងារណាមួយនោះវានឹងត្រូវរលាយដោយខ្លួនឯង ។

ដូចនេះនៅក្នុងរដ្ឋសភាគេច្រើនប្រើពាក្យគណៈកម្មការ ថ្វីត្បិតអត្ថន័យរបស់វាពុំតាមលក្ខណៈអក្សរសាស្ត្រក៏ដោយ តែវាជាទំលាប់របស់រដ្ឋសភានៃបណ្តាប្រទេសនីមួយៗ ។ គណៈកម្មការរដ្ឋសភាមានពីរប្រភេទ គឺគណៈកម្មការអចិន្ត្រៃយ៍ និងគណៈកម្មការបណ្តោះអាសន្ន ។

**ច₁. គណៈកម្មការអចិន្ត្រៃយ៍** (Permanent Commission) : គណៈកម្មការរបៀបនេះវាបង្កើតឡើងពេញមួយអាណត្តិរដ្ឋសភាទាំងមូល ឬក៏មានរហូតដល់អាណត្តិក្រោយទៀត ។ យោងតាម**ប្រការ ៧** នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាកម្ពុជាឆ្នាំ ១៩៩៣ បានកំណត់នូវសមាសភាពនៃគណៈកម្មាធិការអចិន្ត្រៃយ៍ថា "គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមាន :

- ប្រធានរដ្ឋសភា
- អនុប្រធានទាំងពីរនៃរដ្ឋសភា
- ប្រធានគណៈកម្មការនានានៃរដ្ឋសភា

ប្រធានរដ្ឋសភា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា មានអាណត្តិស្មើនឹងនីតិកាលរបស់រដ្ឋសភា"។ ប៉ុន្តែភារកិច្ចរបស់គណៈកម្មការនេះត្រូវបានកំណត់ក្នុង**ប្រការទី ៩** ថា "អនុប្រធានទាំងពីរជួយធ្វើការប្រធាន ។ កាលបើប្រធានអវត្តមាន ឬមកធ្វើការពុំបាន អនុប្រធានធ្វើការជំនួសប្រធាន"។ ដោយយោងតាមរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ក្នុង**មាត្រា ៨៣** ថា "រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗមានថេរៈវេលាយ៉ាងតិចបីខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិច គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។ ក្នុងករណីនេះ របៀបវារៈជាក់លាក់នៃសម័យប្រជុំជាវិសមញ្ញត្រូវផ្សាយដល់ប្រជារាស្ត្រជាមួយនឹងថ្ងៃកំណត់ប្រជុំ"។ និង**មាត្រា ៨៤** កំណត់ថា "នៅចន្លោះសម័យប្រជុំរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភារួមមាន : ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មការទាំងអស់របស់រដ្ឋសភា"។ គួរបញ្ជាក់ផងដែរថា ការបង្កើតគណៈកម្មការអចិន្ត្រៃយ៍នេះធ្វើឡើងតាមការកើតកម្មវត្ថុពិតប្រាកដដ៏សំខាន់ៗ ដូចជាផ្នែកហិរញ្ញវត្ថុ, កិច្ចការបរទេស, និងយោធា...........។ល។ ប៉ុន្តែការបង្កើតគណៈកម្មការអចិន្ត្រៃយ៍នេះ វាមានលក្ខណៈផ្សេងៗគ្នានៅតាមប្រទេសដែលនិយមសភាមួយ (Unicameral) ឬក៏និយមសភាពីរ (Bircameral) ដូចជាប្រទេសជប៉ុនសភាទាំងពីររបស់រដ្ឋសភា (Parliament) ត្រូវមានគណៈកម្មការអចិន្ត្រៃយ៍ ១៦ ក្នុងនោះគឺផ្នែកកិច្ចការគណៈរដ្ឋមន្ត្រី, កិច្ចការស្វ័យគ្រប់គ្រងមូលដ្ឋាន, ផ្នែកតតិយុត្តិ, ផ្នែកកិច្ចការអន្តរជាតិ, ផ្នែកហិរញ្ញវត្ថុ, ផ្នែកអប់រំ, ផ្នែកសង្គម និងការងារ, ផ្នែកកសិកម្ម, រុក្ខាប្រមាញ់ និងនេសាទសមុទ្រ, ផ្នែកពាណិជ្ជកម្ម និងឧស្សាហកម្ម, ផ្នែកសំណង់, ផ្នែកថវិកា, ផ្នែកត្រួតពិនិត្យ, ផ្នែកកិច្ចការនៃសកម្មភាពរដ្ឋសភា, និងគណៈកម្មការវិន័យ ។ ប៉ុន្តែនៅសភាជាន់ទាប (សភាតំណាងរាស្ត្រ) គេបានបង្កើតគណៈកម្មការពីរបន្ថែមទៀតគឺ : ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស, ផ្នែកបរិស្ថាន ។ ប៉ុន្តែរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា"។ រីឯគណៈកម្ម

ការនេះបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងប្រការ ៦ ថា "ក្រោមអធិបតីភាពនៃប្រធានរដ្ឋសភា រដ្ឋសភាដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកនៃគណៈកម្មការនានារបស់រដ្ឋសភា ។

គណៈកម្មការនានានៃរដ្ឋសភា :

១- គណៈកម្មការការពារសិទ្ធមនុស្ស និងទទួលពាក្យបណ្ដឹង

២- គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ

៣- គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិដ្ឋាន

៤- គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត

៥- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តជាតិ ឃោសនាការ និងពត៌មាន

៦- គណៈកម្មការនីតិកម្ម

៧- គណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍

៨- គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី

៩- គណៈកម្មការសាធារណៈការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពលរ៉ែ និងពាណិជ្ជកម្ម" ។

**ច**₂. **គណៈកម្មការបណ្ដោះអាសន្ន** (Provisional Commission) : វាជាគណៈកម្មការមួយដែលបង្កើតឡើងនៅពេលមានបញ្ហា ឬក្នុងករណីចាំបាច់បំផុតនៃការអះអាងឱ្យបានកាន់តែច្បាស់ទៅលើបញ្ហាដែលនាំឱ្យរាំងស្ទះចំពោះសកម្មភាពការងារនៃព្រឹត្តិការណ៍ណាមួយ ។

ក្នុងគណៈកម្មការបណ្ដោះអាសន្ននេះមានសភាជាលក្ខណៈស៊ើបអង្កេត (Committee of inquiry) និងផ្នែកជំនាញ (ដូចជាការបង្កើតគណៈកម្មការបណ្ដោះអាសន្នមួយ សំរាប់សិក្សាទៅលើបញ្ហារបស់បុគ្គលណាមួយ ឬក៏ទៅលើការកែឆ្នៃសេចក្ដីព្រាងច្បាប់) ។ សូមបញ្ជាក់ផងដែរថា គោលដៅរបស់គណៈកម្មការបណ្ដោះអាសន្នពុំមែនដោះស្រាយបញ្ហានេះទេ តែគ្រាន់ជាអ្នកពិភាក្សាស្វែងរកការពិតលើបញ្ហានោះតែប៉ុណ្ណោះ ហើយបន្ទាប់ពីយល់ឃើញមានលក្ខណៈយ៉ាងណានោះទើបគណៈកម្មការបញ្ជូនទៅរដ្ឋសភា ឬទៅអង្គការឯករាជ្យណាមួយជាអ្នកសំរេច (មានដូចជាប្រទេសអាល្លឺម៉ង់. ចក្រភពអង់គ្លេស ......។ល។) ។

## ២. ឋានៈនៃសមាជិករដ្ឋសភា (Status of Parliamentary)

**ក. ធម្មជាតិឥតិយុត្តិនៃអាណត្តិ :** គួរបញ្ជាក់ដែរថា ពាក្យអាណត្តិយើងបានដឹងតាមរយៈអត្ថបទពីមុនខ្លះៗមកហើយ គឺវាផ្តល់នូវសិទ្ធិ និងសេចក្តីទុកចិត្ត ។ ដោយឡែកពាក្យថាសមាជិករដ្ឋសភា (Parliamentary) ពុំមានន័យដូចគ្នាទេ វាជាបុគ្គលទាំងឡាយណាដែលបង្កើតឡើងតាមលក្ខណៈគ្រឹះណាមួយនោះ ដើម្បីក្លាយជាសមាជិករដ្ឋសភា ។ ពាក្យសមាជិករដ្ឋសភានេះគេប្រើប្រាស់តាមប្រទេស នីមួយៗពុំមានឈ្មោះដូចគ្នាទេ ដូចជានៅអង់គ្លេសហៅថា "MP's : Members of Parliament" គឺគេសំដៅតែសភាជាន់ទាប ឬសភាតំណាងរាស្ត្រ ។ រីឯនៅសហរដ្ឋអាមេរិកគេប្រើពាក្យ "Congressmant" ដែលសំដៅតែសភាតំណាងរាស្ត្រ តែសមាជិកសភាជាន់ខ្ពស់គេហៅថា Senators ។

សមាជិកសភាទទួលកាន់កាប់នូវសិទ្ធិពិសេសដែលចាប់កើតមានបន្ទាប់ពីបានជាប់ឆ្នោត ឬក៏កើតមានតាមកាលបរិច្ឆេទដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញ ឬក៏ច្បាប់បោះឆ្នោត ។ ការទទួលបាននូវសិទ្ធិពិសេសនេះហើយដែលជាមូលដ្ឋានគ្រឹះក្នុងការកំនត់ឋានៈរបស់សមាជិករដ្ឋសភា ។

ភារកិច្ចរបស់សមាជិករដ្ឋសភា គឺចូលរួមនៅក្នុងនីតិកម្ម និងបំពេញភារកិច្ចជារដ្ឋសភានូវមុខងារដទៃផ្សេងៗទៀត ។ តើមុខងារទាំងនោះជាអ្វី ? តើអ្នកណាជាអ្នកតំណាងរាស្ត្រ ? តើតំណាងរាស្ត្រមានសិទ្ធិអំណាចតែក្នុងមណ្ឌលបោះឆ្នោតរបស់ខ្លួន ឬក៏ជាអ្នកតំណាងជាតិទាំងមូល ? ចំលើយទៅលើបញ្ហាទាំងនេះ គឺទាក់ទិនទៅនឹងអាណត្តិ (Mandate) របស់រដ្ឋសភា ។

លោក**ហ្សាន់ ហ្សាក់-រូស្សូ** បានកំណត់ថា**អធិបតេយ្យភាព** (Sovereignity) **មិនត្រូវបែងចែក ហើយក៏មិនអាចត្រូវបានតំណាងឱ្យដែរ** : គឺថាអំណាចអាចផ្តល់ឱ្យបាន ប៉ុន្តែមិនអាចផ្តល់ឆន្ទៈរួម ឬអធិបតេយ្យភាព (Sovereignity) បានទេ ។ គាត់បានកំណត់[៦៧] ធ្វើការសន្និដ្ឋានថា "តំណាងរាស្ត្រទាំងអស់មិនមែនជាអ្នកតំណាងអធិបតេយ្យភាពទេ ហើយក៏មិនអាចជាអ្នកតំណាងរបស់រាស្ត្រដែរ តែជាអ្នកតំណាងសិទ្ធិអំណាចតែប៉ុណ្ណោះ (Plenipotentiary)" ។ ដូចនេះប្រជាជន

---

[៦៧]. Treatise(អភិប្រាយ)M-Science 1969.Page 222 ។

ផ្ទេរអំណាច (To delegate Power) ទៅឱ្យតំណាងរាស្ត្រ ក្នុងករណីបែបនេះត្រូវសន្មត់ជាមុនថាពួកគេ (តំណាងរាស្ត្រ) ធ្វើសកម្មភាពស្របនឹងឆន្ទៈទូទៅរបស់រាស្ត្រ កាលដែលពួកគេបានអនុម័តច្បាប់ទាំងឡាយរួចហើយ ។

ដោយយោងតាមខ្លឹមសារខាងលើ វាលេចចេញនូវ**ឋានៈគតិយុត្តិ**ដ៏សំខាន់របស់តំណាងរាស្ត្រ ដែលមានគោលការណ៍មួយចំនួនដូចខាងក្រោម :

**ក. គោលការណ៍នៃអាណត្តិអាជ្ញាបញ្ជា** (Imperative Mandate) : គឺជាគោលការណ៍មួយដែលសិទ្ធិរបស់អ្នកបោះឆ្នោតធ្វើការសំណូមពរទៅតំណាងរាស្ត្រ នូវភារកិច្ចចាំបាច់ជាច្រើនសំរាប់បញ្ហារបស់ពួកគេ (ប្រជាជន) និងធ្វើការកោះហៅ ឬដកចេញ (To take aside) ជាបន្ទាន់ចំពោះអ្នកជាប់ឆ្នោត (Chosen one) ប្រសិនបើពួកនោះ (តំណាងរាស្ត្រ) មិនបានអនុវត្តតាមបញ្ហារបស់ពួកគេ (ប្រជាជន) ឬក៏អនុវត្តពុំបានល្អ ដែលអ្នកជាប់ឆ្នោតទាំងនោះបានសន្យានៅតាមមណ្ឌលនីមួយៗ។ គួរបញ្ជាក់ផងដែរថា គោលការណ៍នេះជាបទពិសោធន៍របស់សហគមប៉ារីស (Parisian Commune) នាឆ្នាំ ១៨៧១ ហើយបានទទួលអនុវត្តក្នុងបណ្តារដ្ឋធម្មនុញ្ញប្រទេសសង្គមនិយម។ តាមគោលការណ៍នេះ ប្រជាជនអាចមានសិទ្ធិបណ្តេញនូវតំណាងរាស្ត្រក្នុងមណ្ឌលរបស់ខ្លួនចេញបាន ដោយពុំចាំបាច់ដល់អាណត្តិថ្មីឡើយ ។ ប៉ុន្តែតំណាងរាស្ត្រពុំអាចសំរេចតាមតែចិត្ត ឬបំណងរបស់អ្នកបោះឆ្នោតបានឡើយ ទោះជាមានការសន្យាក៏ដោយ ព្រោះបើសិនជាតំណាងរាស្ត្រប្រកាន់យកតែការសន្យារបស់ខ្លួនចំពោះអ្នកបោះឆ្នោតក្នុងមណ្ឌលណាមួយនោះ នោះការសំរេចនៅក្នុងរដ្ឋសភាពុំអាចតំណាងរាស្ត្រឈានទៅរកការមូលមតិគ្នាបានឡើយ (Compromise) ។ ប៉ុន្តែការបកស្រាយបែបនេះប្រហែលជាអ្នកអានមានការសង្ស័យហើយថា តំណាងរាស្ត្រពុំបានសំដែងនូវឆន្ទៈរបស់អ្នកបោះឆ្នោត ឬក៏ពុំគោរពនូវការសន្យារបស់ខ្លួនត្រូវតែចុះចេញ ឬដកចេញមុនអាណត្តិ ពីព្រោះគាត់មិនគោរពនូវផលប្រយោជន៍ជាតិ ។ គួរបញ្ជាក់ថាអាណត្តិអាជ្ញាបញ្ជានេះ ពុំមែនអាស្រ័យនឹងប្រព័ន្ធចក្ខុវិស័យ (Power of sight អ្វីៗដែលយល់ឃើញ) នៃសង្គមទេ ប៉ុន្តែវាកើតចេញពីសញ្ញាខន្ធ (Perception ការយល់ដឹងតាមរយៈវិញ្ញាណទាំងឡាយ) នៃសង្គម គឺថាវា (អាណត្តិអាជ្ញាបញ្ជា) គ្រាន់តែចំនួនតូច ឬផ្នែកដ៏តូចមួយតែប៉ុណ្ណោះ ពុំមែនជាទូទៅ ឬក៏គុណភាពពិសេស ឬផលប្រយោជន៍ទាំងឡាយនោះទេ ។

ដោយសារតែវាមានផលប្រយោជន៍តិចតួចនេះហើយ ទើបក្នុងលទ្ធិប្រជាធិបតេយ្យចាត់ទុកអាណត្តិអាជ្ញាបញ្ជាជាមោឃៈ ។

**ក២. គោលការណ៍នៃអាណត្តិសេរី** (Free mandate) : គឺជាគោលការណ៍មួយ ដែលក្នុងនោះអាណត្តិអាជ្ញាបញ្ជាត្រូវបានដកចោល ។ ត្រង់ចំនុចនេះមានន័យថា បើសិនជាគេដកចេញនូវអាណត្តិអាជ្ញាបញ្ជាចេញនោះ តំណាងរាស្ត្រនឹងមានសិទ្ធិសេរីភាពទាក់ទិននឹងពលរដ្ឋដែលមានឈ្មោះថាអាណត្តិសេរី ។

យោងតាមរដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យនោះ គឺថារដ្ឋសភា និងសមាជិករបស់វាទាំងអស់ជាអ្នកតំណាងនៃជាតិទាំងមូល ហើយក៏គ្មានអ្នកណាម្នាក់ដែលផ្តល់ការសន្យាចំពោះគាត់នូវអាជ្ញាបញ្ជាដែរ ។ ពួកគេ (តំណាងរាស្ត្រ) មានបណ្តាញតែមួយគត់ គឺជាមួយនឹងរដ្ឋធម្មនុញ្ញ និងមនសិការរបស់ខ្លួនដែលត្រូវតែសន្មត់ជាមុននៅក្នុងល័ក្ខខ័ណ្ឌកិរិតណាមួយ ហើយធ្វើការដោះស្រាយដោយឈរលើគោលការណ៍នេះ ក្នុង**មាត្រា ៧៧** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "តំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ" ។

ប៉ុន្តែខ្លឹមសារនៃអាណត្តិរដ្ឋសភាបានត្រូវកំណត់តាមវិសមិតភាព (Incompatibility) ផងដែរ គឺថាវាផ្សារភ្ជាប់នឹង**មុខងារកិរិតណាមួយ** និង**ការកាន់តំណែង**ជាឧទាហរណ៍ថា : មនុស្សម្នាក់មិនអាចជាសមាជិកនៃសភាទាំងពីរបានទេក្នុងរយៈពេលតែមួយ ឬក៏ក្នុងមុខងារពីរបានទេ ។ ដូច **មាត្រា ៧៩** រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "អាណត្តិនៃសមាជិករដ្ឋសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនោះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា" ។

**ខ. ការបញ្ចុះបញ្ចូលនៃសមាជិករដ្ឋសភា** (Lobby of Parliamentary) : នៅក្នុងអាណត្តិសេរីត្រូវបានអ្នកតំណាងរាស្ត្រធ្វើការសំរេចតាមមនសិការខ្លួនមែន ប៉ុន្តែត្រូវគិតពីបេក្ខភាពរបស់ខ្លួនដែលចេញមកពីគណៈបក្សរបស់គេផងដែរ ។ ជួនកាលបំណងរបស់ខ្លួនត្រូវគាំទ្រ តែវាខុសនឹងគោលការណ៍គណៈបក្ស ឬវាមិនបានបំពេញតាមកាតព្វកិច្ចគណៈបក្ស ។ ទាំងអស់នោះធ្វើឱ្យការសំរេចនៅរដ្ឋសភាពុំបានទទួលជោគជ័យ ដែលធ្វើឱ្យស្ទះដំណើរការប្រព្រឹត្តិទៅរបស់រដ្ឋសភា។ ដើម្បីដោះស្រាយនូវភាពទ័លច្រកនេះគេត្រូវបង្កើតបក្សប្រភាគ (Party Fraction)[៦៨] តូចៗទៀតនៅក្នុងរដ្ឋសភាដើម្បីធ្វើការដោះស្រាយបញ្ហា ប៉ុន្តែបើតំណាងរាស្ត្រមិនប្រកាន់គោលការណ៍បក្សទេ. នោះបញ្ហា Party Fraction មិនចាំបាច់បង្កើតទេ ។ ការកើតមាននូវគណៈបក្សប្រភាគនេះ វាជាក្រុមមួយដែលគ្របសង្កត់ទៅលើក្រុមមួយទៀត ឬក៏ហៅថាជាសកម្មភាពនៃសមាជិករដ្ឋសភាមិនព្រមចុះសំរុងនឹងគ្នា ដើម្បីសំរេចលើអ្វីមួយ. តែដើម្បីសំរេចបានគេត្រូវបង្កើតវាតាមឧទាហរណ៍ដូចតទៅ : នៅក្នុងសភាមួយមានតំណាងរាស្ត្រ ១០០ នាក់ ដែលចែកជាពីរក្រុមក្នុងនោះក្រុមប្រភាគ Fraction A មាន ៦០ នាក់ និង Fraction B មាន ៤០ នាក់ ពិភាក្សាលើពង្រាងច្បាប់មួយ ។ ការពិភាក្សាពុំធ្វើនៅក្នុងសាលរួមទេ គឺការប្រជុំរបស់ A មាន ៣២ នាក់គាំទ្រ និង ២៨ នាក់ ប្រឆាំងនឹងពង្រាងច្បាប់ ។ ការប្រជុំរបស់ B មាន ១០ នាក់គាំទ្រ និង ៣០ នាក់ប្រឆាំង ។ លទ្ធផលនៃការប្រជុំ Fraction ទាំងពីរចាត់ទុកជាបានការ គឺពង្រាងច្បាប់នោះក្លាយទៅជាច្បាប់ ព្រោះ Fraction A ដែលមានសមាជិកច្រើនបានអនុម័តយល់ព្រម ៣២ នាក់គាំទ្រ ឯ Fraction B មានសមាជិកតិចពុំបានអនុម័តទេ ដោយមានអ្នកប្រឆាំងដល់ទៅ ៣០ នាក់ ។ ទោះបីសរុបចូលគ្នាអ្នកប្រឆាំងកើនដល់ ៥៨ នាក់ក៏ដោយ តែនីតិវិធីនៃការអនុម័តតាម Fraction គឺត្រូវ Fraction ដែលមានសមាជិកតិចគោរពតាម Fraction មានសមាជិកច្រើន ។ ប៉ុន្តែការបង្កើត Fraction នេះនៅក្នុងប្រទេសជាច្រើនពុំសូវមានលក្ខណៈជាទំរង់ច្បាស់

---

[៦៨]. បក្សប្រភាគនេះបង្កើតឡើងនៅក្នុងបរិវេណនៃរដ្ឋសភាតែប៉ុណ្ណោះ ហើយក្រោយពីពិភាក្សា និងបោះឆ្នោតចប់វាត្រូវរលាយដោយស្វ័យប្រវត្តិ ។

. នីតិវិធីនៃការបង្កើតវាត្រូវបក្សមួយមានសមាជិកច្រើនជាងបក្សមួយទៀត ។ ការចុះឈ្មោះធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយគ្រាន់តែប្រាប់ចំនួនសមាជិកបក្សនីមួយៗតែប៉ុណ្ណោះ ។

លាស់ដែលកំណត់ដោយច្បាប់ទេ ព្រោះអំពើនោះវាមានសម្ពាធខ្លាំងទៅតំណាងរាស្ត្រ ឬក៏អាចធ្វើការបណ្តេញតំណាងរាស្ត្រចោលទៀតផង។ សកម្មភាពនេះដូចជាការធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញលើកទី ៥២ របស់ប្រទេសឥណ្ឌាឆ្នាំ ១៩៨៥[៦៩] គឺពេលនោះធ្វើឱ្យមានការប្តូរផ្លាស់តំណាងរាស្ត្រមួយចំនួនក្នុងគណៈបក្ស ដែលមានការគំរាមកំហែងនូវការបាត់បង់អាណត្តិរបស់តំណាងរាស្ត្រ ។

ផ្ទុយទៅវិញបាតុភូតដែលកើតមាននូវលក្ខណៈរបបេបនេះគេឱ្យឈ្មោះថា "**ការរបៀង**"ដែលចេញពីភាសាអង់គ្លេសថា "Lobby" ដូចនេះ "Lobby" ឬការរបៀងនេះ **គឺជាក្រុមបុគ្គលដែលខិតខំធ្វើសកម្មភាពទៅលើសមាជិកទាំងឡាយនៃអង្គការនីតិបញ្ញត្តិ ជាមួយគ្នានោះដើម្បីជំរុញឱ្យអ្នកទាំងនោះទទួលនូវការគាំទ្រតាមការចង់បានណាមួយ ។ ការប្រជុំនៃ "Lobby" ពុំធ្វើនៅក្នុងសាលប្រជុំរដ្ឋសភាទេ តែធ្វើនៅដោយឡែកពីគ្នាក្នុងពេលតែមួយ ។**

ចំពោះអ្នកធ្វើការរបៀង "Lobbyist" គឺជាពួកទីភ្នាក់ងារទាំងឡាយនៃក្រុមហ៊ុន, ធនាគារ, សហគ្រាស, សហជីព និយោជិក.................. ។ល។ ដែលពួកអ្នកទាំងនោះធ្វើការភ្ជាប់ទំនាក់ទំនងគ្រប់មធ្យោបាយជាមួយនឹងសមាជិករដ្ឋសភា ដើម្បីឱ្យមានឥទ្ធិពលលើជំហរផ្សេងៗក្នុងការសំរេចលើបញ្ហាពិតប្រាកដណាមួយនៅក្នុងរដ្ឋសភា ។ ប៉ុន្តែក្នុងការកំរិតទៅលើអ្នកមានសិទ្ធិនៃការធ្វើរបៀង "Lobbyist" ត្រូវបានកំណត់ដោយច្បាប់ស្តីពី Lobby ដូចជានៅឆ្នាំ ១៩៤៦ រដ្ឋសភាអាមេរិក Congress បានអនុម័តច្បាប់ ស្តីពីការធ្វើនិយ័តកម្មនៃការរបៀងនេះ ។

**ឥ. សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិករដ្ឋសភា** (Right and Obligation of parliamentary): សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិករដ្ឋសភាជាទូទៅត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ។ ដូចជា**មាត្រា ៩៦** នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់នូវសិទ្ធិរបស់តំណាងរាស្ត្រថា "តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះត្រូវសរសេរជាលាយល័ក្ខអក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។

[៦៩]. Besis of Constitutional Law of India.M-1986.Page 32 ។

ចំលើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។

ចំលើយរបស់រដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រីអាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយល័ក្ខអក្សរ ។

ចំលើយខាងលើនេះត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ ។

ចំពោះចំលើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសំរេចបើកឱ្យមាន ឬមិនឱ្យមានការជជែកដេញដោល ។ បើគ្មានការបើកឱ្យជជែកដេញដោលទេ នោះចំលើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង ។

បើមានការបើកឱ្យជជែកដេញដោលម្ចាស់សំណួរវាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃ ក្នុងមួយសប្តាហ៍សំរាប់ការឆ្លើយសំណួរ ។

ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសំរាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ......" ។ ចំពោះកាតព្វកិច្ចត្រូវបានកំណត់នៅក្នុងមាត្រាជាច្រើន ជាពិសេសមាត្រាទី ៩០ នៃរដ្ឋធម្មនុញ្ញដដែលនោះ ។

**ឃ. អភ័យឯកសិទ្ធិនៃរដ្ឋសភា** (Immunity of Parliament) : អភ័យឯកសិទ្ធិនៃរដ្ឋសភាគឺជាការធានានូវឋានៈមួយដ៏សំខាន់របស់រដ្ឋសភា ទៅលើអភ័យឯកសិទ្ធិនៃសមាជិករដ្ឋសភា ។ ជាទូទៅអភ័យឯកសិទ្ធិនៃសមាជិករដ្ឋសភា ត្រូវបានធានារួចពីការចោទប្រកាន់ដោយបទព្រហ្មទណ្ឌ ពីខាងភាគីអំណាចនីតិប្រតិបត្តិក្រោមលេសកុហកផ្សេងៗ ។ ប៉ុន្តែគេអាចចាប់តំណាងរាស្ត្រ ឬសមាជិករដ្ឋសភាបានដោយមានការអនុញ្ញាតិពីរដ្ឋសភា ឬក៏ក្នុងករណីប្រព្រឹត្តិបទល្មើសជាក់ស្តែង ។

ជាទូទៅអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភានៅប្រទេសផ្សេងៗ ពុំមានលក្ខណៈដូចគ្នាទេ គឺថាអាស្រ័យនឹងប្រពៃណីជាតិរបស់គេ (ច្បាប់នៃប្រទេសនីមួយៗ) ។ តាម**មាត្រា ៨០** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្រូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់សភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទ័ណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខដើម្បីអនុម័តតាមមតិភាគច្រើន ពីភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាកប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើន បីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល"។ គួរបញ្ជាក់ថា ពាក្យអភ័យឯសិទ្ធិប្រើតែសំរាប់ទៅលើបញ្ហាព្រហ្មទណ្ឌ ឬល្មើសព្រហ្មទណ្ឌចំពោះបុគ្គលដែលច្បាប់បានកំណត់ប៉ុណ្ណោះ ។ រីឯមាត្រា ១០៤ នៃច្បាប់ដដែលនេះបានកំណត់អំពីអភ័យឯកសិទ្ធិនៃសមាជិកព្រឹទ្ធសភា ។

**ង. បំណាច់នៃរដ្ឋសភា** (Indemnity of Parliament) : ពាក្យថា "**បំណាច់នៃរដ្ឋសភា**" (Indemnity of Parliament) នេះមានពីអត្ថន័យគឺ :

**ង១. ន័យទីមួយ :** បំណាច់នៃរដ្ឋសភាមានន័យ[៧០] ថាជាភាពរួចពីការចោទប្រកាន់ ឬទទួលខុសត្រូវផ្សេងៗចំពោះការសំដែងមតិ និងអំពើផ្សេងទៀត ក្រោមរូបភាពក្នុងការបំពេញកិច្ចនៃអាណត្តិ (Mandate) របស់បុគ្គលណាមួយក្រោយពេលដែលខ្លួនអស់អាណត្តិ ។ នៅក្នុងរដ្ឋសភាមួយ ឬក្នុងគណៈកម្មការ ឬក៏ក្នុងករណីជាច្រើនទៀត ការសំដែងមតិនៅក្នុងស្ថានភាពទាំងនោះវាចារឹកនូវ

---

[៧០]. ជូនកាល Indemnity គេហៅថាអភ័យឯកសិទ្ធិផងដែរ គ្រាន់តែល័ក្ខខ័ណ្ឌខុសគ្នាពី Immunity ត្រង់ថា Immunity មាននៅក្នុងអាណត្តិមុខងារ រីឯ Indemnity មានក្រោយពេលអស់អាណត្តិទៅលើសកម្មភាពដែលបានកើតនៅក្នុងអាណត្តិ ។

លក្ខណៈសាធារណៈ ។ វាដូចគ្នាដែរ ការសំដែងចំពោះខ្លឹមសារដែលចារឹកដោយពង្រាងច្បាប់ និង សេចក្ដីសំរេចផ្សេង១, ការសំដែងចំពោះការបោះឆ្នោត, សំនួរ និងវិសោធនកម្មផ្សេង១ ។ល។ ន័យទី មួយនេះ គឺសំដៅទៅលើសមាជិករដ្ឋសភា ដែលរួចខ្លួនពីភាពទទួលខុសត្រូវនូវរាល់អំពើផ្សេង១ក្រៅ ពីបញ្ហាព្រហ្មទណ្ឌជាក់ស្ដែងក្នុងក្របខ័ណ្ឌមុខងាររបស់គេ តែកុំច្រឡំទៅនឹងអភ័យឯកសិទ្ធិ ព្រោះ ពាក្យអភ័យឯកសិទ្ធិនេះវាទាក់ទិននឹងបញ្ហាព្រហ្មទណ្ឌនៅក្នុងអាណត្តិតែប៉ុណ្ណោះ ពុំមែនដូចបំណាច់ នេះទេ **វាការពារបុគ្គលដែលផុតអាណត្តិចំពោះអំពើក្នុងអាណត្តិនោះទេ** ។ ដូច**មាត្រា ៨០** វាក្យខ័ណ្ឌទីពីរ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់អំពីបំណាច់រដ្ឋសភាថា "តំណាងរាស្ត្របណាក៏ ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញ មតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ" ។ ប៉ុន្តែនៅប្រទេសខ្លះអាចរួចខ្លួនពីការទទួលខុសត្រូវ នេះ បន្ទាប់ពីបញ្ចប់អាណត្តិសភាទៀតផង ដោយគេសំដៅយកគោលការណ៍ឯកភាពជាតិដំបូងរបស់ ប្រទេស ដូចជាបទបញ្ជាផ្ទៃក្នុងឆ្នាំ ១៩៨២[៧១] របស់ព្រឹទ្ធសភាអេស្ប៉ាញកំនត់ថា "សមាជិកព្រឹទ្ធសភា ទាំងអស់នឹងប្រើប្រាស់អភ័យឯកសិទ្ធិបន្ទាប់ពីបញ្ចប់អាណត្តិរបស់ខ្លួន ចំពោះការបញ្ចេញមតិដែលបាន ចារិកក្នុងឯកសារទាំងឡាយរបស់រដ្ឋសភា និងការបោះឆ្នោត ក្រោមរូបភាពនៃការបំពេញកិច្ចរបស់ មុខងារខ្លួន"។ ត្រង់នេះបញ្ជាក់ថាទោះជាខ្លួនបញ្ចប់អាណត្តិហើយក៏ដោយ ក៏រាល់សកម្មភាពដែលគេ បានធ្វើនោះនៅតែជាធរមាន និងមិនអាចប៉ះពាល់បានដែរ ប៉ុន្តែសកម្មភាពដែលបានធ្វើនោះពុំមែន ស្ថិតក្នុងកិច្ចការក្រៅផ្លូវការនោះឡើយ ។

**ង₂.ន័យទីពីរ** : ន័យទីពីរនេះវាគឺជាការឱ្យរង្វាន់ (Reward) ដល់សមាជិករដ្ឋសភា ។ រង្វាន់ នេះត្រូវបានកំណត់តំលៃច្រើនប្រភេទណាស់ ។ តាមខ្លឹមសារនេះក្នុង**មាត្រា** ១ ផ្នែកទី ៦ រដ្ឋធម្មនុញ្ញ សហរដ្ឋអាមេរិកបានកំណត់ថា "សមាជិកព្រឹទ្ធសភា និងតំណាងរាស្ត្រទាំងអស់នឹងទទួលបានប្រាក់ ឧបត្ថម្ភដោយសារការបំរើរបស់គេ ដែលត្រូវបានកំណត់ដោយច្បាប់ និងការកំរិតតំលៃដោយរតនា

---

[៧១]. Constitutional Law of Foreign Country, Part II,M1994,Page 161 ។

គារ (Treasury) នៃសហរដ្ឋ"។ សូមបញ្ជាក់ដែរថា រង្វាន់តំណាងរាស្ត្រត្រូវបានកំណត់នៅប្រទេសបារាំងឆ្នាំ ១៨៤៨ និងនៅចក្រភពអង់គ្លេសឆ្នាំ ១៩១១ ។ ដោយឡែក**មាត្រា ៨១** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ក្នុងវាក្យខណ្ឌទីពីរថា "តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់"។ តាមមាត្រានេះ វាគ្រាន់តែចារិកនូវសិទ្ធិរបស់តំណាងរាស្ត្រក្នុងការទទួលប្រាក់បំណាច់តែប៉ុណ្ណោះ ប៉ុន្តែតំលៃនៃប្រាក់បំណាច់នោះពុំបានកំណត់ច្បាស់លាស់ទេ ។ ជាការឱ្យរង្វាន់ផងដែរតាមផ្នែកស្មារតី ដូចជានៅប្រទេសអ៊ីតាលី រដ្ឋធម្មនុញ្ញបានកំនត់ថា រាល់អតីតៈប្រធានាធិបតីសាធារណៈរដ្ឋអ៊ីតាលី ក្លាយជាសមាជិកព្រឹទ្ធសភាដោយស្វ័យប្រវត្តិ បើសិនជាគាត់ចង់បាន។ ដូចនេះបើទោះជាវាមានអត្ថន័យក្នុងការឱ្យរង្វាន់ក្តី ក៏ត្រូវមានច្បាប់កំណត់ឱ្យបានច្បាស់លាស់ទៅលើកំរិតនៃរង្វាន់នោះដែរ ដើម្បីការពារកុំឱ្យកើតមាននូវអតុល្យភាពនៃប្រាក់ចំណូល ឬស្មារតីរបស់ពលរដ្ឋនៅក្នុងសង្គមទាំងមូល ។

## ៣. សណ្តាប់ធ្នាប់នៃការងាររដ្ឋសភា (សម័យប្រជុំ និងនីតិវិធីនៃការងាររបស់រដ្ឋសភា).

សណ្តាប់ធ្នាប់នៃការងាររដ្ឋសភា គឺជាទំរង់ការមួយដែលសំរាប់ឱ្យរដ្ឋសភាដំណើរការទៅបានតាមលក្ខណៈមួយដ៏ប្រសើរ ។ សណ្តាប់ធ្នាប់ទាំងនោះមានលក្ខណៈច្រើនប្រភេទគឺ :

**ក. សម័យប្រជុំនៃរដ្ឋសភា** (Session of parliament) : សម័យប្រជុំគឺជាកំឡុងពេល (Period of time) ក្នុងថេរៈវេលាមួយ ដែលរដ្ឋសភាអាចរៀបចំប្រព្រឹត្តិទៅនូវសម័យប្រជុំពេញអង្គនានា (Plenary Session) និងអនុម័តសេចក្តីសំរេចរបស់ខ្លួនបាន ។

សម័យប្រជុំច្រើនប្រព្រឹត្តិទៅតាមលក្ខណៈពីរប្រភេទ គឺ**សាមញ្ញ** និង**វិសាមញ្ញ** ។ ការប្រជុំជាសាមញ្ញ គឺធ្វើឡើងតាមការកំណត់របស់ច្បាប់ ដូចជា**មាត្រា ៨៣** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ក្នុងវាក្យខណ្ឌទី ១ និងទី ២ ថា "រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។ សម័យប្រជុំនីមួយៗមានថេរៈវេលាយ៉ាងតិច ៣ ខែ"។ រីឯការប្រជុំជាវិសាមញ្ញ គឺជាការប្រជុំដែលធ្វើឡើងនៅក្រៅរង្វង់នៃការកំរិតដោយច្បាប់ តាមកាលបរិច្ឆេទច្បាស់លាស់ ។ ការប្រជុំរបៀបនេះធ្វើឡើងក្នុងល័ក្ខខ័ណ្ឌដែលចាំបាច់ ដូចជាការកោះហៅរបស់ប្រមុខរដ្ឋ, ប្រមុខរដ្ឋាភិបាល, ប្រមុខរដ្ឋសភា ឬក៏ក្នុងករណីប្រទេសមានភាពអាសន្ន ដូចជា**មាត្រា ៨៦** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ក្នុង

វាក្យខ័ណ្ឌ ១ ថា "ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពមានអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប្រចាំ" ។ រីឯនៅកថាខ័ណ្ឌទីពីរនៃ**មាត្រា ៨៣** បានកំណត់ថា "...... បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិច គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ" ។

**ខ. នីតិវិធី ឬកំមរង់ការនៃសម័យប្រជុំពេញអង្គរបស់សភា** : សម័យប្រជុំពេញអង្គ (Plenary Session) គឺជាការប្រជុំនៃសមាជិកទាំងអស់របស់សភា (Chamber) ដែលត្រូវបានកំណត់ និងរៀបចំក្នុងសណ្តាប់ធ្នាប់កំណត់មួយច្បាស់លាស់ (មានន័យថាច្បាប់ជាអ្នកកំណត់)។ ជាទូទៅសម័យប្រជុំពេញអង្គរបស់សភានៃរដ្ឋសភារបស់ប្រទេសនីមួយៗ ប្រព្រឹត្តទៅតាមដំណាក់ពីរខុសគ្នាគឺ :

**ខ១. ដំណាក់ទីមួយ** (First stage) : នេះគឺជាការប្រជុំដំបូងបំផុត ដែលមានលក្ខណៈជាការប្រមូលផ្តុំ ឬជាលក្ខណៈសភាធម្មនុញ្ញ ដោយវាកើតមានបន្ទាប់ពីបោះឆ្នោតជាសាកលរួច (ភាគច្រើនប្រទេសដែលមានសភាតែមួយ)។ ការប្រជុំនេះសំរាប់ធ្វើការជ្រើសរើសអ្នកដឹកនាំនៃអង្គការរដ្ឋសភា ដែលសកម្មភាពទាំងនេះត្រូវបានកំណត់ដោយច្បាប់ ឬបទបញ្ជាផ្ទៃក្នុង ឬក៏រដ្ឋធម្មនុញ្ញ ។ ក្នុងអត្ថន័យនេះត្រូវបានរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ កំណត់ក្នុង**មាត្រា ៨២** ថា "រដ្ឋសភាបើកសម័យប្រជុំដំបូងហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើន ពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល" ។ ប៉ុន្តែដើម្បីកំនត់ឱ្យដំណើរការបាននូវសកម្មភាពដំបូងនៃអង្គនីតិបញ្ញតិនេះ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាកម្ពុជា ១៩៩៣ បានបញ្ជាក់នៅ**ប្រការទី ២** ថា "នៅពេលបើកសម័យប្រជុំលើកទី ១ នៃនីតិកាលនីមួយៗ រដ្ឋសភាត្រូវចាប់ដំណើរការក្រោមអធិបតីភាពនៃប្រធានបណ្តោះអាសន្នមួយរូបដែលជាបេក្ខជនជាប់ឆ្នោត មានអាយុច្រើនជាងគេ ហើយដែលឥតមានគេប្តឹងតវ៉ា ហើយមានសមាជិក ៥ រូប ដែលជាបេក្ខជនជាប់ឆ្នោតដែលមានអាយុតិចជាងគេ ហើយដែលឥតមានគេប្តឹងតវ៉ា ជាលេខាធិការដើម្បីជួយប្រធានក្នុងការងារ ។

ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករដ្ឋសភាខាងលើនេះ រដ្ឋសភាត្រូវចាប់ផ្តើមធ្វើការដូចតទៅ :

ក- ប្រកាសតាំងភ្លាមនូវតំណាងរាស្ត្រពេញសិទ្ធិ ។

ខ- ជ្រើសតាំងប្រធាន និងអនុប្រធានទាំងពីររបស់រដ្ឋសភា ។ រដ្ឋសភាមិនអាចជជែកពិភាក្សាគ្នាអ្វីឡើយ ក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិករដ្ឋសភា" ។ **ប្រការទី ៣** បានកំណត់ថា "នៅពេលបើកសម័យប្រជុំខាងលើនេះ ព្រឹទ្ធសមាជិករដ្ឋសភាប្រកាសជូនអង្គសភា :

- ឈ្មោះបេក្ខជនជាប់ឆ្នោតជាស្ថាពរ ដែលអង្គការរៀបចំបោះឆ្នោតបានបញ្ជូនមក ។
- ឈ្មោះបេក្ខជនជាប់ឆ្នោតដែលមានគេប្តឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធបណ្តឹងទាំងនោះ ។

ដើម្បីសំរេចអំពីសុពលភាព ឈ្មោះអ្នកតំណាងរាស្ត្រពេញសិទ្ធិទាំងនេះត្រូវបានបិទផ្សាយក្នុងរដ្ឋសភា និងផ្សព្វផ្សាយជាសាធារណៈក្រោយពេលប្រជុំ" ។ **ប្រការទី ៥** បានកំណត់ថា "ក្រោយពីព្រះមហាក្សត្រ និងព្រះអគ្គមហេសីបានបើកនីតិកាលរដ្ឋសភារួចហើយ ហើយបើអង្គសភាមានសមាជិកវត្តមានប្រាំពីរភាគដប់យ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាអាចដំណើរការបោះឆ្នោតជ្រើសតាំងដាច់ដោយឡែកពីគ្នា នូវប្រធាន និងអនុប្រធានទាំងពីររបស់ខ្លួន ដោយមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល" ។ និង**ប្រការទី ៦** កំណត់ថា " ក្រោមអធិបតីភាពនៃប្រធានរដ្ឋសភា រដ្ឋសភាដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកនៃគណៈកម្មការនានារបស់រដ្ឋសភា ។

គណៈកម្មការនានានៃរដ្ឋសភាមាន :

១- គណៈកម្មការការពារសិទ្ធមនុស្ស និងទទួលពាក្យបណ្តឹង

២- គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ

៣- គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិដ្ឋាន

៤- គណៈកម្មការក្រសួងមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត

៥- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពត៌មាន

៦- គណៈកម្មការនីតិកម្ម

៧- គណៈកម្មការអប់រំធម្មការ វប្បធម៌ និងទេសចរណ៍

៨- គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី

៩- គណៈកម្មការសាធារណៈការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និង ពាណិជ្ជកម្ម" ។

ដូចនេះនៅក្នុងដំណាក់ដំបូងនៃការប្រជុំរបស់រដ្ឋសភា អង្គការនេះពុំមានសិទ្ធិធ្វើការអនុម័ត សេចក្តីសំរេចណាមួយបានទេ ក្រៅតែពីធ្វើឱ្យមានសុពលភាពនៃរដ្ឋសភា ។

**ខ២.ដំណាក់ទីពីរ** (Second Stage) : នេះជានីតិវិធីនៃការប្រជុំ ដែលប្រព្រឹត្តទៅដោយធម្មតាបន្ទាប់ពីអង្គនីតិបញ្ញត្តិនោះត្រូវបានរៀបចំជាផ្លូវការរួច។ ក្នុងវិធីនេះវាចាំបាច់ត្រូវកំណត់ដោយរដ្ឋធម្មនុញ្ញ ឬក៏បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាដែរ ។ តាមរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ **មាត្រា ៨៣** បានកំណត់ក្នុងវាក្យខ័ណ្ឌទីមួយ និងទីពីរថា "រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។ សម័យប្រជុំនីមួយៗមានថេរវេលាយ៉ាងតិចបីខែ" ។ នេះជាដំណាក់កាលដែលរដ្ឋសភាធ្វើការជាប្រក្រតីតាមបញ្ញត្តិច្បាប់ ដូចជាការអនុម័តច្បាប់នានាដែលបានបញ្ជាក់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ ១៩៩៣ តាម**ប្រការ ២៩** ( វិសោធនកម្មលេខ ២៦១ រស. អនុម័តថ្ងៃទី ០៤ ធ្នូ ១៩៩៥ ) ថា "ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវធ្វើដូចតទៅ :

១- អង្គសភា ពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថាតើគួរទទួលពិចារណា ឬទេ ។

២- អង្គសភា ពិភាក្សា និងអនុម័តលើមាត្រាមួយម្តងៗក៏បាន ឬលើជំពូកមួយម្តងៗក៏បាន ។

អង្គសភា អាចប្រើនីតិវិធីពិភាក្សាសង្ខេបបានដោយពិភាក្សាតែមាត្រា ឬជំពូកណាដែលមានសំណើរ ធ្វើវិសោធនកម្មជាលាយល័ក្ខអក្សរ ដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ ។

ក្នុងករណីដែលនឹងត្រូវប្រើនីតិវិធីណាមួយខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវជូនពតិមានដល់អ្នកតំណាងរាស្ត្រជាមុន ។

៣- អង្គសភា អនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំមូល"។ ប៉ុន្តែដើម្បីសំរេចទៅលើបញ្ហានានា រដ្ឋសភាត្រូវកំណត់នូវមធ្យោបាយជាច្រើនសំរាប់ការបញ្ចេញមតិនោះ ដូចជាវិធីសំងាត់, វិធីចំហរ, វិធីហៅឈ្មោះ និងផ្សេងៗទៀត ។ល។

**៩.២.១. វិធីចំហរ** (Public Polling) : ជាវិធីមួយក្នុងការធ្វើសេចក្តីសំរេចរបស់រដ្ឋសភា ដែលមិនទាក់ទងទៅនឹងការសំងាត់ ហើយវិធីនេះមានលក្ខណៈច្រើនប្រភេទ ដូចជាការលើកដៃ, ក្រោកឈរ, សំរែក ..... ។ល។ តាម**ប្រការទី ៣៧** នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាកម្ពុជាបានកំណត់ថា "ចំពោះការបញ្ចេញមតិដោយវិធីលើកដៃ ប្រធាន និងលេខាធិការទាំងឡាយជាអ្នករាប់ចំនួនសមាជិកដែលលើកដៃ ។ បើប្រធាន និងលេខាធិការទាំងនោះឃើញថាការបញ្ចេញមតិមិនបានលទ្ធផលច្បាស់លាស់ទេនោះ ត្រូវបញ្ចេញមតិ និងរាប់សារជាថ្មី"។ តែនៅពេលខ្លះពុំអាចអនុវត្តបានជោគជ័យនោះ គេត្រូវកិតធ្វើនូវនីតិវិធីផ្សេងទៀត ដូច**ប្រការទី ៣៨** កំនត់ថា "កាលបើការបញ្ចេញមតិដោយវិធីលើកដៃបានធ្វើពីរដង ហើយនៅតែមិនទាន់បានលទ្ធផលច្បាស់លាស់ទេនោះ ត្រូវប្រើវិធីបោះឆ្នោតជាចំហរ ។

វិធីបោះឆ្នោតចំហរនេះត្រូវធ្វើដូចតទៅ :

អាជ្ញាសភាកាន់ហិបឆ្នោតដើរទទួលប្រមូលយកសន្លឹកឆ្នោតពីសមាជិករដ្ឋសភា ។ សមាជិករដ្ឋសភាត្រូវសរសេរឈ្មោះខ្លួនលើសន្លឹកឆ្នោតមានបីយ៉ាង : ពណ៌ខៀវសំគាល់ថាមិនព្រម ពណ៌សសំគាល់ថាព្រម និងពណ៌សឆ្នូតខៀវសំគាល់ថាអនុប្បវាទ ។

ក្រោយពីបោះឆ្នោតរួចស្រេចហើយលេខាធិការរាប់សន្លឹកឆ្នោត ។ ដល់រាប់សន្លឹកឆ្នោតរួចហើយប្រធានរដ្ឋសភាត្រូវប្រកាសលទ្ធផលជូនអង្គសភាស្តាប់"។ និង**ប្រការទី ៣៩** កំនត់ថា "វិធីបោះឆ្នោតចំហរនៅវេទិកាប្រព្រឹត្តទៅដូចតទៅនេះ :

អ្នកតំណាងរាស្ត្រម្នាក់ដើរយកសន្លឹកឆ្នោតមកបោះក្នុងហិបដែលដាក់នៅលើវេទិកា ។

វិធីនេះនឹងយកមកប្រើបាន លុះត្រាតែមានអ្នកតំណាងរាស្ត្រ ១០ នាក់ យ៉ាងតិចស្នើសុំ"។ និងវិធីច្រើនទៀត ដូចជាការកំណត់សំលេង ២/៣ ជាដើម.......... ។ល។

**ខ២.២.វិធីសំងាត់** (Secret Polling) : ជាវិធីមួយដែលគេប្រើប្រាស់សំរាប់ការជ្រើសរើស និងការចាត់តាំងបុគ្គលឱ្យកាន់តំណែងណាមួយ ។ វិធីនេះជាទូទៅគេប្រើប័ណ្ណជាមួយស្រោមសំបុត្រ សំរាប់អនុវត្តក្នុងដំណើរការបោះឆ្នោតជ្រើសរើសផ្សេងៗ ។ តាម**ប្រការ ៤០** នៃបទបញ្ជាផ្ទៃក្នុង ដដែលនោះ បានកំណត់ភារកិច្ចនៃការបោះឆ្នោតសំងាត់ថា "វិធីបោះឆ្នោតសំងាត់ត្រូវតែប្រើក្នុងការ ជ្រើសតាំង ការសំដែង ការទុកចិត្ត និងការអនុម័តញ្ញត្តិបន្ទោស ។ អនុម័តច្បាប់ធ្វើវិសោធនកម្មរដ្ឋ ធម្មនុញ្ញ អាចប្រព្រឹត្តិដោយវិធីបោះឆ្នោតសំងាត់ដែរ"។

**ខ២.៣.វិធីហៅឈ្មោះ** (Call of The Roll) : ជាវិធីបោះឆ្នោតដែលមានលក្ខណៈពុំសំងាត់ ដោយសរសេរឈ្មោះនៅលើសន្លឹកឆ្នោតរាល់អ្នកតំណាងរាស្ត្រ។ វិធីនេះបានកំណត់ក្នុងប្រការ ៣៨ និង ៣៩ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាកម្ពុជា ឆ្នាំ ១៩៩៣ ។ ក្រៅពីនេះនៅមានវិធានច្រើនទៀត ក្នុង ការសំរេចផ្សេងៗរបស់រដ្ឋសភា ដូច**ប្រការទី ៤១** នៃបញ្ញត្តិដដែលនោះកំណត់ថា "ការអនុម័តទាំង ឡាយត្រូវយកតាមមតិភាគច្រើនដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ។ ក្រៅពីនេះមតិភាគច្រើននៃចំនួន សមាជិករដ្ឋសភាទាំងមូល ត្រូវទុកជាបានការ"។ និង**ប្រការ ៤២** កំណត់ថា "បើចំនួនមតិយល់ព្រម និងចំនួនមតិមិនយល់ព្រមស្មើគ្នា ការបោះឆ្នោតត្រូវធ្វើម្តងទៀត។ បើលទ្ធផលនៃការបោះឆ្នោតលើក ទី ២ នៅតែស្មើគ្នាត្រូវចាត់ទុកថារដ្ឋសភាមិនយល់ព្រម" ។ ចំពោះដំណើរការនៃការប្រជុំជាសាមញ្ញ របស់រដ្ឋសភាត្រូវមានកូរ៉ូមកំណត់មួយ ដូច**ប្រការ ៤៧** បទបញ្ជាផ្ទៃក្នុងបានកំណត់ថា "កូរ៉ូមសំរាប់ ប្រជុំត្រូវមានសមាជិករដ្ឋសភា ប្រាំពីរភាគដប់នៃចំនួនសមាជិករដ្ឋសភាទាំងមូល"។

**ចំណាំ** : ពាក្យថាកូរ៉ូមចេញពីពាក្យឡាតាំងថា "quorum" វាមានន័យពីរ គឺទីមួយជា រូបមន្តសំរាប់អនុម័តនៅពេលមានការចាត់តាំងចៅក្រមនៅប្រទេសអង់គ្លេស ។ ន័យទីពីរជាចំនួនចាំ បាច់នៃអ្នកចូលរួមក្នុងការប្រជុំដើម្បីដំណើរការ និងសំរេចរាល់បញ្ហាផ្សេងៗរបស់រដ្ឋសភា ដែលចាត់ ទុកជាបានការ ។

**ច. នីតិវិធី ឬទំរង់ការនៃការប្រជុំគណៈកម្មការធានាររបស់សភា** ៖ នេះគឺជាការប្រជុំមួយ ដែលរៀបចំឡើងដោយមានសមាសភាពចូលរួមមានកំរិត ។ ការប្រជុំររបៀបនេះវាត្រូវបានកំណត់ដោយច្បាប់មួយជាក់លាក់ ( បទបញ្ជាផ្ទៃក្នុង ឬរដ្ឋធម្មនុញ្ញ ) ។ យើងបានដឹងរួចហើយថា គណៈកម្មការរដ្ឋសភាមានលក្ខណៈជាអចិន្ត្រៃយ៍ និងគណៈកម្មការបណ្តោះអាសន្ន ឬគណៈកម្មការនានា។ យោងតាមបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា កំណត់ក្នុងការបង្កើតគណៈកម្មការអចិន្ត្រៃយ៍សភា ក្នុង**ប្រការទី ៧** ថា "គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមាន ៖

- ប្រធានរដ្ឋសភា
- អនុប្រធានទាំងពីរនៃរដ្ឋសភា
- ប្រធានគណៈកម្មការនានានៃរដ្ឋសភា

ប្រធានរដ្ឋសភា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា មានអាណត្តិស្មើនឹងនីតិកាលរបស់រដ្ឋសភា" ។ រីឯគណៈកម្មការនានានៅក្នុងខណៈនេះពុំមានលក្ខណៈជាបណ្តោះអាសន្នទេ តែវាសឹងតែជាអចិន្ត្រៃយ៍ទៅហើយ ព្រោះថាបើមានលក្ខណៈជាបណ្តោះអាសន្ននោះ គឺគេបង្កើតវាតែក្នុងករណីមានហេតុការណ៍ណាមួយ ហើយក៏រំលាយវាភ្លាមបន្ទាប់ពីការងារនោះត្រូវបានបញ្ចប់ ។ តាម**ប្រការទី ៦** បានកំណត់គណៈកម្មការនានាថា "ក្រោមអធិបតីភាពនៃប្រធានរដ្ឋសភា រដ្ឋសភាដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកនៃគណៈកម្មការនានារបស់រដ្ឋសភា ។

គណៈកម្មការនានានៃរដ្ឋសភាមាន ៖

១- គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង

២- គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ

៣- គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិដ្ឋាន

៤- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពត៌មាន

៦- គណៈកម្មការនីតិកម្ម

៧- គណៈកម្មការអប់រំធម្មការ វប្បធម៌ និងទេសចរណ៍

៨- គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី

៩- គណៈកម្មការសាធារណៈការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ។ ចំពោះការប្រជុំរបស់គណៈកម្មការមានលក្ខណៈប្លែកៗគ្នាជាច្រើនទៅតាមមុខងារ និងភារកិច្ចដែលបានកំនត់ដោយច្បាប់" ។ ដូចជា**ប្រការទី ១០** វាក្យខ័ណ្ឌទីបីបានកំណត់ថា "កូរ៉ុមសំរាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មកានានាត្រូវឱ្យមានលើសពីពាក់កណ្តាលនៃចំនួនសមាជិក" ។ រីឯតួនាទីមួយទៀតដែលទាក់ទិននឹងសេចក្តីព្រាងច្បាប់ និងរបៀបវារៈ ត្រូវបានកំណត់សមត្ថកិច្ច គណៈកម្មការ តាមរយៈ**ប្រការ ២១** ថា "សេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។ សេចក្តីព្រាងច្បាប់នោះជាលិខិតលាយល័ក្ខអក្សរ ហើយត្រូវចែកជូនអ្នកតំណាងរាស្ត្រទាំងអស់ ព្រមទាំងសេចក្តីថ្លែងហេតុមកជាមួយផង ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បញ្ជូនសេចក្តីនោះទៅគណៈកម្មការតាមុខជំនាញឱ្យពិនិត្យ ។ កាលបើពិនិត្យរួចហើយប្រធាននៃគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការមកជំរាបជូនរដ្ឋសភា" ។ រីឯសមត្ថកិច្ចរបស់គណៈកម្មាធិការបានកំណត់ក្នុង**ប្រការ ១៩** ថា "គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នករៀបចំរបៀបវារៈនៃពេលប្រជុំនីមួយៗ ។ មុនផុតពេលប្រជុំនីមួយៗ ប្រធានអានរបៀបវារៈសំរាប់ពេលប្រជុំបន្តទៅទៀត" ។ ក្រៅពីការរៀបរាប់ខាងលើនេះ នៅមានចំនុចជាច្រើននៃសណ្តាប់ធ្នាប់ការងាររបស់រដ្ឋសភា ដូចជាការប្រជុំ និងរបៀបរបបក្នុងពេលប្រជុំជាដើម ។

នៅក្នុងប្រទេសខ្លះការប្រជុំរដ្ឋសភា សមាជិកនីមួយៗមានសិទ្ធិនិយាយ ឬសួរស្ថិតក្នុងល័ក្ខខ័ណ្ឌច្បាស់លាស់ ដូចជាតាមការអនុញ្ញាតិរបស់ប្រធានអង្គប្រជុំ, តាមខ្លឹមសារនៃសំនួរ, តាមរយៈពេល ..... ។ល។ ការកំនត់ក្នុងល័ក្ខខ័ណ្ឌនេះដើម្បីកាត់បន្ថយនូវការជជែក ឬសួរមិនចំទិសដៅ ឬក៏អ្នកសួរមានតែមនុស្សដដែលៗ ។

## គំនូសបំព្រួញនៃរដ្ឋសភា (រូបទី ១១)



## ៤. **ដំណើរការនីតិកម្ម** (Legislative Process)

ដំណើរការនីតិកម្ម គឺជាសកម្មភាពសំរេចឱ្យបានជោគជ័យនូវច្បាប់ទាំងពួង ប៉ុន្តែពុំមែនជាទ្រឹស្តីនៃនីតិកម្មទេ (Legislation) ។ នៅក្នុងខ្លឹមសារនៃចំនុចនេះ គឺបកស្រាយតែទៅលើនីតិវិធីនៃការផលិត ឬបង្កើតច្បាប់តែប៉ុណ្ណោះ ប៉ុន្តែពុំបានរៀបរាប់នូវទ្រឹស្តីទាំងមូលនៃនីតិកម្មនោះទេ ។

**ក. អត្ថន័យទូទៅនៃដំណើរការនីតិកម្ម** : ជាទូទៅដំណើរការនីតិកម្មវាជាអត្ថន័យគតិយុត្តិមួយ ដែលមានលក្ខណៈចាំបាច់បំផុតសំរាប់កំណត់ពីអត្ថន័យទូទៅនៃនីតិកម្ម ឬទ្រឹស្តីនៃនីតិកម្ម (Legislation) ។ អត្ថន័យនៃដំណើរការនីតិកម្មចែកជាពីរប្រភេទគឺ :

- **ទីមួយ** : សណ្តាប់ធ្នាប់នៃការងារនីតិកម្ម (ការបង្កើតច្បាប់) : នេះគឺជាមធ្យោបាយទាំងឡាយដែលធ្វើឱ្យដំណើរការទៅក្នុងការបង្កើត ឬផលិតច្បាប់ ។

- **ទីពីរ** : ភារកិច្ចនៃនីតិកម្ម : ភារកិច្ចនេះវាបំពេញដោយអង្គការនីតិកម្ម គឺរដ្ឋសភា និងប្រមុខរដ្ឋ ក្នុងករណីខ្លះដែលផ្តល់លទ្ធភាពឱ្យចូលរួមពីរដ្ឋាភិបាល ឬក៏សកម្មភាពប្រជាមតិ ។ ភារកិច្ចនេះគឺជាការផ្តល់សិទ្ធិទៅឱ្យអង្គការដ្ឋក្នុងការងារបង្កើតច្បាប់ ឬបទដ្ឋានកិច្ចគតិយុត្តិនានា ។

ក្នុងករណីនេះពុំមានការលើកយកភារកិច្ចនីតិកម្មមកបកស្រាយទេ ពីព្រោះយើងបានសិក្សារួចទៅហើយថា តើអង្គការ ឬស្ថាប័នណាដែលមានភារកិច្ចសំរាប់ធ្វើច្បាប់ ? ដូចនេះអាទិភាពទីមួយនៃអង្គការដែលទទួលភារកិច្ចនេះគឺអង្គការនីតិបញ្ញត្តិ ឯអាទិភាពទីពីរ ឬទីបីនោះជាភារកិច្ចរបស់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាលដែលត្រូវបានកំណត់ដោយច្បាប់កំពូល (រដ្ឋធម្មនុញ្ញ) ចំពោះភារកិច្ចធ្វើច្បាប់ ឬបទដ្ឋានកិច្ចគតិយុត្តិផ្សេងៗបន្ទាប់ពីអង្គការនីតិបញ្ញត្តិនោះ ។

ចំពោះអត្ថន័យទីមួយនេះ វាជាកិច្ចការផ្ទៃក្នុងរបស់អង្គការដែលមានសមត្ថកិច្ចធ្វើច្បាប់. ថាតើអង្គការនោះមានវិធី ឬមធ្យោបាយបែបណាខ្លះក្នុងការផលិតច្បាប់ ? ដូចនេះ**ដំណើរការនីតិកម្ម**នឹងត្រូវលើកយកមកបកស្រាយក្នុងដំណាក់បន្តបន្ទាប់ នោះគឺជាការបកស្រាយទៅលើអត្ថន័យទីមួយតែប៉ុណ្ណោះ **គឺសណ្តាប់ធ្នាប់នៃការងារនីតិកម្ម** ។

**ខ. សណ្តាប់ធ្នាប់នៃនីតិកម្ម** : ជាទូទៅដំណើរការនីតិកម្មក្នុងអត្ថន័យនៃសណ្តាប់ធ្នាប់ការងារនៃនីតិកម្មវាជាដំណើរការគតិយុត្តិមួយដែលមានលំដាប់ថ្នាក់ (Stage) ដូចជាធ្វើ : សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ( ការផ្តើមគំនិតនីតិកម្ម ), ការពិភាក្សានៃសេចក្តីព្រាងច្បាប់ក្នុងរដ្ឋសភា និងក្នុងគណៈកម្មការ ( គណៈកម្មាធិការអនុម័តច្បាប់ ), ការចុះហត្ថលេខា, និងការប្រកាសឱ្យប្រើ, ការបោះពុម្ពផ្សាយនៃច្បាប់ ។ល។ ( មើលរូបទី ១២ និងទី ១៣ )

**ខ១. ការផ្តើមគំនិតនីតិកម្ម ឬហៅថាការផ្តើមគំនិតនៃសេចក្តីព្រាងច្បាប់**(Initiation of Bills): វាគឺជាការនាំយកជាផ្លូវការនូវពង្រាងលាយល័ក្ខជាអក្សរ ក្នុងឯកសារមួយទៅកាន់អង្គការមានសមត្ថកិច្ចនៃរដ្ឋសភា ដែលការនាំយកនោះត្រូវបានផ្តល់សិទ្ធិអំណាចទៅសមាជិក នៃការធ្វើសេចក្តីព្រាងច្បាប់ ឬក៏សេចក្តីស្នើច្បាប់ ។

នៅក្នុងឃ្លាខាងលើនេះមានពាក្យ **សេចក្តីព្រាងច្បាប់** (Bill) និងពាក្យ **សេចក្តីស្នើច្បាប់** (Legislative proposal) ដែលវាពុំមានខ្លឹមសារដូចគ្នានោះទេ គឺសេចក្តីព្រាងច្បាប់វាគឺជាអត្ថបទដែលនឹងក្លាយជាច្បាប់នូវរាល់ការសន្មត់ (Attribute) នៃលទ្ធផលចុងក្រោយរបស់វាដូចជា : បុព្វកថា (Preamble), មាត្រា (Article), កថាខ័ណ្ឌ(Paragraph) និងចំនុចទំរង់ពិតប្រាកដជាច្រើនទៀត ។ល។ មានន័យថា វាជា**អត្ថបទមានទំរង់ច្បាប់រួចទៅហើយ គ្រាន់តែពុំទាន់បានចារិកនូវឆន្ទៈរបស់ពលរដ្ឋដើម្បីយកទៅប្រើប្រាស់តែប៉ុណ្ណោះ** ។ រីឯពាក្យសេចក្តីស្នើច្បាប់ គឺជាគំនិតមួយចំពោះពង្រាងច្បាប់ ដែលនឹងធ្វើឱ្យក្លាយទៅជាច្បាប់នៃសេចក្តីព្រាងច្បាប់នោះ ។ មានន័យថាមានពង្រាងច្បាប់រួចហើយ តែត្រូវធ្វើសេចក្តីស្នើមួយទៀតទៅអង្គការមានសមត្ថកិច្ចដើម្បីពិនិត្យ និងធ្វើការអនុម័ត ថាតើសេចក្តីព្រាងច្បាប់នោះវាចាំបាច់ក្នុងកាលៈទេសៈនេះ ឬយ៉ាងណា ? ។ យើងអាចជួបប្រទះដូចជាប្រទេសបារាំង រដ្ឋាភិបាលនាំយកសេចក្តីព្រាងច្បាប់ រីឯសមាជិកសភាជាអ្នកធ្វើសេចក្តីស្នើច្បាប់ ដោយដាក់ឈ្មោះនូវរាល់ការសន្មត់របស់សេចក្តីព្រាងច្បាប់ ។ការអនុវត្តបញ្ញាស់របៀបនេះអនុវត្តក្នុងប្រទេសកម្ពុជា ដូច**ប្រការ ២១** នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ឆ្នាំ ១៩៩៣ បានកំណត់អំពីសេចក្តីព្រាងច្បាប់ថា "សេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល ត្រូវបញ្ជូនមកគណៈកម្មាធិការ

អចិន្ត្រៃយ៍រដ្ឋសភា ។ សេចក្តីព្រាងច្បាប់នោះជាលិខិតលាយល័ក្ខអក្សរ ហើយត្រូវចែកជូនអ្នកតំណាងរាស្ត្រទាំងអស់ ព្រមទាំងសេចក្តីថ្លែងហេតុមកជាមួយផង ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បញ្ជូនសេចក្តីនោះទៅគណៈកម្មការតាមមុខជំនាញឱ្យពិនិត្យ ។ កាលបើពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការនេះត្រូវនាំយកយោបល់របស់គណៈកម្មការមកជំរាបរដ្ឋសភា"។ រីឯ**ប្រការ ២២** នៃបទបញ្ជាដដែលនោះបានកំណត់នូវសេចក្តីស្នើច្បាប់ថា "សេចក្តីស្នើច្បាប់ ដែលអ្នកតំណាងរាស្ត្រអ្នកធ្វើនោះត្រូវធ្វើជាលាយល័ក្ខអក្សរ ចែកជាមាត្រា ហើយមានសេចក្តីថ្លែងហេតុនៅខាងដើមជាប់មកផង"។ ត្រង់នេះបញ្ជាក់ថា រាល់សេចក្តីព្រាងច្បាប់ត្រូវធ្វើឡើងដោយរដ្ឋាភិបាល ឬតាមរយៈរដ្ឋាភិបាល រីឯសេចក្តីស្នើច្បាប់វាជាពង្រាងច្បាប់មួយដែរ តែធ្វើឡើងតាមរយៈតំណាងរាស្ត្រទៅវិញ ពុំមែនតំណាងរាស្ត្រធ្វើសេចក្តីស្នើច្បាប់ចំពោះសេចក្តីព្រាងច្បាប់ដែលធ្វើឡើងដោយរដ្ឋាភិបាលនោះទេ ។

ចំពោះវត្តមាននូវសិទ្ធិរបស់សមាជិកនៃការផ្តើមគំនិតធ្វើពង្រាងច្បាប់ គឺជាការសន្យារបស់រដ្ឋសភា ។ ប៉ុន្តែរដ្ឋសភាពុំអាចសន្យាថានឹងអនុម័តនូវរាល់សេចក្តីព្រាងច្បាប់នោះទេ ។ ត្រង់នេះបញ្ជាក់ថា ពុំមែនរាល់ពង្រាងច្បាប់ដែលបានស្នើមកនោះ សុទ្ធតែបានរដ្ឋសភាអនុម័តទាំងអស់នោះឡើយ ។

ចំពោះសិទ្ធិនៃការផ្តើមគំនិតធ្វើច្បាប់របស់សមាជិកនៃអង្គការរដ្ឋ មានលក្ខណៈច្រើនប្រភេទណាស់ វាស្របទៅតាមប្រទេសនីមួយៗដែលគេបានកំណត់ដោយច្បាប់កំពូល (រដ្ឋធម្មនុញ្ញ) ប៉ុន្តែក្នុងប្រទេសជាច្រើន ការធ្វើពង្រាងច្បាប់នោះផ្ទុកផ្តាក់ទៅរដ្ឋាភិបាល និងសមាជិករដ្ឋសភា ។ សំរាប់នៅសហរដ្ឋអាមេរិក សិទ្ធិនេះត្រូវបានផ្ទុកផ្តាក់ទៅសមាជិកនៃរដ្ឋសភា លើកលែងតែសេចក្តីព្រាងច្បាប់ស្តីពីថវិកាទេ ដែលជាសិទ្ធិផ្តាច់មុខរបស់ប្រធានាធិបតី (ប៉ុន្តែសិទ្ធិរបស់ប្រធានាធិបតីទៅលើសេចក្តីព្រាងច្បាប់អំពីថវិកានោះមានច្រើនប្រភេទ គឺមានន័យថាពុំមែនគ្រប់តែច្បាប់ថវិកាប្រធានាធិបតីជាអ្នកធ្វើនោះទេ)។ នៅក្នុងប្រទេសផ្សេងទៀតគេផ្ទុកផ្តាក់សិទ្ធិនេះ ទៅឱ្យអង្គការរដ្ឋជាន់ខ្ពស់ទាំងឡាយ ដូចជាស្ថាប័នជាន់ខ្ពស់ (ស្ថាប័នកណ្តាល). ស្ថាប័នសាសនា ឬនិម្មិតកម្មសង្គមផ្សេងៗទៀត.

អង្គការផ្ទៃក្នុងរដ្ឋសភា និងអង្គការផ្សេងៗទៀតជាសេនាធិការរបស់រដ្ឋសភា និងក្រុមអ្នកបោះឆ្នោត (ក្រុមពលរដ្ឋ)។

ចំពោះប្រទេសមួយចំនួនទៀតការផ្តល់សិទ្ធិធ្វើច្បាប់ នោះត្រូវផ្តល់តាមលក្ខណៈច្រើនប្រភេទទៅបុគ្គលមានអំណាចរដ្ឋ ដូចជា**មាត្រា ៩១** វាក្យខ័ណ្ឌទីមួយ រដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ថា "សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់......."។

ចំពោះប្រទេសដែលមានសភាពីរ ឬសភាទ្វេភាព (Bicameralism) វាបានផ្តល់សិទ្ធិក្នុងការធ្វើពង្រាងច្បាប់ ឬសំណើច្បាប់ទៅឱ្យសភាមួយក្នុងចំណោមសភាទាំងពីរ (ដូចជាកម្ពុជា) ឬឱ្យសភាទាំងពីរ ឬក៏មានត្រឹមតែសភាជាន់ទាប (សភាតំណាងរាស្ត្រ)។ សំរាប់សហរដ្ឋអាមេរិក ពង្រាងច្បាប់ទាំងអស់អាចនាំទៅកាន់សភាណាមួយក៏បាន ប៉ុន្តែពង្រាងច្បាប់ថវិកាត្រូវតែចាប់ផ្តើមពីសភាតំណាងរាស្ត្រ (House of Representative) ដែលកំណត់ក្នុង**មាត្រា ១** ផ្នែកទី **៧** នៃរដ្ឋធម្មនុញ្ញសហរដ្ឋ។ សំរាប់ប្រទេសអាល្លឺម៉ង់ ពង្រាងច្បាប់ទាំងអស់ត្រូវនាំយកពីសភាតំណាងរាស្ត្រ (Bundestage) ក្នុងមាត្រា ៧៦ នៃច្បាប់គ្រឹះ ។ ដោយឡែកប្រទេសបារាំងក៏មានលក្ខណៈដូចប្រទេសកម្ពុជាដែរ គឺផ្តល់សិទ្ធិទៅឱ្យប្រមុខរដ្ឋាភិបាល ដូច**មាត្រា ៣៩** វាក្យខ័ណ្ឌទី ១ រដ្ឋធម្មនុញ្ញបារាំង បានកំណត់ថា "ការផ្តួចផ្តើមធ្វើច្បាប់ត្រូវផ្តុកផ្តាក់ទៅនាយករដ្ឋមន្ត្រី និងសមាជិករដ្ឋសភា"។ ដូចនេះការផ្តើមគំនិតធ្វើច្បាប់ ត្រូវបានកំណត់ដោយច្បាប់កំពូលនៃប្រទេសនីមួយៗ ដែលមានលក្ខណៈផ្សេងៗគ្នាតាមការវិវត្តន៍នៃប្រពៃណីច្បាប់ជាតិ ។

**ខ**₂**. ការពិភាក្សានៃសេចក្តីព្រាងច្បាប់** (Discussion of Draft Legislation) : នេះគឺជាទំហំនៃដំណាក់ការមួយក្នុងដំណើរការនីតិកម្មដែរ ក្នុងនោះវាបានសំណូមពរឱ្យធ្វើការងារចំពោះសេចក្តីព្រាងច្បាប់នៅឯសម័យប្រជុំពេញអង្គរបស់រដ្ឋសភា និងក្នុងគណៈកម្មាធិការ ឬគណៈកម្មការ ។ ការងារនេះរៀបចំឡើងដោយធាតុផ្សំជាច្រើនផ្សេងៗគ្នា (Combination) ។ ជាទូទៅការពិភាក្សាសេចក្តីព្រាងច្បាប់នៅក្នុងសម័យប្រជុំសភាពេញអង្គ ជានិច្ចកាលមានឈ្មោះថា**បំណកស្រាយនៃសេចក្តីព្រាងច្បាប់** (Reading) ។ ពាក្យបំណកស្រាយ (Reading) នេះដែរ រដ្ឋសភានៃបណ្តាប្រទេសនីមួយៗធ្វើទៅលើសេចក្តីព្រាងច្បាប់មាន ៣ ដំណាក់គឺ :

**ខ២.១. ចំណាក់ចំបូង ឬចំណាកស្រោយទីមួយ** (First Reading) : វាជាការពិភាក្សាដែលត្រូវសំរេចថា តើត្រូវការនូវច្បាប់នោះ ឬទេ ?។ ក្នុងលក្ខណៈនេះសមាជិករដ្ឋសភា ត្រូវការស្តាប់នូវសេចក្តីថ្លែងរបស់អ្នកផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់នោះ ហើយធ្វើការវាយតំលៃ និងសំរេចវាយតំលៃ និងសំរេចយក ឬមិនយក នេះជាការអនុម័តទៅលើការពិភាក្សាលើកទីមួយ ។ ដូចបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ១៩៩៣ របស់កម្ពុជាបានកំណត់ក្នុងវាក្យខ័ណ្ឌទីមួយ នៃ**ប្រការ ២១** ថា "សេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ។ សេចក្តីព្រាងច្បាប់នោះជាលិខិតលាយល័ក្ខអក្សរ ហើយត្រូវចែកជូនអ្នកតំណាងរាស្ត្រទាំងអស់ ព្រមទាំងសេចក្តីថ្លែងហេតុមកជាមួយផង"។ (**មើលរូបទី ១២**) ការសំរេចនូវជំហានទីមួយនេះមានលក្ខណៈច្រើនប្រភេទ ដូច**ប្រការ ២៤** នៃបទបញ្ជាដដែលបញ្ជាក់ថា "គណៈកម្មការអាចសន្និដ្ឋានថា :

- សូមឱ្យរដ្ឋសភាលើកចោលពុំពិចារណាក៏បាន ។
- សូមឱ្យរដ្ឋសភាបញ្ចេញមតិជាមុនសិន តើគួរទទួលពិចារណា ឬទេ ។
- សូមឱ្យរដ្ឋសភាទទួលពិចារណាហើយ និងទុកជាការប្រញាប់ផងក៏បាន"។ ក្រោយពីយល់ព្រមទៅលើជំហានទីមួយនោះ សេចក្តីព្រាងច្បាប់នឹងបញ្ជូនទៅធ្វើការកែឆ្នៃតទៅទៀត ដែលក្នុងករណីនេះប្រធានរដ្ឋសភា ឬប្រធានគណៈកម្មាធិការជាអ្នកបំពេញភារកិច្ចនេះ ដោយអាស្រ័យនឹងគណៈកម្មការជំនាញ ដូចវាក្យខ័ណ្ឌទីពីរនៅ**ប្រការ ២១** នៃបទបញ្ជាផ្ទៃក្នុងដដែលនោះបានកំណត់ថា "គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបញ្ជូនសេចក្តីនោះ (ពង្រាងច្បាប់) ទៅគណៈកម្មការតាមមុខជំនាញឱ្យពិនិត្យ ។ កាលបើពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការនោះត្រូវនាំយកយោបល់របស់គណៈកម្មការមកជំរាបជូនរដ្ឋសភា"។ មុនពេលអនុម័តលើការពិភាក្សាលើកទីមួយ អ្នកតែងច្បាប់អាចដកសេចក្តីស្នើរបស់ខ្លួនបាន ដូចវាក្យខ័ណ្ឌទីមួយ **ប្រការ ២៥** នៃបញ្ញត្តិដដែលនោះកំណត់ថា "អ្នកតែងសេចក្តីច្បាប់អាចដកសេចក្តីនោះចេញបាន ទោះបីរដ្ឋសភាចាប់ពិភាក្សាហើយក៏ដោយ ។ សេក្តីស្នើច្បាប់ដែលដកចេញនោះ សមាជិកឯទៀតអាចសុំឱ្យរដ្ឋសភាពិភាក្សាវិញបាន"។

ដូចនេះដំណាក់ទីមួយ គឺជាដំណាក់ពិភាក្សាសំរេចទទួលយក ឬបដិសេធន៍ទៅលើសេចក្តីព្រាងច្បាប់ទាំងមូល តាមការចាំបាច់ ឬតំរូវការរបស់សង្គម ។

**៩.២.២.ចំណាក់ទីពីរ ឬចំណាកស្រោយលើកទីពីរ** (Second Reading) : នេះគឺជាការពិភាក្សាទៅលើសេចក្តីព្រាងច្បាប់ ដែលបន្ទាប់ពីបានបញ្ចប់លើកទីមួយ ។ ការពិភាក្សានេះធ្វើឡើងក្នុងសម័យប្រជុំពេញអង្គរបស់រដ្ឋសភា ដោយពិភាក្សាយ៉ាងលំអិតទៅលើសេចក្តីព្រាងច្បាប់នោះ ។ ការធ្វើរបៀបនេះ គឺកើតមានឡើងតាមរយៈសេចក្តីថ្លែងការ ឬសុទ្ធរកថារបស់គណៈកម្មាធិការ (គណៈកម្មការ) ដែលទទួលបន្ទុកក្នុងកិច្ចការនៃសេចក្តីព្រាងច្បាប់នោះ ។ ក្នុងជំហាននេះគេបានលើកយកសេចក្តីព្រាងច្បាប់មកធ្វើការបោះឆ្នោតតាមលំដាប់ថ្នាក់របស់វា ដូចជាការលើកយកជំពូក. មាត្រាកថាខ័ណ្ឌ...... នៃសេចក្តីព្រាងច្បាប់នោះមកពិភាក្សា ដោយយកចិត្តទុកដាក់ជាទីបំផុត ។ ដូចបទបញ្ជាផ្ទៃក្នុងរដ្ឋសភា បានកំណត់ក្នុង**ប្រការ ២៩** ថា "ការពិភាក្សាលើសេចក្តីព្រាច្បាប់ ឬសេចក្តីស្នើច្បាប់ ត្រូវធ្វើដូចតទៅ :

១- អង្គសភាពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថា តើគួរទទួលពិចារណាឬទេ ។

២- អង្គសភាពិភាក្សា និងអនុម័តលើមាត្រាមួយម្តង១ក៏បាន ឬលើជំពូកមួយម្តង១ក៏បាន។

អង្គសភាអាចប្រើនីតិវិធីពិភាក្សាសង្ខេបបាន ដោយពិភាក្សាតែមាត្រា ឬជំពូកណាដែលមានសំណើធ្វើវិសោធនកម្មជាលាយល័ក្ខអក្សរ ដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ ។

ក្នុងករណីដែលនឹងត្រូវប្រើនីតិវិធីណាមួយខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវជូនពត៌មានដល់អ្នកតំណាងរាស្ត្រជាមុន ។

៣- អង្គសភាអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូល" ។ ផ្ទុយទៅវិញ បើសិនជាសមាជិករដ្ឋសភាមិនពេញចិត្ត ឬក៏សុំធ្វើវិសោធនកម្មលើសេចក្តីព្រាងច្បាប់នោះ វាជាភារកិច្ចចាំបាច់ត្រូវធ្វើឱ្យបានក្នុងដំណាក់កាលនេះ ដោយពុំទុករង់ចាំពេលទីបីឡើយ ដូច**ប្រការ ២៦** នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាកម្ពុជាបានកំណត់ថា "អ្នកតំណាងរាស្ត្រគ្រប់រូប អាចស្នើសុំធ្វើវិសោធនកម្មលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់បាន ។ ពាក្យសុំធ្វើវិសោធនកម្មនេះ ត្រូវធ្វើជាលាយល័ក្ខអក្សរជូនទៅគណៈកម្មការជំនាញក៏បាន ឬជូនទៅរដ្ឋសភាក្នុងពេលប្រជុំពេញអង្គក៏បាន" ។

ចំពោះពាក្យសុំធ្វើការកែប្រែលើសេចក្តីព្រាងច្បាប់ ដូចដែលបានកំណត់ក្នុងកថាខ័ណ្ឌចុងក្រោយនៃប្រការ ២៦ នេះ ត្រូវបានគេលើកយកទៅពិនិត្យក្នុងអង្គសភា ដូច**ប្រការ ២៧** បានកំណត់ថា "អង្គសភាសំរេចថាយល់ព្រម ឬមិនយល់ព្រមយកពាក្យសុំនោះមកពិភាក្សា"។ ប៉ុន្តែដើម្បីជៀសវាងនូវការសិក្សាពុំបានល្អិតល្អន់ទៅលើសេចក្តីព្រាងច្បាប់ និងធ្វើឱ្យមានការរំខានដល់គណៈកម្មការដែលទទួលបន្ទុកខាងសេចក្តីព្រាងច្បាប់នោះ នៅក្នុងប្រទេសខ្លះគេតែងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ចំពោះការកែប្រែទៅលើសេចក្តីព្រាងច្បាប់ទាំងមូល ដូចជាប្រទេសបារាំងជាដើម បានកំណត់យ៉ាងច្បាស់ថា ការកែប្រែទាំងឡាយត្រូវតែសំដែងចេញមិនតិចជាង ៨ ថ្ងៃ[៧២] មុនពេលពិភាក្សាលើសេចក្តីព្រាងច្បាប់ទាំងមូលនោះទេ នៅពេលប្រជុំពេញអង្គ ។

ចំពោះរយៈពេលពិភាក្សាទៅលើការកែប្រែសេចក្តីព្រាងច្បាប់ក្នុងពេលប្រជុំ (កន្លែងដែលត្រូវកែប្រែ) ជានិច្ចកាលមានកំរិតខ្លីបំផុត ដូចជានៅអាមេរិក, បារាំង, មិនលើស ៥ នាទីទេ ចំណែកនៅប្រទេសអង់គ្លេសប្រធានជាអ្នកសំរេច ។ ជាការពិតណាស់ ដើម្បីឱ្យតំណាងរាស្ត្រយល់ដឹងទៅលើសេចក្តីព្រាងច្បាប់មួយគ្រប់គ្រាន់ លុះត្រាតែចែកជូនច្បាប់ចំលងនោះទៅគ្រប់តំណាងរាស្ត្រ ដែលជាវិធីមួយទប់ស្កាត់មិនឱ្យមានការខុសឆ្គងលើការអនុម័ត ។ ចំពោះប្រទេសកម្ពុជាច្បាប់ពុំបានកំណត់នូវថេរវេលា (ក្នុងពេលប្រជុំ) នៃការសំដែងក្នុងការកែប្រែសេចក្តីព្រាងច្បាប់ទេ តែវាបានកំណត់នូវលក្ខណៈទូទៅក្នុងការនិយាយរបស់តំណាងរាស្ត្រ ដូច**ប្រការ ៥៩** បានកំណត់ថា "តាមធម្មតាអ្នកតំណាងរាស្ត្រដែលបានចុះឈ្មោះសុំនិយាយ និយាយបាន ២០ នាទី យ៉ាងយូរ ។ អ្នកតំណាងរាស្ត្រដែលគ្រាន់តែសុំឆ្លើយតបនិយាយបានតែ ៥ នាទីទេ ។

បើប្រធានយល់ឃើញថាជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សានោះ ប្រធានអាចអនុញ្ញាត្តិឱ្យបន្ថែមពេលឱ្យនិយាយ ១០ នាទី ទៀតបាន ។ ការបន្ថែមនេះអាចអនុញ្ញាតឱ្យបន្តបាន ៣ ដង ក្នុងរឿងដដែល"។ ក្រោយពីបានអនុម័តចប់សព្វគ្រប់ក្នុងដំណាក់ទីពីរនេះ (Second Reading) សភាត្រូវបញ្ជូនត្រលប់ទៅគណៈកម្មាធិការ (ឬគណៈកម្មការ) វិញសំរាប់ធ្វើការបោះពុម្ព

[៧២] .Constitutional Law of foreign country, Part II, M.1994, Page 191 ។

ជាឯកសារ ជាផ្លូវការសំរាប់ដាក់ជូនប្រមុខរដ្ឋចុះហត្ថលេខា ឬជូនទៅសភាថ្នាក់មួយទៀត ( ករណីទ្វេសភា) ។

ដូចនេះដំណាក់ទីពីរ គឺជាដំណាក់កាលដែលត្រូវពិភាក្សាយ៉ាងលំអិតទៅលើសេចក្តីព្រាងច្បាប់ ។

**ខ.២.៣. ដំណាក់ទីបី ឬបំណាកស្រាយលើកទីបី** (Third Reading) : នេះគឺជាការបញ្ចេញមតិរបស់សមាជិករដ្ឋសភាទាំងមូល ទៅលើអត្ថបទច្បាប់ដែលបានកែប្រែ ឬពិភាក្សារួច ប៉ុន្តែមិនអនុញ្ញាតិឱ្យមានការកែប្រែទៅលើចំណុចណាមួយនៃសេចក្តីព្រាងច្បាប់នោះទៀតបានឡើយ ។ ព្រោះថាពេលវេលាសំរាប់ការកែតំរូវពុំមានក្នុងការពិភាក្សាលើកទីបីនេះទេ ប៉ុន្តែជាការសំរេចទៅលើខ្លឹមសាររួមនៃសេចក្តីព្រាងច្បាប់ដែលបានពិភាក្សា ។ ក្នុងដំណាក់ទីបីនេះ អាចមានពេលខ្លះក៏សេចក្តីព្រាងច្បាប់ដែលបានកែប្រែហើយ នោះពុំត្រូវបានរដ្ឋសភាអនុម័តយល់ព្រមដែរ ដោយហេតុមានភាគីជាច្រើនមានការប្រឆាំង ។ ចំពោះប្រទេសខ្លះគេពុំធ្វើតាមទំរង់ទាំងបីលំដាប់ខាងលើនេះទេ ដូចជា : ស៊ុយអែដ, ប៉ូឡូញ, កូឡុំប៊ី ...... ។ល។ គឺប្រទេសទាំងនេះ ធ្វើឡើងតែពីរដំណាក់ប៉ុណ្ណោះ ។

**គ. ការអនុម័តច្បាប់** (Passed Law) : វាក៏ជាលំដាប់ថ្នាក់មួយនៃដំណើរការនីតិកម្មដែរ ។ ការអនុម័តច្បាប់នេះ គឺជាដំណើរចុងក្រោយបន្ទាប់ពីការបញ្ចប់នូវបំណាកស្រាយលើកទីបី (Third Reading) ដើម្បីឱ្យពង្រាងច្បាប់ក្លាយទៅជាច្បាប់ចុងក្រោយដែលយល់ព្រមពីភាគីនៃរដ្ឋសភា (Parliament) ។ ប៉ុន្តែការអនុម័តនេះ វាអាចធ្វើឡើងតាមពង្រាងច្បាប់ទាំងមូលក៏បាន ឬតាមជំពូកក៏បាន ។ មួយវិញទៀត ការអនុម័តទៅលើសេចក្តីព្រាងច្បាប់វាអាស្រ័យទៅនឹងក្របខ័ណ្ឌរដ្ឋសភា (Parliament) ដែលប្រទេសនីមួយៗប្រកាន់សភាទោល (**មើលរូបទី១១ និង១២**) ឬក៏ទ្វេសភា (**មើលរូបទី ១៣**) ។ ពីព្រោះថារាល់ពង្រាងច្បាប់ដែលសំរេចក្នុងសភាមួយ ហើយត្រូវតែឆ្លងកាត់សភាមួយទៀតទើបអាចយកជាការបាន ប៉ុន្តែក្នុងករណីជំទាស់ក្នុងសភាណាមួយ, នោះនឹងបង្កើតគណៈកម្មការសំរបសំរួលមួយ ដែលសមាជិករបស់វាយកមកពីសភាទាំងពីរ ។ ប៉ុន្តែជួនកាលប្រទេសដែលប្រកាន់ទ្វេសភា វាអាចមានលក្ខណៈជាប្រពៃណីរបស់គេ ដែលសភាមួយក្នុងចំណោមសភាទាំងពីរមានអំណាចខ្លាំង ( អាចសភាជាន់ខ្ពស់ ឬសភាជាន់ទាប) ។

ក្នុងករណីដែលមានភាពចំរូងចំរាស់គ្នា រវាងសភាទាំងពីរនៃការអនុម័តច្បាប់នោះ រដ្ឋធម្មនុញ្ញតែងកំនត់ផ្លូវជ្រើសរើសជាច្រើនដែលវិធីនេះមាន :

**ករណី ១ :** ប្រសិនដំណើរការនីតិកម្មក្នុងសភាទាំងអស់ មានការខ្វែងគំនិតគ្នានោះច្បាប់មិនត្រូវបានអនុម័ត ។ ដំណោះស្រាយត្រូវបង្កើតគណៈកម្មការចំរុះមួយ ដើម្បីសំរបសំរួលការងារ ។

**ករណី ២ :** ប្រសិនបើសភាជាន់ទាបមានអំណាចខ្លាំងនោះ ច្បាប់ត្រូវតែអនុម័តនៅទីបញ្ចប់ ។

**ករណី ៣ :** មានម្តងម្កាលដែរ ច្បាប់មួយអាចត្រូវបានអនុម័តដោយត្រឹមតែសភាជាន់ខ្ពស់ ។

**ករណី ៤ :** ច្បាប់មួយអាចអនុម័ត នៅក្នុងសហប្រជុំនៃសភាទាំងអស់ ។

នៅក្នុងករណីទីមួយដូចជានៅសហរដ្ឋអាមេរិក : ច្បាប់មួយមិនអាចត្រូវបានអនុម័តទេ ប្រសិនបើសភាមួយក្នុងចំណោមសភាទាំងពីរនៃរដ្ឋសភា (Congress) ពុំយល់ព្រមគ្នា ហើយបង្កើតគណៈកម្មការសំរបសំរួលមួយ ដែលគណៈកម្មការនោះយល់ព្រមពីសភាទាំងពីរ (មើលរូប ១៣) ក្នុងករណីទីមួយនេះមាននៅប្រទេសអាល្លឺម៉ង់ផងដែរ ។

ប៉ុន្តែក្នុងករណីទីពីរមានដូចជាចក្រភពអង់គ្លេស និងអាល្លឺម៉ង់ផងដែរ ប៉ុន្តែពេលខ្លះក្នុងការអនុម័តច្បាប់មួយធ្វើឡើងដោយសភាជាន់ខ្ពស់ដែរ សំរាប់ប្រទេសអាល្លឺម៉ង់ រីឯប្រទេសបារាំងមានលក្ខណៈចំរុះ ដូចមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញបារាំងបានកំណត់ស្រាប់ ។ រីឯករណីទីបួនមានដូចជាប្រទេសឥណ្ឌាមាត្រា១០៨ នៃរដ្ឋធម្មនុញ្ញរបស់គេបានកំណត់នូវការអនុម័តច្បាប់ បើសិនជាសភាទាំងពីរមិនយល់ព្រមនោះ ប្រធានាធិបតីកោះហៅសភាទាំងពីរចូលប្រជុំរួមគ្នាសំរាប់អនុម័តច្បាប់នោះ ។

ចំពោះដំណើរការនីតិកម្មនៃរដ្ឋសភាកម្ពុជា រដ្ឋធម្មនុញ្ញបានកំនត់ក្នុង**មាត្រា ១១៣** ថា "ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័ត យល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ។ បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

បើព្រឹទ្ធសភាសុំឱ្យកែសំរួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ ។ រដ្ឋសភាត្រូវពិនិត្យ និងសំរេច តែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសំរួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសំរេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃបើជាការប្រញាប់ ។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យាពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះរយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់ ។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី ២ នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសំរេចដូចខាងលើនេះហើយនោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ" ។ តាមខ្លឹមសារបានបញ្ជាក់ក្នុងវាក្យខ័ណ្ឌទីមួយ និងទីពីរ ដោយឱ្យសភាតំណាងរាស្ត្រមានអំណាចខ្លាំងជាងអំណាចព្រឹទ្ធសភា បើទោះបីព្រឹទ្ធសភាយល់ព្រម ឬមិនយល់ព្រមក៏ដោយ ក្នុងរយៈពេលមួយខែ ឬ ៥ ថ្ងៃ បើជាការប្រញាប់នោះ សេចក្តីព្រាងច្បាប់នឹងយកទៅចុះហត្ថលេខាប្រកាសឱ្យប្រើ ។ ផ្ទុយទៅវិញ បើពិនិត្យវាក្យខ័ណ្ឌទី ៣ ទី ៤ និងទី ៥ បញ្ជាក់ថាដំណើរការនីតិកម្មមានលក្ខណៈល្បាយ ឬសំរបសំរួល ។ បើពិនិត្យវាក្យខ័ណ្ឌទី ៦ បញ្ជាក់ថាព្រឹទ្ធសភាមានអំណាចខ្លាំង តែស្ថិតក្នុងល័ក្ខខ័ណ្ឌពេលវេលាមួយកំនត់ ។ រីឯវាក្យខ័ណ្ឌទី ៧ ពុំបានកំនត់ដាច់ណាត់ថា

សភាជាន់ទាបធ្វើតាម ឬបដិសេធទៅលើសេចក្តីព្រាងច្បាប់នោះទេ ។ ត្រង់ចំនុចនេះបញ្ជាក់ថា បើសភាជាន់ទាបប្រឆាំងទៅនឹងការកែប្រែរបស់សភាជាន់ខ្ពស់ នោះសេចក្តីព្រាងច្បាប់ពុំដឹងមានសំណាងដូចម្តេចទេ ឬមួយការប្រឆាំងរបស់ព្រឹទ្ធសភាចាត់ទុកមិនបានការក្នុងរយៈមួយខែ ហើយបន្ទាប់មកសភាជាន់ទាបយកសេចក្តីព្រាង ដែលសភាជាន់ខ្ពស់បដិសេធនោះទៅឱ្យប្រមុខរដ្ឋចុះហត្ថលេខាប្រើប្រាស់ ឬក៏វិធីណាផ្សេងទៀត? ។ ( មើលបំណកស្រាយរូបទី ១២) ។

**ឃ. ការយល់ព្រម** (Approval), **ការប្រកាស** (Promulgation) **និងការបោះផ្សាយ** (Publication) **នៃច្បាប់** : នេះគឺជាលំដាប់ថ្នាក់មួយទៀតនៃដំណើរការនីតិកម្មដែរ ដែលក្នុងដំណាក់ (Stage) នេះអាចមានពីរ ឬបីជំហានទៀត ។ នេះបើគិតក្នុងប្រទេសចក្រភពអង់គ្លេស និងអតីតអាណានិគមអង់គ្លេស គេសង្កេតឃើញថារដ្ឋសភាចក្រភពអង់គ្លេសកើតឡើងពីសមាសភាពបីគឺ : ព្រះរាជា, សភាគហបតី និងសភាសហគមន៍ រីឯប្រទេសឥណ្ឌាក្នុង**មាត្រា ៧៩** នៃរដ្ឋធម្មនុញ្ញបានកំណត់ថា "រដ្ឋសភាសហភាពកើតឡើងពីប្រធានាធិបតី និងសភាពីរទៀតគឺ : ក្រុមប្រឹក្សារដ្ឋ ( សភាតំណាងរដ្ឋ) និងសភាជាតិ ( សភាតំណាងរាស្ត្រ)" ។ ដូចនេះការយល់ព្រមទៅលើសេចក្តីព្រាងច្បាប់នោះវាអាស្រ័យនឹងប្រមុខរដ្ឋ ។

ជាទូទៅ ការយល់ព្រមទៅលើសេចក្តីព្រាងច្បាប់ធ្វើឡើងដោយប្រមុខរដ្ឋ ដូចជាប្រទេសកម្ពុជាជាដើម ប្រមុខរដ្ឋជាអ្នកចុះហត្ថលេខា ប៉ុន្តែពុំបានកំណត់រយៈពេលប៉ុន្មានថ្ងៃនោះទេ ក្នុងការចុះហត្ថលេខាទៅលើសេចក្តីព្រាងច្បាប់ដែលបន្ទាប់ពីអនុម័តដោយរដ្ឋសភាជាតិ ។ គឺវាគ្រាន់តែនិយាយជាចំហរ ដែលបានកំណត់ក្នុង**មាត្រា ៩៣** នៃរដ្ឋធម្មនុញ្ញថា "ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល ១០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល ២០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសឱ្យទាន់តាមពេលកំណត់ខាងលើ ។ ត្រង់នេះបញ្ជាក់ថាសេចក្តីព្រាងច្បាប់ ក្រោយពីឆ្លងកាត់សភាទាំងពីរមកត្រូវបញ្ជូនទៅព្រះមហាក្សត្រ ប៉ុន្តែរយៈពេលចន្លោះពីសភាទៅមហាក្សត្រពុំបានកំនត់ពេលទេ ។

ប៉ុន្តែសំរាប់ប្រទេសខ្លះ ដែលប្រមុខរដ្ឋពុំយល់ព្រមនោះត្រូវបញ្ជូនត្រលប់មកវិញ ដូចជាសហរដ្ឋអាមេរិកជាដើម (មើលបំណកស្រាយរូបទី ១៣) ។ ក្នុងករណីរបៀបនេះគេបានកំណត់រយៈពេល គឺច្បាប់ដែលអនុម័តរួចហើយ ដោយសភាទាំងពីរត្រូវបញ្ជូនទៅប្រធានាធិបតីចុះហត្ថលេខាក្នុងរយៈពេល ១០ ថ្ងៃ ។

ការប្រកាសនៃច្បាប់ (Promulgation) នេះជាពាក្យដែលចេញមកពីអក្សរឡាតាំងថា "Promulgatio" មានន័យថា "**ការប្រកាស**" ។ ដូចនេះការប្រកាសនៃច្បាប់វាជាការយល់ព្រមនៃសេចក្តីព្រាងច្បាប់ ដែលធ្វើឡើងដោយប្រមុខរដ្ឋក្នុងការកំណត់រយៈពេលពិតប្រាកដដោយរដ្ឋធម្មនុញ្ញ។

ការបោះផ្សាយនៃច្បាប់ វាជាការបោះពុម្ពនូវអត្ថបទច្បាប់ជាផ្លូវការ ដោយកំណត់កាលបរិច្ឆេទនៃការធ្វើសកម្មភាពរបស់ច្បាប់នោះ ចាប់ពីថ្ងៃណាដល់ថ្ងៃណា. ទីកន្លែង ..... ដូចមាត្រា ៩៣ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ស្រាប់ ។

**៦. លក្ខណៈពិសេសនៃដំណើរការនីតិកម្មក្នុងវិស័យហិរញ្ញវត្ថុ** : ការអនុម័តច្បាប់ទូទៅ ឬច្បាប់ធម្មតា គឺរដ្ឋសភាពុំមានកំណត់រយៈពេលច្បាស់លាស់ទេ ប៉ុន្តែបើច្បាប់ដែលទាក់ទិននឹងហិរញ្ញវត្ថុរដ្ឋសភានៃប្រទេសនីមួយៗ ពុំអាចផ្តល់ពេលវេលាតាមទំនើងចិត្តក្នុងការអូសបន្លាយពេលនោះបានទេ (មើលមាត្រា ១១៣ នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣) ។ ហិរញ្ញវត្ថុជាដង្ហើមរបស់រដ្ឋដែលមានការចាប់អារម្មណ៍ក្នុងរយៈពេលចុងក្រោយនៃសតវត្សយើងនេះ ។ ការរាប់ចូលវិស័យហិរញ្ញវត្ថុជាលក្ខណៈពិសេសក្នុងការអនុម័តច្បាប់ទាំងឡាយទៅលើវានេះ ពីព្រោះថាថវិកាជាធាតុចាំបាច់សំរាប់ឱ្យរដ្ឋដំណើរការបាន ឬពុំបាន ។ ដូចនេះការអនុម័តច្បាប់ទៅលើវិស័យហិរញ្ញវត្ថុ ត្រូវកំណត់ពេលវេលាច្បាស់លាស់ណាស់ ហើយមានលក្ខណៈពិសេសទៀតផងទៅតាមប្រទេសនីមួយៗ ដូចជា**មាត្រា ៩០**

រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ក្នុងវាក្យខ័ណ្ឌទីពីរថា "រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ" ។ រីឯការធ្វើពង្រាងច្បាប់ត្រូវរៀបចំឡើងពីស្ថាប័ន ដែលបានកំណត់ដោយច្បាប់មួយពិតប្រាកដ ហើយកំណត់រយៈពេលក្នុងការអនុម័តទៅលើពង្រាងច្បាប់នោះនៅក្នុងរដ្ឋសភា ដូចជាក្នុងសភាជាន់ទាបរបស់អង់គ្លេសពិភាក្សាមិនលើស ២៦ ថ្ងៃ, ក្នុងសភាជាន់ទាប បារាំងមិនលើស ៤០ ថ្ងៃ ឯនៅព្រឹទ្ធសភាបារាំងមិនលើស ១៥ ថ្ងៃ។ ក្រៅពីនេះការអនុម័តច្បាប់ហិរញ្ញវត្ថុមានលក្ខណៈផ្សេងៗទៀត វាអាស្រ័យនឹងការិយបរិច្ឆេទ (Financial Period) របស់គេសំរាប់ឆ្នាំនីមួយៗនៃគ្រប់ប្រទេស ដូចជាប្រទេសកម្ពុជា មាត្រាទី ៤ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ អនុម័តថ្ងៃ ២៨ ខែធ្នូ ១៩៩៣ កំណត់ថា "ឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី ០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ"។ ត្រង់មាត្រានេះគឺបញ្ជាក់ថាការអនុម័តច្បាប់ស្តីពីថវិកា គឺត្រូវធ្វើឱ្យបានមុនដំណាច់ឆ្នាំនីមួយៗ ប៉ុន្តែរយៈពេលអនុម័តពុំបានកំណត់ទេសំរាប់ប្រទេសកម្ពុជាទៅលើសភានីមួយៗ ប៉ុន្តែកំណត់រយៈពេលរួម (សភាទាំងពីរ) ដូចមាត្រា ១១៣ នៃរដ្ឋធម្មនុញ្ញបានកំណត់ស្រាប់ ។

**ច. លក្ខណៈពិសេសៗនៃការអនុម័តទៅលើសេចក្តីព្រាងច្បាប់ទាំងឡាយ និងការអនុម័តច្បាប់ធម្មនុញ្ញ ឬច្បាប់ការិតនានា:** ជាទូទៅច្បាប់ដែលរដ្ឋសភាត្រូវអនុម័តមានលក្ខណៈបីក្រុមធំៗគឺ : ច្បាប់ធម្មនុញ្ញ (ដូចជាច្បាប់ធ្វើវិសោធនកម្ម...) ច្បាប់ការិត ឬច្បាប់ពិសេស (ដូចជាច្បាប់ថវិកា, ច្បាប់លើកលែងទោស....) និងច្បាប់ធម្មតា (ច្បាប់នានាដែលពុំបានរាប់បញ្ចូលក្នុងក្រុមទាំងពីរ) ។ សូមបញ្ជាក់ថា ក្នុងន័យនេះ ការបកស្រាយតែអំពីនីតិវិធីនៃការអនុម័តទៅលើសេចក្តីព្រាងច្បាប់តែប៉ុណ្ណោះ ។ ចំពោះការអនុម័តច្បាប់ទៅលើច្បាប់ធម្មនុញ្ញ ឬច្បាប់ពិសេស និងច្បាប់ធម្មតាមានខ្លឹមសារផ្សេងពីគ្នា គឺថាការអនុម័តច្បាប់ធម្មនុញ្ញ គឺជាការអនុម័តទៅលើមាត្រានៃរដ្ឋធម្មនុញ្ញ ដែលបន្ទាប់ពីមានការធ្វើវិសោធនកម្ម (ការធ្វើវិសោធនកម្មទៅលើមាត្រានៃរដ្ឋធម្មនុញ្ញ) ហើយមានសំលេងពីរភាគបីនៃសមាជិកទាំងមូល រីឯការអនុម័តច្បាប់ការិត គឺជាការអនុម័តទៅលើច្បាប់ទាំងឡាយណាដែលរដ្ឋធម្មនុញ្ញ (ច្បាប់គ្រឹះ) បានផ្តុកផ្តាក់ទៅអង្គការណាមួយជាអ្នកមានសមត្ថកិច្ច ចាំបាច់សំរាប់អនុម័ត

(ករណីមានសភាពីរ) ក្នុងលក្ខណៈពិសេស (ការកំណត់ស្ថាប័នណាមួយជាអ្នកធ្វើពង្រាងច្បាប់) ហើយត្រូវការសំលេងពីរភាគបីនៃសមាជិកទាំងមូល ។ សំរាប់ប្រទេសកម្ពុជា នីតិវិធីនៃការអនុម័តច្បាប់ធម្មនុញ្ញត្រូវមានសំលេងពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល រីឯច្បាប់ពិសេស ឬច្បាប់ក៏រិត និងច្បាប់ធម្មតាមានសំលេងលើសហាសិបភាគរយ ឬ ៥០ + ១ តែប៉ុណ្ណោះ ។ ចំពោះការអនុម័តរាល់សេចក្តីព្រាងច្បាប់ធម្មនុញ្ញ និងច្បាប់ក៏រិតវាត្រូវបានកំណត់ដោយនីតិវិធីមួយយ៉ាងត្រឹមត្រូវ ក្នុងការអនុម័តទៅលើច្បាប់ទាំងនេះ ដោយឈរលើកូរ៉ុម **ឬសំលេងចាំបាច់** ។ ការអនុម័តនេះវាអាស្រ័យនឹងសិទ្ធិនៃការផ្តើមគំនិតធ្វើច្បាប់ ។ នីតិវិធីក្នុងការអនុម័តនៃច្បាប់ទូទៅ ឬច្បាប់ធម្មតាវាមាននីតិវិធីរបស់វាគឺផ្តល់លទ្ធភាពទៅឱ្យសមាជិករដ្ឋសភា ក្នុងសម័យប្រជុំពេញអង្គ ។ ដូចជាវាក្យខ័ណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញកម្ពុជា ក្នុង**មាត្រា ៨៨** បានកំណត់ថា "ការប្រជុំរដ្ឋសភានឹងយកជាការបានលុះត្រាតែមានកូរ៉ុម ៧/១០ នៃសមាជិករដ្ឋសភាទាំងមូល"។ ហើយការអនុម័តដោយយកសំលេងលើសពីហាសិបភាគរយនៃសមាជិក សំរាប់តែច្បាប់ធម្មតា ឬច្បាប់ក៏រិតប៉ុណ្ណោះ ប៉ុន្តែក្នុងការសំរេចទៅលើច្បាប់ធម្មនុញ្ញ ដូចជាការធ្វើវិសោធនកម្មវាមានសំលេង ២/៣ នៃសមាជិករដ្ឋសភា ដែលបានកំណត់ក្នុង**មាត្រា ១៥១** ថា "ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភាតាមមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិកទាំងមូល"។ ចំពោះការអនុម័តទៅលើច្បាប់ក៏រិតផ្សេងៗ ឬហៅថាពិសេស ដូចជា**មាត្រា ៩០** បានកំណត់ថា "រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំនត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើន ពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល" ។ នៅក្នុងវាក្យខ័ណ្ឌទី ៧ នៃមាត្រា ៩០ នេះ បានកំនត់អំពីសំលេងបោះឆ្នោត ដោយពុំមានចំនួនកំនត់ ២/៣ នោះឡើយ គឺអាចយកជាការបានតែត្រឹម ៥០ + ១ តែប៉ុណ្ណោះ ។ ប៉ុន្តែសំរាប់ធ្វើការចោទប្រកាន់ណាមួយទៅលើតំណាងរាស្ត្រ ត្រូវសំរេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ដែលក្នុងនោះបានកំណត់នីតិវិធីនៃការប្រជុំគណៈកម្មាធិការ ក្នុងប្រការ ១០ វាក្យខ័ណ្ឌទីបីតាមបទបញ្ជាផ្ទៃក្នុងរដ្ឋសភាថា "កូរ៉ុមសំរាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការនានា ត្រូវឱ្យមានលើសពីពាក់កណ្តាលនៃចំនួនសមាជិក។ ហើយសេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នេះត្រូវបានយកទៅឱ្យសភាពេញអង្គពិនិត្យ ដោយយកសំលេង ២/៣ នៃសមាជិកសភាទាំងមូល" ។ ដូចនេះការអនុម័តទៅលើច្បាប់ពិសេស ឬច្បាប់គំរិត និងច្បាប់ធម្មនុញ្ញ គេច្រើនកំណត់ទៅលើសំលេង ២/៣ ឬភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ ផ្ទុយទៅវិញកម្ពុជាពុំបានគិតពីច្បាប់គំរិត ឬច្បាប់ពិសេសនោះទេ គឺសំលេងក្នុងការអនុម័តដូចៗគ្នា លើកលែងតែច្បាប់ធម្មនុញ្ញប៉ុណ្ណោះ ។

**ខ. លក្ខណៈពិសេសៗនៃសណ្តាប់ធ្នាប់ក្នុងការធ្វើសច្ចាប័ន និងអបរូបករណ៍លើសន្ធិសញ្ញាអន្តរជាតិ :** យើងបានដឹងហើយថា រដ្ឋសភាជាអ្នកបំពេញកិច្ចក្នុងវិស័យនេះ ដូចមាត្រា ៩០ វាក្យខ័ណ្ឌទី ៥ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ" ។ ប៉ុន្តែនីតិវិធីរបស់វាបានកំណត់ក្នុងវាក្យខ័ណ្ឌទី ៧ នៃមាត្រាដដែលនោះថា "ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល" ។ រីឯនីតិវិធីលំអិត

ក្នុងការធ្វើសេចក្តីព្រាងច្បាប់នោះ ពុំបានកំណត់ច្បាស់លាស់ទេ ។ ប៉ុន្តែជាទូទៅពង្រាងច្បាប់ត្រូវធ្វើឡើងដោយសាមីស្ថាប័ន។ សូមបញ្ជាក់ផងដែរថា នីតិវិធីក្នុងការអនុម័តច្បាប់កំណត់ ( ច្បាប់ពិសេស) និងការធ្វើសច្ចាប័នសំរាប់ប្រទេសកម្ពុជាពុំមាននីតិវិធីប្លែកគ្នាទេ ។

## ៥. នីតិវិធីពិសេសៗរបស់រដ្ឋសភា (Special Procedure of Legisletive Inquiry)

ក្នុងការអនុម័តរាល់កិច្ចការចាំបាច់ធំៗក្នុងវិស័យដឹកនាំរបស់រដ្ឋនីមួយៗ រដ្ឋសភាមាននីតិវិធីពិសេសជាច្រើនទៀតដូចជា :

**ក. នីតិវិធីជំរើស និងចំណាត់តាំង** : យើងបានដឹងគោលការណ៍មួយចំនួនរួចហើយ ដែលមាននីតិវិធីរបស់វាគឺការបោះឆ្នោតដោយយកសំលេង ។ ប៉ុន្តែនីតិវិធីផ្សេងមួយទៀតនោះ គឺជំរើស និងចំណាត់តាំង ។ ដូចនេះពាក្យថាជ្រើសរើស គឺជំរើសមួយណាក្នុងចំណោមមួយណា ? រីឯចាត់តាំងត្រូវយកមួយណា ? ក្នុងចំណោមទាំងនោះ ?។ នីតិវិធីជំរើស និងនីតិវិធីចំណាត់តាំង គឺជាលទ្ធផលចុងក្រោយបង្អស់នៃសេចក្តីសំរេចរបស់បុគ្គល ឬអង្គការក្នុងការជ្រើសតាំងបុគ្គលឱ្យមានដំណែងណាមួយស្ថិតក្នុងក្របខ័ណ្ឌនៃឋានានុក្រម ដែលមានច្បាប់បញ្ញត្តិជាបង្អែក ។

ចំពោះការជ្រើសរើស អត្ថន័យរបស់វាបានត្រូវកំណត់តាមរយៈសភាធម្មនុញ្ញ ដែលបានជំរាបជូនរួចទៅហើយ ។ ដូចជា**ប្រការទី ២** នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាកម្ពុជា ១៩៩៣ បានកំណត់ថា "នៅពេលបើកសម័យប្រជុំលើកទី ១ នៃនីតិកាលនីមួយៗរដ្ឋសភា ត្រូវចាប់ដំណើរការក្រោមអធិបតីភាពនៃប្រធានបណ្តោះអាសន្នមួយរូប ដែលជាបេក្ខជនជាប់ឆ្នោតដែលមានអាយុច្រើនជាងគេ ហើយដែលឥតមានគេប្តឹងតវ៉ា ហើយមានសមាជិក ៥ រូប ដែលជាបេក្ខជនជាប់ឆ្នោតដែលមានអាយុតិចជាងគេ ហើយដែលឥតមានគេប្តឹងតវ៉ា ជាលេខាធិការដើម្បីជួយប្រធានក្នុងការងារ ។

ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករដ្ឋសភាខាងលើនេះ រដ្ឋសភាត្រូវចាប់ផ្តើមធ្វើការដូចតទៅ :

ក- ប្រកាសតាំងភ្លាមនូវតំណាងរាស្ត្រពេញសិទ្ធិ ។

ខ- ជ្រើសតាំងប្រធាន និងអនុប្រធានទាំងពីររបស់រដ្ឋសភា ។

រដ្ឋសភាមិនអាចជជែកពិភាក្សាគ្នាអ្វីឡើយ ក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិករដ្ឋសភា" ។ ប៉ុន្តែតាមប្រការខាងលើនេះ ពុំបានកំណត់ច្បាស់នូវលក្ខណៈនៃរបៀបជ្រើសរើសជាបេក្ខជន ចំពោះបេក្ខភាពអនុប្រធានទាំងពីរទេ ។ ប៉ុន្តែនីតិវិធីនៃការជ្រើសតាំងប្រធានគណៈកម្មការនានា ធ្វើឡើងតាមរយៈបោះឆ្នោត ដូចប្រការទី ១០ នៃបញ្ញត្តិដដែលនោះបានកំណត់ថា "គណៈកម្មការនីមួយៗត្រូវជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូប ដោយវិធីបោះ ឆ្នោត ។

គណៈកម្មការនីមួយៗមានសមាជិកយ៉ាងតិច ៧ រូប ។

កូរ៉ុមសំរាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការនានា ត្រូវឱ្យមានលើសពីពាក់កណ្តាលនៃចំនួនសមាជិក" ។ សរុបទៅការចាត់តាំង គឺជាភារកិច្ចរបស់ប្រធាន ឬបុគ្គលដែលបានកំណត់ដោយបញ្ញត្តិច្បាស់លាស់ទៅលើសិទ្ធិចាត់តាំង ឬចំណាត់តាំងដែលជា**លទ្ធផលចុងក្រោយនៃជំរើស ដែលពុំមែនជាលទ្ធផលនៃការបោះឆ្នោតទេ តែជាលទ្ធផលនៃការសំរេចរបស់ក្រុមការងារ ឬបុគ្គលណាមួយតែប៉ុណ្ណោះ** ។ ប៉ុន្តែនីតិវិធីរបស់វាពុំមានលក្ខណៈដូចគ្នាទេ នៅពេលខ្លះបន្ទាប់ពីចាត់តាំងគេត្រូវបោះឆ្នោតទៅស្ថាប័នផ្សេងទៀត និងមានលក្ខណៈគ្រលប់ ដើម្បីឱ្យការតែងតាំង ឬការជ្រើសរើស (បោះឆ្នោត) នោះជាលទ្ធផលពិតចុងក្រោយ ដូចមាត្រា ១១៩ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បញ្ជាក់ថាគណៈបក្សដែលឈ្នះឆ្នោតមានអាសនៈច្រើនក្នុងរដ្ឋសភា ត្រូវចាត់តាំងបុគ្គលម្នាក់មកសុំសេចក្តីទុកចិត្តពីរដ្ឋសភាដើម្បីជ្រើសតាំងជានាយករដ្ឋមន្ត្រី រីឯនីតិវិធីនេះត្រូវបោះឆ្នោតយក សំលេង ២/៣ នៃសមាជិកទាំងមូល ។ បន្ទាប់ពីមានការយល់ព្រមពីរដ្ឋសភា នោះត្រូវមានការតែងតាំងជាផ្លូវការពីព្រះមហាក្សត្រ។ ប៉ុន្តែចំពោះការតែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំង ៩ រូបវិញ បានកំណត់តែត្រឹមការតែងតាំង ឬជ្រើសតាំងទេ តែនីតិវិធីរបស់វានោះពុំបានកំណត់ច្បាស់លាស់ទេ ( មាត្រា ១៣៧ នៃរដ្ឋធម្មនុញ្ញកម្ពុជា) ។

**ខ. នីតិវិធីត្រួតពិនិត្យចំពោះរបាយការណ៍របស់រដ្ឋាភិបាល និងសមាជិករបស់រដ្ឋាភិបាល :** នេះជានីតិវិធីមួយដែលពុំអាស្រ័យនឹងទំរង់គ្រប់គ្រងរបស់រដ្ឋទេ ប៉ុន្តែវាអាស្រ័យនឹងរបបនយោបាយ ។ ជាទូទៅភាពផ្តល់ពត៌មានរបស់រដ្ឋាភិបាល និងរដ្ឋមន្ត្រី ពុំមែនជានិច្ចកាលផ្តល់ទៅតែរដ្ឋសភានោះទេ

ប៉ុន្តែវាមានន័យថា ភាពទទួលខុសត្រូវរបស់វាទាំងនោះចំពោះមុខរដ្ឋសភា ក្នុងរបបសភានិយម ឬទំរង់ចំរុះ ។ ដូច**មាត្រា ១២១** នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូប១នៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភា អំពីការដែលខ្លួនបានប្រព្រឹត្ត"។ ប៉ុន្តែការត្រួតពិនិត្យរបស់រដ្ឋសភានោះត្រូវបានកំណត់ក្នុង**មាត្រា ៩៦** វាក្យខ័ណ្ឌទីមួយកំនត់ថា "តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល"។ រីឯ**មាត្រា ៩៧** កំណត់ថា "គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន"។ ចំណែកនីតិវិធីនៃការត្រួតពិនិត្យនោះ ត្រូវបានកំណត់ក្នុង**មាត្រា ៩៨** ថា "រដ្ឋសភាអាចទំលាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទំលាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញ្ញត្តិបន្ទោសតាមសម្លេងឆ្នោត ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន"។ ដូចនេះយើងឃើញថាសំលេងពីរភាគបី និងចំនួនសាមសិបនាក់ ក្នុងមាត្រា ៩៨ ជានីតិវិធីក្នុងការត្រួតពិនិត្យរបស់រដ្ឋសភាចំពោះរដ្ឋាភិបាល ។

**ឆ. នីតិវិធីនៃការត្រួតពិនិត្យចំពោះនីតិកម្មបន្ទេរ** (Delegated Legislation) : នេះគឺជាការផ្តល់សិទ្ធអំណាចនីតិកម្មរបស់រដ្ឋសភាទៅឱ្យអង្គការមួយ គឺរដ្ឋាភិបាលតាមរយៈសិទ្ធិនីតិកម្មបន្ទេរដែលអាចអនុម័តច្បាប់ខ្លះបាន ដោយអាស្រ័យនឹងច្បាប់រដ្ឋធម្មនុញ្ញបានកំណត់ ។ ប៉ុន្តែសំរាប់ប្រទេសជាច្រើនពុំសូវមានលក្ខណៈនេះទេ ។ នេះគឺជាការអនុម័តតាមបែបបន្ទេរនីតិកម្ម ដែលមានសិទ្ធិអំណាចបន្ទេរ (Delegation of Power) ។ ប៉ុន្តែការផ្តល់សិទ្ធិអំណាចរបៀបនេះ ពុំមែនមានន័យថារដ្ឋសភាពុំគិតដល់បញ្ហាត្រួតពិនិត្យឡើយ ។ ជាការចាំបាច់ណាស់ក្នុងការត្រួតពិនិត្យទៅលើច្បាប់ ដែលអនុម័តតាមលក្ខណៈបន្ទេរនីតិកម្មនេះ ព្រោះថាស្ថាប័នដែលធ្វើច្បាប់នោះ វាត្រូវបានបន្ទេរដោយអង្គការនីតិបញ្ញត្តិតាមច្បាប់កំណត់មួយ ប៉ុន្តែពុំមែនផ្ទេរនូវអំណាចនីតិបញ្ញត្តិទាំងអស់នោះទេ គឺគ្រាន់តែផ្តល់នូវសមត្ថកិច្ចមួយចំណែកក្នុងការបង្កើតច្បាប់ណាមួយ ដែលមានកំណត់ដោយច្បាប់នូវកម្មវត្ថុពិតប្រាកដ ។ វិធីនេះ គឺត្រូវត្រួតពិនិត្យបានដោយកំណត់រយៈពេលពិតប្រាកដ ដើម្បីធ្វើការយល់ព្រម ឬ

បដិសេធន៍របស់រដ្ឋសភាទៅលើបទដ្ឋានកិច្ចទាំងឡាយ ដែលអនុម័តដោយរដ្ឋាភិបាល ។ សូមចំណាំផងដែរថា ការបន្ទេរនៃនីតិកម្មពុំមានលក្ខណៈដូចនីតិវិធីនៃការត្រួតពិនិត្យនីតិកម្មទេ **ពីព្រោះការបន្ទេរជាបញ្ញត្តិច្បាប់ ដែលផ្តល់សិទ្ធិអំណាចទៅឱ្យអង្គការណាមួយក្នុងការបង្កើតបទដ្ឋានកិច្ច រីឯនីតិវិធីចំពោះបន្ទេរនីតិកម្មគឺជារបៀបអនុម័តឱ្យបាន ឬពុំបានទៅលើសេចក្តីព្រាង ឬបទដ្ឋានកិច្ចដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ចនោះ** ។ ដូចជា**មាត្រា ៧៦** រដ្ឋធម្មនុញ្ញអ៊ីតាលី ថ្ងៃ ២២ ខែធ្នូ ១៩៤៧ បញ្ញត្តិថា "ការបំពេញកិច្ចជាមុខងារបន្ទេរនីតិកម្មអាចប្រគល់ឱ្យទៅរដ្ឋាភិបាល ដែលកិច្ចការនោះត្រូវបានកំនត់បញ្ជាក់យ៉ាងច្បាស់នូវគោលការណ៍ និងប្រភេទនានាក្នុងក្របខ័ណ្ឌបន្ទេរ ដោយបានបញ្ជាក់នូវពេលកំនត់ត្រឹមត្រូវចំពោះកម្មវត្ថុ ឬវិស័យណាមួយច្បាស់លាស់" ។ ផ្ទុយទៅវិញសំរាប់កម្ពុជា រដ្ឋាភិបាលពុំមានសិទ្ធិបន្ទេរនីតិកម្មទេ ។

**ឃ. នីតិវិធីចោទសួររបស់សមាជិករដ្ឋសភា** (Parliamentary question)**:** នេះជាការប្រាស្រ័យទាក់ទងរបស់សមាជិករដ្ឋសភា ក្នុងលក្ខណៈឯកជន ឬជាពួក ជាក្រុមទៅនឹងសមាជិក ឬស្ថាប័នផ្សេងៗដែលបានកំណត់ដោយច្បាប់ ។ការប្រាស្រ័យនេះមានលក្ខណៈពីរប្រភេទគឺ: **ការដេញដោល** និង**ការដាក់សំណួរ** ។

**ឃ₁.ការដេញដោល :** វាគឺជាការប្រាស្រ័យរបស់រដ្ឋសភាទាំងអស់ ឬក៏ក្រុមនៃសមាជិករដ្ឋសភាតាមកិច្ចការ ឬបញ្ហានយោបាយធំៗដោយការប្រាស្រ័យនោះ បានដាក់បញ្ជូនទៅក្នុងរបៀបវារៈរបស់រដ្ឋសភា ។ ការដេញដោលអាចបើកឡើងនូវការជជែកជាមួយនឹងលទ្ធភាពបោះឆ្នោត តាមការវាយតំលៃនៃចំលើយ ដូច**មាត្រា ៩៦** នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះត្រូវសរសេរជាលាយល័ក្ខអក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។ ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។

ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយល័ក្ខអក្សរ ។

ចម្លើយខាងលើនេះត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីបានទទួលសំនួរ ។ ចំពោះចម្លើយផ្ទាល់មាត់ប្រធានរដ្ឋសភាអាចសំរេចបើកឱ្យមាន ឬមិនឱ្យមានការជជែកដេញដោល ។ បើគ្មានការបើកឱ្យជជែកដេញដោលទេនោះ ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីនឹងបញ្ចប់សំនួរតែម្តង ។

បើមានការបើកឱ្យជជែកដោយម្ចាស់សំណួរវាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សំរាប់ការឆ្លើយសំនួរ ។

ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ធ្វើសំណួរខាងលើនេះមិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ" ។ នៅក្នុងប្រទេសដែលប្រកាន់ទំរង់គ្រប់គ្រងតាមបែបសភានិយម ឬទំរង់ចំរុះ ការបោះឆ្នោតធ្វើឡើងតាមបញ្ហាមួយ អំពីសេចក្តីទុកចិត្តទៅលើរដ្ឋាភិបាល និងសមាជិករបស់គេ ដូចវាក្យខ័ណ្ឌទី ៨ នៃ**មាត្រា ៩០** រដ្ឋធម្មនុញ្ញកម្ពុជាបានកំនត់ថា "រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើន ពីរភាគបីនៃសមាជិកសភាទាំងមូល" ។ និងគណៈកម្មការនានារបស់រដ្ឋសភាក៏មានសិទ្ធិត្រួតពិនិត្យផងដែរ ដូច**មាត្រា ៩៧** រដ្ឋធម្មនុញ្ញបានកំណត់ថា "គណៈកម្មការទាំងឡាយរបស់រដ្ឋសភាអាច អញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន" ។និង**មាត្រា ៩៨** កំណត់ថា "រដ្ឋសភាអាចទំលាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទំលាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញ្ញត្តិបន្ទោសតាមសម្លេងឆ្នោតពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន" ។

**ឃ២.ការចោទសំណួរ** : គឺជាបញ្ហាមួយដែលតំណាងរាស្ត្រត្រូវធ្វើជាលាយល័ក្ខអក្សរ ឬក៏ផ្ទាល់មាត់តាមបញ្ហាណាមួយ ដោយច្បាស់លាស់សំរាប់ដាក់ទៅរដ្ឋាភិបាល ឬសមាជិករដ្ឋាភិបាលដែលពាក់ព័ន្ធលើបញ្ហានោះ ដូចមានចែងក្នុងមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ ស្រាប់ ។

**ង. ការស៊ើបអង្កេតនានារបស់រដ្ឋសភា** (Investigating Parliament) : នេះគឺជាសកម្មភាពត្រួតពិនិត្យមួយដ៏សំខាន់បំផុតរបស់រដ្ឋសភា ដែលពុំមែនធ្វើឡើងតាមរយៈជាសំណួរ (questionnaires) ដូចដែលបានរៀបរាប់ខាងលើនោះទេ ប៉ុន្តែជាសិទ្ធិអង្កេតដែលប្រើប្រាស់ក្នុងរដ្ឋសភា ដោយផ្តល់សិទ្ធិបង្កើតគណៈកម្មការអង្កេតនានា ជាចាំបាច់នៅពេលមានកើតបញ្ហាគតិយុត្តិក្នុងស្ថាប័នរបស់រដ្ឋ ។

គណៈកម្មាធិការអង្កេត ( គណៈកម្មការ ) នេះចាំបាច់ស្វែងរកភស្តុតាង និងរៀបរៀងរបាយការណ៍ដាក់ជូនសភាពេញអង្គដើម្បីធ្វើការសំរេចជាចុងក្រោយ ។ ប៉ុន្តែការស៊ើបអង្កេតរបស់រដ្ឋសភាគេកំរជួបប្រទះណាស់ ។ ដោយឡែកប្រទេសជឿនលឿនខ្លះៗ រដ្ឋធម្មនុញ្ញរបស់គេបានកំណត់នូវការបង្កើតគណៈកម្មការអង្កេតនេះសំរាប់តំរូវទៅលើអំណាចនីតិប្រតិបត្តិ ដោយមានស្ថាប័នគតិយុត្តិមួយចំនួនជាអ្នកជំនួយការដូចជា : តុលាការ, រដ្ឋបាល... ដើម្បីផ្តល់នូវភ័ស្តុតាងច្បាស់លាស់ ។ លក្ខណៈនេះមានដូចជាប្រទេសអាល្លឺម៉ង់ ( មាត្រា ៤៤ រដ្ឋធម្មនុញ្ញសហព័ន្ធ) និងប្រទេសដទៃទៀត ដែលរដ្ឋធម្មនុញ្ញរបស់គេកំណត់នូវសិទ្ធិស៊ើបអង្កេតនេះ ។

**ច. នីតិវិធីនៃការទទួលខុសត្រូវនយោបាយរបស់រដ្ឋាភិបាល** : ភាពទទួលខុសត្រូវនេះយើងបានយល់ខ្លះៗតាមរយៈបំណកស្រាយពីខាងដើមខ្លះមកហើយ ។ ភាពទទួលខុសត្រូវរបស់រដ្ឋាភិបាលនេះវាកើតមានសំរាប់ប្រទេសប្រកាន់របបគ្រប់គ្រងបែបសភានិយម និងទំរង់ចំរុះផងដែរ ។ ចំពោះភាពទទួលខុសត្រូវរបស់រដ្ឋាភិបាល និងសមាជិករបស់គេក្នុងវិស័យនយោបាយដូច **មាត្រា ១២១** នៃរដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ថា "សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភា អំពីការដែលខ្លួនបានប្រព្រឹត្ត" ។ រីឯនីតិវិធីនៃការទទួលខុសត្រូវបានកំណត់ដោយ **មាត្រា ១២៦** នៃរដ្ឋធម្មនុញ្ញថា "សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះ និងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសំរេចក្នុងរឿងនេះដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល" ។ ក្នុងមាត្រានេះ បានកំណត់នៅវាក្យខ័ណ្ឌចុងក្រោយនូវនីតិវិធីនៃការទទួលខុសត្រូវ ។ ប៉ុន្តែជាទូទៅនីតិវិធីនៃការទទួលខុសត្រូវរបស់រដ្ឋាភិបាល ចំពោះរដ្ឋសភាមាននីតិវិធីពីរប្រភេទគឺ : **ការសុំសេចក្តីមិនទុកចិត្ត** និង**ការបដិសេធន៍លើសេចក្តីទុកចិត្ត** ។

**ច១. ការសុំសេចក្តីមិនទុកចិត្ត** (Vote of no-confidence) : វាគឺជាលទ្ធផលនៃការផ្តើមគំនិតមួយរបស់រដ្ឋសភា (Result of Parliamentary Initiative) ។ នេះជាគោលការណ៍មួយដែលប្រទេសខ្លះទទួលយកដោយមានការកំណត់ក្នុងរដ្ឋធម្មនុញ្ញ ដើម្បីឱ្យមានស្ថេរភាពរបស់រដ្ឋាភិបាល ។ លក្ខណៈនេះគឺតំរូវឱ្យមានការគាំទ្រពីសមាជិករដ្ឋសភា ទៅលើរដ្ឋាភិបាលតាមរយៈការពិភាក្សានៃសំលេងភាគច្រើន ឬសំលេងភាគច្រើនដាច់ខាតក្នុងរដ្ឋសភា ។ ត្រង់នេះគឺមានន័យថា ការកើតមាន "**ការសុំសេចក្តីមិនទុកចិត្ត**" (Vote of no-confidence) នៅពេលដែលរដ្ឋសភាពុំបានអនុម័តទៅលើសេចក្តីបដិសេធន៍នៃសេចក្តីសំរេចណាមួយជាធម្មតានោះទេ តែវាជាអំពើមួយដែលរដ្ឋសភាបានកំណត់នូវប្រមុខរដ្ឋាភិបាលថ្មី ។ អត្ថន័យនេះ តាមវាក្យខ័ណ្ឌទីមួយ **មាត្រា ៦៧** ច្បាប់គ្រឹះសហព័ន្ធអាល្លឺម៉ង់បញ្ជាក់ថា សភាប៊ុនដេស្តាដអាចសំដែងការមិនទុកចិត្តចំពោះអធិការបតីសហព័ន្ធ (នាយករដ្ឋមន្ត្រី) បានតាមវិធីបោះឆ្នោតនៃសំលេងភាគច្រើនរបស់សមាជិកខ្លួនទាំងអស់ ហើយធ្វើការសំណូមពរទៅប្រធានាធិបតីសហព័ន្ធអំពីការដកតំណែងប្រមុខរដ្ឋាភិបាល ។ ហើយប្រធានាធិបតីសន្យាធ្វើកិច្ចការនោះ និងតែងតាំងប្រមុខរដ្ឋាភិបាលថ្មី ។ ប្រព័ន្ធដំណោះស្រាយរបៀបនេះវាអាចគេចផុតពីវិបត្តិរដ្ឋាភិបាល ដែលពុំមានន័យថារដ្ឋសភាផ្តួលរំលំរដ្ឋាភិបាលនោះទេ ។ ដូចនេះនីតិវិធីនៃការសុំសេចក្តីមិនទុកចិត្ត (Constructive Vote of no-Confidence) របស់រដ្ឋសភា វាជា**ភារកិច្ចឯកតោភាគីតែប៉ុណ្ណោះ** ។ ចំនុចនេះមានន័យថា**រដ្ឋសភាជាអ្នកផ្តើមគំនិតធ្វើ** ។

**ច២. ការបដិសេធន៍លើសេចក្តីទុកចិត្ត** (Refusal of Confidence) : នេះគឺមានន័យថា កាលណារដ្ឋាភិបាលបានដាក់ "**សំណួរអំពីសេចក្តីទុកចិត្ត**" ទៅលើរដ្ឋសភា ក្នុងនោះដោយផ្សារភ្ជាប់ជាមួយនឹងញត្តិណាមួយនៃការអនុម័ត ដែលរដ្ឋាភិបាលទទួលជោគជ័យលើរដ្ឋសភា ។ ល័ក្ខខ័ណ្ឌនេះជាមធ្យោបាយមួយដ៏មានឥទ្ធិពលរបស់រដ្ឋាភិបាលដាក់សម្ពាធទៅលើរដ្ឋសភា ជាពិសេសក្នុងល័ក្ខខ័ណ្ឌ

មួយចំនួនដូចជា : កាលណាមានវិបត្តិរដ្ឋាភិបាលនោះ អាចមានការរំលាយរដ្ឋសភា (សភាតំណាងរាស្ត្រ) ដែលគេហៅថា "**ការបដិសេធន៍លើសេចក្តីទុកចិត្ត**"។ ប៉ុន្តែនៅពេលខ្លះក៏ពុំត្រូវបានការយល់ព្រមដោយងាយស្រួលក្នុងការរំលាយរដ្ឋសភានោះដែរ ដែលគេច្រើនហៅថា "**ការបដិសេធន៍របស់រដ្ឋសភា**" (Repudiation of Parliament) ធ្វើឱ្យញ្ញត្តិ (Act) របស់រដ្ឋាភិបាលមានភាពអសកម្ម និងបន្តការតស៊ូនយោបាយរៀង១ខ្លួន។ យើងបានដឹងហើយថា រដ្ឋសភាទទួលយកនូវសេចក្តីទុកចិត្តរបស់រដ្ឋាភិបាល តែបើរដ្ឋាភិបាលប្រឆាំងទៅរដ្ឋសភាវិញនោះ រដ្ឋាភិបាលធ្វើញ្ញត្តិជំទាស់លើសេចក្តីទុកចិត្ត ឬហៅថាការបដិសេធន៍លើសេចក្តីទុកចិត្ត ។

**ឆ. អ៊ីមពិជ្ជមិន** (Impeachment) : នេះជានីតិវិធីមួយដែលមានលក្ខណៈពិសេសបំផុតដោយពុំមែនធ្វើឡើងសំរាប់បុគ្គលដែលជាមន្ត្រីរដ្ឋជាន់ខ្ពស់មានកំហុសខាងផ្នែកនយោបាយនោះទេ ប៉ុន្តែវាជាភាពទទួលខុសត្រូវតាម**ផ្លូវតតិយុត្តិ** (ច្បាប់) ដែលមន្ត្រីរដ្ឋក្នុងអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការត្រូវតែប្រឈមនឹងរដ្ឋសភា ។ "**អ៊ីមពិជ្ជមិន**" ជានីតិវិធីមួយដែលរដ្ឋសភាធ្វើការវិនិច្ឆ័យទៅលើមន្ត្រីរដ្ឋជាន់ខ្ពស់ ដោយមន្ត្រីទាំងនោះប្រព្រឹត្តខុសនូវគោលការណ៍ ឬក៏ខុសនឹងច្បាប់ទាំងឡាយដែលមានជាធរមាន ។ ការអនុវត្តតាមនីតិវិធីនេះជាប្រវត្តិសាស្ត្រមានដូចជា **អាមេរិក, ជប៉ុន, ចក្រភពអង់គ្លេស, ឥណ្ឌា**............ ។ល។ រីឯនីតិវិធីរបស់វាដូចជានៅអាមេរិក គឺសភាតំណាងរាស្ត្រជាអ្នកចោទប្រកាន់ តាមរយៈការផ្តើមគំនិតរបស់គណៈកម្មាធិការតតិយុត្តិ (House Judiciary Committee) របស់រដ្ឋសភាដែលធ្វើការចោទប្រកាន់តាមមាត្រានៃច្បាប់ "អ៊ីមពិជ្ជមិន" បន្ទាប់មកសភាតំណាងរាស្ត្រ (House of Repressentative) ពិភាក្សាដោយអនុម័តមតិភាគច្រើននោះបញ្ជូនទៅសភាជាន់ខ្ពស់ (Senate) ដែលជាអ្នកវិនិច្ឆ័យផ្ទាល់ ។ ប្រសិនបើធ្វើអ៊ីមពិជ្ជមិន ប្រធានាធិបតីនោះត្រូវប្រធានចៅ ក្រមនៃតុលាការជាន់ខ្ពស់ជាអធិបតីក្នុងព្រឹទ្ធសភា ។ ព្រឹទ្ធសភាត្រូវសំរេច ២/៣ នៃវត្តមានរបស់សមាជិកព្រឹទ្ធសភាដែលបានចូលរួម ដែលលក្ខណៈត្រង់នេះហើយបញ្ជាក់ថាព្រឹទ្ធសភាជាអ្នកវិនិច្ឆ័យ។ ក្រៅពីអ៊ីមពិជ្ជមិននៅមាននីតិវិធីផ្សេងទៀតដូចជា "ការពិភាក្សានៃបដ្តនាលិខិត" (Petition គឺជាលិខិតដែលធ្វើទៅអាជ្ញាធរមានសមត្ថកិច្ច ឬទៅសភាដើម្បីធ្វើការប្តឹង ឬបញ្ចេញមតិ) ដែលមាននៅប្រទេសខ្លះ ។ ការពិភាក្សានៃបដ្តនាលិខិតនេះវាជាគោលការណ៍នៃសិទ្ធិ

មនុស្សមួយដែរ ក្នុងការប្រាស្រ័យទាក់ទងជាមួយអង្គការដែលមានអំណាចជាន់ខ្ពស់របស់រដ្ឋ ។ ប៉ុន្តែសំរាប់ប្រទេសកម្ពុជា ពុំបានកំណត់នូវនីតិវិធីនេះច្បាស់លាស់ទេ គឺគ្រាន់តែផ្តល់សិទ្ធិតែប៉ុណ្ណោះ ដូចមាត្រា ១៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ថា "ព្រះមហាក្សត្រ ព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភា និងរដ្ឋសភាដោយព្រះរាជសារ ។ ព្រះរាជសារនេះ ព្រឹទ្ធសភា និងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ" ។ មួយវិញទៀត ដូចជាវាក្យខ័ណ្ឌទីពីរ មាត្រា ៣៥ កំណត់ថា "សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ" ។

ការកំនត់នូវនីតិវិធីក្នុងការដោះស្រាយតាមរយៈបដ្ឋនាលិខិតនេះ វាជាការគោរពសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋមួយយ៉ាងធំធេងក្នុងការការពារ ចំពោះរាល់សកម្មភាពរំលោភបំពានពីពួកបុគ្គលនានាដែលមានអំណាចបុណ្យស័ក្តខ្ពស់ៗ ឬពួកអ្នកមានទ្រព្យទាំងឡាយដែលអាងទ្រព្យសម្បត្តិ និងបក្សពួកនិយម ។

## ៦. ឧបករណ៍ជំនួយការនៃរដ្ឋសភា (Subsidiary organs of Parliament)

នេះគឺជាអង្គការផ្សេងៗដែលជាសេនាធិការ ឬជាស្ថាប័នសេវាកម្មផ្ទាល់របស់រដ្ឋសភា ដែលអង្គការនេះពុំមែនជាអ្នកសំរេចទេ តែជាអ្នកជំនួយការ (មើលរូបទី ១២) ។ ឧបករណ៍ ឬយន្តកម្មជួយដល់រដ្ឋសភាក្នុងផ្នែកបច្ចេកទេស, គ្រប់គ្រង, វិទ្យាសាស្ត្រ, នៅក្នុងកិច្ចការ ឬការងាររបស់រដ្ឋសភា គឺជួយដល់សភា, គណៈកម្មការ និងតំណាងរាស្ត្រ ។ លក្ខន្តិកៈនៃអង្គការនេះ ត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ ឬបទបញ្ជាផ្ទៃក្នុង ដែលជាការកំណត់សកម្មភាពនៃសណ្តាប់ធ្នាប់ការងារ ។ ម្យ៉ាងទៀតអង្គការនេះ វាសំរាប់ទាក់ទងជាមួយនឹងស្ថាប័នផ្សេងៗទៀតជាមួយរដ្ឋសភា ។ គេអាចសង្កេតឃើញជាទូទៅចំពោះឧបករណ៍ដែលជាអង្គការជំនួយរបស់រដ្ឋសភាដ៏សំខាន់នោះគឺ :

**ក. រចនាសម្ព័ន្ធ និងមុខងារនៃអង្គការជំនួយ** : នេះគឺជាសណ្តាប់ធ្នាប់នៃការងារតាមឋានានុក្រមមួយយ៉ាងពិតប្រាកដ ក្នុងសកម្មភាពនៃបុគ្គលក្របខ័ណ្ឌ ។ ជាទូទៅអង្គការជំនួយរដ្ឋសភាមានរចនាសម្ព័ន្ធពីរប្រភេទគឺ :

**ទីមួយ** : អង្គការរបស់សភាផ្ទាល់, មានគណៈកម្មការផ្សេងៗ, លេខាធិការដ្ឋាន.... ។ល។ (ជាស្ថាប័ន)

**ទីពីរ** : អ្នកជំនួយការផ្ទាល់ និងលេខាធិការរបស់សមាជិកសភា ឬប្រធានរដ្ឋសភា...។ល។ (ជាមនុស្ស)

**ក. អង្គការផ្ទាល់នានារបស់រដ្ឋសភា** : នេះជាសេវាកម្មមួយដែលមានគណៈកម្មការនានា និងលេខាធិការដ្ឋានរបស់រដ្ឋសភា ។ អង្គការជំនួយការនេះសំរាប់ផ្គត់ផ្គង់នូវកិច្ចទាំងឡាយ ដែលធ្វើឱ្យរដ្ឋសភាដំណើរការ ដូចជា**មាត្រា ៩៤** នៃរដ្ឋធម្មនុញ្ញកម្ពុជា បានកំនត់ថា "រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅនឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា" ។ រីឯ**ប្រការ ១៩** នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាបានកំណត់ថា "គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នករៀបចំរបៀបវារៈនៃពេលប្រជុំនីមួយៗ ។ មុនផុតពេលប្រជុំនីមួយៗ ប្រធានអានរបៀបវារៈសម្រាប់ពេលប្រជុំបន្តទៅទៀត" ។ សេវាកម្មដ៏សំខាន់មួយទៀតរបស់រដ្ឋសភា ដូចជា **ប្រការ ១៤** នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា បានកំណត់ទៀតថា "រដ្ឋសភាមានអគ្គលេខាធិការដ្ឋានមួយ ទទួលបន្ទុកខាងការរៀបចំធ្វើកំណត់ហេតុរបស់រដ្ឋសភា និងរបស់គណៈកម្មការនានា។ អគ្គលេខាធិការដ្ឋាននេះទទួលរ៉ាប់រងផងដែរនូវគ្រប់កិច្ចការរដ្ឋបាលរបស់រដ្ឋសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅរដ្ឋសភា" ។ (**មើលរូប ១២**) ក្នុងលេខាធិការដ្ឋាននេះត្រូវមានបុគ្គលិកចាំបាច់សំរាប់គ្រប់គ្រង និងដំណើរការ ដូច**ប្រការទី ១៥** នៃបទបញ្ជាផ្ទៃក្នុងដដែលបានកំណត់ថា "អគ្គលេខាធិការដ្ឋានត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយរូបជាអ្នកជំនួយការ ។ អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីជាន់ខ្ពស់ មានពិសោធន៍ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិច ១០ ឆ្នាំ ហើយដែលមិនមែនជាសមាជិករដ្ឋសភា និងមិនមែនជាអ្នកដឹកនាំក្នុងគណៈបក្សនយោបាយណាមួយ" ។ រីឯបុគ្គលិកដទៃទៀតត្រូវបានក៏រិតតាម**ប្រការទី ១៧** ថា "បុគ្គលិកនៃអគ្គលេខាធិការដ្ឋានទាំងអស់ត្រូវតែងតាំងដោយប្រធានរដ្ឋសភា តាមសេចក្ដីស្នើរបស់អគ្គលេខាធិការ" ។

**ក២. ជំនួយការផ្ទាល់ និងលេខាធិការរបស់សមាជិករដ្ឋសភា** : នេះគឺជាសេវាករទាំងឡាយដែលទទួលភារកិច្ចផ្ទាល់ចំពោះជំនាញរបស់ខ្លួន ក្នុងការជួយដល់មន្ត្រីរដ្ឋជាន់ខ្ពស់ក្នុងអង្គការនីតិបញ្ញត្តិ ។ សេវាកម្មរបៀបនេះមាននៅគ្រប់ស្ថាប័នរបស់រដ្ឋ ដោយអាស្រ័យនឹងទំហំការងារនៃស្ថាប័នរដ្ឋកំពូលៗនោះដូចជា : ទីប្រឹក្សា. លេខាធិការ ឬឧបការី....។ល។ អ្នកជំនួយការទាំងនេះត្រូវមានជំនាញច្បាស់លាស់សំរាប់បំរើការ ។ រីឯការជ្រើសរើសគឺជាសិទ្ធិរបស់មន្ត្រីរដ្ឋជាន់ខ្ពស់ ដោយអនុលោមតាមច្បាប់ជាធរមាន ស្របតាមឋានានុក្រមរបស់គេ ប៉ុន្តែចំនួននៃអ្នកជំនាញការទាំងនេះក៏ត្រូវកំរិតផងដែរ ដើម្បីជៀសវាងនូវការប៉ះពាល់សិទ្ធិ និងកាតព្វកិច្ចជាមួយមន្ត្រីរដ្ឋផ្សេងទៀត និងជាពិសេសការខាតបង់ថវិកាសំរាប់ចំណាយឥតប្រយោជន៍ និងឋានៈជាន់គ្នា ជាឧទាហរណ៍ មន្ត្រីសាមញ្ញម្នាក់មានជំនាញ ដែលគាត់ជាសមាជិកក្រោមឱវាទប្រធាននាយកដ្ឋានមួយ ប៉ុន្តែបុគ្គលនោះត្រូវបាននាយករដ្ឋមន្ត្រីតែងតាំងឱ្យទទួលជាទីប្រឹក្សារបស់គាត់ ដែលធ្វើឱ្យគាត់មានឋានៈខ្ពស់ជាងប្រធានក្នុងស្ថាប័នរបស់គាត់ ត្រង់នេះហើយដែលធ្វើឱ្យបុគ្គលនោះមានភាពក្រអើត ។ ម្យ៉ាងវិញទៀត បើសិនជាបុគ្គលនោះទទួលបន្ទុកជំនាញក្នុងនាយកដ្ឋានមួយនោះហើយ ហើយវាស្ថិតក្រោមឱវាទរបស់នាយករដ្ឋមន្ត្រីនោះ ពុំចាំបាច់តែងតាំងបុគ្គលនោះឱ្យទៅជាជំនួយការអ្វីទៀតទេ ព្រោះបុគ្គលនោះស្ថិតក្រោមឱវាទស្រេចទៅហើយ ។ ការគិតគូរដល់បញ្ហាទាំងនេះ គឺជាបច្ច័យមួយដែលធ្វើឱ្យបុគ្គល ឬមន្ត្រីជំនាញមានការទទួលខុសត្រូវតាមឋានានុក្រមរដ្ឋបាល និងបច្ចេកទេស ។

ជាធម្មតាក្នុងប្រទេសនីមួយៗត្រូវកំណត់នូវអ្នកជំនួយការ និងលេខាធិការរបស់បុគ្គលដែលជាមន្ត្រីរដ្ឋជាន់ខ្ពស់ក្នុងការធ្វើការងារផ្សេងៗឱ្យមានប្រក្រតីភាព ។ ប៉ុន្តែអ្នកជំនួយការនោះមានកំរិតខ្ពស់ ឬទាបទៅតាមឋានៈនៃមន្ត្រីរដ្ឋដែលមានមុខងារ ។ ជំនួយការទាំងនោះមានដូចជាផ្នែកច្បាប់. រដ្ឋបាល.....។ល។ ផ្ទុយទៅវិញ ការជ្រើសរើសយកបុគ្គលណាមួយមកធ្វើជាទីប្រឹក្សា ឬជាលេខាធិការវាអាស្រ័យនឹងច្បាប់កំណត់ ឬក៏តាមចំណង់របស់មន្ត្រីរដ្ឋ ។ ប៉ុន្តែមន្ត្រីជាន់ខ្ពស់ ដាច់ខាតវាតំរូវឱ្យមានអ្នកជំនួយការ. តែមន្ត្រីសាមញ្ញពុំចាំបាច់ឱ្យមានជំនួយការ ឬលេខាទេ ព្រោះវាទាក់ទិននឹងប្រាក់បៀវត្ស និងទំហំនៃការងារ ក្រៅពីនេះនៅមានការពិភាក្សាផ្សេងៗទៀត ជាស្ថាប័នជំនួយខាងផ្នែកបច្ចេកទេសក្នុងការធ្វើច្បាប់ ដែលវាពាក់ព័ន្ធក្នុងវិស័យនីមួយៗ ។

រក្សាសិទ្ធិដោយ : អ៊ុន បូផា 

បុគ្គលជំនួយនេះពុំមានលក្ខណៈជាអចិន្ត្រៃយ៍ទេ គឺវាមានលក្ខណៈជាអន្តរកាលតែប៉ុណ្ណោះ នៅក្នុងពេលណាប្រធាន ឬស្ថាប័ននោះផុតអាណត្តិវានឹងរំលាយដោយខ្លួនឯង ។ ជាងនេះទៅទៀត វាអាចកើតមានស្ថាប័នអចិន្ត្រៃយ៍ផងដែរ សំរាប់បង្ហាត់បង្រៀន ឬជាសេវាកម្មបច្ចេកទេសស្រាវជ្រាវ ដូចជា : ស្ថាប័នប្រធានាធិបតី, ស្ថាប័នប្រធានរដ្ឋសភា.....។ល។ ដែលកិច្ចការនេះ ច្រើនកើតមាននៅប្រទេសជឿនលឿន ដូចជាអាមេរិក.បារាំង....។ល។ ព្រោះថានៅពេលចប់អាណត្តិមួយប្រធានាធិបតីចាស់បានចាកចេញ តែមន្ត្រីនៅក្នុងស្ថាប័ននោះដែលជាអ្នកជំនាញបន្សល់ទុកដដែល សំរាប់ផ្តល់ជាបទពិសោធន៏ការងារអ្នកជំនាន់ក្រោយឱ្យស្គាល់ ឬយល់ដឹងពីអាណត្តិដែលបានកន្លងផុត ។

# គំនូសបំព្រួញនៃរចនាសម្ព័ន្ធរដ្ឋសភាកម្ពុជា

## របៀបទី ១ (រូបទី ១២)



# ដំណើរការនីតិកម្មនៃរដ្ឋសភាកម្ពុជា (រូបទី ១២)




រក្សាសិទ្ធិដោយ : អ៊ុន បូផា

### គំនូសបំព្រួញនៃរចនាសម្ព័ន្ធរដ្ឋសភាកម្ពុជា របៀបទី ២ (រូបទី ១២)

### ប្រភព : សេចក្ដីសម្រេចរបស់រដ្ឋសភា លេខ ០២៤ រស ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៩៩



## ៧. បំណកស្រាយដំណើរការនីតិកម្មកម្ពុជា

ចំពោះការបង្កើតច្បាប់នៃរដ្ឋសភា ប្រទេសកម្ពុជាប្រព្រឹត្តិឡើងតាមដំណាក់ដូចខាងក្រោម ៖

**ក. ដំណាក់ធ្វើសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ :** នេះគឺជាដំណាក់ដំបូងដែលអ្នកជំនាញផ្នែកច្បាប់ និងបច្ចេកទេសក្នុងវិស័យនីមួយៗ រៀបចំជាសេចក្តីព្រាងដែលមានលក្ខណៈជាអត្ថបទព្រាងគតិយុត្តិ នៅតាមស្ថាប័នដែលពាក់ព័ន្ធ រួចហើយដាក់ជូនទៅគណៈរដ្ឋមន្ត្រី ( ករណីរដ្ឋាភិបាលអ្នកធ្វើ) ឬទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ( ករណីតំណាងរាស្ត្រ ឬតំណាងព្រឹទ្ធសភាអ្នកធ្វើ) ។

**ខ. គណៈរដ្ឋមន្ត្រី :** នេះជាដំណាក់កាលមួយ ដែលក្រុមប្រឹក្សាអ្នកច្បាប់នៃគណៈរដ្ឋមន្ត្រីត្រូវធ្វើការពិនិត្យកែសំរួលជាលក្ខណៈបច្ចេកទេសគតិយុត្តិ ទៅលើសេចក្តីព្រាងដែលបានដាក់ជូន ។ បន្ទាប់មកគណៈរដ្ឋមន្ត្រីកំណត់ពេលពិភាក្សាទៅលើសេចក្តីព្រាង ដោយមានការចូលរួមប្រជុំជាអន្តរក្រសួងដែលពាក់ព័ន្ធទៅលើវិស័យគ្រប់គ្រងរបស់ខ្លួន ហើយទាក់ទិននឹងសេចក្តីព្រាងនោះ ។ អ្នកដែលជាម្ចាស់នៃសេចក្តីព្រាងត្រូវចូលទៅបំភ្លឺ និងការពារ និងធ្វើជាអ្នកអំណះអំណាង ។ បន្ទាប់ពីអន្តរក្រសួងពិភាក្សាចប់ អត្ថបទជាផ្លូវការនឹងដាក់ឆ្លងគណៈរដ្ឋមន្ត្រីនៃសម័យប្រជុំពេញអង្គ ដើម្បីបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ។

**គ. គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា :** ជាដំណាក់កាលមួយ ដែលបន្ទាប់ពីបានទទួលសេចក្តីព្រាងពីរដ្ឋាភិបាល ឬទទួលសេចក្តីស្នើច្បាប់ពីតំណាងរាស្ត្រ ឬពីសមាជិកព្រឹទ្ធសភា រួចមកគណៈកម្មាធិការអចិន្ត្រៃយ៍នេះត្រូវបញ្ជូនសេចក្តីព្រាង ឬសេចក្តីស្នើនោះទៅគណៈកម្មការជំនាញនីមួយៗរបស់រដ្ឋសភា តាមវិស័យដែលពាក់ព័ន្ធ ។

**ឃ. គណៈកម្មការជំនាញ :** ជាដំណាក់កាលមួយ ដែលគណៈកម្មការនេះធ្វើការពិភាក្សា និងមានការកែសំរួលទាំងបច្ចេកទេស និងផ្នែកគតិយុត្តិ ( គណៈកម្មការនីតិកម្ម) ដោយមានការចូលរួមផ្តល់ជាយោបល់ពីអ្នកជំនាញផ្សេងៗ ព្រមទាំងមានការចូលរួមធ្វើអំណះអំណាងពីភាគីសាមីនៃសេចក្តីពង្រាង ឬសាមីសេចក្តីស្នើផងដែរ ។ ក្រោយពីធ្វើការពិភាក្សាចប់សព្វគ្រប់ គណៈកម្មការជំនាញនេះត្រូវបញ្ជូន ( ជំរាបជូន) សេចក្តីព្រាងនេះទៅគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីកំណត់របៀបវារៈ

សំរាប់ដាក់ចូលទៅ ពិភាក្សា អនុម័ត ដោយតំណាងរាស្ត្រក្នុងសម័យប្រជុំពេញអង្គនៃរដ្ឋសភា ។ បន្ទាប់ពីរដ្ឋសភាអនុម័តចប់សព្វគ្រប់ បញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ដើម្បីឱ្យព្រឹទ្ធសភាពិនិត្យឡើងវិញ (ធ្វើនិយ័តភាព)។ បន្ទាប់ពីព្រឹទ្ធសភាពិនិត្យចប់សព្វគ្រប់ សេចក្តីព្រាង ឬសេចក្តីស្នើនោះនឹងបញ្ជូនទៅព្រះមហាក្សត្រឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើ ។

ចំពោះសិទ្ធិអំណាចក្នុងការអនុម័តច្បាប់ រវាងព្រឹទ្ធសភា និងរដ្ឋសភា ត្រូវបានកំណត់ដោយ **មាត្រា ១១៣** នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ថា "ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ។ បើជាការប្រញាប់រយៈពេលនោះ ត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

បើព្រឹទ្ធសភា សុំឱ្យកែសំរួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ ។ រដ្ឋសភាត្រូវពិនិត្យ និងសំរេច តែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសំរួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសំរេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃបើជាការប្រញាប់ ។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់ ។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី ២ នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសំរេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ" ។

ចំពោះសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ទាំងឡាយណាដែលទាក់ទិននឹងការរៀបចំអង្គការ ឬបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងរដ្ឋសភា ហើយដែលសភាទាំងពីរយល់ព្រមរួចហើយ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យជាមុនសិន មុននឹងបញ្ជូនទៅព្រះមហាក្សត្រប្រកាសឱ្យប្រើ ។

ក្នុងករណីដែលព្រឹទ្ធសភាបដិសេធជាអសារបង់ទៅលើសេចក្តីព្រាង ឬសេចក្តីស្នើ នោះរដ្ឋសភាត្រូវយកសេចក្តីព្រាង ឬស្នើនោះ មកពិនិត្យពិចារណាជាលើកទីពីរឱ្យបានមុនរយៈពេលមួយខែទើបបាន ។

# ដំណើរការនីតិកម្មនៃរដ្ឋសភាសហរដ្ឋអាមេរិក (រូបទី ១៣)



## ៨. បំណកស្រាយនៃនីតិកម្មសហរដ្ឋអាមេរិក

ដើម្បីឱ្យទៅជាច្បាប់ សេចក្តីព្រាងច្បាប់ត្រូវតែសភាទាំងពីរយល់ព្រម រួចហើយផ្ញើទៅប្រធានាធិបតីឱ្យយល់ព្រមផងដែរ ។ សេចក្តីព្រាងច្បាប់ត្រូវតែធ្វើឡើងដោយការពិចារណាច្រើនបែបយ៉ាង ដោយការជជែក និងដោយការបោះឆ្នោតនៅក្នុងរដ្ឋសភា ដូចតទៅនេះ :

**ក.ការស្នើ** : តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា មានសិទ្ធិស្នើសេចក្តីព្រាងច្បាប់ ហើយដាក់ជូនប្រធាននៃសភារបស់ខ្លួនពិចារណា (លើកលែងតែសេចក្តីព្រាងច្បាប់ ស្តីពីពន្ធអាករ ដែលត្រូវតំណាងរាស្ត្រស្នើ) ។ កាលបើប្រធាននៃសភានីមួយៗទទួលសេចក្តីព្រាងច្បាប់នោះហើយ ត្រូវប្រគល់ទៅឱ្យប្រធានគណៈកម្មាធិការដែលទាក់ទងនឹងរឿងនោះពិនិត្យល្អិតល្អន់ ហើយរាយការណ៍តទៅ ។

**ខ.ការពិនិត្យរបស់គណៈកម្មាធិការ** : បន្ទាប់ពីទទួលកិច្ចការហើយ ប្រធានគណៈកម្មាធិការដែលទាក់ទងក្នុងរឿងនោះ ត្រូវចម្លងសេចក្តីព្រាងច្បាប់នោះឱ្យបានច្រើនច្បាប់ រួចចែកទៅសមាជិកទាំងអស់នៃគណៈកម្មាធិការដើម្បីឱ្យពិនិត្យមើល ។ គេអាចហៅសាក្សីឱ្យមកបញ្ចេញយោបល់អំពីសេចក្តីព្រាងច្បាប់នោះ ។ ប្រសិនបើចាំបាច់ គេអាចកែប្រែអត្ថបទដើមបាន ។ លុះពិនិត្យពិច័យហើយ គណៈកម្មាធិការនឹងសម្រេចថា ត្រូវរាយការណ៍ទៅសភាទាំងមូលឱ្យពិភាក្សាបោះឆ្នោត ឬក៏មិន ។ គណៈកម្មាធិការមាននាទីណែនាំឱ្យអនុម័ត ឬមិនឱ្យអនុម័តសេចក្តីព្រាងច្បាប់នោះ ហើយថែមទាំងមានអំណាចទុកចោលមួយអន្លើ គឺមិនបាច់រាយការណ៍ទៅសភាឱ្យសម្រេចឡើយ ។ ក្នុងករណីបែបនេះ អ្នកផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់អាចនឹងស្នើសភាឱ្យបោះឆ្នោត ដើម្បីឱ្យគណៈកម្មាធិការនាំយកសេចក្តីព្រាងច្បាប់នោះទៅពិភាក្សានៅក្នុងអង្គប្រជុំសភាទាំងមូល ប៉ុន្តែតាមការអនុវត្តន៍នីតិវិធីនេះមិនសូវប្រើទេ ព្រោះពិបាកផង ហើយសហការីក្នុងសភាជាមួយគ្នាក៏តែងជំទាស់ផង ។ ដូច្នេះអ្នកផ្តើមគំនិតត្រូវរង់ចាំរហូតដល់សម័យប្រជុំក្រោយទៅទៀត ហើយនឹងដាក់ជូនប្រធានសភាខ្លួនសារជាថ្មីទៀត ។

**ច.ការពិភាក្សា និងបោះឆ្នោត** : កាលណាគណៈកម្មាធិការយល់ព្រមរាយការណ៍សេចក្ដីព្រាងច្បាប់ទៅឱ្យសភាពិភាក្សា និងបោះឆ្នោតហើយ សេចក្ដីព្រាងច្បាប់នោះនឹងត្រូវដាក់ចូលទៅក្នុងកម្មវិធីប្រជុំរបស់សភា ។ វិន័យស្ដីពីការពិភាក្សានៅក្នុងសភាទាំងអស់ផ្សេងគ្នា ។

នៅក្នុងសភាតំណាងរាស្ត្រ ឥតមានតំណាងរាស្ត្រណាមានសិទ្ធិនិយាយហួសពីមួយម៉ោង ដោយឥតមានការយល់ព្រមពីសភាទេ ។ ប្រធានសភាតំណាងរាស្ត្រមានអំណាចបន្ថយពេលសិក្សាឱ្យខ្លី ហើយបិទការពិភាក្សាដើម្បីឱ្យបោះឆ្នោត ។ ដោយផ្ទុយទៅវិញ បទបញ្ញត្តិរបស់ព្រឹទ្ធសភាឥតមានកម្រិតពេលម៉ោងសម្រាប់ឱ្យសមាជិកព្រឹទ្ធសភាបញ្ចេញយោបល់ទេ ដូច្នេះហើយបានជាមានសមាជិកព្រឹទ្ធសភាជាច្រើនបានប្រើល្បិចពន្យាពេលពិភាក្សាឱ្យវែង ហើយឆ្លៀតឱកាសជជែកវែកញែកក្នុងបំណងប្រឆាំងនឹងគម្រោងច្បាប់ដែលខ្លួនមិនគាំទ្រ ។ ដើម្បីកុំឱ្យមានការពន្យាពេល ត្រូវមានសមាជិកព្រឹទ្ធសភាយ៉ាងតិច ១៦ នាក់ ស្នើឡើងដើម្បីបាន ២ ភាគ ៣ នៃសមាជិកព្រឹទ្ធសភាទាំងមូលបោះឆ្នោតយល់ព្រមឱ្យបញ្ឈប់ការជជែកវែកញែកនោះ ។

កាលបើសមាជិកភាគច្រើននៃសភាណាមួយ បានបោះឆ្នោតយល់ព្រមលើសេចក្ដីព្រាងច្បាប់ ហើយសេចក្ដីព្រាងច្បាប់នោះនឹងត្រូវបញ្ជូនទៅសភាមួយទៀត ដើម្បីឱ្យពិនិត្យពិភាក្សា ហើយបោះឆ្នោតតាមនីតិវិធីដូចពោលរួចមកហើយ ។ ប្រសិនបើសភាក្រោយនេះជំទាស់ សេចក្ដីព្រាងច្បាប់នោះមិនអាចទៅជាច្បាប់ឡើយ ។ ប៉ុន្តែប្រសិនជាសភាក្រោយនេះយល់ស្រប សេចក្ដីព្រាងច្បាប់នោះនឹងត្រូវផ្ញើទៅប្រធានាធិបតីឱ្យវិនិច្ឆ័យ ។ ប្រសិនបើមានការកែប្រែអត្ថបទដើមខ្លះ សភាក្រោយនេះនឹងត្រូវបញ្ជូនសេចក្ដីព្រាងនោះ ទៅសភាមុនឱ្យសើរើបោះឆ្នោតសាជាថ្មី ។ ប្រសិនបើសភាដែលស្នើសេចក្ដីព្រាងច្បាប់នោះ មិនយល់ព្រមក្នុងការផ្លាស់ប្ដូរកែប្រែសេចក្ដីក្នុងអត្ថបទទេ គណៈកម្មាធិការសម្រុះសម្រួលមួយត្រូវតែបង្កើតឡើង ( មានសមាជិកពី ៣ ទៅ ៥ នាក់ មកពីសភានីមួយៗ) ដើម្បីដោះស្រាយការខ្វែងគំនិតគ្នា ។ បន្ទាប់ពីគណៈកម្មាធិការនេះ បានពិភាក្សាអំពីអត្ថបទនៃសេចក្ដីព្រាងច្បាប់នោះរួចហើយ សភាទាំងពីរនឹងត្រូវបោះឆ្នោតម្ដងទៀត ដើម្បីទទួលយល់ព្រម ឬបដិសេធសេចក្ដីព្រាងច្បាប់នោះ ហើយឥតត្រូវមានការកែប្រែទៀតឡើយ ។ ប្រសិនបើសភាទាំងពីរយល់ព្រម

សេចក្ដីព្រាងច្បាប់នោះនឹងត្រូវបញ្ជូនទៅប្រធានាធិបតី ដើម្បីវិនិច្ឆ័យ ។ ប្រធានាធិបតីអាចនឹងយល់ព្រម ហើយចុះហត្ថលេខាឱ្យទៅជាច្បាប់ ឬមួយមានអំណាចរារាំង ហើយផ្ញើត្រឡប់ទៅសភាវិញ ឬក៏មានអំណាចទុកសេចក្ដីព្រាងនោះមួយអន្លើ ដោយមិនបាច់រារាំង ឬមិនយល់ព្រមក៏បាន ។

**ឃ.សិទ្ធិអំណាចប្រធានាធិបតី :** ដូច្នេះឃើញថាទាំងបានទៅជាច្បាប់ពេញទីនោះ សេចក្ដីព្រាងច្បាប់ត្រូវមានការពិនិត្យពិច័យជជែកវែកញែកច្រើនបែបយ៉ាង ។ មានសេចក្ដីព្រាងច្បាប់ជាច្រើនដែលមិនបានទៅដល់ប្រធានាធិបតី ។ ឧទាហរណ៍ បណ្ដាសេចក្ដីព្រាងច្បាប់ទាំង ៧១២៥ ដែលបញ្ជូនទៅសភាទី ៨៤ (ឆ្នាំ ១៩៥៥) នោះ មានតែ ១០៤១ ប៉ុណ្ណោះទេដែលបានទៅជាច្បាប់ ។

សេចក្ដីព្រាងដែលសភាអនុម័តហើយ ត្រូវបញ្ជូនទៅប្រធានាធិបតី ក្នុងរយៈពេល ១០ ថ្ងៃ បន្ទាប់ពីទទួលសេចក្ដីព្រាងច្បាប់ ប្រធានាធិបតីអាច :

- ចុះហត្ថលេខា រួចប្រកាសយកសេចក្ដីព្រាងច្បាប់នោះជាច្បាប់ ប្រសិនបើខ្លួនយល់ព្រម ។
- រារាំង រួចបញ្ជូនសេចក្ដីព្រាងច្បាប់នោះទៅសភាវិញ ប្រសិនបើខ្លួនជំទាស់ ។ ក្នុងករណីនេះ ដើម្បីធ្វើឱ្យការរារាំងរបស់ប្រធានាធិបតីទៅជាមោឃៈ សភាទាំងពីរត្រូវមានសម្លេងឆ្នោតឱ្យបានពីរភាគបីឡើងទៅ ។ កាលបើបានសម្លេងឆ្នោតពីរភាគបីហើយ សេចក្ដីព្រាងច្បាប់នោះនឹងទៅជាច្បាប់ដោយស្វ័យប្រវត្តិ ។
- ប្រសិនបើ ១០ ថ្ងៃក្រោយមក ប្រធានាធិបតីមិនបានចុះហត្ថលេខា ហើយបានប្រកាសយកសេចក្ដីព្រាងច្បាប់នោះជាច្បាប់ក្ដី មិនបានជំទាស់ហើយផ្ញើសេចក្ដីព្រាងច្បាប់នោះ ត្រឡប់ទៅសភាវិញក្ដី សេចក្ដីព្រាងច្បាប់នោះនឹងទៅជាច្បាប់ដោយស្វ័យប្រវត្តិ ប្រសិនបើពេលនោះសភានៅក្នុងសម័យប្រជុំនៅឡើយ ។ បើសិនជាសភាបានផ្អាកសម័យប្រជុំរួចហើយ សេចក្ដីព្រាងច្បាប់នោះមិនអាចទៅជាច្បាប់បានទេ ។

**អត្ថបទទី ១៦**

# អំណាចនីតិប្រតិបត្តិ : ប្រមុខរដ្ឋ និងរដ្ឋាភិបាល

## ១. ប្រមុខរដ្ឋ (Head of the state)

**ក. និយមន័យ និងអាសនៈនៃប្រមុខរដ្ឋនៅក្នុងប្រព័ន្ធនៃអំណាចរដ្ឋ** : និយមន័យ និងអាសនៈនៅក្នុងប្រព័ន្ធនៃអំណាចវាគឺជាមន្ត្រីរដ្ឋ ឬក៏អង្គការរដ្ឋ (Organ) ដែលកាន់កាប់អាសនៈខ្ពស់ក្នុងប្រព័ន្ធនៃអង្គការទាំងឡាយរបស់រដ្ឋ ។

ដោយយោងតាមអត្ថបទទាំងឡាយ នៃរដ្ឋធម្មនុញ្ញរបស់បណ្ដាប្រទេសជាច្រើននៅលើពិភពលោកបានបញ្ជាក់នូវតួនាទីរបស់ប្រមុខរដ្ឋនៃរដ្ឋនីមួយៗ ស្របតាម**របបគ្រប់គ្រងនយោបាយ** និង**ទំរង់គ្រប់គ្រងរដ្ឋ**នៃសម័យកាលនីមួយៗ ហើយគេបានសង្កេតឃើញនូវភាពខុសគ្នាបីករណី ដែលកើតមានសំរាប់ប្រមុខរដ្ឋគឺ :

**ក₁. ករណីទីមួយ** : នេះជាករណីដែលប្រមុខរដ្ឋពុំមានទទួលអំណាចអ្វីបន្តិចសោះឡើយ ដែលគេបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់គ្រឹះ ។ ក្នុងករណីរបៀបនេះដូចមានចែងក្នុង**មាត្រាទី ៥៥** តាមវាក្យខ័ណ្ឌទីមួយរដ្ឋធម្មនុញ្ញនៃសហព័ន្ធអាល្លឺម៉ង់ (ច្បាប់គ្រឹះ) ១៩៤៩ បានកំណត់ថា "ប្រធានាធិបតីសហព័ន្ធមិនអាចស្ថិតក្នុងសមាសភាពនៃរដ្ឋាភិបាលសហព័ន្ធ និងអំណាចនីតិបញ្ញត្តិរបស់សហព័ន្ធ ឬក៏សមាសភាពនៃប្រទេស (សមាជិកនៃសហព័ន្ធ) ដែរ"។ ត្រង់នេះបញ្ជាក់ថា ជាទំរង់គ្រប់គ្រងរដ្ឋក្នុងល័ក្ខខ័ណ្ឌសាធារណរដ្ឋបែបសភា។ ផ្ទុយទៅវិញតាមរដ្ឋធម្មនុញ្ញកម្ពុជា វាក្យខ័ណ្ឌទីមួយនៃ**មាត្រា ៧** កំណត់ថា "ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ"។ នេះបញ្ជាក់ថា ជាទំរង់គ្រប់គ្រងរដ្ឋក្នុងល័ក្ខខ័ណ្ឌរាជាធិបតេយ្យអាស្រ័យសភា ឬសាធារណរដ្ឋអាស្រ័យសភា ។ ដូចនេះយើងឃើញថា ករណីទីមួយនេះប្រមុខរដ្ឋគ្មានអំណាចអ្វីទេ គាត់គ្រាន់តែជានិមិត្តរូបរបស់រដ្ឋតែប៉ុណ្ណោះ ។

**ក₂.ករណីទីពីរ** : វាជាករណីដែលកើតឡើងដោយប្រមុខរដ្ឋ អាចទទួលបាននូវអំណាចនីតិបញ្ញត្តិ ឬក៏អំណាចនីតិប្រតិបត្តិ។ ករណីរបៀបនេះ ត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញឥណ្ឌា ឆ្នាំ ១៩៤៩ ក្នុងវាក្យខ័ណ្ឌទីមួយនៃ**មាត្រា ៥៣** កំណត់ថា "អំណាចនីតិប្រតិបត្តិនៃសហភាពត្រូវផ្ទុកផ្ដាក់ទៅប្រធានាធិបតី..."។ ត្រង់នេះបញ្ជាក់ថា ប្រធានាធិបតីមានអំណាចនីតិប្រតិបត្តិ។ ប៉ុន្តែ**មាត្រា ៧៩** នៃរដ្ឋធម្មនុញ្ញដដែលនោះបានកំណត់ថា "រដ្ឋសភាសហភាពត្រូវតែបង្កើតឡើងពីសមាសភាពប្រធានាធិបតី និងសភាពីរទៀត : ក្រុមប្រឹក្សារដ្ឋ (ព្រឹទ្ធសភា) និងសភាប្រជាជន (សភាតំណាងរាស្ត្រ)"។ ដូចនេះយើងឃើញក្នុងមាត្រា ៥៣ នៃរដ្ឋធម្មនុញ្ញឥណ្ឌាប្រធានាធិបតីមានអំណាចនីតិប្រតិបត្តិ រីឯមាត្រា ៧៩ ប្រធានាធិបតីទទួលបាននូវអំណាចនីតិបញ្ញត្តិមួយទៀត ។ ប៉ុន្តែទោះជាប្រធានាធិបតីជាសមាសភាពរបស់រដ្ឋាភិបាល ឬក៏របស់សភាក៏ពិតមែន តែតួនាទីនយោបាយរបស់គាត់ពុំមានសកម្មភាពនោះទេ គឺប្រគល់ទៅឱ្យនាយករដ្ឋមន្ត្រីជាអ្នកទទួលរ៉ាប់រងដឹកនាំប្រទេស ហើយទទួលខុសត្រូវចំពោះរដ្ឋសភា។ នៅក្នុងល័ក្ខខ័ណ្ឌនេះ ក៏ស្ថិតក្នុងទំរង់គ្រប់គ្រងបែបសាធារណរដ្ឋអាស្រ័យសភាដែរ។

**ក₃.ករណីទីបី** : នេះជាករណីដែលប្រមុខរដ្ឋទទួលយកនូវអំណាចមួយ គឺអំណាចនីតិប្រតិបត្តិ។ ឧទាហរណ៍ **មាត្រា ២** ផ្នែក ១ រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកឆ្នាំ ១៧៨៧ កំណត់ថា "អំណាចនីតិប្រតិបត្តិប្រគល់ទៅឱ្យប្រធានាធិបតីនៃសហរដ្ឋអាមេរិក"។

ត្រង់នេះបញ្ជាក់ថា ការគ្រប់គ្រងរដ្ឋក្នុងល័ក្ខខ័ណ្ឌសាធារណរដ្ឋបែបប្រធានាធិបតីនិយម ។ ទោះបីជាមានករណីទាំងបីខាងលើដែលបានរៀបរាប់ហើយក៏ដោយ ក៏ពុំមានន័យថាករណីនោះគ្រប់ជ្រុងជ្រោយហើយនោះទេ ពីព្រោះថានៅមានលក្ខណៈផ្សេងៗទៀត ដែលប្រមុខរដ្ឋត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់របស់សាមីប្រទេស។ ការកំណត់របស់ច្បាប់ និងរដ្ឋធម្មនុញ្ញទៅលើប្រមុខរដ្ឋនូវមុខងារ, សកម្មភាពនៃអំណាចនយោបាយ និងសិទ្ធិអំណាចដ៏ចំបងនោះវាជាខ្នាតមួយដើម្បីកំរិតព្រំដែននៃប្រមុខរដ្ឋ ក្នុងការធ្វើសកម្មភាពតាមប្រព័ន្ធនៃអង្គការគ្រប់គ្រងរដ្ឋនីមួយៗ ។

សកម្មភាពនយោបាយរបស់ប្រមុខរដ្ឋ ដូចរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ក្នុងវាក្យខ័ណ្ឌទីពីរនៃ**មាត្រា ៧** ថា "ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត" ។ ឯវាក្យខ័ណ្ឌទីមួយក្នុងមាត្រានេះនិយាយថា "ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ" ។ និង**មាត្រា ៨** កំណត់ថា "ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ។

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិអធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ" ។**មាត្រា ៩** "ព្រះមហាក្សត្រទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តិទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់" ។ ពិតហើយមុខងារ,តួនាទី,សិទ្ធិអំណាចរបស់ប្រមុខរដ្ឋនៃប្រទេសនីមួយៗពុំមានសមាមាត្រនឹងគ្នាបានទេ ពីព្រោះវាជាលក្ខណៈប្រវត្តិសាស្ត្រ និងប្រពៃណីរបស់រដ្ឋនីមួយៗខុសគ្នាៗ ។

ដូចនេះប្រមុខរដ្ឋ **គឺជាអ្នកតំណាងជាន់ខ្ពស់របស់រដ្ឋនៃផ្ទៃក្នុង និងផ្ទៃក្រៅប្រទេស ហើយជាមួយគ្នានោះវាជាតំណាងនិមិត្តរូបនៃឯកភាពជាតិរបស់រដ្ឋ (ប្រជាជន និងរដ្ឋ) ទៀតផង** ។ តាមនិយមន័យនេះ គឺវាអាស្រ័យទាំងស្រុងទៅនឹង**ទំរង់គ្រប់គ្រង** និង**របបនយោបាយ** ហើយរួមទាំងប្រព័ន្ធ នៃទំនាក់ទំនងនយោបាយដែលមានសំរាប់រដ្ឋនីមួយៗទៀតផង ។

**ខ. ទំរង់គតិយុត្តិនៃប្រមុខរដ្ឋ** : ទំរង់គតិយុត្តិនៃប្រមុខរដ្ឋ គឺជាទំរង់គ្រឹះនៃប្រវត្តិសាស្ត្រក្នុងការគ្រប់គ្រងរដ្ឋនីមួយៗ ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងនោះមានលក្ខណៈដឹកនាំជាឯកត្តបុគ្គល ឬក៏ពហុបុគ្គលដែលបានចារិកក្នុងឯកសារគ្រឹះ (ច្បាប់គ្រឹះ) នៃសម័យកាល ។

ប្រវត្តិសាស្ត្រនៃការដឹកនាំរដ្ឋ វាចាប់កើតចេញពីប្រមុខរដ្ឋជាព្រះរាជា (Monarch) និងក្រោយមកជាបន្តបន្ទាប់ប្រមុខរដ្ឋមានជាប្រធានាធិបតី (President) ។ ដូចនេះប្រពៃណីរបស់ប្រមុខរដ្ឋក្នុងជំហានដំបូងគឺទំរង់គ្រប់គ្រងបែបរាជាធិបតេយ្យ (Monarchy) បន្ទាប់មកទើបមានទំរង់គ្រប់គ្រងបែបសាធារណរដ្ឋ (Republic) ជាក្រោយ ។

ដូចនេះប្រមុខរដ្ឋអាចជាព្រះរាជា ឬប្រធានាធិបតី ដោយអាស្រ័យទៅនឹងប្រវត្តិសាស្ត្រនៃការវិវត្តន៍ក្នុងការគ្រប់គ្រងរដ្ឋរបស់ប្រទេសនីមួយៗនៅលើពិភពលោក ដែលប្រវត្តិសាស្ត្រនោះបានកំណត់នូវទំរង់គតិយុត្តិនៃប្រមុខរដ្ឋមានលក្ខណៈប្លែកៗគ្នាដូចជា :

**ខ១. ទំរង់គតិយុត្តិរបស់ប្រមុខរដ្ឋបែបរាជាធិបតេយ្យ** (Monarchy) : គឺជាទំរង់មួយដែលរដ្ឋនោះមានប្រមុខរដ្ឋរបស់គេជាស្តេច ហើយត្រូវបានកើតដោយលំដាប់ផ្សេងៗ ។ ប៉ុន្តែជាធម្មតាការឡើងកាន់របស់ស្តេចឱ្យក្លាយទៅជាប្រមុខរដ្ឋមានភាពស្មុគស្មាញជាច្រើន ។ នៅក្នុងទំរង់គតិយុត្តិរបៀបនេះ ស្តេចដែលចង់ក្លាយជាប្រមុខរដ្ឋក្នុងប្រទេសរបស់ខ្លួន បានប្រើប្រាស់មធ្យោបាយច្រើនប្រភេទក្នុងការឈានទៅសំរេចបានជាប្រមុខរដ្ឋ ដូចជាតាមរយៈ :

**ខ១.១. ស្តេចជាប្រមុខរដ្ឋតាមរយៈស្នងរាជ្យ** : ស្តេចម្នាក់ៗទទួលយកមុខងារខ្លួនជាប្រមុខរដ្ឋតាមរយៈស្នងរាជ្យ មានដូចជា : **ចក្រភពអង់គ្លេស** (Great Britain), **ជប៉ុន** (Japan), **អេស្ប៉ាញ** (Spain), **បែលហ្ស៊ិក** (Belgium), **ហូឡង់** (Netherlands) ............. ។ល។

**ខ១.២. ស្តេចជាប្រមុខរដ្ឋតាមរយៈតែងតាំង** : ស្តេចម្នាក់ៗអាចទទួលមុខងារជាប្រមុខរដ្ឋតាមរយៈការតែងតាំងដោយសមាជិកនៃវង្សត្រកូលរាជា (ញាត្តិវង្ស) ឬក្រុមប្រឹក្សារាជសម្បត្តិ ដូចជា : **អារ៉ាប់ប៊ីសាអូឌីត** (Saudi Arabi), **កម្ពុជា (ដោយក្រុមប្រឹក្សារាជសម្បត្តិ)**.......... ។ល។

**ខ១.៣. ស្តេចជាប្រមុខរដ្ឋតាមរយៈបោះឆ្នោតជ្រើសតាំង** : ស្តេចម្នាក់ៗអាចទទួលតំណែងជាប្រមុខរដ្ឋក្នុងរដ្ឋសហព័ន្ធ ដែលមានការជ្រើសតាំងក្នុងអាណត្តិកំណត់មួយ (រយៈពេលដែលស្តេចកាន់អំណាចជាប្រមុខរដ្ឋ) ដោយស្តេចទាំងឡាយដែលជាប្រមុខរដ្ឋនៃរដ្ឋ ដែលជាសមាជិកនៃរដ្ឋសហព័ន្ធ។ ករណីនេះមានដូចជាប្រទេស**ម៉ាឡេស៊ី** ស្តេចជាប្រមុខរដ្ឋត្រូវបានបោះឆ្នោតដោយស្តេចនៃរដ្ឋផ្សេងៗទៀត ដែលជាសមាជិកនៃរដ្ឋសហព័ន្ធឱ្យកាន់តំណែងរយៈពេល ៥ ឆ្នាំ[៧៣] ។ ក្រៅពីនេះមានប្រទេស **អារ៉ាប់អេមីរ៉ាត** (United Arab Emirates) ជាដើម ............ ។ល។

---

[៧៣]. Constitutional Law of Foreign Country, M-1994, Part-II, Page 254 ។

**ខ២. ទំរង់គតិយុត្តិរបស់ប្រមុខរដ្ឋបែបសាធារណរដ្ឋ** (Republic) : ជាទំរង់ដែលប្រមុខរដ្ឋត្រូវបានជ្រើសរើសដោយប្រជាជន ឬតំណាងរបស់ប្រជាជនទូទៅ ។ នេះគឺជាទំរង់មួយដែលប្រមុខរដ្ឋពុំមែនជាស្តេចទេ តែជាប្រធានាធិបតីដែលអាសនៈរបស់វានោះកើតឡើងតាមប្រភេទផ្សេងៗដូចជា:

**ខ២.១. តាមរយៈបោះឆ្នោត** : ប្រធានាធិបតីម្នាក់ៗដែលជាប្រមុខរដ្ឋត្រូវបានបោះឆ្នោតដោយប្រជាជន, ដោយរដ្ឋសភា ឬក៏ដោយតំណាងសហការីក្នុងរយៈពេលកំណត់មួយ. ដូចជា**អាមេរិក** (USA), **អាល្លឺម៉ង់** (Germany), **អ៊ីតាលី** (Italy), **ឥណ្ឌា** (India), **ចិន** (China)........ ។ល។

**ខ២.២. ប្រមុខរដ្ឋាភិបាលធើរតួជាប្រមុខរដ្ឋនៃរដ្ឋសមាជិកសហព័ន្ធ** : ប្រមុខរដ្ឋាភិបាលអាចបំពេញមុខងារជាប្រមុខរដ្ឋបានដែរ តាមលក្ខណៈនេះដូចជានៅប្រទេសអាល្លឺម៉ង់ ( មានន័យថាប្រមុខរដ្ឋាភិបាលសហព័ន្ធអាល្លឺម៉ង់ អាចបំពេញមុខងារជាប្រមុខនៃប្រទេសផ្សេងៗដែលជាសមាជិករបស់សហព័ន្ធ)[៧៤] ។ អ្នកតំណាងរបស់ស្តេចនៃចក្រភពអង់គ្លេសនៅក្នុងរដ្ឋមួយចំនួនមានឋានៈមួយ ដោយគេឱ្យឈ្មោះជាសាធារណៈថា : អំណាចវិជិតរាជ (Deminion) ដែលមានលក្ខណៈតំណាងប្រមុខរដ្ឋដែរ ដូចជានៅ**កាណាដា** (Canada), **អូស្ត្រាលី** (Australia), **នូវែលសេឡង់** (New Zealand) ....... ។ល។ គឺថាស្តេចមានសិទ្ធិផ្តល់អំណាចឱ្យទៅតំណាងណាមួយ សំរាប់ទទួលមុខងារជាប្រមុខរដ្ឋចំណុះ ឬជារដ្ឋសហគមន៍របស់ខ្លួន ដែលសព្វថ្ងៃកំពុងអនុវត្តក្នុងសហគមន៍ចក្រភពអង់គ្លេស ។

**គ. សិទ្ធអំណាចរបស់ប្រមុខរដ្ឋ** (Authority) : សិទ្ធិអំណាចរបស់ប្រមុខរដ្ឋ វាជាព្រំដែនមួយដែលត្រូវបានច្បាប់នៃប្រទេសទាំងឡាយចារឹកកំណត់នូវសកម្មភាពក្នុងកិច្ចការសង្គមទាំងមូល ។ ការកំណត់របៀបនេះមានលក្ខណៈពីរប្រភេទគឺ : សិទ្ធិអំណាចទូទៅ និងសិទ្ធអំណាចជាក់លាក់ ។

**គ១. សិទ្ធិអំណាចទូទៅនៃប្រមុខរដ្ឋ** : គឺជាសិទ្ធិអំណាចដែលមាននៅលើកិច្ចការផ្ទៃក្នុង និងផ្ទៃក្រៅនៃប្រទេសសុក្រឹត្យមួយ ។ ជាទូទៅប្រមុខរដ្ឋវាជាអ្នកតំណាងជាន់ខ្ពស់របស់រដ្ឋនៃផ្ទៃក្នុងប្រទេសដែលមានសិទ្ធិអំណាចយ៉ាងជាក់លាក់ក្នុងទំនាក់ទំនងរដ្ឋសភា និងរដ្ឋាភិបាល ហើយរួមទាំងអំណាចតុលាការផងដែរ ។ ក្នុងទំនាក់ទំនងទាំងនេះមានដូចជា សិទ្ធិកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ. សិទ្ធិចុះ

[៧៤]. Constitutional Law of Foreign Country, M-1994, Part-II, Page 254 Point 6:7 ។

ហត្ថលេខាប្រកាសឱ្យប្រើប្រាស់ច្បាប់, សិទ្ធិវេតូ, សិទ្ធិបង្កើតរដ្ឋាភិបាល, សិទ្ធិបង្កើតអង្គការតុលាការ ឬសិទ្ធិផ្សេងៗទៀត ដោយអាស្រ័យនឹងទំរង់គ្រប់គ្រង និងរបបនយោបាយរបស់រដ្ឋ ។ មួយវិញទៀត ប្រមុខរដ្ឋជាអ្នកតំណាងជាន់ខ្ពស់របស់រដ្ឋនៅក្រៅប្រទេស ។ លក្ខណៈរបៀបនេះប្រមុខរដ្ឋអាចធ្វើសច្ចាប័ន និងអប្បជិបត្តិកម្មទៅលើសន្ធិសញ្ញាអន្តរជាតិ, ទទួលសារតាំងនៃរដ្ឋបរទេស ។ល។ ពិសេសទៀត ប្រមុខរដ្ឋជាអគ្គមេបញ្ជាការជាន់ខ្ពស់នៃកងកំលាំងប្រដាប់អាវុធ និងមានសិទ្ធិអំណាចផ្សេងៗទៀតទៅតាមទំរង់គ្រប់គ្រងរដ្ឋ និងរបបនយោបាយដែលរដ្ឋធម្មនុញ្ញបានកំណត់ ។

**គ២. សិទ្ធិអំណាចរបស់ប្រមុខរដ្ឋតាមទំរង់គ្រប់គ្រង ឬសិទ្ធិអំណាចជាក់លាក់ :** គឺជាសិទ្ធិអំណាចរបស់ប្រមុខរដ្ឋ ដែលត្រូវបានចារឹកក្នុងច្បាប់ពិតប្រាកដ ក្នុងការកំណត់ព្រំដែននៃកិច្ចការធំៗរបស់សកម្មភាពប្រមុខរដ្ឋ ។ សិទ្ធិអំណាចរបស់ប្រមុខរដ្ឋតាមលក្ខណៈនេះត្រូវបានកំណត់ដោយច្បាប់ (រដ្ឋធម្មនុញ្ញ ឬច្បាប់កំពូល) របស់ប្រទេសនីមួយៗ សំដៅធ្វើឱ្យមានសកម្មភាពទៀងទាត់តាមទំរង់គ្រប់គ្រងរដ្ឋ ដែលទំរង់នោះមានដូចជា :

**គ២.១. សិទ្ធិអំណាចប្រមុខរដ្ឋក្នុងទំរង់គ្រប់គ្រងសាធារណរដ្ឋបែបសភា:** ប្រមុខរដ្ឋក្នុងប្រទេសដែលកាន់ទំរង់គ្រប់គ្រងនេះត្រូវបានជ្រើសរើសតាមវិធីជាច្រើន រីឯបេក្ខភាពប្រធានាធិបតីជាពលរដ្ឋទូទៅដែលបានកំណត់ដោយច្បាប់ ។ ប៉ុន្តែទំរង់នេះប្រមុខរដ្ឋគ្រាន់តែជាតំណាង ឬជានិមិត្តរូបឱ្យប្រទេសតែប៉ុណ្ណោះ ។ ពុំមែនដើរតួនយោបាយទេ គឺប្រមុខរដ្ឋាភិបាលជាអ្នកដឹកនាំ ហើយទទួលខុសត្រូវចំពោះរដ្ឋសភា ។ ដូចជាប្រទេសអ៊ីតាលីប្រធានាធិបតីសាធារណរដ្ឋជាប្រមុខរដ្ឋ ត្រូវបានជ្រើសតាំងបោះឆ្នោតដោយសំលេងភាគច្រើនដាច់ខាត នៅក្នុងសហសម័យប្រជុំសភាទាំងពីរ ក្នុងអាណត្តិ ៧ ឆ្នាំ។ សិទ្ធិអំណាចរបស់ប្រធានាធិបតីមានថែមទៀត ដូចជាមានសិទ្ធិកំណត់ថ្ងៃបោះឆ្នោតជាសកលរបស់រដ្ឋសភា, អាចរំលាយរដ្ឋសភា និងចាត់តាំង ព្រមទាំងដកតំណែងមន្ត្រីជាន់ខ្ពស់របស់រដ្ឋមានសិទ្ធិលើកលែងទោស និងសុំសុខមាលទោសផ្សេងៗ......។ល។ ប្រធានាធិបតីជាអគ្គមេបញ្ជាការជាន់ខ្ពស់ ប្រធានាធិបតីទទួលតំណាងទូតបរទេស ។ ទាក់ទិននឹងនីតិកម្មគាត់ជាអ្នកប្រកាសឱ្យប្រើប្រាស់ច្បាប់ទាំងឡាយដែលបានអនុម័តដោយរដ្ឋសភា និងគាត់ខ្លួនឯងមានសិទ្ធិបង្កើតក្រឹត្យ (Decree) ដែលមានកំលាំងគតិយុត្តិដែរ ។ ក្រៅពីនេះមានសិទ្ធិពន្យាពេលទៅលើការអនុម័តច្បាប់ ដែលធ្វើឡើងដោយ

រដ្ឋសភាទៀតផង ។ ប្រទេសដែលកាន់ទំរង់នេះ គឺប្រមុខរដ្ឋពុំមានអំណាចខ្លាំងទេ ពីព្រោះថារដ្ឋសភាមានសិទ្ធិអំណាចច្រើន ។

**គ.២.២. សិទ្ធិអំណាចរបស់ប្រមុខរដ្ឋក្នុងទំរង់គ្រប់គ្រងរាជានិយមដោយអាស្រ័យរដ្ឋសភា**

(Parliamentary Monarchy) : ប្រមុខរដ្ឋក្នុងទំរង់នេះជាស្តេចហើយពុំមានអំណាចខ្លាំងទេ ពីព្រោះរាល់សកម្មភាពនៃប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលទទួលខុសត្រូវចំពោះរដ្ឋសភា។ ជាឧទាហរណ៍ក្នុងលក្ខណៈនេះ ដូចជាប្រទេសកម្ពុជាស្តេចជាប្រមុខរដ្ឋអស់មួយជីវិត តាមវាក្យខ័ណ្ឌទីពីរ **មាត្រា ៧** នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ កំណត់ថា "ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត" ឯ**មាត្រា ៨** "ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ។

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ"។ **មាត្រា ៩** "ព្រះមហាក្សត្រទ្រង់មានតួនាទីខ្ពង់ខ្ពស់ ជាអាជ្ញាកណ្តាលដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់"។ ចំពោះទំនាក់ទំនងក្នុងរដ្ឋសភាជាមួយប្រមុខរដ្ឋតាម**មាត្រា ១៨** បានកំណត់ថា "ព្រះមហាក្សត្រ ព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភា និងរដ្ឋសភាដោយព្រះរាជសារ ។ ព្រះរាជសារនេះព្រឹទ្ធសភា និងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ"។ ព្រះអង្គកោះប្រជុំសភាបន្ទាប់ពីបោះឆ្នោតរួច ៦០ ថ្ងៃ ( មាត្រា ៨២ និង ១០៦) ។ ចំពោះទំនាក់ទំនងជាមួយរដ្ឋាភិបាលវិញ តាមបញ្ញត្តិដែលក្នុង**មាត្រា ១៩** កំណត់ថា "ព្រះមហាក្សត្រ ទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩"។ រីឯ**មាត្រា ១១៩** បានកំណត់ថា "តាមសេចក្តីស្នើពីប្រធានដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រ នៃគណៈបក្សដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះនាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណៈបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្គូរផ្គងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។

មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦"។ ជាងនេះទៀត ព្រះអង្គអនុញ្ញាតិឱ្យរដ្ឋាភិបាលចូលគាល់ដើម្បីរាយការណ៍ ដូច**មាត្រា ២០** បញ្ជាក់ថា "ព្រះមហាក្សត្រ ទ្រង់ទទួលសវនាការជាផ្លូវការពីរដងក្នុងមួយខែ ឱ្យនាយករដ្ឋមន្ត្រីចូលគាល់រាយការណ៍ទូលថ្វាយទ្រង់ជ្រាប អំពីសភាពការណ៍នៃប្រទេសជាតិ"។ ក្នុង**វិស័យយោធា** ព្រះអង្គត្រូវបានកំណត់ក្នុង**មាត្រា ២២** ថា "នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា"។ និងវាក្យខ័ណ្ឌទីពីរនៃ**មាត្រាទី ២៤** កំណត់ថា "ព្រះមហាក្សត្រ ទ្រង់ប្រកាសសង្គ្រាមក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា"។ ចំណែក**មាត្រា ២៣** បញ្ជាក់ថា "ព្រះមហាក្សត្រ ទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ"។ ក្នុង**វិស័យតុលាការ**តាមវាក្យខ័ណ្ឌទីពីរ **មាត្រា ២១** បានកំណត់ថា "តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ"។ ក្នុង**វិស័យការបរទេស**តាម**មាត្រា ២៥** បញ្ជាក់ថា "ព្រះមហាក្សត្រ ទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅមកប្រចាំព្រះរាជាណាចក្រកម្ពុជា"។ និង**មាត្រា ២៦** ចែងថា "ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា"។ ក្នុង**វិស័យនីតិកម្ម**តាម**មាត្រា ២៨** កំណត់ថា "ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រម ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី"។ និងព្រះអង្គមានសិទ្ធិ**លើកលែងទោស** ដូច**មាត្រា ២៧** បានកំណត់ថា "ព្រះមហាក្សត្រ ទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស"។ សូមបញ្ជាក់ថា ប្រមុខរដ្ឋក្នុងប្រទេសកម្ពុជាពុំមានសិទ្ធិអំណាចខ្លាំងទេ ព្រោះរដ្ឋសភាមានសិទ្ធិអំណាចច្រើនជាង (រាជាធិបតេយ្យអាស្រ័យសភា) ។

### គ២.៣. សិទ្ធិអំណាចរបស់ប្រមុខរដ្ឋក្នុងទំរង់គ្រប់គ្រងសាធារណរដ្ឋបែបប្រធានាធិបតី

(Presidential Republic) : ទំរង់នេះប្រធានាធិបតីមានអំណាចច្រើនលើសលប់ ព្រោះគាត់ជាប្រមុខរដ្ឋផង និងជាប្រមុខរដ្ឋាភិបាលផង ។ លក្ខណៈនេះមានដូចជាសហរដ្ឋអាមេរិក[៧៥] ប្រមុខរដ្ឋជាប្រធានាធិបតីបោះឆ្នោតតាមវិធីមិនផ្ទាល់ ក្នុងអាណត្តិ ៤ ឆ្នាំ ។ ប្រធានាធិបតីជាប្រមុខរដ្ឋផង និងជាប្រមុខរដ្ឋាភិបាលផង ។ ក្នុងឋានៈជាប្រមុខអំណាចនីតិប្រតិបត្តិ ប្រធានាធិបតីមានសិទ្ធិតែងតាំងមន្ត្រីជាន់ខ្ពស់មួយចំនួនរបស់រដ្ឋ ដូចជារដ្ឋមន្ត្រី, មន្ត្រីតុលាការ, ឯកអគ្គរដ្ឋទូតប្រចាំប្រទេសក្រៅ.... ។ល។ ប៉ុន្តែក៏ត្រូវយល់ព្រមពីព្រឹទ្ធសភាផងដែរ ។ គាត់មានសិទ្ធិទទួលសច្ចាប័ន និងអប្បដិបិត្តិកម្មលើសន្ធិសញ្ញាអន្តរជាតិ ដោយមានការយល់ព្រមពីព្រឹទ្ធសភា ។ ប្រធានាធិបតីជាអគ្គមេបញ្ជាការកងទ័ពសហរដ្ឋអាមេរិក, មានសិទ្ធិតែងតាំងសេនាធិការទ័ព និងរៀបចំកិច្ចការសង្គ្រាម ។ មានសិទ្ធិបន្ធូរបន្ថយទោសដល់ឧក្រិដ្ឋជន ដែលតុលាការបានកាត់ទោសរួចហើយ លើកលែងតែពិរុទ្ធជនណាដែលសភាបានវិនិច្ឆ័យ ។ គាត់មានសិទ្ធិផ្ញើសេចក្តីព្រាងច្បាប់ ដែលរដ្ឋសភាបានអនុម័តបញ្ជូនត្រលប់ក្រោយ ដោយឱ្យសភាទាំងពីរពិចារណាឡើងវិញ ។ គឺថាបន្ទាប់ពីបានទទួលសេចក្តីព្រាងច្បាប់ ដែលបានផ្ញើរមកពីសភាទាំងពីរ ប្រធានាធិបតីអាចចុះហត្ថលេខាប្រសិនយល់ព្រម តែបើសិនជាមានការជំទាស់ គាត់បញ្ជូនត្រលប់ទៅឱ្យសភាណាមួយក្នុងចំណោមសភាទាំងពីរវិញ ។ ក្នុងករណីនេះពង្រាងច្បាប់វានឹងក្លាយជាច្បាប់ ប្រសិនបើសភាទាំងពីរទទួលសំលេងយល់ព្រមពីរភាគបីនៃសភានីមួយៗ ។ ប៉ុន្តែពង្រាងច្បាប់ដែលផ្ញើរមកពីសភាទាំងពីរឱ្យចុះហត្ថលេខាក្នុងរយៈពេលតែ ១០ ថ្ងៃប៉ុណ្ណោះ ទោះជាប្រធានាធិបតីយល់ព្រមក្តី ពុំយល់ព្រមក្តី សេចក្តីព្រាងច្បាប់នេះនឹងក្លាយជាច្បាប់ដោយស្វ័យប្រវត្តិ តែក្នុងល័ក្ខខ័ណ្ឌដែលសភាទាំងពីរកំពុងបើកសម័យប្រជុំ ប្រសិនបើរដ្ឋសភាបានផ្អាកសម័យប្រជុំនោះ

---

[៧៥]. ប្រធានាធិបតីសហរដ្ឋអាមេរិកបោះឆ្នោតពីតំណាក់គឺ :

- តំណាក់ទីមួយ រាស្ត្រជ្រើសរើសតំណាងរបស់ខ្លួន ( ព្រឹទ្ធសភា និងសភាតំណាងរាស្ត្រ ) នៃរដ្ឋនីមួយៗ ប៉ុន្តែសន្លឹកឆ្នោតដែលត្រូវប្រជារាស្ត្រជ្រើសរើសនោះ ត្រូវសរសេរឈ្មោះប្រធានាធិបតី ។
- តំណាក់ទីពីរ តំណាងទាំងនោះបោះឆ្នោតជ្រើសរើសប្រធានាធិបតី ។

សេចក្តីព្រាងនោះពុំអាចជាច្បាប់បានទេ[៧៦] ។ ក្រៅពីនេះប្រធានាធិបតីមានសិទ្ធិអំណាចច្រើនទៀតតាមការកំណត់របស់រដ្ឋធម្មនុញ្ញ ។ សូមបញ្ជាក់ថាទំរង់គ្រប់គ្រងលក្ខណៈរបៀបនេះ ប្រមុខរដ្ឋមានសិទ្ធិអំណាចខ្លាំងជាងគេ។ ប៉ុន្តែទោះជាប្រធានាធិបតីសហរដ្ឋអាមេរិក**មានអំណាចខ្លាំងក៏ដោយ ក៏ពុំអាចរំលាយសភាបានដែរ និងត្រឡប់មកវិញសភាក៏មិនអាចរំលាយរដ្ឋាភិបាលបានដែរ** ប៉ុន្តែអាចដាក់ទណ្ឌកម្មប្រធានាធិបតីតាមច្បាប់អ៊ិមពិជ្ជមិន ។ ត្រង់នេះបញ្ជាក់ថាប្រធានាធិបតីមិនទទួលខុសត្រូវអំពីនយោបាយរបស់ខ្លួនចំពោះរដ្ឋសភាទេ ប៉ុន្តែទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះរដ្ឋសភា។

**គ.២.៤. សិទ្ធិអំណាចនៃប្រមុខរដ្ឋក្នុងទំរង់សាធារណរដ្ឋបែបចំរុះ** : នេះជាទំរង់ដែលយើងបានដឹងរួចមកហើយដែរ គឺវាមានលក្ខណៈជាសាធារណរដ្ឋបែបសភាដែរ ប៉ុន្តែត្រង់ថាវាជាសាធារណរដ្ឋចំរុះ ពីព្រោះប្រធានាធិបតីដើរតួនយោបាយទាំងក្នុង និងក្រៅប្រទេស មានន័យថាប្រធានាធិបតីមានអំណាចច្រើនជាងនាយករដ្ឋមន្ត្រី នៅក្នុងទំរង់សាធារណរដ្ឋបែបសភា។ ប្រវត្តិសាស្ត្រនៃទំរង់ចំរុះនេះបានកើតមានឡើងនៅប្រទេសបារាំង តាមរយៈរដ្ឋធម្មនុញ្ញរបស់ឧត្តមសេនីយ៍ដឺហ្គោល(Général de Gaulle) និងបន្ទាប់មកមានលក្ខណៈនេះនៅឆ្នាំ ១៩៩១ រដ្ឋធម្មនុញ្ញប្រទេសរ៉ូម៉ានី និងមានប្រទេសដទៃទៀតនៅអឺរ៉ុបខាងកើត និងកណ្តាល ។ សិទ្ធិអំណាចរបស់ប្រមុខរដ្ឋនៃប្រទេសបារាំងចំពោះរដ្ឋសភាតាម**មាត្រា ១២** នៃរដ្ឋធម្មនុញ្ញបញ្ជាក់ថា គាត់មានសិទ្ធិរំលាយសភាជាន់ទាប ប៉ុន្តែការសំរេចនេះ គាត់ធ្វើទៅកើតបន្ទាប់ពីបានពិភាក្សាជាមួយនាយករដ្ឋមន្ត្រី និងប្រធានសភាទាំងពីរនៃរដ្ឋសភា ។ ប៉ុន្តែមានករណីពីរយ៉ាងដែលប្រធានាធិបតីត្រូវដឹងនោះ គឺក្នុងរយៈពេលមួយឆ្នាំចាប់ពីពេលបោះឆ្នោត និងកំឡុងពេលនៃការបំពេញកិច្ចជាប្រធានាធិបតីក្នុងសិទ្ធិអំណាចជាវិសាមញ្ញ ទាំងពីរករណីនេះប្រធានាធិបតីពុំអាចរំលាយសភាជាន់ទាបបានទេ ។

សិទ្ធិអំណាចចំពោះរដ្ឋាភិបាលប្រទេសបារាំង ប្រធានាធិបតីតែងតាំងនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីដទៃទៀតតាមសំណូមពររបស់នាយករដ្ឋមន្ត្រី. ប្រធានាធិបតីមានសិទ្ធិដកតំណែងនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីនានា ។

---

[៧៦]. Constitution of United State of America 1787 ។

## ២. ព្រះរាជា (Monarch)

ព្រះរាជា ជាប្រមុខរដ្ឋដែលកើតមានមុនដំបូងក្នុងប្រវត្តិសាស្ត្រនៃការដឹកនាំរដ្ឋ ។

**ក. លក្ខណៈពិសេសៗនៃឋានៈរបស់ព្រះរាជា** : នេះជាលក្ខណៈពិសេសៗដែលអាចកើតមានចំពោះព្រះរាជាក្នុងតំណែងជាប្រមុខរដ្ឋ។ ជាធម្មតាតាមភាពខុសគ្នាដ៏សំខាន់បំផុតមួយរបស់ព្រះរាជាពីពួកមន្ត្រីទាំងពួងរបស់រដ្ឋត្រង់ថា គាត់មានមុខងារជាប្រមុខរដ្ឋតាមរយៈសិទ្ធិពីកំណើត គាត់ទទួលមុខងារជាព្រះរាជាតាមរយៈតំណវង្សត្រកូល ហើយជាធម្មតាគាត់កាន់កាប់មុខងារនោះអស់មួយជីវិត ។ ដូចនេះលក្ខណៈពិសេសនៃឋានៈរបស់ព្រះរាជា មានសណ្តាប់ធ្នាប់នៃការឡើងស្នងរាជ (Succession to the throne) ធ្វើជាប្រមុខរដ្ឋត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញរបស់ប្រទេសនីមួយៗ ដែលជាទូទៅធ្វើឡើងតាមប្រព័ន្ធបីប្រភេទគឺ[៧៧] :

**ក១. ប្រព័ន្ធសាលីកា** (Salyca System or Frankisch Dynasty) : វាគឺជាប្រព័ន្ធមួយដែលប្រមុខរដ្ឋជាស្តេចឡើងសោយរាជ តាមការស្នងខ្សែខាងបុរសដែលមាន**ឋានៈពិសេស** (យកកូនច្បង) ។ ដូចជាប្រទេស**ជប៉ុន. បែលស៊ិក. នរវែស**......... ។ល។

**ក២. ប្រព័ន្ធកាស្ទីលា** (Castilla System) : គឺជាប្រព័ន្ធមួយដែលស្តេចជាប្រមុខរដ្ឋឡើងគ្រងរាជ តាមការស្នងនៃខ្សែខាងបុរសមាន**លក្ខណៈពេញចិត្ត** ជាពិសេស (ប្អូនប្រុសពៅ) លើកលែងតែបងស្រីច្បង ។ មានប្រទេសដូចជា**អេស្ប៉ាញ. ចក្រភពអង់គ្លេស. ហូឡង់**..... ។ល។ គឺថាបើមានកូនស្រីច្បងនោះអាចមានសិទ្ធិឡើងស្នងបានដែរ ប៉ុន្តែប្រព័ន្ធនេះសំដៅយកការពេញចិត្តរបស់ព្រះរាជា ។

**ក៣. ប្រព័ន្ធអូទ្រីស្ត** (Austrian System) : ជាប្រព័ន្ធមួយដែលស្ត្រីទទួលគ្រងរាជ ស្នងបានក្នុងករណីដែលអវត្តមាននូវខ្សែខាងបុរស ។ ប្រព័ន្ធនេះប្រើសំរាប់តែប្រទេសអូទ្រីស្ត ។

---

[៧៧]. Constitutional Law of Foreign Country.M-1994.Page 266

ជាសរុបទៅលក្ខណៈទាំងបីខាងលើនេះពុំទាន់គ្រប់គ្រាន់នៅឡើយទេ ពីព្រោះវាអាស្រ័យនឹងច្បាប់ ឬទំលាប់ដែលជាប្រវត្តិសាស្ត្រនៃការកកើតរដ្ឋនីមួយៗ ដោយមានការនិយមផ្សេងៗគ្នា ។ ការលើកយកប្រព័ន្ធធំៗបីខាងលើនេះ គ្រាន់តែជាមូលដ្ឋានមួយដែលប្រទេសក្រោមអាណានិគមប្រកាន់យកតាម បន្ទាប់ពីប្រទេសនោះស្ថិតនៅក្រោមអាណាព្យាបាលជាច្រើនឆ្នាំមក ។

**ខ. អំពីតំណែងរាជានុសិទ្ធិរបស់ព្រះរាជា** (Regency) : នេះគឺជាសិទ្ធិមួយដែលកំណត់ដោយរដ្ឋសភា ឬតាមរយៈឆន្ទានុសិទ្ធិរបស់ព្រះរាជា។ តាមខ្លឹមសារនេះដូចជា**មាត្រា ១១** រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ក្នុងវាក្យខ័ណ្ឌទីមួយថា "ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតា ដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះអង្គ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ" ។ សិទ្ធិនេះត្រូវបានកំណត់យ៉ាងជាក់លាក់សំរាប់បុគ្គលណាមួយទទួលយក ដូច**មាត្រា ១២** នៃបញ្ញត្តិដដែលបានកំណត់ក្នុងវាក្យខ័ណ្ឌទីមួយថា "នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជាណាចក្រកម្ពុជា" ។

**គ. អំពីភាពមិនអាចរំលោភបានរបស់ព្រះរាជា** (Inviolability) : នេះជាសកម្មភាពមួយដែលគ្មានអ្នកណាម្នាក់ហ៊ានរំលោភបំពានទៅលើព្រះរាជាបានឡើយ ដោយគេបានចារឹកក្នុងរដ្ឋធម្មនុញ្ញ ។ ដូច**មាត្រា ៧** វាក្យខ័ណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "អង្គព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ" ។ ការដែលមិនអាចរំលោភទៅលើព្រះរាជា វាជាល័ក្ខខ័ណ្ឌមួយដែលត្រូវបានកំណត់ដោយច្បាប់ទៅលើសកម្មភាពរបស់ប្រមុខរដ្ឋ ។ ការកំនត់ល័ក្ខខ័ណ្ឌទាំងនេះ ដូចជាព្រះរាជាមិនអាចបង្កើត ឬចូលជាសមាជិកគណៈបក្សនយោបាយជាដើម ។

**ឃ. អំពីឋានន្តរនៃព្រះរាជា** (Title) : ជាទូទៅព្រះរាជាតែងមានឈ្មោះហៅទៅតាមលក្ខណៈនៃប្រទេសនីមួយៗ ដូចជាឈ្មោះ (Title) របស់ស្ដេច (King) អធិរាជ (Emperor), ហ្សាហ (Shah មហាក្សត្រប្រទេសអៀរ៉ង់), ត្សារ (Tsar) ប្រទេសរុស្ស៊ី ។ល។ ទាំងអស់នេះជាលក្ខណៈសញ្ញារបស់

រដ្ឋដែលមានស្តេច (State Regalia) ដោយលក្ខណៈទាំងនោះត្រូវបានទទួលស្គាល់ចំពោះបរមរាជវាំង សំរាប់កំណត់លើបញ្ជីស៊ីវិល (Civillist) ជាឧទាហរណ៍**មាត្រា ៨៩** រដ្ឋធម្មនុញ្ញបែលស៊ិកបានកំនត់ថា បញ្ជីស៊ីវិលត្រូវបានកំណត់ដោយច្បាប់មួយទៅចំពោះកាលវេលាមួយ នៃរាល់ការឡើងកាន់អំណាច ។ ជាទូទៅគេហៅឋានន្តរនេះជានិមិត្តរូបនៃអំណាចកំពូល ។

**ង. អំពីព្រះមហេសីរបស់ព្រះរាជា** : ជាទូទៅមហេសីរបស់ព្រះរាជា ជានិច្ចកាលច្រើនពាក់ព័ន្ធឋានន្តរដូចស្តេចដែរ ប៉ុន្តែសិទ្ធិអំណាចពុំមានដូចស្តេចទេ ដែលគេបានចារឹកក្នុងច្បាប់កំពូលដូចជា **មាត្រា ១៦** រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា "ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ ។

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ទុកព្រះរាជកាយពលបំពេញព្រះរាជភារៈបំរើប្រយោជន៍សង្គមមនុស្សធម៌ សាសនា និងជួយព្រះមហាក្សត្រក្នុងព្រះរាជាកាតព្វកិច្ច ផ្នែកពិធីការ និងការទូត" ។

សរុបទៅ ប្រមុខរដ្ឋដែលជាស្តេចពិតជាមានលក្ខណៈខុស១គ្នា គឺថាស្តេចខ្លះកើតឡើងពីការសោយរាជស្នង, ស្តេចខ្លះកើតឡើងពីការជ្រើសរើសពីស្តេចផ្សេង១ ឬជ្រើសរើសពីពូជអំបូរ ឬវង្សត្រកូលស្តេច ដូចដែលបានជំរាបពីចំនុចខាងដើមរួចមកហើយ ។

## ៣. ប្រធានាធិបតី (President) :

**ក. ប្រវត្តិដើម** : ពាក្យថា "ប្រធានាធិបតី" ចេញពីពាក្យឡាតាំង "Presidens" មានន័យថា "**អ្នកដែលអង្គុយនៅពីមុខ**" ។ បន្ទាប់មកវាក៏កើតមាននូវប្រធានាធិបតីនៃព្រឹទ្ធសភា (President of Senate) នេះវាបញ្ជាក់នូវមុខងារ ឬតួនាទីមួយ ។ ប៉ុន្តែពាក្យប្រធានាធិបតីជាប្រមុខរដ្ឋក្នុងសាធារណរដ្ឋបុរាណក្រិច និងរ៉ូម ពុំត្រូវប្រើប្រាស់ទេ ហើយក៏ពុំមានអាទិភាពក្នុងសាធាណរដ្ឋគហបតីអង់គ្លេសដែរ ។ ព្រោះថានៅអង់គ្លេសកើតមានសាធារណរដ្ឋក្នុងរយៈពេលខ្លីបំផុត ដែលពេលនោះអំណាចនីតិប្រតិបត្តិផ្តល់រំលំរាជា ហើយបំពេញមុខងារជា "**ក្រុមប្រឹក្សារដ្ឋ**" ។

ដោយមានហេតុផលជាសាធារណរដ្ឋនៅអឺរ៉ុប ការអនុម័តយកការអនុវត្តនូវប្រធានាធិបតីក៏ចាប់កើតមានដំបូងក្នុងការបង្កើតអំណាចនីតិប្រតិបត្តិនៅសហរដ្ឋអាមេរិក ។ នៅក្នុងដំណាក់កាលដំបូងនៃរដ្ឋអាមេរិកអំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិរួមបញ្ចូលគ្នា នៅក្នុងអង្គការតំណាងរាស្ត្រតែមួយគត់គឺ Continental Congress ក្នុងខណៈនេះពុំអាចមានប្រមុខរដ្ឋតែមួយនោះទេ បន្ទាប់ពីបានពិភាក្សាយ៉ាងយូរ ក្នុងឆ្នាំ ១៧៨៧ ដើម្បីបង្កើតរដ្ឋធម្មនុញ្ញ ។ ក្នុងករណីនេះគេបានសំរេចថា មានតែបុគ្គលម្នាក់ទេដែលមានអំណាចនីតិប្រតិបត្តិ អញ្ចឹងហើយបានជាគេបង្កើតប្រមុខរដ្ឋជាសហព័ន្ធរបស់អាមេរិក ក្នុងក្របខ័ណ្ឌអំណាចនីតិប្រតិបត្តិមានឈ្មោះថា "**ប្រធានាធិបតី**" តាមរដ្ឋធម្មនុញ្ញនៃសហព័ន្ធ ។

ក្នុងប្រវត្តិសាស្ត្រមានតែសហរដ្ឋអាមេរិកមួយទេ ដែលចាប់កំណើតនូវមុខងារប្រធានាធិបតីដែលបង្រួមចូលគ្នាទៅបុគ្គលតែម្នាក់ គឺប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល ក្រោយមកទៀតកើតមាននៅប្រទេសពីរនៅអឺរ៉ុប ដែលប្រមុខរដ្ឋជាប្រធានាធិបតីក្នុងឆ្នាំ ១៨៤៨ គឺបារាំង និងស្វីស ។

**៩. ឋានៈធម្មនុញ្ញគតិយុត្តិ និងកិច្ចការនានារបស់ប្រធានាធិបតីក្នុងប្រព័ន្ធនយោបាយ** : នេះគឺជាសិទ្ធិអំណាចរបស់ប្រធានាធិបតី, តួនាទី និងឋានៈរបស់គាត់ក្នុងកិច្ចការនយោបាយ ឬជីវភាពនយោបាយរបស់ប្រទេសនីមួយៗ សិទ្ធិអំណាចទាំងនោះ ត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញគតិយុត្តិមួយច្បាស់លាស់ ។ ដូច**មាត្រា ៨៧** រដ្ឋធម្មនុញ្ញអ៊ីតាលីបានកំនត់ថា "ប្រធានាធិបតីសាធារណរដ្ឋ គឺជាប្រមុខរដ្ឋ....." ។ និង**មាត្រា ២** ចំណុច ១ រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកចែងថា "អំណាចនីតិប្រតិបត្តិត្រូវបានប្រគល់ទៅប្រធានាធិបតីសហរដ្ឋអាមេរិក" ។ យើងបានសិក្សាពីទំរង់គ្រប់គ្រងរដ្ឋរួចទៅហើយថាវាមានទំរង់របស់រដ្ឋពីរ គឺរាជាធិបតេយ្យ និងសាធារណរដ្ឋ ប៉ុន្តែក្នុងទំរង់សាធារណរដ្ឋមានបីប្រភេទ គឺបែបប្រធានាធិបតី, បែបសភា, បែបចំរុះ, (ពាក់កណ្តាលប្រធានាធិបតី) ដូចនេះយើងនឹងដឹងថា តើតួនាទីរបស់ប្រមុខរដ្ឋក្នុងទំរង់នីមួយៗមានលក្ខណៈខុសគ្នាយ៉ាងណា នោះក្នុងក្របខ័ណ្ឌសិទ្ធិអំណាចនឹងត្រូវសិក្សានូវតារាងដូចខាងក្រោម (មើលរូបទី ១៤ និងទី ១៥) ។ នៅក្នុងឋានៈធម្មនុញ្ញគតិយុត្តិ និងកិច្ចការរបស់ប្រធានាធិបតីកើតមានប្លែកៗតាមទំរង់គ្រប់គ្រងដូចជា :

**ខ៦. តាមទំរង់គ្រប់គ្រង** : ក្នុងទំរង់សាធារណរដ្ឋចំរុះ និងសាធារណរដ្ឋបែបប្រធានាធិបតី ការគ្រប់គ្រងរដ្ឋនៅក្នុងទំរង់គ្រប់គ្រងបែបនេះ ប្រធានាធិបតីជ្រើសរើសដោយប្រជាជន តាមវិធីបោះឆ្នោតដោយផ្ទាល់ និងពេលខ្លះដោយប្រយោល ( តាមរយៈសហការី) ឬ ( អ្នកជាប់ឆ្នោតលើកទី ១) ដូចជានៅអាមេរិកជាដើម ។ ចំពោះទំរង់សាធារណរដ្ឋបែបសភា ប្រធានាធិបតីជ្រើសរើសពីរដ្ឋសភា ឬក៏ពីសហការី ( សមាជិកដំបូង) ដោយមានការចូលរួមពីរដ្ឋសភា ដូចជាអ៊ីតាលី, ឥណ្ឌា, អាល្លឺម៉ង់........។ល។ នៅក្នុងទំរង់បែបនេះប្រមុខរដ្ឋពុំមានអំណាចច្រើន ដូចក្នុងទំរង់ប្រធានាធិបតីនិយមឡើយ ។

**ខ៧. បេក្ខភាពនៃប្រធានាធិបតី** : វាជាការកំណត់នូវលក្ខណៈសម្បត្តិមួយចំនួន ដើម្បីក្លាយខ្លួនជាបេក្ខជនសំរាប់តំណែងប្រធានាធិបតី ដូចជាអាយុ ( អាច ៣៥, ៤០, ៥០ ឆ្នាំ) កំណត់នូវសញ្ជាតិពីកំណើត ប៉ុន្តែពុំមែនសញ្ជាតូបនីយកម្មទេ ដូចជាអាមេរិក, ហ្វាំងឡង់....។ល។ ការកំណត់នូវអាណត្តិរបស់ប្រធានាធិបតី ភាគច្រើន ៤, ឬ ៥ ឆ្នាំ, ៦ ឆ្នាំ ( មិកស៊ិកូ), ៧ ឆ្នាំ ( អ៊ីតាលី, បារាំង.....) ។ល។ ក្រៅពីនេះប្រធានាធិបតីមានអភ័យឯកសិទ្ធិផ្សេងៗទៀត ដែលមានតិច ឬច្រើន ទៅតាមប្រទេសនីមួយៗដោយមានច្បាប់កំណត់ច្បាស់លាស់ ។ សព្វថ្ងៃនេះបេក្ខភាពប្រធានាធិបតី ត្រូវបានគេសង្កេតឃើញមានការកំនត់នូវល័ក្ខខ័ណ្ឌជាច្រើនខុសៗគ្នា ទៅតាមទំរង់នីមួយៗដូចជា : បែបសភា, បែបប្រធានាធិបតីនិយម, និងបែបចំរុះ ។

# តារាងទី ១

## ប្រទេសដែលកាន់របបសាធារណរដ្ឋ (រូបទី ១៤)

| សធារណរដ្ឋបែបប្រធានាធិបតី | សាធារណរដ្ឋចំរុះ | សាធារណរដ្ឋបែបសភា |
|---|---|---|
| សហរដ្ឋអាមេរិក | បារាំង | អាល្លឺម៉ង់ |
| ម៉ិកសិក្ធ | អ៊ីតាលី | អូទ្រីស្ត |
| អាស៊្សង់ទីន | ប៉័រទុយហ្គាល់ | ក្រិច |
| ប្រេស៊ីល | តួគី | ស្វីស |
| អ៊ូរ៉ុហ្គាយ | ហ្វាំងឡង់ | អៀរឡង់ |
| កូរ៉េ (ត្បូង) | ប៉ូឡូញ | អ៊ីស្លង់ |
| សេរី | ប៊ុលហ្គារី | ហុងគ្រី |
| អ៊ីរ៉ាក់ | រ៉ូម៉ានី | ស្លូវ៉ាគី |
| ហ្វីលីពីន | អ៊ុយក្រែន | ឡាទ្វី |
| អេស៊្សប | ឆេក្ធ | អ៊ីស្រាអែល |
| នីសេរី | ស៊ែប | ឥណ្ឌា |
| កាមេរូន | តៃវ៉ាន់ | ............. |
| កុងហ្គោ | ប៉ាគីស្ថាន | ............. |
| សេណេហ្គាល់ | លីបង់ | ។ល។ |
| អ៊ូហ្គង់ដា | .............. | |
| អាហ្វ្រិកខាងត្បូង | .............. | |
| សាធារណរដ្ឋឆាដ | ។ល។ | |

ក្នុងតារាងទី ១ នេះ ពុំមែនបញ្ជាក់នូវរបបនយោបាយទេ គឺគ្រាន់តែបង្ហាញអំពីប្រមុខរដ្ឋដែលមានទំរង់គ្រប់គ្រងរដ្ឋតាមបែបសាធារណរដ្ឋប៉ុណ្ណោះ ។ ព្រោះថាក្នុងប្រទេសដែលប្រកាន់ទំរង់សាធារណរដ្ឋខ្លះ ដែលមានប្រមុខរដ្ឋជាប្រធានាធិបតីប្រកាន់របបផ្តាច់ការ ឬអប្រជាធិបតេយ្យ ដូចជាប្រទេសអ៊ីរ៉ាក់ ( អាជ្ញាព្រឹត្ត ), ប្រទេសសង្គមនិយម ( លទ្ធិសង្គមនិយម ) ។

ដោយយោងតាមរបបសាធារណរដ្ឋមានលក្ខណៈបីទំរង់ខុសៗគ្នា នោះយើងអាចប្រៀបធៀបនូវចំណុចខ្លះៗដែលលក្ខណៈទាំងបីនោះ មានតាមរយៈតារាងទី ២ ( រូបទី ១៥ ) ដើម្បីបញ្ជាក់នូវសិទ្ធិអំណាចរបស់ប្រមុខរដ្ឋនៃប្រទេសដែលប្រកាន់របបសាធារណរដ្ឋ កំពុងមានសកម្មភាពជាក់ស្តែងនៃសម័យកាលបច្ចុប្បន្ន ។

### កំណត់សំគាល់ក្នុងតារាងទី ២ : (សំដៅលើសិទ្ធិអំណាចរបស់ប្រមុខរដ្ឋ)

- សញ្ញា n₀ ទំរង់ទាំងបីមានលក្ខណៈដូចគ្នា ។
- សញ្ញា ➔ ទំរង់ប្រធានាធិបតី និងទំរង់បែបចំរុះមានលក្ខណៈដូចគ្នា ។
- សញ្ញា ➪ ទំរង់ចំរុះ និងទំរង់បែបសភាមានលក្ខណៈដូចគ្នា ។

### តារាងទី ២ (រូបទី ១៥)
### សិទ្ធិអំណាចរបស់ប្រធានាធិបតីបែបសាធារណរដ្ឋ

| សាធារណរដ្ឋបែបប្រធានាធិបតី (ប្រមុខរដ្ឋ) | សាធារណរដ្ឋបែបចំរុះ (ប្រមុខរដ្ឋ) | សាធារណរដ្ឋបែបសភា (ប្រមុខរដ្ឋ) |
|---|---|---|
| ①. **និម្មិត្តរូប** ( មានអំណាចច្រើន )<br>- ជាប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល ។<br>②. **ការទទួលខុសត្រូវ :**<br>- រដ្ឋាភិបាល ទទួលខុសត្រូវចំពោះប្រធានាធិបតី និងមិនទទួលខុសត្រូវចំពោះរដ្ឋសភាទេ ។ | ①. **និម្មិតរូប**<br>- ប្រធានាធិបតីជាប្រមុខរដ្ឋ, អំណាចនីតិប្រតិបត្តិ ត្រូវចែកគ្នាជាមួយប្រមុខរដ្ឋាភិបាល ។ | ①. **និម្មិតរូប :**<br>- ប្រធានាធិបតីជាប្រមុខរដ្ឋគ្រាន់តែជានិម្មិតរូប ។ អំណាចនីតិប្រតិបត្តិប្រគល់ទៅប្រមុខរដ្ឋាភិបាល ។ |

| | | |
|---|---|---|
| ③. **មុខងារតែងតាំង**<br>- តែងតាំងសមាជិកទាំងឡាយរបស់រដ្ឋាភិបាល ។<br>- ដកមុខងារសមាជិករដ្ឋាភិបាលពីតំណែងតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។<br>④. **មុខងារនីតិកម្ម :**<br>- មានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ ឬក៏សិទ្ធិសំណើរច្បាប់ ។<br>$\eta_o$ ការកាន់កាប់សិទ្ធិប្រកាសឱ្យប្រើប្រាស់ច្បាប់នានាដែលអនុម័តដោយរដ្ឋសភា ។<br>➔ មានសិទ្ធិវេតូច្បាប់នានាដែលអនុម័តដោយរដ្ឋសភា ។<br>- មានសិទ្ធិបង្កើតក្រឹត្យទាំងឡាយតាមឆន្ទានុសិទ្ធិរបស់ខ្លួនដែលមានកំលាំងច្បាប់ ។<br>⑤. **មុខងារយោធា :**<br>➔ ប្រធានាធិបតីក្នុងមុខងារជាអគ្គមេបញ្ជាការកំពូលនៃកងកំលាំងប្រដាប់អាវុធ ។ | ②. **ការទទួលខុសត្រូវ :**<br>- រដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខរដ្ឋសភា និងមានករណីខ្លះៗទទួលខុសត្រូវចំពោះប្រធានាធិបតី ។<br>- ប្រធានាធិបតីមិនទទួលខុសត្រូវនូវសកម្មភាពរបស់រដ្ឋាភិបាលទេ ។<br>③. **មុខងារតែងតាំង :**<br>⇨ ប្រធានាធិបតីចាត់តាំងប្រមុខរដ្ឋាភិបាលតាមវិន័យមួយ គឺជ្រើសរើសចេញពីចំនួនអ្នកដឹកនាំទាំងអស់ដែលមានឥទ្ធិពលក្នុងបក្សនយោបាយ ឬបក្សនយោបាយដែលមានឥទ្ធិពលក្នុងរដ្ឋសភា និងតាមការស្នើសុំពីប្រមុខរដ្ឋាភិបាល.ប្រធានាធិបតីចាត់តាំងសមាជិកនានារបស់រដ្ឋាភិបាល ។<br>- ប្រធានាធិបតីអាចដកប្រមុខរដ្ឋាភិបាលក្រោមល័ក្ខខ័ណ្ឌកំណត់ទាំងឡាយ ។<br>- តាមការស្នើសុំពីប្រមុខរដ្ឋាភិបាលប្រធានាធិបតីមានសិទ្ធិដកសមាជិកនានារបស់រដ្ឋាភិបាល ។ | ②. **ការទទួលខុសត្រូវ :**<br>- រដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខរដ្ឋសភាប៉ុណ្ណោះ ។<br>- ប្រមុខរដ្ឋាភិបាលទទួលខុសត្រូវនូវសកម្មភាពរបស់ខ្លួនពុំមែនប្រធានាធិបតីជាអ្នកទទួលខុសត្រូវឡើយ ។<br>③. **មុខងារតែងតាំង :**<br>⇨ ប្រធានាធិបតីក្នុងមុខងារនេះមានសិទ្ធិអំណាចដូចមុខងារប្រធានាធិបតីក្នុងរបបចំរុះដែរ.ប៉ុន្តែប្រធានាធិបតីមិនអាចដកប្រមុខរដ្ឋាភិបាលតាមចំណង់របស់ខ្លួនបានទេ តែតាមសំណើររបស់ប្រមុខរដ្ឋាភិបាល.គាត់មានសិទ្ធិដកសមាជិករដ្ឋាភិបាល ។<br>④. **មុខងារនីតិកម្ម :**<br>-ប្រធានាធិបតីមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ដោយមានការយល់ព្រមជាមួយរដ្ឋាភិបាល ។<br>$\eta_o$ ប្រកាសឱ្យប្រើប្រាស់ច្បាប់នានាដែលបានអនុម័តដោយរដ្ឋសភា ។<br>- គ្មានសិទ្ធិវេតូទៅលើច្បាប់នានាដែលអនុម័តដោយរដ្ឋសភា<br>- គាត់មានសិទ្ធិផ្តល់នូវការបញ្ហាណាមួយដែលមានការយល់ព្រមជាមួយរដ្ឋាភិបាល ។ |

| | | |
|---|---|---|
| **⑥. មុខងារក្រៅប្រទេស :**<br>- ប្រធានាធិបតីកំណត់កម្មវិធីនយោបាយក្រៅប្រទេសតាមឆន្ទានុសិទ្ធិរបស់ខ្លួនដាក់ទៅលើរដ្ឋាភិបាលរបស់គាត់ ។<br>**⑦. មុខងារសណ្ដាប់ធ្នាប់ :**<br>- ប្រធានាធិបតីមានសិទ្ធិកោះហៅប្រជុំវិសាមញ្ញរបស់រដ្ឋសភាតាមឆន្ទានុសិទ្ធិ ។<br>- ប្រធានាធិបតីមាន( អាចគ្មាន) សិទ្ធិរំលាយរដ្ឋសភានិងជ្រើសតាំងបោះឆ្នោតសភាថ្មី ។<br>- ប្រធានាធិបតីមាន( អាចគ្មាន) សិទ្ធិរៀបចំធ្វើប្រជាមតិតាមឆន្ទានុសិទ្ធិ ។<br>➔ ប្រធានាធិបតីមានសិទ្ធិកំណត់ ឬមិនកំណត់ចំពោះការប្រកាសភាពអាសន្នក្នុងប្រទេស ។<br>**⑧. មុខងារលើកលែងទោស:**<br>ៗ ប្រធានាធិបតីមានសិទ្ធិ.សុំសុខមាលទោសជូនមេដាយ.ផ្ដល់សញ្ជាតិនិងសេចក្ដីសំរេចជាឯកត្តបុគ្គលផ្សេងៗទៀត ។<br>**⑨. មុខងារបក្ស :**<br>- ប្រធានាធិបតីជាប្រមុខដែលដឹកនាំបក្សនយោបាយ និងកម្មវិធីបក្សនយោ បាយ ។ | **④. មុខងារនីតិកម្ម :**<br>- ប្រធានាធិបតីមានសិទ្ធិសំណើច្បាប់ ។<br>- ប្រធានាធិបតីមានសិទ្ធិបង្កើតក្រឹត្យដែលបានទទួលអនុញ្ញាតពីរដ្ឋាភិបាល ។<br>ៗ ប្រកាសឱ្យប្រើប្រាស់ច្បាប់នានាដែលបានអនុម័តដោយរដ្ឋសភា ។<br>➔ សិទ្ធិវ៉ែតូច្បាប់នានាដែលបានអនុម័តដោយរដ្ឋសភា ។<br>**⑤. មុខងារយោធា :**<br>➔ ប្រធានាធិបតីក្នុងមុខងារជាអគ្គមេបញ្ជាការកំពូលនៃកងកំលាំងប្រដាប់អាវុធ ។<br>**⑥. មុខងារក្រៅប្រទេស :**<br>- ប្រធានាធិបតីមានសិទ្ធិអំណាចយ៉ាងទូលាយក្នុងនយោបាយក្រៅប្រទេសប៉ុន្តែគាត់សិក្សាលើគោលជំហរនយោបាយក្រៅប្រទេសរបស់រដ្ឋាភិបាល ។<br>**⑦. មុខងារសណ្ដាប់ធ្នាប់ :**<br>- ប្រធានាធិបតីអាចមានរឺគ្មានសិទ្ធកោះហៅប្រជុំជាវិសាមញ្ញរបស់សភាតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។<br>- ប្រធានាធិបតីមានសិទ្ធកំណត់ ឬមិនកំណត់ក្នុងការរំលាយរដ្ឋសភា និងចាត់តាំងបោះឆ្នោតសភាថ្មី ។<br>- ប្រធានាធិបតីមានសិទ្ធរៀបចំធ្វើប្រជាមតិក្នុងល័ក្ខខ័ណ្ឌកំណត់នានា ។<br>➔ ប្រធានាធិបតីមានសិទ្ធិកំណត់ ឬមិនកំណត់ចំពោះការប្រកាសភាពអាសន្នក្នុងប្រទេស ។ | **⑤. មុខងារយោធា :**<br>- ប្រធានាធិបតីអាចជាអគ្គមេបញ្ជាការកំពូលតាមទំរង់ ប៉ុន្តែការពិតជាក់ស្តែងការដឹកនាំកំលាំងយោធាត្រូវបានបំពេញនាទីដោយរដ្ឋមន្ត្រីការពារជាតិដែលបានផ្ទុកផ្ដាក់ទៅប្រមុខរដ្ឋាភិបាល ។<br>**⑥. មុខងារក្រៅប្រទេស :**<br>- ប្រធានាធិបតីតំណាងឱ្យរដ្ឋនៅក្នុងមជ្ឈដ្ឋាននយោបាយក្រៅប្រទេសហើយយល់ស្របគ្នានូវសកម្មភាពរបស់ខ្លួនជាមួយកម្មវិធីនយោបាយក្រៅប្រទេសរបស់រដ្ឋាភិបាល ។<br>**⑦. មុខងារសណ្ដាប់ធ្នាប់ :**<br>➔ ប្រធានាធិបតីអាចមានរឺគ្មានសិទ្ធកោះហៅប្រជុំជាវិសាមញ្ញរបស់សភាតាមចំណង់របស់ខ្លួន ។<br>- ប្រធានាធិបតីមានសិទ្ធិរំលាយរដ្ឋសភា និងចាត់តាំងបោះឆ្នោតសភាមុនអាណត្តិក្នុងករណីដែលរដ្ឋសភាសំដែងការមិនទុកចិត្តដល់រដ្ឋាភិបាល ដោយមានល័ក្ខខ័ណ្ឌ ។<br>- ប្រធានាធិបតីគ្មានសិទ្ធិរៀបចំធ្វើប្រជាមតិ ។<br>- ប្រធានាធិបតីគ្មានសិទ្ធិប្រកាសនូវភាពអសន្នបានទេបើគ្មានការយល់យល់ព្រមពីរដ្ឋាភិបាល ឬរដ្ឋសភា |

| | | |
|---|---|---|
| | **⑧. មុខងារលើកលែងទោសៈ**<br>ៗ ប្រធានាធិបតីមានសិទ្ធិសុំសុខមាលទោស.ជូនមេដាយឥស្សរយស. ផ្តល់សញ្ជាតិ និងសំរេចធ្វើសេចក្តីសំរេចជាឯកត្តបុគ្គលផ្សេងៗ ។<br>**⑨. មុខងារបក្ស :**<br>- ប្រធានាធិបតីមិនមែនជាប្រមុខដឹកនាំបក្សនយោបាយទេហើយក៏មិនមានទំនាក់ទំនងផ្ទាល់នឹងបក្សដែរក្នុងករ ណីខ្លះផ្ទុយពីនេះ ។<br>- អាចជាប្រមុខដឹកនាំបក្ស | **⑧. មុខងារលើកលែងទោសៈ**<br>ៗ ប្រធានាធិបតីមានសិទ្ធិសុំសុខមាលទោសនិងលើកលែងទោសដូចទំរង់ពីរទៀតដែរ ។<br>**⑨. មុខងារបក្ស :**<br>-ប្រធានាធិបតីក្នុងសកម្មភាពរបស់ខ្លួនមិនអាស្រ័យនឹងបក្សនយោបាយទេ ។ |

**ឍ. អង្គការជំនួយនានា និងស្ថាប័នដែលជាសេនាធិការរបស់ប្រមុខរដ្ឋ** : នៅក្នុងអត្ថន័យនេះគេអាចបរិយាយបានហៅថា "**ឧបករណ៍របស់ប្រមុខរដ្ឋ**" ដែលយើងជួបនៅក្នុងស្មាដៃផ្សេងៗ ។ ដោយយោងតាមភាពខ្លាំង ឬខ្សោយរបស់ប្រមុខរដ្ឋនៃប្រទេសនីមួយៗ នោះតំរូវការជំនួយកិច្ចការផ្សេងៗ ពីសមាជិកក៏មានចំនួនទៅតាមការកើតការងារនោះដែរ ។ ការបង្កើតស្ថាប័នជំនួយនេះសំរាប់ផ្តល់ការងាយស្រួលដល់ការផ្តល់ពត៌មាន ឬត្រួតពិនិត្យរបស់ប្រធានាធិបតីពីប្រភពផ្សេងៗ នៃការគ្រប់គ្រងក្នុងប្រទេស និងពត៌មានក្រៅប្រទេស ជាក់ស្តែងដូចជាឧបករណ៍របស់ប្រធានាធិបតីបារាំង "វិមានប្រធានាធិបតី" មានសមាជិក ៥០០ នាក់ ហើយចែកជាពីរផ្នែក គឺផ្នែកស៊ីវិល និងយោធា ។

ដោយឡែកចំពោះឧបករណ៍ជំនួយផ្ទាល់ទៅប្រធានាធិបតី ត្រូវបានកំណត់ដោយច្បាប់ច្បាស់លាស់ដែលមានដូចជាលេខាធិការ. ទីប្រឹក្សា. ជំនួយការ. និងសេវាផ្សេងៗខាងផ្នែកជំនាញ ។ល។

សរុបទៅស្ថាប័នជំនួយ ឬឧបករណ៍ជំនួយប្រធានាធិបតី គឺជាភារកិច្ចមួយដែលសំរាប់ធ្វើសមិទ្ធិ. ត្រួតពិនិត្យ ផ្តល់ពត៌មាន. និងសកម្មភាពដទៃទៀតជូនទៅប្រធានាធិបតីផ្ទាល់ ។ រីឯចំនួននៃសមាជិកនោះ វាអាស្រ័យនឹងទំហំការងាររបស់ប្រមុខរដ្ឋក្នុងកិច្ចការអំណាចសាធារណៈ ។ ស្ថាប័នជំនួយដែលជាសេនាធិការរបស់ប្រមុខរដ្ឋមានរូបរាងពីរប្រភេទគឺ : **ទីមួយ** : ស្ថាប័នចំណុះផ្ទាល់របស់

ប្រមុខរដ្ឋ ដែលជាសេនាធិការ (ជាស្ថាប័ន) និង**ទីពីរ** : ជាលេខាធិការ ឬទីប្រឹក្សាផ្ទាល់របស់ប្រមុខរដ្ឋ (ជាមនុស្ស)។ ប៉ុន្តែការបង្កើតស្ថាប័ន ឬសេវាកម្មជំនួយនេះ វាជាល័ក្ខខ័ណ្ឌនៃការអនុវត្តន៍ជាក់ស្តែងរបស់ប្រទេសនីមួយៗតែប៉ុណ្ណោះ ។

## ៤. **រដ្ឋាភិបាល** (Government)

### ក. **លក្ខណៈទូទៅនៃរដ្ឋាភិបាល**

រដ្ឋាភិបាលគឺជាអង្គការសហសេវិកមួយនៃសមត្ថកិច្ចទូទៅ ដែលបំពេញនាទីក្នុងការដឹកនាំនៃសកម្មភាពប្រតិបត្តិការរដ្ឋបាលនៅក្នុងប្រទេស។ ជាងនេះទៅទៀតរដ្ឋាភិបាលវាមានឈ្មោះផ្សេងៗទៀតដូចជាក្រុមប្រឹក្សារដ្ឋមន្ត្រី (Council of Minister) ឬគណៈរដ្ឋមន្ត្រី (Cabinet) និងឈ្មោះដទៃទៀតដូចជាប្រទេសន័រវែស, ហ្វាំងឡង់, ស៊ុយអ៊ែដ រដ្ឋាភិបាលប្រទេសទាំងនេះមានឈ្មោះថាក្រុមប្រឹក្សារដ្ឋ ឯនៅក្នុងប្រទេសស្វីសមានឈ្មោះថាក្រុមប្រឹក្សាសហព័ន្ធ ។ល។ តាម**មាត្រា ១១៨** រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ក្នុងវាក្យខ័ណ្ឌទីមួយថា "គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា" ។ ពាក្យថារដ្ឋាភិបាលដែលប្រើក្នុងរដ្ឋធម្មនុញ្ញជាភាសាអង់គ្លេសថា "Government" ប្រែជាធម្មតាថា "**រដ្ឋាភិបាល**" ប៉ុន្តែវាមានន័យលើសនេះទៅទៀតនូវពាក្យ "Government" នោះគឺថែមន័យ**គ្រប់គ្រង** ឬក៏រួមទាំង**ប្រព័ន្ធអង្គការនីតិបញ្ញត្តិ** និងនីតិប្រតិបត្តិដែលជាសមាសភាពប្រមុខរដ្ឋក្នុងរដ្ឋាភិបាលនោះ ដែលរដ្ឋាភិបាលក្នុងន័យនេះគឺតំណាងឱ្យ "**ប្រទេស ឬរដ្ឋ**" ទាំងមូល ។ ដូចនេះតាមន័យនៃពាក្យ "Government" ក្នុងល័ក្ខខ័ណ្ឌនៃការបង្កើតរដ្ឋាភិបាល នៃប្រទេសនីមួយៗប្រព្រឹត្តឡើងតាមលក្ខណៈពីរប្រភេទគឺ[៧៨] :

**ក₁. ប្រភេទទីមួយ** : នៅក្នុងប្រភេទនេះគេអាចនិយាយថា ជាទស្សនៈនៃសមាសភាពនយោបាយរបស់រដ្ឋាភិបាល គឺថាតាមទស្សនៈនេះរដ្ឋាភិបាលច្រើនរៀបចំឡើង ឬកើតឡើងពីភាគផ្សំផ្សេងៗច្រើនករណីទៀត ដូចជារដ្ឋាភិបាលមានលក្ខណៈជាបក្សតែមួយ, រដ្ឋាភិបាលមានលក្ខណៈចំរុះ, រដ្ឋាភិបាលមានលក្ខណៈគ្មានបក្សនយោបាយ..... ។

[៧៨]. Constitutional Law of Foreign Country, Part II, M.1995, Page 272 ។

**ក.១.១. រដ្ឋាភិបាលបក្សតែមួយ** : គឺជារដ្ឋាភិបាលដែលកើតមានដោយបក្សតែមួយ ក្នុងរដ្ឋាភិបាលពិតប្រាកដនៃប្រទេសសុក្រឹត្យណាមួយ ។ រដ្ឋាភិបាលរបៀបនេះនៅក្នុងរដ្ឋប្រជាធិបតេយ្យច្រើនប្រព្រឹត្តទៅនៅក្នុងប្រទេសដែលមានទំរង់គ្រប់គ្រងបែបសភា ឬបែបចំរុះ ។ វាកើតមានត្រង់ថាកាលណាបក្សនយោបាយមួយក្នុងចំណោមបក្សនយោបាយនានា បានទទួលសំលេងឆ្នោតច្រើនដាច់ខាត ដែលមានអាសនៈច្រើនបំផុតនៅក្នុងរដ្ឋសភា ឬក៏ក្នុងសភាតំណាងរាស្ត្រ ដោយហេតុនេះគណៈបក្សឈ្នះនោះទទួលរៀបចំរដ្ឋាភិបាលតែភាគីម្នាក់ឯង ។ ត្រង់នេះហើយគេហៅថារដ្ឋាភិបាលបក្សតែមួយ ដែលវាច្រើនកើតមាននៅចក្រភពអង់គ្លេស និងកើតមានក្នុងបណ្តាប្រទេសដែលប្រកាន់របបសាធារណរដ្ឋបែបប្រធានាធិបតី ព្រោះថារដ្ឋាភិបាលវានឹងត្រូវរៀបចំឡើងដោយប្រធានាធិបតីដែលជាប់ឆ្នោត ។ រីឯក្នុងរបបផ្តាច់ការ (លទ្ធិផ្តាច់ការ) រដ្ឋាភិបាលកើតមានពីបក្សតែមួយប៉ុណ្ណោះដែរ ដូចជារបបនយោបាយកុំម្មុយនីស្ត ។

**ក.១.២. រដ្ឋាភិបាលចំរុះ** : គឺជារដ្ឋាភិបាលដែលកើតមានដោយការចូលរួមពីបក្សជាច្រើន ។ វាជារដ្ឋាភិបាលដែលកើតមាននៅក្នុងទំរង់គ្រប់គ្រងបែបសភា ឬចំរុះ ដែលកាលណាគណៈបក្សណាមួយវាពុំបានទទួលសំឡេងច្រើនដាច់ខាតក្នុងអាសនៈរដ្ឋសភា ឬសភាតំណាងរាស្ត្រ ។ ជយនកាលគេអាចនិយាយបានថារដ្ឋាភិបាលចំរុះ គឺជាលទ្ធផលនៃការព្រមព្រៀងគ្នារវាងបក្សទាំងឡាយ អំពីកម្មវិធីគ្រប់គ្រងរួមគ្នា ។ រដ្ឋាភិបាលបក្ស ឬរដ្ឋាភិបាលចំរុះនេះត្រូវទទួលគាំទ្រពីសមាជិកសភាភាគច្រើនដាច់ខាត ។ រដ្ឋាភិបាលចំរុះច្រើនកើតមាននៅអាល្លឺម៉ង់. អ៊ីតាលី..... និងកើតមាននៅក្នុងប្រទេសកម្ពុជាឆ្នាំ ១៩៩៣ តាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ១៩៩៤ កំណត់ក្នុងវាក្យខ័ណ្ឌចុងក្រោយនៃមាត្រា ៤ ថា "ក្នុងករណីដែលព្រះមហាក្សត្រ ទ្រង់បានតែងតាំងនាយករដ្ឋមន្ត្រីទីមួយមួយរូប និងនាយករដ្ឋមន្ត្រីទីពីរមួយរូប តាមមាត្រា[៧៩] ១៣៨ នៃរដ្ឋធម្មនុញ្ញនាយក

---

[៧៩]. មាត្រានេះត្រូវបានលប់ចោល ក្រោយពីរដ្ឋធម្មនុញ្ញធ្វើវិសោធនកម្ម ឆ្នាំ ១៩៩៨ ។

. នៅក្នុងអាណត្តិទី ២ ពីឆ្នាំ ១៩៩៨-២០០៣ រដ្ឋាភិបាលកម្ពុជាកើតឡើងពីគណៈបក្សនយោបាយពីរ គឺប្រជាជន និងហ៊្វុន ស៊ិនប៉ិច (រដ្ឋាភិបាលចំរុះ) ប៉ុន្តែមាននាយករដ្ឋមន្ត្រីតែមួយទេមកពីគណៈបក្សប្រជាជន ។

រដ្ឋមន្ត្រីទាំងពីររូបនេះមានសិទ្ធិអំណាច និងបុព្វសិទ្ធិស្មើៗគ្នាដើម្បីដឹកនាំរាជរដ្ឋាភិបាល ដោយឈរលើគោលការណ៍សហព័ន្ធសំរេច" ។

**ក៑.៣. រដ្ឋាភិបាលគ្មានបក្សនយោបាយ :** នេះជារដ្ឋាភិបាលដែលកំរកើតមានណាស់ ព្រោះរដ្ឋាភិបាលរបៀបនេះកើតមានកាលណាក្នុងករណីដែលបក្សនយោបាយទាំងអស់ ពុំបានទទួលជោគជ័យក្នុងការបង្កើតរដ្ឋាភិបាលចំរុះមួយតាមរយៈរដ្ឋសភា មានន័យថារដ្ឋសភាពុំបានបោះឆ្នោតឱ្យបង្កើតរដ្ឋាភិបាលចំរុះ ហើយបក្សទាំងអស់នោះក៏គ្មានលទ្ធភាពនឹងរំលាយរដ្ឋសភាដែរ (សភាតំណាងរាស្ត្រ)។ ដូចនេះរដ្ឋាភិបាលអាចកើតមានដែលគេហៅថា "**រដ្ឋាភិបាលសេវាកម្ម**" "**ឬរដ្ឋាភិបាលការងារ**" សមាសភាពនៃរដ្ឋាភិបាលរបៀបនេះ កើតពីអ្នកជំនាញនានារបស់បក្សនយោបាយផ្សេងៗ ប៉ុន្តែពុំមែនជាកម្មសិទ្ធិនៃបក្សទាំងនោះទេ ។ ការបង្កើតរដ្ឋាភិបាលមានលក្ខណៈជាសេវាកម្មនេះ គឺគ្រាន់តែបញ្ចៀសចេញពីវិបត្តិគណៈបក្សតែប៉ុណ្ណោះ ដើម្បីអត់ធ្មត់ក្នុងពេលវេលាមួយដ៏ចាំបាច់ ។ ផ្ទុយទៅវិញបើកើតមានករណីនេះឡើង សំរាប់ប្រទេសអង់គ្លេសត្រូវបានដោះស្រាយដោយព្រះមហាក្សត្រ គឺព្រះអង្គជាអ្នកចង្អុលបង្ហាញតាមទំលាប់របស់ប្រទេសអង់គ្លេស ។

**ក២. ប្រភេទទីពីរ ឬទស្សនៈតាមការកំណត់ដោយច្បាប់ :** គឺជាទស្សនៈមួយដែលរដ្ឋាភិបាលត្រូវបង្កើតឡើងដោយច្បាប់ពិតប្រាកដ។ រដ្ឋាភិបាលទាំងឡាយដែលគេប្រកាន់យកច្បាប់ជាធំ គឺមានន័យថាការបង្កើតរដ្ឋាភិបាលត្រូវបានកំណត់ដោយច្បាប់មួយច្បាស់លាស់ តាមរយៈការប្តូរវេណគ្នាក្នុងការគ្រប់គ្រង ប៉ុន្តែវាស្របនឹងរដ្ឋធម្មនុញ្ញដែលគេនិយាយថារដ្ឋាភិបាលមានលក្ខណៈអចិន្ត្រៃយ៍ ទោះជាមានការផ្លាស់ប្តូរសមាសភាពរដ្ឋសភា ឬក៏បោះឆ្នោតទំលាក់ប្រធានាធិបតីក៏ដោយ ។ រដ្ឋាភិបាលដែលមានលក្ខណៈរបៀបនេះ គឺកើតមានក្នុងប្រទេសប្រកាន់ទំរង់គ្រប់គ្រងបែបសភា និងទំរង់ចំរុះដែរ ដែលពេលនោះគេបានរៀបចំធ្វើការបោះឆ្នោតក្នុងរដ្ឋសភា (សភាជាន់ទាប) ដើម្បីសុំសេចក្តីទុកចិត្ត ឬមិនទុកចិត្តពីរដ្ឋសភាចំពោះរដ្ឋាភិបាល ឬប្រធានាធិបតី។ ការប្តូរវេណក្នុងពេលកើតមានរដ្ឋាភិបាលរបៀបនេះវាមានលក្ខណៈជាបណ្តោះអាសន្ន ។

## ៥. អត្ថន័យគតិយុត្តិនៃរដ្ឋាភិបាល

ពាក្យថារដ្ឋាភិបាលវាមានន័យសំខាន់ជាងនេះទៀត ដែលមានលក្ខណៈយ៉ាងទូលាយ ដូច **មាត្រា ២** ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ១៩៩៤ របស់កម្ពុជាកំណត់ថា "រាជរដ្ឋាភិបាល. គ្រប់គ្រង. បញ្ជា. ប្រើប្រាស់យោធា. នគរបាល កំលាំងប្រដាប់អាវុធផ្សេងៗទៀត និងរដ្ឋបាលក្នុងការធ្វើសកម្មភាពរបស់ខ្លួន" ។ ដើម្បីបញ្ជាក់នូវអត្ថន័យនៃរដ្ឋាភិបាល សូមតាមដាននូវចំនុចមួយចំនួនដូចខាងក្រោម :

**ក. សមត្ថកិច្ចនៃរដ្ឋាភិបាល** (Competence of Government) : សមត្ថកិច្ចនៃរដ្ឋាភិបាលគឺជាវិន័យមួយដែលត្រូវបានកំណត់ដោយច្បាប់គ្រឹះ ឬបទដ្ឋានកិច្ចនានាតាមទំរង់របស់រដ្ឋបែបរាជាធិបតេយ្យ ឬបែបសាធារណរដ្ឋក្នុងក្របខ័ណ្ឌដែនដីឯកភូត ឬសហព័ន្ធ ។ ប៉ុន្តែជាទូទៅគេបានកំណត់នូវអំណាចបីជាសំខាន់ គឺអំណាចនីតិបញ្ញត្តិ. នីតិប្រតិបត្តិ និងអំណាចតុលាការតាម**មាត្រា ១** ច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រីកម្ពុជា ១៩៩៤ បានកំណត់ថា "រាជរដ្ឋាភិបាលកម្ពុជា ជាអង្គការនីតិប្រតិបត្តិមានភារកិច្ចកំណត់ និងអនុវត្តនយោបាយរបស់រដ្ឋ ស្របតាមគោលការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ ។ រាជរដ្ឋាភិបាលធានាការអនុវត្តន៍ច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការអ្វីដែលជាសមត្ថកិច្ចរបស់អង្គការនីតិបញ្ញត្តិ និងអង្គការតុលាការ ។

រាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅ និងសកម្មភាពរបស់ខ្លួន" ។ នៅវាក្យខ័ណ្ឌចុងក្រោយនេះ វាស្របតាមប្រទេសដែលមានដែនដីជារដ្ឋឯកភូត និងប្រកាន់របបរាជាធិបតេយ្យអាស្រ័យរដ្ឋសភា ។ ដើម្បីឱ្យមានលក្ខណៈកាន់តែច្បាស់ទៀតនោះ តាម**មាត្រា ៣** នៃច្បាប់ដដែលបានកំណត់ថា "រាជរដ្ឋាភិបាលដឹកនាំកិច្ចការទូទៅរបស់រដ្ឋ តាមកម្មវិធីនយោបាយ និងផែនការរដ្ឋ ដែលរដ្ឋសភាបានអនុម័ត" ។

ដូចនេះសមត្ថកិច្ចនៃរដ្ឋាភិបាល ឬសមាជិករដ្ឋាភិបាល គឺជាភារកិច្ចចាំបាច់ដែលបានចារឹកកំណត់ដោយច្បាប់ច្បាស់លាស់ ក្នុងកម្មវត្ថុនៃប្រភេទមុខងារទាំងឡាយ ។ គេអាចសង្កេតឃើញសមត្ថកិច្ចនៃរដ្ឋាភិបាលនីមួយៗ ទោះជាក្នុងទំរង់គ្រប់គ្រងណាក៏ដោយ វាមានលក្ខណៈពីរប្រភេទគឺ សមត្ថកិច្ចទូទៅ និងសមត្ថកិច្ចពិសេស ។

**ក១. សមត្ថកិច្ចទូទៅនៃរដ្ឋាភិបាល** : ជាសមត្ថកិច្ចដែលមិនកំរិតទៅលើបញ្ហា ឬកម្មវត្ថុណាមួយទេ ដូចមាត្រា ៨ នៃច្បាប់ដដែលបានកំនត់ថា "នាយករដ្ឋមន្ត្រី ប្រមុខរាជរដ្ឋាភិបាលមានភារៈទទួលខុសត្រូវរួមជាមួយសមាជិកទាំងឡាយ នៃរាជរដ្ឋាភិបាលចំពោះមុខរដ្ឋសភា អំពីនយោបាយទូទៅ និងសកម្មភាពរបស់រាជរដ្ឋាភិបាល"។ ត្រង់នេះបញ្ជាក់ថា គេពុំបានកំណត់នូវសមត្ថកិច្ចណាមួយពិតប្រាកដទៅចំពោះរដ្ឋាភិបាលទេ ក្នុងការធ្វើសកម្មភាពដឹកនាំនយោបាយ ។

**ក២. សមត្ថកិច្ចពិសេសនៃរដ្ឋាភិបាល** : សមត្ថកិច្ចនេះមានពីរប្រភេទ គឺសមត្ថកិច្ចឯកទេសរបស់ក្រសួង ឬស្ថាប័ននានា (ផ្នែកបច្ចេកទេស) ដែលរដ្ឋាភិបាលផ្ទុកផ្តាក់ទៅក្រសួងមានសមត្ថកិច្ច ដូចជាផ្នែកសេដ្ឋកិច្ច, មហាផ្ទៃ, អប់រំ.... ។ល។ និងសមត្ថកិច្ចកំរិតជាកំណត់របស់រដ្ឋាភិបាល ដូចជាមាត្រា ១២ នៃច្បាប់ដដែលបានកំណត់ថា "នាយករដ្ឋមន្ត្រីដឹកនាំការចរចារ, វិទ្យាសាស្ត្របច្ចេកទេស និងការពារប្រទេស ។ នាយករដ្ឋមន្ត្រី អាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាលណាម្នាក់ជាអ្នកចរចារ និងជាអ្នកចុះហត្ថលេខា"។ សមត្ថកិច្ចកំរិតនេះមានច្រើនប្រភេទ ដូចជាសមត្ថកិច្ចនីតិកម្មតាមមាត្រា ១៣ នៃច្បាប់ដដែលបានកំនត់ថា "នាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអនុក្រឹត្យ សេចក្តីសំរេច និងសារាចររបស់គណៈរដ្ឋមន្ត្រី"។ មាត្រា ១៤ "នាយករដ្ឋមន្ត្រីលើកសំណើដល់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាឱ្យកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ លើកលែងតែសំណើស្តីពីសេចក្តីព្រាងច្បាប់ និងសំណើតែងតាំង ផ្លាស់ប្តូរ បញ្ឈប់ភារកិច្ចសមាជិករាជរដ្ឋាភិបាល ជូនរដ្ឋសភាដើម្បីអនុម័ត ។

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធាដូចតទៅ :

- ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
- ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង
- ប្រតិភូរាជរដ្ឋាភិបាល
- អភិបាលខេត្ត-ក្រុង

- ឯកអគ្គរាជទូត

- ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព

- នាយអគ្គសេនាធិការ និងនាយអគ្គសេនាធិការរង

- ឧត្តមសេនីយ៍ឡើងទៅ....." ។ ក្រៅពីនេះសមត្ថកិច្ចក៏រឹតមានដូចជាសមត្ថកិច្ចប្រតិបត្តិច្បាប់នានា, សមត្ថកិច្ចបង្កើតឧបករណ៍ដឹកនាំរដ្ឋ (សមាជិករដ្ឋាភិបាល ដូចជាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រី.......), សមត្ថកិច្ចរៀបចំថវិកា និងអនុវត្តថវិកា, សមត្ថកិច្ចនយោបាយក្រៅប្រទេស សមត្ថកិច្ចចូលរួមក្នុងសកម្មភាពនីតិកម្ម សមត្ថកិច្ចនីតិកម្ម (ចូលរួម និងបង្កើតច្បាប់)........ ។ល។

**ខ. ការរៀបចំ និងសមាសភាពនៃរដ្ឋាភិបាល** : ដោយអាស្រ័យនឹងទំរង់គ្រប់គ្រង និងផ្សារភ្ជាប់ជាមួយនឹងកំរិតនៃការចូលរួមរបស់រដ្ឋសភានៅក្នុងការរៀបចំរដ្ឋាភិបាល គេអាចកំណត់បាននូវគំរូគ្រឹះសំខាន់ៗគឺ : គំរូបែបសភា និងគំរូក្រៅសភា ក្នុងនីតិវិធីនៃការបង្កើតរដ្ឋាភិបាល ។

**ខ₁. គំរូបែបសភា** : នេះគឺជានីតិវិធីនៃការបង្កើតរដ្ឋាភិបាល ដោយឈរលើមូលដ្ឋានគ្រឹះមួយនៃលទ្ធផលសរុបក្នុងការបោះឆ្នោតដោយរដ្ឋសភា ។ មានន័យថាជាវិធីមួយដែលរដ្ឋសភាជាអ្នកបោះឆ្នោតបង្កើតសេចក្តីទុកចិត្តទៅលើទំរង់ ឬទ្រង់ទ្រាយរដ្ឋាភិបាល (ក្នុងប្រទេសដែលមានទ្វេសភា, ការបោះឆ្នោតច្រើនប្រព្រឹត្តទៅនៅសភាតំណាងរាស្ត្រ) ។ លក្ខណៈនៃការបង្កើតរដ្ឋាភិបាលរបៀបនេះមានក្នុងសាធារណរដ្ឋបែបសភា និងបែបរាជាធិបតេយ្យ និងជាពិសេសក្នុងសាធារណរដ្ឋបែបចំរុះផងដែរ ។ ការប្រកាន់គំរូសភានេះជាទូទៅប្រមុខរដ្ឋចាត់តាំងប្រមុខរដ្ឋាភិបាល ប៉ុន្តែត្រូវការសុំសេចក្តីទុកចិត្តភាគច្រើនពីរដ្ឋសភា ឬពីសភាជាន់ទាប ដូចជាប្រទេសកម្ពុជាជាទំរង់គ្រប់គ្រងរាជាធិបតេយ្យតាម**មាត្រា ១៩** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "ព្រះមហាក្សត្រព្រះអង្គ ទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩" ។ រីឯ**មាត្រា ១១៩** បានកំណត់ថា "តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រ នៃគណៈបក្សដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណៈបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្គូរផ្គងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល

ទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។

មុនចូលកាន់តំណែងគណៈរដ្ឋមន្ត្រី ត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦" ។ ក្រោយពីបានទទួលអនុម័តរួចហើយ ប្រមុខរដ្ឋាភិបាលរៀបចំបង្កើតសមាសភាពរដ្ឋាភិបាល និងនាំមកនូវកម្មវិធីនៃសកម្មភាពនានា ដើម្បីធ្វើអំណះអំណាងចំពោះរដ្ឋសភា (សំរាប់ប្រទេសអង់គ្លេសអំណះអំណាងនៅសភាជាន់ទាបតែសំរាប់ប្រទេសអ៊ីតាលី, នៅក្នុងសភាទាំងពីរ) រីឯសមាសភាព រដ្ឋាភិបាលក៏ពុំមានលក្ខណៈដូចគ្នាគ្រប់ប្រទេសដែរ ដោយវាអាស្រ័យនឹងកិច្ចការនៃការគ្រប់គ្រង និងស្ថានភាពជាប្រវត្តិសាស្ត្រ ដូច**មាត្រា** ១៤ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីកម្ពុជា ១៩៩៤ កំណត់ថា "សមាសភាពនៃរាជរដ្ឋាភិបាលមាន :

- នាយករដ្ឋមន្ត្រី
- ឧបនាយករដ្ឋមន្ត្រី
- ទេសរដ្ឋមន្ត្រី
- រដ្ឋមន្ត្រី
- រដ្ឋលេខាធិការ" ។

ប៉ុន្តែសណ្ដាប់ធ្នាប់នៃសមាជិកភាពរដ្ឋាភិបាល ត្រូវបានកំណត់ក្នុង**មាត្រា** ៤ នៃច្បាប់ដដែលថា "នាយករដ្ឋមន្ត្រីជាសមាជិករដ្ឋសភា។ សមាជិករាជរដ្ឋាភិបាលឯទៀតអាចជ្រើសរើសក្នុងចំណោមសមាជិករដ្ឋសភា ឬក្រៅសមាជិករដ្ឋសភា ប៉ុន្តែត្រូវជាសមាជិកគណៈបក្សមានតំណាងនៅក្នុងរដ្ឋសភា ។ សមាជិករាជរដ្ឋាភិបាលទាំងអស់ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយពីបានសេចក្ដីអនុម័តទុកចិត្តពីរដ្ឋសភា" ។

**ខ២.គំរូក្រៅសភា** : នេះជាគំរូមួយដែលរដ្ឋាភិបាលត្រូវបានបង្កើតឡើងតាមនីតិវិធីមួយ ដោយមិនអាស្រ័យសភាទេ គឺមានន័យថាការបង្កើតរដ្ឋាភិបាល (អំណាចនីតិប្រតិបត្តិ) ពុំត្រូវការយល់ព្រមពីរដ្ឋសភាទេ ។ ជាទូទៅការកើតមានរូបរាងនូវរដ្ឋាភិបាលក្រៅសភានេះ ច្រើនមាននៅក្នុងរដ្ឋដែលមានទំរង់គ្រប់គ្រងបែបរាជាធិបតេយ្យទិកភាព ឬរបបរាជានិយម (និយមប្រមុខរដ្ឋជា ស្ដេច), ឬ

ពេលខ្លះគេច្រើនហៅថារាជាធិបតេយ្យទ្វិកភាពបែបរាជាធិបតេយ្យដាច់ខាត និងសាធារណ រដ្ឋបែបប្រធានាធិបតី។ ជាពិសេសទៀតនោះ កើតមាននៅក្នុងប្រទេសមួយចំនួនដែលប្រកាន់របបសាធារណរដ្ឋបែបចំរុះ ឬសាធារណរដ្ឋពាក់កណ្តាលប្រធានាធិបតីផងដែរ ។

នៅក្នុងឋានៈនៃការបង្កើតរដ្ឋាភិបាលមិនអាស្រ័យរដ្ឋសភា ដូចជាប្រទេសកូឡុំប៊ីតាម**មាត្រា ១៨៩** វាក្យខ័ណ្ឌទីមួយនៃរដ្ឋធម្មនុញ្ញបានកំណត់ជាស្រេចហើយថា "ប្រធានាធិបតីសាធារណរដ្ឋ. ជាប្រមុខរដ្ឋាភិបាល និងជាអំណាចរដ្ឋបាលកំពូល មានសិទ្ធិចាត់តាំងជ្រើសរើសរដ្ឋមន្ត្រីនានានៃគណៈរដ្ឋមន្ត្រីដោយសេរី ប៉ុន្តែក៏មានកំណត់ការកាន់កាប់តំណែងនេះ ទាមទារនូវការបោះឆ្នោតក្នុងសភាជាន់ទាបដែលមានមាត្រា ២០៧ ផងដែរ ។ ប៉ុន្តែនៅក្នុងប្រទេសដែលកាន់របបប្រធានាធិបតី ការបង្កើតអំណាចកណ្តាលនីតិប្រតិបត្តិ ត្រូវមានការចូលរួមពីរដ្ឋសភាផងដែរ ដូចជានៅសហរដ្ឋអាមេរិកតាមមាត្រា ២ ផ្នែកទី ២ នៃរដ្ឋធម្មនុញ្ញរបស់គេបានកំណត់ហើយថា ប្រធានាធិបតីរៀបចំការតែងតាំងធ្វើឡើងតាមដំបូន្មាន ឬក៏យល់ព្រមពីព្រឹទ្ធសភា ។

**ឥ. ប្រមុខរដ្ឋាភិបាល** (Head of the Government) : ប្រមុខរដ្ឋាភិបាល. គឺជាអ្នកដឹកនាំនៃអង្គការប្រតិបត្តិជាន់ខ្ពស់របស់អំណាចរដ្ឋ ។ ជាទូទៅក្នុងការអនុវត្តជាក់ស្តែងនៃគ្រប់ទំរង់គ្រប់គ្រងរដ្ឋ. ការប្រមូលផ្តុំនៃអំណាចនីតិប្រតិបត្តិស្ថិតក្នុងកណ្តាប់ដៃប្រមុខរដ្ឋាភិបាល ។ ប្រមុខរដ្ឋាភិបាលក្លាយជាអ្នកដឹកនាំពេញច្បាប់ក្នុងក្របខ័ណ្ឌអំណាចនីតិប្រតិបត្តិ ។

ឈ្មោះនៃរដ្ឋាភិបាលរបស់ប្រទេសនីមួយៗពុំមានដូចគ្នាទេដោយអាស្រ័យនឹងលទ្ធិ និងប្រពៃណីនៃការកកើតរដ្ឋនីមួយៗ ។ ដូចជាតាមប្រព័ន្ធអង់គ្លេសាក់សុង ឬតាមប្រព័ន្ធកុងតីណង់តាល់ជាដើម ។ នៅក្នុងប្រទេសខ្លះគេឱ្យឈ្មោះថា នាយករដ្ឋមន្ត្រីដែលចេញពីពាក្យបារាំងថា Premier មានន័យថា "**ទីមួយ**" ខ្លះទៀតមានឈ្មោះថា "**ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី**" ខ្លះទៀតមានឈ្មោះថា "**អធិការបតី**" ( អាល្លឺម៉ង់. អូទ្រីស្ត....) ។ល។ ប៉ុន្តែនៅក្នុងប្រទេសដែលកាន់ទំរង់សាធារណរដ្ឋបែបប្រធានាធិបតី ប្រមុខរដ្ឋាភិបាលជាប្រធានាធិបតី ដូចជាអាមេរិក និងប្រទេសមួយចំនួននៅអាមេរិកឡាទីន។ ចំណែករដ្ឋាភិបាលក៏មានឈ្មោះខុសៗគ្នាដែរ ដូចជាប្រទេសកម្ពុជាបានកំណត់**មាត្រា ១១៨** រដ្ឋធម្មនុញ្ញ ១៩៩៣ ថា "គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។ គណៈរដ្ឋមន្ត្រី

ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, និងរដ្ឋលេខាធិការជាសមាជិក" ។

**ឃ. ស្ថាប័ននានា និងអ្នកដឹកនាំរបស់ស្ថាប័ន** (Department): ស្ថាប័ន ឬក្រសួង គឺជាប្រភេទនៃអង្គការរដ្ឋដែលធ្វើសកម្មភាពក្នុងអំណាចនីតិប្រតិបត្តិ តាមល័ក្ខខ័ណ្ឌនៃសមត្ថកិច្ចពិសេស( ជំនាញ) ហើយត្រូវបានកំនត់ដោយច្បាប់ក្នុងប្រទេសនីមួយៗ ។ ស្ថាប័ននេះមានន័យថា វាបង្កើតមកក្នុងក្របខ័ណ្ឌកំណត់មួយនៃការដឹកនាំរបស់រដ្ឋ ដែលមានសិទ្ធិអំណាចកំណត់ច្បាស់លាស់ ។ ជាទូទៅស្ថាប័នមានលក្ខណៈជារដ្ឋាភិបាល និងគ្មានលក្ខណៈជារដ្ឋាភិបាល ។ ស្ថាប័នដែលមានលក្ខណៈជារដ្ឋាភិបាល គឺកាលណាអ្នកដឹកនាំរបស់ស្ថាប័ននេះ ឬស្ថាប័ននោះស្ថិតក្នុងសមាសភាពរដ្ឋាភិបាល។ ជាឧទាហរណ៍ តាម**មាត្រាទី ៤** នៃច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ១៩៩៤ បានកំណត់សមាសភាពនៃរាជរដ្ឋាភិបាលមាន : នាយករដ្ឋមន្ត្រី, ឧបនាយករដ្ឋមន្ត្រី, ទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រី និងរដ្ឋ លេខាធិការ, ប៉ុន្តែ**មាត្រា ២១** នៃច្បាប់ដដែលនោះបានចារឹកនូវខ្លឹមសារ នៃស្ថាប័នដែលមានលក្ខណៈរដ្ឋាភិបាលថា "សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលដែលដឹកនាំ គ្រប់គ្រងក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ហៅថាប្រធានស្ថាប័ន ។ ប្រធានស្ថាប័នដឹកនាំការងារក្នុងស្ថាប័ន និងគ្រប់គ្រងបុគ្គលិក មន្ត្រីរាជការ ដែលជាភ្នាក់ងាររដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាននៅក្រោមឱវាទ" ។ ចំណែកឯស្ថាប័នដែលពុំមានលក្ខណៈជារដ្ឋាភិបាល គឺកាលណាអ្នកដឹកនាំរបស់ស្ថាប័ននោះពុំមែនស្ថិតក្នុងសមាសភាព នៃរដ្ឋាភិបាល ដូចជាគណៈកម្មការ, ទីភ្នាក់ងារការិយាល័យ......... ។ល។ ដែលអាចស្ថិតនៅក្រោមចំណុះរដ្ឋាភិបាល ឬក៏អាចស្ថិតនៅក្រោមចំណុះផ្ទាល់ពីប្រមុខរដ្ឋាភិបាល ឬរដ្ឋាភិបាល ។ ក្រៅពីនេះនៅមានស្ថាប័នឯករាជ្យមួយចំនួនទៀត ដែលការបង្កើតនូវស្ថាប័នរបៀបនេះត្រូវកំណត់ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់ រីឯអ្នកដឹកនាំចំពោះស្ថាប័នអំណាចនីតិបញ្ញត្តិ ដូចជាក្នុងពេលមានការបោះឆ្នោតម្តងៗរបស់រដ្ឋាភិបាលគេតែងបង្កើតនូវស្ថាប័នរបៀបនេះជាចាំបាច់ ដូចច្បាប់បោះឆ្នោតកម្ពុជា ១៩៩៤ បានកំណត់ក្នុង**មាត្រា ៤** ថា "ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត" ។ ក្នុង**មាត្រា ១២** កំណត់ថា "គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាអង្គការឯករាជ្យ និងអព្យាក្រឹត្យក្នុងការអនុវត្តន៍សមត្ថកិច្ចរបស់ខ្លួន ។ សមាជិក

ទាំងឡាយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិកនៃគណៈកម្មាធិការរៀបចំការបោះឆ្នោតទាំងអស់ ត្រូវមានជំហរអព្យាក្រឹត្យឥតលំអៀងក្នុងការអនុវត្តន៍ការងារបោះឆ្នោត" ។ ប៉ុន្តែតាម**មាត្រា ១៣** វាក្យខ័ណ្ឌទី ៣ នៃច្បាប់ដដែលបានកំណត់ថា "ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងតិចប្រាំបួនខែ មុនថ្ងៃបោះឆ្នោត តាមសំណើរបស់គណៈរដ្ឋមន្ត្រី ក្រោយពីបានទទួលយល់ព្រមពីរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល" ។ ដូចនេះក្នុងមាត្រា ១៣ វាបានកំណត់នូវការយល់ព្រមរវាងអង្គការនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ក្នុងការបង្កើតស្ថាប័នមួយ គឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រង់នេះហើយដែលហៅថាស្ថាប័នពុំមានលក្ខណៈជារដ្ឋាភិបាល[៨០] ។ អំពីបញ្ហាមួយទៀតស្តីពីសិទ្ធិពិសេស (Privilege) ឬការឱ្យសិទ្ធិ ឬហៅថាបុព្វសិទ្ធិ (Prerogative) និងអភ័យឯកសិទ្ធិ (Immunity) ដែលត្រូវបានកំណត់ដោយច្បាប់ច្បាស់លាស់ សំរាប់ផ្តល់ជូនទៅប្រមុខរដ្ឋាភិបាល ។ ទោះជាសមាជិករដ្ឋាភិបាលប្រទេសកម្ពុជា ពុំបានកំណត់នូវអភ័យឯកសិទ្ធិក៏ដោយ ក៏សមាជិកទាំងនោះមានជាស្វ័យប្រវត្តិដែរ ព្រោះសមាជិក ឬនាយករដ្ឋមន្ត្រី ជាសមាជិករដ្ឋសភា ដូចនេះគេត្រូវប្រើអភ័យឯក សិទ្ធិសភា ។ ទាក់ទងនឹងបុព្វសិទ្ធិគឺវាកំណត់នូវឋានៈ ដូច**ប្រការ ៨** នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាកំណត់ ថា "អ្នកតំណាងរាស្ត្រមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា" ។ ប៉ុន្តែបុព្វសិទ្ធិរបស់សមាជិករដ្ឋាភិបាល ត្រូវបានកំណត់ដោយក្រឹត្យរបស់ប្រមុខរដ្ឋ ។ នៅមានករណីមួយទៀត ស្តីពីមុខងារសាធារណៈ ឬឯកត្តភាពរបស់សមាជិករដ្ឋាភិបាល ព្រោះថាក្នុងប្រទេសខ្លះ ពិសេសប្រទេសដែលប្រកាន់របបសភានិយម សមាជិករដ្ឋាភិបាលពុំអាចមានតំណែងពីរបានឡើយ ដែលគេហៅថាវិសមិតភាព (Incompatibility) ។

---

[៨០]. នៅមានអង្គការមួយចំនួនទៀតដែលពុំមែនជាស្ថាប័នរបស់រដ្ឋាភិបាល ដែលអង្គការទាំងនោះបំរើឱ្យសង្គមស៊ីវិល ឬក៏បំរើឱ្យប្រយោជន៍របស់ក្រុមណាមួយ ។

. អង្គការនេះមានទាំងជាតិ និងអន្តរជាតិ ។

. អង្គការទាំងនេះពុំមានសមាសភាពរដ្ឋាភិបាលទេ តែវាជួយជំរុញឱ្យរដ្ឋាភិបាលមានការអភិវឌ្ឍន៍ថែមទៀត និងមានតម្លាភាពក្នុងការគ្រប់គ្រងរដ្ឋ ។

. មាត្រា ១៣ នៃច្បាប់បោះឆ្នោតត្រូវបានធ្វើវិសោធនកម្មថ្មីហើយ កាលពីថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០០២ ។

**៦. ភាពទទួលខុសត្រូវរបស់រដ្ឋាភិបាល និងសមាជិករដ្ឋាភិបាល** : ការទទួលខុសត្រូវរបស់រដ្ឋាភិបាលវាអាស្រ័យនឹងទំរង់គ្រប់គ្រងរបស់រដ្ឋនីមួយៗ ប៉ុន្តែជាទូទៅរដ្ឋាភិបាលតែងទទួលខុសត្រូវរួមគ្នាជាមួយសមាជិករបស់គេ អំពីនយោបាយរួមចំពោះរដ្ឋសភា ឬប្រមុខរដ្ឋ ហើយទទួលខុសត្រូវតាមផ្លូវច្បាប់ទៀតផង ។ ដូចមាត្រា ១២១ រដ្ឋធម្មនុញ្ញកម្ពុជាកំណត់ថា "សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល" ។

ចំពោះការទទួលខុសត្រូវនយោបាយរួមមានន័យថាកិច្ចការក្នុង និងក្រៅប្រទេសដែលទាក់ទិននឹងការគ្រប់គ្រង ឬការអនុវត្តន៏ដែលរដ្ឋាភិបាលត្រូវតែទទួលខុសត្រូវរួមគ្នា ដូចមាត្រា ១២១ រដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់រួចហើយក្នុងវាក្យខ័ណ្ឌទីមួយ ។ ប៉ុន្តែអ្វីដែលរដ្ឋាភិបាលទទួលខុសត្រូវអំពីផ្លូវច្បាប់នោះ គឺរដ្ឋាភិបាលត្រូវតែកំណត់នូវតួនាទី និងភារកិច្ចរបស់សមាជិករដ្ឋាភិបាលតាមឋានានុក្រម និងលំដាប់ថ្នាក់នៃការគ្រប់គ្រងស្ថាប័ន ។ ការទទួលខុសត្រូវចំពោះមុខច្បាប់របស់សមាជិករដ្ឋាភិបាល គឺរដ្ឋាភិបាលធានានូវការអនុវត្តន៏ច្បាប់នានា ដែលអនុម័តឡើងដោយរដ្ឋសភា. អនុវត្តនូវរាល់បទដ្ឋានកិច្ចគតិយុត្តិទាំងឡាយដូចជាក្រឹត្យរបស់ប្រមុខរដ្ឋ ជាពិសេសទៀតនោះរដ្ឋាភិបាលមានសិទ្ធិបង្កើតនូវបទដ្ឋានកិច្ចផ្សេងៗដែលមានកំលាំងគតិយុត្តិតិច ជាងច្បាប់ដែលអនុម័តដោយរដ្ឋសភា ។ ដូចនេះរដ្ឋាភិបាលទទួលខុសត្រូវរាល់ការអនុវត្តន៏ច្បាប់ និងការធ្វើសមិទ្ធិច្បាប់ ឬបទដ្ឋានកិច្ចនានារបស់រដ្ឋ ។ បើទោះជារដ្ឋធម្មនុញ្ញពុំបានកំណត់ថា តើសមាជិករដ្ឋាភិបាលទទួលខុសត្រូវនូវអ្វីខ្លះនោះក៏ដោយ ក៏វាជាច្បាប់គោលដើម្បីឈានទៅបង្កើតច្បាប់ ឬបទដ្ឋានកិច្ចផ្សេងៗទៀត ដើម្បីកំណត់ក្នុងការងារទទួលខុសត្រូវចំពោះផ្លូវច្បាប់ដែរ ដូចមាត្រា ១២១ រដ្ឋធម្មនុញ្ញកម្ពុជាបានសរសេរជាចំហរក្នុងវាក្យខ័ណ្ឌទីពីរថា "សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួន ចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត" ។

## អនុបមនទី ១៧

# អំណាចតុលាការ

## ១. លក្ខណៈទូទៅនៃអំណាចតុលាការ

**ក. និយមន័យ និងមុខងារសង្គមទូទៅនៃអំណាចតុលាការ :** យើងបានស្គាល់រួចមកហើយនូវអំណាចធំពីរគឺ នីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ។ ដូចនេះប្រសិនបើអំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិដែលចារីកដោយរដ្ឋធម្មនុញ្ញថាជាអំណាចខ្ពស់បំផុតនៃអំណាចរដ្ឋ ( អាស្រ័យនឹងប្រមុខរដ្ឋ ឬក៏ប្រមុខរដ្ឋសភា. ប្រមុខរដ្ឋ ឬក៏ប្រមុខរដ្ឋាភិបាល) នោះវានឹងកើតឡើងនូវភាពស្មុគស្មាញយ៉ាងច្រើនទៅលើអំណាចតុលាការ ។ ព្រោះថាអំណាចតុលាការត្រូវបានប្រមូលផ្តុំនៅក្នុងអង្គការតុលាការ (Judicial Body) តាំងពីថ្នាក់ទាបបំផុតរហូតដល់ថ្នាក់ខ្ពស់បំផុត ។ រៀងរាល់អង្គការតុលាការក្នុងអំណាចតុលាការនោះ ( ថ្នាក់ទាបដល់ខ្ពស់) វាមិនអាស្រ័យនឹងទីតាំងរបស់វាទេ គឺថាវាស្ថិតក្នុង**ប្រព័ន្ធតែមួយ គឺដោះស្រាយកិច្ចការពិតៗប្រកបដោយសុក្រឹត្យ និងស្វ័យភាពដែលមានច្បាប់**(Law) **និងមនសិការគតិយុត្តិ** (Legal Sense)[៨១] **ជាគោល** ។ គ្រប់អង្គការតុលាការ ( ថ្នាក់ទាបដល់ខ្ពស់) ពុំមែនតែតុលាការជាន់ខ្ពស់នោះទេ **គឺសុទ្ធតែជាអ្នកចំលងនៃអំណាចតុលាការ** គឺមានន័យថាអង្គការតុលាការទាំងនោះមានអំណាចតុលាការដែរ ។ ប៉ុន្តែបណ្តុំ ឬសំណុំនៃតុលាការដោយរួមទាំង**សកម្មភាព** ( កិច្ចការទាំងឡាយ) របស់វាមានឈ្មោះថា "**យុត្តិធម៌**" (Justice ពាក្យឡាតាំងថា Justitia) ។ ត្រង់ចំនុចនេះបញ្ជាក់ថាកិច្ចការរបស់តុលាការ គឺស្វែងរកយុត្តិធម៌ជូនសង្គមទាំងមូល ។

---

[៨១]. មនសិការគតិយុត្តិ គឺជាគំនិតដែលគិតទៅលើរឿងណាមួយប្រកបដោយត្រឹមត្រូវតាមផ្លូវច្បាប់ ឬក៏រាល់គំនិត ឬរាល់ដំណើរការយកចិត្តទុកដាក់លើអ្វីមួយប្រកបដោយត្រឹមត្រូវ ( យុត្តិធម៌) ដោយមានគោលការណ៍រួម ឬច្បាប់ជាបង្អែក ។ មនសិការគតិយុត្តិនៅក្នុងល័ក្ខខ័ណ្ឌនេះ គឺសំដៅយកភាពត្រឹមត្រូវ បើទោះជាច្បាប់ពុំបានចែងក៏ដោយ ព្រោះថាភាពយុត្តិធម៌ត្រូវបានដក់ជាប់ជានិច្ចក្នុងគំនិតរបស់ចៅក្រម ។

សកម្មភាព (កិច្ចការ) របស់តុលាការ ក្នុងការដោះស្រាយនៃទំនាស់គតិយុត្តិនានា (ទំនាស់តាមផ្លូវច្បាប់) មានឈ្មោះថា "សកម្មភាពយុត្តាធិការ" រីឯមជ្ឈដ្ឋានជាកម្មវត្ថុ និងទំហំនៃកិច្ចការរបស់តុលាការនោះមានឈ្មោះថា "**យុត្តាធិការ**" (Jurisdiction) មកពីពាក្យឡាតាំងថា "Jurisdictio" មានន័យថាជា "**សណ្តាប់ធ្នាប់នៃកិច្ចការរបស់តុលាការ**"។ សកម្មភាពយុត្តាធិ-ការវាជាដែនសមត្ថកិច្ចរបស់តុលាការ ក្នុងការងារមួយជាក់លាក់ផ្នែកវិនិច្ឆ័យ ដែលអាចមានអង្គការតុលាការរដ្ឋបាល ឬអង្គការតំណាងផ្សេងៗដែរ ប៉ុន្តែក៏ស្ថិតក្រោមការត្រួតមើលរបស់តុលាការដែរ ។ ដើម្បីឱ្យសំរេចបាននូវសកម្មភាពនៃយុត្តាធិការនេះ អំណាចតុលាការ ឬអង្គការតុលាការ ត្រូវប្រកាន់គោលការណ៍មួយចំនួន ដូចជា៖

**ក១. គោលការណ៍យុត្តិធម៌នៃតុលាការ** : សកម្មភាពយុត្តាធិការនៃគ្រប់តុលាការនាំមកនូវយុត្តិធម៌មួយ ដែលមានន័យថាជាការបំពេញនូវសេចក្តីសំរេចជាគតិយុត្តិ ប្រកបដោយត្រឹមត្រូវទៅលើរឿងទំនាស់ផ្សេងៗ ។ ការធ្វើបានជោគជ័យនូវដំណោះស្រាយត្រឹមត្រូវនេះបាន គឺអាស្រ័យដោយនីតិវិធីគ្រប់លំដាប់ថ្នាក់រួមទាំងប្រមូលគ្រឿងបន្ទាល់ (ភស្តុតាង) និងការវិនិច្ឆ័យ ។

**ក២. គោលការណ៍ច្បាប់នៃតុលាការ** : តួនាទីដ៏សំខាន់មួយទៀតនៃអំណាចតុលាការចំពោះការដោះស្រាយទំនាស់គតិយុត្តិ គឺធានានូវបរមានុភាពនៃច្បាប់ដែលគេហៅថាជា "**តួនាទីសង្គម**" ឬអំណាចតុលាការដើរតួនៅក្នុងសង្គមទូទៅ (មុខងារសង្គម) ។ តាមលក្ខណៈនៃមុខងារសង្គមនេះជាគោលការណ៍នៅក្នុងសៀវភៅដែលបោះពុម្ពដោយ **អាឡិកស៊ីស ដឺ តុកវិល** ឆ្នាំ ១៨៣៥ កំណត់ទៅលើការដោះស្រាយបញ្ហាជាសង្គម ដែលកើតមានរវាងរដ្ឋ (អ្នកគ្រប់គ្រង) និងពលរដ្ឋថា : "**គ្រប់រដ្ឋាភិបាលមានលទ្ធភាពពីរក្នុងការយកជ័យជំនះលើការប្រឈមមុខគ្នា ដែលបង្កឡើងដោយពលរដ្ឋចំពោះរដ្ឋាភិបាលគឺ :**[៨២] ទីមួយ : **មធ្យោបាយជាសំភារៈដែលពួកគេមាន** និងទីពីរ : **មធ្យោបាយជាសេចក្តីសំរេចរបស់តុលាការ** ។

---

[៨២]. DeTocqueville. A (1805-1859) អ្នកប្រវត្តិសាស្ត្របារាំង និងជារដ្ឋមន្ត្រីការបរទេសបារាំងឆ្នាំ១៨៤៩ ស្នាដៃរបស់លោកមានដូចជា: "អំពីលទ្ធិប្រជាធិបតេយ្យនៅសហរដ្ឋអាមេរិក": De Tocqueville.A:Democratic in America.M.Progress 1992.Page120.

រដ្ឋាភិបាលដែលអាចបង្ខំឱ្យស្តាប់ឱវាទច្បាប់បាន តាមការប្រើកំលាំងប្រដាប់អាវុធដែលសឹងតែឆ្ពោះទៅកាន់ការកាប់សំលាប់ ។ ដោយអាស្រ័យនឹងការប្រើប្រាស់កំលាំងនេះ រដ្ឋាភិបាលមានពីរ ករណីគឺ :

-ប្រសិនជារដ្ឋាភិបាលមានអំណាចខ្សោយ ឬរដ្ឋាភិបាលមានអំណាចមធ្យមនោះ រដ្ឋាភិបាលពឹងផ្អែកលើកំលាំងតែប៉ុណ្ណោះ ក្នុងការដោះស្រាយ ទោះជាករណីណាក៏ដោយ ដោយមិនគិតពីករណីតូចតាចនៃការមិនគោរពតាមឱវាទនោះទេ ។ ត្រង់ចំនុចនេះរដ្ឋាភិបាល ហាក់ដូចជាស្ថិតក្នុងអំណាចអាណាធិបតេយ្យ ។

-ករណីទីពីរ គឺបើសិនជារដ្ឋាភិបាលមានអំណាចខ្លាំង ឬក៏មានអំណាចមោះមុត នោះវានឹងពឹងផ្អែកទៅលើកំលាំងដដែល ដោយវានឹងប្រែក្លាយទៅជាសង្គ្រាមផ្តាច់ការ ។ សកម្មភាពរបស់រដ្ឋាភិបាល ហាក់ដូចជាឈានទៅរកការបាត់បង់នៃប្រជាជនរបស់ខ្លួន ។

គោលដៅដ៏មហាធំធេងនៃដំណោះស្រាយគតិយុត្តិរបស់តុលាការ វាជាការផ្លាស់ប្តូរគំនិតមួយនៃការប្រើកំលាំងឆ្ពោះទៅរកការទប់ស្កាត់ រវាងរដ្ឋាភិបាល និងអ្នកប្រើកំលាំងរបស់រដ្ឋាភិបាល" ។

តាមលក្ខណៈខាងលើនេះយើងឃើញថា អំណាចតុលាការមានឥទ្ធិពលយ៉ាងច្រើនទៅលើស្ថេរភាពសង្គម ។ គឺមានន័យថាខ្វះអំណាចតុលាការនាំឱ្យគ្មានស្ថេរភាពសង្គម ។ ជារួមទៅអំណាចតុលាការ គឺជាឧបករណ៍ដែលវាធ្វើសកម្មភាពតាមរយៈច្បាប់ ទៅលើរាល់ទំនាក់ទំនងសង្គម (សាធារណៈ)។ ពាក្យថាឧបករណ៍ពុំមានប្រភេទតែមួយនោះទេ គឺមានន័យថាជាប្រភេទដ៏សំខាន់បំផុតគឺ "ឧបករណ៍សំខាន់បំផុត" សំរាប់ប្រើប្រាស់ក្នុងគ្រប់ដំណោះស្រាយទំនាស់ ។ ត្រង់ចំនុចនេះបញ្ជាក់ថា អំណាចតុលាការជាអំណាចខ្លាំង ប៉ុន្តែសំរាប់វិនិច្ឆ័យទៅលើទំនាស់រវាងពលរដ្ឋ និងរដ្ឋ ។ ផ្ទុយទៅវិញ បើប្រៀបធៀបអំណាចតុលាការទៅនឹងអំណាចផ្សេងៗទៀត ដូចជាអំណាចនីតិបញ្ញត្តិ. អំណាចនីតិប្រតិបត្តិ គឺអំណាចតុលាការមានឥទ្ធិពលខ្សោយជាងគេ ពីព្រោះអំណាចតុលាការពុំមានការគាំទ្រពីអ្នកបោះឆ្នោតទេ (មិនកើតឡើងតាមរយៈបោះឆ្នោតទេ)។ ប៉ុន្តែអំណាចតុលាការមានកំលាំងខ្លាំងបានដោយឈរលើច្បាប់ជាមូលដ្ឋាន និងរៀងរាល់សេចក្តីសំរេចប្រកបដោយយុត្តិធម៌ ។

ដោយឈរលើសកម្មភាពគតិយុត្តិរបស់តុលាការ ទើបរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗបានកំណត់នូវគោលការណ៍គ្រឹះសំខាន់ៗសំរាប់ផ្តល់លទ្ធភាពឱ្យទៅអំណាចតុលាការ ដូចមាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការធានារក្សាអនាគត និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់" ។

ដូចនេះអំណាចតុលាការគឺជាអំណាចមួយដែលឯករាជ្យ ហើយវាធានាបាននូវសិទ្ធិ សេរីភាពរបស់ពលរដ្ឋក្នុងការបំពេញកិច្ចគតិយុត្តិ ដោយឈរលើគោលការណ៍គ្រឹះនៃការវិនិច្ឆ័យទៅលើហេតុផលដែលកើតមានទំនាស់រវាងពលរដ្ឋ និងពលរដ្ឋ ឬពលរដ្ឋ និងរដ្ឋដោយមានច្បាប់ជាបង្អែក និងប្រកបដោយយុត្តិធម៌ ។ នេះមានន័យថាអំណាចតុលាការជាអំណាចវិនិច្ឆ័យ ។

**ខ. រចនាសម្ព័ន្ធ នៃអំណាចតុលាការ** (Structure of Judicial Power) : ពាក្យថារចនាសម្ព័ន្ធ (Structure) វាជារូបធាតុទាំងឡាយនៃទិដ្ឋភាពខាងក្នុងរបស់អ្វីមួយ ទោះជាឥតជីវិត ឬមានជីវិតក្តី ដើម្បីបង្កើតបានជាគ្រោងនៃរូបរាងពិតប្រាកដ។ ផ្ទុយទៅវិញរចនាសម្ព័ន្ធនៃអំណាចតុលាការគឺជាគ្រោងមួយដែលកើតឡើងពីធាតុផ្សំរបស់វាគឺតុលាការ ។ រចនាសម្ព័ន្ធនៃអំណាចនេះ គឺផ្តុកផ្តាក់ទៅតុលាការទាំងអស់ដែលស្ថិតក្នុងក្របខ័ណ្ឌនៃរដ្ឋមួយ ។ ជាធម្មតារចនាសម្ព័ន្ធនៃអំណាចតុលាការប្រទេសនីមួយៗ បង្កើតមកសំរាប់ធ្វើឱ្យមានការងាយស្រួលដល់ដំណើរការគតិយុត្តិ ទៅលើរឿងក្តីក្នុងសង្គមរបស់គេដែលមានលក្ខណៈសាំញ៉ាំ និងធំធេង ដោយរឿងទាំងនោះវាពាក់ព័ន្ធនឹងអំណាចកំពូលៗរបស់រដ្ឋ និងច្បាប់គ្រឹះ។ ប្រទេសទាំងនោះបានកំណត់យកតាមគោលការណ៍ពីរប្រភេទ ដោយអាស្រ័យនឹងប្រព័ន្ធគតិយុត្តិ (Legal System) គឺរចនាសម្ព័ន្ធអំណាចតុលាការដែលទាក់ទិននឹងតុលាការកំពូលដែលមានច្រើនទិដ្ឋភាព ឬប្រភេទ (ច្រើនប្រទេសប្រើប្រព័ន្ធគតិយុត្តិអង់គ្លោសាក់សុង) និងរចនាសម្ព័ន្ធនៃអំណាចតុលាការដែលប្រតិបត្តិតាមនិន្នាការនៃប្រព័ន្ធពហុភាព (រចនាសម្ព័ន្ធប្រភេទនេះច្រើនមាននៅប្រទេសប្រើប្រព័ន្ធគតិយុត្តិកុងទីណង់តាល់) ។

ដូចនេះរចនាសម្ព័ន្ធនៃអំណាចតុលាការ គឺជាប្រព័ន្ធ (System) នៃអង្គការតុលាការគ្រប់ស្រទាប់ជាន់ថ្នាក់ ដែលក្នុងនោះវាកំណត់នូវព្រំដែននៃសកម្មភាពគតិយុត្តិ ស្របតាមសមត្ថកិច្ចដែលមានកំណត់ក្នុងច្បាប់ពិតប្រាកដ ។

**ខ១.រចនាសម្ព័ន្ធអំណាចតុលាការតាមប្រព័ន្ធគតិយុត្តិអង់គ្លោសាក់ស៊ុង** : នៅក្នុងប្រទេសដែលកាន់ប្រព័ន្ធគតិយុត្តិនេះ រចនាសម្ព័ន្ធ ឬការបង្កើតប្រព័ន្ធតុលាការមានលក្ខណៈមួយ ដែលទាក់ទិនទៅនឹងតុលាការកំពូល ហើយមានមែកធាងជាច្រើនទៀត ត្រង់នេះគឺចង់បញ្ជាក់ថាប្រទេសទាំងនោះបង្កើតនូវប្រព័ន្ធតុលាការមួយប្រភេទដោយឡែក១ពីគ្នា គឺថាបង្កើតតុលាការកំពូលមួយដែលតុលាការនេះមានសមត្ថកិច្ចដោះស្រាយរឿងជាច្រើនប្រភេទ ដូចជារឿងព្រហ្មទណ្ឌ, រដ្ឋប្បវេណី, រដ្ឋបាល ......... ។ល។ ជាឧទាហរណ៍ ដូចជានៅចក្រភពអង់គ្លេសតុលាការជាន់ខ្ពស់របស់គេមានតែមួយ គឺ Chamber of Lords ដែលក្នុងនោះមានផ្នែកជាច្រើនទៀតខាងរដ្ឋប្បវេណី និងខាងឧទ្ធរណ៍ហើយផ្នែកទាំងនេះចែកជាបន្តទៀត ។

**ខ២.រចនាសម្ព័ន្ធនៃអំណាចតុលាការតាមប្រព័ន្ធគតិយុត្តិកុងទីណង់តាល់** : នេះជារចនាសម្ព័ន្ធដែលគេបានបង្កើតនូវប្រព័ន្ធតុលាការច្រើន ដែលប្រព័ន្ធទាំងនោះមួយចំនួនពុំអាស្រ័យគ្នាទេ គឺមានន័យថាប្រព័ន្ធខ្លះវាមានលក្ខណៈឯករាជ្យក្នុងភារកិច្ចរបស់ខ្លួន ដែលសំដៅទៅរាល់តុលាការជាន់ខ្ពស់មួយចំនួន ។ តាមលក្ខណៈនេះមានជាឧទាហរណ៍ មាត្រា ៩២-៩៥ នៃរដ្ឋធម្មនុញ្ញសហព័ន្ធអាល្លឺម៉ង់ឆ្នាំ ១៩៤៩ កំណត់ថាតុលាការជាន់ខ្ពស់អាល្លឺម៉ង់ មាន ៥ គឺ : តុលាការយុត្តិធម៌សហព័ន្ធ (Federal court of justice), តុលាការរដ្ឋបាលសហព័ន្ធ (Federal Administrative Court), តុលាការហិរញ្ញវត្ថុសហព័ន្ធ (Federal Finance Court), តុលាការការងារសហព័ន្ធ (Federal Labour Court), និងតុលាការសង្គមកិច្ចសហព័ន្ធ (Federal Social Court),។

ដោយយោងតាមរចនាសម្ព័ន្ធនៃអំណាចតុលាការ យើងអាចដឹងថាវាបង្កើតនូវតុលាការជាច្រើនក្នុងការវិនិច្ឆ័យលើរឿងផ្សេងគ្នាតាមសាខានៃនីតិសាស្ត្រ ឬក៏តាមកម្មវត្ថុនៃនិយ័តកម្មគតិយុត្តិក្នុងសង្គម ។ ប៉ុន្តែនៅក្នុងរដ្ឋធម្មនុញ្ញដែលមានលក្ខណៈប្រជាធិបតេយ្យ គេពុំត្រូវយល់ថាមានលទ្ធ

ភាពបង្កើតតុលាការតាមទំនើងចិត្តនោះបានទេ នេះគឺចង់និយាយថាតុលាការវិសាមញ្ញត្រូវបានហាមឃាត់ដែលតាមលក្ខណៈនេះ ដូចមាត្រា ១០១ វាក្យខ័ណ្ឌទី ១ ច្បាប់គ្រឹះអាល្លឺម៉ង់កំណត់ថា "តុលាការវិសាមញ្ញនានាត្រូវបានហាមឃាត់ (មិនឱ្យបង្កើត)។ ..........."។ គួបញ្ជាក់ដែរថាគ្មានអ្នកណាម្នាក់ជាចៅក្រមនៅក្នុងរឿងរបស់ខ្លួនឡើយ ។ យើងឃើញថារចនាសម្ព័ន្ធនៃអំណាចតុលាការវាគ្របដណ្តប់ពុំគ្រាន់តែតុលាការទាំងនោះទេ ថែមទាំងរួមបញ្ចូលទាំងអង្គការរដ្ឋមួយចំនួនទៀតផង ដែលស្ថាប័នទាំងនោះបំរើឱ្យអំណាចតុលាការ ដូចជាអង្គការដែលស៊ើបអង្កេតដំបូង១ អង្គការអយ្យការ. ក្រុមអ្នកការពារក្តី (ជួយខាងផ្លូវច្បាប់) ជាដើម។ល។

**ខ. ឋានៈនៃចៅក្រម, រដ្ឋអាជ្ញា, និងសភាចារបុរស :** ចៅក្រម. រដ្ឋអាជ្ញា. សភាចារបុរស គឺជាមន្ត្រីរដ្ឋការដែលបំពេញមុខងារឱ្យតុលាការ ។ ផ្ទុយទៅវិញឋានៈរបស់បុគ្គលទាំងនោះត្រូវបានកំណត់ដោយច្បាប់ ឬក៏ទំលាប់របស់ប្រទេសនីមួយ១ ដែលមានជាប្រពៃណីស្របតាមប្រព័ន្ធគតិយុត្តិអង់គ្លេសាក់សុង ឬក៏កុងទីណង់តាល់ ។ ជាទូទៅឋានៈរបស់បុគ្គលទាំងនោះនៅក្នុងប្រទេសដែលប្រកាន់ប្រព័ន្ធគតិយុត្តិរ៉ូម៉ាំង ឬកុងទីណង់តាល់ និងប្រទេសផ្សេង១ជាច្រើនទៀតគេបានកំណត់ស្ថាប័នដោយឡែក១របស់គេ ដូចជាចៅក្រម.រដ្ឋអាជ្ញា និងសភាចារបុរស ជាធម្មតាបង្រួមចូលគ្នាជាអត្ថន័យរួម (General definition) ដែលមានឈ្មោះថា "**ឋានន្តរសក្តិនៃអង្គចៅក្រម**" (Magistracy) ឬស្ថាប័នឋានន្តរសក្តិនៃតុលាការី (ប៉ុន្តែអ្នកដែលបាន ឬបុគ្គលដែលបានបំពេញងារជា Magistracy មានឈ្មោះថា "Magistrat" ឬរដ្ឋបុរស (States man)[៨៣] ឬវរបុរស ដូចជា**ចៅក្រម. រដ្ឋអាជ្ញា. សភាចារបុរស**នេះឯង ។ ប៉ុន្តែនៅប្រទេសអាល្លឺម៉ង់ គេពុំប្រើពាក្យ Magistratus នេះទេ គឺប្រើពាក្យចៅក្រមស៊ើបអង្កេត ដែលជាភាសាអាល្លឺម៉ង់ ថា "Untersuchungsrichter"។ ដូចនេះ

---

[៨៣]. ពាក្យថា Magistrat ចេញពីពាក្យឡាតាំង Magistratus មានន័យថា ជារដ្ឋបុរស ឬវរបុរសវាគឺជាប្រភេទមួយក្នុងចំណោមប្រភេទជាច្រើននៃការធ្វើសមិទ្ធិរបស់អំណាចរដ្ឋក្នុងនាមប្រជាជនរ៉ូម ដែលបានធ្វើសកម្មភាពជាបុគ្គលរដ្ឋបំពេញមុខងារអ្វីមួយ (តាមច្បាប់រ៉ូម) ដែលគេឱ្យឈ្មោះជា Magistratus ។ មន្ត្រីរដ្ឋទាំងនោះមានទាំងថ្នាក់ខ្ពស់ និងទាប ។ រីឯនៅបណ្តាប្រទេសខ្លះគេប្រើសំរាប់មន្ត្រីតុលាការ ឬអង្គចៅក្រម ។

ប្រទេសដែលប្រកាន់យកបុគ្គលដែលបំពេញមុខងារក្នុងអំណាចតុលាការតាមលក្ខណៈ Magistracy នេះ គឺសំដៅទៅលើលក្ខណៈចាំបាច់មួយ ដែលរាល់បុគ្គល (Magistrat) ទាំងនោះមានសិទ្ធិអំណាចក្នុងមុខងារបានតាមរយៈនៃ**ការចាត់តាំង** ប៉ុន្តែក៏មានការជ្រើសរើសតាមរយៈបោះឆ្នោតដែរ ដូចជាចៅក្រមមួយចំនួននៃសហរដ្ឋអាមេរិក ( រដ្ឋមួយចំនួន) ត្រូវបានបោះឆ្នោតជ្រើសរើស ។

គោលការណ៍ដ៏សំខាន់មួយដែលធានានូវឯករាជ្យភាពរបស់អ្នកចំលង ឬអ្នកមានមុខងារបំរើក្នុងក្របខ័ណ្ឌអំណាចតុលាការនោះគឺ "**ភាពមិនអាចបំលាស់ទីបាន**" (Irremovability) របស់ពួកគេ ។ តាមលក្ខណៈនេះពួកគេពុំត្រូវបានបញ្ជូនពីកន្លែងមួយទៅកន្លែងមួយ ដោយគ្មានការយល់ព្រមពីសាមីខ្លួន ឬក៏ពីសេចក្តីសំរេចរបស់អំណាចជាន់ខ្ពស់ ( ប្រទេសខ្លះប្រកាន់យកអំណាចជាន់ខ្ពស់ធ្វើការបន្ទេរចៅក្រម) ។ ត្រង់នេះគឺចង់បញ្ជាក់ថាការដកតំណែង ឬក៏ផ្ទេរតំណែងរបស់ចៅក្រមទាំងឡាយ ( ចៅក្រម, រដ្ឋអាជ្ញា, សភាចារបុរស) ពុំត្រូវបានធ្វើតាមទំនើងចិត្តទេ ប៉ុន្តែត្រូវបានធានាការពារនូវលទ្ធភាពពិសេសៗទៀតផង ។ ដូចជានៅសហរដ្ឋអាមេរិក ចៅក្រមសហព័ន្ធអាចបណ្តេញចេញមុនអាណត្តិបានតាមរយៈនីតិវិធីអឹមពិជ្ជមិន[៥៤] (Impeachment) ។ ប៉ុន្តែចៅក្រមដែលបានដកទាំងនោះបន្សល់ទុកនូវ "**ដំណែង**" (during good Behaviour) របស់ពួកគេដដែល មានន័យថាដរាបណាគាត់ពុំទាន់លាឈប់ពីតំណែង ដរាបនោះគាត់នៅតែមានតំណែងដដែល ព្រោះគាត់ពុំបានប្រព្រឹត្តិបទល្មើស ឬក៏អសមត្ថភាពនោះទេ ។ លក្ខណៈភាពមិនអាចបំលាស់ទីបាន នេះជាចាំបាច់ត្រូវកំណត់ដោយច្បាប់មួយពិតប្រាកដ ជាងនេះទៅទៀតរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់ក្នុង**មាត្រា ១១៤** ថា "ចៅក្រមមិនអាចត្រូវគេដកពីមុខដំណែងបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។............" ។ ផ្ទុយទៅវិញចំពោះប្រទេសដែលប្រកាន់យកប្រព័ន្ធគតិយុត្តិកុងទីណង់តាល់ ជាពិសេសនៅអឺរ៉ុប ជាធម្មតាគេបានកំណត់អាយុចូលនិវត្តន៍នៃចៅក្រម ឬក៏មន្ត្រីផ្សេងៗទៀតដែលបំរើការងារក្នុងក្របខ័ណ្ឌអំណាចតុលាការ គឺថាដល់គ្រប់អាយុត្រូវតែលាឈប់ពីមុខងារជាស្វ័យប្រវត្តិ ដោយរក្សានូវអភ័យឯកសិទ្ធិ និងការសំរួលផ្សេងៗ ។

[៥៤]. Constitutional Law of Foreign Country Part II M.1994.Page 306

ចំពោះវិសមិតភាពនៃមុខងារចៅក្រម ឬ ( Magistrats) ជាធម្មតាត្រូវបានកំណត់ដោយច្បាប់នៃប្រទេសនីមួយៗដោយស្របទៅនឹងមុខងារដែលកំពុងបំពេញ ។ ជាពិសេសទៀតនោះច្បាប់ត្រូវបានហាមឃាត់ពុំឱ្យចៅក្រមទាំងអស់ ឬ Magistrats ចូលប្រឡូកក្នុងការងារនយោបាយ ឬក៏ក្នុងសហជីពផ្សេងៗឡើយ ជាក់ស្តែងតាម**មាត្រា ១២៧** វាក្យខ័ណ្ឌទីមួយនៃរដ្ឋធម្មនុញ្ញអេស្ប៉ាញ ១៩៧៨ បានកំណត់ថា ចៅក្រម និងតុលាការី (Magistrats) ទាំងអស់ រួមទាំងរដ្ឋអាជ្ញាផងនោះដរាបណានៅបំរើការក្នុងអំណាចតុលាការនោះ ពុំមានកាន់កាប់មុខងារសាធារណៈផ្សេងៗទៀតបានទេ ដូចជាក្នុងបក្សនយោបាយ ឬសហជីពនានាជាដើម ។

**ឃ. អង្គការជាន់ខ្ពស់នានានៃស្ថាប័នតុលាការស្វ័យគ្រប់គ្រង** : យើងបានដឹងខ្លះហើយថាអង្គការជាន់ខ្ពស់នានាមួយចំនួនរបស់តុលាការ ជាទូទៅវាប្រកាន់យកស្ថាប័នដែលមានឈ្មោះផ្សេងៗគ្នា ទៅតាមប្រទេសនីមួយៗ ផ្ទុយទៅវិញអង្គការជាន់ខ្ពស់ទាំងនោះត្រូវបានកំណត់ដោយច្បាប់កំពូលយ៉ាងសុក្រិត្យ ជាឧទាហរណ៍ដូចជាប្រទេស**អ៊ីតាលី, បារាំង, រ៉ូម៉ានី, កម្ពុជា,** មានឈ្មោះថា "**ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**" (Supreme Council of Magistracy) ប្រទេសអេស្ប៉ាញមានឈ្មោះថា "អគ្គក្រុមប្រឹក្សានៃអំណាចតុលាការ" រីឯតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៤ បានកំណត់តួនាទី និងសមាសភាពរបស់ខ្លួនតាម**មាត្រា ១** ថា "....បង្កើតឱ្យមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជួយព្រះមហាក្សត្រក្នុងការធានាឯករាជ្យនៃអំណាចតុលាការ ធានាវិន័យរបស់ចៅក្រម និងធានាការប្រព្រឹត្តិទៅនៃសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា ឱ្យដំណើរការបានល្អប្រសើរ"។ និង**មាត្រា ២** កំណត់ថា "ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសមាសភាពដូចខាងក្រោម :

១- ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ...................... ប្រធាន
២- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ...................................... សមាជិក
៣- ប្រធានតុលាការកំពូល ...................................... សមាជិក
៤- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល............................ សមាជិក

៥- ប្រធានសាលាឧទ្ធរណ៍............................................ សមាជិក

៦- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍................................ សមាជិក

៧- ចៅក្រមបីរូបដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រម......... សមាជិក ........" ។

នៅក្នុងច្បាប់នេះសំរាប់ធានានូវឯករាជ្យភាពនៃអំណាចតុលាការ ហើយដែលជាស្ថាប័នជាន់ខ្ពស់បំផុតនៃអង្គការតុលាការ ។ ការសំរេចរបស់អង្គការនេះត្រូវធ្វើឡើងតាមមតិភាគច្រើន ដូច**មាត្រា ៩** នៃបញ្ញត្តិដដែលនោះកំណត់ថា "សេចក្តីសំរេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវយកតាមមតិភាគច្រើននៃសមាជិកវត្តមាន និងតាមការបោះឆ្នោតជាសម្ងាត់ ។ ប្រធានអង្គប្រជុំមិនចូលរួមក្នុងការបោះឆ្នោតនេះទេ ។ ប៉ុន្តែក្នុងករណីដែលមានការបែងចែកសំលេងជាពីរស្មើគ្នា ប្រធានអង្គប្រជុំជាអ្នកសម្រេច" ។ រីឯកូរ៉ុមនៃការប្រជុំរបស់អង្គការនេះចាត់ទុកជាផ្លូវការ លុះត្រាតែមានសមាជិកចូលរួមយ៉ាងតិច ៧ រូប ដូចបានចែងក្នុងមាត្រា ៨ នៃច្បាប់ដដែលនោះ ។

ដូចនេះអង្គការជាន់ខ្ពស់នៃស្ថាប័នស្វ័យគ្រប់គ្រងតុលាការ គឺជាស្ថាប័នជាន់ខ្ពស់សំរាប់កំណត់ និងដាក់ទណ្ឌកម្មទៅលើចៅក្រម ឬព្រះរាជអាជ្ញានានា ក្នុងក្របខ័ណ្ឌនៃអំណាចតុលាការ ។ ប៉ុន្តែនៅក្នុងប្រទេសខ្លះស្ថាប័នរបៀបនេះគេពុំបានបង្កើតទេ ដូចជាប្រទេសជប៉ុនជាដើម ការដាក់វិន័យទៅលើចៅក្រម ត្រូវធ្វើតាមរយៈគណៈកម្មការ Impeachment ដែលសមាជិកគណៈកម្មការនេះមកពីសភាទាំងពីរស្មើគ្នាគឺប្រាំពីររូបមកពីសភាជាប់ទាប និងប្រាំពីររូបមកពីសភាជាន់ខ្ពស់ ។

ចំពោះអ្នកដែលស្នើដកចៅក្រម គឺតាមរយៈគណៈកម្មការរដ្ឋសភា ដែលសមាជិកមកពីសភាទាំងពីរស្មើគ្នាគឺ : ដប់នាក់មកពីសភាជាន់ទាប និងដប់នាក់ទៀតមកពីសភាជាន់ខ្ពស់ ។

## ២.គោលការណ៍ធម្មនុញ្ញគតិយុត្តិនៃការគ្រប់គ្រង និងសកម្មភាពរបស់ប្រព័ន្ធតុលាការ

**ក. គោលការណ៍នានានៃការគ្រប់គ្រង** : ជាធម្មតានៅក្នុងប្រទេសនីមួយៗ រដ្ឋធម្មនុញ្ញរបស់គេបានកំណត់យ៉ាងច្បាស់នូវប្រភេទនានានៃប្រព័ន្ធតុលាការ ឬក៏ប្រភេទនានានៃតុលាការរបស់ប្រទេសទាំងនោះ ដើម្បីញែកនូវកិរិតឯកទេសរបស់តុលាការក្នុងសកម្មភាពយុត្តាធិការនានា ។ គោលការណ៍នានាទាំងនោះត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ដូចជាគោលការណ៍ឯករាជ្យភាពនៃតុលាការត្រូវស្ថិត

នៅក្រោមច្បាប់ជាកំណត់ មានន័យថា "**តុលាការមានឯករាជ្យ លុះត្រាតែស្ថាប័នអំណាចតុលាការនោះគ្រប់ជាន់ថ្នាក់ស្ថិតនៅក្រោមច្បាប់មួយច្បាស់លាស់**" ។ ជាពិសេសទៀតនោះការធានាផ្សេងៗទៅលើអង្គការតុលាការ ដូចជាភាពមិនបំលាស់ប្តូរ (ភាពមិនបំលាស់ទី Irremovability), អភ័យឯកសិទ្ធិ (Immunity),.........។ល។ ក្នុងពេលបំរើការងារ ។ គោលការណ៍មួយទៀតនោះគឺ "**មុខងារយុត្តិធម៌ត្រូវធ្វើឡើងដោយតុលាការ តាមច្បាប់កំណត់ជាដាច់ខាត**" ដូចមាត្រា ១២៩ នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន" ។ ជាពិសេសទៀតនោះរដ្ឋធម្មនុញ្ញប្រទេសខ្លះហាមឃាត់មិនឱ្យបង្កើតតុលាការជាវិសាមញ្ញណាមួយឡើយ ។ ផ្ទុយទៅវិញនៅប្រទេសខ្លះគេអាចបង្កើតតុលាការសំរាប់ជំរះក្តីណាមួយបានដែរ ដោយអាស្រ័យនឹងច្បាប់គ្រឹះនៃប្រទេសនោះបានកំណត់ ។ តុលាការដែលត្រូវបានបង្កើតនោះមានឈ្មោះថា "ប្រឹក្សាតុលាការ" (Juror) ដែលមានការចូលរួមពីប្រជាជន ហើយច្រើនប្រើក្នុងប្រទេសប្រកាន់របបសង្គមនិយម ។ សូមចំណាំថា **ប្រឹក្សាតុលាការពុំមែនជំនុំជំរះតាមអង្គច្បាប់ទេ ប៉ុន្តែតាមអង្គហេតុ** ។

គោលការណ៍សំខាន់មួយទៀត ដែលរដ្ឋធម្មនុញ្ញប្រទេសជាច្រើនបានចារឹកនោះ គឺ**គោលការណ៍នៃដំណាក់កាលបណ្តឹង** (Instance) ដែលជានិច្ចកាលវាសំដែងក្នុងទិដ្ឋភាពមួយនៃសិទ្ធិជំទាស់ទៅលើសេចក្តីសំរេចរបស់តុលាការ ។ ត្រង់គោលការណ៍នេះចង់បញ្ជាក់ថា រាល់សេចក្តីសំរេចរបស់តុលាការពុំមែនសុទ្ធតែចូលជាធរមានភ្លាមៗនោះទេ គឺមានរយៈពេលកំណត់មួយ អញ្ចឹងហើយបានជាមានឱកាសមួយទុកសិទ្ធិឱ្យមានបណ្តឹងតវ៉ាតទៅទៀត ។ ដូចជារឿងមួយបានដោះស្រាយនៅតុលាការថ្នាក់ក្រោម ឬសាលាដំបូង (First instance) ដោយម្ចាស់ក្តីពុំសុខចិត្តក៏ប្តឹងទៅតុលាការ

ថ្នាក់ខ្ពស់ទៀត[៨៥] ឬហៅថាសាលាឧទ្ធរណ៍ (Appeals instance) (នៅក្នុងសាលាឧទ្ធរណ៍នេះមានមួយ ឬពីដំណាក់ទៀត តាមប្រទេសនីមួយៗ) ។ សរុបទៅសិទ្ធិបណ្ដឹងតវ៉ានេះមានទំរង់ពីរគឺ :

- បណ្ដឹងឧទ្ធរណ៍ដំណាក់ទីពីរ (Appeals instance). គឺជាបណ្ដឹងដែលធ្វើទៅតុលាការជាន់ខ្ពស់ដើម្បីពិនិត្យឡើងវិញនូវរឿងដែលមាននោះ ដោយចេញសាលក្រមសំរេចមួយសំរាប់បញ្ជាក់ទៅលើតុលាការថ្នាក់ក្រោមណាមួយដែលបានសំរេចរឿងនោះ ។ បណ្ដឹងរបៀបនេះគេថាជាបណ្ដឹងដែលតុលាការពិនិត្យត្រឹមតែអង្គហេតុ គឺពុំពិនិត្យអង្គច្បាប់ទេ ។

- បណ្ដឹងឧទ្ធរណ៍ដំណាក់កាលទីបី (Third appeal instance). នេះគឺជាបែបបទបណ្ដឹងមួយ ដែលក្នុងនោះតុលាការជាន់ខ្ពស់ត្រួតពិនិត្យឡើងវិញ ក្នុងការប្រតិបត្តិច្បាប់របស់តុលាការជាន់ទាបតែប៉ុណ្ណោះ ដោយគ្រាន់តែចេញសេចក្ដីថ្លែងការណ៍មួយក្នុងក្របខ័ណ្ឌនៃបណ្ដឹងនោះ ។ ប្រសិនបើសេចក្ដីសំរេចរបស់តុលាការជាន់ទាបត្រូវបានកត់សំគាល់ដោយតុលាការជាន់ខ្ពស់ តាមលំដាប់ថ្នាក់បណ្ដឹងឧទ្ធរណ៍ទីបីហើយនោះ នោះត្រូវបញ្ជូនរឿងទៅឱ្យតុលាការជាន់ទាបសំរេចជាថ្មីម្ដងទៀត ប៉ុន្តែផ្លាស់ប្ដូរសមាសភាពចៅក្រមដែលបានជំរះលើកមុនរបស់តុលាការនោះ ។ ករណីបណ្ដឹងឧទ្ធរណ៍នេះដូចជា**មាត្រា ២** ផ្នែកទីពីរនៃរដ្ឋធម្មនុញ្ញសហរដ្ឋបានកំណត់ថា "តុលាការកំពូលត្រូវតែមានយុត្តាធិការឧទ្ធរណ៍ក្នុងទំនាក់ទំនងអង្គច្បាប់ និងអង្គហេតុ" ។

បណ្ដឹងឧទ្ធរណ៍របៀបនេះគេហៅថាបណ្ដឹងពិនិត្យអង្គច្បាប់ ពុំមែនអង្គហេតុទេ ឬពិនិត្យទាំងពីរករណីក៏មានដែរ ។ ពាក្យថាអង្គច្បាប់ ពុំមានន័យថាច្បាប់ដែលធ្វើមកហើយនោះពុំយុត្តិធម៌ ឬអយុត្តិធម៌នោះទេ តែការពិនិត្យទៅលើអង្គច្បាប់មានន័យថា រឿងដែលកើតមកនោះវាត្រូវការច្បាប់ ឬសេចក្ដីសំរេច (ករណីយុត្តិសាស្ត្រ) បែបណាមួយសំរាប់អនុវត្តទៅលើវា ។

---

[៨៥]. តុលាការថ្នាក់ខ្ពស់ ជាតុលាការដែលមានសិទ្ធិដោះស្រាយបណ្ដឹងតវ៉ា ឬបណ្ដឹងឧទ្ធរណ៍ពីសាលាជាន់ទាប (First instance) ។
. តុលាការជាន់ខ្ពស់អាចមានពីរថ្នាក់ ឬបី វាអាស្រ័យនឹងប្រព័ន្ធយុត្តិធម៌នៃប្រទេសនីមួយៗ ។ សំរាប់ប្រទេសកម្ពុជាមានតែពីរថ្នាក់ទេ គឺសាលាឧទ្ធរណ៍ និងតុលាការកំពូល ។
. តុលាការកំពូលមានសិទ្ធិបកស្រាយច្បាប់ និងធ្វើសេចក្ដីសំរេចបែបយុត្តិសាស្ត្រក្នុងករណីដែលច្បាប់ពុំបានចែង ឬក៏ចែងពុំបានច្បាស់ ។

**៩. គោលការណ៍នានានៃសកម្មភាពរបស់ប្រព័ន្ធតុលាការ** ៖ គឺជាគោលការណ៍គ្រឹះសំខាន់ៗនៃនីតិវិធីរបស់តុលាការ ឬដំណើរការរបស់តុលាការ ដែលនៅក្នុងនីតិវិធីទាំងនោះត្រូវបានកំណត់ដោយច្បាប់មួយ ដើម្បីធ្វើនិយ័តកម្មទៅលើ**សណ្តាប់ធ្នាប់នៃសវនាការ និងការសំរេចផ្សេងៗរបស់ការងារតុលាការ** ។ នៅក្នុងវិធានទូទៅ ចំពោះគោលការណ៍ទាំងអស់នោះត្រូវបានកំណត់ក្នុងនីតិកម្ម ឬច្បាប់នៃប្រទេសនីមួយៗ ដូចជាក្នុងក្រមព្រហ្មទណ្ឌ, ក្រមរដ្ឋប្បវេណី, ក្រមរដ្ឋបាល............។ល។ ដោយរួមទាំងក្រមនីតិវិធីនៃវិស័យនីមួយៗផងដែរ ។ ប៉ុន្តែផ្ទុយទៅវិញ ក្នុងប្រទេសមួយចំនួនគោលការណ៍នានានៃដំណើរការតុលាការ ត្រូវបានគេកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ដែលគោលការណ៍នោះមានលក្ខណៈដូចជាការប្រកាសជាសាធារណៈ (Publicity) នៃការបើកសវនាការតុលាការ ។ តាម **មាត្រា ១២០** វាក្យខ័ណ្ឌទី ៣ រដ្ឋធម្មនុញ្ញអេស្ប៉ាញ កំណត់ថា "រាល់សេចក្តីសំរេចរបស់តុលាការត្រូវប្រកាសជាសាធារណៈ........", រីឯវាក្យខ័ណ្ឌទី ១ **មាត្រា ១២៩** រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "ការជំរះក្តីផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន"។ គោលការណ៍ធម្មនុញ្ញសំខាន់មួយទៀត ដែលកំណត់ទៅលើនីតិវិធីនៃតុលាការ គឺ**គោលការណ៍ផ្សារភ្ជាប់របស់ចៅក្រមមានតែច្បាប់ប៉ុណ្ណោះ** ។ ត្រង់គោលការណ៍នេះបញ្ជាក់ថា ចៅក្រមទាំងអស់ធ្វើការវិនិច្ឆ័យរឿងក្តីទាំងឡាយត្រូវតែប្រកាន់យកច្បាប់ជាមូលដ្ឋាន **តែពុំមែនទទួលយកការចង្អុលបង្ហាញពីអ្នកណាមួយឡើយ** ក្នុងនោះទោះជារាល់បទដ្ឋានកិច្ចរបស់តុលាការជាន់ទាប ឬខ្ពស់ក៏ដោយ ទោះបទដ្ឋានកិច្ចទាំងនោះ ឬសេចក្តីសំរេចនោះ ជាទំនាក់ទំនងមួយដែលមានអត្ថន័យជាផ្លូវច្បាប់សំរាប់មតិរបស់តុលាការក៏ដោយ ។ គោលបំណងនេះពុំត្រូវអនុវត្តឡើយ គឺថារឿងណាត្រូវអនុវត្តច្បាប់ណាដែលបានចែងជាកំណត់ មិនត្រូវយកបទដ្ឋានកិច្ចផ្សេងៗ ដែលមតិរបស់ខ្លួនថាមានអត្ថន័យអាចដោះស្រាយបាននោះទេ ។ ដូចជាវាក្យខ័ណ្ឌទី ២ **មាត្រា ១២៩** រដ្ឋធម្មនុញ្ញកម្ពុជា កំណត់ថា "មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឹងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន" ។ **ប៉ុន្តែចៅក្រមអាចយកសេចក្តីសំរេចបែបយុត្តិសាស្ត្រ របស់តុលាការកំពូលមកដោះស្រាយបានដែរ បើសិនជាច្បាប់គ្រឹះកំណត់ថាសេចក្តីសំរេចរបស់តុលាការកំពូលជាប្រភពនៃច្បាប់ ។**

**គ. ប្រព័ន្ធតុលាការនៃយុត្តាធិការទូទៅ** : ជាទូទៅយុត្តាធិការនៃប្រទេសនីមួយៗត្រូវបានរៀបចំឡើងផ្សេងៗគ្នា ដោយអាស្រ័យនឹងប្រព័ន្ធតុលាការសាម៉ីប្រទេសរបស់គេ ។ ប្រព័ន្ធតុលាការរបៀបនេះវាពឹងផ្អែកទាំងស្រុងទៅនឹងចំនួននៃលំដាប់ថ្នាក់ (Instance) ក្នុងដំណើរការគតិយុត្តិទូទៅ (យុត្តាធិការ ឬនីតិវិធីធ្វើឱ្យត្រឹមត្រូវតាមផ្លូវច្បាប់) ឬក៏គេអាចហៅថាជាប្រភេទនីតិវិធីនានា សំរាប់ធ្វើការជំនុំជំរះរឿងក្តី ឬបណ្តឹងផ្សេងៗ ។ ដូចនេះ លំដាប់ថ្នាក់សាលាក្តីរបស់តុលាការនៅថ្នាក់ក្រោមគេឱ្យឈ្មោះថា "*សាលាដំបូង*" ដែលមានលំដាប់ថ្នាក់ទីមួយ (First instance) រីឯនៅសាលាក្តីរបស់តុលាការជាន់ខ្ពស់ អាចមានតុលាការថ្នាក់**ឧទ្ធរណ៍ទីមួយ, ឧទ្ធរណ៍ទីពី, ឬឧទ្ធរណ៍ទីបី** (មើលរូបទី ១៦) ។ ជាទូទៅប្រព័ន្ធតុលាការរបស់ប្រទេសនីមួយៗ ច្រើនយកតាមគំរូគ្រឹះនៃប្រព័ន្ធគតិយុត្តិអង់គ្លោសាក់សុង ឬប្រព័ន្ធគតិយុត្តិកុងទីណង់តាល់ សំរាប់ចាត់ចែងនូវយុត្តាធិការចំពោះរឿងក្តីនានា។ ប្រព័ន្ធគំរូនោះមាន[៨៦] :

**គ១. សញ្ញាណគ្រឹះសំខាន់ៗនៃគំរូអង់គ្លោសាក់សុង** : តាមប្រព័ន្ធគតិយុត្តិនេះគេប្រកាន់យកគោលការណ៍សំខាន់ៗមួយចំនួនសំរាប់អនុវត្តក្នុងក្របខ័ណ្ឌនៃតុលាការមាន :

- សជ្ជកម្ម ឬការប្រតិបត្តិតៗគ្នាទៅលើសេចក្តីសំរេចរបស់តុលាការ (Adherence) ។ ជាប្រវត្តិសាស្ត្រ ចំពោះប្រទេសដែលប្រកាន់យកច្បាប់សកល (Common Law), ដូចជាប្រទេសអង់គ្លេសមានការទទួលស្គាល់នូវតួនាទីនីតិកម្មរបស់តុលាការ និងតួនាទីនៃសាលក្រមរបស់តុលាការ (សេចក្តីសំរេច) ចាត់ទុកជាប្រភពនៃច្បាប់ ។ តុលាការនៅក្នុងល័ក្ខខ័ណ្ឌនេះ គឺជាតុលាការជាន់ខ្ពស់របស់ប្រទេស ។

- ការបង្កើតឱ្យមាននូវទំរង់នីតិវិធីនានា នៃការចោទប្រកាន់របស់តុលាការ ដែលក្នុងនោះត្រូវធ្វើឡើងតាមការប្រតិបត្តិរបស់តុលាការ តែពុំមែនកំណត់ដោយច្បាប់ទេ ។ នៅក្នុងន័យនេះការចោទប្រកាន់របស់តុលាការ ត្រូវបានធ្វើឡើងតាមនីតិវិធីដែលតុលាការធ្លាប់អនុវត្ត ដែលនីតិវិធីនោះពុំបានកំណត់ដោយច្បាប់ណាមួយនោះទេ ។

---

[៨៦]. Constitutional Law of Foreign Country Part II, M.1994, Page 316

- ទំរង់ឧទ្ធរណ៍ក្នុងការបណ្តឹង ចំពោះសេចក្តីសំរេចតុលាការមានលក្ខណៈពិសេសបំផុត ។ ត្រង់នេះចង់បញ្ជាក់ថា រាល់សេចក្តីសំរេចរបស់តុលាការអាចឱ្យមានបណ្តឹងឧទ្ធរណ៍បាន តាមល័ក្ខខ័ណ្ឌនៃរឿងតែប៉ុណ្ណោះ ។

- មានការកំរិតនូវវិវាទកម្ម ដែលក្នុងនោះចៅក្រមសំដែងជាលក្ខណៈអកម្ម ដោយគ្រាន់តែតាមអង្កេតមើលការប្រតិបត្តិចំពោះគូក្តី តាមទំរង់នីតិវិធីប៉ុណ្ណោះ ។ តុលាការធ្វើការសន្មត់ (Presumption) ទៅលើរឿងក្តីអំពីការទទួលស្គាល់នៃកំហុស ។

- មានការប្រើប្រាស់យ៉ាងទូលាយនូវស្ថាប័ននៃប្រឹក្សាតុលាការ និងចៅក្រមសន្តិភាព ។ នៅក្នុងគំរូនេះគេអាចបង្កើតតុលាការជាវិសាមញ្ញណាមួយបាន តាមទំលាប់ដែលទាក់ទិនទៅនឹងរឿងក្តីតែប៉ុណ្ណោះ ។

- មានការជ្រើសរើសចៅក្រមយ៉ាងទូលាយ ។ ក្នុងគំរូនេះរឿងក្តីខ្លះគេអាចជ្រើសរើសចៅក្រមមកកាត់ក្តីបាន ទៅតាមរឿងក្តីដែលចៅក្រមទាំងនោះពុំមែនជាចៅក្រមអាជីព ជាអ្នកច្បាប់នោះទេ ។

**ច២. សញ្ញាណគ្រឹះសំខាន់ៗនៃគំរូកុងទីណង់តាល់** : នេះជាគំរូមួយដែលប្រទេសមួយចំនួនបានប្រកាន់យកតាមមូលដ្ឋានមួយចំនួនដូចខាងក្រោម :

- យកច្បាប់ជាធំក្នុងការកំណត់អង្គការគ្រប់គ្រង និងសកម្មភាពរបស់តុលាការ ។

- មិនទទួលស្គាល់នូវសេចក្តីសំរេចរបស់តុលាការជាប្រភពនៃច្បាប់ ។

- ប្រើប្រាស់ទំរង់តាមលំដាប់ថ្នាក់នៃឧទ្ធរណ៍ ដូចជាសេចក្តីសំរេចរបស់តុលាការលើអង្គហេតុ និងអង្គច្បាប់ ។ មានន័យថា រាល់សេចក្តីសំរេចរបស់តុលាការត្រូវតែមានបើកផ្លូវឧទ្ធរណ៍ ។

- ចៅក្រមដើរតួយ៉ាងសំខាន់នៅក្នុងដំណើរការកាត់ក្តី ដោយពុំមានការកំរិតនូវវិវាទកម្ម ឬកំរិតនូវការជជែកនៃគូក្តីឡើយ ។

- មានការប្រើប្រាស់តិចបំផុតនូវស្ថាប័ននៃប្រឹក្សាតុលាការ និងចៅក្រមសន្តិភាព ។

- ការបង្កើតឱ្យមាននូវអង្គការស្វ័យគ្រប់គ្រងតុលាការដាច់ដោយឡែក ឬជាអន្លើៗ ដោយស្របនឹងមុខងាររបស់បុគ្គលិក និងសិទ្ធិអំណាច ( មានន័យថា បង្កើតឱ្យមានសិទ្ធិអំណាចឯករាជ្យរបស់មន្ត្រីនៃតុលាការគ្រប់ជាន់ថ្នាក់។

ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធទាំងពីរនេះពុំមាននិន្នាការដូចគ្នាបានទេ ព្រោះប្រព័ន្ធអង់គ្លោសាក់សង់ យកសេចក្តីសំរេចរបស់តុលាការជានិយ័តកម្មគតិយុត្តិ (ចាត់ទុកជាច្បាប់) ឯប្រព័ន្ធកុងទីណង់តាល់យកនិយ័តកម្មគតិយុត្តិ (ច្បាប់) ធ្វើជាមូលដ្ឋានគ្រឹះសំរាប់កំណត់គ្រប់ទំនាក់ទំនងសង្គម។ ប៉ុន្តែប្រព័ន្ធកុងទីណង់តាល់ សេចក្តីសំរេចរបស់តុលាការជាន់ខ្ពស់ក៏ចាត់ទុកជាប្រភពនៃច្បាប់បានដែរ សំរាប់ឱ្យតុលាការថ្នាក់ទាប និងបន្តអនុវត្តទៅមុខទៀត ។ សេចក្តីសំរេចបៀបនេះធ្វើបានតែលើចំនុចកង្វះចន្លោះនៃច្បាប់តែប៉ុណ្ណោះ មានន័យថាច្បាប់ណាមួយ ចែងពុំគ្រប់គ្រាន់នូវអំពើណាមួយក្នុងការដាក់វិន័យ ឬទណ្ឌកម្ម ។

ដូចនេះប្រព័ន្ធតុលាការនៃយុត្តាធិការទូទៅ (General Jurisdiction) ដែលកើតមាននៅក្នុងបណ្តាប្រទេសនានា ដោយឈរលើប្រភេទមួយចំនួន បើគិតតាមកំរិតនៃបណ្តឹង ដែលមានពីថ្នាក់ទាបបំផុតរហូតដល់ថ្នាក់ខ្ពស់បំផុត ។ កំរិតទាំងនោះមានតុលាការដូចជា :

- ថ្នាក់ដំបូងបំផុត : តុលាការសន្តិភាព, ប៉ូលីសយុត្តិធម៌, តុលាការសហគមន៍ ។ល។
- ថ្នាក់មូលដ្ឋានគ្រឹះ : តុលាការ ខេត្ត-ក្រុង ឬតំបន់, តុលាការយោធា
- ថ្នាក់ឧទ្ធរណ៍ : សាលាឧទ្ធរណ៍, តុលាការជាន់ខ្ពស់ ។ល។
- ថ្នាក់កំពូល : តុលាការកំពូល, តុលាការបណ្តឹងសាទុក្ខ ។ល។ ដោយយោងទៅលើកំរិតនៃតុលាការក្នុងយុត្តាធិការទូទៅនេះ តាមច្បាប់ការគ្រប់គ្រងរបស់ប្រទេសអេស្ប៉ាញស្តីពីអំណាចតុលាការ[៨៧] បានកំណត់អំពីប្រព័ន្ធតុលាការផ្នែកយុត្តាធិការទូទៅនោះមាន :

[៨៧]. Constitutional Law of Foreign Country, Part II, M.1994, Page 317

- តុលាការសន្តិភាព (Juzgados de Paz)

- តុលាការថ្នាក់ដំបូង និងការស៊ើបសួរ (Juzgados de Primera Instancia e Instruccion) ទទួលបន្ទុករឿងព្រហ្មទណ្ឌ, រឿងរដ្ឋបាល, រឿងសង្គមកិច្ច, រឿងអនីតិជន និងទទួលបន្ទុកកិច្ចការពន្ធធនាគារ (ការត្រួតមើល ការដកសិទ្ធិនានា) ។

- សាលាក្តីខេត្តនានា (Audiencias Provinciales)

- សាលាក្តីយុត្តិធម៌ជាន់ខ្ពស់មួយចំនួន (Tribunales Superiores de Justicia) នៅក្នុងសហគមន៍ស្វយ័តនានា ដែលស្ថិតក្នុងសមាសភាពរបស់អេស្ប៉ាញ.

- សាលាក្តីមួយថ្នាក់ជាតិ (Audiencia Nacional)

- សាលាក្តីកំពូលមួយ (Tribunal Supremo)

នៅក្នុងច្បាប់នេះ ពុំបានកំណត់អំពីការដោះស្រាយទំនាស់ដែលទាក់ទិននឹងអធម្មនុញ្ញភាពនោះទេ គឺតុលាការទាំងនេះដោះស្រាយតែទំនាស់ដែលកើតមានក្នុងសង្គមផ្ទុយនឹងច្បាប់តែប៉ុណ្ណោះ រីឯទំនាស់ដែលកើតចេញពីភាពផ្ទុយគ្នានៃការចែងច្បាប់នោះ គឺជាសមត្ថកិច្ចតុលាការធម្មនុញ្ញ ។

យើងឃើញថា ប្រព័ន្ធតុលាការក្នុងផ្នែកយុត្តាធិការនៃប្រទេសនីមួយៗវាមានប្រភេទផ្សេងៗគ្នា ប្រទេសខ្លះនៅសាលាក្តីជាន់ទាប គេអាចបង្កើតជារចនាសម្ព័ន្ធច្រើនទៀត ដូចជាសាលាក្តីថ្នាក់ក្រុងមានសាលាក្តីថ្នាក់សង្កាត់ ឬឃុំ ជាដើម ........ ។ល។ ដែលមានព្រំដែនគ្រប់គ្រងអាស្រ័យនឹងដែនដីរដ្ឋបាលរបស់ខ្លួន ។ ដូច**មាត្រា ២** វាក្យខ័ណ្ឌទី ២ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ឆ្នាំ ១៩៩៣ កំណត់ថា "តុលាការខេត្ត-ក្រុង ដែលត្រូវតាំងនៅខេត្តក្រុងមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃខេត្តក្រុងទាំងនោះ" ។ ប៉ុន្តែក៏មានសាលាជំរះក្តីខ្លះពុំកើតអាស្រ័យនឹងដែនដីនោះទេ ដូចជា**មាត្រា ២** វាក្យខ័ណ្ឌទី ៣ នៃ បញ្ញត្តិដដែលកំណត់ថា "តុលាការយោធាដែលត្រូវតាំងនៅភ្នំពេញ មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃរដ្ឋកម្ពុជាទាំងមូល" ។ និង**មាត្រា ៣** វាក្យខ័ណ្ឌទី ២ កំណត់ថា "សាលាឧទ្ធរណ៍ និងតុលាការកំពូល មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃរដ្ឋកម្ពុជាទាំងមូល" ។

## គំនូសបំព្រួញនៃប្រព័ន្ធតុលាការកម្ពុជា (រូបទី ១៦) (គំរូទី ១)



# គំនូសបំព្រួញនៃលំដាប់ថ្នាក់របស់តុលាការកម្ពុជា
## (រូបទី ១៦) (គំរូទី ២)



ដូចនេះប្រព័ន្ធតុលាការនៃយុត្តាធិការទូទៅរបស់ប្រទេសនីមួយៗ ទោះជាតាមប្រភេទគំរូអង់គ្លេសាក់សុង ឬកុងទីណង់តាល់ក៏ដោយ ចាំបាច់ត្រូវមានគំរូរួមមួយជាដាច់ខាតគឺ : **ផ្នែកដំបូងគឺ** អាចមានតុលាការសន្តិភាព, ប៉ូលីសយុត្តិធម៌ ឬហៅថា "តុលាការលហុ", តុលាការសហគមន៍, **ផ្នែកគំរូត្រឹះទីពីរ** ឬហៅថា "សាលាដំបូង" មានតុលាការខេត្ត-ក្រុង, តុលាការយោធា..........) ។ **ផ្នែកទីបី** ឬឧទ្ធរណ៍ ឬហៅថាតុលាការជាន់ខ្ពស់ មានតុលាការជាន់ខ្ពស់ ឬតុលាការកំពូល ។

**ឃ. យុត្តិធម៌រដ្ឋបាល** (Administrative Justice) : យុត្តិធម៌រដ្ឋបាល គឺជាមែកធាងនៃអំណាចតុលាការដែរ ដែលក្នុងនោះវាជាស្ថាប័នសំខាន់បំផុតដើម្បីរក្សានូវសិទ្ធិ និងសេរីភាពមនុស្ស, សិទ្ធិ និងសេរីភាពពលរដ្ឋ និងផ្ដត់ផ្ដង់ជាទូទៅនូវសណ្ដាប់ធ្នាប់គតិយុត្តិ ដែលកើតមានក្នុងការគ្រប់គ្រងសង្គមទាំងមូល ដូចជាវិន័យរបស់មន្ត្រីរដ្ឋក្នុងការបំពេញការងារជាដើម ។

នៅក្នុងប្រទេសខ្លះ គេអាចបង្កើតប្រព័ន្ធតុលាការសំរាប់វិនិច្ឆ័យខាងផ្នែករដ្ឋបាល នេះជាតុលាការរដ្ឋបាលថ្នាក់ខ្ពស់ ឬតុលាការរដ្ឋបាលកំពូល ជាពិសេសប្រទេសដែលប្រកាន់ប្រព័ន្ធគតិយុត្តិកុងទីណង់តាល់ ដូចជាប្រទេសបារាំងអ៊ីតាលី....... ប្រព័ន្ធតុលាការយុត្តិធម៌រដ្ឋបាលនេះមានឈ្មោះថា "**ក្រុមប្រឹក្សារដ្ឋ**" ភារកិច្ចរបស់អង្គការនេះ គឺដោះស្រាយរាល់ទំនាស់រដ្ឋបាលដែលកើតមានឡើងរវាងនីតិបុគ្គល និងរូបវន្តបុគ្គល ជាមួយនឹងអង្គការផ្សេងៗទៀត និងបុគ្គលដែលមានមុខងាររដ្ឋ (មន្ត្រីរដ្ឋ) នៃការគ្រប់គ្រងសាធារណៈ ឬការគ្រប់គ្រងរដ្ឋបាល ។ ក្នុងការដោះស្រាយរបៀបនេះ តុលាការរដ្ឋបាលត្រូវត្រួតពិនិត្យមើលនូវ**យុត្តិភាព** (Legality) **នៃបទដ្ឋានកិច្ច** (Acts) **នានារបស់អង្គការទាំងឡាយ និងមន្ត្រីរដ្ឋនៃការគ្រប់គ្រងសាធារណៈ** ថាតើវាបានបំពានទៅលើបទដ្ឋានកិច្ចទាំងនោះ ឬក៏បទដ្ឋានកិច្ចទាំងនោះបំពានទៅលើអង្គការគ្រប់គ្រងសាធារណៈ ឬក៏សេចក្ដីសំរេចរបស់អង្គការ ឬមន្ត្រីទាំងនោះ បំពានទៅនឹងបទដ្ឋានកិច្ចដែលមានកំលាំងគតិយុត្តិខ្ពស់ជាង ។

យុត្តិធម៌រដ្ឋបាលនៅក្នុងប្រទេសខ្លះ រដ្ឋធម្មនុញ្ញពុំបានកំណត់ប្រព័ន្ធតុលាការរដ្ឋបាលឱ្យវានៅដាច់ចេញពីយុត្តាធិការទូទៅនោះទេ ដោយទុកវានៅក្នុងប្រព័ន្ធយុត្តាធិការរួម ដូចជា[៨៨] **ជប៉ុន,**

---

[៨៨]. Constitutional Law of Foreign Country Part II, M.1994, Page 319

**អាមេរិក, បែលស៊ិក, អេស្ប៉ាញ, រ៉ូម៉ានី** និងប្រទេសដ៏ទៃទៀត ។ល។ ប៉ុន្តែប្រទេសមួយចំនួនទៀត បានបង្កើតអង្គការយុត្តិធម៌រដ្ឋបាលជាន់ខ្ពស់នេះនៅដាច់ពីយុត្តាធិការទូទៅ ដូចជា : **អាល្លឺម៉ង់, អ៊ីតាលី, បារាំង, ប៊ុលហ្គារី, ឆេក** និងប្រទេសមួយចំនួនទៀត ។ យើងអាចសង្កេតឃើញប្រព័ន្ធយុត្តិធម៌រដ្ឋបាលនៅក្នុងសមាសភាពយុត្តាធិការទូទៅ ដូចជានៅចក្រភពអង់គ្លេស និងអាមេរិក មានប្រព័ន្ធតុលាការត្រួតពិនិត្យទៅលើលិខិតស្នាមរដ្ឋបាលនានា ធ្វើឡើងដោយតុលាការនៃយុត្តាធិការទូទៅ ចាប់តាំងពីមុនមកក៏ដោយ ក៏នៅក្នុង ស.វ ទី ២០ នេះគេបានបង្កើតអង្គការរដ្ឋបាលដាច់ដោយឡែក ដើម្បីត្រួតពិនិត្យកិច្ចការរដ្ឋបាលដែរ ។ អង្គការរដ្ឋបាលនេះវាមានមុខងារប្រហាក់ប្រហែលនឹងតុលាការដែរ ហៅថា "ស្ថាប័នប្រហាក់ប្រហែលតុលាការ" (quasi-judicial) ដែលវាអាចដោះស្រាយរឿងបានលឿនជាងតុលាការធម្មតា ដែលមានពីមុន ។

ប៉ុន្តែបើទោះបីជាប្រទេសទាំងពីរមានអង្គការរដ្ឋបាល ដោយឡែកសំរាប់ត្រួតពិនិត្យកិច្ចការរដ្ឋបាលនានា (យុត្តិធម៌រដ្ឋបាល) ក៏ដោយ ក៏ស្ថាប័នរដ្ឋបាល (តុលាការរដ្ឋបាល) ទាំងនេះនៅតែស្ថិត **ក្រោមការត្រួតពិនិត្យពីតុលាការយុត្តាធិការទូទៅដដែល**[៨៩] ។

គេអាចសង្កេតឃើញការត្រួតពិនិត្យរបស់អង្គការទាំងនោះក្នុងពេលចុងក្រោយ ដូចជាការត្រួតពិនិត្យលើបទបញ្ញត្តិរដ្ឋបាលនានា ដែលហៅថា "**បទបញ្ជាតុលាការ**"[៩០] តាមរយៈ "Writ of Mandamus" នេះគឺជាបទបញ្ជារបស់តុលាការ ដែលបង្គាប់ឱ្យមន្ត្រីកាន់កាប់តួនាទីណាមួយប្រព្រឹត្តនូវអំពើ ឬបង្កើតបទបញ្ញត្តិ (រដ្ឋបាល) ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រីឯបទបញ្ជាតុលាការមួយផ្សេងទៀតមានឈ្មោះថា "Writ of Injunction" នេះជាបទបញ្ជាដែលមានលក្ខណៈអធិបញ្ជាមួយរបស់តុលាការ ដែលហាមឃាត់ទៅលើបុគ្គលដែលមានឋានៈណាមួយ មិនឱ្យប្រព្រឹត្ត ឬបង្កើតបទបញ្ញត្តិបានឡើយ ។

---

[៨៩]. Constitutional Law of Foreign Country Part II. M.1994. Page 319

[៩០]. Constitutional Law of Foreign Country Part II. M.1994. Page 319

យើងអាចឃើញអង្គការដាច់ដោយឡែក (តុលាការរដ្ឋបាល) ដែលមាននាទីក្នុងកិច្ចការយុត្តិធម៌រដ្ឋបាល ហើយមិនស្ថិតក្នុងសមាសភាពនៃតុលាការយុត្តាធិការទូទៅនោះទេ ។ តុលាការនេះមានលក្ខណៈឯករាជ្យ ដាច់ចេញពីមែកធាងនៃប្រព័ន្ធយុត្តាធិការទូទៅរបស់តុលាការ ដូចជាសហព័ន្ធអាល្លឺម៉ង់ជាដើម ។ ប្រព័ន្ធតុលាការរដ្ឋបាលត្រូវបានបង្កើតឡើងតាមបញ្ញត្តិមួយក្នុងឆ្នាំ ១៩៦០ ដែលក្នុងនោះគេបានកំណត់នូវកំរិតបណ្ដឹងបីដំណាក់កាល[៩១] គឺ : ទីមួយ : **តុលាការរដ្ឋបាល**, ទីពីរ : **តុលាការរដ្ឋបាលជាន់ខ្ពស់នៃរដ្ឋសមាជិក ឬសាលាឧទ្ធរណ៍រដ្ឋបាល** និងទីបី :**តុលាការរដ្ឋបាលសហព័ន្ធ ឬតុលាការបណ្ដឹងសារទុក្ខ** ។ តុលាការទាំងបីលំដាប់នេះធ្វើសកម្មភាពស្របគ្នា ។ សមាសភាពចៅក្រមនៅក្នុងតុលាការលំដាប់ទីមួយ និងទីពីរ ដោះស្រាយរឿងត្រូវមានចៅក្រមវិជ្ជាជីវៈបីនាក់ និងទីប្រឹក្សាប្រជាជនពីររូប ដែលបោះឆ្នោតជ្រើសរើសពីប្រជាពលរដ្ឋមានអាណត្តិ ៤ ឆ្នាំ ហើយដែលពុំមែនជាមនុស្សក្នុងក្រុមវិជ្ជាជីវៈណាមួយ ។

ចំពោះប្រទេសកម្ពុជា តាមរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ បានកំណត់អំពីការដោះស្រាយរឿងរដ្ឋបាលនេះស្ថិតក្នុងប្រព័ន្ធយុត្តាធិការទូទៅ ។ ត្រង់នេះគឺមានន័យថា តុលាការយុត្តាធិការទូទៅដោះស្រាយរឿងរដ្ឋបាលបានតាមលំដាប់នៃតុលាការធម្មតាបាន មិនចាំបាច់បង្កើតតុលាការរដ្ឋបាលពិសេសផ្សេងទៀតឱ្យទទួលចាត់ការរឿងនោះឡើយ ។

## ៣. ធម្មនុញ្ញត្រួតពិនិត្យ និងធម្មនុញ្ញយុត្តិធម៌

**ក. និយមន័យនៃធម្មនុញ្ញត្រួតពិនិត្យ :** ពាក្យថា "**ត្រួតពិនិត្យ**" (Control) និងពាក្យ "**សង្កេតការណ៍**" (Sepervision) ពាក្យទាំងពីរនេះតាមអត្ថបទច្បាប់នៃប្រទេសនីមួយៗ ពុំមានន័យដូចគ្នាទេ ប៉ុន្តែយើងតែងហៅថាជាការត្រួតពិនិត្យដូចគ្នា ។ ពាក្យថាត្រួតពិនិត្យ គឺជាប្រព័ន្ធមួយនៃទំនាក់ទំនងទាំងឡាយរវាងអង្គការនានានៃអំណាចរដ្ឋ ដែលនៅក្នុងនោះអង្គការត្រួតពិនិត្យអាចលុបចោលនូវបទដ្ឋានកិច្ចនានារបស់អង្គការក្រោមបង្គាប់ ឬអង្គការដែលស្ថិតនៅក្រោមការត្រួតពិនិត្យ ។ ប៉ុន្តែ

---

[៩១]. Constitutional Law of Foreign Country, Part II, M.1994, Page 320 ។

វាស្មើនឹងពាក្យថា "**ធ្វើអធិការកិច្ច**" (Inspection)។ ចំពោះពាក្យសង្កេតការណ៍ (Supervision) គឺជាប្រព័ន្ធមួយនៃទំនាក់ទំនងទាំងឡាយ រវាងអង្គការនានានៃអំណាចរដ្ឋ ដែលនៅក្នុងនោះអង្គការសង្កេតការណ៍អាចមានត្រឹមតែការយកចិត្តទុកដាក់ដោយល្អិតល្អន់ទៅលើសកម្មភាព ឬកំហុសរបស់អង្គការ ដែលស្ថិតនៅក្រោមការសង្កេតការណ៍តែប៉ុណ្ណោះ ប៉ុន្តែអាចមានលើសពីនេះទៀត អាចផ្អាកសកម្មភាពទៅលើបទដ្ឋានកិច្ចរបស់វាបាន ប៉ុន្តែអាចលប់ ឬកែតំរូវបានលើបទដ្ឋានកិច្ចនោះ គឺអាស្រ័យនឹងអង្គការ ក្រោមការសង្កេតការណ៍ខ្លួនឯងផ្ទាល់ជាអ្នកសំរេច ។ ប៉ុន្តែក៏មានន័យផ្សេងទៀតដែរ គឺត្រួតពិនិត្យវាធ្វើទៅលើតែសកម្មភាពនៃអង្គការថ្នាក់ក្រោម ឯការសង្កេតការណ៍គឺជាការសង្កេតជាអចិន្ត្រៃយ៍ទៅលើសកម្មភាពនៃអង្គការដែលត្រូវសង្កេត ។

ដូចនេះធម្មនុញ្ញត្រួតពិនិត្យគឺជាប្រព័ន្ធមួយនៃទំនាក់ទំនងនានា ដែលក្នុងនោះមានទំរង់ត្រួតពិនិត្យនានា ទៅលើធម្មនុញ្ញភាពនៃបទដ្ឋានកិច្ចនានា និងទៅលើរាល់អំពើ ឬសកម្មភាពរបស់អង្គការនានានៃអំណាចរដ្ឋ (អំណាចសាធារណៈ) ដោយរួមទាំងការត្រួតពិនិត្យទៅលើការប្រមូលផ្តុំសង្គមផ្សេងៗ ដែលបំពេញមុខងារជាសាធារណៈ ឬក៏បង្កើតឡើងសំរាប់ការចូលរួមនៅក្នុងការបំពេញកិច្ចនៃអំណាចសាធារណៈ។

ពាក្យថា "**ធម្មនុញ្ញភាព**" (Constitutionality) នៃបទដ្ឋានកិច្ចនានា (Acts) គឺជា**ភាពគ្មានទំនាស់ ឬការផ្ទុយនៃបទដ្ឋានកិច្ចនានាទៅលើបទដ្ឋាននៃរដ្ឋធម្មនុញ្ញ** (ច្បាប់គ្រឹះ)។ ត្រង់នេះគឺយើងពិបាកពិនិត្យណាស់ ព្រោះថានិយ័តកម្មគតិយុត្តិចំពោះព្រំដែនទាំងនោះ ពុំអាចត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញមួយបានទេ។ ដោយហេតុថាទំនាក់ទំនងសង្គមមានភាពទូលាយណាស់ ហើយច្បាប់ទាំងនោះតំរូវឱ្យធ្វើនិយ័តកម្មទៅលើទំនាក់ទំនងសង្គមដោយស្រប ឬប្រកាន់ខ្ជាប់នូវធម្មនុញ្ញភាព ឬស្របនឹងរដ្ឋធម្មនុញ្ញ ។ ប៉ុន្តែច្បាប់ខ្លះដែលបង្កើតមកហើយ ក៏មានលក្ខណៈផ្ទុយនឹងរដ្ឋធម្មនុញ្ញដែរ ដែលគេហៅថា "**អធម្មនុញ្ញភាពនៃបទដ្ឋានកិច្ច**"។ អធម្មនុញ្ញភាពនៃបទដ្ឋានកិច្ចមួយ មានអត្ថន័យផ្សេងៗទៅលើធម្មនុញ្ញភាព ឬក៏និយាយបានថាបទដ្ឋានកិច្ចនោះមានខ្លឹមសារផ្ទុយនឹងរដ្ឋធម្មនុញ្ញ ។

ប្រវត្តិដើមនៃគំនិតក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនេះ កើតមាននៅដើមស.វ ទី XVII នៅចក្រភពអង់គ្លេស ដែលនៅពេលនោះវាបានផ្សារភ្ជាប់ជាមួយនឹងសកម្មភាពនៃ "**ក្រុមប្រឹក្សាសំងាត់**"[៩២] មួយដោយក្នុងនោះក្រុមប្រឹក្សានេះ បានទទួលស្គាល់នូវច្បាប់នានានៃឡេជីស្លេជ័រ (Legislature អំណាចនីតិបញ្ញត្តិ) របស់ប្រទេសអាណានិគមចំណុះខ្លះថាគ្មានសកម្មភាពទេ ប្រសិនបើច្បាប់ទាំងនោះផ្ទុយនឹងច្បាប់មួយរបស់រដ្ឋសភាអង់គ្លេស ឬផ្ទុយនឹងច្បាប់សកល (Common Law)។ ត្រង់ចំណុចនេះបញ្ជាក់ថា បើប្រទេសណានៅក្រោមចំណុះអាណានិគមចក្រភពអង់គ្លេស ធ្វើច្បាប់មិនស្របនឹងច្បាប់របស់ចក្រភព មានន័យថាអធម្មនុញ្ញភាពគឺមិនអាចយកទៅប្រើបានទេ ។ ក្រោយមកទៀតកើតមានធម្មនុញ្ញត្រួតពិនិត្យជាហូរហែរ[៩៣] ក្នុងសហរដ្ឋអាមេរិក នាឆ្នាំ ១៨០៣ ដែលក្នុងនោះក្រោមអធិបតីភាពលោក **ជ្យ ម៉ារសាល់** បានប្រកាសនៅតុលាការកំពូលថា **រដ្ឋធម្មនុញ្ញសហព័ន្ធ គឺជាច្បាប់កំពូលរបស់ប្រទេស ហើយច្បាប់នានារបស់រដ្ឋសភា** (Congress) **ដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញអាចទទួលស្គាល់ដោយតុលាការ អំពីអធម្មនុញ្ញភាពនៃច្បាប់ទាំងនោះ**[៩៤] ។ បន្ទាប់មកកើតមានប្រទេសមួយចំនួននៅអាមេរិកឡាទីន បានអនុវត្តតាមគំរូនេះ ដូចជាប្រេស៊ីល ឆ្នាំ ១៨៩១, ម៉ិកស៊ិក ១៩១៧.......) និងនៅមុនសង្គ្រាមលោកលើកទី I កើតមាននៅអឺរ៉ុប ដូចជា **ន័រវែស, ក្រិច, ស្វីស** ។

បន្ទាប់ពីសង្គ្រាមលោកលើកទី I នៅអឺរ៉ុបក៏កើតមានការកែច្នៃឱ្យកាន់តែប្រសើរឡើង នូវគំរូកម្មសិទ្ធិមួយអំពីធម្មនុញ្ញត្រួតពិនិត្យនេះ ទាំងអឺរ៉ុបខាងលិច និងខាងកើត ដែលសព្វថ្ងៃមានការទទួលយកគំរូទាំងនេះទៅអនុវត្តនៅក្នុងបណ្តាប្រទេសនានា នៃទ្វីបទាំង ៥ ។ គំនិតនៃគំរូអឺរ៉ុប លើវិស័យធម្មនុញ្ញត្រួតពិនិត្យនេះ ត្រូវបានបង្កើតឡើងដោយអ្នកប្រាជ្ញច្បាប់ពិភពលោកម្នាក់ ឈ្មោះ Hans Kelsen ដែលជាអ្នកច្បាប់ជនជាតិអូទ្រីស្តបានចូលរួមបង្កើតច្បាប់ធម្មនុញ្ញអូទ្រីស្ត ឆ្នាំ ១៩២០ បន្ទាប់ មកក្លាយជាសមាជិកតុលាការធម្មនុញ្ញនៃប្រទេសនេះ។

---

៩២. Constitutional Law of Foreign Country, Part II, M.1994, Page 322 ។

៩៣. Constitutional Law of foreign Country Part II M-1994 Page 322 ។

៩៤. នៅសហរដ្ឋអាមេរិក តុលាការកំពូលជាអ្នកពិនិត្យធម្មនុញ្ញភាព ។

ជាទូទៅ លក្ខណៈគ្រឹះសំខាន់១នៃការប្រើប្រាស់ទៅលើធម្មនុញ្ញត្រួតពិនិត្យនេះ មានមូលដ្ឋានទ្រឹស្ដីបីប្រភេទគឺ :[៩៥]

**ក១. ទ្រឹស្ដីការពារនៃធម្មនុញ្ញត្រួតពិនិត្យ** : វាកំណត់ថារដ្ឋធម្មនុញ្ញ គឺជាបទដ្ឋានកិច្ចនៃអំណាចនីតិបញ្ញត្តិ ដូចនេះរាល់បទដ្ឋានកិច្ចរបស់អង្គការនានា ដែលកំណត់ដោយរដ្ឋធម្មនុញ្ញវាមានអំណាច ហើយពុំត្រូវផ្ទុយនឹងបទដ្ឋានកិច្ចនៃអំណាចនីតិបញ្ញត្តិនេះទេ ។ **មាត្រា ១៥០** នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ត្រង់ចំណុចនេះស្រាប់ គឺចង់បញ្ជាក់ថារាល់លិខិតបទដ្ឋានរបស់អង្គការអំណាចរដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញ ។

**ក២. ទ្រឹស្ដីគ្រឹះនៃធម្មនុញ្ញភាពត្រួតពិនិត្យ** : លក្ខណៈនេះរដ្ឋធម្មនុញ្ញកំណត់នូវវិធានមួយសំរាប់អង្គការនានានៃអំណាចរដ្ឋ ត្រង់ថាគ្មានអង្គការណាមួយក្នុងចំណោមអង្គការទាំងនោះ ហ៊ានទន្ទ្រានយកសិទ្ធិអំណាចពីអង្គការមួយផ្សេងទៀតរបស់រដ្ឋបានទេ ។ ដូច**មាត្រា ១៣០** រដ្ឋធម្មនុញ្ញកម្ពុជាកំណត់ថា "គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ" ។

**ក៣. ទ្រឹស្ដីធម្មជាតិគតិយុត្តិ (ពិត) ឬទ្រឹស្ដីសន្ធិសញ្ញាសកល** : គឺថារដ្ឋធម្មនុញ្ញកំណត់នូវវិធានមួយសំរាប់អ្នកគ្រប់គ្រង និងសំរាប់អ្នកដែលត្រូវគេគ្រប់គ្រង ដូចជាកំណត់នូវការធានាសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ។ ហើយការត្រួតពិនិត្យធម្មនុញ្ញ ត្រូវតែតាមឃ្លាំមើលនូវការអនុវត្តទាំងឡាយចំពោះវិធានទាំងនោះ ។

ទ្រឹស្ដីទាំងបីនេះបំពេញគ្នាទៅវិញទៅមក ។ ដោយផ្អែកលើសមត្ថកិច្ចនៃធម្មនុញ្ញត្រួតពិនិត្យជាទូទៅមានទំរង់ពីរប្រភេទគឺ : **ទំរង់តុលាការធម្មនុញ្ញ ឬក្រុមប្រឹក្សាធម្មនុញ្ញ** គឺជាទំរង់ដែលប្រទេសនោះបានបង្កើតតុលាការមួយ ឬអង្គការមួយ សំរាប់តែត្រួតពិនិត្យទៅលើធម្មនុញ្ញភាពតែប៉ុណ្ណោះ (Italy, Germany, Spain...) ។ ប្រភេទទីពីរ គឺជារបៀបត្រួតពិនិត្យដែលផ្ទុកផ្ដាក់ទៅ

---

[៩៥]. La Documentation française. Document d'etudes. N° 1-15. Paris 1987. Page 3
. ដូច 93. Page 322.

"យុត្តាធិការទូទៅ" គឺមានន័យថា បញ្ហាដែលកើតមានទាក់ទិននឹងធម្មនុញ្ញ ត្រូវតុលាការធម្មតាជាអ្នកវិនិច្ឆ័យ ( ផ្ដុកផ្ដាក់ទៅតុលាការកំពូល) ។

ដូចនេះធម្មនុញ្ញត្រួតពិនិត្យ វាជាដំណើរការនៃនីតិវិធីរបស់ធម្មនុញ្ញយុត្តិធម៌ គឺមានន័យថា ការប្រព្រឹត្តិទៅនៃធម្មនុញ្ញត្រួតពិនិត្យដោយមានលក្ខណៈសុក្រិត្យនោះ គេឱ្យឈ្មោះថាធម្មនុញ្ញយុត្តិធម៌ ។ សំរាប់ប្រទេសអ៊ីស្លាម ដូចជាអ៊ីរ៉ង់ ច្បាប់ ឬបទដ្ឋានកិច្ចនានា មិនត្រឹមតែត្រួតពិនិត្យឱ្យស្របទៅនឹងរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ថែមទាំងពិនិត្យឱ្យស្របទៅនឹងគម្ពីរកូរ៉ានទៀតផង ។

**៩. កម្មវត្ថុនៃធម្មនុញ្ញត្រួតពិនិត្យ** : នេះគឺជាទីតាំងមួយដែលរដ្ឋធម្មនុញ្ញកំណត់នូវបទដ្ឋានកិច្ចនានានៃអំណាចរដ្ឋឱ្យមានឋានានុក្រមច្បាស់លាស់ ដូចជាច្បាប់ធម្មនុញ្ញ និងច្បាប់គំរិត មានកំលាំងគតិយុត្តិខ្ពស់ជាងច្បាប់ធម្មតា ។ ដូចនេះការត្រួតពិនិត្យនៃច្បាប់ធម្មតាទៅលើភាពស្របគ្នាទាំងឡាយត្រូវផ្ដុកផ្ដាក់ទៅធម្មនុញ្ញត្រួតពិនិត្យ **ប៉ុន្តែច្បាប់ដែលអនុម័តតាមវិធីធ្វើប្រជាមតិ ពុំផ្ដល់លទ្ធភាពឱ្យត្រួតពិនិត្យតាមលក្ខណៈធម្មនុញ្ញភាពទេ ព្រោះជាអធិបតេយ្យភាពរបស់ប្រជាជន** ។ តែបើមានការផ្លាស់ប្ដូរ ឬអនុម័តនៃរដ្ឋធម្មនុញ្ញ តាមវិធីប្រជាមតិតំរូវឱ្យមានសំលេងភាគច្រើនដាច់ខាត ប៉ុន្តែបើច្បាប់នានាដែលអនុម័តតាមរយៈប្រជាមតិ ពុំមានការគាំទ្រដោយមតិភាគច្រើនដាច់ខាត. គេអាចយកច្បាប់ទាំងនោះទៅធ្វើការត្រួតពិនិត្យនូវធម្មនុញ្ញភាពរបស់វាបានដែរ ។ ដោយសារទំនាក់ទំនងសង្គមមានភាពធំទូលាយពេក និងមានភាពសាំញ៉ាំ ធ្វើឱ្យការងារត្រួតពិនិត្យអំពីអធម្មនុញ្ញភាពនៃច្បាប់នានាមានការពិបាក ។ ទាក់ទិននឹងភាពស្មុគស្មាញនេះ ការត្រួតពិនិត្យទៅបានលុះត្រាតែមានការចែងច្បាស់លាស់នៅក្នុងច្បាប់គ្រឹះ សំរាប់ឱ្យស្ថាប័នមានសមត្ថកិច្ចធ្វើការបកស្រាយ ។ ជាទូទៅគេសង្កេតឃើញកម្មវត្ថុធំៗមួយចំនួន ដែលប្រទេសនីមួយៗផ្ដល់លទ្ធភាពឱ្យពិនិត្យនូវធម្មនុញ្ញភាពនៃសកម្មភាពរបស់ស្ថាប័នទាំងនោះ ដូចជា :

- ការត្រួតពិនិត្យនូវសកម្មភាពរបស់មន្ត្រីរដ្ឋជាន់ខ្ពស់ ។
- ការត្រួតពិនិត្យទៅលើបទដ្ឋានកិច្ច និងសកម្មភាពនានារបស់អង្គការរដ្ឋ ។
- ការត្រួតពិនិត្យទៅលើបទដ្ឋានកិច្ច និងសកម្មភាពនានារបស់អង្គការសង្គម ដូចជាបក្សនយោបាយជាដើម ។

ជារួមរដ្ឋធម្មនុញ្ញត្រួតពិនិត្យ មានគោលការណ៍ច្បាស់លាស់ក្នុងការធ្វើសកម្មភាព ជាពិសេសធ្វើសកម្មភាពទៅលើកិច្ចផ្ទៃក្នុងរដ្ឋ (ច្បាប់នានា) និងផ្ទៃក្រៅរដ្ឋ (កិច្ចព្រមព្រៀង) ជាដើម ។ នៅក្នុងការត្រួតពិនិត្យកិច្ចព្រមព្រៀងជាមួយនឹងរដ្ឋធម្មនុញ្ញពិតជាមានការពិបាកច្រើនណាស់ ព្រោះពេលខ្លះការព្រមព្រៀងនោះមិនស្របនឹងរដ្ឋធម្មនុញ្ញក៏មានដែរ ដូចជា : តំរូវឱ្យធ្វើការកែប្រែលើមាត្រានៃរដ្ឋធម្មនុញ្ញទៀតផងក៏មាន ពីព្រោះថាយកការព្រមព្រៀងជាអន្តររដ្ឋ ជាមូលដ្ឋានធំជាងច្បាប់គ្រឹះ ព្រោះតំរូវតាមនយោបាយរបស់រដ្ឋ ។

**ឆ. ប្រភេទនៃធម្មនុញ្ញត្រួតពិនិត្យ** : ដើម្បីកំណត់បាននូវលក្ខណៈត្រួតពិនិត្យទៅលើច្បាប់ ឬបទដ្ឋានកិច្ចគតិយុត្តិនានាឱ្យស្រប ឬក៏ថាមិនស្របនឹងរដ្ឋធម្មនុញ្ញ ជាទូទៅការត្រួតពិនិត្យត្រូវបានធ្វើឡើងតាមចំណាត់ថ្នាក់ជាច្រើនប្រភេទដូចខាងក្រោម :

**ឆ១. ធម្មនុញ្ញត្រួតពិនិត្យតាមកាល** : នេះជាការត្រួតពិនិត្យលើភាពជាធរមាននៃបទដ្ឋានកិច្ចគតិយុត្តិនានា ដែលការត្រួតពិនិត្យរបៀបនេះមានលក្ខណៈជាពីរប្រភេទគឺ :

**ឆ១.១. ការត្រួតពិនិត្យបឋម** : នេះជាការត្រួតពិនិត្យនូវរាល់បទដ្ឋានកិច្ចគតិយុត្តិនានា នៅមុនពេលចូលជាធរមាន (គឺថាពិនិត្យមុនពេលប្រកាសឱ្យប្រើ គឺបន្ទាប់ពីរដ្ឋសភាអនុម័ត ឬក៏ក្នុងចន្លោះពេលនៃថ្ងៃប្រកាស និងថ្ងៃចូលជាធរមាន) ។ ដូចជាមាត្រា ១៤០ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់ស្រាប់ ។

**ឆ១.២. ការត្រួតពិនិត្យបន្ទាប់** : នេះជាការត្រួតពិនិត្យទៅលើបទដ្ឋានកិច្ចនានា ដែលបានចូលជាធរមានរួចហើយ ។ ការត្រួតពិនិត្យនេះធ្វើឡើងតាមល័ក្ខខ័ណ្ឌច្បាស់លាស់ ដូចជាមានពាក្យបណ្តឹង ឬក៏ច្បាប់ ឬបទដ្ឋានកិច្ចនោះ វាប៉ះពាល់ដល់សង្គមសាធារណៈខ្លាំងពេកលើវិស័យយុត្តាធិការ ឬយុត្តិធម៌ ។ ដូចមានកំណត់ក្នុងមាត្រា ១៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានបញ្ជាក់ទៅលើខ្លឹមសារនៃចំណុចនេះ ។

** គ២. ធម្មនុញ្ញត្រួតពិនិត្យតាមសមត្ថកិច្ច** : នេះជាការត្រួតពិនិត្យរបស់អង្គការ ដែលមានសិទ្ធិបង្កើតបទដ្ឋានកិច្ចនានា ។ ជាឧទាហរណ៍រដ្ឋសភាមានសិទ្ធិអនុម័តច្បាប់, ប្រមុខរដ្ឋមានសិទ្ធិចេញក្រឹត្យ, ប្រមុខរដ្ឋាភិបាលមានសិទ្ធិចេញអនុក្រឹត្យ ឬសេចក្តីប្រកាស ។ល។ ការត្រួតពិនិត្យតាមលក្ខណៈនេះមានពីរប្រភេទដែរគឺ :

**គ២.១. ការត្រួតពិនិត្យផ្ទៃក្នុង** : នេះជាការត្រួតពិនិត្យដែលធ្វើឡើងដោយអង្គការសាមីជាអ្នកបង្កើតបទដ្ឋានកិច្ចនោះ គឺថាអង្គការណាបង្កើតបទដ្ឋានកិច្ច ត្រូវតែសមត្ថកិច្ចអង្គការនោះត្រួតពិនិត្យមើលនូវបទដ្ឋានកិច្ចដែលបង្កើតមកនោះស្របនឹងរដ្ឋធម្មនុញ្ញ ឬយ៉ាងណា ។

**គ២.២. ការត្រួតពិនិត្យផ្ទៃក្រៅ** : នេះជាការត្រួតពិនិត្យដែលធ្វើឡើងដោយអង្គការផ្សេងៗ ដែលពុំមែនជាអ្នកបង្កើតបទដ្ឋានកិច្ចនោះ ។ ការត្រួតពិនិត្យបៀបនេះគឺអង្គការដទៃទៀតមានសិទ្ធិពិនិត្យមើលអំពីបទដ្ឋានកិច្ចនានា ដែលចេញដោយស្ថាប័នមួយពុំស្របទៅនឹងរដ្ឋធម្មនុញ្ញ ហើយធ្វើការដាក់ជូនទៅអង្គការណាមួយមានសមត្ថកិច្ចពិនិត្យ ឬពិភាក្សា ។

ទស្សនៈតាមសមត្ថកិច្ច ឬទីតាំងនេះ វាជាទស្សនៈមួយនៃហេតុផលគតិយុត្តិ ដែលក្នុងនោះធម្មនុញ្ញត្រួតពិនិត្យអាចមានសណ្តាប់ធ្នាប់ពីរ **គឺការត្រួតពិនិត្យជាលក្ខណៈពិភាក្សា និងការត្រួតពិនិត្យជាលក្ខណៈសំរេច** ។ សេចក្តីសំរេចក្នុងសណ្តាប់ធ្នាប់ជាលក្ខណៈពិភាក្សា វាត្រូវប្រកាន់យក **កំលាំងសីលធម៌ តែពុំមែនកំលាំងច្បាប់ទេ** រីឯសេចក្តីសំរេចដែលធ្វើឡើងតាមសណ្តាប់ធ្នាប់នៃការត្រួតពិនិត្យជាលក្ខណៈសំរេច **ត្រូវតែមានកាតព្វកិច្ចអនុវត្តជាសកល**[៥៦] នោះមានករណីពីរគឺ: ប្រសិនបើសេចក្តីសំរេចមួយប្រកាសថាបទដ្ឋានកិច្ចមួយ (Act) នោះស្របនឹងរដ្ឋធម្មនុញ្ញ នោះការទាមទារផ្សេងៗទៀតចំពោះបទដ្ឋានកិច្ចនោះ មិនត្រូវទទួលយកបន្ថែមទៀតបានឡើយ ។ ផ្ទុយទៅវិញបើបទដ្ឋានកិច្ចមួយត្រូវបានប្រកាសថាអធម្មនុញ្ញភាព នោះវា (បទដ្ឋានកិច្ច) បាត់បង់នូវកំលាំង

---

[៥៦]. លក្ខណៈសំរេចក្នុងក្របខ័ណ្ឌកាតព្វកិច្ច ជាលក្ខណៈសាកលនេះ គឺសំដៅយកសេចក្តីសំរេចនោះក្រោយពីបានធ្វើរួចហើយ ត្រូវមានប្រសិទ្ធិភាពអនុវត្តទៅទូទាំងប្រទេស ដូចជាសេចក្តីសំរេចរបស់តុលាការធម្មនុញ្ញជាដើម ។

ច្បាប់ មានន័យថាច្បាប់នោះគ្មានអ្នកណាទំនាក់ទំនង និងក៏គ្មានកាតព្វកិច្ចជាមួយវាដែរ (គឺថាបទដ្ឋានកិច្ចនោះបង្កើតមកហើយតែគេពុំយកវាមកប្រើ) ។ ប៉ុន្តែធម្មនុញ្ញត្រួតពិនិត្យត្រូវតែធ្វើឡើងជាលក្ខណៈសំរេច ឬចេញសេចក្តីសំរេច ព្រោះវាជាលក្ខណៈកំលាំងគតិយុត្តិ ។

**ឥ៣. ធម្មនុញ្ញត្រួតពិនិត្យតាមកាតព្វកិច្ច** : នេះជាការត្រួតពិនិត្យដែលអាចធ្វើឡើងតាមពីរករណីគឺ : ការត្រួតពិនិត្យលក្ខណៈចាំបាច់ និងការត្រួតពិនិត្យលក្ខណៈជ្រើសរើស ។

**ឥ៣.១. លក្ខណៈត្រួតពិនិត្យចាំបាច់** : គឺថាបទដ្ឋានកិច្ចមួយដែលបានអនុម័តរួចហើយ ត្រូវតែស្ថិតក្រោមការត្រួតពិនិត្យជាចាំបាច់អំពីធម្មនុញ្ញភាព នៃបទដ្ឋានកិច្ចនោះជាដំបូងសិន (សំរាប់កម្ពុជាដូចជាច្បាប់រៀបចំអង្គការ. បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ជាដើម ត្រូវបានកំណត់ក្នុងវាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ រដ្ឋធម្មនុញ្ញ ។

**ឥ៣.២. ការត្រួតពិនិត្យលក្ខណៈជ្រើសរើស** : គឺជាការត្រួតពិនិត្យដែលធ្វើឡើងដោយការផ្តើមគំនិតនៃអ្នកមានសិទ្ធិអំណាច ឬក៏មន្ត្រីរដ្ឋដែលមានលក្ខណៈជាឯកជន ដែលពួកគេទាំងនោះកើតមានការសង្ស័យទៅលើបទដ្ឋានកិច្ចនោះ អំពីអធម្មនុញ្ញភាពនៃបទដ្ឋានកិច្ចណាមួយ ។ លក្ខណៈនេះត្រូវបានកំណត់ដោយមាត្រា ១៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ ។

**ឥ៤. ទ្រង់ទ្រាយនៃការត្រួតពិនិត្យ** : ជាទូទៅគេសង្កេតឃើញទ្រង់ទ្រាយនៃការត្រួតពិនិត្យអំពីធម្មនុញ្ញភាពនៃបទដ្ឋានកិច្ច ច្រើនធ្វើឡើងតាមរូបភាពអរូបី ឬជាលក្ខណៈសុក្រឹត្យ ។

**ឥ៤.១. ការត្រួតពិនិត្យជាលក្ខណៈអរូបី** : គឺជាសកម្មភាពមួយដែលមានន័យថាធ្វើការអង្កេត ឬធ្វើការផ្ទៀងផ្ទាត់ទៅលើធម្មនុញ្ញភាពនៃច្បាប់ណាមួយ ឬបទដ្ឋានកិច្ចណាមួយ ដោយមិនជាប់ពាក់ព័ន្ធទៅនឹងរឿងជាក់ស្តែងណាមួយពិតប្រាកដនោះឡើយ ។ ការត្រួតពិនិត្យរបៀបនេះ វាធ្វើសកម្មភាពដូចគ្នានឹង*ការត្រួតពិនិត្យដំបូង*ផងដែរ ដូចដែលបានពន្យល់ខាងលើរួចហើយ ។

**ឥ៤.២. ការត្រួតពិនិត្យជាលក្ខណៈសុក្រឹត្យ** : នេះជាសកម្មភាពមួយនៃការបំពេញកិច្ច ដែលធ្វើការអង្កេត ឬផ្ទៀងផ្ទាត់លើធម្មនុញ្ញភាពនៃច្បាប់ ឬបទដ្ឋានណាមួយបាន ដោយផ្សារភ្ជាប់ទៅនឹងរឿងដែលកើតមានពិតជាក់ស្តែងតែប៉ុណ្ណោះ ។ ការត្រួតពិនិត្យនេះ ដូចជាសេចក្តីសំរេចមួយរបស់

តុលាការដែលទាក់ទិននឹងរឿងណាមួយ ដែលត្រូវឱ្យអនុវត្តចំពោះសេចក្តីសំរេចនោះ ដែលធ្វើឡើងតាមច្បាប់ ឬបទដ្ឋានណាមួយដែលប្រឆាំងនឹងធម្មនុញ្ញភាព។ ដូច **មាត្រា ១៩** នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៨ បានកំណត់ថា "បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសំរេចរបស់ស្ថាប័ននានា ដែគេអះអាងថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន ....................." ។

ដូចនេះ ការត្រួតពិនិត្យតាមលក្ខណៈទ្រង់ទ្រាយទាំងពីរយើងឃើញថា ការត្រួតពិនិត្យជាលក្ខណៈអរូបី វាមានឥទ្ធិពលពិត១ជាងលក្ខណៈសុក្រឹត្យ ត្រង់នេះវាបង្ហាញឱ្យឃើញនូវទស្សនៈយ៉ាងទូលាយ ទៅលើបញ្ហាណាមួយដែលទាក់ទិនយ៉ាងប្រាកដនៃច្បាប់ ឬបទដ្ឋានដែលប្រឆាំងនឹងរដ្ឋធម្មនុញ្ញ ។ ជាពិសេសវាធានាបាននូវ **ឯកភាព** និងពុំមាន **ភាពបដិមតិ** នៃការត្រួតពិនិត្យនោះឡើយ។ ច្បាស់ជាងនេះទៅទៀត វាបានឆ្លើយតបទៅនឹងគំនិតនៃការបែងចែកអំណាចយ៉ាងពិតប្រាកដ ។ ដោយឡែកការត្រួតពិនិត្យជាលក្ខណៈសុក្រឹត្យ វាបានបង្កើតឱ្យមានលទ្ធភាពកាន់តែប្រសើរឡើងសំរាប់ប្រតិបត្តិការក្នុងការការពារសិទ្ធិមនុស្ស ក្នុងក្របខ័ណ្ឌដែលយើងអាចមើលឃើញប្រព័ន្ធការពារសិទ្ធិមនុស្ស នោះមាន **តិចតួច** ឬ **ច្រើនបាន** នៅក្នុងប្រទេស ឬរដ្ឋមួយ ។

**ខ៤. ទំហំនៃការត្រួតពិនិត្យ :** នេះជាការត្រួតពិនិត្យធម្មនុញ្ញភាពទៅលើបទដ្ឋានកិច្ចនានា តាមរូបភាពជាទូទៅ ឬក៏អន្លើ១ នៃទំនាក់ទំនងសង្គមដែលបានចារឹកដោយរដ្ឋធម្មនុញ្ញ ។

**ខ៤.១. ការត្រួតពិនិត្យជាលក្ខណៈទូទៅ :** វាគ្របដណ្តប់ទៅលើប្រព័ន្ធទាំងអស់នៃទំនាក់ទំនងសង្គម ដែលទំនាក់ទំនងទាំងនោះត្រូវបានធ្វើនិយ័តកម្ម ឬកំនត់ដោយរដ្ឋធម្មនុញ្ញ ។ អង្គការមានសមត្ថកិច្ចអាចពិនិត្យមើលទាំងមូលនូវបទដ្ឋានកិច្ចនានា ដែលធ្វើនិយ័តកម្មទៅលើទំនាក់ទំនងសង្គម ហើយដែលទំនាក់ទំនងសង្គមទាំងនោះបានចារឹកដោយរដ្ឋធម្មនុញ្ញ ដោយពុំចាំបាច់គិតពីវិស័យអ្វីមួយនោះទេ ។

**ច៥.២. ការត្រួតពិនិត្យជាលក្ខណៈអន្លើៗ** ៖ គឺវាធ្វើឡើងដោយមានការគិតទៅលើព្រំដែននៃកម្មវត្ថុពិតប្រាកដ ជាឧទាហរណ៍ដូចជាទំនាក់ទំនងសិទ្ធិមនុស្ស និងពលរដ្ឋ. ទំនាក់ទំនងសមាជិកនៃសហព័ន្ធជាដើម ។ សូមបញ្ជាក់ថាការត្រួតពិនិត្យ វាអាស្រ័យនឹងសមត្ថកិច្ចនៃអង្គការត្រួតពិនិត្យដែលមុខងាររបស់វាត្រូវបានកំណត់ដោយច្បាប់ច្បាស់លាស់ ។

**ច៦. ខ្លឹមសារនៃការត្រួតពិនិត្យ** ៖ អត្ថន័យនៃការត្រួតពិនិត្យអំពីធម្មនុញ្ញភាព អាចធ្វើឡើងមានលក្ខណៈជាទំរង់ ឬលក្ខណៈជាសម្ភារៈ។

**ច៦.១. ការត្រួតពិនិត្យជាទំរង់** ៖ គឺធ្វើឡើងដោយមានការត្រួតពិនិត្យទៅលើការប្រតិបត្តិនានា តាមលក្ខណៈទាំងឡាយដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញ និងការទាមទារនានា ដែលតំរូវឱ្យមានការទាក់ទិនចំពោះការបង្កើតបទដ្ឋានកិច្ចណាមួយនោះ ។ គឺថាតើការបង្កើតបទដ្ឋានកិច្ចនោះតំរូវដោយអង្គការណា ? តើអង្គការនោះធ្វើតាមនីតិវិធីត្រឹមត្រូវ ក្នុងទំរង់នៃការបង្កើតបបទដ្ឋានកិច្ចនោះដែរ ឬទេ ?។

**ច៦.២. ការត្រួតពិនិត្យជាលក្ខណៈសំភារៈ** ៖ គឺវាសំដៅពិនិត្យមើលទៅលើខ្លឹមសារនៃបទដ្ឋានកិច្ច ដែលត្រូវបញ្ជាក់ថាខ្លឹមសារនោះមានអត្ថន័យស្របនឹងរដ្ឋធម្មនុញ្ញ ឬយ៉ាងណា ?។ នៅក្នុងការត្រួតពិនិត្យរបៀបនេះ គឺអ្នកដែលមានសមត្ថកិច្ចត្រូវមានសមត្ថភាពគ្រប់គ្រាន់ ក្នុងវិស័យនីតិសាស្ត្រ ហើយមានគំនិតយល់ដឹងច្បាស់លាស់ អំពីវិទ្យាសាស្ត្រនៃនីតិសាស្ត្រនោះទៀតផង ។ ខ្លឹមសារនៃបទដ្ឋានកិច្ចមួយ ឬខ្លឹមសារនៃបទបញ្ញត្តិ ឬបទដ្ឋានមួយ ឬមាត្រាមួយនៃបទដ្ឋានកិច្ច (ច្បាប់) វាមានលក្ខណៈអធម្មនុញ្ញភាព លុះត្រាតែច្បាប់កំណត់យ៉ាងជាក់ច្បាស់ ទៅលើបុគ្គលដែលមានសមត្ថកិច្ចត្រួតពិនិត្យស្របនឹងចំណេះដឹងខ្ពស់ផង ដូចច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៨ បានកំណត់ខ្លឹមសារនៃបទបញ្ញត្តិណាមួយ នៃច្បាប់ដែលមានលក្ខណៈអធម្មនុញ្ញភាព តាម**មាត្រាទី ២០** ថា "បើក្រុមប្រឹក្សាធម្មនុញ្ញកំណត់ថាបទបញ្ញត្តិណាមួយនៃច្បាប់មិនស្របនឹងរដ្ឋធម្មនុញ្ញ ៖

ក- បើបទបញ្ញត្តិនោះមិនអាចបំបែកចេញពីអត្ថបទដែលនៅសល់បានទេ អត្ថបទច្បាប់ទាំងមូលមិនអាចយកទៅប្រកាសឱ្យប្រើ ឬយកទៅអនុវត្តបានឡើយ ។

ខ- បើបទបញ្ញត្តិអាចបំបែកចេញពីអត្ថបទដែលនៅសល់បាន នោះមានតែបទបញ្ញត្តិដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ដែលមិនអាចយកទៅប្រកាសឱ្យប្រើ ឬយកទៅអនុវត្តបាន" ។

**ឃ. កំលាំងគតិយុត្តិនៃសេចក្តីសំរេច អធម្មនុញ្ញភាព** : ការត្រួតពិនិត្យធម្មនុញ្ញភាពទៅលើបទដ្ឋានកិច្ច ឬស្ថាប័ននានារបស់រដ្ឋមួយ ពុំមែនមានលក្ខណៈដូចគ្នានោះទេ ។ ជាពិសេសវាអាចធ្វើឡើងបានគឺអាស្រ័យទៅនឹងសមត្ថកិច្ចរបស់អង្គការត្រួតពិនិត្យមានព្រំដែនច្បាស់លាស់ ហើយត្រូវបានកំណត់ដោយច្បាប់យ៉ាងសុក្រឹត្យ ។ ជាងនេះទៅទៀតវិធីសាស្ត្រ ឬបែបផែននៃការត្រួតពិនិត្យក៏មានលក្ខណៈច្រើនប្រភេទដែរ ដោយអាស្រ័យនឹងការវិវត្តន៍នៃជនជាតិរបស់រដ្ឋនីមួយៗក្នុងវិស័យនីតិសាស្ត្រ និងយុត្តិធម៌សង្គម ។ បើយើងពិនិត្យទៅលើការត្រួតពិនិត្យក្នុងប្រភេទនៃការចូលជាធរមានរបស់បទដ្ឋានកិច្ចមួយ ក្នុងក្របខ័ណ្ឌនៃកំលាំងប្រតិសកម្មនៃច្បាប់នោះ តាមសេចក្តីសំរេចរបស់អង្គការមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ ដែលរដ្ឋខ្លះបានប្រកាន់យកជំហរដោយឡែកៗទៀតផង ។ ត្រង់ចំណុចនេះចង់បញ្ជាក់ថា តើសេចក្តីសំរេចរបស់អង្គការត្រួតពិនិត្យនោះមានកំលាំងគតិយុត្តិយ៉ាងដូចម្តេច ដើម្បីមានឥទ្ធិពលទៅលើច្បាប់ ឬបទដ្ឋានណាមួយដែលបានពិនិត្យរួចហើយនោះ ។

ជាទូទៅ ការចូលជាធរមាននៃសេចក្តីសំរេចមួយ ដែលធ្វើឡើងដោយអង្គការមានសមត្ថកិច្ចក្នុងក្របខ័ណ្ឌនៃភាពត្រួតពិនិត្យធម្មនុញ្ញទៅលើបទដ្ឋានកិច្ចនានា វាតែងឈរនៅលើទំរង់ពីរប្រភេទ [៩៧] ក្នុងការកំណត់នូវកំលាំងគតិយុត្តិរបស់សេចក្តីសំរេចនោះ ។ ទំរង់ទាំងពីរនោះគឺ :

**ឃ១. ទំរង់** Ex tune : គឺជាទំរង់មួយប្រភេទដែលមានអត្ថន័យថា សេចក្តីសំរេចមួយស្តីអំពីការទទួលស្គាល់នូវអធម្មនុញ្ញភាព វាបញ្ជាក់ថាសេចក្តីសំរេចនោះមាន**កំលាំងគតិយុត្តិត្រលប់** ( ប្រតិសកម្ម) ចំពោះច្បាប់ ឬបទដ្ឋានទាំងឡាយណាដែលបានប្រកាសថាអធម្មនុញ្ញភាពរួចហើយ និងច្បាប់ ឬបទដ្ឋានទាំងនោះ ចាត់ទុកថា**គ្មានសកម្មភាពចាប់តាំងពីដើមដំបូងម្លេះ** ។ ការចាត់ទុកថាគ្មាន

[៩៧]. Constitutional Law of Foreign Country. Part II. Page 328. M.1994

សកម្មភាពពីដើមដំបូងនេះមានមូលដ្ឋានពីរគឺ : ចាប់ពីពេលបង្កើតបទដ្ឋាន ឬបង្កើតច្បាប់ទាំងនោះ ឬក៏ចាប់គិតពីថ្ងៃដែលបានចូលជាធរមាននៃច្បាប់ ឬបទដ្ឋានទាំងនោះហើយវាបានផ្ទុយទៅនឹងបទដ្ឋាននៃរដ្ឋធម្មនុញ្ញ ។ នៅក្នុងទំរង់នេះវាមានកើតបញ្ហានៅត្រង់ថា នៅមុនពេលមានសេចក្ដីសំរេចអំពីអធម្មនុញ្ញភាពនៃបទដ្ឋានកិច្ចមួយ វាបានកើតមានរួចទៅហើយនូវការខូចខាត ឬព្យសនកម្មផ្សេងៗ ដោយសារតែការអនុវត្តតាមបទដ្ឋានកិច្ចនោះ ។ ត្រង់ចំនុចនេះយើងអាចមានចំងល់ថា បើសេចក្ដីសំរេចមានលក្ខណៈត្រឡប់ថយក្រោយយ៉ាងដូច្នេះ តើត្រូវមានការទូទាត់ជូនដល់ការខូចខាតនោះ ឬទេ ?។ ទាំងនេះគឺជាបញ្ហាដ៏ស្មុគស្មាញដែលរដ្ឋនីមួយៗ ត្រូវតែយកចិត្តទុកដាក់ និងកំណត់អំពីទំរង់នៃកំលាំងគតិយុត្តិរបស់សេចក្ដីសំរេចអំពីអធម្មនុញ្ញភាព ។

**ឃ₂.ទំរង់** Ex Nune : គឺជាទំរង់ប្រភេទទីពីរ នៃកំលាំងគតិយុត្តិរបស់សេចក្ដីសំរេចមួយអំពីអធម្មនុញ្ញភាពទៅលើបទដ្ឋានកិច្ច ឬច្បាប់ណាមួយដោយសេចក្ដីសំរេចនោះមានកំលាំងគតិយុត្តិ និងធ្វើសកម្មភាពបានតែក្នុង**ពេលវេលាខាងមុខ** ( ថ្ងៃមុខ) តែប៉ុណ្ណោះ ។ ចំណែកហេតុផលគតិយុត្តិដែលបានធ្វើសកម្មភាពកន្លងមក ដោយមានលក្ខណៈអធម្មនុញ្ញភាពនៃបទដ្ឋានកិច្ច ឬច្បាប់ទាំងនោះទុកឱ្យវានៅមាន**ធរមានដដែល** ។ ជាការពិតណាស់ ដូចជា**មាត្រា ១៤៥** វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញរ៉ូម៉ានី ឆ្នាំ ១៩៩១ បានកំណត់ថា "សេចក្ដីសំរេចទាំងឡាយរបស់តុលាការធម្មនុញ្ញ ជាសេចក្ដីសំរេចចាំបាច់បំផុត ហើយមាន**កំលាំងគតិយុត្តិ**បានសំរាប់តែក្នុងពេលអនាគតខាងមុខតែប៉ុណ្ណោះ" ។ ត្រង់នេះបញ្ជាក់ថា សេចក្ដីសំរេចរបស់តុលាការធម្មនុញ្ញ អំពីអធម្មនុញ្ញភាពនៃច្បាប់ណាមួយមានប្រសិទ្ធភាពចាប់ពីថ្ងៃដែលចេញសេចក្ដីសំរេចនោះតែប៉ុណ្ណោះ គឺមានន័យថា "**ច្បាប់ ឬបទដ្ឋានកិច្ចដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញនោះ មិនអាចយកទៅប្រើប្រាស់បានទេ បន្ទាប់ពីតុលាការធម្មនុញ្ញបានប្រកាសរួចមក**" ។

**៦. អង្គការនានាដែលមានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាព** : ដោយយោងទៅលើសេចក្ដីសំរេចនានាដែលទាក់ទិននឹងរដ្ឋធម្មនុញ្ញ ( ធម្មនុញ្ញភាព) គេសង្កេតឃើញមានអង្គការជាច្រើន ដែលមានការពាក់ព័ន្ធនឹងសមត្ថកិច្ចក្នុងព្រំដែនរបស់ខ្លួន។ នៅក្នុងន័យនេះគឺចង់បញ្ជាក់ថា អង្គការនានាមួយចំនួនធំរបស់រដ្ឋមានសិទ្ធិពិនិត្យទៅលើធម្មនុញ្ញភាព ដែលមានដូចជា :

• **ក្រុមទីមួយ :**

- **ក្រុមអង្គការរដ្ឋទូទៅ** : នេះជាក្រុមអង្គការរដ្ឋ ដែលច្បាប់បានអនុញ្ញាតិឱ្យមានសិទ្ធិក្នុងការត្រួតមើលធម្មនុញ្ញដូចជា : ប្រមុខរដ្ឋនានា, រដ្ឋសភា, រដ្ឋាភិបាល, តុលាការនៃយុត្តាធិការទូទៅ, តុលាការរដ្ឋបាល ដែលមានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញ ឬក៏មានមុខងារជំនាញដទៃទៀត ។ល។

• **ក្រុមទីពីរ :**

- **ក្រុមអង្គការរដ្ឋដែលកំណត់ពិសេស ឬអង្គការជំនាញ** : នេះជាក្រុមអង្គការរដ្ឋដែលមានសមត្ថភាពពិសេស សំរាប់ដោះស្រាយតែរឿងទំនាស់ធម្មនុញ្ញភាពតែប៉ុណ្ណោះ ។ អង្គការរបៀបនេះមានដូចជាតុលាការធម្មនុញ្ញ ច្រើនបង្កើតនៅបណ្តាប្រទេសអឺរ៉ុប ឬអង្គការប្រហាក់ប្រហែលតុលាការ (Quasi-Judicial) មានដូចជាក្រុមប្រឹក្សាធម្មនុញ្ញនៅប្រទេសបារាំង និងបណ្តាប្រទេសដទៃទៀតដែលយកតាមគំរូបារាំង ដូចជាកម្ពុជាជាដើម ។

**៦. ការត្រួតពិនិត្យធម្មនុញ្ញភាពបែបនយោបាយ** : នៅក្នុងសមត្ថកិច្ចត្រួតពិនិត្យរបស់ក្រុមទីមួយដែលបានបញ្ជាក់ខាងលើនេះ គឺជាការបំពេញកិច្ចទាំងឡាយរបស់ស្ថាប័នមួយចំនួន ដូចជាប្រធានាធិបតី, រដ្ឋាភិបាល ឬក៏អង្គការដទៃទៀតដែលបានបញ្ជាក់ខាងលើនោះ វាត្រួតពិនិត្យធម្មនុញ្ញភាពក្នុងនាម ឬ**បំរើឱ្យផលប្រយោជន៍នយោបាយរបស់អង្គការទាំងនោះតែប៉ុណ្ណោះ** ។ ពីព្រោះថាអង្គការទាំងនោះជ្រើសរើសមកតាមពេលកំណត់ជាក់លាក់មួយ ដូចជាការបោះឆ្នោតតាមលំដាប់លំដោយ ឬក៏ជាវិសាមញ្ញ ដែលទង្វើទាំងនេះអាចធ្វើឱ្យមានការផ្លាស់ប្តូរនូវសមាសភាពនយោបាយទាំងមូល ហើយនាំឆ្ពោះទៅរកការប្រែប្រួលក្នុងការដឹកនាំនយោបាយរបស់ពួកគេ (អង្គការទាំងនោះ) ។ត្រង់ចំនុចនេះហើយ បានជាអង្គការទាំងនោះត្រូវបានបំពេញកិច្ចក្នុងការត្រួតពិនិត្យអំពីនយោបាយធម្មនុញ្ញ **ដើម្បីគំរូវតាមបញ្ហានយោបាយបច្ចុប្បន្នភាព** ជៀសវាងអស្ថេរភាពក្នុងសង្គម ។ នៅក្នុងក្រុមនេះដូចជាប្រធានាធិបតី, ឬនាយករដ្ឋមន្ត្រី ។ល។ ពួកគាត់សុទ្ធសឹងជាអ្នកនយោបាយដូចនេះដើម្បីឱ្យច្បាប់ ឬបទដ្ឋានកិច្ចស្របនឹងរដ្ឋធម្មនុញ្ញ ឬក៏ចង់កែរដ្ឋធម្មនុញ្ញ ដើម្បីគំរូវទៅនឹងគោលនយោបាយរបស់ពួកគាត់ក្នុងពេលបោះឆ្នោតខាងមុខ ពួកគាត់ត្រូវតែមានការប្រមើលមើលនូវ

នយោបាយរបស់ខ្លួន ជាមួយនឹងច្បាប់នានាទាំងនោះ ។ ជាពិសេសពួកគេត្រូវតាមដាននូវសកម្មភាពនៃរដ្ឋធម្មនុញ្ញ ដើម្បីនយោបាយរបស់ខ្លួន ។

ដូចនេះការត្រួតពិនិត្យរដ្ឋធម្មនុញ្ញ ត្រូវបានធ្វើឡើងទៅលើលក្ខណៈនយោបាយ គេសង្កេតឃើញមានជានិច្ចកាល បានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រនៃរដ្ឋធម្មនុញ្ញប្រទេសបារាំង ដែលក្នុងនោះបានយកមូលដ្ឋានទ្រឹស្តីមួយស្ថិតក្រោមគំនិតដែលមានឈ្មោះថា "**អង្គជំនុំជំរះធម្មនុញ្ញ**" សំរាប់ធ្វើប្រតិបត្តិការទៅលើធម្មនុញ្ញភាពនៃច្បាប់នានា ដែលគំនិតនេះបញ្ចេញដោយបុព្វជិតវិទូ កាតូលិកបារាំង ដ៏ល្បីម្នាក់ឈ្មោះ Sieyès នៅឆ្នាំ ១៧៩៥[៩៨] ។ គំនិតរបស់លោកត្រូវបានធ្វើសមិទ្ធិដោយព្រឹទ្ធសភា បន្ទាប់ពីបានបញ្ញត្តិដោយរដ្ឋធម្មនុញ្ញនានា ក្នុងឆ្នាំ ១៧៩៩ និងឆ្នាំ ១៨៥២ ទោះបីជាតួនាទី និងមុខងាររបស់ព្រឹទ្ធសភា នៅពេលនោះពុំត្រូវទទួលបាននូវការប្រតិបត្តិយ៉ាងណាក៏ដោយ ។ នៅក្នុងសករាជថ្មីបំផុតនៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋបារាំង នាឆ្នាំ ១៩៤៦ ដែលនៅក្នុងនោះដឹកនាំដោយប្រធានាធិបតីបែបសាធារណរដ្ឋ ។ នៅក្នុងរដ្ឋធម្មនុញ្ញ បានបង្កើតឱ្យមានគណៈកម្មាធិការក្រុមប្រឹក្សាធម្មនុញ្ញមួយ ដែលក្នុងនោះមានសមាសភាពប្រធានសភាជាតិ (សភាជាន់ទាប) និងប្រធានក្រុមប្រឹក្សាសាធារណៈរដ្ឋ (សភាជាន់ខ្ពស់).សមាជិក ៧ នាក់ ដែលត្រូវបានតែងតាំងដោយសភាជាតិ (សភាជាន់ទាប) នៅក្នុងពេលនៃការបើកសម័យប្រជុំប្រចាំឆ្នាំដំបូង និងសមាជិក ៣ នាក់ទៀតត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសាធារណរដ្ឋ ក្នុងសម័យប្រជុំលើកដំបូងប្រចាំឆ្នាំដែរ មានន័យថាសមាជិកទាំង ១០ មកពីសភាទាំងពីរនេះ មិនមែនជាអ្នកបំរើការឱ្យសភាទាំងពីរនេះទេ ប៉ុន្តែពួកគេតំណាងឱ្យភាពសមាមាត្រនៃបក្សប្រភាគរបស់រដ្ឋសភាទាំងពីរនេះ ។ ចាប់តាំងពីបង្កើតគណៈកម្មាធិការនោះមក រហូតដល់កើតមាននូវសាធារណរដ្ឋទី ៤ (ឆ្នាំ ១៩៥៨) សកម្មភាពរបស់វាបានបញ្ចេញ**នូវសេចក្តីសំរេចរបស់ខ្លួនបានតែមួយគត់ប៉ុណ្ណោះ**[៩៩] ។ ត្រង់នេះបញ្ជាក់ថា បើទោះបីជា

[៩៨]. លោក Sieyès ជាវីរៈជនបដិវត្តន៍ល្បីល្បាញរបស់បារាំងដែលលោកកើតនៅឆ្នាំ ១៧៤៨ ហើយស្លាប់នៅឆ្នាំ ១៨៣៦ ។

[៩៩]. សេចក្តីសំរេចនេះទាក់ទិននឹងនយោបាយ រីឯខ្លឹមសារនៃសេចក្តីសំរេចនេះពុំដឹងមានខ្លឹមសារយ៉ាងដូចម្តេចនោះទេ ព្រោះឯកសារពុំបាននិយាយ ។
. មើល Constitional law of Foreign Country Part II. M.1994. Page 329 ។

គណៈកម្មាធិការមានសិទ្ធិត្រួតពិនិត្យ អំពីធម្មនុញ្ញភាពនៃច្បាប់នានាក៏ពិតមែន តែកិច្ចការរបស់វាពុំមានលក្ខណៈជាមមាញឹកនោះទេ ។ នៅក្នុងទំរង់ត្រួតពិនិត្យជាលក្ខណៈនយោបាយនេះ មានដូចជាប្រទេសស៊ុយអែត តាមច្បាប់ស្តីពីទំរង់គ្រប់គ្រង ឆ្នាំ ១៩៧៤ បានបង្ហាញថា ក្រុមប្រឹក្សានីតិបញ្ញត្តិបំពេញកិច្ចជាលក្ខណៈត្រួតពិនិត្យបែបពិគ្រោះយោបល់ ឯរដ្ឋាភិបាល និងរដ្ឋសភា (រីកស្តាគ) បំពេញភារកិច្ចត្រួតពិនិត្យជាលក្ខណៈសំរេច ឬចេញសេចក្តីសំរេច ត្រង់នេះបញ្ជាក់ថាសេចក្តីសំរេចរបៀបនេះមានលក្ខណៈនយោបាយ ។

ដូចនេះការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់នានា ដែលធ្វើឡើងដោយស្ថាប័ន ឬអ្នកនយោបាយនោះគេឱ្យឈ្មោះថា **ជាការត្រួតពិនិត្យបែបនយោបាយ** ។ ក្រុមនេះពុំមែនជាអ្នកសំរេចទេ ប៉ុន្តែជាអ្នកតាមដានគ្នាទៅវិញទៅមក នូវរាល់សកម្មភាពរបស់អង្គការរដ្ឋទាំងនោះ ដោយផ្ទៀងផ្ទាត់ទៅនឹងច្បាប់គ្រឹះ ជាឧទាហរណ៍រដ្ឋសភាមានសិទ្ធិអនុម័តច្បាប់នានា និងមានអាណត្តិ ៥ ឆ្នាំ ត្រង់នេះគឺមានការផ្លាស់ប្តូរអំណាចគ្រប់គ្រងក្នុងរយៈពេល ៥ ឆ្នាំម្តង ដោយមិនអាចបន្តបានឡើយ ។

នៅក្នុងក្របខ័ណ្ឌនៃមុខងាររបៀបនេះ ដូចជាមុខងារប្រធានាធិបតី.រដ្ឋសភា. រដ្ឋាភិបាល. និងអង្គការរដ្ឋនានាទៀត ត្រូវបានបំពេញនាទីជាធម្មនុញ្ញត្រួតពិនិត្យ ទៅលើ**សកម្មភាពនយោបាយសាធារណៈ** (អំណាចរដ្ឋ) ។ អង្គការទាំងនេះ ត្រូវបានជ្រើសតាំងនៅលើរយៈពេលកំណត់មួយជាលក្ខណៈសាមញ្ញ ឬជាលក្ខណៈវិសាមញ្ញ ដែលការជ្រើសរើសនោះអាចផ្លាស់ប្តូរនូវសមាសភាពនយោបាយ (អ្នកមានអំណាចរដ្ឋ) ដែលនាំឆ្ពោះទៅរកការផ្លាស់ប្តូរនយោបាយពិតប្រាកដ ។ តាមខ្លឹមសារនៃការត្រួតពិនិត្យផ្នែកនយោបាយនេះ ដូចមាត្រា ១១៩ នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ បានកំណត់ថា "តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណៈបក្សដែលឈ្នះឆ្នោត ឱ្យបង្កើតរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះនាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណៈបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្គូរផ្គងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។.................." ។

**ង២. ការត្រួតពិនិត្យធម្មនុញ្ញភាពបែបតុលាការ** : ក្រុមនេះសមត្ថកិច្ចរបស់វាពុំផ្តល់លទ្ធភាពទៅឱ្យអង្គការរដ្ឋទូទៅទេ គឺ*សំរាប់តែស្ថាប័នជំនាញប៉ុណ្ណោះ*។ ការត្រួតពិនិត្យធម្មនុញ្ញភាពរបៀបនេះ គឺគេពិនិត្យលក្ខណៈយុត្តិធម៌នៃធម្មនុញ្ញ ដែលផ្តល់ទៅឱ្យស្ថាប័នតុលាការ (តុលាការធម្មនុញ្ញ) ឬអនុស្ថាប័នតុលាការ (ស្ថាប័នប្រហាក់ប្រហែលតុលាការ ដូចជាក្រុមប្រឹក្សាធម្មនុញ្ញជាដើម) ជាអ្នកសំរេចអំពីធម្មនុញ្ញភាពនៃបទដ្ឋានកិច្ចនានា ។

ជាទូទៅការត្រួតពិនិត្យរបស់អង្គការរដ្ឋជំនាញ ឬអង្គការតុលាការនេះប្រព្រឹត្តិទៅតាមប្រព័ន្ធពីរផ្សេងៗគ្នាគឺ : ប្រព័ន្ធអាមេរិកកាំង និងប្រព័ន្ធអឺរ៉ុប ។

**ង២.១. ប្រព័ន្ធអាមេរិកកាំង** (American System) : ប្រព័ន្ធនេះជាវិធីមួយដែលការត្រួតពិនិត្យអំពីធម្មនុញ្ញភាពទៅលើបទដ្ឋានកិច្ចគតិយុត្តិនានា ត្រូវបានធ្វើឡើងតាមរយៈចៅក្រមនៃ*តុលាការគ្រប់យុត្តាធិការ* ។ ប្រព័ន្ធនេះបានកើតមុនគេ តាមប្រវត្តិសាស្ត្រនៃការកកើតនូវដំណោះស្រាយក្នុងប្រព័ន្ធគតិយុត្តិ ។

- ការអនុវត្តន៍តាមប្រព័ន្ធនេះ ចៅក្រមទាំងឡាយនៃតុលាការគ្រប់យុត្តាធិការ មានសិទ្ធិត្រួតពិនិត្យមើលនូវធម្មនុញ្ញភាពនៃច្បាប់ទាំងឡាយ និងបទដ្ឋានកិច្ចនានានៅពេលដែលចៅក្រមទាំងនោះ**ធ្វើការពិចារណា** ទៅលើរឿងក្តីពិតប្រាកដនានា (មានន័យថាជាការត្រួតពិនិត្យជាបន្តបន្ទាប់តាមរឿងពិតជាក់ស្តែង) ។

- ប្រសិនបើតុលាការមួយទទួលស្គាល់ថា អធម្មនុញ្ញភាពនៃច្បាប់មួយ ហើយបន្ទាប់មករឿងនោះបានបញ្ជូនដល់តុលាការកំពូល ដែលតុលាការកំពូលនេះបានធ្វើសេចក្តីសំរេចចុងក្រោយមួយដែលទាក់ទិននឹងបញ្ហា ដែលតុលាការមួយបានទទួលស្គាល់ថាអធម្មនុញ្ញភាពនៃច្បាប់នោះ។ តុលាការកំពូលនេះ កាលបើទទួលស្គាល់ថា**ច្បាប់មួយមានធម្មនុញ្ញភាពរួចហើយ** នោះតុលាការដទៃទៀតត្រូវតែមានកាតព្វកិច្ចចាំបាច់ ដើម្បីទទួលស្គាល់ទៅលើសេចក្តីសំរេចនោះ។ ផ្ទុយទៅវិញបើច្បាប់មួយត្រូវបានទទួលស្គាល់ដោយតុលាការកំពូល ថា**អធម្មនុញ្ញភាព**នោះការធ្វើសកម្មភាពរបស់ច្បាប់នោះនៅតែបន្តតាមលក្ខណៈទំរង់ដដែល ប៉ុន្តែគ្មានតុលាការណាមួយយកច្បាប់នោះទៅអនុវត្តន៍នោះទេ ។ ច្បាប់ដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញនេះ វាបានបាត់**បង់នូវការការពារតាមផ្លូវតុលាការរួចទៅហើយ**

មានន័យថាកាលដែលច្បាប់នោះធ្វើសកម្មភាពជាទំរង់ណាមួយជាអត្ថិភាព (ជាវិជ្ជមាន) នោះវាបាន **បាត់បង់នូវកំលាំងគតិយុត្តិរួចស្រេចទៅហើយ** ។ នៅក្នុងល័ក្ខខ័ណ្ឌនេះរដ្ឋសភាត្រូវតែលប់ច្បាប់នោះជាបន្ទាន់ផងដែរ ។

នៅក្នុងប្រព័ន្ធនេះ ថ្វីត្បិតតែផ្ទុកផ្ដាក់ទៅឱ្យចៅក្រមនានានៃតុលាការគ្រប់យុត្តាធិការ មានសិទ្ធិត្រួតត្រាមើលនូវធម្មនុញ្ញភាពនៃច្បាប់ណាមួយក៏ពិតមែន ប៉ុន្តែវាពុំមែនជាភារកិច្ចត្រូវតែពិនិត្យគ្រប់ច្បាប់នោះទេ គឺវាអាស្រ័យទឹងរឿងក្ដីតែប៉ុណ្ណោះ ។ ការប្រកាន់យកប្រព័ន្ធរបៀបនេះគេសង្កេតឃើញមានភាពផ្សេងៗគ្នាផងដែរ ដូចជាប្រទេស**អាមេរិក**, **អាហ្សង់ទីន**, **ជប៉ុន**, **ន័រវែស** ធម្មនុញ្ញភាពនៃច្បាប់មួយតាមផ្លូវច្បាប់ **តុលាការណា**[១០០] ក៏មានសិទ្ធិត្រួតមើលដែរ ប៉ុន្តែសំរាប់ប្រទេសមួយចំនួនដូចជា**អូស្រ្តាលី**, **ឥណ្ឌា**, **ម៉ាល់តា** មានតែ**តុលាការកំពូល**ប៉ុណ្ណោះទេ ទើបមានសិទ្ធិត្រួតពិនិត្យអំពីធម្មនុញ្ញភាព ។

**ង២.២. ប្រព័ន្ធអឺរ៉ុប** (Europen System) : គឺជាប្រព័ន្ធមួយដែលបង្កើតឱ្យមាននូវស្ថាប័ន **ជំនាញតុលាការ** ឬក៏ស្ថាប័នដែលមានតួនាទីប្រហាក់ប្រហែលតុលាការ (Quasi-Judicial) ដើម្បីត្រួតពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ និងបទដ្ឋានកិច្ច ។ ស្ថាប័នដែលជាអង្គការទទួលភារកិច្ចក្នុងការត្រួតពិនិត្យនេះមានដូចជា : តុលាការធម្មនុញ្ញនៅប្រទេស**អ៊ីតាលី** និង**ប្រទេសប៉ូឡូញ** ហៅថា "**សាលាក្ដីធម្មនុញ្ញ**" (Constitutional Tribunal), "**ក្រុមប្រឹក្សារដ្ឋ ឬក្រុមប្រឹក្សាធម្មនុញ្ញ**" នៅប្រទេសបារាំង, "**តុលាការធម្មនុញ្ញជាន់ខ្ពស់**" នៅប្រទេសអេស្ប៉ាញ, "**តុលាការធម្មនុញ្ញសហព័ន្ធ**" នៅអាល្លឺម៉ង់ ។

ប្រព័ន្ធអឺរ៉ុបនេះ ក៏បានរីកសាយដល់ទ្វីបអាមេរិកឡាទីនផងដែរ ដូចជាតុលាការជំនាញធម្មនុញ្ញ ប្រទេសប្រេស៊ីលតាមរដ្ឋធម្មនុញ្ញ ១៩៨៨ ដែលឱ្យឈ្មោះថា "**សាលាក្ដីកំពូលសហព័ន្ធ**", រដ្ឋធម្មនុញ្ញនយោបាយប្រទេសកូឡុំប៊ី ១៩៩១ កំណត់ឈ្មោះតុលាការនេះថា "**តុលាការធម្មនុញ្ញ**" និងប្រទេសកូស្តារីកា បានហៅថា "**សភាធម្មនុញ្ញនៃតុលាការកំពូល**" ។

---

[១០០] . សំដៅយកតុលាការយុត្តាធិការទូទៅ និងមើល Constitutional law of Forcign Country Part II.M1994.Page 331

នៅក្នុងប្រទេសដែលជារដ្ឋសហព័ន្ធនានា ការបង្កើតតុលាការ ឬស្ថាប័នជំនាញផ្នែកត្រួតពិនិត្យធម្មនុញ្ញនេះ ក៏ត្រូវបានអនុញ្ញាតិឱ្យសមាជិកនៃរដ្ឋសហព័ន្ធមានសិទ្ធិបង្កើតផងដែរ ដូចជានៅ **សហព័ន្ធអាល្លឺម៉ង់** ជាដើម ។ រដ្ឋមួយដែលជាសមាជិករបស់សហព័ន្ធអាល្លឺម៉ង់ ឈ្មោះ **ហ្គិស្សិន** តាមរដ្ឋធម្មនុញ្ញរបស់ខ្លួន (ហ្គិស្សិន) ឆ្នាំ ១៩៤៦ បានកំណត់ថាការត្រួតពិនិត្យធម្មនុញ្ញ ត្រូវប្រគល់សមត្ថកិច្ចទៅឱ្យ "***សភាតុលាការរដ្ឋ***" រីឯរដ្ឋធម្មនុញ្ញ ១៩៥២ របស់រដ្ឋសេរីភាពសាក់ស្វ៍នី ដែលជាសមាជិករបស់សហព័ន្ធអាល្លឺម៉ង់ដែរនោះ បានកំណត់ថាការត្រួតពិនិត្យធម្មនុញ្ញ ត្រូវផ្ទុកផ្ដាក់សមត្ថកិច្ចទៅសភាតុលាការធម្មនុញ្ញ ។

សូមចំណាំផងដែរថា តុលាការធម្មនុញ្ញរបស់ប្រទេសសហព័ន្ធ និងតុលាការធម្មនុញ្ញរបស់រដ្ឋដែលជាសមាជិកសហព័ន្ធ មិនអាចបង្កើតមកស្ថិតក្នុង**ប្រព័ន្ធតែមួយបានទេ** ពីព្រោះថាតុលាការធម្មនុញ្ញសហព័ន្ធ និងតុលាការធម្មនុញ្ញរបស់រដ្ឋសមាជិកសហព័ន្ធ **ពុំមានកើតនូវទំនាក់ទំនងណាមួយដែលទាក់ទិននឹងលំដាប់ថ្នាក់នៃបណ្ដឹង** (ការធ្វើឧទ្ធរណ៍) បានទេ គឺវាត្រួតពិនិត្យតែក្នុងសមត្ថកិច្ចដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញរបស់ខ្លួនតែប៉ុណ្ណោះ អំពីបទដ្ឋានកិច្ចនានាទាំងនោះ ។

នៅក្នុងប្រទេសខ្លះទៀត ការបង្កើតអង្គការជំនាញក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនេះ ត្រូវបានប្រគល់ទៅអង្គការផ្សេងទៀត ដែលជាស្ថាប័នប្រហាក់ប្រហែលតុលាការដែរ ដូចជានៅប្រទេសបារាំងគេបង្កើតឱ្យមាន "**ក្រុមប្រឹក្សាធម្មនុញ្ញ**" ដែលមានតួនាទីត្រួតពិនិត្យធម្មភាពទៅលើច្បាប់នានា ។ ផ្ទុយទៅវិញ បើសិនជាការត្រួតពិនិត្យធម្មនុញ្ញភាពនៃបទដ្ឋានកិច្ចរបស់អំណាចនីតិប្រតិបត្តិ ត្រូវបានធ្វើឡើងដោយ**ក្រុមប្រឹក្សារដ្ឋ**ជំនួសវិញ ព្រោះថាក្រុមប្រឹក្សារដ្ឋទទួលបន្ទុក**ប្រព័ន្ធយុត្តិធម៌រដ្ឋបាល** ។ ចំពោះការយកវិធានរបៀបប្រទេសបារាំង ក្នុងការបង្កើតស្ថាប័នជំនាញប្រហាក់ប្រហែលតុលាការនេះ កើតមាននៅក្នុងប្រទេសមួយចំនួនដែលជាអតីតៈក្រោមអាណានិគមបារាំង ដូចជាប្រទេសកម្ពុជា ជាដើម ។ តាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានបង្កើតឱ្យមានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីត្រួតពិនិត្យនូវធម្មនុញ្ញភាពនៃច្បាប់ ដែលអនុម័តឡើងដោយសភាទាំងពីរ ប៉ុន្តែធម្មនុញ្ញភាពនៃបទដ្ឋានកិច្ច (ក្រឹត្យ. អនុក្រឹត្យ. និងសេចក្ដីសំរេចផ្សេងៗ..........) របស់រដ្ឋាភិបាលពុំដឹងថាស្ថាប័នណាជាអ្នកមើលនោះទេ (ពុំទាន់បង្កើតឱ្យមានស្ថាប័នត្រួតពិនិត្យនៅឡើយ) ។

ចំពោះការធ្វើឱ្យសំរេចផល ទៅលើ**ការទទួលខុសត្រូវ**របស់មន្ត្រីជាន់ខ្ពស់នានា របស់រដ្ឋនៅប្រទេសបារាំង បង្កើតនូវតុលាការពីរសំរាប់ដោះស្រាយទៅលើបញ្ហានោះគឺ "**តុលាការយុត្តិធម៌ជាន់ខ្ពស់**" និង "**តុលាការយុត្តិធម៌សាធារណរដ្ឋ**" រីឯនៅប្រទេស**ប៉ូឡូញ**វិញ ត្រូវដោះស្រាយដោយ "**សាលាក្តីរដ្ឋ**" ។ ការបង្កើតតុលាការពិសេសនេះ សំរាប់ដោះស្រាយទៅលើមន្ត្រីរដ្ឋជាន់ខ្ពស់ ព្រោះថាខ្លាចក្រែងតុលាការជាន់ក្រោមមិនហ៊ានដោះស្រាយ ដែលនេះជាវិធីមួយដ៏ល្អ ដើម្បីធ្វើឱ្យមន្ត្រីរដ្ឋជាន់ខ្ពស់ប្រយ័ត្នប្រយែងក្នុងភារកិច្ចរបស់ខ្លួន ។

ដោយឡែកនៅប្រទេសកាន់សាសនាអ៊ីស្លាមមួយចំនួន ក៏មានស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពដែរ ប៉ុន្តែវាមានលក្ខណៈផ្សេងៗពីគ្នា ។ ជាក់ស្តែងរដ្ឋធម្មនុញ្ញសាធារណរដ្ឋអ៊ីស្លាម នៃប្រទេស**អ៊ីរ៉ង់ ឆ្នាំ ១៩៧៩** បានបង្កើតអង្គការត្រួតពិនិត្យធម្មនុញ្ញភាពនេះ ដែលមានឈ្មោះថា "**ក្រុមប្រឹក្សាគាំពារ**" (Board of guardian) ។ យោងតាម**មាត្រា ៩៤** នៃរដ្ឋធម្មនុញ្ញនេះបានបញ្ជាក់ថា គ្រប់ច្បាប់ទាំងអស់ដែលអនុម័តដោយសភាពិគ្រោះអ៊ីស្លាម ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាគាំពារ ដែលក្រុមប្រឹក្សានេះត្រូវត្រួតពិនិត្យក្នុងរយៈពេល ១០ ថ្ងៃ ដើម្បីឱ្យច្បាប់នោះស្របនឹងគម្ពីរអ៊ីស្លាមនានា និងរដ្ឋធម្មនុញ្ញ ។ ក្នុងករណីដែលច្បាប់ទាំងនេះមិនស្របទៅនឹងគម្ពីរ និងរដ្ឋធម្មនុញ្ញនោះត្រូវតែបញ្ជូនត្រឡប់ឱ្យសភាធ្វើការពិចារណាម្តងទៀត រហូតដល់ច្បាប់នោះអាចចាត់ទុកថាធ្វើសកម្មភាពបាន ។ រយៈពេលនៃការត្រួតពិនិត្យ ក្រុមប្រឹក្សាគាំពារអាចសុំបន្តពេលបានថែមទៀត ប៉ុន្តែមិនអាចលើសពី ១០ ថ្ងៃទេ ។

**ខ. អង្គការគ្រប់គ្រងនៃតុលាការធម្មនុញ្ញ** : គោលការណ៍សំខាន់ៗនៃការគ្រប់គ្រងទៅលើស្ថាប័នតុលាការធម្មនុញ្ញ ជាធម្មតាស្ថាប័នទាំងនេះត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់យ៉ាងច្បាស់លាស់បំផុត ។ គេសង្កេតឃើញនូវវិធានមួយចំនួន ដែលទាក់ទិននឹងការគ្រប់គ្រងនៃតុលាការនេះ ដែលមានដូចជា :

**ខ្ញ. ការបង្កើតតុលាការធម្មនុញ្ញដោយរដ្ឋសភា** : ដោយប្រៀបធៀបទៅលើការបង្កើតនៃស្ថាប័ននេះ គេសង្កេតឃើញប្រទេសភាគច្រើនត្រូវបានបង្កើតតុលាការធម្មនុញ្ញ តាមរយៈស្ថាប័នរដ្ឋសភា មានន័យថារដ្ឋសភាជាអ្នកបង្កើតតុលាការធម្មនុញ្ញ។ ជាក់ស្តែងដូចជានៅអាល្លឺម៉ង់ សមាជិកទាំងអស់នៃតុលាការធម្មនុញ្ញសហព័ន្ធ ត្រូវបានបោះឆ្នោតដោយសភាជាន់ទាប និងសភាជាន់ខ្ពស់ ។ តាម**មាត្រា ៩៤** ចំនុចទី ១ នៃច្បាប់គ្រឹះ អាល្លឺម៉ង់[១០១] បានចែងថា "តុលាការធម្មនុញ្ញសហព័ន្ធកកើតឡើងពីសមាសភាពចៅក្រមសហព័ន្ធ និងចៅក្រមនៃរដ្ឋសមាជិកដទៃទៀត១"[១០២] ។ចំនួនពាក់កណ្តាលនៃសមាជិកតុលាការធម្មនុញ្ញ ត្រូវបានបោះឆ្នោតជ្រើសតាំងដោយសភាតំណាងរាស្ត្រ (Bundestag) និងពាក់កណ្តាលទៀតបោះឆ្នោតជ្រើសតាំងដោយសភាតំណាងរដ្ឋ (Bundesrat) ។សមាជិកទាំងអស់របស់តុលាការធម្មនុញ្ញ ពុំមែនជាសមាជិករបស់សភាតំណាងរាស្ត្រ, សភាតំណាងរដ្ឋ, រដ្ឋាភិបាលសហព័ន្ធ ឬក៏អង្គការនានារបស់សមាជិកសហព័ន្ធ[១០៣] ទេ ។

តាមបញ្ញត្តិនៃមាត្រានេះបានបង្ហាញថា វាបានបកស្រាយគ្រប់គ្រាន់ទៅហើយអំពីការបង្កើតតុលាការធម្មនុញ្ញ ។ ដោយយោងតាមច្បាប់ស្តីពីតុលាការធម្មនុញ្ញសហព័ន្ធ ឆ្នាំ ១៩៥១ ហើយបោះពុម្ព ឆ្នាំ ១៩៨៥ បានបញ្ជាក់នូវនីតិវិធីនៃការជ្រើសរើសយ៉ាងច្បាស់ថា : សភាតំណាងរាស្ត្រជ្រើសរើសចៅក្រមនៃតុលាការធម្មនុញ្ញ តាមរយៈ**បោះឆ្នោតដោយប្រយោល** គឺមានន័យថាបោះឆ្នោតតាមរយៈ**តំណាងរបស់សភាជាន់ទាបចំនួន ១២ នាក់** ដែលអ្នកតំណាងទាំង ១២ នាក់នេះត្រូវបានជ្រើសតាំងដោយសភាជាន់ទាប ដោយប្រើប្រាស់ប្រព័ន្ធតំណាងសមាមាត្រ ។ បេក្ខជនដែលក្លាយជាចៅក្រមនៃតុលាការធម្មនុញ្ញនៅក្នុងល័ក្ខខ័ណ្ឌនេះ លុះត្រាតែបេក្ខជនម្នាក់ៗត្រូវបានទទួលគាំទ្រដោយសំឡេងរបស់អ្នកតំណាងទាំង ១២ នាក់នោះ មិនតិចជាង ៨ សំលេង ។

---

[១០១]. Basic law for the Federal Republic of Germany. Published by the press and Information office of the Federal Goverment of Germany. Bonn. 1994

[១០២]. ចៅក្រម និងសមាជិកតុលាការធម្មនុញ្ញនៃរដ្ឋជាសមាជិកសហព័ន្ធ ។

[១០៣]. រដ្ឋាភិបាលនៃប្រទេសនានាដែលជាសមាជិកសហព័ន្ធ ។

ចំណែកចៅក្រមនៃតុលាការធម្មនុញ្ញ ដែលជ្រើសតាំងដោយសភាតំណាងរដ្ឋ (Bundesrat) គឺធ្វើឡើងដោយផ្ទាល់តាមរយៈសំលេងគាំទ្រ ⅔ នៃសមាជិកសភាតំណាងរដ្ឋ ។ បេក្ខភាពទាំងអស់ត្រូវស្នើឡើងដោយតុលាការធម្មនុញ្ញសហព័ន្ធ ។

ក្រៅពីប្រទេសអាល្លឺម៉ង់ក៏មានប្រទេសផ្សេងៗទៀតដែរ ដូចជាក្រូអាទី, ហុងគ្រី ប្រទេសទាំងនេះបង្កើតតុលាការធម្មនុញ្ញតាមរយៈរដ្ឋសភា ។

**ច₂. ការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញដោយអង្គការផ្សេងៗរបស់រដ្ឋ** : នៅក្នុងប្រទេសភាគច្រើនផ្សេងទៀត បានបង្កើតអង្គការដែលមានលក្ខណៈប្រហាក់ប្រហែលតុលាការដែរ ដូចជាក្រុមប្រឹក្សាធម្មនុញ្ញជាដើម ដោយស្ថាប័នទាំងនេះត្រូវបានបង្កើតឡើងដោយអង្គការជាន់ខ្ពស់របស់រដ្ឋ ដែលជាស្ថាប័នតំណាងនៃគ្រប់អំណាច (អំណាចនីតិបញ្ញត្តិ, នីតិប្រតិបត្តិ, តុលាការ) ។

ជាឧទាហរណ៍ការបង្កើតតាមប្រព័ន្ធនេះ ត្រូវបានធ្វើឡើងដោយប្រទេសបារាំង និងប្រទេសដែលធ្លាប់ស្ថិតក្រោមអាណានិគមរបស់បារាំង ដូចជាកម្ពុជាជាដើម ។

សមាសភាពនៃក្រុមប្រឹក្សាធម្មនុញ្ញប្រទេសបារាំង ស្របតាម**មាត្រា ៥៦** នៃរដ្ឋធម្មនុញ្ញបានបញ្ជាក់ថា : សមាជិកបីនាក់នៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានតែងតាំងដោយប្រធានាធិបតីសាធារណៈរដ្ឋ, បីនាក់ដោយប្រធានសភាតំណាងរាស្ត្រ និងបីនាក់ទៀតដោយប្រធានព្រឹទ្ធសភា (អតីតៈប្រធានាធិបតី តាមច្បាប់ក្លាយជាសមាសភាពនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែរ) ។ ចំពោះប្រទេសកម្ពុជា សមាជិកបីរូបនៃក្រុមប្រឹក្សាធម្មនុញ្ញ តែងតាំងដោយព្រះមហាក្សត្រ, បីរូបត្រូវជ្រើសតាំងដោយសភាតំណាងរាស្ត្រ ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ដូចនេះការបង្កើតតុលាការធម្មនុញ្ញមានភាពខុសគ្នា ទៅតាមប្រទេសដែលធ្លាប់មានទំនាក់ទំនងក្នុងប្រព័ន្ធគតិយុត្តិជាមួយប្រទេសនានា ។ ជាងនេះទៅទៀត**នីតិវិធីនៃការដឹកនាំ និងការអនុវត្ត**ទៅលើស្ថាប័នធម្មនុញ្ញនេះក៏មានបែបបទខុសៗគ្នាដែរ តាមប្រព័ន្ធយុត្តាធិការទូទៅរបស់ប្រទេសនីមួយៗ ។

**ខ. សវនាការធម្មនុញ្ញ ឬដំណើរការក្តីធម្មនុញ្ញ** : នេះគឺជាសណ្តាប់ធ្នាប់នៃការជំនុំជំរះ និងការធ្វើសេចក្តីសំរេចទៅលើកិច្ចការនានា នៅក្នុងតុលាការធម្មនុញ្ញ ។ គោលការណ៍ដោយឡែកៗទាំងឡាយក្នុងកិច្ចការដែលទាក់ទិននឹងសវនាការធម្មនុញ្ញនេះ ត្រូវបានគេជួបប្រទះនៅក្នុងរដ្ឋធម្មនុញ្ញមួយចំនួន ប៉ុន្តែជាគំរូទូទៅបែបបទនេះត្រូវបានកំណត់ដោយច្បាប់ទាំងឡាយ ស្តីអំពីតុលាការធម្មនុញ្ញ និងកាន់តែលំអិតនោះ នីតិវិធីនៃសវនាការធម្មនុញ្ញនេះត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់តុលាការធម្មនុញ្ញនោះទៀតផង ។ ដំណើរការក្តីធម្មនុញ្ញត្រូវបានកំណត់ទៅលើ**នីតិវិធីរួម** ដូចជា : សណ្តាប់ធ្នាប់នៃការចាត់ចែងរឿង, សកម្មភាព ឬដំណើរការសវនាការរបស់តុលាការ និងដំណើរការនៃកិច្ចការក្នុងការធ្វើសេចក្តីសំរេច ។ ចំពោះការកំនត់ទៅលើនីតិវិធីពិសេសៗ ឬនីតិវិធីជំនាញត្រូវមានគោលការណ៍ដូចជា : កំណត់ប្រភេទនៃរឿងដែលត្រូវដោះស្រាយជាដើម ។ ត្រង់នេះបញ្ជាក់ថាដំណើរការក្តីធម្មនុញ្ញពុំមែនប្រព្រឹត្តទៅគ្រប់តែរឿងនោះទេ គឺត្រូវកំណត់នូវប្រភេទនៃរឿងឱ្យបានច្បាស់លាស់ ថាតើរឿងណាមួយត្រូវបើកសវនាការធម្មនុញ្ញ ។ ចំពោះរឿងដែលត្រូវបានកំណត់ថាមិនចាំបាច់បើកសវនាការទេនោះ ចាំបាច់ត្រូវតែប្រកាន់យកគោលការណ៍មួយយ៉ាងជាក់លាក់ ស្ថិតក្នុងក្របខ័ណ្ឌនៃ**ទំរង់ផ្សេងគ្នា** ដូចជា : វិវាទកម្មមួយ[១០៤] ឬពាក្យសំដីណាមួយ ជានិច្ចកាលត្រូវបានកំណត់តាមក្រឹត្យក្រមមួយយ៉ាងជាក់លាក់ ហើយនៅពេលគេពិភាក្សាទៅលើ**ប្រភេទនៃរឿងទាំងនោះ** វាអាចពុំកើតមាននូវវិវាទកម្មនោះទេ ។

ដូចនេះរាល់បណ្តឹងដែលធ្វើឡើងចំពោះបញ្ហាអធម្មនុញ្ញភាព ជាដំបូងត្រូវពិនិត្យមើលប្រភេទនៃរឿងជាមុនសិន ជៀសវាងការបើកសវនាការពិភាក្សា ស្រាប់តែរឿងនោះវាស្ថិតក្នុងប្រភេទរឿងផ្សេងៗទៅវិញ ដូចជា : ព្រហ្មទណ្ឌ, រដ្ឋប្បវេណី, ឬរដ្ឋបាលជាដើម ដែលជាវិវាទកម្មផ្ទុយនឹងភារកិច្ចរបស់តុលាការធម្មនុញ្ញ ។

---

[១០៤]. វិវាទកម្មមួយតែងតែជារឿងពិត ពុំមែនយកសម្មតិកម្មមកបកស្រាយក្នុងការអនុវត្តន៍ច្បាប់នោះទេ ។

**ក.១. នីតិវិធីទូទៅ** : នីតិវិធីទូទៅ ឬនីតិវិធីរួមក្នុងការពិភាក្សាលើរឿងក្ដីធម្មនុញ្ញ ត្រូវរួមបញ្ចូលនូវសណ្ដាប់ធ្នាប់នៃការប្រាស្រ័យទាក់ទងនានា ទៅចំពោះតុលាការធម្មនុញ្ញ ដែលភារកិច្ចក្នុងការប្រាស្រ័យនោះត្រូវបានផ្ដល់ទៅឱ្យបុគ្គលនានាដែលមានសិទ្ធិ - អំណាច គ្រប់គ្រាន់ក្នុងកិច្ចការទាំងនោះចំពោះតុលាការ ។ វាក៏រួមបញ្ចូលផងដែរ នូវសណ្ដាប់ធ្នាប់នៃការពិចារណាដំបូង១នៃការប្រាស្រ័យនានា ដើម្បីធ្វើសេចក្ដីសំរេចទៅលើបញ្ហាណាមួយអំពីការទទួលយក ឬក៏បដិសេធន៍មិនទទួលយកចំពោះរឿងណាមួយនោះ ។ នីតិវិធីនេះ វាក៏បានបញ្ចូលនូវសមាសភាពនៃការប្រព្រឹត្តទៅក្នុងដំណើរការក្ដី ដូចជាសិទ្ធិនានារបស់ចៅក្រម. របស់អ្នកថ្លែង ព្រមទាំងសណ្ដាប់ធ្នាប់នៃតំរូវការចាំបាច់ក្នុងការផ្សព្វផ្សាយពតិមាន ។ លើសពីនេះទៅទៀតនីតិវិធីទូទៅ បានរាប់បញ្ចូលនូវការផ្ដល់ពតិមានទាំងឡាយតាមរយៈបុគ្គលផ្សេង១ ដូចជាកោះអញ្ជើញសាក្សីនានា និងអ្នកជំនាញការដើម្បីមកបំភ្លឺអំពីបញ្ហានានាដែលតុលាការចង់ដឹង ។ នីតិវិធីនេះបានកំណត់ទៅលើសណ្ដាប់ធ្នាប់នៃដំណើរការកាត់ក្ដី ដូចជាការពិភាក្សា និងការបោះឆ្នោតក្នុងការធ្វើសេចក្ដីសំរេចណាមួយ និងការបោះផ្សាយរបស់សេចក្ដីសំរេចនោះ ។ នីតិវិធីក៏បានកំណត់សណ្ដាប់ធ្នាប់ផងដែរ អំពីការធ្វើបន្តនៃដំណើរការក្ដីនៅក្នុងករណីចាំបាច់នានា ។ និងមានបញ្ញត្តិដទៃទៀតដែលត្រូវបានកំណត់អំពីស្ថានភាពតាមទីកន្លែង ឬប្រទេស ដូចជាការបង់ពន្ធរបស់តុលាការជាដើម ។

**ក.២. នីតិវិធីពិសេស** : នេះជានីតិវិធីដែលកំណត់ទៅលើរង្វង់នៃបុគ្គលនានា ដែលមានតួនាទីសិទ្ធិ-អំណាច ចូលមកបំភ្លឺតាមប្រភេទនៃរឿង ដែលបុគ្គលទាំងនោះពាក់ព័ន្ធនៅពេលមានបើកសវនាការធម្មនុញ្ញ ។ ជាពិសេសទៅទៀតក្នុងសវនាការដែលទាក់ទិនទៅនឹងហេតុផលគតិយុត្តិ នៃសេចក្ដីសំរេចផ្សេង១របស់តុលាការ និងបទបញ្ញត្តិនានានៃអំណាច នីតិប្រតិបត្តិជាដើម។ ក្នុងការកំណត់រឿងទាំងនោះមានច្រើនប្រភេទណាស់ ដូចជាទំនាស់រវាងតុលាការកំពូល និងតុលាការរដ្ឋបាល. ទំនាស់អង្គការរដ្ឋ. ទំនាស់ធម្មនុញ្ញភាព. និងការអនុម័តច្បាប់នានាជាដើម ។

សូមបញ្ជាក់ផងដែរថា តុលាការធម្មនុញ្ញប្រទេសខ្លះពុំមានសមត្ថកិច្ចពិនិត្យ ដោះស្រាយនូវរាល់ទំនាស់ដែលទាក់ទិនទៅនឹងអង្គការរដ្ឋទាំងឡាយនោះទេ ដូចជាក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសកម្ពុជា ជាដើម ពុំមានសិទ្ធិពិនិត្យមើលទំនាស់ដែលទាក់ទិននឹងបទដ្ឋានកិច្ចរបស់រដ្ឋាភិបាលទេ ។ ប៉ុន្តែបុគ្គលដែលពាក់ព័ន្ធរឿងក្តីយល់ឃើញថា សេចក្តីសំរេចរបស់ស្ថាប័នណាមួយប៉ះពាល់ដល់សិទ្ធិរបស់គេ បុគ្គលនោះអាចលើកបញ្ហាអំពីអធម្មនុញ្ញភាពនៃសេចក្តីសំរេចរបស់ស្ថាប័ននោះ ទៅតុលាការធម្មនុញ្ញបានតាមរយៈតុលាការសាមី ( ទទួលបន្ទុកចាត់ការរឿង) បន្ទាប់ពីតុលាការកំពូលយល់ព្រមតាមការលើកឡើងរបស់តុលាការថ្នាក់ទាបរួចមក ( មាត្រា ១៩ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ថ្ងៃទី ១៩ ខែមិនា ឆ្នាំ ១៩៩៨) ។

ដើម្បីជាមូលដ្ឋានក្នុងការយល់ដឹងទៅលើនីតិវិធីនៃការត្រួតពិនិត្យ អំពីធម្មនុញ្ញភាពនៃច្បាប់នានា ដែលជាមូលដ្ឋានសំខាន់បំផុតនៃប្រភេទរឿង ដែលត្រូវដោះស្រាយនៅតុលាការធម្មនុញ្ញ នោះយើងនឹងពិនិត្យនូវច្បាប់របស់ប្រទេសខ្លះ ដូចខាងក្រោមនេះ ។ តាមច្បាប់ស្តីពីតុលាការធម្មនុញ្ញសហព័ន្ធរបស់ប្រទេស**អូទ្រីស្ត** ក្នុងចំនុចទី ១ នៃ**មាត្រា ១៤០** បានកំណត់អំពីសិទ្ធិ-អំណាច ក្នុងការប្រាស្រ័យនៅតុលាការធម្មនុញ្ញ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ទាំងច្បាប់សហព័ន្ធ និងច្បាប់រដ្ឋសមាជិក មានដូចជាស្ថាប័ន :

- តុលាការរដ្ឋបាល,តុលាការកំពូល និងតុលាការដទៃទៀតដែលមានសិទ្ធិ-អំណាច ជំនុំជំរះក្តីក្នុងដំណាក់ទី ២ (Instance) និងរួមទាំងតុលាការធម្មនុញ្ញជាសាមីផងដែរ ប្រសិនបើច្បាប់តំរូវឱ្យតុលាការធម្មនុញ្ញនេះពិនិត្យលើទំនាស់គតិយុត្តិដែលអង្គការទាំងនេះបានធ្វើរួចហើយ ប៉ុន្តែវាពុំសូវកើតមានទេនូវករណីដែលផ្តួចផ្តើមឡើងដោយតុលាការធម្មនុញ្ញខ្លួនឯង ដើម្បីដោះស្រាយលើទំនាស់ដែលកើតមានលើខ្លួនឯងនោះ ព្រោះថាគ្មានអ្នកណា ឬស្ថាប័នណាមួយជាចៅក្រមនៅក្នុងរឿងរបស់ខ្លួនបានទេ ។

- រដ្ឋាភិបាលសហព័ន្ធ និងរដ្ឋាភិបាលនៃរដ្ឋជាសមាជិក

- ⅓ នៃសមាជិកសភាតំណាងរាស្ត្រសហព័ន្ធ ( ក្រុមប្រឹក្សាជាតិ) និង ⅓ នៃសមាជិកសភាតំណាងរាស្ត្ររបស់រដ្ឋសមាជិក

- បុគ្គលណាមួយបញ្ជាក់ថាមានអធម្មនុញ្ញភាពនៃច្បាប់មួយ ដែលកំពុងប៉ះពាល់សិទ្ធិរបស់បុគ្គលនៅក្នុងដំណើរការក្តីនៅតុលាការ ។ ត្រង់នេះបញ្ជាក់ថាបើបុគ្គលម្នាក់យល់ថាច្បាប់មួយដែលកំពុងធ្វើសកម្មភាព ហើយបានយកទៅប្រើប្រាស់នៅក្នុងរឿងរបស់បុគ្គល នោះនៅតុលាការដែលច្បាប់នោះមានលក្ខណៈអធម្មនុញ្ញភាព (ឬផ្ទុយនឹងធម្មនុញ្ញ) បុគ្គលនោះអាចប្តឹងទៅតុលាការធម្មនុញ្ញបាន ។

ដូចនេះតាមការបង្ហាញខាងលើនេះ គឺវាសំដៅទៅលើការត្រួតពិនិត្យនូវលក្ខណៈធម្មនុញ្ញភាពនៃច្បាប់តែប៉ុណ្ណោះ គឺពុំបាននិយាយអំពីបទដ្ឋានកិច្ចដែលមានតំលៃក្រោមច្បាប់នោះទេ ដូចជាក្រឹត្យ. អនុក្រឹត្យ ជាដើម ។ល។

ចំពោះប្រទេសកម្ពុជា ការប្រាស្រ័យទៅតុលាការធម្មនុញ្ញ (ក្រុមប្រឹក្សាធម្មនុញ្ញ) ក្នុងការត្រួតពិនិត្យនូវធម្មនុញ្ញភាពនៃច្បាប់ណាមួយត្រូវបានកំណត់តាម**មាត្រា ១៤១** នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ នោះថា "ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ. ប្រធានព្រឹទ្ធសភា. ប្រធានរដ្ឋសភា. នាយករដ្ឋមន្ត្រី. សមាជិកព្រឹទ្ធសភាចំនួន ¼ .តំណាងរាស្ត្រចំនួន ១/១០ ឬតុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ អំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា. ប្រធានព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌទីមួយនៃមាត្រានេះ" ។

តុលាការធម្មនុញ្ញក៏មាននីតិវិធីជាច្រើនទៀតដែរ ក្នុងការជំនុំជំរះទៅលើ**បណ្តឹងទាំងឡាយដែលជាលក្ខណៈឯកត្តបុគ្គល** អំពីការបំពានសិទ្ធិគោល ឬសិទ្ធិធម្មនុញ្ញដែលបានកំណត់រួចហើយនោះ ។ការប្រកាន់យកនីតិវិធីរបៀបនេះសំរាប់ប្រទេសជឿនលឿន ដូចជាសហព័ន្ធអាល្លឺម៉ង់ជាដើម ។

គោលដៅក្នុងនីតិវិធីនេះ គឺតុលាការធម្មនុញ្ញ ត្រូវធានាឱ្យបាននូវសិទ្ធិគោលរបស់ពលរដ្ឋចំពោះការបំពានទាំងឡាយណាពីរយៈ**អំណាចសាធារណៈ តាមរូបភាពនៃការបង្កើតបទដ្ឋានកិច្ច**ផ្សេងៗដែលស្ថាប័នទាំងនោះមាន ។ នៅប្រទេសអាល្លឺម៉ង់[១០៥] គ្រប់បុគ្គលអាចដាក់ពាក្យបណ្តឹង

[១០៥] . Constitutional Law of Foreign Country Part II. M.1994. Page 343

ធម្មនុញ្ញទៅតុលាការធម្មនុញ្ញសហព័ន្ធបាន ដោយបញ្ជាក់អំពីអ្វីៗដែលអំណាចសាធារណៈបានរំលោភបំពានទៅលើសិទ្ធិគោល ដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ពួកគេ ។ ប៉ុន្តែប្រសិនបើបញ្ហានោះវាទាក់ទិននឹងយុត្តាធិការ ឬដែនសមត្ថកិច្ច (Jurisdiction) នៃតុលាការធម្មតា នោះបណ្តឹងដែលបានធ្វើនៅតុលាការធម្មនុញ្ញសហព័ន្ធនោះ នឹងត្រូវបានចាត់ការបន្ទាប់ពីបណ្តឹងនោះត្រូវបានជំនុំជំរះ ដោយតុលាការយុត្តាធិការធម្មតា តាមលំដាប់ថ្នាក់បានចប់សព្វគ្រប់សិន ។ ប៉ុន្តែប្រសិនបើបណ្តឹងនោះមានអត្ថន័យធំធេង ឬក៏នៅពេលជំនុំជំរះទៅលើបណ្តឹងនោះ នៅតុលាការយុត្តាធិការគ្រប់លំដាប់ដែលអាចធ្វើឱ្យម្ចាស់បណ្តឹងទទួលនូវការខាតបង់យ៉ាងធ្ងន់ធ្ងរនោះ តុលាការធម្មនុញ្ញសហព័ន្ធអាចសំរេចដោះស្រាយបណ្តឹងនោះជាបន្ទាន់បំផុត ។

## ៤. អង្គការ និងស្ថាប័ននានាដែលជួយដល់អំណាចតុលាការ

ថ្វីត្បិតតែអំណាចតុលាការជាអំណាចឯករាជ្យសំរាប់វិនិច្ឆ័យទៅលើរឿងក្តីក៏ពិតមែន ប៉ុន្តែដើម្បីឱ្យការវិនិច្ឆ័យនោះមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីសំរេច វាក៏ត្រូវមានការជួយជ្រោមជ្រែងពីស្ថាប័ន ឬអង្គការនានាដទៃទៀត ដែលមានតួនាទីក្នុងក្របខ័ណ្ឌយុត្តិធម៌ផងដែរ ។ ប៉ុន្តែស្ថាប័នទាំងនោះពុំមែនជាមូលដ្ឋាននៃការធ្វើអន្តរាគមន៍មកលើអំណាចវិនិច្ឆ័យនេះទេ តែវាជាស្ថាប័ន ឬអង្គការដែលមាននាទីជួយបញ្ជាក់ឱ្យបានច្បាស់ទៅលើការអនុវត្តច្បាប់ ចំពោះអង្គហេតុ ឬក៏វិវាទកម្មណាមួយដែលបានកើតមានរួចមកហើយ ។ អង្គការ ឬស្ថាប័នទាំងនេះ ជាមូលដ្ឋានជំនួយអនុវត្តច្បាប់ តាមវិជ្ជាជីវៈឯករាជ្យរបស់គេដ៏មានប្រសិទ្ធិភាព ដែលធ្វើឱ្យអំណាចតុលាការកាន់តែមានភាពប្រសើរឡើង និងទទួលបាននូវការទុកចិត្តពីគ្រប់បុគ្គល ក្នុងគ្រប់ស្រទាប់នៃវណ្ណៈសង្គម ។ អង្គការ ឬស្ថាប័នទាំងនោះមានដូចជា :

**ក. អង្គការអយ្យការ** (Prosecution) : អង្គការនេះមុខងារទាំងឡាយរបស់វាជាធម្មតារួមមានការតាមដានកិច្ចការព្រហ្មទណ្ឌទៅលើគ្រប់បុគ្គល ដែលបានប្រព្រឹត្តិអំពើល្មើសនានា ដោយក្នុងនោះមានការធានានូវការចោទប្រកាន់ជាសាធារណៈ នៅចំពោះមុខតុលាការ ។ មុខងារដ៏សំខាន់មួយទៀត អង្គការនេះជានិច្ចកាលត្រូវមានការត្រួតត្រាមើលភាពស្របច្បាប់ នៃការអង្កេត

ជា**បឋមទៅលើបទល្មើសនានា** និងព្រមទាំងការឃុំខ្លួនទាំងឡាយនៅក្នុងទីកន្លែងនានា ដែលជាមូលដ្ឋានដកសិទ្ធិសេរីភាពរបស់បុគ្គលទាំងនោះ ។

បើទោះបីអង្គការនេះ ជាស្ថាប័នដែលមាននាទីដ៏ធំក្នុងការអនុវត្តន៍ច្បាប់ក៏ដោយចុះ ក៏នៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសជាច្រើនពុំបានកំណត់ ឬចែងយ៉ាងធំៗ និងច្បាស់លាស់អំពីការបង្កើត ឬកំណត់មុខងារទៅលើស្ថាប័ននោះដោយផ្ទាល់នោះទេ ។ ត្រង់នេះបញ្ជាក់ថា បើគេអានរដ្ឋធម្មនុញ្ញនៃប្រទេសមួយចំនួនចប់ គេពុំទាន់បានទឹកចាំថា តើស្ថាប័នអយ្យការរបស់ប្រទេសមួយនោះមានសិទ្ធិនិងអំណាចបែបណានោះទេ ទៅលើមុខងារលំអិតធំៗក្នុងនាមជាស្ថាប័នឯករាជ្យមួយដែរនោះ។ ប៉ុន្តែគេឱ្យដឹងបាននូវលក្ខន្តិកៈរបស់ស្ថាប័នអយ្យការ ដែលកំណត់នូវមុខងារច្បាស់លាស់នោះ តាមរយៈច្បាប់ដោយឡែកនានាទៅវិញ ។

**ខ. ការបង្កើតស្ថាប័នអយ្យការ** : ដោយយោងទៅលើមូលដ្ឋាននៃប្រវត្តិសាស្ត្រក្នុងការកកើតនៃសង្គមជាតិសាសន៍នេះ ទើបរដ្ឋនីមួយៗពុំបានបង្កើតឱ្យមានស្ថាប័នអយ្យការស្របគ្នានោះទេ ប៉ុន្តែមុខងាររបស់វាមានគោលដៅតែមួយដូចគ្នា ។ ផ្តើមចេញពីគោលដៅតែមួយនោះ ស្ថាប័នអយ្យការនៅក្នុង**ប្រព័ន្ធនៃអង្គការរដ្ឋ** ត្រូវបានបង្កើតឡើងទៅតាមក្រុមប្រទេសជាបួនក្រុមធំៗ ដែលមាននៅលើលោកយើងនេះសព្វថ្ងៃ គឺ[១០៦] :

**ខ₁. ក្រុមទីមួយ** : គឺជាក្រុមប្រទេសដែលបង្កើតស្ថាប័នអយ្យការ ឱ្យស្ថិតក្នុងសមាសភាពនៃក្រសួងយុត្តិធម៌ ។ នៅក្នុងក្រុមប្រទេសទាំងនេះក៏មានប្រភេទ និងលក្ខណៈផ្សេងៗពីគ្នាផងដែរ ទោះបីជាស្ថាប័នអយ្យការនៅក្នុងសមាសភាពក្រសួងយុត្តិធម៌ក៏ដោយ ដូចជានៅសហរដ្ឋអាមេរិក និងប្រទេសប៉ូឡូញ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើរតួជាអគ្គរដ្ឋអាជ្ញាតែម្តង ត្រង់នេះបញ្ជាក់**ថាក្រសួងយុត្តិធម៌ជាស្ថាប័នអយ្យការ** ក្នុងមុខងារនៃអំណាចរដ្ឋក្នុងការចោទប្រកាន់ ។ ដោយឡែកប្រទេសខ្លះទៀត ដូចជាជប៉ុន, បារាំងជាដើម ស្ថាប័នអយ្យការស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌

[១០៦]. Constitutional law of Foreign country Part II, M.1994 Page 345

**គឺមានន័យថាមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្សេង និងអគ្គរដ្ឋអាជ្ញាផ្សេងដែលរួមនៅក្នុងដំបូល ស្ថាប័នតែមួយ ប៉ុន្តែមានមុខងារខុសគ្នា ។**

បើយើងក្រឡេកមើលទៅលើប្រទេសអាមេរិក ដែលជារដ្ឋសហព័ន្ធនោះនឹងឃើញថា ប្រព័ន្ធអយ្យការនៅតាមរដ្ឋនីមួយៗ ដែលដឹកនាំដោយអគ្គរដ្ឋអាជ្ញានៃរដ្ឋនោះ មិនស្ថិតនៅក្រោមអយ្យការរបស់សហព័ន្ធឡើយ ។ ត្រង់នេះបញ្ជាក់ថា អយ្យការសហព័ន្ធដឹកនាំដោយអគ្គរដ្ឋអាជ្ញាដែលជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយមានរដ្ឋអាជ្ញាសហព័ន្ធមួយចំនួននៅពីក្រោមបន្តបន្ទាប់ ។ រីឯស្ថាប័នអយ្យការនៃរដ្ឋនីមួយៗដែលជាសមាជិកសហព័ន្ធវិញ ត្រូវបានដឹកនាំដោយអគ្គរដ្ឋអាជ្ញានៃរដ្ឋនោះ ដោយមានរដ្ឋអាជ្ញាមួយចំនួនរបស់រដ្ឋនៅក្រោមបន្តបន្ទាប់ ដោយមានភាពឯករាជ្យពីប្រព័ន្ធអយ្យការសហព័ន្ធ។

រដ្ឋអាជ្ញាទាំងអស់របស់សហព័ន្ធត្រូវបានតែងតាំងដោយប្រធានាធិបតី តាមការស្នើសុំពីអគ្គរដ្ឋអាជ្ញាសហព័ន្ធដោយមានការឯកភាព និងដំបូន្មានពីព្រឹទ្ធសភាសហព័ន្ធ ។ ចំពោះរដ្ឋអាជ្ញានៃរដ្ឋជាសមាជិកសហព័ន្ធ ត្រូវតែងតាំងដោយអភិបាលរដ្ឋសាមីរបស់គេ ។

ដោយឡែកនៅប្រទេសបារាំង យោងតាមច្បាប់ (Ordinance) លេខ ៥៨-១២៧០ ដែលបានកំណត់ទៅលើលក្ខន្តិកៈនៃអង្គចៅក្រម ឆ្នាំ ១៩៥៨ ដែលក្នុងនោះបានកំណត់ឱ្យរដ្ឋអាជ្ញាទាំងអស់ស្ថិតនៅក្រោម**ការដឹកនាំ** និង**ត្រួតពិនិត្យ**របស់អ្នកដឹកនាំជាន់ខ្ពស់បន្តបន្ទាប់ (មានន័យថាមានប្រធានគ្រប់គ្រងបន្តបន្ទាប់ តាមការិតរបស់គេដែលស្ថិតក្នុងប្រព័ន្ធនៃអយ្យការ) ហើយរដ្ឋអាជ្ញាទាំងនេះស្ថិតនៅ**ក្រោមក្រសួងយុត្តិធម៌** ។ នៅក្នុងច្បាប់នោះ ក៏ផ្តល់សិទ្ធិឱ្យរដ្ឋអាជ្ញាមានសិទ្ធិនិយាយដោយសេរីនៅក្នុងពេលសវនាការរបស់តុលាការ ។ នៅតុលាការសារទុក្ខ (Court of Cassation) ឬតុលាការជាន់ខ្ពស់ និងតុលាការឧទ្ធរណ៍ទាំងឡាយ ត្រូវមាន**អគ្គរដ្ឋអាជ្ញាមួយចំនួនជាអ្នកធ្វើ**សកម្មភាព (ដំណើរការ) រីឯនៅក្នុងពេលមានដំណើរការក្តីធំៗ ត្រូវមានរដ្ឋអាជ្ញាសាធារណរដ្ឋចូលរួមដំណើរការ ។ ចំពោះរដ្ឋអាជ្ញានៅប្រទេសជប៉ុនវិញ ពួកគេមានសិទ្ធិអំណាចដោយឥតល័ក្ខខ័ណ្ឌ (Discretion) ក្នុងវិស័យនៃបណ្តឹងអាជ្ញានៅតុលាការតាមផ្លូវច្បាប់ (អាចបញ្ចប់រឿងតាមឆន្ទានុសិទ្ធិរបស់ពួកគេបាន) ។ តាមច្បាប់ស្តីពីស្ថាប័នអយ្យការសាធារណៈ (The public prosecutors office law) របស់ជប៉ុន លេខ ៦១ ឆ្នាំ ១៩៤៧ ហើយមានការកែប្រែតាមច្បាប់លេខ ១៩៥ ឆ្នាំ ១៩៤៧

និងមានការកែប្រែរហូតដល់ឆ្នាំ ១៩៨៣ បានកំណត់នៅក្នុងមាត្រា ១ ចំនុចទីពីរថា ស្ថាប័នអយ្យការសាធារណៈមាន : អយ្យការកំពូល, អយ្យការជាន់ខ្ពស់, អយ្យការតំបន់ និងអយ្យការមូលដ្ឋាន ។ ដែលអយ្យការទាំងនេះត្រូវធ្វើសេវាកម្មជាមួយនឹងតុលាការកំពូល គឺអយ្យការកំពូល,តុលាការជាន់ខ្ពស់ គឺអយ្យការជាន់ខ្ពស់, តុលាការតំបន់ គឺអយ្យការតំបន់, តុលាការលហុ (Summary Courts) គឺអយ្យការមូលដ្ឋាន ។ រីឯអយ្យការតំបន់នឹងធ្វើសេវាកម្មក្នុងអំណាចរបស់ខ្លួន ជាមួយតុលាការគ្រួសារផងដែរ ។

រដ្ឋអាជ្ញានៅប្រទេសជប៉ុនមាន អគ្គរដ្ឋអាជ្ញា, អគ្គរដ្ឋអាជ្ញារង, រដ្ឋអាជ្ញាជាន់ខ្ពស់មួយចំនួន (Superintending Prosecutors) ព្រមទាំងរដ្ឋអាជ្ញា និងជំនួយការរដ្ឋអាជ្ញាជាច្រើនទៀត ។ ការតាំងនៅរបស់អយ្យការកំពូល និងការកំណត់ដទៃទៀត និងការតាំងនៅនានានៃអយ្យការដទៃទៀតនឹងត្រូវសំរេចតាមបទបញ្ញត្តិរបស់គណៈរដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចបង្កើតសាខាមួយចំនួននៃអយ្យការជាន់ខ្ពស់ ឬក៏អាចបង្កើតអយ្យការតំបន់មួយដែលជាសមត្ថកិច្ចរបស់ខ្លួន ដើម្បីបំរើការជាមួយសាខានានា នៃតុលាការជាន់ខ្ពស់នានា, តុលាការតំបន់មួយ ឬក៏តុលាការគ្រួសារមួយ បើយល់ឃើញថាការងារនោះវាចាំបាច់ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមមាត្រាទី ១៤ អាចត្រួតមើលការងាររបស់រដ្ឋអាជ្ញាទាំងអស់ដែលបានចែងនៅក្នុងច្បាប់ ដែលទាក់ទិននឹងមុខងាររបស់ពួកគេ ។ ចំពោះការឃ្លាំមើលបញ្ហាស៊ើបអង្កេត និងរឿងដែលទាក់ទងនឹងការសំរេចទៅលើកិច្ចការឯកត្តបុគ្គល (ការដកតំណែង) គាត់អាចត្រួតមើលបានតែទៅលើអគ្គរដ្ឋអាជ្ញាតែប៉ុណ្ណោះ ។ ចំពោះការតែងតាំង និងដកហូតទៅលើអគ្គរដ្ឋអាជ្ញា, អគ្គរដ្ឋអាជ្ញារង និងរដ្ឋអាជ្ញាជាន់ខ្ពស់ ត្រូវធ្វើឡើងដោយគណៈរដ្ឋមន្ត្រី ព្រមទាំងមានការបញ្ជាក់ពីអធិរាជផងដែរ។ រដ្ឋអាជ្ញាជាន់ខ្ពស់មួយចំនួន, រដ្ឋអាជ្ញាទាំងអស់ និងជំនួយការរដ្ឋអាជ្ញានានា នឹងត្រូវបានចុះហត្ថលេខាតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ចំពោះអគ្គរដ្ឋអាជ្ញា ដែលជាប្រធានអយ្យការកំពូល មានភារកិច្ចត្រួតមើលទាំងអស់នៃគ្រប់ស្ថាប័នអយ្យការ ។

ដូចនេះយើងឃើញថា ការងារអយ្យការនៅប្រទេសជប៉ុន មានលក្ខណៈឯករាជ្យពីក្រសួងយុត្តិធម៌ បើទោះបីជារដ្ឋអាជ្ញាទាំងឡាយ ត្រូវបានតែងតាំងឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏ពិតមែន **តែការងារបច្ចេកទេសរបស់ស្ថាប័នអយ្យការ ពុំត្រូវបានជ្រៀតជ្រែកដោយក្រសួងនោះទេ** ។ ត្រង់នេះបញ្ជាក់ថា ក្រសួងយុត្តិធម៌ជាអ្នកពិនិត្យមើលនូវការងាររដ្ឋបាលទូទៅរបស់ស្ថាប័នអយ្យការតែប៉ុណ្ណោះ ។

**ខ២.ក្រុមទីពីរ :** គឺជាក្រុមប្រទេសដែលស្ថាប័នអយ្យការ ស្ថិតក្នុងសមាសភាពនៃអង្គចៅក្រម (អង្គនៃមន្ត្រីតុលាការ មានទាំងចៅក្រម និងរដ្ឋអាជ្ញា) ហើយស្ថាប័នអយ្យការទាំងនេះស្ថិតនៅតាមតុលាការនានា ។ ក្រុមប្រទេសដែលប្រកាន់យកគោលការនេះមាន ដូចជាអេស្ប៉ាញ, អ៊ីតាលីជាដើម ។ យោងតាមច្បាប់ឆ្នាំ ១៩៨១ របស់អេស្ប៉ាញ កំណត់ទៅលើលក្ខន្តិកៈនៃស្ថាប័នអយ្យការ (Ministerio Fiscal) បានកំណត់ថា ស្ថាប័នអយ្យការធ្វើសកម្មភាពយុត្តិធម៌ក្នុងការការពារទៅលើភាពគតិយុត្តិ (ត្រឹមត្រូវតាមច្បាប់), ទៅលើសិទ្ធិពលរដ្ឋ និងទៅលើផលប្រយោជន៍សាធារណៈដែលត្រូវបានគាំពារដោយច្បាប់ តាមរយៈ**កំលាំងនៃមុខងាររបស់ខ្លួនផ្ទាល់ ឬក៏តាមរយៈបណ្តឹងរបស់បុគ្គលដែលមានពាក់ព័ន្ធនានា** (តាមការបណ្តឹងពីបុគ្គលសាធារណៈ) ។ ជាងនេះទៅទៀត ស្ថាប័នអយ្យការ តាមដាន **ឃ្លាំមើល នូវការអនុវត្តច្បាប់ដោយឯករាជ្យ**នៅពេលជំរះក្តី ដើម្បីឱ្យទទួលបានជោគជ័យក្នុងផលប្រយោជន៍សាធារណៈ ។ ដោយយោងទៅលើមុខងារស្វ័យយ័តរបស់អង្គការអយ្យការនេះ វាធ្វើសកម្មភាពស្របតាមគោលការឯកភាព និងគោលការណ៍ឯករាជ្យតាមខ្សែបណ្តោយរបស់ខ្លួន នៅក្នុងគ្រប់ករណីទាំងអស់នៃការអនុវត្តគតិយុត្តិ និងគ្មានការជ្រៀតជ្រែកពីបក្សនយោបាយនានា ។ អង្គការអយ្យការនេះធ្វើសកម្មភាពនៅតាមតុលាការនានា រហូតដល់ខេត្ត-ក្រុង ។ អង្គការអយ្យការត្រូវដឹកនាំដោយអគ្គរដ្ឋអាជ្ញារដ្ឋមួយរូប ដែលត្រូវបានតែងតាំងដោយព្រះរាជា តាមសំណើររបស់រដ្ឋាភិបាល បន្ទាប់ពីបានស្តាប់យោបល់របស់**អគ្គក្រុមប្រឹក្សា**នៃអំណាចតុលាការរួចមក ។

សូមបញ្ជាក់ថា "អគ្គក្រុមប្រឹក្សា នៃអំណាចតុលាការ" វាជាស្ថាប័នជាន់ខ្ពស់ដែលគ្រប់គ្រងទៅលើអំណាចតុលាការ ។ អង្គការនេះទទួលខុសត្រូវទៅលើការតែងតាំង, ការដាក់វិន័យទៅលើចៅក្រម និងរដ្ឋអាជ្ញា ព្រមទាំងគ្រប់គ្រងទៅលើមន្ត្រីបំរើការងារផ្សេងៗទៀត ដែលធ្វើសេវាកម្មក្នុងអំណាចតុលាការ ។ អង្គការនេះជាសេនាធិការមួយរបស់អំណាចតុលាការ ដែលមានសមាសភាពប្រធានតុលាការកំពូលជាប្រធាន និងមានសមាជិក ២០ នាក់ទៀត ដែលត្រូវបានតែងតាំងដោយព្រះរាជាមានអាណត្តិ ៥ ឆ្នាំ ។ នៅក្នុងចំណោមទាំងអស់នោះមានចំនួន ១២ នាក់ ត្រូវជ្រើសតាំងពីសមាសភាពនៃចៅក្រម និងរដ្ឋអាជ្ញានៃគ្រប់ប្រភេទស្ថិតក្នុងល័ក្ខខ័ណ្ឌនានា ដែលបានកំណត់ដោយច្បាប់រៀបចំអង្គការ (ច្បាប់ដែលបានកំណត់អំពីអំណាចតុលាការ ដូចមានចែងក្នុងមាត្រា ១២២ នៃរដ្ឋធម្មនុញ្ញអេស្ប៉ាញ ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៧៨) ។ ហើយមានចំនួន ៤ នាក់ទៀត តាមការស្នើសុំពីសភាតំណាងរាស្ត្រ និង ៤ នាក់ទៀត តាមការស្នើសុំពីព្រឹទ្ធសភា ដែលធ្វើឡើងតាមការបោះឆ្នោត យកសំលេង ៣/៥ នៃសភានីមួយៗ ។ អ្នកទាំង ៨ នាក់ នោះសុទ្ធតែជាមេធាវី និងជាអ្នកច្បាប់ដែលមានសមត្ថភាព ហើយបានបំរើការក្នុងវិជ្ជាជីវៈច្បាប់ ចាប់ពី ១៥ ឆ្នាំឡើងទៅ ។

ដូចនេះយើងឃើញថាប្រទេសអេស្ប៉ាញ អំណាចតុលាការត្រូវបានប្រគល់ទៅឱ្យស្ថាប័នមួយដាច់ដោយឡែកជាអ្នកគ្រប់គ្រង ទាំងចៅក្រម និងរដ្ឋអាជ្ញា ដោយមិនបានជ្រៀតជ្រែកទៅលើមុខងារវិជ្ជាជីវៈរបស់ចៅក្រម ឬរដ្ឋអាជ្ញាទេ ដោយមើលទៅលើរដ្ឋបាល និងការអនុវត្តច្បាប់របស់ចៅក្រម និងរដ្ឋអាជ្ញាតែប៉ុណ្ណោះ ។

**ខ៣.ក្រុមទីបី** : គឺជាក្រុមប្រទេសដែលបង្កើតអង្គការអយ្យការ នៅក្នុងប្រព័ន្ធដាច់ដោយឡែកមួយ ហើយមានការទទួលខុសត្រូវចំពោះរដ្ឋសភា ។ ក្រុមប្រទេសដែលប្រកាន់យកប្រព័ន្ធនេះច្រើនជាពួកប្រទេសសង្គមនិយម ។ អង្គការអយ្យការមានតួនាទីត្រួតពិនិត្យការអនុវត្តច្បាប់នានា ទៅគ្រប់ស្ថាប័ន ឬបុគ្គល ។ អគ្គរដ្ឋអាជ្ញាដែលជាអ្នកដឹកនាំស្ថាប័នអយ្យការ គ្រប់ជាន់ថ្នាក់តាមខ្សែរបណ្តោយរបស់ខ្លួន ត្រូវបានតែងតាំងដោយរដ្ឋសភាមានអាណត្តិដូចរដ្ឋសភាដែរ ឬក៏អាចមានរយៈពេលយូរជាង ។

អគ្គរដ្ឋអាជ្ញាពិនិត្យមើលការអនុវត្តច្បាប់ជាទូទៅ ហើយទទួលខុសត្រូវចំពោះមុខរដ្ឋសភា ។ អគ្គរដ្ឋអាជ្ញាតែងតាំងរដ្ឋអាជ្ញាដទៃទៀត ដែលនៅក្រោមបន្តបន្ទាប់ ។ ការតែងតាំង និងការដក តំណែងរដ្ឋអាជ្ញានានា ត្រូវធ្វើឡើងតាមសេចក្តីសំរេចរបស់បក្សកុំម្មុយនីស្ត តាមជាន់ថ្នាក់របស់គេ ។

ការប្រកាន់យកប្រព័ន្ធរបៀបនេះ គឺចង់ឱ្យស្ថាប័នអយ្យការ ជាពិសេសអគ្គរដ្ឋអាជ្ញាទទួលខុសត្រូវនូវការអនុវត្តច្បាប់នានាដែលរដ្ឋសភាបានអនុម័តរួច ។ អគ្គរដ្ឋអាជ្ញាឃ្លាំមើលនូវសកម្មភាពគតិយុត្តិនានា ក្នុងអំណាចឯករាជ្យរបស់ខ្លួននៃផលប្រយោជន៍សាធារណៈ ( ក្នុងនាមរដ្ឋ) ។

ដូចនេះប្រព័ន្ធអយ្យការក្នុងក្រុមទីបី វាជាស្ថាប័នត្រួតពិនិត្យ. តាមដានទៅលើភាពគតិយុត្តិនៅក្នុងទូទាំងប្រទេស ដោយមិនចំណុះស្ថាប័នណាមួយឡើយ តែទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខរដ្ឋសភា ។ ចំពោះស្ថាប័នដែលបង្កើតមកមាននៅតាមជាន់ថ្នាក់ ពីស្ថាប័នកណ្តាលរហូតដល់មូលដ្ឋាន ( ខេត្ត - ក្រុង ឬតំបន់) ។

**ខ៤. ក្រុមទីបួន :** គឺជាក្រុមប្រទេសដែលពុំមានបង្កើតអង្គការអយ្យការនោះទេ ដូចជាចក្រភពអង់គ្លេសជាដើម ។ ប្រព័ន្ធអយ្យការនៃចក្រភពអង់គ្លេស គេពុំបង្កើតទេ **ប៉ុន្តែគេឱ្យស្ថាប័នមេធាវីដើរតួជាដើមចោទវិញ** ។ អគ្គមេធាវី (General Attorney) ដើរតួជាអគ្គរដ្ឋអាជ្ញាដឹកនាំអង្គការមេធាវី ( គណៈមេធាវី)[១០៧] ។ មេធាវីទាំងនោះដើរតួជាដើមចោទ នៅពេលសំដែងក្នុងដំណើររឿងនៃការកាត់ក្តីនៅតុលាការ ។

សូមបញ្ជាក់ថា ប្រព័ន្ធតុលាការនៅចក្រភពអង់គ្លេសមានភាពស្មុគស្មាញជាខ្លាំង ទោះបីជាមានការកែទំរង់ជាច្រើនលើកក៏ដោយ ។ ប្រព័ន្ធអយ្យការមានតួនាទីសំខាន់ណាស់ក្នុងការចោទប្រកាន់ និងសាកសួរនៅពេលបើកសវនាការនៅឯតុលាការ ប៉ុន្តែភារកិច្ចនោះផ្ទុកផ្តាក់ឱ្យមេធាវី ដែលយើងច្រើនយល់ថាមេធាវីនៅប្រទេសអង់គ្លេស មានសិទ្ធិអំណាចច្រើននៅពេលបើកសវនាការ ។

[១០៧]. ការគ្រប់គ្រង និងការបង្កើតស្ថាប័ននេះយើងកំពុងស្រាវជ្រាវបន្ត ពីព្រោះប្រព័ន្ធតុលាការចក្រភពអង់គ្លេសមានភាពស្មុគស្មាញជាងប្រព័ន្ធក្នុងទីណាង់តាល់ ។

**គ. អង្គការវិជ្ជាជីវៈមេធាវី** : នេះគឺជាការប្រមូលផ្តុំមួយ ( អង្គភាព) ទៅលើអ្នកច្បាប់ដែលមានគុណសម្បត្តិខ្ពស់ៗក្នុងវិជ្ជាជីវៈរបស់ពួកគេ ដើម្បីជួយដល់រូបវន្តបុគ្គល និងនីតិបុគ្គលនានាតាមផ្លូវគតិយុត្តិ ឬផ្លូវច្បាប់ ។ នីតិបុគ្គលមានទាំងស្ថាប័នសាធារណៈមានអំណាច ឬគ្មានអំណាចផងដែរ ។ អង្គការវិជ្ជាជីវៈមេធាវីគឺជាវិទ្យាស្ថានសង្គមមួយ ដែលពេលខ្លះវាបានបែងចែកយ៉ាងច្បាស់លាស់ទៅលើសិទ្ធិអំណាចសាធារណៈ ។ អង្គការមេធាវី គឺជាអង្គការដែល**ប្រកបរបរវិជ្ជាជីវៈច្បាប់** ។ រដ្ឋធម្មនុញ្ញទាំងឡាយរបស់ប្រទេសមួយចំនួន កំរបានកំណត់នូវស្ថាប័ន ឬអង្គការមេធាវីនេះដោយផ្ទាល់ណាស់ ។ ព្រោះគេតែងកំណត់វាតាមច្បាប់ដោយឡែក ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៥ បានកំណត់តាម**មាត្រា** ទី ១ ថា "វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរី ដែលចូលរួមបំរើវិស័យយុត្តិធម៌ ។ វិជ្ជាជីវៈមេធាវីប្រព្រឹត្តិទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី" ។ ប៉ុន្តែប្រទេសខ្លះបានចែងដោយផ្ទាល់ នូវអត្ថន័យរួមនៃអង្គការមេធាវីនេះ នៅក្នុងរដ្ឋធម្មនុញ្ញតែម្តង ដូចជាវាក្យខ័ណ្ឌទីមួយនៃ**មាត្រា ១៣៤** រដ្ឋធម្មនុញ្ញ**ប៊ុលហ្គារី** បានចែងថា "វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈសេរី, ឯករាជ្យ, និងគ្រប់គ្រងដោយខ្លួនឯង ។ វិជ្ជាជីវៈនេះជួយដល់ពលរដ្ឋ និងនីតិបុគ្គល នៅពេលដែលមានការការពារសិទ្ធិ និងសណ្តាប់ធ្នាប់" រីឯវាក្យខ័ណ្ឌទី ២ នៃមាត្រានេះបានបញ្ជាក់ថា ការគ្រប់គ្រង និងសណ្តាប់ធ្នាប់នៃការងាររបស់វិជ្ជាជីវៈមេធាវីនេះត្រូវកំណត់ដោយច្បាប់ ។

ដូចនេះយើងអាចនិយាយបានថា បើទោះបីជារដ្ឋធម្មនុញ្ញនៃប្រទេសជាច្រើនពុំបានគិតដល់អង្គការមេធាវីនេះក៏ដោយ ក៏លក្ខន្តិកៈរបស់អង្គាករនេះត្រូវបានកំនត់ដោយច្បាប់មួយយ៉ាងជាក់លាក់ផងដែរ ។ ជាឧទាហរណ៍ សមាគមវិជ្ជាជីវៈមេធាវីពីរនៅចក្រភពអង់គ្លេស គឺ "Barristers"[១០៨] ដែលជាអង្គការមួយឯករាជ្យពីស្ថាប័នរដ្ឋទាំងការគ្រប់គ្រង និងសកម្មភាពរបស់វា ។ ត្រង់នេះបានន័យថា រដ្ឋពុំមានសិទ្ធិអន្តរាគមន៍ទៅលើស្ថាប័ននោះទេ ។ វាជាសាជីវកម្មដែលពុំអាចប៉ះពាល់បានដោយប្រមូលផ្តុំនូវ**មេធាវីដែលមានគុណសម្បត្តិខ្ពស់ៗជាច្រើន** ។ កិច្ចការរបស់មេធាវីនៅក្នុង

[១០៨]. Barristers : គឺជាក្រុមមេធាវីនៅចក្រភពអង់គ្លេស ប៉ុន្តែគេពុំមែនជាអ្នករៀបចំសំណុំរឿងពីដំបូងឡើយ សំរាប់ដាក់ទៅតុលាការនោះទេ ។

សមាគមន៍ ឬសាជីវកម្មនេះភ្ជាប់ជាមួយតែតុលាការជាន់ខ្ពស់នានាប៉ុណ្ណោះ ។ រីឯសាជីវកម្មមួយទៀតឈ្មោះថា "Solicitors"[១០៩] គឺជាសមាគម ឬសាជីវកម្មដែលប្រមូលផ្តុំនៅក្នុងសង្គមគតិយុត្តិ (សមាគមច្បាប់) ដែលលក្ខន្តិកៈរបស់វាត្រូវបានកំណត់ដោយច្បាប់ស្តីពី Solicitors ឆ្នាំ ១៩៧៤ ។

ដោយសារតែ Solicitors ជាជំនួយការឱ្យមេធាវី "Barristers" ដូចនេះ Solicitors ដើរតួជាអ្នកសំរុះសំរួល (Mediators) ដ៏ចាំបាច់បំផុតរវាងមេធាវី "Barristers" និង "អតិថិជន" នៅពេលដែលពួក "Solicitors" រៀបចំរឿងសំរាប់ឱ្យពួកមេធាវី "Barristers" ទាំងនោះ.ដែលលក្ខណៈត្រង់នេះបញ្ជាក់ថាជំនួយការមេធាវីពួក "Solicitors" ទទួលដឹកនាំនូវការងារដ៏លំបាកៗបំផុត ។ ជំនួយការមេធាវីទាំងអស់ដែលជា Solicitors នោះវាធ្វើសកម្មភាពក្រោមការត្រួតពិនិត្យ ឬឃ្លាំមើលរបស់តុលាការជាន់ខ្ពស់ និងតុលាការឧទ្ធរណ៍ ។ នៅចក្រភពអង់គ្លេស មន្ត្រីរូបណាក៏ដោយដែលបានធ្វើការក្នុងប្រព័ន្ធនៃអំណាចតុលាការ អាចសុទ្ធតែបានឆ្លងកាត់ជាមេធាវីរួចហើយ ។ មេធាវីនៅចក្រភពអង់គ្លេស មានអាទិភាពខ្លាំងណាស់ នៅពេលដែលមានការតែងតាំងឱ្យចូលជាមន្ត្រីរដ្ឋបាល (មេធាវីជាអ្នកដែលមានសិទ្ធិមុនគេ) ដូចជាការជ្រើសរើស ឬតែងតាំងឱ្យបំរើការនៅក្នុងផ្នែកបច្ចេកទេសនានា តាមសាកលវិទ្យាល័យជាដើម (សំដៅក្នុងវិស័យនីតិសាស្ត្រ) ។

ចំពោះនៅសហរដ្ឋអាមេរិកវិញ ការប្រមូលផ្តុំមេធាវីដែលមានឈ្មោះល្បីនៅក្នុងសង្គមនោះត្រូវបានគេស្គាល់ថា "**សមាគមអ្នកច្បាប់អាមេរិកកាំង**" ។ នៅតាមរដ្ឋនីមួយៗមានសមាគមមេធាវីរៀងៗខ្លួន ។ ចំពោះប្រទេសអាមេរិកកាំង ពុំមានច្បាប់រួមមួយកំណត់ទៅលើសកម្មភាពនៃអង្គការមេធាវីនេះទេ ព្រោះវាធ្វើសកម្មភាពតាមច្បាប់នៃរដ្ឋនីមួយៗ. តាមវិធានរបស់តុលាការ. ឬក៏តាមបញ្ញត្តិនានារបស់សមាគមមេធាវីនៅតាមរដ្ឋនានា ។

រីឯនៅប្រទេសបារាំង សកម្មភាពនៃមេធាវីត្រូវបានកំណត់ដោយច្បាប់ ស្តីពីការកែទំរង់នៃវិជ្ជាជីវៈច្បាប់ និងវិជ្ជាជីវៈតុលាការ ឆ្នាំ ១៩៧១ ។ រីឯប្រទេសអាល្លឺម៉ង់ ត្រូវបានកំណត់ដោយច្បាប់ស្តីពីមេធាវី ឆ្នាំ ១៩៥៩ ។

---

[១០៩]. Solicitors : គឺជាក្រុមជំនួយការមេធាវីដែលមាននាទីរៀបចំសំណុំរឿងតាំងពីដំបូងទីម្ល៉េះ សំរាប់ដាក់ទៅតុលាការ ។

ក្រៅពីអង្គការមេធាវីនៅមានស្ថាប័នដទៃៗទៀត ដែលមាននាទីជួយដល់អំណាចតុលាការ ដូចជាស្ថាប័ន "**ប៉ូលីសយុត្តិធម៌ ឬមន្ត្រីទាំងឡាយនៅក្នុងដំណែងដែលបានកំណត់ដោយច្បាប់**" ដូចជា : មន្ត្រីឃុំ-សង្កាត់, មន្ត្រីបង្ក្រាបបទល្មើសព្រៃឈើ, ជលផល, បរិស្ថាន...... ជាដើម។ល។ (សំរាប់ប្រទេសកម្ពុជា) រីឯប្រទេសខ្លះទៀតបង្កើតនូវស្ថាប័នជំនាញមួយចំនួន ទាក់ទិននឹងមុខងារយុត្តិធម៌ដូចជា :

- ស្ថាប័នសាការី ជួយដល់ទំនាក់ទំនងរដ្ឋប្បវេណីគតិយុត្តិ ។
- ស្ថាប័នអាជ្ញាសាលា ជួយដល់ការអនុវត្តសាលក្រម ឬកិច្ចការរដ្ឋបាលមួយចំនួនដល់តុលាការ ។
- ស្ថាប័នឯករាជ្យក្នុងការស៊ើបអង្កេតមួយចំនួន ដូចជាខាងផ្នែកហិរញ្ញវត្ថុជាដើម ។

# ការពន្យល់ពាក្យគន្លឹះសំខាន់ៗក្នុងអត្ថបទនីមួយៗ

## អត្ថបទទី ១

- **ស្វ័យភាពនៃនីតិរដ្ឋធម្មនុញ្ញ** : គឺជាសកម្មភាព ឬអំពើដែលកើតមានជាស្វ័យប្រវត្តិរបស់ទ្រឹស្តីនៃនីតិរដ្ឋធម្មនុញ្ញ ។
- **ប្រព័ន្ធគតិយុត្តិ** : គឺជាបណ្តាញនានានៃវិស័យច្បាប់ ឬបទដ្ឋានដែលបង្កើតមកសំរាប់ការពារដល់ផលប្រយោជន៍នៃសមាជិករបស់សង្គម និងរដ្ឋនៃប្រទេសនីមួយៗ ។
- **ទំនាក់ទំនងសង្គម** : គឺជាទំនាក់ទំនង ឬសកម្មភាពនានារបស់មនុស្សដែលធ្វើឡើងក្នុងការប្រាស្រ័យទាក់ទងគ្នាតាមគ្រប់រូបភាព ទោះជាសកម្មភាពនោះល្អ ឬអាក្រក់ក្តី មានជីវិត ឬឥតជីវិតក្តី។
- **អាទិភាពនៃអំណាចរដ្ឋ** : គឺជាការប្រកាន់យកអំណាចរដ្ឋធ្វើជាគំរូដ៏សំខាន់ ក្នុងការអនុវត្តក្នុងប្រទេស ។ ម្យ៉ាងទៀតវាជាការចាត់ទុកអំណាចរដ្ឋមានវិសាលភាពគ្របដណ្តប់ទៅលើអំណាចផ្សេងទៀត ។
- **វិធាននៃនីតិរដ្ឋធម្មនុញ្ញ** : គឺជាមធ្យោបាយដែលធ្វើឱ្យមានការប្រតិបត្តិដ៏ជោគជ័យ និងមានប្រសិទ្ធិភាពខ្ពស់ចំពោះច្បាប់នានា នៅក្នុងទំនាក់ទំនងសង្គម ។
- **អានុភាពគតិយុត្តិ** : គឺជាច្បាប់ ឬបទដ្ឋាន ដែលមានឥទ្ធិពលគ្របដណ្តប់ទៅលើច្បាប់ ឬបទដ្ឋានផ្សេងៗទៀត ក្នុងពេលអនុវត្ត ។
- **ធ្វើនិយ័តកម្ម** : គឺជាសកម្មភាពដែលធ្វើឱ្យមានដំណើរការយ៉ាងទៀងទាត់នៅក្នុងទំនាក់ទំនងសង្គម ។

- **និយ័តកម្មធម្មនុញ្ញគតិយុត្តិ** : គឺជាបទដ្ឋាន ឬបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ដែលត្រូវអនុវត្តទៅលើទំនាក់ទំនងសង្គមឱ្យមានភាពទៀងទាត់ ។
- **បទដ្ឋានកាតព្វកិច្ច** : គឺជាបទបញ្ញត្តិដែលបានចែងតំរូវឱ្យបុគ្គលដែលមានអំណាច ឬគ្មានអំណាចណាមួយទទួលខុសត្រូវចំពោះមុខច្បាប់ នូវសកម្មភាពរបស់បុគ្គលនោះ ដែលធ្វើសកម្មភាពក្នុងទំនាក់ទំនងសង្គម ។
- **បទដ្ឋានហាមឃាត់** : គឺជាបទបញ្ញត្តិដែលចែងទាក់ទិននឹងការហាមប្រាមនានា ទៅលើសកម្មភាពអ្វីមួយនៅក្នុងទំនាក់ទំនងសង្គម ។
- **បទដ្ឋានអនុញ្ញាត** : គឺជាបទបញ្ញត្តិដែលផ្តល់សិទ្ធិឱ្យធ្វើសកម្មភាពនៅក្នុងទំនាក់ទំនងសង្គម ។
- អំណាចអាជ្ញាបញ្ញា (Imperative) : នៅក្នុងអត្ថន័យនេះ វាគ្រាន់តែជាការកំណត់មួយដោយរដ្ឋធម្មនុញ្ញដែលជាច្បាប់គ្រឹះ រីឯការអនុវត្តពុំអាចយករដ្ឋធម្មនុញ្ញ ឬបទបញ្ញត្តិនេះទៅអនុវត្តដោយត្រង់ ផ្ទាល់នៅក្នុងសង្គមបានទេ ។ អំណាចរបៀបនេះមានលក្ខណៈបញ្ជាទៅគ្រប់អំណាចក្រោមបង្គាប់ ។
- អំណាចអធិបញ្ញា (Injunction) : គឺជាអំណាចដែលបញ្ជាឱ្យអនុវត្តផ្ទាល់នូវរាល់ច្បាប់ ឬបទដ្ឋាននានានៅក្នុងទំនាក់ទំនងសង្គម ។ ដូចនេះបើមានតែច្បាប់ ហើយគ្មានអ្នកបញ្ជាឱ្យអនុវត្ត នោះសង្គមទាំងមូលពុំអាចមានទំនាក់ទំនងទៀងទាត់បានឡើយ ទោះបីមានច្បាប់ច្រើនយ៉ាងណាក៏ដោយ ។
- **ប្រព័ន្ធបទដ្ឋានកិច្ចគតិយុត្តិ** : គឺជាបណ្តាញនានាដែលមានសកម្មភាពក្នុងការបង្កើតឱ្យមាននូវច្បាប់ ឬបទដ្ឋាននានានៅក្នុងសង្គម ឬរដ្ឋមួយ ។

- **និយ័តភាព** : គឺជាបទដ្ឋាននានា ដែលធ្វើឱ្យមានភាពទៀងទាត់នៅក្នុងសកម្មភាពនៃទំនាក់ទំនងសង្គម ។
- **ឥទ្ធិពលអញ្ញមញ្ញនៃទស្សនធម្មនុញ្ញគតិយុត្តិ** : គឺជាសកម្មភាពគ្របដណ្តប់ទៅលើទំនាក់ទំនងទៅវិញទៅមករបស់សង្គម ដោយប្រកាន់យកគំនិតធម្មនុញ្ញ ឬយកច្បាប់ធម្មនុញ្ញធ្វើជាច្បាប់គោល នៅក្នុងចំណោមច្បាប់នានា ។
- **ឯកភាព** : ជាទ្រឹស្តីមួយ ដោយអ្នកឯកទេសយល់ឃើញនូវគំនិតនានាទៅលើកម្មវត្ថុនៃរដ្ឋធម្មនុញ្ញមានខ្លឹមសារដូចគ្នា ។
- **ភាពទីទៃគ្នា** : គឺជាការកំណត់នូវលក្ខណៈ ឬរចនាបថផ្សេងពីគ្នាទៅលើរដ្ឋធម្មនុញ្ញ ឬច្បាប់គ្រឹះ តាមប្រទេសនីមួយៗ ។
- **អត្ថានៃនីតិ ឬប្រធាននៃនីតិ** : ប្រធាននៃច្បាប់ ត្រូវបានកំណត់ដោយច្បាប់គ្រឹះនៃប្រទេសនីមួយៗទៅលើសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកក្នុងសង្គមរបស់ពួកគេ ។
- **និយ័តករ** : គឺជាអ្នកដែលមាននាទីក្នុងការអនុវត្តច្បាប់នៅក្នុងសង្គម ។
- **សកម្មភាពអញ្ញមញ្ញ** : ជាសកម្មភាពដែលមានទៅវិញទៅមក នៅក្នុងទំនាក់ទំនងសង្គម ។
- **ទំនាក់ទំនងអញ្ញមញ្ញ** : គឺជាទំនាក់ទំនងដែលមានទៅវិញទៅមក នៅក្នុងទំនាក់ទំនងសង្គម ។
- **សង្គមបូនីយកម្ម** : ការធ្វើឱ្យមានកើតនូវសង្គម ហើយមានភាពផ្លាស់ប្តូរត្រឹមត្រូវតាមច្បាប់គ្រឹះ ទៅលើការវិវត្តនៃសង្គមនីមួយៗ ។
- **លទ្ធិប្រជាធិបតេយ្យបូនីយកម្ម** : គឺជាសកម្មភាពដែលសង្គមមួយត្រូវបានគ្រប់គ្រងដោយអំណាចរបស់ពលរដ្ឋ កាន់តែមានភាពរីកចំរើន និងទុកចិត្ត ។

- **អន្តរជាតូបនីយកម្ម** : គឺជាសកម្មភាពនៃជាតិសាសន៍នីមួយ ទទួលយកបាននូវបទពិសោធន៍ពីគ្នាទៅវិញទៅមក ដើម្បីគ្រប់គ្រងសង្គមរបស់ខ្លួនឱ្យមានភាពប្រសើរឡើង ។

**អត្ថបទទី ២**

- **បទដ្ឋានធម្មនុញ្ញគតិយុត្តិ** : គឺជាបទបញ្ញត្តិនានារបស់រដ្ឋធម្មនុញ្ញ ឬច្បាប់គ្រឹះដែលបានចារឹកនៅក្នុងច្បាប់ទាំងនោះ ដោយមានជាប្រភេទ មាត្រានានា ។
- **មូលដ្ឋានគ្រឹះគតិយុត្តិ** : គឺជាបទដ្ឋាន ឬបទបញ្ញត្តិដែលបានចារឹកនៅក្នុងច្បាប់គោល ឬរដ្ឋធម្មនុញ្ញ ។ ម្យ៉ាងទៀតវាជាបទបញ្ញត្តិដែលបានចែងនៅក្នុងច្បាប់នានា ដោយច្បាប់ទាំងនោះជាមូលដ្ឋាននៃប្រភពរបស់រដ្ឋធម្មនុញ្ញ ។
- **គោលជំហរនីត្យានុកូលកម្ម** : គឺជាការប្រកាន់យកការគ្រប់គ្រងរដ្ឋ ដោយមានក្បួនខ្នាត ឬច្បាប់ច្បាស់លាស់ ដែលមានកំណត់អំពីសកម្មភាពនៃរដ្ឋទាំងនោះ ។
- **បទដ្ឋានសម្ភារៈ** : ជាបទដ្ឋាន ឬបទបញ្ញត្តិដែលបានចែងនៅក្នុងច្បាប់រួចទៅហើយ ហើយចាត់ទុកច្បាប់ទាំងនោះជាវត្ថុ ឬទ្រព្យមួយប្រភេទ សំរាប់ធ្វើនិយ័តភាពទៅលើទំនាក់ទំនងសង្គម ។
- **ទស្សនទាន** : គឺជាការផ្តល់នូវទស្សនៈនានា ដែលគេបានយល់ឃើញចំពោះទ្រឹស្តីនៃនីតិរដ្ឋធម្មនុញ្ញ ។
- **អភិជនាធិបតេយ្យ** : គឺជាពួកដែលគ្រប់គ្រងសង្គម ចូលចិត្តយកការសំរេចអ្វីមួយជាលក្ខណៈអាត្មានិយមធ្វើជាត្រីមុខ ។

## អត្ថបទទី ៣

- **អត្តភាព** : ភាពជាបុគ្គលម្នាក់ដែលជាសមាជិកនៃសង្គម ។ គេច្រើននិយាយថាសិទ្ធិអត្តភាព មានដូចជាសិទ្ធិរស់នៅ, សិទ្ធិមានគំនិត ឬយោបល់ផ្សេងៗ នៅក្នុងទំនាក់ទំនងសង្គម ។
- **សហសម្ព័ន្ធ** : គឺជាការទំនាក់ទំនងរួមគ្នាមួយក្នុងគំនិត ឬទស្សនៈទៅលើសកម្មភាព ឬដំណើរការអ្វីៗនៅក្នុងសង្គម ។ គេអាចនិយាយបានថាជាទំនាក់ទំនងអញ្ចឹមញ្ចក៏បានដែរ ។
- **ឯកធិភាព** : គឺជាការប្រកាន់យកគោលជំហរបង្កើតនូវអ្វីៗដោយពុំមានការប្រលងប្រជែងពីអ្នកដទៃ ។ វាជាសកម្មភាពផ្តាច់មុខមួយនៅក្នុងទំនាក់ទំនងសង្គម ។
- **ប្រព័ន្ធនិយ័តកម្មគតិយុត្តិ** : គឺជាបណ្តាញនៃបទដ្ឋានទាំងឡាយ ដែលធ្វើឱ្យទៀងទាត់ទៅលើទំនាក់ទំនងសង្គមរបស់រដ្ឋនីមួយៗ ។
- **ការធ្វើនិយ័តកម្មធម្មនុញ្ញ** : គឺជាសកម្មភាពនៃបញ្ញត្តិរបស់រដ្ឋធម្មនុញ្ញ ធ្វើទៅលើទំនាក់ទំនងសង្គមឱ្យមានលក្ខណៈទៀងទាត់ និងត្រឹមត្រូវ ។
- **កិច្ច** (Act) : នៅក្នុងន័យនេះវាជាច្បាប់ ឬបទដ្ឋានកិច្ចដែលសរសេរលាយលក្ខណ៍ជាអក្សរ ហើយអនុម័តដោយអង្គការមានអំណាចរដ្ឋជាន់ខ្ពស់ ហើយដាក់បង្ខំឱ្យមនុស្សប្រតិបត្តិ ។

## អត្ថបទទី ៤

- **ទំរង់ក្រៅនៃរដ្ឋធម្មនុញ្ញ** : វាជាទ្រង់ទ្រាយ ឬរូបភាពនៃការចែងជាអត្ថបទដែលមានខ្លឹមសារធ្វើនិយ័តកម្មទៅលើទំនាក់ទំនងសង្គម ។ ទ្រង់ទ្រាយខាងក្រៅនេះគេអាចមើលឃើញជាបណ្តុំ ឬជាលក្ខណៈដោយឡែកៗនៃច្បាប់គោលនានា ។

- **ទំរង់ក្នុងនៃរដ្ឋធម្មនុញ្ញ** : គឺជាទ្រង់ទ្រាយនៃការសាងសង់ ឬរចនាបថនៃការបង្កើតនូវប្រព័ន្ធនានានៃបញ្ញត្តិរបស់ច្បាប់គោល ដូចជាមាត្រា, វាក្យខ័ណ្ឌ, កថាខ័ណ្ឌ ។
- **នីតិកម្ម** : គឺជាសកម្មភាពធ្វើបទដ្ឋាន ឬច្បាប់នានា តាំងពីការចាប់ផ្ដើម រហូតដល់ទីបញ្ចប់ ។
- **អ្នកកិច្ចអនុវត្តតតិយុត្តិ** : គឺជាពួកមន្ត្រីដែលមាននាទីក្នុងអំណាចរដ្ឋ សំរាប់បង្ខំឱ្យមានការអនុវត្តច្បាប់ ឬបទបញ្ញត្តិនានា ។

**អត្ថបទទី ៥**

- **រដ្ឋធម្មនុញ្ញនិយម** : គឺជាការប្រកាន់យកគោលជំហរនៅខាងរដ្ឋធម្មនុញ្ញ ក្នុងការគ្រប់គ្រងប្រទេស រឺនិយាយថាចាត់ទុករដ្ឋធម្មនុញ្ញជាច្បាប់គោល ។
- **លទ្ធិប្រជាធិបតេយ្យភាវូបនីយកម្ម** : គឺការរីកចំរើនឡើងនូវលទ្ធិប្រជាធិបតេយ្យ ក្នុងការគ្រប់គ្រងប្រទេស ។
- **កិច្ចឯកតោភាគី** : នៅក្នុងន័យនេះគឺសំដៅយករដ្ឋធម្មនុញ្ញ ឬបទដ្ឋានមួយកើតឡើងពីភាគីស្ដេចតែម្ខាងប៉ុណ្ណោះ ។

**អត្ថបទទី ៦**

**អត្ថបទទី ៧**

- **ទំលាប់នយោបាយអាជ្ញាបញ្ញា** : គឺជាសកម្មភាពនៃអ្នកនយោបាយ ដែលមានអំណាចបញ្ជាទៅលើមនុស្ស តាមអាទិភាពនៃអំណាចរបស់ខ្លួន ដោយបំពានទៅលើសិទ្ធិទាំងឡាយរបស់មនុស្ស ។

- ន័យមួយទៀតគឺទំលាប់នយោបាយអាជ្ញាបញ្ជា វាជាមាត្រា គតិយុត្តិមួយ ដែលអ្នកនយោបាយបានបន្សល់ទុកតាមរយៈ រដ្ឋធម្មនុញ្ញ ដូចជាចារឹកទទួលស្គាល់នូវសិទ្ធិសេរីភាពមនុស្ស ប៉ុន្តែអ្នកជំនាន់ក្រោយគ្រាន់តែបាននិយាយអំពីបញ្ហាសិទ្ធិ របស់មនុស្សដែលបានចារឹកតែប៉ុណ្ណោះ រីឯខ្លឹមសារជាក់ស្តែង វិញគឺសំរាប់បំរើឱ្យនយោបាយរបស់អ្នកមានអំណាចតែ ប៉ុណ្ណោះ ។

- **ទំរង់គតិយុត្តិ** : ជាទ្រង់ទ្រាយផ្លូវច្បាប់មួយ ឬក៏ត្រូវបានទទួលស្គាល់តាម ច្បាប់ ជាលក្ខណៈទ្រង់ទ្រាយណាមួយជាដើម ។
- **និម្មិតកម្មសង្គម** : គឺជាសកម្មភាពនៃការបង្កើតនូវអង្គការប្រមូលផ្តុំនានា ដើម្បី ការពារប្រយោជន៍របស់ពួកគេ ដូចជា : អង្គការនានា, សមាគម, សហគមន៍, ក្រុម ........។
- **អត្តវិស័យ** : គឺជាសិទ្ធិនានាដែលត្រូវបានផ្តល់ឱ្យទៅបុគ្គល តាមកិរិតណា មួយច្បាស់លាស់ ហើយត្រូវបានចារឹកដោយច្បាប់ ឬវិធាន ណាមួយ ។
- **ខ្នាតកំរិតនូវចរិត** : វាជាព្រំដែនដែលកំណត់នូវសកម្មភាពនៃអកប្បកិរិយារបស់ មនុស្ស ដែលមាននៅក្នុងសង្គម ។
- **រូបមន្តធម្មនុញ្ញ** : គឺជាវិធានរួមមួយដែលត្រូវបានចែង ឬកំណត់ទៅលើសិទ្ធិ សេរីភាព និងកាតព្វកិច្ចរបស់មនុស្ស ហើយត្រូវបានកំណត់ នៅក្នុងរដ្ឋធម្មនុញ្ញ ។
- **ផលសិទ្ធិ** : គឺជាសិទ្ធិ និងកាតព្វកិច្ចដែលត្រូវបានកំណត់ដោយច្បាប់សំរាប់ បុគ្គល ។ ផលសិទ្ធិនេះវាដូចគ្នានឹងសិទ្ធិអត្តវិស័យផងដែរ ។

## អត្ថបទទី ៨

• **សម្បត្តិវប្បធម៌ធម្មជាតិ** : ជាទ្រព្យសម្បត្តិដែលកើតឡើងពីធម្មជាតិ ហើយជាកម្មសិទ្ធិរបស់រដ្ឋណាមួយ ។ ទ្រព្យទាំងនេះដូចជា រ៉ែ, ដី, ភ្នំ, ទន្លេ, ព្រៃ, សមុទ្រ........... ។ល។

• **សម្បត្តិវប្បធម៌លទ្ធកម្ម** : គឺជាទ្រព្យដែលកើតឡើងពីស្នាដៃរបស់មនុស្សដូចជា : ប្រាសាទ, សំណង់បុរាណ និងទំនើប, ផ្លូវ ............ ។

## អត្ថបទទី ៩

• **គតិយុត្តិសង្គម** : គឺជាសង្គមដែលធ្វើសកម្មភាពសំរេចទៅបានតាមច្បាប់កំណត់ច្បាស់លាស់ ។

• **រដ្ឋភាវូបនីយកម្ម** : គឺជាសកម្មភាពដែលបំលែងទ្រព្យ ជាកម្មសិទ្ធិឯកជនឱ្យក្លាយទៅជាទ្រព្យក្នុងកម្មសិទ្ធិរបស់រដ្ឋជាផ្លូវការ ។ រាល់ការបំលែងនេះ ត្រូវមានកំណត់ក្នុងច្បាប់ ។

• **ឯកជនភាវូបនីយកម្ម** : គឺជាសកម្មភាពដែលបំលែងទ្រព្យ ជាកម្មសិទ្ធិរដ្ឋឱ្យក្លាយទៅជាកម្មសិទ្ធិឯកជនជាផ្លូវការ ។ សកម្មភាពទាំងនេះត្រូវធ្វើតាមច្បាប់ ។

## អត្ថបទទី ១០

• **កាតាលីករ** : នៅក្នុងអត្ថន័យនេះគឺជាពួក ឬជាសកម្មភាពដែលជួយដល់កិច្ចការរបស់រដ្ឋក្នុងវិស័យណាមួយ ដើម្បីទទួលលទ្ធផលសំរាប់សាធារណៈ ប៉ុន្តែសកម្មភាព ឬពួកទាំងនោះ (កាតាលីករ) ពុំមែនចូលរួមក្លាយជាឧបករណ៍រដ្ឋទេ នៅពេលបញ្ចប់សកម្មភាពរបស់ខ្លួន ។

- **យន្តកម្មនៃមតិមហាជន** : ជាក្បាលម៉ាស៊ីន ឬថ្នាក់ដឹកនាំមហាជន ដូចជាការដឹកនាំសមាគម, អង្គការ ឬទិម្មិតកម្មសង្គមនានាទៀត ។
- **ឯកសារគតិយុត្តិពិសេស** : គឺជាឯកសារផ្លូវច្បាប់ដែលកំណត់អំពីភារកិច្ច និងសកម្មភាពផ្សេងៗទាក់ទិននឹងសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលិករដ្ឋ ។
- **សម្ព័ន្ធអន្តរនីតិ ឬសម្ព័ន្ធគតិយុត្តិអន្តររដ្ឋ** : គឺជាទំនាក់ទំនងដែលពុំមានជាការចងសម្ព័ន្ធតាមប្រព័ន្ធច្បាប់រួមណាមួយរវាងរដ្ឋ និងរដ្ឋនោះទេ តែវាជាសម្ព័ន្ធភាពខាងទំនាក់ទំនងសេដ្ឋកិច្ច ឬវិស័យណាមួយតែប៉ុណ្ណោះ ។ ការប្រើពាក្យនេះនៅក្នុងរដ្ឋដែលមានរចនាសម្ព័ន្ធ Confederation ។
- **អាណត្តិប្រជាជន** : គឺជារយៈពេលដែលបានកំណត់ដោយច្បាប់ក្នុងការបោះឆ្នោតជ្រើសរើសតំណាងរបស់ប្រជាជន ក្នុងការគ្រប់គ្រងរដ្ឋ ។
- **បាតុភូតហាយន្តភាពសង្គម** : គឺជាបាតុភូតដែលធ្វើឱ្យបាត់បង់នូវសណ្តាប់ធ្នាប់សង្គមទាំងមូល ទោះជាបាតុភូតនោះកើតឡើងដោយវិធីណាក៏ដោយ ។
- **តថភាពនៃបទដ្ឋាន** : ជាបទដ្ឋានដែលកើតមានពិតៗ ហើយត្រូវបានទទួលស្គាល់ជាសាធារណៈនៅក្នុងសង្គមទាំងមូល ។
- **រដ្ឋទេវាធិបតេយ្យ** : គឺជារដ្ឋដែលមាននយោបាយ និងជំនឿទៅលើទេវតា គឺមិនជឿលើកំលាំងខ្លួនឯងនោះទេ ។
- **អាញ្ញត្តិច្បាប់** : គឺជាសេចក្តីព្រាងច្បាប់នានា ។

## អត្ថបទទី ១១

- **សមាសភាគ** : គឺជាធាតុទាំងឡាយដែលផ្សំបានជាប្រព័ន្ធមួយនៅក្នុងការគ្រប់គ្រង និងដឹកនាំសង្គម និងរដ្ឋ ។
- **បក្សគហបតីឯកធិភាព** : ជាបក្សរបស់វណ្ណៈអ្នកមានទ្រព្យ និងមានអំណាច ហើយពុំមានបក្សណាបង្កើតឡើងដើម្បីប្រលងប្រជែងឡើយ ។

• ស្ថាប័នការបនីយកម្មនៃបក្សនយោបាយ : ជាការបង្កើតឱ្យមានបក្សនយោបាយតាមមូលដ្ឋានរួមមួយ ដែលជាខ្នាតគ្រឹះ ដូចជារដ្ឋធម្មនុញ្ញអនុញ្ញាតិឱ្យមានបក្សជាច្រើន ។

• ការរបៀង : គឺជាសកម្មភាពរបស់បុគ្គល ឬក្រុមណាមួយធ្វើការកៀងគ ឬបញ្ចុះបញ្ចូលទៅលើក្រុមមនុស្សផ្សេងទៀត ក្នុងគោលដៅឱ្យមានការគាំទ្រលើគំនិតអ្វីមួយជាផ្លូវការ ។

## អត្ថបទទី ១២

• អន្តរសកម្ម : គឺជាសកម្មភាព ឬអំពើរបស់ស្ថាប័ន ឬអង្គការ ដោយមានទាំងអ្នកគ្រប់គ្រងផងដែល ត្រូវបានកំណត់ដោយច្បាប់ ឬខ្នាតណាមួយ ដើម្បីរួមគ្នាធ្វើសកម្មភាពឱ្យបានសំរេចតាមគោលបំណងនៃច្បាប់ទាំងនោះ ។

## អត្ថបទទី ១៣

• ទស្សនកម្មវិធីគ្រឹះ : គឺជាគំនិតធំៗដែលបក្សនយោបាយនីមួយៗសំរេចយកធ្វើជាគោល ក្នុងការធ្វើសកម្មភាពរបស់បក្ស ។ ទស្សនទាំងអស់នេះត្រូវបានចាត់ទុកជាមាគ៌ាដ៏ធំបំផុតរបស់បក្ស ។

• សាមយិកភាពនៃការបោះឆ្នោត : គឺជារង្វិលជុំក្នុងការជ្រើសរើសអង្គការតំណាង ។ សាមយិកភាព (Period) នេះ វាជាខួបមួយយ៉ាងទៀងទាត់ក្នុងដែនកំណត់ណាមួយ ។

• នីតិសាស្ត្រ : គឺជាវិទ្យាសាស្ត្រដែលសិក្សាទៅលើក្បួនខ្នាតទាំងឡាយ ហើយក្បួនខ្នាតទាំងនោះវាធ្វើនិយ័តកម្មទៅលើវិស័យនានា ដែលមាននៅក្នុងសង្គម ។ ជាឧទាហរណ៍ នីតិរដ្ឋប្បវេណីគឺជា

វិទ្យាសាស្ត្រដែលសិក្សាទៅលើតែទំនាក់ទំនងបេតិកភណ្ឌ និងអបេតិកភណ្ឌ ដែលទំនាក់ទំនងទាំងនេះត្រូវបានកំណត់ ឬកំរិតឱ្យមានភាពទៀងទាត់នៃសកម្មភាពរបស់ខ្លួននៅក្នុងសង្គម ។

- សាខានៃនីតិសាស្ត្រ : វាជាវិទ្យាសាស្ត្រមួយដែលសិក្សាទៅលើវិស័យនីមួយៗដាច់ដោយឡែកៗ ដែលវិស័យទាំងនេះស្ថិតក្នុងក្របខ័ណ្ឌនៃនីតិសាស្ត្រ ។ ជាឧទាហរណ៍ : នីតិព្រហ្មទណ្ឌគឺជាសាខានៃនីតិសាស្ត្រ ។
- រដ្ឋសុក្រឹត្យ ឬប្រទេសសុក្រឹត្យ : គឺជារដ្ឋដែលកើតមាននៅក្នុងពិភពយើង នេះហើយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងសកម្មភាពនៃអធិបតេយ្យភាពរបស់រដ្ឋនោះ ។

## អត្ថបទទី ១៤

- ធម្មនុញ្ញយុត្តិធម៌ : គឺជាសកម្មភាពរបស់ស្ថាប័ន មាននាទីក្នុងការស្វែងរកយុត្តិធម៌ ក្នុងទំនាក់ទំនងនៃបទបញ្ញត្តិនានារបស់រដ្ឋធម្មនុញ្ញ។ ស្ថាប័ន ឬអង្គការដែលទទួលបន្ទុកកិច្ចការនេះ ដូចជាតុលាការធម្មនុញ្ញជាដើម ។ល។ ដើម្បីត្រួតពិនិត្យនូវធម្មនុញ្ញភាពនៃបទដ្ឋានកិច្ចគតិយុត្តិនានារបស់រដ្ឋ ។
- ទស្សនាការ : ជាការបង្កើតឡើងនូវគំនិតនៃការយល់ឃើញទៅលើអ្វីមួយ ហើយចាត់ទុកគំនិតយល់ឃើញនោះជាមូលដ្ឋានត្រឹមត្រូវសំរាប់សង្គម ។

- ប្រតិស្ឋាន : គឺជាការកំណត់ទៅលើអ្វីមួយ ដើម្បីយកការកំណត់នោះធ្វើជាមូលដ្ឋានសំរាប់អនុវត្តដល់ទំនាក់ទំនងផ្សេងៗទៀតក្នុងសង្គម ។
- លក្ខណៈប្រជាជន : គឺជាសកម្មភាពនៃលទ្ធផលអ្វីមួយដែលកើតបានមកតាមរយៈឆន្ទៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យពលរដ្ឋទទួលស្គាល់នូវលទ្ធផលនោះ ហើយងាយស្រួលក្នុងការអនុវត្តទៀតផង ។
- សមត្ថកិច្ចធម្មនុញ្ញគតិយុត្តិ : គឺជាសមត្ថកិច្ចនានារបស់រដ្ឋសភា ដែលត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញទៅលើកិច្ចធំៗដែលទាក់ទិននឹងសង្គមជាតិ ។
- មត្តទេស្តនៃរដ្ឋសភា : គឺជាសកម្មភាពរបស់រដ្ឋសភា ក្នុងការបង្កើតនូវអ្វីៗដែលមានប្រយោជន៍ ធ្វើជាគំរូដល់អំណាចដទៃទៀតរបស់រដ្ឋ ដូចជាការ បង្កើតច្បាប់នានា ។
- អាណត្តិច្បាប់ : គឺជាច្បាប់ដែលនៅជាសេចក្តីព្រាង ឬសេចក្តីស្នើនៅឡើយ ។ (មាននៅក្នុងអត្ថបទទី ១០)
- អធិបបញ្ញាធម្មនុញ្ញ : គឺជាបញ្ញត្តិដែលមានលក្ខណៈបញ្ហា ហើយត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញ ។

## អត្ថបទទី ១៥

- អភិប្រាយ : គឺជាសេចក្តីអធិប្បាយដែលមានការពន្យល់យ៉ាងច្បាស់លាស់ទៅលើហេតុផល ចំពោះការប្រព្រឹត្តទៅរបស់មនុស្ស និងសង្គម ។
- ចក្ខុវិស័យ : គឺជាការយល់ ឃើញទៅលើអ្វីៗតាមរយៈភ្នែករបស់មនុស្ស ដោយពុំបានពិចារណាគ្រប់ជ្រុងជ្រោយនោះទេ ។

• សញ្ញាខន្ត : គឺជាការយល់ដឹងតាមរយៈវិញ្ញាណទាំងឡាយរបស់មនុស្ស ទៅលើព្រឹត្តការណ៍ ឬសកម្មភាពអ្វីមួយ រវាងសង្គម និង មនុស្ស ។

## អត្ថបទទី ១៦

• ទំរង់គតិយុត្តិនៃប្រមុខរដ្ឋ : គឺសកម្មភាពដែលបានកំណត់ដោយច្បាប់ត្រឹមត្រូវ ទៅលើ បុគ្គលដែលជាប្រមុខដឹកនាំរដ្ឋនីមួយៗ ចាប់តាំងពីការកកើត នៃរដ្ឋទាំងនោះ ។

• អំណាចវិជិតរាជ : គឺជាសិទ្ធិអំណាចដែលត្រូវបានប្រគល់ឱ្យដោយស្តេច ទៅ ចំពោះអ្នកតំណាងរបស់ព្រះរាជា ដើម្បីគ្រប់គ្រង ឬធ្វើជា តំណាងនៃរដ្ឋចំណុះណាមួយ ។

## អត្ថបទទី ១៧

• យុត្តាធិការរបស់តុលាការ : គឺជាការកំណត់ទៅលើដែនសមត្ថកិច្ចរបស់តុលាការនានា ដែលមាននៅក្នុងក្របខ័ណ្ឌនៃប្រព័ន្ធតុលាការរបស់រដ្ឋ សុក្រឹត្យណាមួយ ។ ការកំណត់សមត្ថកិច្ចនេះមានទាំងរចនា សម្ព័ន្ធខ្សែបណ្តោយរបស់តុលាការ និងផ្នែកជំនាញនៃតុលា ការនីមួយៗ ដូចជាពាណិជ្ជកម្ម, រដ្ឋបាល, ......។ យុត្តាធិការ ក៏ត្រូវបញ្ជាក់ពីសកម្មភាព នៃមធ្យោបាយដោះស្រាយរឿង តាមនីតិវិធីមួយកំណត់ច្បាស់លាស់ផងដែរ ។

• ប្រព័ន្ធតុលាការ : គឺជាបណ្តាញនៃស្ថាប័នតុលាការដែលមាននៅក្នុងប្រទេស សុក្រឹត្យមួយ ចាប់តាំងពីតុលាការជាន់ទាបរហូតដល់ជាន់ ខ្ពស់ ។

- **យុត្តិភាពនៃបទដ្ឋានកិច្ច** : គឺជាភាពត្រឹមត្រូវនៃការបង្កើតនូវបទដ្ឋានកិច្ចនានារបស់អង្គការនានារបស់រដ្ឋ តាមឋានានុក្រមនៃការគ្រប់គ្រង ។
- **គម្ពីរកូរ៉ាន** : គឺជាក្បួនសាស្ត្រដែលបានសរសេរនូវវិន័យទាំងឡាយ សំរាប់អប់រំដល់អ្នកដែលកាន់សាសនាអ៊ីស្លាម ។

# ប្រភពឯកសារស្រាវជ្រាវ

## ក-ផ្នែកបទដ្ឋានគតិយុត្តិ និងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលទាក់ទិននឹងច្បាប់គ្រឹះ

### ១-ច្បាប់

១- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។

២- ច្បាប់គណបក្សនយោបាយនៃប្រទេសអាល្លឺម៉ង់ (ការផ្សាយរបស់ Internationer, ភ្នំពេញ ឆ្នាំ ១៩៩៦)

៣- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណរដ្ឋមន្ត្រីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៤ ។

៤- ច្បាប់ស្តីពីសញ្ជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៦ ។

៥- ច្បាប់អន្តោប្រវេសន៍កម្ពុជា ឆ្នាំ ១៩៩៤ ។

៦- បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ឆ្នាំ ១៩៩២ ។

៧- ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ឆ្នាំ ១៩៩៣ ។

៨- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឆ្នាំ ១៩៩៤ ។

៩- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ ១៩៩៧ ។

១០- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ឆ្នាំ ១៩៩៧ ។

១១- ច្បាប់ស្តីពីគណបក្សនយោបាយរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៧ ។

### ២-ថាតុក្រមនៃច្បាប់

១- បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ឆ្នាំ ១៩៩៣ ។

### ឃ-កិច្ចព្រមព្រៀងអន្តរជាតិ

១- កិច្ចព្រមព្រៀងទីក្រុងប៉ារីស អំពីបញ្ហាកម្ពុជា ឆ្នាំ ១៩៩១ ។

២- កតិកាសញ្ញាអន្តរជាតិ អំពីសិទ្ធិក្នុងវិស័យសេដ្ឋកិច្ច-សង្គម និងវប្បធម៌ ឆ្នាំ ១៩៦៦ ។

៣- កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ឆ្នាំ ១៩៦៦។

៤- អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់ចោលសព្វបែបយ៉ាងនៃការប្រកាន់ពូជសាសន៍ ឆ្នាំ ១៩៦៥ ។

### ខ.ផ្នែកទ្រឹស្តីសំខាន់ៗ និងទិន្នន័យ នៃនីតិរដ្ឋធម្មនុញ្ញ

1- Constitutional law in Malaysia and Singapore, by Kevin Tan, Singapore 1991.
2- Modern Constitutional law, Cases and Notes, Third Edition, by Ronal. D. Rotunda Western Publishing, Co.1989.
3- British Constitutional law, by Harry Calvert, London 1985.
4- Major Legal System in the World Today, Third Edition, by René David and Jhon E C Brierly, London 1985.
5- State law of Germany (Vol : I and II), M-1994.
6- Constitutional law of Foreign Country (Vol : I and II), M-1993.
7- United State of America, Constitutional and Legislative Acts, M-1993.
8- Basis of State and law (Sketch), M-1995.
9- Reference Book (Legal System of Foreign Country) M-1993.
10- Government, Ministry and Department in Foreign Country, M-1994.
11- Foreign Constitutional law, Publishing, by Professor Maklakov. V. U, M-1996.
12- Institutional of Presidency in Foreign Country, M-1994.
13- Theory of law (Book), for Student of law Faculty, M-1994.
14- Theory of State and law (General Theory), M-1994.
15- Organization of the Government of Japan, Tokyo 1996.

# គ.ការប្រើវចនានុក្រម


1. English-Khmer Dictionary, by Huffman, Franklin E and Im-Prom, Yal University, 1978 .
2. The Oxford Russian-English Dictionary, by Marcus Wheeler, Oxford 1972, M-1993.
3. Russian-English Dictionary, by Professor A. I Smirnitsky 13 th ed, M-1985.
4. Russian Encyclopedia, by A.M. Prokhorov, M-1990.
5. Khmer-Russian Dictionary, by Long-Siem, M-1984.
6. English-Russian law Dictionary by, S.N Andrianov, A.S Berson, A.S Nikifirov, 1993.
7. Cambodian-English Dictionary, the Catholic University of America, W-1977.
8. Judicial Encyclopedia, M-1984 and 1995.
9. Petit Dictonnaire Francais-Khmer, Phnom Penh –1967.
10. Law Dictionary, Second Edition, by Daniel Oran, J-D Western Publishing Co. 1985.
11. Law Dictionary, 12 th edit. by E.R Harday Ivamy, London-1993.
12. Oran's Dictionary of the law, by Daniel Oran J.D, Western Publishing Co, Los Angeles-1983.

**លេខបោះពុម្ព №០២៧**

- បោះពុម្ពលើកទី ១ ចំនួន ១០០០ ច្បាប់
- បោះពុម្ពថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៣
- នៅរោងពុម្ពក្រសួងអប់រំ អគារលេខ ១៤៨ មហាវិថីព្រះនរោត្តម ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- ខ្នាតសៀវភៅ ១៩ x ២៣
- ប្រភេទក្រដាស ខ្នាត ៦០ mg.
- ប្រភេទក្រប : ពណ៌ធម្មជាតិ អ៊ុតញ្ញស្ទិច

**រក្សាសិទ្ធិ © ដោយ : អ៊ិន បូផា**

**យោង :** - ពាក្យសុំ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ ២០០៣ នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

- មាត្រា ៣៨, ៣៩ និងមាត្រា ៤០ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលបានអនុម័តនៅថ្ងៃទី២១ ខែមករា ឆ្នាំ ២០០៣ហើយបានប្រកាសឱ្យប្រើនៅថ្ងៃទី ០៥ ខែមិនា ឆ្នាំ ២០០៣ ។

**ការីកុំព្យូទ័រ : កញ្ញា ស្វាយ សុផានិត**

# កំណត់សំគាល់

## នឹងចេញពីអ្នកនិពន្ធដដែល :

១. នីតិអន្តរជាតិឯកជន (វិធានជាទ្រឹស្តី)

២. មូលដ្ឋានគ្រឹះនៃនីតិ ឬសេចក្តីផ្តើមនៃនីតិសាស្ត្រ

៣. មូលដ្ឋានគ្រឹះនៃនីតិរដ្ឋធម្មនុញ្ញខ្មែរ

៤. ឯករាជ្យភាពនៃអំណាចតុលាការ (ទ្រឹស្តី និងទស្សនៈ)

ទូរស័ព្ទទាក់ទង : ០១១ ៨៧៦ ៦២៩